# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវគ្គ

## ភាគ ៦_៧_៨

# សមន្តបាសាទិកា

## អដ្ឋកថា  វិនយបិដក

## មហាវគ្គ

## ភាគ  ៦_៧_៨

ឈ្មោះសៀវភៅ **សមន្តបាសាទិកា អដ្ឋកថាបិដក មហាវគ្គ**

**ភាគ ៦_៧_៨**

ប្រែដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ **ភិក្ខុ_សាមណេរវត្តនិគ្រោធវ័ន“គល់ទទឹង”**

ភិក្ខុ គូ សុភាព
ភិក្ខុ ភួង សុវណ្ណ
ភិក្ខុ ឈូក សុមន
ភិក្ខុ សឹម ស៊ីសាមុត
ភិក្ខុ តុន ប៊ុនសាយ
ភិក្ខុ ឈឹម ហ៊ាន
សាមណេរ គល់ សុភាព
សាមណេរ នៅ ហៃឡ្យុន
សាមណេរ សឿន សាន

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

“គល់ទទឹង” ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុក

កៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306044



ភិក្ខុ  អគ្គធីរោ    គង់~សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៩ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។

ញោមប្រុសឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង

កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡុយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

## ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ)" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្តែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានខ្ទិះជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងស្គាល់ដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារពពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពពាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដ ចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្តីចម្រើន ដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ( ឥឡូវ )ភិក្ខុសង្ឃនៅមិនទាន់មានពុត( ហ៊ានលបលួចធ្វើអាក្រក់ )នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធស្អឹងតែផូរផង់ផ្ទង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ ទីងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្តែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកប្ញាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ គ្របសង្កត់ពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះមានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញាំញីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (ស្វាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រូបទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាននឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នកណាហ្ន៎ស្រែកជាសំឡេងដូចលា" ។ ឃោសៈព្រាហ្មណ៍នោះសួរថា "នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?" ព្រះថេរៈតបថា "យើង

ដឹង” ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បាន លំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួនឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវនេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុងការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា “នែព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹងសាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?” ព្រាហ្មណ៍តបថា “ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ” ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា “**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ :** ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

---

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

*ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់”[១] ។*

*ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា “បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?” ព្រះថេរៈតបថា “ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត” ។ ព្រាហ្មណ៍សួរថា “លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?” ព្រះថេរៈតបថា “ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែអ្នកបួសជាបព្វជិតដូចយើង” ។*

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

*ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹងអត្ថធម៌របស់ព្រះត្រៃបិដកថា “នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរជាងលទ្ធិចាស់របស់ខ្លួន)” (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច*

---

*១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្តរបស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។*

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្តើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្តែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតរមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង” ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្តាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

## តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្តាប់( ជ្រាបសេចក្តី ) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយជឿទុកចិត្តថា “នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត” ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា “សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា” ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្តែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្តាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្តាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស(ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្តាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសភ្លាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំរហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

---

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈ ទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដក ក្នុងភាសាមគធ ដែលជាមូលភាសា ( គឺភាសាដើម ) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ ( អាចារ្យធំ ) ជាដើម កាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តបាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ធឃោស: ធ្វើអដ្ឋកថាសីហឡ:ទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធ: ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរ: ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយ:កាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ធឃោស: ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្ដេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្ដីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញ    យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន    ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ    សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ    បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ    មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ    សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស    សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ    សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញ៉ាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្តីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្តីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្តី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្មាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| វិន. បារា. | វិន័យបិដក | ខុទ្ទកនិកាយ | បារាជិក | ភាគ ១ |
| វិន. សង្ឃា. | វិន័យបិដក | ខុទ្ទកនិកាយ | សង្ឃាទិសេស | ភាគ ២ |
| វិន. និស្ស. | វិន័យបិដក | ខុទ្ទកនិកាយ | និស្សគ្គិយ | ភាគ ៣ |
| វិន. បាចិ. | វិន័យបិដក | ខុទ្ទកនិកាយ | បាចិត្តិយ | ភាគ ៤ |
| វិន. ភិក្ខុនី. | វិន័យបិដក | ខុទ្ទកនិកាយ | ភិក្ខុនីវិភង្គ | ភាគ ៥ |
| វិន. មហា. | វិន័យបិដក | ខុទ្ទកនិកាយ | មហាវគ្គ | ភាគ ៦-៨ |
| វិន. ចុល្ល. | វិន័យបិដក | ខុទ្ទកនិកាយ | ចុល្លវគ្គ | ភាគ ៩-១១ |
| វិន. បរិ. | វិន័យបិដក | ខុទ្ទកនិកាយ | បរិវារៈ | ភាគ ១២-១៣ |
| ទីឃ. សីល. | សុត្តន្តបិដក | ទីឃនិកាយ | សីលក្ខន្ធវគ្គ | ភាគ ១៤-១៥ |
| ទីឃ. មហា. | សុត្តន្តបិដក | ទីឃនិកាយ | មហាវគ្គ | ភាគ ១៦-១៧ |
| ទីឃ. បាដិ. | សុត្តន្តបិដក | ទីឃនិកាយ | បាដិកវគ្គ | ភាគ ១៨-១៩ |
| មជ្ឈិ. មូល. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មូលបណ្ណាសក | ភាគ ២០-២២ |
| មជ្ឈិ. មជ្ឈិ. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក | ភាគ ២៣-២៥ |
| មជ្ឈិ. ឧប. | សុត្តន្តបិដក | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក | ភាគ ២៦-២៨ |
| សំយុ. សគា. | សុត្តន្តបិដក | សំយុត្តនិកាយ | សគាថវគ្គ | ភាគ ២៩-៣០ |
| សំយុ. និទា. | សុត្តន្តបិដក | សំយុត្តនិកាយ | និទានវគ្គ | ភាគ ៣១-៣២ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុកនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អបទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សមន្ត. ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | ពាហិរនិទាន |
| សមន្ត. វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | វេរញ្ជក័ណ្ឌ |
| សមន្ត. បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បារាជិកក័ណ្ឌ |
| សមន្ត. សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | សង្ឃាទិសេស |
| សមន្ត. និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | និស្សគ្គិយ |
| សមន្ត. បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បាចិត្តិយ |
| សមន្ត. មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | មហាវគ្គ |
| សមន្ត. ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | ចុល្លវគ្គ |
| សមន្ត. បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បរិវារៈ |
| សុមង្គ. សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុកនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ច. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្ដាលជាលេខឃ្នាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្នាបទី ៤៧៦ ទំព័រទី ៤៧៨ ។



# បញ្ជីមាតិកា

**មាតិកា** **ទំព័រ**

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ … … … … … … ក
ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ … … … … … … … … ង
ឧប្បត្តិកថា … … … … … … … … … … … … … ឋ
អក្សរសង្ខេប និងអក្សរពេញ … … … … … … … … ផ
បញ្ជីមាតិកា … … … … … … … … … … … … … ម

## មហាវគ្គវណ្ណនា អដ្ឋកថាព្រះវិន័យបិដក ភាគ ៦

### ១. មហាខន្ធកវណ្ណនា

អបលោកគាថា … … … … … … … … … … … ១
ពោធិកថា ទ្រង់រំពឹងបដិច្ចសមុប្បាទធម៌ … … … … … ២
អជបាលនិគ្រោធកថា … … … … … … … … … ១៦
មុចលិន្ទកថា … … … … … … … … … … … … ២១
រាជាយតនកថា រឿងពាណិជឈ្មោះតបុស្ស និងភល្លិកៈ … ២៥
ពុទ្ធបរិវិតក្កកថា … … … … … … … … … … … ៣១
ព្រហ្មយាចនកថា … … … … … … … … … … ៣៥
អាឡារឧទកតាបសកថា .. … … … … … … … … … ៤០
រឿងឧបកាជីវក … … … … … … … … … … … ៤៣

រឿងបញ្ចវគ្គិយភិក្ខុ ... ... ... ... ... ... ... ... ... ... ៤៦



## បញ្ជីមាតិកាអដ្ឋកថាមហាវគ្គ

**មាតិកា** **ទំព័រ**

យសវត្តកថា ... ... ... ... ... ... ... ... ... ... ... ... ៥០
បឋមមារកថា ... ... ... ... ... ... ... ... ... ... ... ៥២
បព្វជ្ជានិងឧបសម្បទា ... ... ... ... ... ... ... ... ... ៥៣
ទុតិយមារកថា ... ... ... ... ... ... ... ... ... ... ... ៦៤
រឿងភទ្ទវគ្គិយកុមារជាសម្លាញ់នឹងគ្នា ... ... ... ... ... ... ៦៥
រឿងជដិលជាបងប្អូននឹងគ្នា ... ... ... ... ... ... ... ... ៦៦
ការជួបជុំរបស់ព្រះបាទពិម្ពិសារ ... ... ... ... ... ... ... ៧០
បព្វជ្ជារបស់បរិព្វាជកឈ្មោះសារីបុត្តនិងមោគ្គល្លាន ... ... ៧៧
ឧបជ្ឈាយ៍វត្ត ... ... ... ... ... ... ... ... ... ... ... ៨៦
សទ្ធិវិហារិកវត្ត ... ... ... ... ... ... ... ... ... ... ... ១០២
បណាមកថា ... ... ... ... ... ... ... ... ... ... ... ១០៣
ពណ៌នារឿងរាធព្រាហ្មណ៍ ... ... ... ... ... ... ... ... ១០៦
ឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា ... ... ... ... ... ១០៧
ឧបជ្ឈាយ៍សទ្ធិវិហារិកកថា ... ... ... ... ... ... ... ... ១០៩
អាចរិយន្តេវាសិកកថា ... ... ... ... ... ... ... ... ... ១១២
ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍ និងអាចារ្យ ... ... ... ... ១១៤
ឧបសម្បទេតព្វបញ្ចក ១៦ ជង ... ... ... ... ... ... ... ១២១

ពោលអំពីបុគ្គលដែលធ្លាប់ជាតិត្ថិយដទៃ ... ... ... ... ... ១២៧


មាតិកាឧបោសថក្ខន្ធកៈ ណា

**មាតិកា** **ទំព័រ**


អន្តរាយិកធម្មកថា ... ... ... ... ... ... ... ... ... ... ១៤០

អភយូវរភាណវារៈ ... ... ... ... ... ... ... ... ... ... ១៤៥

រឿងត្រកូលធ្វើមរណកាលដោយអហិវាតករោគ ... ... ... ១៦២

រឿងភិក្ខុនៅជាប់និស្ស័យ ... ... ... ... ... ... ... ... ... ១៦៣

រាហុលសាមណេរបព្វជ្ជា ... ... ... ... ... ... ... ... ១៦៤

វិន័យរបស់សាមណេរ ... ... ... ... ... ... ... ... ... ១៨៨

មនុស្សខ្ទើយ ... ... ... ... ... ... ... ... ... ... ... ... ១៩៧

មនុស្សលួចសំវាស ... ... ... ... ... ... ... ... ... ... ១៩៩

មនុស្សចូលពួកតិត្ថិយ ... ... ... ... ... ... ... ... ... ២១០

រឿងនាគ ... ... ... ... ... ... ... ... ... ... ... ... ... ២១៣

បុគ្គលដែលសង្ឃមិនត្រូវឱ្យឧបសម្បទា៥២ចំពូក ... ... ... ២១៦

និស្សយវិធី ... ... ... ... ... ... ... ... ... ... ... ... ២៤០

ពណ៌នាឧបសម្បទាយត្តវិធី ... ... ... ... ... ... ... ... ២៤៥


## ២. ឧបោសថក្ខន្ធកវណ្ណនា


វិនិច្ឆ័យក្នុងឧបោសថក្ខន្ធកៈ ... ... ... ... ... ... ... ២៤៩

ការសន្មតសីមា ... ... ... ... ... ... ... ... ... ... ... ២៥២

ការសន្មតរោងនូវឧបោសថជាដើម ... ... ... ... ... ... ២៨១

វិធីដកសីមា ... ... ... ... ... ... ... ... ... ... ... ... ២៨៧



បញ្ជីមាតិកាអដ្ឋកថាមហាវគ្គ

**មាតិកា** **ទំព័រ**

ពណ៌នាអពទ្ធសីមា ... ... ... ... ... ... ... ... ... ... ២៨៩
ពណ៌នាសត្តព្ភន្តរសីមា ... ... ... ... ... ... ... ... ... ២៩០
ពណ៌នាឧទកុក្ខេបសីមា ... ... ... ... ... ... ... ... ... ២៩២
ការទម្លាយសីមា ... ... ... ... ... ... ... ... ... ... ៣០០
ឧបោសថមានពីរ ... ... ... ... ... ... ... ... ... ... ... ៣០២
ការសម្តែងបាតិមោក្ខមាន ៥ យ៉ាង ... ... ... ... ... ... ៣០៣
អជ្ឈេសនា ... ... ... ... ... ... ... ... ... ... ... ... ៣០៦
ពណ៌នាបារិសុទ្ធិនិងឆន្ទៈ ... ... ... ... ... ... ... ... ... ៣១៧
ពណ៌នាការសម្តែងអាបត្តិ ... ... ... ... ... ... ... ... ៣២៣
ពណ៌នាការធ្វើឧបោសថមិនត្រូវអាបត្តិ ១៥ យ៉ាងជាដើម ៣២៧

## ៣. វស្សូបនាយិកក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងរឿងវស្សូបនាយិកក្ខន្ធក ... ... ... ... ... ... ៣៣៧
កិរិយាធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ... ... ... ... ៣៤១
អន្តរាយទាំងឡាយកើតដល់ពួកភិក្ខុ ... ... ... ... ... ... ៣៤៧
ការបំបែកសង្ឃកើតដល់ពួកភិក្ខុ ... ... ... ... ... ... ៣៤៩
ការចាំវស្សាក្នុងលំនៅរបស់គង្វាលគោ ... ... ... ... ... ៣៥០

ពួកភិក្ខុចូលចាំវស្សាក្នុងទីវាលជាដើម ... ... ... ... ... ៣៥៣



**មាតិកា** **ទំព័រ**

## ៤. បវារណាខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងបវារណាខន្ធកៈ ... ... ... ... ... ... ... ... ៣៥៨
បវារណាវិធី ... ... ... ... ... ... ... ... ... ... ... ... ៣៦០
បវារណាកម្ម ... ... ... ... ... ... ... ... ... ... ... ... ៣៦២
ការឱ្យបវារណា ... ... ... ... ... ... ... ... ... ... ... ៣៦៣
ការឱ្យឆន្ទៈ ... ... ... ... ... ... ... ... ... ... ... ... ៣៦៤
អធិដ្ឋានបវារណា ... ... ... ... ... ... ... ... ... ... ៣៦៥
ថ្ងៃបវារណារបស់ពួកអាវាសិកភិក្ខុ និងអាគន្តុកភិក្ខុផ្សេងគ្នា ៣៦៦
សាមគ្គីបវារណា ... ... ... ... ... ... ... ... ... ... ៣៦៩
ញត្តិវិធាន ... ... ... ... ... ... ... ... ... ... ... ... ៣៧០
ការឃាត់បវារណា ... ... ... ... ... ... ... ... ... ... ៣៧១
ការធ្វើបវារណាសង្គហៈនៃពួកភិក្ខុអ្នកព្រមព្រៀងគ្នាជាដើម ៣៨០

## ៥. ចម្មក្ខន្ធកវណ្ណនា

រឿងព្រះសោណកោលិវិសត្ថេរ ... ... ... ... ... ... ... ៣៨២
ស្បែកជើង ... ... ... ... ... ... ... ... ... ... ... ... ៣៩៣

ទ្រនាប់ជើង ... ... ... ... ... ... ... ... ... ... ... ... ៣៩៨

យាន ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៩៩

៥ បញ្ជីមាតិកាអដ្ឋកថាមហាវគ្គ

**មាតិកា** **ទំព័រ**

ឧច្ចាសយនៈ និងមហាសយនៈ ... ... ... ... ... ... ... ៤០១

រឿងព្រះសោណកុដិកណ្ណៈ ... ... ... ... ... ... ... ... ៤០៤

ស្បែក ... ... ... ... ... ... ... ... ... ... ... ... ... ៤១០

## ៦. ភេសជ្ជក្ខន្ធកវណ្ណនា

ការចម្អិនក្នុងកុដិជាដើម ... ... ... ... ... ... ... ... ... ៤២៣

ការវះកាត់ក្នុងទីចង្អៀតជាដើម ... ... ... ... ... ... ... ៤២៥

ពណ៌នាសាច់ដែលគួរនិងមិនគួរ ... ... ... ... ... ... ... ៤២៦

ពណ៌យាគូជាដើម ... ... ... ... ... ... ... ... ... ... ៤២៩

រឿងស្តេចលិច្ឆវី ... ... ... ... ... ... ... ... ... ... ៤៣៥

ពណ៌នាឧទ្ទិស្សមំសៈ ... ... ... ... ... ... ... ... ... ... ៤៣៦

កប្បិយភូមិ ... ... ... ... ... ... ... ... ... ... ... ... ៤៣៩

បញ្ចគោរសនិងស្បៀងតាមមក ... ... ... ... ... ... ... ៤៤៧

ទឹកអដ្ឋបាន ... ... ... ... ... ... ... ... ... ... ... ... ៤៤៨

រស ៤ យ៉ាង ... ... ... ... ... ... ... ... ... ... ... ៤៥០

បន្លែនិងម្សៅ ... ... ... ... ... ... ... ... ... ... ... ៤៥២

រឿងភិក្ខុធ្លាប់ជាជាងកោរសក់ ... ... ... ... ... ... ... ៤៥៣

មហាបទេស ៤ ... ... ... ... ... ... ... ... ... ... ... ៤៥៥

កាលិកលាយគ្នា ... ... ... ... ... ... ... ... ... ... ... ៤៥៨


មាតិកាបវារណាខន្ធក: ណ

**មាតិកា** **ទំព័រ**

## ៧. កឋិនក្ខន្ធកវណ្ណនា


រឿងភិក្ខុក្នុងដែនបាវេយ្យៈ ... ... ... ... ... ... ... ... ៤៦១

អានិសង្ស ៥ ... ... ... ... ... ... ... ... ... ... ... ៤៦៤

ពណ៌នាអំពីអ្នកបានក្រាលកឋិន ... ... ... ... ... ... ... ៤៦៥

អ្នកថ្វាយកឋិន ... ... ... ... ... ... ... ... ... ... ... ៤៦៧

អ្នកគួរក្រាល ... ... ... ... ... ... ... ... ... ... ... ... ៤៦៩

កឋិនវត្ថុ ... ... ... ... ... ... ... ... ... ... ... ... ... ៤៧០

អនត្ថតាការនិងអត្ថតាការ ... ... ... ... ... ... ... ... ... ៤៧៣

ការដោះកឋិន ... ... ... ... ... ... ... ... ... ... ... ៤៨០


## ៨. ចីវរក្ខន្ធកវណ្ណនា


រឿងហ្មជីវក ... ... ... ... ... ... ... ... ... ... ៤៨៧

រឿងរាជគហសេដ្ឋី ... ... ... ... ... ... ... ... ... ... ៤៩៥

រឿងព្រះបាទចណ្ឌបជ្ជោត ... ... ... ... ... ... ... ... ៤៩៧

ទ្រង់អនុញ្ញាតសំពត់បាវារជាដើម ... ... ... ... ... ... ៥០០

ទ្រង់អនុញ្ញាតចីវរ៦ប្រភេទ ... ... ... ... ... ... ... ... ៥០៤

ការទទួលចីវរជាដើម ... ... ... ... ... ... ... ... ... ... ៥០៦
បុគ្គលដែលមិនគួរបណ្តេញ ... ... ... ... ... ... ... ... ៥១២

ឋ បញ្ជីមាតិកាអដ្ឋកថាមហាវគ្គ

**មាតិកា** **ទំព័រ**

ភិក្ខុជាអ្នកចែកចីវរ ... ... ... ... ... ... ... ... ... ... ៥១៣
ទឹកជ្រលក់ ... ... ... ... ... ... ... ... ... ... ... ... ៥២០
ចីវរកាត់ ... ... ... ... ... ... ... ... ... ... ... ... ... ៥២៣
ត្រៃចីវរ ... ... ... ... ... ... ... ... ... ... ... ... ... ៥២៦
កាន់យកដោយវិស្សាសៈជាដើម ... ... ... ... ... ... ... ៥៣០
អំពីផ្ញើសទ្ធាទេយ្យឱ្យធ្លាក់ជាដើម ... ... ... ... ... ... ៥៣២
សំពត់ដែលកើតឡើងក្នុងចីវរកាល ... ... ... ... ... ... ៥៣៣
សំពត់ដែលកើតឡើងក្នុងវជ្ជវកាល ... ... ... ... ... ... ៥៣៦
គិលានុបដ្ឋាក ... ... ... ... ... ... ... ... ... ... ... ៥៤២
វិនិច្ឆ័យក្នុងលាភរបស់ភិក្ខុដែលព្យាបាលជម្ងឺ ... ... ... ... ៥៤៥
ចីវរដែលមិនគួរ ... ... ... ... ... ... ... ... ... ... ៥៤៨
អ្នកគួរទទួលចីវរជាដើម ... ... ... ... ... ... ... ... ... ៥៥០
មាតិកា៨នៃការកើតឡើងរបស់ចីវរ ... ... ... ... ... ... ៥៥២
ថ្វាយដល់សីមា ... ... ... ... ... ... ... ... ... ... ... ៥៥៣
ថ្វាយតាមកតិកា ... ... ... ... ... ... ... ... ... ... ... ៥៥៩
ថ្វាយក្នុងទីដែលតាក់តែងភិក្ខា ... ... ... ... ... ... ... ៥៦០

ថ្វាយដល់សង្ឃ. ... ... ... ... ... ... ... ... ... ... ... ៥៦២
ថ្វាយដល់សង្ឃពីរចំណែក ... ... ... ... ... ... ... ... ៥៦៧

មាតិកាបវារណាខន្ធកៈ ណ

**មាតិកា** **ទំព័រ**

ថ្វាយដល់សង្ឃដែលចាំវស្សា ... ... ... ... ... ... ... ៥៧៣
ថ្វាយចំពោះ ... ... ... ... ... ... ... ... ... ... ... ៥៧៦
ថ្វាយដល់បុគ្គល ... ... ... ... ... ... ... ... ... ... ៥៧៩

## ៩. ចម្មេយ្យក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងចម្មេយ្យក្ខន្ធកៈ ... ... ... ... ... ... ... ... ៥៨០
កម្ម៦យ៉ាង ... ... ... ... ... ... ... ... ... ... ... ... ៥៨២
ឱសារណា ... ... ... ... ... ... ... ... ... ... ... ... ៥៨៦

## ១០. កោសម្ពិកក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងកោសម្ពិកក្ខន្ធកៈ ... ... ... ... ... ... ... ... ៥៨៩
អត្ថនៃគាថា ... ... ... ... ... ... ... ... ... ... ... ... ៦០៤

មាតិកាមហាវគ្គវណ្ណនា ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### មហាវគ្គ

## បឋមភាគ

## ៦

# ១. មហាខន្ធកវណ្ណនា

## អបលោកគាថា

ព្រះមហាថេរៈទាំងឡាយ ជាអ្នកដឹងសេចក្តីក្នុងខន្ធកៈបានសង្គាយនាខន្ធកៈ ណា ជាលំដាប់នៃការសង្គាយនាបាតិមោក្ខទាំង ២ ។ ឥឡូវនេះដល់លំដាប់ពណ៌នានៃខន្ធកៈនោះហើយ ព្រោះដូច្នេះ វណ្ណនានេះ ទើបជាសេចក្តីអធិប្បាយនូវអត្ថដែលមិនទាន់ជាក់ច្បាស់នៃខន្ធកៈនោះ, សេចក្តីនៃបទទាំងឡាយណា យើងខ្ញុំព្រះករុណាទាំងឡាយ បានប្រកាសហើយក្នុងបទភាជនី, បើយើងខ្ញុំព្រះករុណា នឹងពោលពណ៌នានូវសេចក្តីនៃបទទាំងនោះដដែល ៗ ទៀត កាលណានឹងចប់ ។ ឯសេចក្តីទាំងឡាយណាដែលជាក់ច្បាស់ហើយ នឹងមានប្រយោជន៍អ្វី ដោយការពណ៌នាសេចក្តីទាំងនោះ ។ ក៏ឯសេចក្តីទាំងឡាយណា មិនទាន់ជាក់ច្បាស់ដោយអធិប្បាយ និងអនុសន្ធិ និងដោយព្យញ្ជនៈ សេចក្តីទាំងនោះ បើមិនពណ៌នាទុក មិនមានអ្នកណា ៗ អាចជ្រាបបាន, ព្រោះដូច្នោះ ទើបមានពណ៌នាន័យសេចក្តីទាំងនោះ ដូច្នេះ ។

# ពោធិកថា ទ្រង់រំពឹងបដិច្ចសមុប្បាទធម៌

[១] ក្នុងពាក្យថា តេន សមយេន ពុទ្ធោ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ : សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគ បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្សក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស នេះមានពាក្យវិនិច្ឆ័យដែលគួរជ្រាប ដូច្នេះ ៖

សូម្បីក្នុងពាក្យនេះ ទឹងមិនមានហេតុពិសេស ព្រោះតតិយាវិភត្តិ ដូចក្នុងពាក្យដែលថា តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ ជាដើម ក៏ពិតហើយ តែវោហារនេះ លោកលើកឡើងដោយតតិយាវិភត្តិដូចគ្នា ព្រោះសម្លឹងយកវិន័យ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានថា ពាក្យនោះ លោកពោលតាមពាក្យទំនងវោហារ ដែលលើកឡើងតាំងពីដំបូងនុ៎ះឯង ។ សូម្បីក្នុងពាក្យដទៃ ៗ ក្រៅចាកពីពាក្យនេះ ក៏មានន័យដូចគ្នាដែរ ។

សួរថា ក៏អ្វីជាប្រយោជន៍ក្នុងការពោលពាក្យនោះហ្ន៎ ?

ឆ្លើយថា ការសម្តែងហេតុ តាំងពីដំបូងនៃវិន័យកម្មទាំងឡាយ មានបព្វជ្ជាជាដើម ជាប្រយោជន៍ ។

មែនពិត អ្នកសិក្សាគប្បីជ្រាបថា ប្រយោជន៍ក្នុងការពោលពាក្យ

នោះ ក៏គឺ ការសម្តែងហេតុតាំងពីដំបូងនៃវិន័យកម្មទាំងឡាយ មានបព្វជ្ជាជាដើមទាំងនោះ យ៉ាងនេះថា បព្វជ្ជា និងឧបសម្បទាយ៉ាងណា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងឡាយនេះ"[១] ដូច្នេះ និងវត្តទាំងឡាយ មានឧបជ្ឈាយវត្ត អាចរិយវត្តជាដើមទាំងឡាយណា ដែលទ្រង់អនុញ្ញាតក្នុងទីទាំងឡាយ មានក្រុងរាជគ្រឹះជាដើម បព្វជ្ជា ឧបសម្បទា និងឧបជ្ឈាយវត្តជាដើម ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់ សម្រេចអភិសម្ពោធិញាណហើយ ឱ្យ ៧ សប្តាហ៍កន្លងផុតទៅក្រោមម្លប់ពោធិមណ្ឌល ទ្រង់ប្រកាសព្រះធម្មចក្កក្នុងក្រុងពារាណសីហើយ ទ្រង់យាងដល់ស្ថាននេះ ៗ ដោយលំដាប់នេះ ហើយទ្រង់បញ្ញត្តិព្រោះរឿងនេះ ៗ ។

ក្នុងបទទាំងនោះ បទថា ឧរុវេលាយំ : ក្នុងឧរុវេលាប្រទេស បានដល់ ដែនដ៏ធំ ៗ អធិប្បាយថា គំនរខ្សាច់ធំ ៗ មួយប្រការទៀត ខ្សាច់ ហៅថា ឧរុ, ខេត្ត ដែន ហៅថា វេលា ។ គប្បីឃើញសេចក្តីក្នុងបទនេះ យ៉ាងនេះថា ខ្សាច់ដែលគេជញ្ជូនមក ព្រោះហេតុដែលកន្លងខេត្តដែន ឈ្មោះថា ឧរុវេលា ។

---

១. វិន. មហា. មហាខន្ធក. ៦. ៣៤/៧១ ។

បានឮថា ក្នុងអតីតកាល កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង មានកុលបុត្រមួយម៉ឺននាក់ បួសជាតាបសនៅត្រង់ប្រទេសនោះ ថ្ងៃមួយបានប្រជុំគ្នាធ្វើកតិកាវត្តទុកថា "ធម្មតាកាយកម្មវចីកម្ម ជារបស់ប្រាកដដល់អ្នកដទៃបាន ចំណែកមនោកម្ម មិនប្រាកដឡើយ ។ ព្រោះដូច្នោះ អ្នកណាមានកាមវិតក្កៈ ឬព្យាបាទវិតក្កៈ ឬ វិហឹង្សាវិតក្កៈ អ្នកដទៃនឹងចោទអ្នកនោះ រមែងមិនមានអ្នកនោះ ត្រូវចោទខ្លួនដោយខ្លួនឯង ហើយយកភាជន៍[១] គឺ បាត្រជញ្ជូនខ្សាច់មកគរក្នុងទីនេះ ដោយតាំងចិត្តថា នេះគប្បីជាទណ្ឌកម្ម" ចាប់ផ្តើមអំពីនោះមក អ្នកណាត្រិះរិះយ៉ាងនោះ អ្នកនោះ រមែងយកភាជនៈ គឺ បាត្រជញ្ជូនខ្សាច់មកគរក្នុងទីនោះ ។ ដោយប្រការយ៉ាងនេះ គំនរខ្សាច់ក្នុងទីនោះ ទើបធំឡើងដោយលំដាប់ ។ ខាងក្រោយមកពួកជន បានលោមព័ទ្ធរបងគំនរខ្សាច់ធំនោះ ធ្វើឱ្យជាចេតិយស្ថាន ។

ខ្ញុំព្រះករុណាសំដៅយកគំនរខ្សាច់នោះ ទើបពោលថា បទថា ឱរុវេលាយំ បានដល់ ដែនដ៏ធំ អធិប្បាយថា គំនរខ្សាច់ធំ ។ សំដៅ

---

១. ឬថា ស្លឹកឈើសម្រាប់ខ្ចប់ តាមន័យអដ្ឋកថា សត្តិគុម្ពជាតកដែលលោកនាំមកទុកក្នុងមង្គលត្ថទីបនីថា បត្តបុដសេវ្វាតិ ...បលិវេឋនបណ្ណស្សេវ ។ គួរតែ ជារបស់ដែលហៅថា កន្ទោង គឺ យកស្លឹកឈើមកដេរខ្ទាស់ជាប់គ្នា ជាភាជន៍ ដាក់របស់បាន ។ ក្នុងយោជនា ភាគ ២ ពោលថា បត្តបុដេនាតិ បណ្ណបុដេន ។

យកគំនរខ្សាច់នោះឯងពោលថា មួយប្រការទៀត ខ្សាច់ ហៅថា ឧរុ, ខេត្ត ដែន ហៅថា វេលា, និងគប្បីឃើញសេចក្តីក្នុងបទនេះ យ៉ាងនេះថា ខ្សាច់ដែលគេដឹកនាំមក ព្រោះហេតុដែលកន្លងខេត្តដែន ឈ្មោះថា ឧរុវេលា ។

បទថា ពោធិរុក្ខមូលេ : ក្រោមម្លប់ពោធិព្រឹក្ស មានសេចក្តីថា ញាណក្នុងមគ្គ ៤ ហៅថា ពោធិញ្ញាណ ព្រះមានព្រះភាគទ្រង់សម្រេចពោធិញ្ញាណនោះ ក្រោមដើមឈើនេះ ព្រោះដូច្នោះ ដើមឈើនោះ ទើបបាននាមថា ពោធិព្រឹក្ស, គល់នៃពោធិព្រឹក្សនោះ ឈ្មោះថា ពោធិរុក្ខមូល ។

បទថា បឋមាភិសម្ពុទ្ធោ : ព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងជាដំបូងបានដល់ ការត្រាស់ដឹងដំបូង ។ អធិប្បាយថា ជាអ្នកត្រាស់ដឹងព្រមមុនគេបង្អស់ ។

បទថា ឯកបល្លង្កេន : ទ្រង់គង់ដោយព្រះភ្នែនតែមួយ មានសេចក្តីថា ទ្រង់ប្រថាប់ ដោយបល្ល័ង្កតែមួយ ដែលទ្រង់ពែនហើយប៉ុណ្ណោះ ស្តេចមិនក្រោកឡើងសូម្បីតែម្តង ។

បទថា វិមុត្តិសុខប្បដិសំវេទី : ទ្រង់សោយវិមុត្តិសុខ មានសេចក្តីថា សោយវិមុត្តិសុខ គឺ សុខដែលកើតអំពីផលសមាបត្តិ ។

បទថា **បដិច្ចសមុប្បាទំ : នូវបដិច្ចសមុប្បាទធម៌** បានដល់បច្ចយករ ។ ពិតមែន បច្ចយាការលោកហៅថា បដិច្ចសមុប្បាទ ព្រោះអត្ថវិគ្រោះថា អាស្រ័យគ្នានិងគ្នា ញ៉ាំងធម៌ដែលបន្តជាប់គ្នាឱ្យកើតឡើង ។ សេចក្តីសង្ខេបក្នុងបទថា **បដិច្ចសមុប្បាទំ** នេះ ប៉ុណ្ណេះ ។

ចំណែកសេចក្តីពិស្តារ អ្នកប្រាថ្នាវិនិច្ឆ័យដែលដល់ព្រមដោយអាការទាំងពួង គប្បីកាន់យកចាកវិសុទ្ធិមគ្គ[1] និងមហាបករណ៍ ។

បទថា **អនុលោមបដិលោមំ : បណ្តាយចុះនិងច្រាសឡើង** មានវិគ្រោះថា តាមលំដាប់ផង បញ្ច្រាសលំដាប់ផង ឈ្មោះថា **បណ្តាយចុះនិងច្រាសឡើង** ។ អ្នកសិក្សា គប្បីឃើញសេចក្តីក្នុងបទយ៉ាងនេះឯងថា ក្នុងអនុលោម និងបដិលោមទាំង ២ នោះ បច្ចយាការមានអវិជ្ជាជាដើម ដែលលោកពោលដោយន័យជាដើមថា **អវិជ្ជាបច្ចយា សង្ខារា : សង្ខារទាំងឡាយ កើតមាន ព្រោះមានអវិជ្ជាជាហេតុ** ដូច្នេះ ហៅថាអនុលោម ព្រោះធ្វើកិច្ចដែលខ្លួនគប្បីធ្វើ ។

បច្ចយាការនោះ ៗឯង ដែលលោកពោលដោយន័យជាដើមថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ : សេចក្តីរលត់សង្ខារកើតមាន ព្រោះរលត់មិនមានសេសសល់នៃអវិជ្ជា** ដូច្នេះ កាល

---

១. វិសុ. បញ្ញា. តតិយ. ១០៧ ។ ឬក្នុងសម្មោហវិនោទនី ។

រលត់ព្រោះនិរោធ គឺ មិនកើតឡើង រមែងមិនធ្វើកិច្ចនោះ ព្រោះដូច្នោះ ទើបហៅថា បដិលោម ព្រោះមិនធ្វើកិច្ចនោះ ។ ម្យ៉ាងទៀត បច្ចយាការដែលពោលហើយ តាមន័យមុនន៉ុះឯង ប្រព្រឹត្តទៅតាមហេតុ ក្រៅពីនេះ ប្រព្រឹត្តទៅបញ្ច្រាសហេតុ ។ ក៏ឯសេចក្ដីជាអនុលោម និងបដិលោមក្នុងបច្ចយាការនេះ មិនទាន់ត្រូវដោយសេចក្ដីដទៃចាកពីនេះ ព្រោះលោកមិនបានពោល តាំងពីដើមដរាបដល់ចុង និងតាំងពីចុងដរាបដល់ដើម ។

បទថា **មនសាកាសិ** កាត់បទថា **មនសិ** **អកាសិ** ប្រែថា **ទ្រង់រំពឹង** គឺ បានធ្វើក្នុងព្រះហឫទ័យ ក្នុងអនុលោម និងបដិលោមទាំង ២ នោះ ព្រះមានព្រះភាគទ្រង់បានធ្វើក្នុងព្រះហឫទ័យដោយអនុលោមដោយប្រការណា ដើម្បីសម្ដែងប្រការនេះ មុនព្រះធម្មសង្គាហកាចារ្យ ទើបពោលពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម ។ ក្នុងពាក្យនោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីក្នុងបទ ទាំងពួងដោយន័យនេះថា អវិជ្ជានោះផងជាបច្ច័យផង ព្រោះដូច្នោះ ឈ្មោះថា អវិជ្ជាជាបច្ច័យ, សង្ខារទាំងឡាយរមែងកើតព្រម ព្រោះអវិជ្ជាដែលជាបច្ច័យនោះ សេចក្ដីសង្ខេបក្នុងបទថា **មនសាកាសិ** នេះប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដារអ្នកត្រូវការវិនិច្ឆ័យដែលដល់ព្រមដោយអាការគ្រប់យ៉ាង គប្បីកាន់យកចាក ពីវិសុទ្ធិមគ្គ[1] សម្មោហវិនោទនី[2] និងអដ្ឋកថានៃមហាវិភង្គ ។ ព្រះមានព្រះភាគទ្រង់បាន

១. វិសុ. បញ្ញា. តតិយ. ១២៤ ។ ២. សម្មោ. វិភ. ១៦៨ ។

ធ្វើក្នុងព្រះហឫទ័យ ដោយបដិលោមដោយប្រការណា ដើម្បីសម្តែងប្រការនេះ លោកទើបពោលពាក្យថា អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ ជាដើម ។ ក្នុងពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ

បទថា អវិជ្ជាយ ត្វេវ កាត់បទថា អវិជ្ជាយ តុ ឯវ ។

បទថា អសេសវិរាគនិរោធា : ព្រោះរលត់មិនមានសេសសល់ មានសេចក្តីថា ព្រោះរលត់មិននៅសេសសល់ ដោយមគ្គពោលគឺវិរាគៈ ។

បទថា សង្ខារនិរោធោ : សេចក្តីរលត់សង្ខារ បានដល់សេចក្តីរលត់ គឺ សេចក្តីមិនកើតឡើងនៃសង្ខារទាំងឡាយ ។ ក៏ឯដើម្បីសម្តែងថា សេចក្តីរលត់នៃវិញ្ញាណ កើតមាន ក៏ព្រោះរលត់សង្ខារទាំងឡាយ ដែលរលត់ទៅហើយយ៉ាងនោះ និងធម៌ទាំងឡាយមាននាមរូបជាដើម ទឹងជាធម៌ដែលរលត់ល្អហើយតែម្តង ក៏ព្រោះរលត់នៃធម៌ទាំងឡាយ មានវិញ្ញាណជាដើម លោកទើបពោលពាក្យថា សង្ខារនិរោធា វិញ្ញាណនិរោធោ ជាដើម ហើយពោលពាក្យថា កងទុក្ខទាំងអស់នេះ ជាការរលត់ទៅដោយប្រការយ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា កេវលស្ស : ទាំងអស់នេះ បានដល់ទាំង មូលឫសុទ្ធ សេចក្តីថា ប្រាសចាកសត្វ ។

បទថា ទុក្ខក្ខន្ធស្ស : **នៃគំនរទុក្ខ** បានដល់ កងទុក្ខ ។

ពីរបទថា និរោធោ ហោតិ : **សេចក្ដីរលត់ កើតមាន** មានសេចក្ដីថា សេចក្ដីមិនកើត រមែងមាន ។

ពីរបទថា ឯតមត្ថំ វិទិត្វា : **ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ** មានសេចក្ដីថា សេចក្ដីនេះណា ដែលព្រះធម្មសង្គាហកាចារ្យពោលថា កងទុក្ខមានសង្ខារជាដើម ជាការកើតឡើង ដោយអំណាចនៃបច្ច័យមានអវិជ្ជាជាដើម និង ជាការរលត់ទៅដោយអំណាចរលត់នៃបច្ច័យ មានអវិជ្ជាជាដើម ដូច្នេះ ទ្រង់ ជ្រាបសេចក្ដីនោះ ដោយអាការទាំងពួង ។

ពីរបទថា តាយំ វេលាយំ : **ក្នុងវេលានោះ** បានដល់ ក្នុងវេលាដែលទ្រង់ជ្រាបសេចក្ដីនោះ ៗ ។

បទថា ឥមំ ឧទានំ ឧទានេសិ : **ទើបបន្លឺនូវឧទានគាថា** មានសេចក្ដីថា ទ្រង់បន្លឺឧទាន ដែលកើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មានពាក្យថា យទា ហវេ បាតុភវន្តិ : **ធម៌ទាំងឡាយរមែងប្រាកដ ក្នុងកាលណា** ជាដើមនេះ ដែលសម្ដែងអានុភាពដែលទ្រង់ជ្រាបហេតុ និងធម៌ដែលកើតអំពីហេតុ ក្នុងសេចក្ដីដែលទ្រង់ជ្រាបហើយនោះ មានពាក្យអធិប្បាយថា ទ្រង់បន្លឺព្រះវាចាសម្ដែងសេចក្ដីរីករាយព្រះហឫទ័យ ។

សេចក្ដីនៃឧទាននោះថា បទថា យទា ហវេ : ក្នុងកាលណា បានដល់ ក្នុងកាលឯណា ។

បទថា បាតុភវន្តិ : រមែងប្រាកដ បានដល់ រមែងកើត ។ ពោធិបក្ខិយធម៌ ដែលឱ្យសម្រេចនូវការត្រាស់ដឹងបច្ចយាការដោយអនុលោម ឈ្មោះថា ធម៌ ។

ម្យ៉ាងទៀត បទថា បាតុភវន្តិ មានសេចក្ដីថា ជាក់ច្បាស់ គឺជារបស់ច្បាស់លាស់ ប្រាកដដោយអំណាចការត្រាស់ដឹង ។ ធម៌គឺអរិយសច្ចៈ ៤ ឈ្មោះថា ធម៌ ។ សេចក្ដីព្យាយាម ហៅថា អាតាបៈ ព្រោះអត្ថថា ដុតកិលេសឱ្យក្ដៅ ។

បទថា អាតាបិនោ : អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្ដៅ បានដល់ អ្នកមានសេចក្ដីព្យាយាម ដែលបុគ្គលគប្បីតាំងទុកដោយប្រពៃ ។

បទថា ឈាយតោ : អ្នកដុតបង់នូវកិលេស មានសេចក្ដីថា អ្នកសម្ងំដោយឈាន ២ គឺ ដោយការកំណត់ គឺ អារម្មណូបនិជ្ឈាន ១ ដោយការកំណត់ គឺ លក្ខណូបនិជ្ឈាន ១ ។

បទថា ព្រាហ្មណស្ស : ដល់ព្រះខីណាស្រពព្រាហ្មណ៍ បានដល់ ព្រះខីណាស្រពដែលបណ្ដេតបាបហើយ ។

ច្រើនបទថា អថស្ស កង្ខា វបយន្តិ ៖ សេចក្តីសង្ស័យទាំងឡាយរបស់ព្រះខីណាសវព្រាហ្មណ៍នោះ រមែងរម្ងាប់ទៅ មានសេចក្តីថា កាលនោះ សេចក្តីសង្ស័យរបស់ព្រាហ្មណ៍នោះ គឺអ្នកមានធម៌ប្រាកដហើយយ៉ាងនោះ រមែងអស់ទៅ ។

បទថា សព្វា ៖ ទាំងពួង មានសេចក្តីថា សេចក្តីសង្ស័យក្នុងបច្ចយាការដែលលោកបានពោលទុក ដោយន័យជាដើមថា កាលគេសួរថា "បពិត្រព្រះអង្គដ៏ចម្រើន នណាហ្ន៎ តែងពាល់ត្រូវ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះមិនត្រូវទេ"[១] ដូច្នេះ និងដោយន័យជាដើមថា កាលគេសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ជរា និងមរណៈ តើដូចម្តេចហ្ន៎ មួយទៀត ជរានិងមរណៈនេះ ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះមិនត្រូវទេ"[២] ដូច្នេះ ។ និងសេចក្តីសង្ស័យ ១៦ យ៉ាងជាដើមថា ក្នុងអតីតកាលយើងបានមានហើយឬហ្ន៎ ? ដែលមកហើយ ព្រោះមិនទាន់បានត្រាស់ដឹងបច្ចយាការនុ៎ះឯង ទាំងអស់នេះ រមែងអស់ទៅ គឺ រមែងប្រាសចាកទៅ រមែងរលត់ទៅ ។ ព្រោះហេតុអ្វី ? ព្រោះហេតុដែលដឹងធម៌ព្រមទាំងហេតុ ។ មានអធិប្បាយថា ព្រោះ

---

១. សំយុ. និទា. អាហារវគ្គ. ៣១. ៣៣/២៧ ។ ២. សំយុ. និទា. កឡារខត្តិយវគ្គ. ៣១. ១២៩/១៣៣ ។

ជ្រាប គឺ ជ្រាបច្បាស់ ត្រាស់ដឹងធម៌ គឺ កងទុក្ខទាំងអស់មានសង្ខារជាដើមនេះ ព្រមទាំងហេតុ ដោយហេតុ មានអវិជ្ជាជាដើម ។

(២) គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវារ ៖

បីបទថា ឥមំ ឧទានំ ឧទានេសិ : **ទើបបន្លឺនូវឧទានគាថានេះ** មានសេចក្តីថា ទ្រង់បន្លឺឧទាន មានប្រការដូចពោលហើយនេះ ដែលសម្តែងអានុភាពនៃការត្រាស់ដឹង ការអស់បច្ច័យ ពោលគឺ និព្វានដែលប្រាកដហើយ យ៉ាងនេះថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ក្នុងសេចក្តីដែលទ្រង់ជ្រាបហើយនោះ ។

សេចក្តីសង្ខេបក្នុងឧទាននោះ ដូចតទៅនេះ ៖

ព្រោះបានដឹង គឺ បានជ្រាបច្បាស់បានត្រាស់ដឹងនិព្វានពោលគឺសេចក្តីអស់បច្ច័យទាំងឡាយ កាលណាធម៌ទាំងឡាយ មានប្រការដូចពោលហើយប្រាកដដល់ព្រាហ្មណ៍នោះ ដែលមានព្យាយាម កាលនោះសេចក្តីសង្ស័យគ្រប់យ៉ាង ដែលនឹងគប្បីកើតឡើង ព្រោះមិនដឹងនិព្វានរមែងអស់ទៅ ។

(៣) គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយវារៈ តទៅ ៖

បីបទថា ឥមំ ឧទានំ ឧទានេសិ មានសេចក្តីថា ទ្រង់បន្លឺឧទានមានប្រការដូចពោលហើយនេះ ដែលសម្តែងអានុភាពនៃអរិយមគ្គ ដែល

ជាហេតុ ទ្រង់ជ្រាបសេចក្តីពោលគឺ ការកើតនិងការរលត់នៃកងទុក្ខនោះ ដោយអំណាចកិច្ច និងដោយធ្វើឱ្យជាអារម្មណ៍ ។

សេចក្តីសង្ខេបក្នុងឧទាននោះ ដូចតទៅនេះ ៖

ធម៌ទាំងឡាយ ប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឱ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា, ក្នុងកាលនោះ ខីណាសវព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារ ដោយពោធិបក្ខិយធម៌ដែលកើតហើយទាំងនោះ ឬដោយអរិយមគ្គជាគ្រឿងប្រាកដនៃចតុសច្ចធម៌ឋិតនៅ ។

ពាក្យថា វិធូបយំ តិដ្ឋតិ មារសេនំ : រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារ ហើយឋិតនៅ សេចក្តីថា រមែងកម្ចាត់ គឺ ផ្ចាញ់បង្ក្រាបសេនាមារ មានប្រការដូចពោលហើយ ដោយន័យជាដើមថា "កាមទាំងឡាយ ជាសេនាទី ១ របស់អ្នក"[១] ដូច្នេះ តាំងនៅ ។

សួរថា កម្ចាត់យ៉ាងណា ?

ឆ្លើយថា ដូចព្រះអាទិត្យបំភ្លឺអាកាសឱ្យភ្លឺដូច្នោះ ។

អធិប្បាយថា ព្រះអាទិត្យរះឡើងទៅហើយ កាលបំភ្លឺអាកាសឱ្យភ្លឺ ដោយរស្មីរបស់ខ្លួនឯង ឈ្មោះថា កម្ចាត់ងងឹតចេញ សេចក្តីនេះយ៉ាង

១. ខុទ្ទ. សុត្ត. បធានសូត្រ. ៥៤. ៤២/១៣៧ ។

ណា ៗ ព្រាហ្មណ៍សូម្បីនោះ កាលត្រាស់ដឹងសច្ចៈទាំងឡាយ ដោយធម៌ទាំងនោះ ឬដោយមគ្គនោះឯង ឈ្មោះថា កម្ចាត់សេនាមារចេញបានសេចក្ដីនេះក៏យ៉ាងនោះ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានថាក្នុងឧទានទាំង ៣ នេះ ឧទានទី ១ កើតឡើងដោយអំណាចសេចក្ដីពិចារណាបច្ចយករ ឧទានទី ២ កើតឡើងដោយអំណាចសេចក្ដីពិចារណាព្រះនិព្វាន ឧទានទី ៣ កើតឡើងដោយអំណាចសេចក្ដីពិចារណាមគ្គ ដោយប្រការដូច្នេះ ។

ចំណែកក្នុងឧទាន[១] លោកពោលថា "ទ្រង់រំពឹងក្នុងព្រះហឫទ័យចំពោះបដិច្ចសមុប្បាទធម៌ជាអនុលោម គឺ ពិចារណាបណ្ដោយអស់រាត្រីបឋមយាម, ជាបដិលោមគឺពិចារណាច្រាស់ឡើង អស់មជ្ឈិមយាមនៃរាត្រី, ជាអនុលោម និងបដិលោម អស់រាត្រីបច្ឆិមយាម" ពាក្យនោះលោកពោលសំដៅយកមនសិការ ដែលព្រះមានព្រះភាគ ទ្រង់ឱ្យកើតឡើងរហូតអស់រាត្រី ដោយទ្រង់តាំងព្រះហឫទ័យថា "ក្នុងថ្ងៃស្អែកតថាគតនឹងក្រោកចាកពីអាសនៈ ព្រោះគ្រប់ ៧ ថ្ងៃ" ។ ពិតមែន គ្រានោះ ព្រះមានព្រះភាគទ្រង់បានពិចារណាចំណែកមួយ ៗ ប៉ុណ្ណោះ រហូតអស់បឋមយាម និងមជ្ឈិមយាម ដោយអំណាចនៃការជ្រាបច្បាស់នូវ

១. ខុទ្ទ. ឧទា. ពោធិវគ្គ. ៥២. ៣៨-៤០/១១៣-៦ ។

បច្ចយាការ និងសេចក្តីសម្រេចសេចក្តីអស់បច្ច័យ ដែលមានអានុភាព ដែលឧទានគាថា ២ ខាងដើមសម្តែងទុក តែក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់បានពិចារណាយ៉ាងនោះ ក្នុងរាត្រីថ្ងៃបាដិបទ (១រោច) ។ ពិតមែន ក្នុងរាត្រីពេញបូណ៌មីខែវិសាខ ព្រះមានព្រះភាគ ទ្រង់រលឹកបុព្វេនិវាសក្នុង បឋមយាមទ្រង់ជម្រះទិព្វចក្ខុ ក្នុងមជ្ឈិមយាមទ្រង់ពិចារណាបដិច្ចសមុប្បាទ ដោយអនុលោម និងបដិលោម ក្នុងបច្ឆិមយាមទ្រង់សម្រេច ភាពជាព្រះសព្វញ្ញូ ក្នុងខណៈដែលនឹងគប្បីពោលថា អរុណនឹងរះឡើង ឥឡូវនេះ ។ អរុណរះ ក្នុងវេលាបន្ទាប់ពីវេលាដែលទ្រង់បានសម្រេច ភាពជាព្រះសព្វញ្ញូតែម្តង ។ តពីនោះ ព្រះអង្គទ្រង់ញ៉ាំងថ្ងៃនោះ ឱ្យកន្លង ផុតទៅដោយការអង្គុយចម្រើនសមាធិនោះឯង ហើយទ្រង់ពិចារណាយ៉ាង នោះ បន្លឺឧទានទាំងនេះ ក្នុងយាមទាំង ៣ នៃរាត្រីថ្ងៃបាដិបទ ដែលដល់ ព្រមហើយ ។ ព្រះមានព្រះភាគទ្រង់ពិចារណាយ៉ាងនោះ ក្នុងរាត្រីថ្ងៃ បាដិបទឱ្យ ៧ ថ្ងៃដែលលោកពោលយ៉ាងនេះថា "ទ្រង់គង់នៅដោយ ភ្នែនតែមួយ អស់ ៧ ថ្ងៃក្រោមម្លប់ពោធិព្រឹក្ស" នោះ កន្លងផុតទៅ ក្រោមម្លប់ពោធិព្រឹក្សនោះឯង ដោយប្រការដូច្នេះ ។

ពោធិកថា ចប់

# អជបាលនិគ្រោធកថា

[៤] ក្នុងពាក្យថា អថ ខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋហិត្វា ពោធិរុក្ខមូលា, យេន អជបាលនិគ្រោធោ តេនុបសង្កមិ : លុះថ្ងៃ ៧ កន្លងទៅហើយ គ្រានោះ ព្រះមានព្រះភាគទ្រង់ចេញចាកសមាធិនោះ ហើយទ្រង់ចេញពីម្លប់ពោធិព្រឹក្ស យាងចូលទៅកាន់ដើមអជបាលនិគ្រោធ នេះ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ព្រះមានព្រះភាគចេញចាកសមាធិនោះហើយ ស្តេចចូលទៅត្រង់ដើមអជបាលនិគ្រោធបន្ទាប់ពីគល់ពោធិព្រឹក្សក្នុងខណៈនោះតែម្តងក៏ទេ ដូចក្នុងពាក្យដែលនិយាយថា "អ្នកនេះស៊ីហើយ ក៏ដេក" នឹងមានពាក្យអធិប្បាយថា គេមិនលាងដៃ មិនខ្ពុរមាត់ មិនទៅជិតទីដេក មិនធ្វើការចរចាប្រាស្រ័យអ្វីខ្លះ យ៉ាងដទៃ ហើយដេក ក៏ទេ តែក្នុងពាក្យនេះ មានន័យសេចក្តីដែលអ្នកពោលសម្តែងដូច្នេះថា គេដេកខាងក្រោយអំពីការបរិភោគ គេមិនបានដេក ក៏មិនមែន សេចក្តីនេះយ៉ាងណា សូម្បីក្នុងពាក្យនេះ ក៏យ៉ាងនោះ នឹងមានពាក្យអធិប្បាយថា ព្រះមានព្រះភាគចេញពីសមាធិនោះហើយ ស្តេចជៀសចេញទៅក្នុងខណៈនោះ ក៏ទេ ៗ ការពិត ក្នុងពាក្យនេះ មានអត្ថដែលលោកពោលសម្តែង ដូច្នេះថា ព្រះអង្គ

ស្ដេចជៀសចេញទៅខាងក្រោយ អំពីការចេញ ស្ដេចមិនបានជៀសចេញទៅ ក៏ទេ ។

សួរថា ក៏ព្រះមានព្រះភាគស្ដេចមិនជៀសចេញទៅក្នុងខណៈនោះហើយ ទ្រង់បានធ្វើអ្វីហ្ន៎ ?

ឆ្លើយថា ទ្រង់បានឱ្យ ៣ សប្ដាហ៍សូម្បីដទៃទៀត កន្លងផុត ទៅក្នុងប្រទេសជិតពោធិព្រឹក្សនុ៎ះឯង ។

ក្នុងសេចក្ដីនោះ មានអនុបុព្វីកថា ដូច្នេះ ៖

បានឮថា កាលព្រះមានព្រះភាគបានត្រាស់ដឹងជាព្រះពុទ្ធហើយ ទ្រង់គង់ដោយភ្លែនតែមួយ ចម្រើនសមាធិអស់មួយសប្ដាហ៍ ទេវតាពួកខ្លះកើតសេចក្ដីសង្ស័យឡើងថា ព្រះមានព្រះភាគ មិនក្រោកឡើង ធម៌ដែលធ្វើភាពជាព្រះពុទ្ធ សូម្បីដទៃ និងមានម្ដងទៀតទេដឹង ? លំដាប់នោះព្រះមានព្រះភាគចេញចាកសមាបត្តិក្នុងថ្ងៃទី ៨ ទ្រង់ជ្រាបសេចក្ដីសង្ស័យរបស់ពួកទេវតា ដើម្បីកាត់សេចក្ដីសង្ស័យ ទើបទ្រង់ហោះឡើងទៅក្នុងអាកាសសម្ដែងយមកបាដិហារ្យ កម្ចាត់សេចក្ដីសង្ស័យរបស់ពួកទេវតាទាំងនោះហើយ ប្រថាប់ឈរសម្លឹងមើលដោយព្រះនេត្រ មិនបានប៉ប្រិចនូវព្រះបល្ល័ង្ក និងពោធិព្រឹក្ស ដែលជាស្ថានទីសម្រេចផលនៃព្រះបារមី ដែលសាងមករហូតដល់អស់ ៤ អសង្ខេយ្យក្រៃលែងដោយមួយសែនកប្ប ឱ្យមួយសប្ដាហ៍ កន្លងផុតទៅក្នុងទិសឧត្តរ ឆៀងទៅទិស

បស្ចិមបន្ទិច (ទិសពាយព្យ) អំពីព្រះបល្ល័ង្ក ស្ថានទីនោះ ឈ្មោះថា **អនិមិ្មសចេតិយ** ។

លំដាប់នោះ ស្តេចចង្រ្កមក្នុងរតនចង្រ្កមដ៏វែង ទៅមកខាងមុខ និងខាងក្រោយចន្លោះព្រះបល្ល័ង្ក និងទីដែលស្តេចប្រថាប់ឈរ (អនិម្មិស ចេតិយ) មួយសប្តាហ៍ កន្លងផុតទៅ ។ ស្ថានទីនោះ ឈ្មោះថា **រតន ចង្រ្កមចេតិយ** ។

តពីនោះ ទេវតាទាំងឡាយ និមិត្តផ្ទះកែវឡើងក្នុងទិសខាងលិច ព្រះមានព្រះភាគ ទ្រង់គង់ចម្រើនសមាធិក្នុងផ្ទះកែវនោះ ទ្រង់ពិចារណា អភិធម្មបិដក គឺ សមន្តប្បដ្ឋាន ដែលមានន័យមិនមានទីបំផុត ក្នុង អភិធម្មបិដកនេះដោយពិស្តារ ឱ្យមួយសប្តាហ៍កន្លងផុតទៅ ។ ស្ថានទី នោះ ឈ្មោះថា **រតនឃរចេតិយ** ។ ព្រះមានព្រះភាគឱ្យ ៤ សប្តាហ៍កន្លង ផុតទៅក្នុងទីជិតពោធិព្រឹក្សនុ៎ះឯង ទើបក្នុងសប្តាហ៍គម្រប់ ៥ ស្តេចចេញ ពីគល់ពោធិព្រឹក្ស ចូលទៅក្រោមដើមអជបាលនិគ្រោធ ដោយប្រការ ដូច្នេះ ។ បានឮថា អ្នកចិញ្ចឹមពពែទៅអង្គុយក្រោមម្លប់នៃដើមជ្រៃនោះ ព្រោះហេតុនោះ ដើមជ្រៃនោះ ទើបបានឈ្មោះថា **អជបាលនិគ្រោធ** ។

ពីរបទថា សត្តាហំ វិមុត្តិសុខបដិសំវេទី **: សោយវិមុត្តិសុខ អស់ ៧ ថ្ងៃ** មានសេចក្តីថា កាលទ្រង់ពិចារណាធម៌ នៅក្រោមម្លប់ដើម អជបាលនិគ្រោធនុ៎ះឯង ឈ្មោះថា សោយវិមុត្តិសុខ, ដើមឈើនោះ នៅ

ទិសខាងកើតអំពីដើមពោធិព្រឹក្ស ។ ក៏កាលព្រះមានព្រះភាគគង់ប្រថាប់យ៉ាងនោះ នៅក្រោមម្លប់ដើមអជបាលនិគ្រោធនេះ ព្រាហ្មណ៍ម្នាក់ បានមកទូលសួរបញ្ហាចំពោះព្រះអង្គ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលពាក្យថា អថ ខោ អញ្ញតរោ ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ហុំហុំកជាតិកោ** : ឈ្មោះ**ហុំហុំជាតិក:** មានសេចក្ដីថា បានឮថា ព្រាហ្មណ៍នោះ ឈ្មោះទិដ្ឋមង្គលិក: ដើរមកគម្រាមថា **ហុំហុំ** ដោយអំណាចសេចក្ដីប្រកាន់ខ្លួន និងដោយអំណាចសេចក្ដីក្រោធ ព្រោះហេតុនោះ គេទើបហៅគាត់ថា ព្រាហ្មណ៍ហុំហុំកជាតិក អាចារ្យខ្លះក៏ពោលថា ព្រាហ្មណ៍ហុហុកជាតិក ។

ពីរបទថា **ឯតមត្ថំ វិទិត្វា** : ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ មានសេចក្ដីថា ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្ដីនៃពាក្យដែលគាត់ពោលនោះ ទើបទ្រង់បន្លឺឧទាននេះក្នុងវេលានោះ ។

សេចក្ដីនៃឧទាននោះថា ព្រាហ្មណ៍ណា មានបាបធម៌ បណ្ដែតចោលហើយ មានសំឡេងគម្រាមថា **ហុំហុំ** និងកិលេស ដូចទឹកអម្ចត់ជាដើមលះចោលហើយ ព្រោះតម្លៃដែលមកកាន់ថា វត្ថុដែលឃើញហើយជាមង្គល ប្រដ្ឋានូវភាពនៃខ្លួនជាព្រាហ្មណ៍ ដោយហេតុត្រឹមតែជាតិម្យ៉ាងក៏ទេ, ព្រាហ្មណ៍នោះ ឈ្មោះថា ជាអ្នកមានបាបធម៌ដែលបណ្ដែតហើយ

ព្រោះជាអ្នកបណ្តែត បាបធម៌ចេញ ឈ្មោះថា អ្នកមិនមានកិលេសជាគ្រឿងគម្រាមអ្នកដទៃថា ហុំហុំ ព្រោះលះកិលេសជាគ្រឿងគម្រាមអ្នកដទៃថា ហុំហុំ ចេញបាន ឈ្មោះថា អ្នកមិនមានកិលេសដូចទឹកអម្ចត់ ព្រោះមិនមានកិលេសដូចទឹកអម្ចត់ មានរាគៈជាដើម ឈ្មោះថា មានខ្លួនសង្រួមហើយ ព្រោះជាអ្នកមានចិត្តប្រកបដោយភាវនានុយោគ មួយទៀត ឈ្មោះថា អ្នកមានខ្លួនសង្រួមហើយ ព្រោះជាអ្នកមានចិត្ត សង្រួមហើយដោយសីលសំវរៈ ឈ្មោះថា អ្នកចប់វេទហើយ ព្រោះជាអ្នកដល់ទីបំផុតដោយវេទទាំងឡាយ ពោលគឺ ចតុមគ្គញ្ញាណ ឬព្រោះជាអ្នករៀនចប់ត្រៃវេទ ឈ្មោះថា អ្នកចប់ព្រហ្មចរិយហើយ ព្រោះព្រហ្មចរិយគឺ មគ្គ ៤ ដែលខ្លួនបាននៅរួចហើយ ។

បាទព្រះគាថាថា ធម្មេន សោ ព្រហ្មវាទំ វទេយ្យ : ព្រាហ្មណ៍នោះ គួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន មានសេចក្តីថា កិលេសគ្រឿងប៉ោងឡើង ៥ យ៉ាងនេះ គឺ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ព្រោះតែអារម្មណ៍បន្តិចបន្តួច គឺ ថា សូម្បីក្នុងអារម្មណ៍តែមួយក្នុងលោកទាំងមូល មិនមានដល់ព្រាហ្មណ៍ណា ព្រាហ្មណ៍នោះដោយមកធម៌ គួរពោលវាទៈនេះថា យើងជាព្រាហ្មណ៍ ។

អជបាលនិគ្រោធកថា ចប់

# មុចលិន្ទកថា

[៥] ភ្លៀងដែលកើតឡើង ក្នុងកាលមិនទាន់ដល់រដូវភ្លៀង ឈ្មោះថា ភ្លៀងពុំជួកាល គឺឯភ្លៀងនេះកើតឡើងក្នុងខែចុងនៃរដូវក្តៅ ។

បទថា សត្តាហវទ្ទលិកា : ភ្លៀងមានរលឹមអស់ ៧ ថ្ងៃ មានសេចក្តីថា កាលភ្លៀងពុំជួកាលនោះ កើតឡើងហើយ មានភ្លៀងរលឹមស្រិច ៗរហូតដល់ ៧ ថ្ងៃ ។

បទថា សីតវាតទុទ្ទិនី : បណ្តាលឱ្យអាប់ពន្លឺព្រះអាទិត្យដោយអំណាចខ្យល់ត្រជាក់ មានសេចក្តីថា គឺឯភ្លៀងរលឹមស្រិច ៗរហូតដល់ ៧ ថ្ងៃនោះ បានឈ្មោះថា ភ្លៀងលាយខ្យល់ត្រជាក់ ព្រោះថា ថ្ងៃដែលខ្យល់ត្រជាក់ លាយគ្រាប់ភ្លៀងបក់ផាត់ទៅជុំវិញ ពាល់ត្រូវហើយ ។

ច្រើនបទថា អថ ខោ មុចលិន្ទោ នាគរាជា : គ្រានោះឯង មុចលិន្ទនាគរាជ មានសេចក្តីថា ស្តេចនាគដែលមានអានុភាពធំ កើតឡើងនៅក្នុងស្រះបោក្ខរណីជិតដើមរាំងនុ៎ះឯង ។

ច្រើនបទថា សត្តក្ខត្តុំ ភោគេហិ បរិក្ខិបិត្វា : ហើយពេនព័ទ្ធព្រះកាយព្រះមានព្រះភាគ ៧ ជុំ ដោយភ្នែន មានសេចក្តីថា កាលស្តេចនាគនោះវង់ព័ទ្ធជុំវិញព្រះកាយ ដោយព័ទ្ធពេន ៧ ជុំ បើកពពារធំបាំងនៅខាងលើព្រះសិរសាយ៉ាងនោះ រួមក្នុងនៃវង្វង់ភ្នែនរបស់

ស្តេចនាគនោះ មានប្រមាណប៉ុន បន្ទប់ឃ្លាំងក្នុងលោហប្រាសាទ, ព្រោះហេតុនោះ ព្រះមានព្រះភាគ ហាក់ដូចជាទ្រង់គង់ក្នុងប្រាសាទដែលហាប់ខ្យល់ មានទ្វារបង្អួចបិទ ។

ពាក្យថា មា ភគវន្តំ សីតំ : ផ្សារកុំបៀតបៀនព្រះមានព្រះភាគជាដើម សម្តែងហេតុដែលស្តេចនាគនោះ ធ្វើយ៉ាងនោះ ។ ពិតមែនស្តេចនាគបានធ្វើយ៉ាងនោះ ក៏ដោយតាំងចិត្តថា "រងារកុំបៀតបៀនព្រះមានព្រះភាគ" ។ ក្តៅកុំបៀតបៀនព្រះមានព្រះភាគ និងសម្ផស្សរបោមជាដើម កុំបៀតបៀនព្រះមានព្រះភាគ ។ ការពិត កាលមានភ្លៀងបង្អុរធ្លាក់រហូតអស់ ៧ ថ្ងៃ ក្នុងទីនោះ មិនមានសេចក្តីក្តៅឡើយ ។ ទោះជាយ៉ាងនោះ ក៏សមគួរដល់ស្តេចនាគនោះ នឹងគិតយ៉ាងនេះថា "បើមេឃនឹងស្រឡះទៅក្នុងចន្លោះ ៗ កម្តៅគង់នឹងមាន សូម្បីកម្តៅនោះ កុំបៀតបៀនព្រះអង្គឡើយ" ។

បទថា វិទ្ធំ : រាំងភ្លៀងហើយ បានដល់ ស្រឡះហើយ អធិប្បាយថា ជារបស់ទៅឆ្ងាយ ព្រោះអស់ពពក ។

បទថា វិគតវលាហកំ : ស្រឡះហើយ បានដល់ ប្រាសចាកពពក ។

បទថា ទេវំ : មេឃ បានដល់ អាកាស ។

បទថា សកវណ្ណំ : ភេទរបស់ខ្លួន បានដល់ រូបរបស់ខ្លួន ។

ពីរបទថា សុខោ វិវេកោ ៖ សេចក្ដីស្ងាត់ចាកកិលេស ជាគុណឱ្យកើតសេចក្ដីសុខ មានសេចក្ដីថា ឧបធិវិវេកពោលគឺ និព្វានជាសុខ ។

បទថា តុដ្ឋស្ស ៖ របស់បុគ្គលអ្នកត្រេកអរ មានសេចក្ដីថា អ្នកសន្ដោសដោយសេចក្ដីត្រេកអរក្នុងចតុមគ្គញាណ ។

បទថា សុត[១]ធម្មស្ស ៖ មានធម៌ប្រាកដហើយ បានដល់ អ្នកមានធម៌ប្រាកដហើយ ។

បទថា បស្សតោ ៖ បានឃើញធម៌ មានសេចក្ដីថា អ្នកឃើញហើយនូវវិវេកនោះ ឬធម៌យ៉ាងណាមួយ ដែលទឹងគប្បីឃើញបានទាំងអស់ដោយកែវភ្នែកគឺ ញាណ ដែលបានសម្រេចដោយកម្លាំងសេចក្ដីព្យាយាមរបស់ខ្លួន ។

សេចក្ដីមិនទាស់ទែងគ្នា ឈ្មោះថា សេចក្ដីមិនព្យាបាទ ។

ធម៌ជាចំណែកខាងដើមនៃមេត្តា ព្រះមានព្រះភាគ ទ្រង់សម្ដែងដោយបទថា សេចក្ដីមិនព្យាបាទនោះ ។

ពីរបទថា បាណភូតេសុ សញ្ញមោ ៖ សេចក្ដីសង្រួម មិនបៀតបៀនសត្វទាំងឡាយ មានសេចក្ដីថា និងសេចក្ដីសង្រួមក្នុងសត្វទាំង

---

១. សុត ស័ព្ទក្នុងទីនេះ លោកឱ្យប្រែថា ប្រាកដ ។ ដូចអាងទុកក្នុងសុមង្គលវិលាសិនីភាគ ១ ។

ឡាយ អធិប្បាយថា ការដែលមិនបៀតបៀនគ្នា ជាសេចក្ដីសុខ ។

ធម៌ជាចំណែកខាងដើមនៃករុណា ព្រះមានព្រះភាគទ្រង់សម្ដែងដោយបទថា សេចក្ដីសង្រួមនោះ ។

បាទគាថាថា **សុខា វិរាគតា លោកេ : សេចក្ដីណាយចាករាគៈ ជាគុណឱ្យកើតសេចក្ដីសុខក្នុងលោក** មានសេចក្ដីថា សូម្បីសេចក្ដីប្រាសចាកតម្រេក ក៏ចាត់ថា សេចក្ដីសុខ ។

សួរថា សេចក្ដីប្រាសចាកតម្រេក ដូចម្ដេច ?

ឆ្លើយថា គឺ សេចក្ដីកន្លងកាមទាំងឡាយចេញ ។

អធិប្បាយថា សេចក្ដីប្រាសចាកតម្រេកយ៉ាងណា ដែលលោកហៅថា "ការប្រព្រឹត្តកន្លងកាមទាំងឡាយ" សូម្បីការប្រាសចាកតម្រេកយ៉ាងនោះ ក៏ចាត់ថា សេចក្ដីសុខ ។ អនាគាមិមគ្គ ព្រះមានព្រះភាគត្រាស់ដោយបទថា "សេចក្ដីណាយចាករាគៈ" នោះ ។

ចំណែកព្រះអរហត្ត ព្រះមានព្រះភាគ ត្រាស់ដោយពាក្យនេះថា "កិរិយាកម្ចាត់បង់នូវអស្មិមានះ" ។ ពិតមែន ព្រះអរហត្ត លោកពោលថា ជាការកម្ចាត់ដោយរម្ងាប់អស្មិមានះ ។ ក៏ដែលឈ្មោះថា សុខដទៃក្រៅពីព្រះអរហត្តនេះមិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "កិរិយាកម្ចាត់បង់នូវអស្មិមានះនុ៎ះ ជាសុខយ៉ាងក្រៃលែង" ។

មុចលិន្ទកថា ចប់

# រាជាយតនកថា រឿងពាណិជឈ្មោះតបុស្ស និងភល្លិកៈ

[៦] បទថា **មុចលិន្ទមូលា** : ម្លប់ដើមរាំង បានដល់ ចាកពីគល់ដើមរាំងដែលតាំងនៅក្នុងទិសបស្ចឹមជិតមហាពោធិព្រឹក្ស ។

បទថា **រាជាយតនំ** : ដើមរាជាយតនៈ មានសេចក្តីថា ស្តេចចូលទៅកាន់គល់នៃដើមកែស ដែលតាំងនៅទិសទក្សិណ ។

ពាក្យថា **តេន ខោ បន សមយេន** : សម័យនោះឯង មានពាក្យសួរថា ក្នុងសម័យណា ?

ឆ្លើយថា ក្នុងសម័យដែលព្រះមានព្រះភាគ ទ្រង់គង់ដោយភ្នែនតែមួយចម្រើនសមាធិ រហូតអស់ ៧ ថ្ងៃ ក្រោមម្លប់ដើមកែស សក្កទេវរាជទ្រង់ជ្រាបថា ត្រូវមានកិច្ចជាប់ដោយព្រះក្រយាហារ ទើបទ្រង់បង្អោនផ្លែសម៉ជាព្រះឱសថថ្វាយ ក្នុងអរុណរះ ក្នុងថ្ងៃដែលទ្រង់ចេញចាកសមាធិតែម្តង ។ ព្រះមានព្រះភាគ សោយផ្លែសម៉ព្រះឱសថនោះល្មមសោយស្រេចប៉ុណ្ណោះ ក៏បានមានកិច្ចជាប់ដោយព្រះសរីរៈ ស្តេចសក្កៈបានថ្វាយទឹកខ្ពុរព្រះឱស្ឋហើយ ។ ព្រះមានព្រះភាគទ្រង់ខ្ពុរព្រះឱស្ឋហើយ ប្រថាប់ក្រោមម្លប់ឈើនោះឯង ។ កាលព្រះមានព្រះភាគគង់ប្រថាប់ក្នុងកាលអរុណរះហើយ ដោយប្រការយ៉ាងនោះ ។

ពីរបទថា តបុស្សភល្លិកា វាណិជា : មានពាណិជឈ្មោះតបុស្ស១ ភល្លិកៈ១ បានដល់ ពាណិជពីរនាក់បងប្អូន គឺ តបុស្សៈនិងភល្លិកៈ ។

បទថា ឧក្កលា បានដល់ ចាកពីឧក្កលជនបទ ( នៅភូមា ) ។

ពីរបទថា តំ ទេសំ : ប្រទេសនោះ មានសេចក្តីថា កាន់ប្រទេសជាទីនៅរបស់ព្រះមានព្រះភាគ ។

សួរថា ក៏ព្រះមានព្រះភាគស្តេចនៅក្នុងប្រទេសណាហ្ន៎ ?

ឆ្លើយថា ក្នុងមជ្ឈិមប្រទេស ។ ព្រោះដូច្នោះ ក្នុងពាក្យនេះ ទើបមានសេចក្តីដូច្នេះ ពាណិជពីរនាក់នោះ ជាអ្នកធ្វើដំណើរមកឆ្ងាយ ដើម្បីទៅកាន់មជ្ឈិមប្រទេស ។

ពីរបទថា ញាតិសាលោហិតា ទេវតា : មានទេវតាជាញាតិសាលោហិត បានដល់ ទេវតាដែលធ្លាប់ជាញាតិ របស់ពាណិជពីរនាក់នោះ ។

ពីរបទថា ឯតទវោច : បាននិយាយពាក្យនេះ មានសេចក្តីថា បានឮថា ទេវតានោះ បានបណ្តាលឱ្យរទេះទាំងអស់របស់ពាណិជនោះឈប់ ។ លំដាប់នោះ គេទាំងពីរមកពិចារណាមើលថា "នេះជាហេតុអ្វី ?" ទើបបានធ្វើពលីកម្មដល់ទេវតា ដែលជាម្ចាស់មកទាំងឡាយ ។

ក្នុងវេលាធ្វើពលីកម្មរបស់គេ ទេវតានោះសម្ដែងកាយឱ្យឃើញបានពោលពាក្យនេះ ។

ពីរបទថា មន្ថេន ច មធុបិណ្ឌិកាយ ច : សដូវផង់និងសដូវដុំ បានដល់ សដូវផង់ និងសដូវដុំ ផ្សំហើយដោយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករ អំពៅជាដើម ។

បទថា បដិមានេថ : ចូរបូជា បានដល់ ចូរទំនុកបម្រុង ។

ពីរបទថា តំ វោ : ការបូជានោះ ... ដល់អ្នកទាំងឡាយ មានសេចក្ដីថា សេចក្ដីទំនុកបម្រុងនោះ នឹងមានដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់លោកទាំងឡាយ រហូតអស់កាលយូរអង្វែង ។

ពីរបទថា យំ អម្ហាកំ : ការទទួលណា ... ដល់យើងខ្ញុំទាំងឡាយ មានសេចក្ដីថា ការទទួលយ៉ាងណានឹងគប្បីមាន ដើម្បីប្រយោជន៍ សេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់ពួកខ្ញុំព្រះអង្គរហូតអស់កាលយូរអង្វែង ។

ពីរបទថា ភគវតោ ឯតទហោសិ : ព្រះមានព្រះភាគទ្រង់ត្រិះរិះថា មានសេចក្ដីថា បានឮថា បាត្រណារបស់ព្រះអង្គ បានមានក្នុងវេលាទ្រង់ប្រកបសេចក្ដីព្យាយាម បាត្រនោះបានបាត់ទៅតាំងពីកាលនាងសុជាតាមកថ្វាយបាយបាយាស ។ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់បានមានព្រះ

រំពឹងនេះថា បាត្ររបស់តថាគតមិនមាន ក៏ឯព្រះតថាគតទាំងឡាយ អង្គមុន ៗ ទ្រង់មិនទទួលដោយព្រះហស្តឡើយ ។ តថាគតនឹងគប្បីទទួលសដូវផង់និងសដូវដុំផ្សំទឹកឃ្មុំដោយអ្វីហ្ន៎ ?

បទថា បរិវិតក្កមញ្ញាយ : ជ្រាបព្រះតម្រិះ មានសេចក្តីថា ក្រយាហារដែលនាងសុជាតា ថ្វាយចំពោះព្រះមានព្រះភាគក្នុងកាលមុននោះ តាំងនៅដោយអំណាចដែលផ្សំឱជៈទុក សេចក្តីស្រេក សេចក្តីឃ្លាន ភាពជាអ្នកមិនលំបាកកាយ អស់កាលប៉ុណ្ណោះ ក៏ឥឡូវនេះ ព្រះអង្គរំពឹងដោយន័យជាដើមថា ន ខោ តថាគតា : ធម្មតាព្រះតថាគតទាំងឡាយ មិនដែល... បានកើតឡើង ក៏ព្រោះព្រះអង្គ ប្រាថ្នានឹងទ្រង់ទទួលព្រះក្រយាហារ ។ ជ្រាបព្រះរំពឹងក្នុងព្រះហឫទ័យរបស់ព្រះមានព្រះភាគ ដែលកើតឡើងយ៉ាងនោះ ដោយចិត្តរបស់ខ្លួន ។

បទថា ចតុទ្ទិសា គឺ ចតូហិ ទិសាហិ : អំពីទិសទាំង ៤ ។

ពីរបទថា សេលមយេ បត្តេ : បាត្រថ្មកែវទាំងឡាយ បានដល់បាត្រដែលធ្វើដោយសិលាមានពណ៌ស្រដៀងសណ្តែកបាយ ។ ព្រះមានព្រះភាគទ្រង់ទទួលបាត្រនេះឯង ។ ពាក្យថា បាត្រដែលសម្រេចដោយសិលា លោកពោលសំដៅយកបាត្រទាំងនោះ ។ ក៏ស្តេចមហារាជទាំង

៤ បានបង្អោនថ្វាយបាត្រ ដែលសម្រេចដោយកែវឥន្ទនិល[១] ជាដំបូង ។ ព្រះមានព្រះភាគទ្រង់មិនទទួលបាត្រទាំងនោះ ក្រោយពីនោះ ទើបបង្អោនថ្វាយបាត្រដែលសម្រេចដោយសិលា មានពណ៌, ដូចសណ្តែកបាយទាំង ៤ បាត្រនេះ ។ ព្រះមានព្រះភាគទ្រង់បាន ទទួលបាត្រទាំង ៤ ដើម្បីរក្សាសេចក្តីជ្រះថ្លារបស់ស្តេចមហារាជទាំង ៤ នោះ មិនមែនព្រោះសេចក្តីប្រាថ្នាច្រើន ។ ក៏គ្រាទ្រង់ទទួលហើយ ទ្រង់បានអធិដ្ឋានបាត្រទាំង ៤ ឱ្យជាបាត្រតែមួយ ផលបុណ្យនៃស្តេចទាំង ៤ បានដូចគ្នា ព្រះមានព្រះភាគទ្រង់ទទួលសដូវផង់ និងសដូវដុំ លាយផ្សំទឹកឃ្មុំ ដោយបាត្រសិលាមានតម្លៃច្រើន ដែលទ្រង់អធិដ្ឋានឱ្យជាបាត្រតែមួយ ដោយប្រការដូច្នេះ ។

បទថា បច្ចគ្ឃេ គឺ មានតម្លៃច្រើន អធិប្បាយថា សូម្បីក្នុងបាត្រមួយ ក៏មានតម្លៃច្រើន ។

ម្យ៉ាងទៀត បទថា បច្ចគ្ឃេ បានដល់ ថ្មីថែស គឺ ទើបតែដុតរួចស្រេច សេចក្តីថា កើតក្នុងខណៈនោះ ។

---

១. មានពណ៌ខៀវចែងចាំងជាបកភស្សរះ ដូចពន្លឺស្លាបសត្វកំភេម ខាងក្នុងសម្រាប់សេយ្យសាស្ត្រ ឈ្មោះថា កែវមរកត ។

ពាណិជ្ជទាំងពីរនាក់នោះ គេឈ្មោះថា មានវាចាពីរ ព្រោះអត្ថវិគ្រោះថា បានជាអ្នកមានវាចាពីរ ។ ម្យ៉ាងទៀត សេចក្ដីថា ពាណិជពីរនាក់នោះ ដល់ភាពជាឧបាសកដោយវាចាពីរ ។ ពាណិជទាំងពីរនាក់នោះកាលប្រកាសភាពជាឧបាសកយ៉ាងនោះហើយ បានក្រាបទូល ព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន តាំងពីថ្ងៃនេះទៅ តើខ្ញុំព្រះអង្គគប្បីធ្វើការអភិវាទ និងឈរទទួលបុគ្គលណាហ្ន៎ ព្រះអង្គ ?" ព្រះមានព្រះភាគទ្រង់ស្ទាបព្រះសិរសា ។ ព្រះកេសាជាប់ព្រះហស្ត បានប្រទានព្រះកេសាទាំងនោះ ដល់អ្នកទាំងពីរ ដោយត្រាស់ថា "លោកចូររក្សាសក់ទាំងនេះទុក" ។ ពាណិជពីរនាក់នោះ បានព្រះកេសធាតុ ហាក់ដូចជាបានអភិសេកដោយអមតធម៌ រីករាយត្រេកអរ ថ្វាយបង្គំព្រះមានព្រះភាគហើយជៀសចេញទៅ ។

រាជាយតនកថា ចប់

# ពុទ្ធបរិវិតក្កកថា

[៧] គ្រានោះឯង លុះមកន្លងប្រាំពីរថ្ងៃទៅ ព្រះមានព្រះភាគទ្រង់ចេញចាកសមាធិនោះ សម្រេចកិច្ចទាំងពួង មានសេចក្ដីដូចពោលហើយនោះឯង ចេញពីគល់នៃដើមកែស ស្ដេចចូលទៅកាន់ដើមអជបាលនិគ្រោធទៀត ។

ពីរបទថា **បរិវិតក្កោ ឧទបាទិ :** ទើបទ្រង់ព្រះតម្រិះ មានសេចក្ដីថា សេចក្ដីរំពឹងនៃចិត្តនេះ ដែលព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ប្រព្រឹត្តតមកជាអាចិណ្ណ កើតឡើងចំពោះព្រះមានព្រះភាគ ដែលលុះទ្រង់គង់ប្រថាប់ក្រោមម្លប់គល់ដើមអជបាលនិគ្រោធនោះប៉ុណ្ណោះ ។

សួរថា ក៏ព្រោះហេតុអ្វី សេចក្ដីរំពឹងនៃចិត្តនេះ ទើបកើតឡើងដល់ព្រះពុទ្ធគ្រប់ព្រះអង្គ ?

ឆ្លើយថា ព្រោះទ្រង់ពិចារណានូវព្រះធម៌ជាគុណធំ ជាគុណលើសលប់ ជារបស់ធ្ងន់ និងព្រោះទ្រង់ប្រាថ្នានឹងសម្ដែងតាមពាក្យដែលព្រហ្មទូលសូមអារាធនា ។

ពិតមែន ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងជ្រាបថា កាលព្រះអង្គទ្រង់រំពឹងយ៉ាងនោះ ព្រហ្មនឹងមកទូលអារាធនាឱ្យសម្ដែងធម៌ គ្រានោះសត្វទាំងឡាយនឹងឱ្យកើតសេចក្ដីគោរពក្នុងធម៌ ព្រោះថា លោកសន្និវាស

គោរពព្រហ្ម ។ សេចក្តីរំពឹងនេះ កើតឡើង ព្រោះហេតុ ២ ប្រការនេះ ដោយប្រការដូច្នេះឯង ។

បណ្តាបទទាំងនោះ ប្រើនបទថា អធិគតោ ខោ ម្យាយំ កាត់បទថា អធិគតោ ខោ មេ អយំ : ដែលតថាគតបានត្រាស់ដឹងហើយ សេចក្តីថា ធម៌នេះ ដែលតថាគតសម្រេចហើយ ។

បទថា អាលយរាមា : រីករាយក្នុងសេចក្តីអាល័យ មានសេចក្តីថា សត្វទាំងឡាយ រមែងជាប់ជំពាក់ក្នុងកាមគុណ ៥ យ៉ាង ព្រោះហេតុនោះ កាមគុណទាំង ៥ នោះ លោកទើបហៅថា អាល័យ ពួកសត្វ រមែងរីករាយដោយកាមគុណ ជាទីជាប់ជំពាក់ទាំងនោះ ហេតុនោះ ទើបឈ្មោះថា អ្នករីករាយក្នុងសេចក្តីអាល័យ ។ ពួកសត្វត្រេកអរហើយ ក្នុងកាមគុណជាទីជាប់ជំពាក់ទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកត្រេកត្រអាលក្នុងសេចក្តីអាល័យ ។ ពួកសត្វសប្បាយរីករាយក្នុងកាមគុណជាទីជាប់ជំពាក់ទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកស្រើបស្រាលក្នុងសេចក្តីអាល័យ ។

បទថា យទិទំ ជានិបាត សេចក្តីនៃបទថា យទិទំ នោះ សំដៅយកឋានៈ គប្បីឃើញយ៉ាងនេះថា យំ ឥទំ : ណា នេះ សំដៅយកបដិច្ចសមុប្បាទ គប្បីឃើញយ៉ាងនេះថា យោ អយំ ។

បទថា ឥទប្បច្ចយតាបដិច្ចសមុប្បាទោ : បដិច្ចសមុប្បាទធម៌ គឺ ធម៌ជាបច្ច័យដល់គ្នានិងគ្នា មានអត្ថវិគ្រោះថា ធម៌ទាំងនេះ ជាបច្ច័យនៃធម៌ទាំងនេះ ឈ្មោះថា ឥទប្បច្ចយា, ឥទប្បច្ចយា នោះ ឈ្មោះថា ឥទប្បច្ចយតា ធម៌ទាំងនេះ ជាបច្ច័យនៃធម៌ទាំងនេះ, ជាធម៌អាស្រ័យគ្នាកើតឡើង ព្រោះដូច្នោះ ទើបឈ្មោះថា ធម៌ទាំងនេះ ជាបច្ច័យនៃធម៌ពួកនេះ ជាធម៌អាស្រ័យគ្នាកើតឡើង ។

ពាក្យថា សោ មមស្ស កិលមថោ : សេចក្តីលំបាកមុខជានឹងមានដល់តថាគតមិនខាន មានសេចក្តីថា ដែលឈ្មោះថា ទេសនាដល់ពួកជនដែលមិនដឹង គប្បីជាការនឿយហត់ដល់តថាគត គប្បីជាការលំបាកដល់តថាគត ។

បទថា ភគវន្តំ គឺ ភគវតោ : ព្រះមានព្រះភាគ ។

បទថា អនច្ឆរិយា : ជាហេតុអស្ចារ្យសមគួរ បានដល់ ជាភាពអស្ចារ្យខ្លាំងណាស់[១] ។

បទថា បដិភំសុ : ក៏កើតប្រាកដដល់ព្រះអង្គ មានសេចក្តីថា បានជាអារម្មណ៍នៃញាណ ពោលគឺ បដិភាណ គឺ ដល់ភាពជាគាថាដែល

១. ប្រែយកសេចក្តីតាមន័យដីកាសារត្ថទីបនី ភាគ ១ ដែលពន្យល់បានថា អនុអច្ឆរិយាតិ សវនកាលេ ឧបរូបរិ វិម្ហយករាតិ អត្ថោ ។

ព្រះអង្គគប្បីរំពឹង ។ ហ អក្សរ ក្នុងបទថា ហលំ នេះ ត្រឹមតែជានិបាត សេចក្ដីថា មិនគួរ ។

បទថា បកាសិតុំ : គួរសម្ដែង បានដល់ ដើម្បីសម្ដែង ។ មានពាក្យអធិប្បាយថា ឥឡូវនេះ មិនគួរសម្ដែងធម៌ដែលតថាគតសម្រេចបានដោយលំបាកនេះ ។

បាទគាថាថា ឆាយំ ធម្មោ សុសម្ពុទ្ធោ : មិនអាចនឹងត្រាស់ដឹងនូវធម៌នេះបានដោយងាយទេ មានសេចក្ដីថា ធម៌នេះធ្វើបានងាយ ៗ ដើម្បីនឹងត្រាស់ដឹងមិនបាន អធិប្បាយថា ការដែលនឹងដឹង មិនមែនធ្វើបានងាយ ៗទេ ។

បទថា បដិសោតគាមី : ធម៌ដែលនាំសត្វទៅ មានសេចក្ដីថា ឱ្យដល់និព្វានដែលលោកហៅថា ធម៌ដែលប្រាសក្រសែ ។

បទថា រាគរត្តា : កំពុងត្រេកអរដោយរាគៈ មានសេចក្ដីថា សត្វទាំងឡាយ អ្នកដែលកំពុងត្រេកអរហើយ ដោយកាមរាគៈ ភវរាគៈ និងទិដ្ឋិរាគៈ ។

បទថា ន ទក្ខន្តិ : មុខជានឹងមិនបានឃើញ បានដល់ រមែងមិនឃើញ ។

ពីរបទថា តមោក្ខន្ធេន អាវុដា : ដែលគំនរងងឹតកំពុងបិទបាំង មានសេចក្ដីថា អ្នកដែលកងនៃអវិជ្ជាគ្របដណ្ដប់ទុកហើយ ។

បទថា អប្បោស្សុក្កតាយ : មិនខ្វល់ទៅដើម្បីសម្ដែងធម៌ឡើយ មានសេចក្ដីថា ដើម្បីភាពជាអ្នកមិនប្រាថ្នានឹងសម្ដែង ព្រោះជាអ្នកប្រាសចាកសេចក្ដីខ្វល់ខ្វាយ ។

ពុទ្ធបរិវិតក្កកថា ចប់

## ព្រហ្មយាចនកថា

[៨] បទថា យត្រ ហិ នាម មានសេចក្ដីថា ឈ្មោះថា ក្នុងលោកនា (ដែលព្រះសម្មាសម្ពុទ្ធ មានព្រះទ័យខ្វល់ខ្វាយតិច មិនសម្ដែងធម៌(យ៉ាងនេះ) ឱ សត្វក្នុងលោកនោះវិនាសតើហ្ន៎ ) ។

បទថា ភគវតោ បុរតោ បាតុរហោសិ : ក៏បាត់ពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ មានសេចក្ដីថា ស្ដេចសហម្បតីព្រហ្ម បាននាំមហាព្រហ្មទាំងឡាយ ក្នុងម៉ឺនចក្រវាឡមកប្រាកដចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដើម្បីទូលអង្វរឱ្យទ្រង់សម្ដែងធម៌ ។

បទថា អប្បរជក្ខជាតិកា : ដែលមានធូលីស្រាលស្ដើងក្នុងភ្នែក មានអត្ថវិគ្រោះថា ធូលី គឺ រាគៈ ទោសៈ មោហៈ តិច ក្នុងចក្ខុដែលធ្វើដោយបញ្ញា ជាប្រក្រតីនៃខ្លួនរបស់សត្វទាំងនេះ ហេតុនោះ សត្វ

ទាំងនេះ ឈ្មោះថា អ្នកមានជាតិនៃសត្វមានធូលីតិចក្នុងចក្ខុ ។

បទថា គមិស្សន្តិ ធម្មស្ស : ធម៌ ក៏គង់មាន បានដល់ ធម៌គឺសច្ចៈ ៤ ។

បទថា អញ្ញាតារោ : បម្រុងនឹងត្រាស់ដឹង បានដល់ អ្នកត្រាស់ដឹង ។

បទថា ធាតុរហោសិ : កើតប្រាកដហើយ បានដល់ មានប្រាកដ ។

ពីរបទថា សមលេហិ ចិន្តិតោ : អ្នកប្រកបដោយមន្ទិល តែងគិត មានសេចក្តីថា ដែលគ្រូទាំង៦ ជាអ្នកមានមន្ទិល មានរាគៈជាដើមគិតហើយ ។

បទថា អបាបុរេតំ : សូមព្រះអង្គបើក មានសេចក្តីថា សូមបើកទ្វារនោះ ។

ពីរបទថា អមតស្ស ទ្វារំ : ទ្វារនៃព្រះនិព្វាននុ៎ះ មានសេចក្តីថា អរិយមគ្គជាទ្វារ នៃនិព្វានដែលជាធម៌មិនស្លាប់ ។

បាទព្រះគាថាថា សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ : សត្វទាំងឡាយ ចូរប្រុងស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹងតាម( លំអានព្រះពុទ្ធពីបុរាណ ) មានសេចក្តីថា សត្វទាំងនេះ ចូរ

ស្តាប់ធម៌គឺ សច្ចៈ ៤ ដែលព្រះសម្ពុទ្ធទ្រង់ប្រាសចាកមន្ទិល ព្រោះមិនមានមន្ទិល មានរាគៈជាដើម ត្រាស់ដឹងសមគួរហើយ ។

បាទព្រះគាថាថា សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ : ដូចបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ពេញហើយដោយថ្មសុទ្ធ មានសេចក្តីថា ដូចឧបមាថា បុរសអ្នកមានកែវភ្នែកនោះ ឈរលើកំពូលភ្នំថ្មសុទ្ធជាជួរជាមួយគ្នា នឹងគប្បីឃើញប្រជុំជនបានជុំវិញទាំងអស់ យ៉ាងណា ។ បពិត្រព្រះមានព្រះភាគទ្រង់មានប្រាជ្ញាល្អ គឺ ទ្រង់មានបញ្ញាល្អ ទ្រង់មានព្រះចក្ខុជុំវិញ ប្រកបដោយព្រះសព្វញ្ញុតញ្ញាណ សូម្បីព្រះអង្គស្តេចឡើងកាន់ប្រាសាទ ដែលសម្រេចហើយដោយធម៌ គឺ សម្រេចដោយបញ្ញាព្រះអង្គឯង ប្រាសចាកសេចក្តីសោកហើយ សូមទ្រង់ក្រលេកមើល គឺ ទ្រង់ពិចារណាប្រជុំជន ដែលចង្អៀតចង្អល់ដោយសេចក្តីសោក ត្រូវសេចក្តីកើតនិងសេចក្តីចាស់គ្របសង្កត់ហើយ ដូច្នោះចុះ ។ ស្តេចសហម្បតីព្រហ្ម កាលនឹងទ្រង់អង្វរឱ្យព្រះមានព្រះភាគ ស្តេចចារិកទៅដើម្បីទ្រង់សម្តែងធម៌ ទើបទូលថា "សូមព្រះអង្គក្រោកឡើង" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា វីរៈជាដើម ដូច្នេះ ព្រះមានព្រះភាគមានព្រះនាមថា វីរៈ ព្រោះទ្រង់មានសេចក្តីព្យាយាម ទ្រង់ព្រះនាមថា វិជិតសង្គ្រាម ព្រោះទ្រង់ឈ្នះទេវបុត្តមារ មច្ចុមារ កិលេសមារ និងអភិសង្ខារមារ ទ្រង់ព្រះនាមថា សត្ថវាហៈ ព្រោះទ្រង់អាចជួយពួកសត្វ

ឱ្យផុតពីកន្ទារ មានជាតិកន្ទារជាដើម ទ្រង់ព្រះនាមថា អ្នកមិនមានបំណុល ព្រោះមិនមានបំណុល គឺកាមឆន្ទៈ ។

[៩] បទថា អជ្ឈេសនំ : សេចក្តីអារាធនា បានដល់ ពាក្យអង្វរ ។

បទថា ពុទ្ធចក្ខុនា : ដោយពុទ្ធចក្ខុ គឺ ដោយឥន្ទ្រិយបរោបរិយត្តិញាណ និងអាសយានុសយញាណ ។ ពិតមែន ពាក្យថា ពុទ្ធចក្ខុ ជាឈ្មោះនៃព្រះញាណ ២ យ៉ាងនេះ ។

បទថា អប្បរជក្ខេ : មានធូលីតិចក្នុងភ្នែក ជាដើម មានសេចក្តីថា ធូលីមានរាគៈជាដើម ក្នុងបញ្ញាចក្ខុរបស់សត្វពួកណាមានតិច សត្វពួកនោះ ឈ្មោះថា មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក, របស់សត្វពួកណា មានច្រើន សត្វពួកនោះ ឈ្មោះថា **មានធូលី គឺ រាគាទិក្កិលេសច្រើនក្នុងភ្នែក** ។

ឥន្ទ្រិយមានសទ្ធាជាដើម របស់សត្វពួកណាខ្លាំងក្លា សត្វពួកនោះ ឈ្មោះថា **អ្នកមានឥន្ទ្រិយរឹង** (ចាស់ក្លា), របស់សត្វពួកណាខ្សោយ សត្វពួកនោះ ឈ្មោះថា **អ្នកមានឥន្ទ្រិយទន់** ។

អាការមានសទ្ធាជាដើម របស់សត្វពួកណាល្អ សត្វពួកនោះ ឈ្មោះថា **អ្នកមានអាការល្អ**, របស់សត្វពួកណាមិនល្អ សត្វពួកនោះ ឈ្មោះថា **អ្នកមានអាការអាក្រក់** ។

សត្វពួកណា កំណត់ហេតុដែលលោកពោលបាន គឺ ជាអ្នកដែលអាចនឹងឱ្យដឹង បានដោយងាយ សត្វពួកនោះ ឈ្មោះថា ជាសត្វដែលព្រះអង្គគួរឱ្យត្រាស់ដឹងបានដោយងាយ ។ សត្វពួកណា មិនជាយ៉ាងនោះ សត្វពួកនោះ ឈ្មោះថា ជាសត្វដែលឱ្យត្រាស់ដឹងបានដោយកម្រ ។

សត្វពួកណាឃើញបរលោក និងទោសដោយភាពជាភ័យ សត្វពួកនោះ ឈ្មោះថា ជាអ្នកឃើញបរលោក និងទោសដោយភាពគួរខ្លាច ។

បទថា ឧប្បលិនិយំ : ផ្កាព្រលិត បានដល់ ផ្កាក្នុងគុម្ពព្រលិត ។ សូម្បីក្នុងបទក្រៅពីនេះ ក៏ន័យនេះដូចគ្នា ។

បទថា អន្តោនិមុគ្គបោសីនិ : លិចនៅក្នុងទឹកនៅឡើយ បានដល់ ផ្កាឈូកដែលនៅលិចនៅខាងក្នុងទឹក ដែលទឹកចិញ្ចឹមទុក ។

បទថា សមោទកដ្ឋិតានិ : ឋិតនៅត្រឹមស្មើនឹងទឹក បានដល់ ផ្កាឈូកដែលតាំងនៅស្មើនឹងទឹក ។

ច្រើនបទថា ឧទកាំ អច្ចុគ្គម្ម តិដ្ឋន្តិ : ដុះខ្ពស់ឡើងជាងទឹក បានដល់ តាំងនៅផុតពីទឹក ។

បទថា អបារុតា : បើកហើយ បានដល់ របើកហើយ, ចំហហើយ ។

ពីរបទថា អមតស្ស ទ្វារា : ទ្វារនៃព្រះនិព្វាន បានដល់ អរិយមគ្គ ។ ពិតមែន អរិយមគ្គនោះ ជាទ្វារនៃព្រះនិព្វាន ពោលគឺអមតធម៌ ។

ពីរបទថា បមុញ្ចន្តុ សទ្ធំ : សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាចុះ មានសេចក្ដីថា ជនទាំងពួងចូរបញ្ចេញ គឺចូរបើកនូវសទ្ធារបស់ខ្លួនចុះ ។ ក្នុងពីរបទខាងចុង មានសេចក្ដីដូច្នេះឯង, ព្រោះថា តថាគតជាអ្នកមានសេចក្ដីសម្គាល់ថា នឹងត្រូវលំបាកកាយវាចា ទើបមិនបានសម្ដែងធម៌ដ៏ប្រណីត ឧត្ដមនេះ សូម្បីដែលប្រព្រឹត្តទៅយ៉ាងស្ទាត់ជំនាញល្អ សម្រាប់ខ្លួន ក្នុងពួកមនុស្ស គឺ ក្នុងទេវតា និងមនុស្សទាំងឡាយ ។

ព្រហ្មយាចនកថា ចប់

## អាឡារឧទកតាបសកថា

[១០] បទថា បណ្ឌិតោ : ជាបណ្ឌិត បានដល់ អ្នកប្រកបដោយគុណដែលជាបណ្ឌិត ។

បទថា ព្យត្តោ : ជាអ្នកឆ្លៀវឆ្លាស បានដល់ អ្នកប្រកបដោយគុណដែលជាអ្នកឆ្លាត ។

បទថា មេធាវី : វាងវៃជាអ្នកមានបញ្ញា បានដល់ អ្នកប្រកបដោយបញ្ញាដែលកើតឡើងឆាប់រហ័ស[១] ។

បទថា អប្បរជក្ខជាតិកោ : មានធូលីតិចក្នុងភ្នែក មានសេចក្តីថា ជាអ្នកមានជាតិនៃអ្នកមិនមានកិលេស គឺ ជាអ្នកបរិសុទ្ធិ ព្រោះគ្របសង្កត់កិលេសទុកដោយសមាបត្តិ ។

បទថា អាជានិស្សតិ : នឹងត្រាស់ដឹងធម៌នេះ បានដល់ នឹងកំណត់បាន គឺ នឹងចាក់ធ្លុះ ។

ប្រើនបទថា ភគវតោបិ ខោ ញាណំ ឧទបាទិ : ព្រះមានព្រះភាគក៏ទ្រង់ជ្រាប មានសេចក្តីថា ព្រះសព្វញ្ញុតញ្ញាណបានកើតឡើងថា អាឡារតាបសកាលាមគោត្រនោះ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងអាកិញ្ចញ្ញាយតនភព ក្នុងវេលា ៧ ថ្ងៃ តាំងពីថ្ងៃនេះទៅ ។

បទថា មហាជានិយោ : មានសេចក្តីសាបសូន្យធំ មានអត្ថវិគ្រោះថា សេចក្តីសាបសូន្យធំ ឈ្មោះថា មានដល់លោក ព្រោះជាអ្នក

---

១. ហានសព្ទចុះក្នុងអត្ថថា ខណៈ គឺឆាប់រហ័ស ភ្លាម ៗ ដូចពាក្យថា ហានសោ ឧបកប្បតិ : ទើបសម្រេចផលដោយរួសរាន់, ក្នុងតិកេកុឌ្ឍកណ្ឌ ។ មួយទៀត ពាក្យនេះ ក៏មានពាក្យខែទុក ក្នុងការពន្យល់អត្ថនៃបទថា វិមំសាយ : ដោយបញ្ញាពិចារណា, ទំព័រ ១៣២ ខាងមុខ ។

សាបសូន្យចាកមគ្គផល ដែលនឹងត្រូវសម្រេច ក្នុងខាងក្នុង៧ ថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកមានសេចក្តីសាបសូន្យធំ ។ មួយទៀតឈ្មោះថា អ្នកមានសេចក្តីសាបសូន្យធំ ព្រោះកើតក្នុងអក្ខណៈ[1] ។

បទថា អភិទោសកាលកតោ : **ធ្វើកាលកិរិយា ស្លាប់អំពីពេលព្រលប់ទៅហើយដែរ** មានសេចក្តីថា បានធ្វើកាលកិរិយាទៅ ក្នុងថ្ងៃម្សិលមិញ ។ ព្រះមានព្រះភាគទ្រង់បានឃើញថា សូម្បីឧទកតាបសនោះក៏កើតហើយក្នុងនេវសញ្ញានាសញ្ញាយតនភព ។

បទថា ពហូបការា[2] : **មានឧបការៈច្រើន** គឺ ជាអ្នកមានឧបការៈច្រើន ។

បទថា បធានបហិតត្តំ : **កំពុងបញ្ជូនចិត្តទៅក្នុងព្យាយាម** មានសេចក្តីថា អ្នកព្រមតម្កល់ខ្លួនដើម្បីប្រយោជន៍ដល់សេចក្តីព្យាយាម ។

បទថា ឧបដ្ឋហឹសុ : **បានបម្រើ** មានសេចក្តីថា បានបម្រុងដោយវត្តមានឱ្យទឹកខ្ទរមាត់ជាដើម ។

អាឡារឧទកតាបសកថា ចប់

---

១. សម័យមិនមែនកាលមានព្រះពុទ្ធ ។ ២. ពហូការាតិ ពហូបការា ។

# រឿងឧបកាជីវក

[១១] ច្រើនបទថា អន្តរា ច គយំ អន្តរា ច ពោធឹ : ក្នុងចន្លោះគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង មានសេចក្តីថា អាជីវកឈ្មោះ ឧបកៈ បានជួបព្រះមានព្រះភាគក្នុងចន្លោះពោធិមណ្ឌលនិងគយាប្រទេស ។

បទថា អទ្ធានមគ្គប្បដិបន្នំ មានសេចក្តីថា អទ្ធានមគ្គំ បដិបន្នំ ប្រែថា ស្តេចយាងទៅកាន់មកឆ្ងាយ ។

បទថា សព្វាភិភូ : ភូមិកធម៌ទាំងអស់ មានសេចក្តីថា តថាគតគ្របសង្កត់ត្រៃភូមិកធម៌ទាំងពួង ។

បទថា សព្វវិទូ : ត្រាស់ដឹងធម៌ទាំងអស់ មានសេចក្តីថា បានដឹង គឺ បានយល់ ធម៌ដែលមានភូមិ ៤ ទាំងអស់ ។

បាទព្រះគាថាថា សព្វេសុ ធម្មេសុ អនូបលិត្តោ : មិនប្រឡាក់ដោយកិលេសក្នុងធម៌ទាំងអស់ សេចក្តីថា ដែលគ្រឿងប្រឡាក់ គឺ កិលេស មិនបានប្រឡាក់ ក្នុងត្រៃភូមិកធម៌ទាំងពួង ។

បទថា សព្វញ្ជហោ : បានលះចោលទាំងអស់ សេចក្តីថា កាត់

ផ្ដាច់ត្រៃភូមិកធម៌ទាំងពួងបាន ។

បទថា តណ្ហក្ខយេ វិមុត្តោ : ផុតស្រឡះ ព្រោះអស់តណ្ហា សេចក្ដីថា ជាអ្នកផុតវិសេស ព្រោះធម៌ជាទីអស់តណ្ហាគឺនិព្វាន ដោយការធ្វើឱ្យជាអារម្មណ៍ ។

បទថា សយំ អភិញ្ញាយ : ដឹងច្បាស់ដោយខ្លួនឯង បានដល់តថាគតដឹងធម៌មាន ៤ ភូមិទាំងអស់ដោយខ្លួនឯង ។

បទថា កមុទ្ទិសេយ្យំ : ចំពោះបុគ្គលណា សេចក្ដីថា នឹងគប្បីអាងដល់អ្នកណា គឺ អ្នកដទៃថា អ្នកនេះជាអាចារ្យរបស់តថាគតហ្ន៎ ។

ប្រើនបទថា ន មេ អាចរិយោ អត្ថិ : តថាគតមិនមានអាចារ្យ មានសេចក្ដីថា ដែលឈ្មោះថា អាចារ្យក្នុងលោកុត្តរធម៌របស់តថាគតរមែងមិនមាន ។

ប្រើនបទថា នត្ថិ មេ បដិបុគ្គលោ : មិនមានបុគ្គលណាប្រៀបផ្ទឹមនឹងតថាគតបានឡើយ មានសេចក្ដីថា ដែលឈ្មោះថា បុគ្គលដែលប្រៀបស្មើនឹងតថាគត មិនមាន ។

បទថា សីតិភូតោ : មានសេចក្ដីត្រជាក់ មានសេចក្ដីថា ចាត់ថាជាអ្នកមានសេចក្ដីត្រជាក់ចិត្ត ព្រោះរំលត់ភ្លើង គឺ កិលេសចេញទាំង

អស់ ។

បទថា និព្វុតោ : រលត់ហើយ មានសេចក្ដីថា ចាត់ថា ជាអ្នករលត់ហើយ ព្រោះកិលេសទាំងឡាយទុំះឯង រលត់ទៅ ។

ពីរបទថា កាសីនំ បុរំ : ក្រុងនៃពួកជនអ្នកកាសី បានដល់ក្រុងក្នុងដែនកាសី ។

បាទគាថាថា អហញ្ញី អមតទុន្ទុភឹ : តថាគតនឹងទូងស្គរ គឺអមតនិព្វាន សេចក្ដីថា តថាគតនឹងទៅដោយគិតថា នឹងវាយស្គរគឺអមតៈ ដើម្បីបានចក្រ គឺធម៌ ។

ពីរបទថា អរហាសិ អនន្តជិនោ : អ្នកថា អនន្តជិន មានសេចក្ដីថា ព្រះអង្គសមគួរជាអ្នកឈ្នះ មិនមានទីបំផុត ។

បទថា ហុវេយ្យាវុសោ : អាវុសោ ពាក្យយ៉ាងហ្នឹង មានសេចក្ដីថា អ្នកមានអាយុ គប្បីជាអ្នកបានសម្រេចដល់ភាពយ៉ាងនោះឯង[១] ។

ពីរបទថា សីសំ ឱកម្បេត្វា : ក៏ផងក់ក្បាល បានដល់កម្រើកក្បាល ។

---

១. បឋមសម្ពោធិថា ម្នាលអាវុសោ នាមថា អនន្តជិនោ គប្បីជានាមបាន ។

# រឿងបញ្ចវគ្គិយភិក្ខុ

[១២] បទថា សណ្ហបេសុំ : ធ្វើប្ដេជ្ញាគ្នា គឺ បានធ្វើកតិកា ។

បទថា ពាហុល្លិកោ : ប្រតិបត្តិដើម្បីល្មោភ បានដល់ អ្នកបដិបត្តិដើម្បីប្រយោជន៍ដល់ភាពជាអ្នកមានចីវរច្រើនជាដើម ។

បទថា បធានវិព្ភន្តោ : ឃ្លាតចាកព្យាយាមហើយ បានដល់ ជាអ្នករលាយសូន្យហើយ គឺ ធ្លាក់ចុះទៅហើយ សាបសូន្យទៅហើយ អំពីសេចក្ដីព្យាយាម ។

ពីរបទថា អាវត្តោ ពាហុល្លាយ : វិលត្រឡប់ដើម្បីភាវៈល្មោភ បានដល់ អ្នកវិលមកដើម្បីជាអ្នកប្រាថ្នាច្រើនដោយបច្ច័យ មានចីវរជាដើម ។

ច្រើនបទថា ឱទហថ ភិក្ខវេ សោតំ : អ្នកទាំងឡាយ ចូរប្រុងសោតប្បសាទចុះ មានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរផ្ទៀងសោតៈ គឺ ចូរធ្វើសោតិន្ទ្រិយឱ្យបែរមុខ ដើម្បីស្ដាប់ធម៌ ។

ពីរបទថា អមតមធិគតំ : អមតធម៌ដែលតថាគតត្រាស់ដឹងហើយ ព្រះមានព្រះភាគទ្រង់សម្ដែងថា ព្រះនិព្វានជាធម៌មិនស្លាប់

តថាគតបានសម្រេចហើយ ។

បទថា ឥរិយាយ[1] : ឥរិយាបថទាំង ៤ គឺ ដោយការប្រព្រឹត្ត ដែលធ្វើបានដោយលំបាក ។

បទថា បដិបទាយ : ការប្រតិបត្តិ បានដល់ ដោយការបដិបត្តិ ដែលធ្វើបានលំបាក ។

ច្រើនបទថា អភិជានាថ មេ នោ : អ្នកទាំងឡាយ ចូរពិចារណាមើល នូវពាក្យរបស់តថាគត មានសេចក្តីថា អ្នកទាំងឡាយចាំបាន គឺ សម្លឹងឃើញឬ (នូវភាសិតបែបនេះ)របស់យើង ។

បទថា ឯវរូបំ ភាសិតមេតំ បានដល់ ការបើកបង្ហាញពោល បែបនេះ ។

ពាក្យថា អសក្ខិ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ សញ្ញាបេតុំ : ព្រះមានព្រះភាគបានអាចញ៉ាំងបញ្ចវគ្គិយភិក្ខុទាំងឡាយឱ្យយល់ច្បាស់ (ក្នុងពេលនោះ) មានសេចក្តីថា ព្រះមានព្រះភាគ ទ្រង់អាចឱ្យភិក្ខុ បញ្ចវគ្គិយជ្រាបថា ព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ ។

---

១. បិដក. ចរិយាយ ។

# ធម្មចក្កប្បវត្តនសូត្រ

[១៣] បទថា ចក្ខុករណី : ធ្វើឱ្យកើតចក្ខុ ព្រះមានព្រះភាគ ត្រាស់សំដៅយកភ្នែក គឺ បញ្ញា ។ តពីនេះទៅគ្រប់បទ ពោលសេចក្ដី ដោយចំពោះបទហើយ ជាពាក្យងាយយល់ទាំងអស់ ពោលដោយការ ផ្សេងនៃអធិប្បាយអនុសន្ធិ និងពាក្យប្រកបគប្បីជ្រាបតាមន័យ ដែល ពោលហើយក្នុងអដ្ឋកថា នៃមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនីចុះ ។ តាំងពីនេះទៅ កាលខ្ញុំព្រះករុណារក្សាទឹកចិត្តរបស់មហាជន ដែលសង្វាត ចំពោះសេចក្ដីពិស្ដារ មិនចាំបាច់ពណ៌នា សុត្តន្តកថា នឹងពណ៌នាតែ វិន័យកថាប៉ុណ្ណោះ ។

[១៨] ពាក្យថា សាវ តស្ស អាយស្មតោ ឧបសម្បទា អហោសិ : ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់អញ្ញាកោណ្ឌញ្ញដ៏មានអាយុនោះ មានសេចក្ដីថា ក្នុងថ្ងៃពេញបូណ៌មីខែអាសាឡ្ហ កាល ព្រះកោណ្ឌញ្ញៈដ៏មានអាយុ និងទេវតាដប់ប្រាំបីកោដិ តាំងនៅក្នុង សោតាបត្តិផលហើយ ព្រះវាចានេះឯង ដែលសម្រេចដោយព្រះពុទ្ធវចនៈ របស់ព្រះមានព្រះភាគថា "អ្នកចូរមកជាភិក្ខុចុះ" ដូច្នេះ បានជាឯហិភិក្ខុ ឧបសម្បទារបស់ព្រះកោណ្ឌញ្ញៈដ៏មានអាយុនោះ ។

[១៩] ក្នុងពាក្យថា អថ ខោ អាយស្មតោ ច វប្បស្ស : លំដាប់នោះឯង ... ដល់វប្បភិក្ខុដ៏មានអាយុផង ជាដើម មានវិនិច្ឆ័យថា

ក្នុងថ្ងៃ ១ កេច ភ្នែកឃើញធម៌បានកើតឡើងដល់ព្រះវប្បត្ថេរៈ ក្នុងថ្ងៃ ២ កេច បានកើតឡើងដល់ព្រះភទ្ទិយត្ថេរ ក្នុងថ្ងៃ ៣ កេច បានកើតដល់ព្រះមហានាមត្ថេរ ក្នុងថ្ងៃ ៤ កេច បានកើតឡើងដល់ព្រះអស្សជិត្ថេរ ។ ក៏ដើម្បីជម្រះមន្ទិលដែលកើតឡើង ក្នុងកម្មដ្ឋានរបស់ភិក្ខុទាំងនេះ ព្រះមានព្រះភាគទ្រង់បាននៅខាងក្នុងវិហារប៉ុណ្ណោះ ។ កាលមន្ទិលនៃកម្មដ្ឋានកើតឡើងទីណា ក៏បានស្តេចចុះមកមកអាកាសហើយទ្រង់ជម្រះចេញ ។

## អនត្តលក្ខណសូត្រ

[២០] ក្នុងថ្ងៃ ៥ កេច នៃបក្ខទ្រង់ឱ្យភិក្ខុទាំងអស់ប្រជុំគ្នាហើយត្រាស់ទូន្មានដោយអនត្តសូត្រ[១] ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គហកាចារ្យពោលពាក្យថា អថខោ ភគវា បញ្ចវគ្គិយេ : គ្រានោះព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយ ជាដើម ។

[២៤] ពាក្យថា តេន ខោ បន សមយេន ឆ លោកេ អរហន្តោ ហោន្តិ : ក្នុងសម័យនោះឯង មានព្រះអរហន្ត ៦ អង្គក្នុងលោកជាដំបូង (រួមទាំងព្រះពុទ្ធផង) មានសេចក្តីថា ក្នុងថ្ងៃ ៥ កេច មនុស្ស ៦ នាក់ ជាព្រះអរហន្តក្នុងលោក ។

រឿងបញ្ចវគ្គិយភិក្ខុ ចប់

១. សំយុ. ខន្ធ. ឧបាយវគ្គ. ៣៣. ១២៧/១៥៥ ។

# រឿងយសកុលបុត្រ

[៣១] បទថា បុព្វានុបុព្វកានំ : មានបុព្វបុរសជាលំដាប់នៃបុព្វបុរស មានសេចក្តីថា ចាស់ជាលំដាប់ដោយអំណាចតំណតវង្សគ្នាមក ។

ពាក្យថា តេន ខោ បន សមយេន ឯកសដ្ឋី លោកេ អរហន្តោ ហោន្តិ : មានព្រះអរហន្តទាំងឡាយ ៦១ អង្គ កើតឡើងក្នុងលោក ក្នុងកាលនោះឯង មានសេចក្តីថា ខាងក្នុងវស្សាប៉ុណ្ណោះ មានមនុស្សជាព្រះអរហន្ត ៦១ អង្គ គឺ ពួកមុន ៦ អង្គ និងពួកនេះ ៥៥ អង្គទៀត ។ បណ្តាមនុស្សទាំងនោះ យសកុល បុត្រជាដើម មានបុព្វប្រយោគដូចតទៅនេះ ៖

បានឮមកថា ក្នុងអតីតកាល សម្លាញ់ ៥៥ នាក់ នឹងធ្វើបុណ្យរួមគ្នាជាពួក ទើបដើរជួយគ្នាចាត់ចែងសាកសពមនុស្សអនាថាទាំងឡាយ ។ ថ្ងៃមួយពួកគេជួបស្រីមានគភ៌ធ្វើកាលកិរិយាគិតថា នឹងដុតទើបនាំទៅកាន់ព្រៃជាទីចោលសាកសព ។ ក្នុងពួកជនទាំងនោះ រៀរជនប្រាំនាក់ទុកត្រង់ព្រៃជាទីចោលសាកសព បន្ទាប់ថា ចូរជួយគ្នាដុត ជនដ៏សេសនាំគ្នាចូលស្រុក ។ យសអ្នកមានវ័យក្មេង ចាក់ប្រែត្រឡប់សាកសពនោះឱ្យឆេះ ក៏បាន អសុភសញ្ញា ។ យសបានបង្ហាញដល់សំឡាញ់

៤ នាក់ថា អ្នកដ៏ចម្រើនចូរមើលរបស់មិនស្អាត គួរខ្ពើមនេះ ។ ជន ៤ នាក់ទៀត ក៏បានអសុភសញ្ញាក្នុងសាកសពនោះផង ។ ជនទាំង ៥ នាក់ នាំគ្នាទៅស្រុកហើយប្រាប់ដល់សម្លាញ់ដ៏សេស ។ ចំណែកយសដែល នៅវ័យក្មេង ទៅផ្ទះហើយបានប្រាប់ដល់មាតា បិតា និងភរិយា ។ ជន ទាំងអស់នោះ បានចម្រើនអសុភសញ្ញាផងដែរ ។ បុព្វប្រយោគរបស់ ជនទាំងនេះប៉ុណ្ណេះ ។ ព្រោះហេតុនោះ សេចក្តីសម្គាល់ក្នុងពួកជនរបាំថា ជាព្រៃខ្មោចទុំះឯង ទើបបានកើតឡើង ដល់ព្រះយសដ៏មានអាយុ ។ និង ដោយឧបនិស្ស័យ សម្បត្តិនោះ ការសម្រេចធម៌ពិសេស បានកើតដល់ សំឡាញ់គ្រប់ ៗគ្នាដែរ ។

[៣២] ពាក្យថា អជ្ឈោ ភគវា ភិក្ខូ អាមន្តេសិ **:** **គ្រានោះ ឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ** មានសេចក្តីថា ព្រះមានព្រះភាគស្តេចនៅក្នុងក្រុងពារាណសី ដរាបដល់ថ្ងៃ ពេញបូណ៌មី ខែកត្តិក, ក្នុងថ្ងៃមួយត្រាស់ហៅភិក្ខុ ៦០ រូប ដែលជាព្រះខីណាស្រព ទាំងនោះ ។

អន្ទាក់ គឺ សេចក្តីលោភក្នុងអារម្មណ៍ទាំងឡាយ ដែលជាទិព្វ ចាត់ជារបស់ទិព្វ ។ អន្ទាក់ គឺ សេចក្តីលោភ ក្នុងអារម្មណ៍ទាំងឡាយ ដែលជារបស់មនុស្ស ចាត់ជារបស់មនុស្ស ។

ច្រើនបទថា មា ឯកេន ទ្វេ : កុំទៅពីរនាក់តាមមកមួយជាមួយគ្នាឡើយ មានសេចក្ដីថា អ្នកទាំងឡាយ កុំទៅរួមគ្នា ២ រូបដោយមកជាមួយគ្នា ។

បទថា អស្សវនតា : មិនបានស្ដាប់ មានសេចក្ដីថា ព្រោះហេតុដែលមិនបានស្ដាប់ ។

បទថា បរិហាយន្តិ : ដាច់សូន្យ មានសេចក្ដីថា កាលមិនបានសម្រេចធម៌ពិសេស ដែលមិនទាន់បានសម្រេច ឈ្មោះថា រមែងសាបសូន្យចាកពីសេចក្ដីសម្រេចធម៌ពិសេស ។

យសវត្ថុកថា ចប់

## បឋមមារកថា

[៣៣] បទថា អន្តក : ពុតកំណាច បានដល់ ម្នាលមារដ៏អាក្រក់ថោកទាប គឺ ជាសត្វទាបថោក ។

ព្រះមានព្រះភាគទ្រង់សំដៅយកអន្ទាក់ គឺ រាគៈ ត្រាស់ថា ត្រាច់ទៅក្នុងអាកាស ។ ពិតមែន ព្រះអង្គទ្រង់ជ្រាបអន្ទាក់ គឺ រាគៈនោះទើបត្រាស់ថា ត្រាច់ទៅក្នុងអាកាស ។

បឋមមារកថា ចប់

# បព្វជ្ជានិងឧបសម្បទា

[៣៤] ពីរបទថា នានាទិសា នានាជនបទា : អំពីទិសផ្សេង ៗ អំពីជនបទផ្សេង ៗ មានសេចក្ដីថា អំពីទិសផ្សេង ៗផង អំពីជនបទផ្សេង ៗផង[១] ។

ពាក្យថា អនុជានាមិ ភិក្ខវេ តុម្ហេវទានិ តាសុ តាសុ ទិសាសុតេសុ តេសុ ជនបទេសុ បព្វាជេថាតិ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថា អ្នកទាំងឡាយចូរឱ្យបព្វជ្ជាឱ្យឧបសម្បទា (ដល់កុលបុត្រ)ក្នុងទិសនោះ ៗ ក្នុងជនបទនោះ ៗ ក្នុងកាលឥឡូវនេះចុះ ជាដើម មានវិនិច្ឆ័យថា កាលនឹងឱ្យកុលបុត្រដែលសម្លឹងបព្វជ្ជាបួស គប្បីវៀរបុគ្គលដែលទ្រង់ហាមទុក ចាប់ផ្ដើមថា "ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយ មិនគប្បីបំបួសឡើយ"[២] ដូច្នេះ ដរាបដល់យ៉ាងនេះថា មនុស្ស ទាំងខ្វាក់ទាំងគរទាំងថ្លង់ដែលលោកទាំងឡាយ មិនគួរបំបួស ដូច្នេះ ខាងមុខ គប្បីបំបួសបុគ្គលវៀរចាកបព្វជ្ជាទោស ។ បុគ្គលសូម្បីនោះដែលមាតាបិតាអនុញ្ញាតហើយទាំងអស់នោះ ។ លក្ខណៈនៃការអនុញ្ញាតនូវបុគ្គលដែលសមគួរ

---

១. ពាក្យថា ជនបទ សំដៅយកប្រទេស ។ ២. វិន. មហា. មហាខន្ធកៈ. ៦. ១០១/២៤៣ ។

នោះ ខ្ញុំព្រះករុណានឹងពណ៌នាក្នុងសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ បុត្រដែលមាតានិងបិតាមិនបានអនុញ្ញាត ភិក្ខុមិនគប្បីបំបួសឡើយ ភិក្ខុណាបំបួស ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ"[១] ។ ក៏ឯកាលទឹងបំបួសកុលបុត្រដែលវៀរចាកបព្វជ្ជាទោស ដែលមាតាបិតាអនុញ្ញាតហើយយ៉ាងនោះ ប្រសិនបើកុលបុត្រនោះ មិនទាន់បានកោរសក់ ។ សូម្បីពួកភិក្ខុដទៃដែលមាននៅក្នុងសីមាជាមួយគ្នា ។ គប្បីប្រាប់ភណ្ឌុកម្ម[២] ដើម្បីប្រយោជន៍ ដល់ការកោរសក់ អាការប្រាប់ភណ្ឌុកម្មនោះ ខ្ញុំព្រះករុណានឹងពណ៌នាក្នុងសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអបលោក (ប្រាប់) សង្ឃហើយ សឹមធ្វើភណ្ឌុកម្ម"[៣] ។ បើមានឱកាស គប្បីបំបួសដោយខ្លួនឯង ។ បើត្រូវខ្វល់ខ្វាយដោយកិច្ចការមានឧទ្ទេស និងបរិបុច្ឆាជាដើម មិនបានឱកាស គប្បីបង្គាប់ភិក្ខុកំលោះមួយរូបថា លោកចូរឱ្យកុលបុត្រនេះបួសចុះ ។ បើភិក្ខុកំលោះ ដែលឧបជ្ឈាយ៍មិនបានបង្គាប់ទេ លោកបំបួសជំនួសឧបជ្ឈាយ៍ ការធ្វើយ៉ាងនោះ សមគួរ ។ បើភិក្ខុកំលោះមិនមានឧបជ្ឈាយ៍គប្បីប្រាប់សាមណេរក៏បាន ថា "លោកចូរនាំអ្នកនេះ ទៅកាន់ខណ្ឌសីមាឱ្យកោរសក់ ឱ្យស្លៀក

---

១. វិន. មហា. មហាខន្ធកៈ. ៦. ១៨/២៧៥ ។ ២. ពិធីកោរសក់, សាមណេរក៏បាន ។ ៣. វិន. មហា. មហាខន្ធកៈ. ៦. ១១០/២៥៤ ។

ដណ្តប់សំពត់កាសាយៈ រួចស្រេចហើយ សឹមមក ។ ចំណែកសរណៈ ឧបជ្ឈាយ៍គប្បីឱ្យដោយខ្លួនឯង ។ កុលបុត្រនោះ ជាការដែលភិក្ខុទាំងឡាយ បំបួសហើយ ដោយប្រការ ដូច្នេះ ។ ពិតមែន មនុស្សដទៃក្រៅ ពីភិក្ខុមិនបានដើម្បីឱ្យបុរសបួស ។ មនុស្សដទៃក្រៅ ពីភិក្ខុនី មិនបាន ដើម្បីឱ្យមាតុគ្រាមបួសដូចគ្នា ។ ចំណែកសាមណេរឬសាមណេរី បាន ដើម្បីនឹងឱ្យសំពត់កាសាយៈ តាមពាក្យបង្គាប់ ។ ការកោរសក់ អ្នកណា មួយធ្វើហើយ ក៏ជាការដែលធ្វើហើយដោយល្អ ។ ក៏បើថា កុលបុត្រជា អ្នកមានរូបសមគួរ មានកុសលកម្មជាហេតុ មានកេរ្តិ៍ឈ្មោះ មានយស ឧបជ្ឈាយ៍ សូម្បីធ្វើឱកាសហើយ ក៏គួរបំបួសដោយខ្លួនឯងពិត ទាំងមិន គួរបញ្ជូនទៅថា "ចូរកាន់យកដីស្អិតមួយក្តាប់ ផ្ចិតហើយកក់សក់ ហើយ ចូរមក" ។ ព្រោះថា ឧស្សាហ៍របស់អ្នកដែលប្រាថ្នា នឹងបួស ជារបស់ ខ្លាំងក្លាក្នុងកាលមុន តែក្នុងកាលខាងក្រោយ បានឃើញសំពត់កាសាយៈ និងកាំបិតកោរសក់ចូលមក នឹងតក់ស្លុត នឹងរកមកចេញចាកទីនោះទៅក៏ បាន ព្រោះហេតុនោះ ឧបជ្ឈាយ៍ឯងទាំងឡាយ គួរនាំទៅកាន់កំពង់សម្រាប់ ផ្ចិត បើកុលបុត្រនោះ មិនជាក្មេងណាស់ទេ គប្បីប្រាប់ថា "ចូរផ្ចិតទឹក ចេញ" ចំណែកសក់របស់គេ គប្បីកាន់យកដីស្អិតកក់ឱ្យ ដោយខ្លួនឯង តែម្តង ។ ចំណែកកុលបុត្រនៅក្មេង ឧបជ្ឈាយ៍គប្បីចុះទឹកដុសសំអាត

ដោយអាចម៍គោ និងដីស្អិតផ្តួតឱ្យដោយខ្លួនឯង[១] បើថា គេកើតរោគកមក្រិន ឬបូសនៅក្នុងទីខ្លះ[២] មាតាមិនខ្ពើមបុត្រយ៉ាងណា ឧបជ្ឈាយ៍មិនគប្បីខ្ពើមយ៉ាងនោះដែរ គប្បីឱ្យផ្ដួតដុសជម្រះតាំងពីដៃនិងជើងដរាបដល់ក្បាលជាការល្អ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថា ដោយឧបការៈត្រឹមតែប៉ុណ្ណេះ កុលបុត្រទាំងឡាយ នឹងជាអ្នកមានសេចក្ដីស្រឡាញ់ខ្លាំងក្លា មានសេចក្ដីគោរពច្រើនក្នុងអាចារ្យ និងឧបជ្ឈាយ៍ និងក្នុងព្រះសាសនា នឹងជាអ្នកមិនវិលត្រឡប់ជាធម្មតា នឹងបន្ទោបង់សេចក្ដីធុញទ្រាន់ដែលកើតឡើងចេញ ឋិតនៅទាល់តែដល់ភាពជាព្រះថេរៈ និងជាអ្នកកតញ្ញូកតវេទី ។ ឯងក្នុងវេលាដែលឱ្យផ្ដួតទឹក ឬក្នុងវេលាកោរសក់ និងពុកមាត់ ដោយអាការយ៉ាងនេះ ឧបជ្ឈាយ៍មិនគួរនិយាយចំពោះដល់កុលបុត្រថា លោកជាអ្នកមានកេរ្តិ៍ឈ្មោះ មានយស ឥឡូវនេះ ពួកយើងបានអាស្រ័យអ្នកហើយ

នឹងមិនលំបាកដោយបច្ច័យ ។ ពាក្យសំដីដែលមិនមែនពាក្យដឹកនាំយ៉ាងដទៃ ក៏មិនគួរនិយាយដូចគ្នា ។ ដែលត្រូវគួរនិយាយដល់

---

១. ជាលទ្ធិនិយមរបស់អ្នកពួកខ្លះ ។ ២. នេះជារោគដែលត្រូវហាម រាប់ជាឧបសម្បទាទោស ) ។

កុលបុត្រថា អ្នកមានអាយុ លោកចូរពិចារណាមើលឱ្យល្អ ចូរឃុំគ្រងសតិ ហើយគប្បីប្រាប់តចបញ្ចកកម្មដ្ឋាន[1] កាលប្រាប់ គប្បីចង្អុលបង្ហាញឱ្យច្បាស់លាស់ដល់សេចក្ដីក្នុងចំណែកទាំង ៥ នោះ ជារបស់មិនស្អាត គួរខ្ពើម បដិកូលដោយអំណាចពណ៌, សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាស ឬសេចក្ដីក្នុងចំណែកទាំង ៥ នោះ មិនមែនសត្វ មិនមែនជីវៈ មិនមែនខ្លួនប្រាណ ៗ ក៏បើក្នុងកាលមុន កុលបុត្រជាអ្នកធ្លាប់ពិចារណាសង្ខារ ចម្រើនភាវនាមក ដូចជាបួសដែលទុំ រង់ចាំការជោះដោយបន្ទា និងដូចជាផ្កាបទុមធំរង់ចាំតែព្រះអាទិត្យរះឡើង ភ្លាមនោះកាលការពិចារណាកម្មដ្ឋាន គ្រាន់តែកុលបុត្រនោះប្រារព្ធហើយ រមែងប្រព្រឹត្តទៅ ដូចជាអាវុធរបស់ព្រះឥន្ទ្រប្រហារភ្នំឱ្យខ្ទេចខ្ទីទៅ យ៉ាងណាញាណដែលកម្ចាត់កិលេសឱ្យខ្ទេចខ្ទីទៅ ក៏យ៉ាងនោះឯង ៗ កុលបុត្ររមែងសម្រេចព្រះអរហត្តក្នុងវេលាកោរសក់រួចស្រេចតែម្ដង ៗ ពិតមែនតាំងពីដំបូងនោះឯង កុលបុត្រឯណាមួយ បានសម្រេចព្រះអរហត្ត ក្នុងខណៈកោរសក់រួចស្រេច កុលបុត្រទាំងអស់នោះ បានការស្ដាប់បែបនេះអាស្រ័យន័យដែលអាចារ្យជាកល្យាណមិត្តឱ្យ ទើបបានសម្រេចមិនបានអាស្រ័យហើយ ក៏មិនបានសម្រេចដែរ ព្រោះហេតុនោះ ឧបជ្ឈាយ៍ទើបគួរពោលពាក្យនោះដល់គេ, មួយទៀត កាលកោរសក់រួចស្រេចហើយ

---

១ សក់, រោម, ក្រចក, ធ្មេញ, ស្បែក ៗ

គួរប្រើល្មៀត ឬ លំអិតគ្រឿងក្រអូបលាបក្បាលនិងរាងកាយ កម្ចាត់ក្លិនគ្រហស្ថចេញហើយ គប្បីឱ្យទទួលសំពត់កាសាយៈ ៣ ដង ឬ ២ ដង ឬម្តង ក៏បាន ។ សូម្បីបើអាចារ្យ ឬឧបជ្ឈាយ៍ នឹងមិនប្រគល់ឱ្យក្នុងដៃរបស់គេនឹងស្លៀកដណ្តប់ឱ្យដោយខ្លួនឯងតែម្តង យ៉ាងនោះ ក៏សមគួរ សូម្បីបើថា នឹងបង្គាប់អ្នកដទៃជាភិក្ខុកំលោះក្តី សាមណេរក្តី ឧបាសកក្តីថា "អ្នកមានអាយុ លោកចូរកាន់យកសំពត់កាសាយៈ ទាំងនេះ ស្លៀកដណ្តប់ឱ្យអ្នកនេះ" ឬនឹងបង្គាប់កុលបុត្រនោះឯងថា "លោកចូរកាន់យកសំពត់កាសាយៈទាំងនេះ ទៅស្លៀកដណ្តប់" គួរគ្រប់យ៉ាង ។ ពិតមែនសំពត់កាសាយៈទាំងអស់នោះ ជាការដែលភិក្ខុនោះឯងឱ្យហើយ ។ តែបើគេស្លៀក ឬដណ្តប់នូវសំពត់យ៉ាងណា ដែលមិនបានបង្គាប់, គប្បីដោះសំពត់ស្លៀក ឬសំពត់ដណ្តប់នោះចេញ ហើយឱ្យថ្មីម្តងទៀត ។ ព្រោះសំពត់ កាសាយៈដែលភិក្ខុឱ្យដោយដៃរបស់ខ្លួន ឬដោយបង្គាប់ប៉ុណ្ណោះ ទើបគួរ, ដែលភិក្ខុមិនបានឱ្យ មិនគួរ; សូម្បីថា សំពត់កាសាយៈនោះ នឹងជារបស់កុលបុត្រខ្លួនឯង ក៏ត្រូវបដិបត្តិយ៉ាងនោះដែរ ។ ហើយនឹងបាច់ពោលទៅថ្វី ក្នុងសំពត់កាសាយៈដែលមានឧបជ្ឈាយ៍ជាមូលសោត ។ នេះជាវិនិច្ឆ័យក្នុងពាក្យថា (កុលបុត្រនោះ) ភិក្ខុគប្បីកោរសក់ និងពុកមាត់ឱ្យជាដំបូង ហើយឱ្យស្លៀកសំពត់កាសាយៈទាំងឡាយ រួចឱ្យពាក់ចីពរឆៀងស្មាម្ខាង នេះ ។

ពាក្យថា ឱ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ជាដើម មានសេចក្ដីថា ពួកភិក្ខុណាប្រជុំគ្នាក្នុងទីនោះ គប្បីឱ្យថ្វាយបង្គំបាទាភិក្ខុទាំងនោះហើយ លំដាប់នោះ គប្បីឱ្យអង្គុយប្រហោងផ្គងអញ្ជលី ហើយប្រាប់ថា “**ឯវំ វទេហិ** : អ្នកចូរពោលយ៉ាងនេះ” គឺ គប្បីបង្គាប់ថា “**យមហំ វទាមិ តំ វទេហិ** : យើងពោលយ៉ាងណា អ្នកចូរពោលយ៉ាងនោះ” ដើម្បីទទួលសរណៈ ។ លំដាប់នោះ ឧបជ្ឈាយ៍ឬអាចារ្យគប្បីឱ្យសរណៈដល់កុលបុត្រនោះ ដោយន័យជាដើមថា **ពុទ្ធំ សរណំ គច្ឆាមិ** ដូច្នេះ ។ គប្បីឱ្យតាមលំដាប់ ដែលពោលហើយយ៉ាងណា ពិតមែន មិនគប្បីឱ្យខុសលំដាប់គ្នា ។ បើខុសលំដាប់តែមួយបទក្ដី មួយអក្សរក្ដី ឬឱ្យ **ពុទ្ធំ សរណំ** ប៉ុណ្ណោះ គ្រប់ ៣ ដងហើយ ខាងក្រោយទើបឱ្យសរណៈក្រៅពីនេះ ក្នុងមួយបទ ៣ ដង, សរណៈមិនចាត់ថា បានឱ្យ ។ ក៏ឯឧបសម្បទាដែលព្រះមានព្រះភាគ ទ្រង់ហាមសរណគមនូបសម្បទានេះចេញហើយ ទ្រង់អនុញ្ញាតទុក បរិសុទ្ធិតែម្ខាង ក៏គួរ ។ ចំណែកសាមណេរបព្វជ្ជាបរិសុទ្ធិទាំង ២ ខាង ទើបគួរ ។ បរិសុទ្ធិតែម្ខាងមិនគួរ ព្រោះហេតុនោះ ក្នុងឧបសម្បទា បើអាចារ្យធ្វើកម្មវៀរញត្តិទោស និងកម្មវាចាទោសហើយ កម្មជាការធ្វើត្រឹមត្រូវ ។ ចំណែកក្នុងបព្វជ្ជា អាចារ្យនិងអន្តេវាសិក ត្រូវពោលសរណៈទាំង៣ នេះ មិនឱ្យខូចសេចក្ដី ព្រមទាំងមូលនៃឋានករណ៍របស់ព្យញ្ជនៈទាំងឡាយ មាន ពុ អក្សរ និង ធ អក្សរជាដើម ។ បើ

អាចារ្យអាចពោលបាន តែអន្តេវាសិកមិនអាច ឬអន្តេវាសិកអាច តែអាចារ្យមិនអាច ។ ឬទាំង ២ ខាង មិនអាច មិនគួរ ។ តែបើទាំងពីរចំណែកអាច យ៉ាងនោះ ទើបគួរ ។ ក៏ឯកាលឱ្យសរណៈទាំងនេះ គប្បីឱ្យពោលបទដែលមាននិគ្គហិតជាទីបំផុត ឱ្យជាប់ជិតជាមួយយ៉ាងនេះថា ពុទ្ធំ សរណំ គច្ឆាមិ ឬគប្បីឱ្យ ពោលបទដែលមាន ម អក្សរជាទីបំផុតឱ្យដាច់រយៈគ្នាយ៉ាងនេះ ថា ពុទ្ធម៑ សរណម៑ គច្ឆាមិ[១] ។ ក្នុងអន្ធកដ្ឋកថា លោកពន្យល់ថា អន្តេវាសិក គប្បីប្រកាសឈ្មោះ ទទួលសរណៈយ៉ាងនេះថា "អហំ ភន្តេ ពុទ្ធរក្ខិតោ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ : បពិត្រលោកម្ចាស់ពុទ្ធរក្ខិតៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ដរាបដល់អស់ជីវិត" ដូច្នេះ ។ ពាក្យនោះ មិនមានសូម្បីក្នុងអដ្ឋកថា ទាំងក្នុងព្រះបាលី ក៏មិនពោលទុក គ្រាន់តែជាសេចក្តីពេញចិត្តរបស់ព្រះអាចារ្យទាំងនោះ ព្រោះដូច្នោះ មិនគួរកាន់យក ។ ពិតមែន កាលមិនពោលយ៉ាងនោះ សរណៈនឹងកម្រើក ក៏ទេដែរ ។

ពាក្យថា អនុជានាមិ ភិក្ខវេ ឥមេហិ តីហិ សរណគមនេហិ បព្វជ្ជំ ឧបសម្បទំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងឡាយនេះ មានសេចក្តីថា

---

១. ជាសំនៀងពោលដូចសំស្រ្កិត ។

តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងនេះ ដែលពោលបរិសុទ្ធិទាំង ២ ខាង គ្រប់ ៣ ដង យ៉ាងនេះថា ពុទ្ធំ សរណំ គច្ឆាមិ ជាដើម ។ ក្នុងបព្វជ្ជា និងឧបសម្បទាទាំង ២ នោះ ឧបសម្បទា ព្រះមានព្រះភាគទ្រង់ហាមនៅខាងមុខ[1] ព្រោះដូច្នោះ ឥឡូវនេះ ឧបសម្បទានោះ ទើបមិនឡើងដោយត្រឹមតែសរណៈ ប៉ុណ្ណោះ ។ ចំណែកបព្វជ្ជាទ្រង់អនុញ្ញាតទុកខាងមុខថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាមណេរបព្វជ្ជា ដោយត្រៃសរណគមន៍នេះ”[2] ព្រោះហេតុនោះ ឥឡូវនេះ បព្វជ្ជានោះ រមែងឡើងដោយត្រឹមតែសរណៈប៉ុណ្ណោះ ។ ពិតមែន កុលបុត្រ ជាការតាំងនៅក្នុងភូមិនៃសាមណេរ ដោយអាការត្រឹមតែប៉ុណ្ណោះ ។ ក៏បើសាមណេរនោះ ជាអ្នកមានបញ្ញា មានជាតិជាអ្នកឆ្លាត លំដាប់នោះ គប្បីសម្តែងសិក្ខាបទទាំងឡាយ ដល់លោកក្នុងទីនោះតែម្តង ។ សម្តែងដូចម្តេច ? សម្តែងដូចដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ ពិតមែន ព្រះមានព្រះភាគបានត្រាស់ទុកយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំងឡាយ ១០ ដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឱ្យសាមណេរទាំងឡាយ

---

១. វិន. មហា. មហាខន្ធក. ៦. ៨៥/១៦៩ ថា “ម្នាលភិក្ខុទាំងឡាយ ឧបសម្បទាណា ដែលតថាគតបានអនុញ្ញាតដោយត្រៃសរណគមន៍រួចហើយ ចាប់ដើមពីថ្ងៃនេះទៅ តថាគតឃាត់នូវឧបសម្បទានោះវិញ” ។ ២. វិន. មហា. មហាខន្ធក. ៦. ១១៨/២៧២ ។

សិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នោះ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង ១ ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យ ១ ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ ១ ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ១ ចេតនាជាហេតុ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកនូវទឹកស្រវឹង គឺ សុរានិងមេរ័យ ១ ចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ១ ចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ១ ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ១ ចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ១ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ ១”[១] ។

ចំណែកក្នុងអន្ធកដ្ឋកថា ព្រះអដ្ឋកថាចារ្យ ពោលសូម្បីនូវការឱ្យសិក្ខាបទដូចការឱ្យសរណៈយ៉ាងនេះថា អហំ ភន្តេ ឥត្ថន្នាមោ យាវជីវំ បាណាតិបាតា វេរមណីំ សិក្ខាបទំ សមាទិយាមិ : បពិត្រលោក

១. វិន. មហា. មហាខន្ធក. ៦. ១២០/២៧៧ ។

ម្ចាស់ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺ កិរិយាវៀរចាកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ដរាបដល់អស់ជីវិត” ដូច្នេះ ៗ សូម្បីវិធីនោះ ក៏មិនមានក្នុងបាលី ទាំងមិនមានក្នុងអដ្ឋកថាទាំងឡាយ ព្រោះដូច្នោះ គួរសម្តែងតែល្មម សមគួរដល់បាលី ពិតមែនបព្វជ្ជាសម្រេចដោយសរណគមន៍ប៉ុណ្ណោះ ៗ ចំណែកសិក្ខាបទ ទាំងឡាយដែលសាមណេរគួរជ្រាប ដើម្បីធ្វើសិក្ខាឱ្យបរិបូណ៌តែម្យ៉ាង ព្រោះដូច្នោះ កាលសាមណេរ មិនអាចនឹងរៀនសិក្ខាបទទាំងនោះ តាមន័យដែលមក ក្នុងព្រះបាលីបាន នឹងប្រាប់ត្រឹមតែសេចក្តីដោយភាសាណាមួយ ក៏គួរ ៗ ចំណែកសាមណេរមិនទាន់ដឹងសិក្ខាបទដែលខ្លួនគួរសិក្សាមិនទាន់ឆ្លាតក្នុងការទ្រទ្រង់សំពត់សង្ឃាដិ[1] បាត្រ និងចីវរ ការឈរ និងការអង្គុយជាដើម និងក្នុងវិធីមានផឹកនិងឆាន់ជាដើម ត្រឹមណា មិនគួរបណ្តាយសាមណេរនោះទៅកាន់សាលាឆាន់ ឬទីចែកស្លាក ឬស្ថានទីដូច្នោះដទៃ ត្រឹមនោះ ៗ គួរឱ្យសាមណេរត្រាច់នៅក្នុងសំណាក់ប៉ុណ្ណោះ ៗ គួរបំរុងសាមណេរដូចក្មេងខ្ចី ៗ គួរប្រាប់វត្តដែលគួរ និងមិនគួរគ្រប់យ៉ាង ដល់សាមណេរ គួរណែនាំសាណេរ ក្នុងអភិសមាចារិកវត្ត មានស្លៀកដណ្តប់ជាដើម ៗ សូម្បីសាមណេរនោះសោត ក៏គួរ

---

១. សាមណេរក៏មានសង្ឃាដី ដែរ ៗ

វៀរឱ្យឆ្ងាយនូវទោសទន្ត:១០ ដែលព្រះមានព្រះភាគត្រាស់ទុកខាងមុខ យ៉ាង នេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ ញ៉ាំងសាមណេរ ដែលប្រកបដោយអង្គ ១០ ឱ្យវិនាស"[១] ដូច្នេះ ធ្វើអភិសមាចារិកវត្ត ឱ្យ បរិបូណ៌, គប្បីសិក្សាឱ្យល្អក្នុងសីល ១០ យ៉ាង ដូច្នេះឯង ។

បព្វជ្ជានិងឧបសម្បទា ចប់

## ទុតិយមារកថា

[៣៥] ច្រើនបទថា មយ្ហំ ខោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ តថាគត មានអត្ថថា មយា ខោ ។ម្យ៉ាងទៀត មានសេចក្ដីថា ការ ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញារបស់តថាគត អធិប្បាយថា ព្រោះ សេចក្ដីធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញារបស់តថាគតជាហេតុ ។ កាលផ្លាស់វិភត្តិហើយ ក៏គប្បីពោលពាក្យថា មយា ជាអនភិហិតកត្តា ក្នុងបទថា អនុប្បត្តា : បានសម្រេច នេះ (ព្រោះ មយ្ហំ ជាសាមីស ម្ពន្ធទៅហើយ) ។

ទុតិយមារកថា ចប់

---

១. វិន. មហា. មហាខន្ធក. ៦. ១២៤/២៨២ ។

# រឿងភទ្ទវគ្គិយកុមារជាសម្លាញ់នឹងគ្នា

[៣៦] បទថា ភទ្ទវគ្គិយា : ពួកភទ្ទវគ្គិយកុមារ មានសេចក្តីថា បានឮថា សម្លាញ់ទាំងនោះ ជារាជកុមារ អ្នកមានសេចក្តីចម្រើនដោយរូបរាង និងចិត្ត ត្រាច់ទៅ ដោយរួមគ្នាជាពួកមួយ ព្រោះដូច្នោះ លោកទើបហៅថា "ភទ្ទវគ្គិយ" វា អក្សរក្នុងបទថា តេនហិ វា : បើដូច្នោះ អ្នកទាំងឡាយ ដូច្នេះ ត្រឹមតែជា និបាត ។

ពីរបទថា ធម្មចក្ខុំ ឧទបាទិ : ឯធម្មចក្ខុ ក៏កើតឡើង មានសេចក្តីថា សោតាបត្តិមគ្គបានកើតឡើងដល់ពួកខ្លះ សកទាគាមិមគ្គបានកើតឡើងដល់ពួកខ្លះ អនាគាមិមគ្គបានកើតឡើងដល់ពួកខ្លះ ។ ពិតមែនមគ្គទាំង ៣ នេះ លោកហៅថា ធម្មចក្ខុ ។ បានឮថា សម្លាញ់ទាំងនោះបានជាអ្នកលេង ៣០ នាក់ ក្នុងតុណ្ឌិលជាតក[១] ។ គ្រានោះ ពួកគេបានស្តាប់តុណ្ឌិលោវាទហើយរក្សាសីល ៥ ។ បុព្វកម្មរបស់សម្លាញ់ទាំងនោះប៉ុណ្ណោះ ។

រឿងភទ្ទវគ្គិយកុមារជាសម្លាញ់នឹងគ្នា ចប់

---

១. ខុទ្ទ. ជាត. ៥៩. ២១៦៥៦ ។

# រឿងជាដិលជាបងប្អូននឹងគ្នា

(៣៧) បទថា បមុខោ : ជាប្រមុខ គឺ ជាប្រធាន ។

បទថា បាមោក្ខោ : ជាបុគ្គលឧត្តមប្រសើរ មានសេចក្តីថា ជាអ្នកខ្ពស់បំផុត គឺ មានបញ្ញាផូរផង់ ។

(៣៨) បទថា អនុប្បហច្ច : មិនបានប៉ះពាល់ បានដល់ មិនឱ្យខូច ។

ពីរបទថា តេជសា តេជំ : តេជៈដោយតេជៈ មានសេចក្តីថា គ្របសង្កត់តេជនៃនាគដោយតេជៈរបស់ព្រះអង្គ ។

បទថា បរិយាទេយ្យំ : គ្របសង្កត់ មានសេចក្តីថា គប្បីគ្របសង្កត់ចេញ ឬនាំឱ្យវិនាសទៅ ។

បទថា មក្ខំ : លុបគុណ បានដល់ សេចក្តីក្រោធ ។

ពាក្យថា ន ត្វេវ ច ខោ អរហា យថា អហំ : តែបើទុកជាយ៉ាងនោះ ក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ មានសេចក្តីថា បុគ្គលអ្នកដូចជាយើងសម្គាល់ខ្លួនថា យើងជាអរហន្ត អួតអាងយ៉ាងណា នឹងបានជាអរហន្តយ៉ាងនោះ ក៏ទេដែរ ។

(៣៩) ពីរបទថា អជ្ឈុណ្ហោ អគ្គិសរណម្ហិ : តថាគតសូមនៅ

ក្នុងពេលភ្លើង ក្នុងថ្ងៃនេះបាន ១ ថ្ងៃសិន មានសេចក្តីថា តថាគត គប្បីនៅអស់ថ្ងៃមួយក្នុងថ្ងៃនេះ ។

បទថា ផាសុកាមោ : ប្រាថ្នាសេចក្តីសប្បាយ គឺ ប្រាថ្នាសេចក្តីចម្រើន ។

បទថា សុមានសោ : ទ្រង់មានព្រះទ័យរីករាយ បានដល់ អ្នកមានចិត្តប្រកបព្រមដោយបីតិ និងសោមនស្ស ។

បទថា ន វិមនោ : ឥតមានសេចក្តីអាក់អន់ បានដល់ អ្នកមានចិត្តល្អ អធិប្បាយថា ចិត្តដែលទោសៈមិនគ្របសង្កត់ ។

ពីរបទថា អគ្យាគារំ ឧធិច្ឆរេ : ក៏បណ្តាលភ្លើងឱ្យឆេះឡើង មានសេចក្តីថា ពេលភ្លើង ក៏បណ្តាលឆេះឡើង ។

បទថា ជដិលា ប្រែភ្ជាប់នឹងបទនេះថា ភណន្តិ : ជដិលទាំងឡាយ និយាយគ្នា ។

ច្រើនបទថា អហិនាគស្ស អច្ចិយោ ន ហោន្តិ : រស្មីរបស់អហិនាគ ក៏រលត់សូន្យទៅ មានសេចក្តីថា អណ្តាតភ្លើងនៃនាគមានពន្លឺមិនរុងរឿង មានពណ៌ខុសប្លែក ។

បទថា ផលិកវណ្ណាយោ : ពណ៌ផ្លេក គឺ មានវណ្ណៈដូចកែវផលិក ។

បទថា **អង្គីរសស្ស : ព្រះនាមថា អង្គីរស** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា អង្គីរស ហេតុថា មានព្រះកាយជាដែនផ្សាយចេញនៃរស្មីរបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា អង្គីរសព្រះអង្គនោះ[១] ។

[៤០-២] ពីរបទថា **អភិក្កន្តាយ រត្តិយា : លុះរាត្រីនោះកន្លងហើយ** មានសេចក្តីថា កាលរាត្រីអស់ទៅច្រើនហើយ អធិប្បាយថា នៅសល់តិច ។

បទថា **អភិក្កន្តវណ្ណា : មានសម្បុរល្អ** គឺ មានវណ្ណៈល្អ បានដល់ មាន វណ្ណៈគួរគាប់ចិត្តណាស់ ។

បទថា **កេវលកប្បំ** បានដល់ ទាំងអស់ គឺ មិនមានសេសសល់ ។

ជដិលឧរុវេលកស្សបៈ សំដៅដល់ រស្មីនៃវណ្ណៈរបស់ស្តេចមហារាជទាំង ៤ ពោលថា **បុរិមាហិ វណ្ណនិភាហិ** ។

បទថា **បាណិនា** គឺ ដោយដៃ ។

---

១. តាំងវិគ្រោះឱ្យបទចុះជាបឋមាវិភត្តិសិន ហើយសឹមប្រើសព្វនាម យោគតាមរូបពីដើមជា ខាងក្រោយ, មួយទៀត ក្នុងវិគ្រោះនេះសង្ស័យថា នឹងធ្លាក់ ស័ព្ទ ឆដ្ឋីវិភត្តិទៅស័ព្ទមួយ ។

[៤៤-៩] ច្រើនបទថា កកុធេ អធិវត្ថា ទេវតា : លំដាប់នោះ ទេវតាអាស្រ័យនៅលើដើមថ្នាន់ បានដល់ ទេវតាដែលស្ថិតនៅលើដើមថ្នាន់ ។

បទថា វិស្សជ្ជេយ្យំ : ត្រដាងហាល មានសេចក្តីថា គប្បីត្រដាងហាលទុកដើម្បីត្រូវការនឹងឱ្យស្ងួត ។ ដើមថ្នាន់នោះបង្អោនចុះហាក់ដូចជាទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ឈោង ព្រះហស្តមកចុះ" ព្រោះដូច្នោះ ដើមថ្នាន់នោះ ទើបឈ្មោះថា អាហរហត្ថោ បង្អោនចុះដូចទូលថា សូមទ្រង់ឈោងព្រះហស្តមក ។

បទថា ឧយ្យោជេត្វា : បញ្ជូនមក បានដល់ ចោល ។

ភាជនៈសម្រាប់ដុតភ្លើង ហៅថា មន្ទាមុខី : ចង្ក្រាន ។

[៥១] បទថា ចិរបដិកា : យូរណាស់មកហើយ មានសេចក្តីថា ចាប់ផ្តើមតាំងពីកាលយូរ ។

[៥២] បទថា កេសមិស្សំ : គ្រឿងបរិក្ខាព្រមទាំងសក់ ជាដើម មានសេចក្តីថា សក់ទាំងឡាយនុ៎ះឯង ឈ្មោះថា កេសមិស្សំ : ផ្នួងសក់ ។ គ្រប់បទមានន័យដូចគ្នា ។ អម្រែកសម្រាប់ដាក់បរិក្ខាររបស់តាបស ឈ្មោះថា ខារិកាជៈ ។

រឿងជដិលជាបងប្អូននឹងគ្នា ចប់

# ការជួបជុំរបស់ព្រះបាទពិម្ពិសារ

[៥៦] បទថា លដ្ឋិវនេ : ព្រៃត្នោត បានដល់ សួនត្នោត ។

ពីរបទថា សុប្បតិដ្ឋេ ចេតិយេ បានដល់ ក្រោមម្លប់ដើមជ្រៃមួយដើម ។ បានឮថា ពាក្យថា សុប្បតិដ្ឋចេតិយ នេះ ជាឈ្មោះរបស់ដើមជ្រៃនោះ ។ ១ ម៉ឺន ជា ១ នហុត ក្នុងពាក្យថា ទ្វាទសនហុតេហិ នេះ ។

[៥៧] បទថា អបេ្បកច្ចេ កាត់បទថា អបិ ឯកច្ចេ

បទថា អជ្ឈភាសិ មានសេចក្តីថា បានត្រាស់ដើម្បីកាត់សេចក្តីសង្ស័យរបស់ព្រាហ្មណ៍និងគហបតីទាំងនោះ ។

ពីរបទថា កិមេវ ទិស្វា : តើអ្នកឃើញអ្វី មានសេចក្តីថា ឃើញអ្វីហ្ន៎ ?

បទថា ឧរុវេលវាសី : ក្នុងឧរុវេលាប្រទេស គឺ អ្នកមានប្រក្រតីនៅត្រង់ឧរុវេលប្រទេស ។ លោក រមែងជាអ្នកលះភ្លើងដែលខ្លួនបូជាហើយបួស, មានឧបាយអ្វី ?

បទថា កិសកោវទានោ : ជាអ្នកប្រដៅពួកតាបស មានសេចក្តីថា ជាអ្នកជាស់តឿន ទូន្មានតាបសទាំងឡាយ ដែលបានទាមថា អ្នកស្គម ព្រោះមានរាងកាយស្គម ដោយការប្រព្រឹត្តរបស់អ្នកដុតកំដៅ

កិលេស ។

ម្យ៉ាងទៀត មានសេចក្ដីថា ជាតាបសស្គមនោះឯង និងជាអ្នកឱ្យឱវាទ អធិប្បាយថា ជាស់តឿនទូន្មានតាបសដែលស្គមពួកដទៃផង ។

ពីរបទថា គាថំ បហីនំ : អ្នកលះបង់ហើយ តើព្រោះហេតុអ្វី មានសេចក្ដីថា ព្រោះហេតុអ្វី ទើបលះចេញ ? មានពាក្យអធិប្បាយថា លោកនៅឱរុវេលាមកយូរហើយ ខ្លួនឯងធ្លាប់ជាអាចារ្យ ប្រៀនប្រដៅពួកតាបសដែលបម្រើភ្លើង ឃើញឧបាយអ្វី ទើបលះបង់ភ្លើងចេញ ? យើងសួរសេចក្ដីនេះនឹងលោក តើហេតុដូចម្ដេច ទើបលោកលះបង់ការបូជាភ្លើងរបស់លោកចេញ ?

ក្នុងគាថា ទី ២ មានសេចក្ដីដូច្នេះ ៖

យញ្ញទាំងឡាយ ពោលសរសើរកាមទាំងឡាយ មានរូបជាដើមទាំងនេះនិងស្ត្រីទាំងឡាយ ខ្ញុំព្រះករុណានោះ បានជ្រាបប្រភេទរបស់កាមមានរូបជាដើម ទាំងអស់នេះថា ជាមន្ទិលក្នុងខន្ធជាទីក្រសោបទុក្ខទុក ទើបមិនបានត្រេកអរក្នុងការសែន និងការបូជា អធិប្បាយថា មិនអភិរម្យហើយក្នុងការសែន ឬការបូជា ព្រោះយញ្ញទាំងឡាយ ផ្សងដោយការសែននិងការបូជាទាំងនេះ ពោលសរសើរ ផល ជាមន្ទិលទាំងអស់ ។

វិនិច្ឆ័យក្នុងគាថា ទី ៣ ៖

បទថា អជ គោចរេហិ **: ម្យ៉ាងទៀត ...ខ្វះដែរឬ** មានសេចក្តីថា ក៏ទីនោះ ... ក្នុងវត្ថុណាហ្ន៎ ? បទដ៏សេសងាយយល់ទាំងអស់ ។

វិនិច្ឆ័យក្នុងគាថា ទី ៤ ៖

បទថា បធំ ជាដើម មានសេចក្តីថា មកគឺ ព្រះនិព្វានចាត់ថា ស្ងប់និងមានសេចក្តីស្ងប់ជាសភាព ចាត់ថា មិនមានកិលេសដែលជាហេតុក្រសោបទុក្ខ ព្រោះមិនមានកិលេសទាំងឡាយ ដែលចូលទៅក្រសោបយកទុក្ខទុក, ចាត់ថា មិនមានកង្វល់ ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ទាំងឡាយ មានរាគៈជាដើម, ចាត់ថា មិនជាប់ជំពាក់ស្ងប់ក្នុងកាមភព ដែលជាទីពោលសរសើរនៃយញ្ញទាំងឡាយ ព្រោះមិនជាប់នៅក្នុងភពទាំង ៣ ហើយ, ចាត់ថា មានកិរិយាមិនប្រែប្រួលទៅជាដទៃ ព្រោះមិនមានកើត ចាស់ ស្លាប់, ចាត់ថា មិនមែនធម៌ដែលអ្នកដទៃនឹងគប្បីណែនាំឱ្យបាន ព្រោះត្រូវសម្រេចដោយមគ្គ ដែលខ្លួនឯងចម្រើនហើយប៉ុណ្ណោះ ដែលទោះជាអ្នកដទៃណាក៏ដោយ នឹងឱ្យសម្រេចមិនបាន ខ្ញុំព្រះករុណាមិនត្រេកអរហើយក្នុងការសែន និងការបូជាក៏ព្រោះឃើញមកដូច្នេះ ។ ព្រះឧរុវេលកស្សបសម្តែងយ៉ាងណា ? ដោយពាក្យថា បានឃើញមកដែលស្ងប់ ជាដើមនោះ ? សម្តែងថា "ខ្ញុំព្រះករុណា មិន

បានត្រេកអរហើយក្នុងការសែននិងការបូជា ដែលឱ្យសម្រេចសម្បត្តិក្នុងទេវលោកនិងមនុស្សលោក ខ្ញុំព្រះករុណានោះនឹងពោលយ៉ាងណា ?"

[៥៨] គ្រានោះឯង ព្រះឧរុវេលកស្សបដ៏មានអាយុ គ្រាប្រកាសនូវសេចក្តីមិនត្រេកអរ ក្នុងលោកទាំងពួងយ៉ាងនេះថា "ចិត្តរបស់ខ្ញុំព្រះករុណាមិនត្រេកអរក្នុងទេវលោក និងមនុស្សលោក ឈ្មោះនេះហើយ" ដូច្នេះហើយ ទើបប្រកាសនូវភាពនៃខ្លួនជាសាវករបស់ព្រះមានព្រះភាគយ៉ាងនេះថា "សាវកោហមស្មិ : ខ្ញុំព្រះអង្គជាសាវក" ក៏ឯលោកសម្តែងបាដិហារ្យច្រើនយ៉ាងក្នុងអាកាស ដើម្បី ប្រកាសសេចក្តីខ្លួន ជាសាវករបស់ព្រះមានព្រះភាគនោះឯង ហើយចុះថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីម្ខាង ។

បទថា ធម្មចក្ខុំ : ឯធម្មចក្ខុ បានដល់ សោតាបត្តិមគ្គញ្ញាណ ។

[៥៩] បទថា អស្សាសកា : បំណង បានដល់ សេចក្តីប្រាថ្នា អធិប្បាយថា ការប៉ុនប៉ងចង់បាន ។

ក៏វិនិច្ឆ័យក្នុងពាក្យថា ឯសាហំ ភន្តេ : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ នេះ គប្បីជ្រាបដូចតទៅនេះ ៖

ពិតមែន សរណគមណ៍របស់ព្រះបាទពិម្ពិសារនោះ សម្រេច

ហើយដោយ ការត្រាស់ដឹងមគ្គដោយពិត ប៉ុន្តែថា ស្តេចសម្រេចព្រះហឫទយក្នុងសរណគមន៍នោះហើយ ឥឡូវនេះ ទើបទ្រង់ធ្វើការប្រគល់ព្រះអង្គថ្វាយដោយព្រះវាចា គឺថា ព្រះបាទពិម្ពិសារនេះ ទ្រង់បានដល់សរណគមន៍ដែលពិតប្រាកដ ដោយអំណាចនៃមគ្គនោះឯងហើយ កាលនឹងទ្រង់ធ្វើការដល់សរណៈនោះ ឱ្យប្រាកដដល់អ្នកដទៃដោយព្រះវាចាឯកាលទឹងទ្រង់ដល់ដោយសេចក្តីនមស្ការ ទើបត្រាស់យ៉ាងនោះ ។

## គាថាជាចម្រៀងរបស់ព្រះឥន្ទ្រ

[៦១] បទថា សិង្គីនិក្ខសុវណ្ណោ : ពណ៌ល្អដូចសិង្គី មានសេចក្តីថា មានវណ្ណៈស្មើដោយដុំមាស ឈ្មោះសិង្គី ។

បទថា ទសវាសោ : អរិយវាស ១០ បានដល់ ទ្រង់នៅជាប្រចាំក្នុងធម៌ជាទីនៅរបស់ព្រះអរិយៈ ១០ ប្រការ ។

បទថា ទសធម្មវិទូ : ជ្រាបច្បាស់នូវធម៌ ១០ បានដល់ ទ្រង់ជ្រាបកម្មបថ ១០ ប្រការ ។

ពីរបទថា ទសភិ ចុបេតោ : ប្រកបដោយអង្គ ១០ បានដល់ទ្រង់ប្រកបដោយអង្គរបស់ព្រះអសេក្ខបុគ្គល ១០ យ៉ាង[១] ។

១. ទីឃ. បាដិ. សង្គីតិសូត្រ. ១៩. ២៣៣/២៥២ : ១. សម្មាទិដ្ឋិ ។ល។ ៨. សម្មាសមាធិ ៩. សម្មាញាណ ១០. សម្មាវិមុត្តិ ។

ពីរបទថា សច្ចធិ ធរេន្តោ : ទ្រទ្រង់នូវឥន្ទ្រិយទាំងអស់បានហើយ បានដល់ អ្នកទូន្មានហើយក្នុងឥន្ទ្រិយទាំងពួង

ពិតមែន បណ្តាឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើមរបស់ព្រះមានព្រះភាគ ឥន្ទ្រិយណា ៗ ដែលឈ្មោះថា មិនទាន់បានទូន្មាន រមែងមិនមាន ។

[៦៣] ពាក្យថា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ : ទ្រង់កំណត់ដឹងនូវព្រះមានព្រះភាគដែលទ្រង់សោយរួចហើយ ត្រង់ដែលទ្រង់ដាក់ព្រះហស្តចុះចាកបាត្រ រួចក៏ស្តេចគង់នៅក្នុងទីដ៏សមគួរ មានសេចក្តីថា កំណត់ដឹងនូវព្រះមានព្រះភាគសោយរួចស្រេចហើយ ដកព្រះហស្ត ចេញអំពីបាត្រហើយ ទើបគង់ប្រថាប់ក្នុងទីដ៏សមគួរ ។

បទថា អត្ថិកានំ : ដែលត្រូវការ មានសេចក្តីថា អ្នកមានសេចក្តីត្រូវការដោយការទៅគាល់ព្រះពុទ្ធ និងដោយការស្តាប់ធម៌ ។

បទថា អភិក្កមនីយំ : គួរជាទីចូលទៅរក មានសេចក្តីថា គប្បីអាចទៅគាល់បាន ។

បទថា អប្បកិណ្ណំ : មិនបានច្រឡូកច្រឡំ គឺ មិនច្របូកច្របល់ ។

បទថា អប្បសទ្ទំ : មានសំឡេងតិច បានដល់ ស្ងាត់សំឡេងដែលនិយាយចរចារគ្នា ។

បទថា អប្បនិគ្ឃោសំ **:** មិនមានសេចក្ដីគឹកកង បានដល់ មិនមានសំឡេងគឹកកងដោយសំឡេងអូ, អរក្នុងព្រះនគរ ។

បទថា វិជនវាតំ **:** មានខ្យល់បក់ស្រួល បានដល់ ប្រាសចាកខ្យល់ក្នុងសរីរៈរបស់ជនដែលសញ្ចររឿយ ៗ ។

បាលីថា ប្រាសចាកការនិយាយចរចារបស់ជនខ្លះ ។ អធិប្បាយថា ប្រាសចាកការនិយាយចរចារបស់អ្នកខាងក្នុង ។

បាលីថា ប្រាសចាកការត្រាច់ទៅរបស់ជនខ្លះ អធិប្បាយថា វៀរចាកការត្រាច់អន្ទោលរបស់ជន ។

បទថា មនុស្សរាហសេយ្យកំ **:** គួរដល់កិរិយាពួននៅនៃមនុស្សទាំងឡាយ បានដល់ គួរជាទីធ្វើកម្មកំបាំងរបស់ពួកមនុស្ស ។

បទថា បដិសល្លានសារុប្បំ **:** ជាទីគួរដល់ការសម្ងំនៅ គឺសមគួរជាទីស្ងាត់ ។

ពណ៌នាពិម្ពិសារវត្ថុ ចប់

# បព្វជ្ជារបស់បរិព្វាជកឈ្មោះសារីបុត្តនិងមោគ្គល្លាន

[៦៤] បទថា សារីបុត្តមោគ្គល្លានា : ព្រះសារីបុត្តមោគ្គល្លាន បានដល់ ព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ លោកទាំង ២ បានធ្វើកតិកាគ្នាទុកថា អ្នកណាដឹងនូវអមតធម៌មុន អ្នកនោះចូរប្រាប់ដល់អ្នកម្នាងទៀត ។

បានឮថា លោកទាំង ២ នោះ ក្នុងកាលនៅជាគ្រហស្ថ មានឈ្មោះប្រាកដយ៉ាងនេះថា ឧបតិស្ស: កោលិត: មានមាណព ២៥០ ជាបរិវារ បានទៅមើលមហោស្រពដែលមាននៅលើកំពូលភ្នំ[១] ។ សម្លាញ់ទាំងពីរឃើញមហាជនក្នុងទីនោះហើយ បានពិចារណាថា ដែលឈ្មោះថាពួកមហាជនយ៉ាងនេះ ៗ មិនទាន់ដល់ ១០០ ឆ្នាំផង ក៏នឹងធ្លាក់នៅក្នុងមាត់នៃសេចក្តីស្លាប់ ។

លំដាប់នោះ សម្លាញ់ទាំង ២ កាលបរិស័ទក្រោកឡើងហើយ បានសាកសួរគ្នានិងគ្នាមានអធ្យាស្រ័យរួមគ្នា មានសេចក្តីសម្គាល់ថាសេចក្តីស្លាប់ប្រាកដចំពោះមុខ ប្រឹក្សាគ្នាថា “ម្នាលសម្លាញ់ កាលសេចក្តីស្លាប់មាន ធម៌ដែលមិនស្លាប់ ក៏ត្រូវមានដែរ ។ ណ្ហើយចុះ យើងស្វែងរកធម៌ដែលមិនស្លាប់ចុះ” ដូច្នេះ ។

---

១. គិរគ្គសមជ្ជ មហោស្រពប្រចាំឆ្នាំក្នុងក្រុងរាជគ្រឹះ, មហោស្រពលើកំពូលភ្នំ ។

ដើម្បីស្វែងរកធម៌ដែលមិនស្លាប់ ទើបបួសក្នុងសំណាក់សញ្ជ័យបរិព្វាជក ជាអ្នកស្លៀកសំពត់ព្រមដោយបរិស័ទ មិនបានប៉ុន្មានថ្ងៃផង ក៏ដល់ត្រើយក្នុងលទ្ធិសម័យ ដែលជាវិស័យនៃញាណរបស់សញ្ជ័យនោះ ។

កាលមើលមិនឃើញអមតធម៌ ទើបសួរថា "លោកអាចារ្យខ្ញុំសូមសួរខ្លឹមសារ សូម្បីដទៃក្នុងបព្វជ្ជានេះ តើនឹងនៅមានតទៅទៀតឬ ?"

បានស្តាប់ពាក្យឆ្លើយតបរបស់លោកថា "មិនមានទេ អ្នកមានអាយុ" និងថា "លទ្ធិនេះមានប៉ុណ្ណេះឯង" ។

ទើបធ្វើកតិកាទុកថា "អ្នកមានអាយុ លទ្ធិនេះទទេ មិនមានខ្លឹមសារ ពេលនេះ បណ្តាពួកយើង អ្នកណាដឹងនូវអមតធម៌មុន អ្នកនោះចូរប្រាប់ដល់ម្នាក់ទៀត" ។

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលពាក្យជាដើមថា លោកទាំង២ បានធ្វើកតិកាគ្នាទុក ។

តតិយាវិភត្តិ ក្នុងលក្ខណៈនៃឥត្ថម្ភូត អ្នកសិក្សាគប្បីជ្រាបក្នុងបទទាំងឡាយថា បាសាទិកេន អភិក្កន្តេន : ដើរទៅ គួរជាទីជ្រះថ្លា ជាដើម ។ ពាក្យនេះថា អត្ថិកេហិ ឧបញ្ញាតំ មគ្គំ : គង់ដឹងនូវមគ្គញាណដែលជនទាំងឡាយត្រូវការដឹង ជាពាក្យសម្តែងហេតុការជាប់

តាម ។ ពិតមែន មានពាក្យដែលលោកអធិប្បាយទុកដូច្នេះថា បើដូច្នោះ យើងគប្បីតាមភិក្ខុនេះទៅខាងក្រោយ ៗ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ធម្មតាការតាមជាប់ទៅខាងក្រោយ ៗ នេះ ជាមកដែលអ្នកមានសេចក្តីត្រូវការទាំងឡាយ ដឹងច្បាស់ ហើយអធិប្បាយថា ជាមកដែលជនទាំងឡាយ អ្នកមានសេចក្តីត្រូវការដឹងហើយទិងដើរចូលមករកហើយ ។

ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងពាក្យនេះ យ៉ាងនេះថា ដែលឈ្មោះថា និព្វាន ដែលយើងទាំងឡាយ អ្នកមានសេចក្តីត្រូវការដឹងច្បាស់ហើយថា មានពិតប្រាកដ ដោយអនុមតិយ៉ាងនេះថា "កាលសេចក្តីស្លាប់មាន ធម៌ដែលមិនស្លាប់ក៏ត្រូវមានដែរ" បើដូច្នោះ យើងកាលស្វែងរក គឺកាលស្រាវជ្រាវរកនិព្វាននោះ គប្បីតាមជាប់ភិក្ខុនេះទៅខាងក្រោយ ៗ ។

ប្រើទបទថា **បិណ្ឌបាតំ អាទាយ បដិក្កមិ : ទទួលបិណ្ឌបាតហើយត្រឡប់មកវិញ** មានសេចក្តីថា ព្រះអស្សជិដ៏មានអាយុ ចូលទៅអន្តរយប្រែបជញ្ជាំងសាលាមួយ ដែលមានសេចក្តីដូចពោលហើយ ក្នុងសុទិន្នកណ្ឌ ។ សូម្បីសារីបុត្ត ក៏ឈរវេធចាំវេលាថា មិនមែនជាវេលាដែលត្រូវសួរបញ្ហាទេ ដើម្បីនឹងបំពេញវត្តបដិបត្តិ ទើបថ្វាយទឹកអំពីកំសៀវ

របស់ខ្លួន ដល់ព្រះថេរៈដែលសម្រេចភត្តកិច្ចហើយ ធ្វើបដិសណ្ឋារៈដល់ព្រះថេរៈ ដែលលាងដៃនិងជើងហើយ ទើបសួរបញ្ហា ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា អថ ខោ សារីបុត្តោ បរិព្វាជកោ : បរិព្វាជកឈ្មោះសារីបុត្រ ក្នុងកាលនោះ ជាដើម ។

ពីរបទថា ន តាហំ សក្កោមិ កាត់បទថា ន តេ អហំ សក្កោមិ ប្រែថា អាត្មាមិនអាចដើម្បី...អ្នក គឺ សម្រាប់លោក អាត្មាមិនអាច( សម្តែងឱ្យពិស្តារទេ ) ។

ប៉ុន្តែថា ព្រះថេរៈដល់បដិសម្ភិទាញាណក្នុងធម្មវិន័យនេះ នឹងមិនអាចសម្តែងធម៌ត្រឹមតែប៉ុណ្ណោះក៏ទេ តាមការពិត លោកគិតថា យើងនឹងបណ្តុះសេចក្តីគោរពក្នុងធម៌ដល់អ្នកនេះ បានកាន់យកសេចក្តីដែលជាការសម្តែងធម៌ក្នុងពុទ្ធវិស័យដោយអាការទាំងពួងមិនមែនវិស័យរបស់លោក ទើបពោលយ៉ាងនោះ ។

[៦៥] បាទគាថាថា យេ ធម្មា ហេតុប្បភវា : ធម៌ទាំងឡាយណា តែងកើតអំពីហេតុ មានសេចក្តីថា បញ្ចក្ខន្ធ ឈ្មោះថា ធម៌មានហេតុជាដែនកើត ។ ព្រះថេរៈសម្តែង ទុក្ខសច្ចៈ ដល់សារីបុត្តនោះដោយពាក្យនោះ ។

បាទគាថាថា តេសំ ហេតុំ តថាគតោ អាហ : ព្រះតថាគត ពោលនូវហេតុនៃធម៌ទាំងឡាយនោះ មានសេចក្តីថា សមុទយសច្ចៈ ឈ្មោះថា ហេតុនៃបញ្ចក្ខន្ធនោះ ព្រះថេរៈសម្តែងថា ព្រះតថាគតត្រាស់ សមុទយសច្ចៈនោះឯង ។

បាទគាថាថា តេសញ្ច យោ និរោធោ : ម្យ៉ាងទៀត សេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយណា មានសេចក្តីថា ព្រះតថាគតត្រាស់សេចក្តីរលត់ គឺ ការមិនប្រព្រឹត្តទៅនៃសច្ចៈ សូម្បីទាំង ២ នោះផង ព្រះថេរៈ សម្តែងនិរោធសច្ចៈដល់សារីបុត្តនោះ ដោយពាក្យនោះ ។ ចំណែកមគ្គសច្ចៈ សូម្បីលោកមិនបានសម្តែងរួមទុកក្នុងគាថានេះ ក៏ឈ្មោះថា សម្តែងហើយដោយន័យ ។ ព្រោះថា កាលពោលនិរោធ មគ្គដែលជាហេតុឱ្យដល់និរោធនោះ ក៏ឈ្មោះថា ពោលហើយផង ។

ម្យ៉ាងទៀត ក្នុងបាទគាថាថា តេសញ្ច យោ និរោធោ នេះ សច្ចៈសូម្បីទាំង ២ ឈ្មោះថា ព្រះថេរៈសម្តែងហើយយ៉ាងនេះថា សេចក្តីរលត់នៃសច្ចៈទាំង ២ នោះ និងឧបាយនៃសេចក្តីរលត់នៃសច្ចៈ ទាំង ២ នោះ ដូច្នេះឯង ។ ឥឡូវនេះ ព្រះថេរៈកាលនឹងញ៉ាំងសេចក្តីនោះឯងឱ្យតជាប់គ្នា ទើបពោលថា ព្រះមហាសមណៈមានប្រក្រតីត្រាស់

យ៉ាងនេះ ។

[៦៦-៩] បាទគាថាថា ឯសេវ ធម្មោ យទិ តាវទេវ : សារីបុត្របរិព្វាជកពោលថា និព្វានធម៌នេះមានប្រាកដមែន មានសេចក្តីថា ប្រសិនបើធម៌ដ៏ក្រៃលែងជាងនេះមិនមាន ធម៌ត្រឹមតែប៉ុណ្ណេះ គឺគុណប៉ុណ្ណោះ កំណត់ប្រមាណថា សោតាបត្តិផល នេះប៉ុណ្ណោះ ដែលខ្ញុំព្រះករុណាគប្បីសម្រេចយ៉ាងនោះ ធម៌នេះឯង ដែលខ្ញុំព្រះករុណាស្វែងរកហើយ[១] ។

បាទគាថាថា បច្ចព្យថា បទមសោកំ : លោកម្ចាស់បានត្រាស់ដឹងនូវនិព្វាន ដែលមិនមានសេចក្តីសោក មានសេចក្តីថា ពួកខ្ញុំព្រះករុណា ត្រាច់ស្វែងរកមកដែលមិនមានសេចក្តីសោកណា លោកទាំងឡាយនុ៎ះឯង រមែងត្រាស់ដឹងមកដែលមិនមានសេចក្តីសោកនោះ អធិប្បាយថា មកនោះ ដែលលោកទាំងឡាយ សម្រេចហើយ ។

កន្លះគាថាថា អទិដ្ឋំ អព្ភតិតំ ពហុកេហិ កប្បនហុតេហិ : ព្រះនិព្វាននោះ ខ្ញុំមិនដែលបានឃើញ មិនដែលបានជួបប្រទះឡើយ

---

១. បាលីក្នុងអដ្ឋកថា ថា តថាបិ ឯសោ ឯវ ធម្មោ ។ យោជនា ពន្យល់ពង្រីកសេចក្តីថា តថាបិ ឯសោ ឯវ មយា គវេសិតោ និព្វានសង្ខាតោ ធម្មោតិ អត្ថោ ។ ទើបបានប្រែទុកយ៉ាងនេះ ឬន័យមួយទៀតថា ធម៌ដែលខ្ញុំព្រះករុណាគន់រកហើយ ក៏ធម៌នេះឯង ។

ដោយម៉ឺននៃកប្បទាំងឡាយជាច្រើន មានសេចក្តីថា មកដែលមិនមានសេចក្តីសោកនេះ ឈ្មោះថា ដែលខ្ញុំព្រះករុណាទាំងឡាយ មិនដែលបានឃើញហើយ មិនដែលបានជួបប្រទះ អស់ម៉ឺននៃកប្បច្រើន សារីបុត្តបរិញ្ញាជក សម្តែងនូវភាវៈនៃខ្លួនមានសេចក្តីសាបសូន្យធំរហូតដល់អស់កាលយូរ ព្រោះហេតុដែលមិនបានឃើញមកនោះ ដោយប្រការដូច្នេះ ។

[៧១] បាទគាថាថា គម្ភីរេ ញាណវិសយេ : ក្នុងធម៌ដ៏ជ្រាលជ្រៅ ក្នុងញាណវិស័យ មានសេចក្តីថា ជាធម៌ដែលជ្រាលជ្រៅផង ជាវិស័យនៃញាណដ៏ជ្រាលជ្រៅផង ។

បាទគាថាថា អនុត្តរេ ឧបធិសង្ខយេ : ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏ប្រសើរ បានដល់ ព្រះនិព្វាន ។

បទថា វិមុត្តេ : ដែលមានចិត្តយាងចុះ មានសេចក្តីថា អ្នកនោះផុតហើយដោយវិមុត្តិ មានព្រះនិព្វាននោះជាអារម្មណ៍ ។

បទថា ព្យាកាសិ : ព្យាករនូវជនទាំងពីរនោះ មានសេចក្តីថា ព្រះសាស្តាកាលត្រាស់ថា “ឯតំ មេ សាវកយុគំ ភវិស្សតិ អគ្គំ ភទ្ទយុគំ : ហ្នឹងហើយជាគូនៃសាវករបស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន” ដូច្នេះ ឈ្មោះថា ទ្រង់ព្យាករណ៍ហើយនូវគូនៃសាវកបារមីញាណ ។

[៧២] ពាក្យថា សា វ តេសំ អាយស្មន្តានំ ឧបសម្បទា អហោសិ : ព្រះពុទ្ធដីកានេះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងនោះ មានសេចក្ដីថា ឯហិភិក្ខុឧបសម្បទានោះឯង បានជាឧបសម្បទារបស់អ្នកទាំង ២ ព្រមទាំងបរិស័ទ ។

ក៏ឯក្នុងព្រះថេរៈទាំង ២ ដែលឧបសម្បទាហើយយ៉ាងនោះ ព្រះមហាមោគ្គល្លានត្ថេរ ៧ ថ្ងៃ ទើបបានសម្រេចព្រះអរហត្ត ព្រះសារីបុត្តត្ថេរកន្លះខែ ទើបបានសម្រេចព្រះអរហត្ត ។

បានឮថា ក្នុងអតីតកាល ព្រះពុទ្ធព្រះនាមថា អនោមទស្សី ស្ដេចឧប្បត្តិ ក្នុងលោក ។ តាបសឈ្មោះសរទៈ ធ្វើមណ្ឌបដោយផ្កាឈើផ្សេង ៗ ក្នុងអាស្រមរបស់ខ្លួន ដើម្បីព្រះពុទ្ធនោះ យាងព្រះមានព្រះភាគឱ្យប្រថាប់លើអាសនៈផ្កា ឈើនោះ ធ្វើមណ្ឌបយ៉ាងនោះឯង តាក់តែងអាសនៈផ្កាឈើសម្រាប់ភិក្ខុសង្ឃផង ហើយប្រាថ្នាជាអគ្គសាវក ក៏ឯគ្រាប្រាថ្នាហើយ ទើបបញ្ជូនដំណឹងទៅប្រាប់ដល់សេដ្ឋីឈ្មោះសិរិវឌ្ឍនៈថា "ខ្ញុំបានប្រាថ្នាតំណែងអគ្គសាវកហើយ សូម្បីលោកក៏ចូរមកប្រាថ្នាតំណែងមួយ" ។ សេដ្ឋីធ្វើមណ្ឌបផ្កាឧប្បលខៀវ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជា ប្រធានឆាន់ក្នុងមណ្ឌបនោះ កាលនិមន្តឆាន់រួចស្រេចហើយ បានប្រាថ្នាជាសាវក ទី ២, បណ្ដាជនទាំង ២ នោះ សរទតាបសបានជាព្រះ

សារីបុត្តត្ថេរ សិរីវឌ្ឍនសេដ្ឋី បានជាព្រះមហាមោគ្គល្លានត្ថេរ ដូច្នេះឯង បុព្វកម្មរបស់ព្រះអគ្គសាវកទាំង ២ នោះប៉ុណ្ណេះ[១] ។

[៧៣] វិនិច្ឆ័យក្នុងបទថា អបុត្តកតាយ : ដើម្បីធ្វើមនុស្ស មិនឲ្យមានកូន ជាដើម ដូចតទៅនេះ ៖

ព្រះសមណគោតមបដិបត្តិដើម្បីធ្វើជនទាំងឡាយ ដែលមានបុត្រ បួស ឲ្យជាអ្នកគ្មានបុត្រ ដើម្បីធ្វើស្រីទាំងឡាយដែលមានប្តីបួស ត្រូវជាមេមាយ គឺ ត្រូវជាមនុស្សដែលប្តីលះបង់ចោលហើយ ។ ដើម្បីចូលទៅកាត់ត្រកូល សូម្បីដោយអាការទាំង ២ យ៉ាង ។

បទថា សញ្ជយានិ : ជាពួកសញ្ជ័យ គឺ អ្នកជាអន្តេវាសិករបស់សញ្ជ័យ ។

ពីរបទថា មាគធានំ គិរិព្វជំ : យាងមកហើយកន់ក្រុងគិរិព្វជ: (ភ្នំមានសណ្ឋានដូចក្រោល) មានសេចក្តីថា កាន់គិរិព្វជនគរនៃជនបទរបស់អ្នកនគរមគធ: ។

[៧៣] បទថា មហាវីរា : មានសេចក្តីព្យាយាមដ៏មាំ បានដល់អ្នកមានសេចក្តីព្យាយាមធំ ។

---

១. ឈ្មោះនេះត្រូវនឹងអដ្ឋកថាធម្មបទ, តែក្នុងអបទានថា ពីដើមព្រះសារីបុត្តឈ្មោះសុរុចិតាបស ព្រះមោគ្គល្លានជាស្តេចនាគឈ្មោះ អរុណ ។

បទថា **នីយមានានំ** : ជាអ្នកណែនាំសត្វ មានសេចក្ដីថា កាលកុលបុត្រទាំងឡាយ ដែលព្រះអង្គទ្រង់ណែនាំ ។ បទថា **នីយមានានំ** នេះជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថនៃសត្តមីវិភត្តិន័យមួយទៀត ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។

បាទគាថាថា **កា ឧស្សុយ្យា**[១] **វិជានតំ** : ហេតុដូចម្ដេច ក៏មានសេចក្ដីប្រណែន មានសេចក្ដីថា នឹងត្រូវឫស្យាអ្វីផងសោត កាលដឹងយ៉ាងនេះថា ព្រះតថាគតទាំងឡាយ ទ្រង់ណែនាំដោយធម៌ ។

ពណ៌នាសារីបុត្តមោគ្គល្លានបព្វជ្ជា ចប់

## ឧបជ្ឈាយវត្ត

[៧៧] បទថា **អនុបជ្ឈាយកា** : មិនមានឧបជ្ឈាយ៍ មានសេចក្ដីថា វៀរចាកគ្រូដែលចាំសម្លឹងនូវទោសតូចនិងទោសធំ ។

បទថា **អនាកប្បសម្បន្នា** : ឫកមារយាទក៏មិនបរិបូរណ៍, បានដល់ អ្នកមិនដល់ព្រមដោយមារយាទ ។ អធិប្បាយថា ប្រាសចាកមារយាទដែលសមគួរដល់សមណៈ ។

១. ថៃ. ឧស្សុយា; ភូមា. ឧសូយា ។

[៧៩] បទថា ឧបរិភោជនេ : ទៅពីខាងលើភោជន បានដល់ខាងលើនៃភោជន ។

បទថា ឧត្តិដ្ឋបត្តំ : បាត្រសម្រាប់សូម បានដល់ បាត្រសម្រាប់ត្រាច់ទៅដើម្បីបិណ្ឌបាត មែនពិត មនុស្សទាំងឡាយមានសេចក្ដីសម្គាល់ក្នុងបាត្រនោះថា ជាដែល(គឺសំណល់) ព្រោះហេតុនោះ លោកទើបពោលថា ឧត្តិដ្ឋបត្តំ ។ម្យ៉ាងទៀត អ្នកសិក្សាគប្បីឃើញសេចក្ដីក្នុងបទថា ឧត្តិដ្ឋបត្តំ នេះយ៉ាងនេះថា ភិក្ខុទាំងឡាយឈរឡើងបង្អោនបាត្រចូលទៅ ។

[៨០] ពាក្យថា អនុជានាមិ ភិក្ខវេ ឧបជ្ឈាយំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបជ្ឈាយ៍ មានសេចក្ដីថា តថាគតអនុញ្ញាត ដើម្បីឱ្យភិក្ខុកាន់យកនូវឧបជ្ឈាយ៍ ។

ពីរបទថា បុត្តចិត្តំ ឧបដ្ឋបេស្សតិ : យកចិត្តទុកដាក់ឱ្យដូចជាកូន មានសេចក្ដីថា ព្រះឧបជ្ឈាយ៍នឹងចូលទៅតាំងចិត្ត ទុកដោយអំណាចសេចក្ដីស្រឡាញ់ ដូចបិតានិងបុត្រយ៉ាងនេះថា អ្នកនេះជាបុត្ររបស់យើង សូម្បីក្នុងបទទីពីរក៏ន័យនេះ ។

ពីរបទថា សគារវា សប្បតិស្សា : ប្រកបដោយសេចក្ដីគោរពកោតក្រែង មានសេចក្ដីថា ឧបជ្ឈាយ៍ និងសទ្ធិវិហារិក នឹងចូលទៅតាំង

ភាវៈជាអ្នកជូន និងភាវៈជាអ្នកជំដល់គ្នានិងគ្នា ។

បទថា **សភាគវុត្តិកា : មានការចិញ្ចឹមជីវិតស្មើគ្នា** បានដល់មានភាវៈ ជាអ្នករស់នៅត្រូវគ្នា ។

ប្រាំបទ មានបទថា **សាហូតិ វា : កម្មនេះប្រពៃហើយក្តី** ជាដើម ជាវេវចនៈ នៃពាក្យទទួលជាឧបជ្ឈាយ៍ ។

ពីរបទថា **កាយេន វិញ្ញាបេតិ : ឱ្យដឹងដោយកាយ** មានសេចក្តីថា កាលសទ្ធិវិហារិកពោល ៣ ដងថា "បពិត្រលោកដ៏ចម្រើន សូមលោកជាឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាចុះ" ។ យ៉ាងនោះហើយ បើព្រះឧបជ្ឈាយ៍ ទទួលការកាន់យកឧបជ្ឈាយ៍ថា "ឧបជ្ឈាយ៍ដែលអ្នកកាន់ហើយ" ដូច្នេះ ដោយកាយឬវាចា ឬទាំងកាយទាំងវាចា ដោយអំណាចនៃបទមួយ ៗ ក្នុងប្រាំបទ មាន សាហុ ជាដើម ឧបជ្ឈាយ៍ ឈ្មោះថា សទ្ធិវិហារិកកាន់យកហើយ ។

ពិតមែន ការប្រើវាចាប្រកាស ឬការប្រើកាយកម្រើកឱ្យដឹងសេចក្តីនៃបទណាបទមួយ ក្នុងប្រាំបទនេះ របស់ព្រះឧបជ្ឈាយ៍នេះឯង ជាការកាន់ឧបជ្ឈាយ៍ ក្នុងពាក្យថា **គប្បីកាន់ឧបជ្ឈាយ៍** នេះ ។ ចំណែកគេចិអាចារ្យ ពោលសំដៅយកពាក្យទទួលថា "សាធុ" ពាក្យរបស់គេចិអាចារ្យនោះ មិនជាប្រមាណ ។ ព្រោះថា ឧបជ្ឈាយ៍ រមែងជាការ

ដែលសទ្ធិវិហារិកកាន់ហើយ ដោយហេតុត្រឹមតែថា ពាក្យសូមនិងពាក្យឱ្យ ពាក្យទទួលមិនរាប់ថា ជាអង្គក្នុងការកាន់ឧបជ្ឈាយ៍នេះ ។ ចំណែកសទ្ធិវិហារិកនឹងគួរជ្រាបត្រឹមតែថា "ឧបជ្ឈាយ៍ឈ្មោះថា យើងកាន់ហើយ"ដោយបទនេះ ក៏ទេ គួរជ្រាបសេចក្តីនេះដោយពាក្យថា "ឥឡូវនេះ មានថ្ងៃនេះជាដើម ព្រះថេរៈជាភារៈរបស់យើង សូម្បីយើងក៏ជាភារៈរបស់ព្រះថេរៈ" ។

[៨១] ពាក្យថា តត្រាយំ សម្មាវត្តនា : ឯការប្រព្រឹត្តដោយប្រពៃក្នុងឧបជ្ឈាយ៍នោះ( ដូច្នេះ ) មានសេចក្តីថា ពាក្យណា ដែលយើងពោលហើយថា គប្បីប្រព្រឹត្តដោយប្រពៃ, ការប្រព្រឹត្តដោយប្រពៃក្នុងពាក្យនោះ ដូច្នេះ ។

ច្រើនបទថា កាលស្សេវ ឧដ្ឋាយ ឧបាហនា ឱមុញ្ចិត្វា : ត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង មានសេចក្តីថា បើស្បែកជើងរបស់សទ្ធិវិហារិកនោះ ដែលលោកកំពុងពាក់ គឺ ជារបស់ដែលនៅក្នុងជើង ដើម្បីប្រយោជន៍ដល់ការចង្រ្កមក្នុងវេលាជិតភ្លឺ ឬដើម្បីប្រយោជន៍ដល់ការរក្សាជើងដែលលាងហើយ ។ គប្បីក្រោកឡើងពីព្រឹកព្រលឹមដោះស្បែកជើងទាំងនោះចេញ ។

ពាក្យថា ទន្តកដ្ឋំ ទាតព្វំ : រូបប្រគេនឈើស្ទន់ មានសេចក្តី

ថា គប្បីបង្អោនថ្វាយ ឈើស្ទន់ ៣ ខ្នាត គឺ ខ្នាតធំ ខ្នាតកណ្តាល ខ្នាតតូច ចាកពី ៣ ខ្នាតនោះ លោកកាន់យកខ្នាតណាគ្រប់ ៣ ថ្ងៃ តាំងពីថ្ងៃទី ៤ ទៅ គប្បីថ្វាយខ្នាតនោះប៉ុណ្ណោះ បើថា លោកកាន់យកតាមមាន តាមបាន មិនមានកំណត់ចុះទៅ តទៅបានប្រភេទណា គប្បីថ្វាយប្រភេទនោះ ៗ

ពាក្យថា **មុខោទកំ ទាតព្វំ :** ប្រគេនទឹកលុបមុខ មានសេចក្តីថា គប្បីនាំចូលទៅទាំងទឹកត្រជាក់ និងទឹកក្តៅ លោកប្រើយ៉ាងណា អំពីទឹក ២ យ៉ាងនោះ គ្រប់ ៣ ថ្ងៃ តាំងពីថ្ងៃទី ៤ ទៅគប្បីថ្វាយទឹកលាងមុខប្រភេទនោះប៉ុណ្ណោះ បើថា លោកប្រើតាមមាន តាមបាន មិនកំណត់តទៅបានប្រភេទណា គប្បីថ្វាយប្រភេទនោះ ៗ បើថា លោកប្រើទាំង ២ យ៉ាង ៗ គប្បីនាំចូលទៅថ្វាយទាំង ២ យ៉ាង ៗ គប្បីតាំងទឹកទុកក្នុងទីលាងមុខហើយ គប្បីបោសតាំងពីវច្ចកុដិមក ៗ កាលព្រះថេរៈទៅវច្ចកុដិ គប្បីបោសបរិវេណ ៗ ដោយប្រការយ៉ាងនេះ បរិវេណជាការមិនស្មាត់ ៗ គប្បីតាំងអាសនៈ ទុកតាំងពីកាលព្រះថេរៈមិនទាន់ចេញពីវច្ចកុដិតែម្តង កាលលោក ធ្វើសរីរកិច្ចរួចស្រេចហើយ មកអង្គុយលើអាសនៈនោះ គប្បីធ្វើវត្តតាមដែលពោលទុកដោយន័យជាដើមថា បើបបរមាន គប្បីថ្វាយ ៗ

បទថា ឧក្លាបោ : សម្រាម មានសេចក្តីថា ដេរដាស់ដោយសម្រាមយ៉ាងណាមួយ តែបើមិនមានសម្រាមដទៃ មានតែដំណក់ទឹកទីកន្លែងនោះ គួរជូតសូម្បីដោយដៃ ។

ពីរបទថា សគុណំ កត្វា : ដែលត្រួតគ្នាហើយ មានសេចក្តីថា គប្បីត្រួតចីវរ ២ ផ្ទាំងចូលជាមួយគ្នាហើយ ថ្វាយសង្ឃាដិទាំង ២ ផ្ទាំងដែលត្រួតហើយនោះ ។ ពិតមែន ចីវរទាំងអស់ ហៅថា សង្ឃាដិ ព្រោះត្រួតគ្នាទុក ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "សង្ឃាដិយោ ទាតព្វា : ប្រគេនសង្ឃាដិទាំងឡាយ" ។

ក្នុងពាក្យថា នាតិទូរេ គន្តព្វំ នាច្ចាសន្នេ : មិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក នេះ មានវិនិច្ឆ័យថា បើដោយជំហានជើងត្រឹមតែមួយជំហាន ២ ជំហាន នឹងទៅដល់ឧបជ្ឈាយ៍ ដែលក្រឡេកមកមើលដោយចម្ងាយត្រឹមតែប៉ុណ្ណេះ គប្បីជ្រាបថា ជាអ្នកដើរមិនឆ្ងាយលោក មិនជិតលោក ។

ពាក្យថា បត្តបរិយាបន្នំ បដិគ្គហេតព្វំ : គប្បីទទួលយកវត្ថុដែលដាក់ចុះក្នុងបាត្រ មានសេចក្តីថា បើឧបជ្ឈាយ៍បានបបរឬបាយក្នុងទីភិក្ខាចារហើយ បាត្រក្តៅឬធ្ងន់ គប្បីថ្វាយបាត្ររបស់ខ្លួនដល់លោក ទទួលបាត្រនោះមក ។

ពាក្យថា ន ឧបជ្ឈាយស្ស ភណមានស្ស អន្តរន្តរា កថា ឱបាតេតព្វា : ឧបជ្ឈាយ៍កំពុងពោល **សទ្ធិវិហារិកមិនត្រូវនិយាយស្កាត់ពាក្យនោះឡើយ** មានសេចក្ដីថា កាលឧបជ្ឈាយ៍កំពុងអង្គុយនិយាយនៅក្នុងចន្លោះស្រុក ឬក្នុងទីដទៃ កាលពាក្យរបស់លោកមិនទាន់ចប់ មិនគួរនិយាយស្កាត់រឿងដទៃឡើយ ។

ក៏ឯតាំងពីនេះទៅ ក្នុងទីណា ៗ លោកធ្វើការហាមទុកដោយ ន អក្សរ ដែលប្រែថា មិន ឬ កុំ, ក្នុងទីនោះគ្រប់កន្លែង គប្បីជ្រាបថាជាអាបត្តិទុក្កដ ។ ពិតមែន សេចក្ដីនេះ ជាធម្មតាក្នុងខន្ធកៈ ។

ពាក្យថា អាបត្តិសាមន្តា ភណមានោ : **ឧបជ្ឈាយ៍កំពុងពោលនូវពាក្យជាទំនងនឹងត្រូវអាបត្តិ** មានសេចក្ដីថា កាលឧបជ្ឈាយ៍ពោលវាចាជិតត្រូវអាបត្តិ ដោយអំណាចបទសោធម្មសិក្ខាបទ និងទុដ្ឋុល្លសិក្ខាបទជាដើម ។

បទថា និវារេតព្វោ : **សទ្ធិវិហារិកត្រូវឃាត់** សេចក្ដីថា គប្បីហាមជារបៀបសួរយ៉ាងនេះថា "និយាយដូច្នេះ គួរឬលោកម្ចាស់ មិនជាអាបត្តិឬ ?" តែតាំងចិត្តថា នឹងហាមហើយ ក៏មិនគួរនិយាយនឹងលោកថា "លោកម្ចាស់ កុំនិយាយយ៉ាងនោះ" ។

ពាក្យថា បឋមតរំ អាគន្ត្វា : **សទ្ធិវិហារិកត្រូវត្រឡប់មកមុន**

ឧបជ្ឈាយ៍ មានសេចក្តីថា បើស្រុកនៅជិត ឬក្នុងវិហារមានភិក្ខុឈឺ គប្បីត្រឡប់មកអំពីស្រុកជាមុន ។ បើស្រុកនៅឆ្ងាយ មិនមានអ្នកណាមកជាមួយឧបជ្ឈាយ៍ គួរចេញពីស្រុកជាមួយឧបជ្ឈាយ៍តែម្តង ហើយយកចីវរចង់បាត្រស្ពាយ ប្រញាប់មកមុនតាំងពីកណ្តាលមក កាលត្រឡប់យ៉ាងនេះមកដល់មុនហើយ គប្បីធ្វើវត្តគ្រប់យ៉ាង មានក្រាលអាសនៈជាដើម ។

ពីរបទថា សិន្នំ ហោតិ : សើមដោយញើសក្អែល មានសេចក្តីថា ជារបស់សើម គឺទទឹកដោយញើស ។

ពាក្យថា ចតុរង្គុលំ កណ្ណំ ឧស្សារេត្វា : ត្រូវបំផ្លើសជាយម្ខាងឱ្យលើសប្រមាណ ៤ ធ្នាប់ មានសេចក្តីថា គប្បីធ្វើមុំឱ្យលើសពីគ្នាប្រមាណ ៤ ធ្នាប់ ត្រូវបត់ចីវរយ៉ាងនេះ ព្រោះហេតុអ្វី ? ព្រោះតាំងចិត្តនឹងមិនឱ្យបាក់ត្រង់កណ្តាល ។ ពិតមែន ចីវរដែលបត់ឱ្យមុំស្មើគ្នារមែងបាក់ត្រង់កណ្តាល ។ ចីវរដែលបាក់ផ្ទត់ជានិច្ចព្រោះបត់ដូច្នោះរមែងទ្រុឌទ្រោម ។ ព្រះមានព្រះភាគត្រាស់ពាក្យនេះ ក៏ដើម្បីការពារសេចក្តីទ្រុឌទ្រោមនោះ ។ ព្រោះហេតុនោះ ក្នុងថ្ងៃស្អែកចីវរនឹងមិនបត់ចំត្រង់ទីដែលបាក់ក្នុងថ្ងៃនេះ ដោយវិធីណា គប្បីបត់ឱ្យហួសគ្នាមួយថ្ងៃ ៤ ធ្នាប់ដោយវិធីនោះ ។

ពាក្យថា ឱភោគេ កាយពន្ធនំ កាតព្វំ : ហើយគប្បីដាក់វត្ថពន្ធបង្កេះផ្ទែកខាងក្នុងមានសេចក្តីថា គប្បីបត់វត្ថពន្ធបង្កេះ ទុកដាក់ក្នុង

ផ្ទត់ចីវរ ។

ពាក្យថា **សចេ បិណ្ឌបាតោ ហោតិ** : បើបិណ្ឌបាតមាន នេះមានវិនិច្ឆ័យថា ឧបជ្ឈាយ៍ណា ឆាន់ក្នុងស្រុកនុ៎ះឯង ឬក្នុងចន្លោះស្រុក ឬក្នុងបន្ទប់ឆាន់ហើយ ទើបមក ឬមិនបានបិណ្ឌបាត ។ បិណ្ឌបាតរបស់ឧបជ្ឈាយ៍នោះ ឈ្មោះថា មិនមាន តែរបស់ឧបជ្ឈាយ៍អ្នកមិនបានឆាន់ក្នុងស្រុកឬអ្នកបានភិក្ខា ឈ្មោះថា មាន ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា បើបិណ្ឌបាតមាន បើសូម្បីបិណ្ឌបាតរបស់លោកមិនមាន និងលោកប្រាថ្នានឹងឆាន់ គប្បីថ្វាយទឹកហើយ បង្អោនថ្វាយបិណ្ឌបាត សូម្បីដែលខ្លួនបានហើយ ។

ពាក្យថា **បានីយេន បុច្ឆិតព្វោ** : ត្រូវសួរអំពីទឹកឆាន់ មានសេចក្ដីថា គប្បីសួរឧបជ្ឈាយ៍ដែលកំពុងឆាន់ ដល់ទឹកឆាន់ ៣ ដងថា ខ្ញុំព្រះករុណា នឹងនាំទឹកឆាន់មកបានឬ លោកម្ចាស់ ? បើពេលសមគួរកាលឧបជ្ឈាយ៍ឆាន់រួចហើយ ខ្លួនឯងសឹមឆាន់ ។ បើវេលាជិតអស់ គប្បីតាំងទឹកឆាន់ទុកក្នុងទីជិតឧបជ្ឈាយ៍ ហើយខ្លួនឯង គប្បីឆាន់ខ្លះ ។

ពាក្យថា **អនន្តរហិតាយ** : មិនត្រូវតម្កល់ទុកបាត្រលើទីដែលមិនសមគួរ មានសេចក្ដីថា មិនគួរដាក់បាត្រលើផែនដីដែលលាយដោយ

ធូលីនិងគ្រួស មិនបានក្រាលដោយកម្រាល មានកន្ទេលទន់ និងកំណាត់ស្បែកជាដើម ប្រភេទណាមួយ ។ តែបើផែនដីជាទីដែលគេលាបម្រាក់[1] ឬបូកដោយកំបោរ ឬមិនមានលំអងនិងដី ទឹងដាក់លើផែនដីបែបនោះគួរ ។ ទឹងដាក់សូម្បីលើខ្សាច់ដែលស្អាត ក៏គួរ ។ ទឹងដាក់លើ អាចម៍ដីនិងគ្រួសជាដើម មិនគួរ ។ តែគប្បីដាក់ស្លឹកឈើ ឬជើងបាត្រលើវត្ថុទាំងនោះហើយ រក្សាបាត្រលើស្លឹកឈើ ឬជើងបាត្រនោះចុះ ។

ពាក្យថា **ធ្វើនូវជាយនៃចីវរខាងនាយឱ្យជាផ្នត់ខាងអាយ**[2] នេះ ព្រះមានព្រះភាគត្រាស់ទុក ដើម្បីឱ្យលូកដៃទៅក្រោមស្នួរចីវរជាដើម ហើយ ពាក់សន្ទ្រឹម ៗ ដោយដៃដែលនៅត្រង់មុខ ។ ក៏កាលចាប់ជាយទាំង ២ យកផ្នត់ពាក់ឡើងទៅលើស្នួរចីវរជាដើម ផ្នត់រមែងប៉ះខ្ទប់ជញ្ជាំង ព្រោះហេតុនោះ ទើបមិនគួរធ្វើយ៉ាងនោះ ។

ពាក្យថា **ចុណ្ណំ សន្នេតព្វំ : ត្រូវលាយគ្រឿងលំអិត** មានសេចក្ដីថា លំអិតសម្រាប់ងូតទឹក គប្បីឱ្យជោគដោយទឹកហើយពូតជាដុំទុក ។

ពាក្យថា **ឯកមន្តំ និក្ខិបិតព្វំ : ត្រូវយកបាត្រចីវរទៅតម្កល់**

---

១. បាឋៈក្នុងអដ្ឋកថាថា **កាឡវណ្ណកតា** ធ្វើហើយឱ្យមានពណ៌ខ្មៅ ។

២. ខាងនាយ គឺខាងក្រៅ, ខាងអាយ គឺខាងក្នុង ។

ទុកក្នុងទីដ៏សមគួរ មានសេចក្តីថា ចីវរគប្បីដាក់តែក្នុងទីដែលមិនមានផ្សែងភ្លើងណាមួយ ។ កិច្ចទាំងពួងមានឱ្យរងើកភ្លើង ដីនិងទឹកក្តៅជាដើម ឈ្មោះថា បរិកម្មក្នុងរោងភ្លើង ។

ពាក្យថា ឧទកេបិ បរិកម្មំ : ត្រូវធ្វើបរិកម្មក្នុងទឹក បានដល់កិច្ចគ្រប់យ៉ាងមានដុសខ្លួនជាដើម ។

ពាក្យថា ធានីយេន បុច្ឆិតព្វោ : ត្រូវសួរអំពីទឹកឆាន់ មានសេចក្តីថា សេចក្តីស្រេក រមែងមាន ព្រោះសេចក្តីក្តៅស្អុះក្នុងរោងភ្លើង ព្រោះដូច្នោះ ទើបគួរ សួរលោកអំពីទឹកឆាន់ ។ ពាក្យថា សចេ ឧស្សហតិ : បើសទ្ធិវិហារិកអាចធ្វើបាន មានសេចក្តីថា បើសទ្ធិវិហារិកអាច គឺជាអ្នកមិនមានជម្ងឺយ៉ាងណាមួយគ្របសង្កត់ ។ ពិតមែន សទ្ធិវិហារិកដែលមិនមានជម្ងឺ សូម្បីមានវស្សា ៦០ ក៏គួរធ្វើឧបជ្ឈាយ៍វត្តគ្រប់យ៉ាង កាលមិនធ្វើ ដោយមិនអើពើ ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ, និងកាលសទ្ធិវិហារិកដែលមានជម្ងឺ ទៅធ្វើការដែលទ្រង់ហាម ក្នុងបទទាំងឡាយដែលមានអក្សរថា "ន : មិន" ជាប់តាម ក៏ជាទុក្កដដូចគ្នា ។

បទថា អបរិឃំសន្តេន : កុំឱ្យទង្គិចទង្គុកនឹងផែនដី មានសេចក្តីថា កុំអូសទៅលើផែនដី ។

បទថា កវាដបិដ្ឋំ : កុំឱ្យប៉ះក្របទ្វារ មានសេចក្តីថា កុំឱ្យប៉ះ

ទន្តិចសន្ទះទ្វារ និងក្របទ្វារ ។

បទថា សន្ដានកំ : គ្រឿងស្អុកស្អាញ បានដល់ សំបុកកន្ទាត និងសរសៃពីងពាងជាដើមយ៉ាងណាមួយ ។

ពាក្យថា ឱល្លោកា បឋមំ ឱហារេតព្វំ : ត្រូវបោសតាំងអំពីពិតានជាមុន មានសេចក្ដីថា គប្បីបោសតាំងពីពិតានជាមុន គឺ បោសពិតានជាដើមចុះមក ។

បទថា អាលោកសន្ធិកណ្ណភាគា : កន្លៀតជ្រុងសន្ទះបង្អួច បានដល់ ចំណែកសន្ទះទ្វារ និងចំណែកកន្លៀតជ្រុង (សន្ទះទ្វារ) ។ អធិប្បាយ គប្បីជូតសន្ទះបង្អួច និងសន្លឹកទ្វារទាំងខាងក្នុងខាងក្រៅ ទាំង ៤ ជ្រុង ។

ពាក្យថា យថាបញ្ញត្តំ បញ្ញាបេតព្វំ : ត្រូវនាំយកមកក្រាលដូចដើមវិញ មានសេចក្ដីថា កម្រាលផែនដីពីដើមគេក្រាលទុកយ៉ាងណា គប្បីក្រាលទុកដូចយ៉ាងនោះ ។ ពិតមែន ដើម្បីប្រយោជន៍នេះឯង ទើបទ្រង់បញ្ញត្តិវត្តទុកជាដំបូងថា គប្បីសង្កេតទីដែលក្រាលពីដើម ទុកហើយជញ្ជូន ចេញទៅដាក់ទុកចំណែកមួយ ។ តែបើកម្រាលផែនដីនោះ ជារបស់អ្នកខ្លះដែលមិនដឹង បានក្រាលទុកមុន គប្បីក្រាលឱ្យឆ្ងាយជញ្ជាំងដោយជុំវិញត្រឹមតែ ២ ធ្នាប់ ឬ ៣ ធ្នាប់ ។

តាមធម្មទំនៀមការក្រោលមានដូច្នេះ ៖

បើមានកន្ទេលផែនធំពេក គប្បីកាត់ជាយបត់ដេរចងហើយ សឹមក្រាល បើមិនចេះបត់ជាយដេរចង កុំគប្បីកាត់ ។

ពាក្យថា បុរត្ថិមា វាតបានា ជកោតព្វា : ត្រូវបិទបង្អួចទិសខាងកើត មានសេចក្តីថា គប្បីបិទបង្អួចខាងកើត ។ បង្អួចសូម្បីដ៏សេសក៏គប្បីបិទយ៉ាងនោះ ។

បទថា វូបកាសេតព្វោ : ត្រូវនាំចៀសចេញទៅ មានសេចក្តីថា ខ្លួនឯងគប្បីនាំទៅទីដទៃ ។

បទថា វូបកាសាបេតព្វោ : ត្រូវឱ្យភិក្ខុដទៃនាំចៀសចេញទៅ មានសេចក្តីថា គប្បីពឹងពាក់ភិក្ខុដទៃថា "សូមលោកជួយនាំព្រះថេរៈទៅទីដទៃចុះ" ។

បទថា វិវេចេតព្វំ : ត្រូវដោះស្រាយ មានសេចក្តីថា ខ្លួនឯងគប្បីនិយាយឱ្យលោកលះបង់ចេញ ។

បទថា វិវេចាបេតព្វំ : ត្រូវឱ្យភិក្ខុដទៃដោះស្រាយ មានសេចក្តីថា គប្បីពឹងអ្នកដទៃថា "សូមលោកជួយនិយាយឱ្យព្រះថេរៈលះបង់ទិដ្ឋិអាក្រក់" ។

ពាក្យថា ឧស្សុក្កំ កាតព្វំ : ត្រូវធ្វើសេចក្តីខ្វល់ខ្វាយ មាន

សេចក្តីថា ភិក្ខុនោះ ដែលសទ្ធិវិហារិក គប្បីចូលទៅរកសង្ឃ សូមអង្វរដើម្បីឱ្យបរិវាស បើសទ្ធិវិហារិកជាអ្នកអាចដោយខ្លួនឯង គប្បីឱ្យបរិវាសដោយខ្លួនឯង បើមិនអាច គប្បីពឹងភិក្ខុដទៃឱ្យជួយ ។

ពាក្យថា កិន្តិ នុ ខោ : ដោយឧបាយដូចម្តេចហ្ន៎ មានសេចក្តីថា ដោយឧបាយយ៉ាងណាហ្ន៎ ។ មានន័យដូចគ្នាគ្រប់កន្លែង ។

ពាក្យថា លហុកាយ វា បរិណាមេយ្យ : ឬសង្ឃគប្បីបង្អោនទៅដើម្បីកម្មស្រាល មានសេចក្តីថា សង្ឃកុំគប្បីធ្វើឧក្ខេបនីយកម្មឡើយ គប្បីធ្វើតជ្ជនីយកម្ម ឬ និយស្សកម្មជំនួស ។

ពិតមែន សទ្ធិវិហារិកនោះបានជ្រាបថា សង្ឃប្រាថ្នានឹងធ្វើឧក្ខេបនីយកម្មដល់ឧបជ្ឈាយ៍របស់យើង គប្បីចូលទៅរកភិក្ខុមួយរូបអង្វរថា "បពិត្រលោកម្ចាស់ សូមកុំធ្វើកម្មដល់ឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាឡើយ", បើភិក្ខុទាំងឡាយ នឹងធ្វើតជ្ជនីយកម្ម ឬនិយស្សកម្មឱ្យបាន ។ គប្បីអង្វរលោកទាំងឡាយថា "មេត្តាកុំធ្វើឡើយ" ។ បើភិក្ខុទាំងឡាយនឹងធ្វើពិត ៗ, គ្រានោះ គប្បីអង្វរឧបជ្ឈាយ៍ថា "បពិត្រលោកម្ចាស់ សូមត្រឡប់ប្រព្រឹត្តដោយប្រពៃវិញចុះ" កាលអង្វរឱ្យលោកត្រឡប់ប្រព្រឹត្តដោយប្រពៃបានយ៉ាងនោះ គប្បីអង្វរភិក្ខុទាំងឡាយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមមេត្តារម្ងាប់កម្មចុះ" ។

ពីរបទថា សម្បរិវត្តកំ សម្បរិវត្តកំ : ប្រែត្រឡប់ឱ្យសព្វល្អ បានដល់ បង្វិលប្ដូរដោយជុំវិញ ។

ពាក្យថា ន ច អច្ឆិន្នេ ថេវេ បក្កមិតព្វំ : បើដំណក់ទឹកមិនទាន់ដាច់ទេ សទ្ធិវិហារិកមិនត្រូវចៀសចេញទៅឡើយ មានសេចក្ដីថា បើទឹកជ្រលក់សូម្បីត្រឹមតែបន្តិចបន្តួច នៅមានដំណក់ កុំគប្បីជៀសចេញទៅ ។

វត្តគ្រប់យ៉ាង មានជាដើមថា មិនទាន់បានប្រាប់ឧបជ្ឈាយ៍ កុំឱ្យបាត្រដល់ភិក្ខុពួកខ្លះ ដូច្នេះ ព្រះមានព្រះភាគ ត្រាស់សម្រាប់ បុគ្គលដែលជាវិសភាគរបស់ឧបជ្ឈាយ៍ ។

ពាក្យថា ន ឧបជ្ឈាយំ អនាបុច្ឆា គាមោ បវិសិតព្វោ : សទ្ធិវិហារិកមិនបានលាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុកទេ មានសេចក្ដីថា សទ្ធិវិហារិកប្រាថ្នានឹងចូលទៅដើម្បីបិណ្ឌបាត ឬដោយករណីយ៍យ៉ាងដទៃ គប្បីពោលលាជាមុនសិន សឹមចូលទៅ ។

បើឧបជ្ឈាយ៍ប្រាថ្នានឹងក្រោកឡើងតាំងអំពីព្រឹកទៅភិក្ខាចារឆ្ងាយ គប្បីផ្ដាំទុកថា "ពួកភិក្ខុកំលោះចូរទៅបិណ្ឌបាតចុះ" ហើយសឹមទៅ ។

កាលឧបជ្ឈាយ៍មិនបានផ្ដាំទុកទេ ចេញទៅ សទ្ធិវិហារិកទៅដល់បរិវេណ មិនឃើញឧបជ្ឈាយ៍នឹងចូលស្រុក ក៏គួរ ។

បើសូម្បីកំពុងចូលទៅក្នុងស្រុក និងជួប គួរនឹងពោលលា តាំងពីទីដែលជួបតែម្តង ។

ពាក្យថា ន សុសានំ គន្តព្វំ : **មិនត្រូវទៅកាន់ព្រៃស្មសាន** មានសេចក្តីថា មិនទៅដើម្បីត្រូវការនៅ ឬដើម្បីត្រូវការមើល ។

ក្នុងពាក្យថា ន ទិសា បក្កមិតព្វា : **មិនត្រូវចៀសទៅកាន់ទិសឡើយ** នេះ មានវិនិច្ឆ័យថា សទ្ធិវិហារិកដែលប្រាថ្នានឹងទៅ គប្បីបង្ហាញដល់កិច្ចការ ហើយអង្វរត្រឹមបីដង ។ បើលោកអនុញ្ញាត ជាការសម្រេច, បើមិនអនុញ្ញាត កាលភិក្ខុអាស្រ័យនៅនឹងលោក ឧទ្ទេសក្តី បរិបុច្ឆាក្តី កម្មដ្ឋានក្តី មិនសម្រេច (ព្រោះ)ឧបជ្ឈាយ៍ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនព្រមឱ្យទៅដូច្នោះ ព្រោះបំណងនឹងឱ្យនៅក្នុងសំណាក់របស់ខ្លួនតែម្យ៉ាង កាលឧបជ្ឈាយ៍ដូច្នេះ សូម្បីហាម នឹងចចេសតែទៅ ក៏គួរ ។

ពាក្យថា វុដ្ឋានស្ស អាគមេតព្វំ : **ត្រូវរង់ចាំត្រាតែឧបជ្ឈាយ៍ចេញចាកអាពាធ** មានសេចក្តីថា គប្បីរង់ចាំដរាបដល់ជាសះស្បើយអំពីជម្ងឺ មិនគួរចេញទៅខាងណាឡើយ ។ បើមានភិក្ខុដទៃជាអ្នកព្យាបាល គប្បីរកថ្នាំមកប្រគល់ទុក ក្នុងដៃរបស់ភិក្ខុនោះ ហើយប្រាប់លោកថា "បពិត្រលោកដ៏ចម្រើន ភិក្ខុនេះ នឹងព្យាបាល" ហើយសឹមទៅ ។

ឧបជ្ឈាយ៍វត្តកថា ចប់

# សទ្ធិវិហារិកវត្ត

[៨២] គប្បីជ្រាបវិនិច្ឆ័យ ក្នុងការដែលឧបជ្ឈាយ៍ប្រព្រឹត្តដោយប្រពៃក្នុងសទ្ធិវិហារិកតទៅ ៖

ពាក្យថា សង្គហេតព្វោ អនុគ្គហេតព្វោ : ត្រូវសង្គ្រោះ ត្រូវអនុគ្រោះ មានសេចក្តីថា ឧបជ្ឈាយ៍គប្បីធ្វើការសង្គ្រោះ និងឧបត្ថមសទ្ធិវិហារិកដោយកិច្ចមានឧទ្ទេសជាដើម ។ ក្នុងកិច្ចមានឧទ្ទេសជាដើមនោះ ឧទ្ទេសនោះ បានដល់ ការប្រាប់បាលី ។ បរិបុច្ឆានោះ បានដល់ អធិប្បាយសេចក្តីនៃបាលី ។ ឱវាទនោះ បានដល់ ការពោលថា ចូរធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនេះ ក្នុងកាលរឿងមិនទាន់កើត ។ អនុសាសនីនោះ បានដល់ ការពោលយ៉ាងនោះថា ក្នុងកាលរឿងកើតហើយ ។ មួយទៀត រឿងនឹងកើតឬមិនកើតក៏ដោយ ការពោលលើកដំបូង ឈ្មោះថា ឱវាទ ។ ការទូន្មានរឿយ ៗ ឈ្មោះថា អនុសាសនី ។

ពាក្យថា សចេ ឧបជ្ឈាយស្ស បត្តោ ហោតិ : បើឧបជ្ឈាយ៍មានបាត្រ មានសេចក្តីថា បើអតិរេកបាត្រមាន ។ មានន័យដូចគ្នាគ្រប់កន្លែងសមណបរិក្ខារ សូម្បីដទៃ ឈ្មោះថា បរិក្ខារ ។ សេចក្តីស្រាវជ្រាវរកឧបាយដែលកើតឡើង ដោយន័យដែលត្រឹមត្រូវតាមធម៌ ឈ្មោះថា សេចក្តីខ្វល់ខ្វាយ ក្នុងសទ្ធិវិហារិកវត្តនេះ ។ បន្ទាប់ពីនេះទៅ វត្ត

ចាប់តាំងពីឱ្យឈើស្ទន់ដល់ទីបំផុតថែម ទឹកក្នុងឆ្នាំងជម្រះ ឧបជ្ឈាយ៍គួរធ្វើដល់សទ្ធិវិហារិកចំពោះអ្នកមានជម្ងឺ ។ មួយទៀត កិច្ចមាននាំដើរទៅដើម្បីរម្ងាប់សេចក្តីអផ្សុកជាដើម សូម្បីសទ្ធិវិហារិកមិនមានជម្ងឺ ឧបជ្ឈាយ៍ក៏គួរធ្វើពិត ។

ពាក្យថា ចីវរំ រជន្តេន : កាលបើជ្រលក់ចីវរ មានសេចក្តីថា កាលបានស្តាប់ឧបាយអំពីឧបជ្ឈាយ៍ថា "គប្បីជ្រលក់យ៉ាងនេះ" ហើយសឹមជ្រលក់ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនោះ ។

សទ្ធិវិហារិកវត្តកថា ចប់

## បណាមកថា

[៨៣] ពាក្យថា ន សម្មាវត្តន្តិ : មិនបានប្រព្រឹត្តល្អ មានសេចក្តីថា មិនធ្វើឧបជ្ឈាយ៍វត្តតាមដែលទ្រង់បញ្ញត្តទុកឱ្យពេញបរិបូណ៌ ។

ពាក្យថា យោ ន សម្មាវត្តេយ្យ : ភិក្ខុណាដែលមិនបានប្រព្រឹត្តល្អ មានសេចក្តីថា សទ្ធិវិហារិកណា មិនធ្វើវត្តតាមដែលទ្រង់បញ្ញត្តទុកឱ្យពេញ សទ្ធិវិហារិកនោះ ត្រូវអាបត្តិទុក្កដ ។

[៨៤] បទថា បណាមេតព្វោ : ត្រូវតែបណ្ដេញចេញបានបានដល់ អបសាទេតព្វោ : មិនគប្បីជ្រះថ្លា (គប្បីរុកកួន) ។

ពាក្យថា នាធិមត្តំ បេមំ ហោតិ : មិនបានស្រឡាញ់ដោយពិតមានសេចក្ដីថា មិនមានការស្រឡាញ់ដូចជាបុត្រ និងធីតាក្រៃលែងណាស់ក្នុងឧបជ្ឈាយ៍ ។

ពាក្យថា នាធិមត្តា ភាវនា ហោតិ : មិនមានការចម្រើនភាវនាដោយពិត មានសេចក្ដីថា មិនដាំ មិនបណ្ដុះមេត្រីក្រៃលែងណាស់ ។ ចំណែកល្អគប្បីជ្រាបដោយបដិបក្ខនឹងន័យដែលពោលហើយ ។

ពាក្យថា អលំ បណាមេតុំ : គួរឱ្យបណ្ដេញចេញ មានសេចក្ដីថា សមគួរបណ្ដេញចេញ ។

ពាក្យថា អប្បណាមេន្តោ ឧបជ្ឈាយោ សាតិសារោ ហោតិ : នឹងមានទោស បើឧបជ្ឈាយ៍មិនបណ្ដេញចេញទេ មានសេចក្ដីថា កាលឧបជ្ឈាយ៍មិនបណ្ដេញចេញ រមែងជាអ្នកមានទោស គឺ រមែងត្រូវអាបត្តិ ។ ព្រោះហេតុដូច្នោះ កាលសទ្ធិវិហារិកមិនប្រព្រឹត្តដោយប្រពៃគួរតែបណ្ដេញចេញពិត ។ ក៏ក្នុងការមិនប្រព្រឹត្តដោយប្រពៃ មានវិនិច្ឆ័យដូច្នេះ ៖

កាលសទ្ធិវិហារិក មិនធ្វើវត្តត្រឹមតែជ្រលក់ចីវរ សេចក្ដីសាប

សូន្យ រមែងមានដល់ឧបជ្ឈាយ៍ ។ ព្រោះហេតុនោះ កាលសទ្ធិវិហារិកដែលផុតនិស្ស័យហើយក្តី មិនទាន់ផុតក្តី មិនធ្វើវត្តនោះ ជាអាបត្តិដូចគ្នា ។ តាំងពីឱ្យបាត្រដល់ភិក្ខុពួកខ្លះទៅ ជាអាបត្តិដល់អ្នកមិនទាន់ផុតនិស្ស័យប៉ុណ្ណោះ ។ ពួកសទ្ធិវិហារិកប្រព្រឹត្តដោយប្រពៃ ឧបជ្ឈាយ៍មិនប្រព្រឹត្តដោយប្រពៃ ជាអាបត្តិដល់ឧបជ្ឈាយ៍ ។ ឧបជ្ឈាយ៍ប្រព្រឹត្តដោយប្រពៃ ពួកសទ្ធិវិហារិកមិនប្រព្រឹត្តដោយប្រពៃ ជាអាបត្តិដល់ពួកលោក ។ កាលឧបជ្ឈាយ៍ត្រេកអរវត្ត ពួកសទ្ធិវិហារិក សូម្បីមានច្រើន ជាអាបត្តិគ្រប់រូប ។ បើឧបជ្ឈាយ៍ពោលថា ឧបដ្ឋាករបស់យើងមាន ពួកលោកចូរធ្វើសេចក្តីព្យាយាមក្នុងការស្វាធ្យាយ និងមនសិការជាដើមរបស់ខ្លួនចុះ មិនជាអាបត្តិដល់ពួកសទ្ធិវិហារិក ។ បើឧបជ្ឈាយ៍មិនស្គាល់សេចក្តីត្រេកអរ ឬមិនត្រេកអរ ជាបុគ្គលល្ងង់ សទ្ធិវិហារិកមានច្រើនរូប ក្នុងពួកលោក បើភិក្ខុដល់ព្រមដោយវត្តមួយរូប អាចដោះភិក្ខុក្រៅនោះចេញ ទទួលជាភារៈរបស់ខ្លួនយ៉ាងនេះថា "ខ្ញុំព្រះករុណា នឹងធ្វើកិច្ចរបស់ឧបជ្ឈាយ៍ជំនួស ពួកលោកចូរជាអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ" ដូច្នេះ មិនជាអាបត្តិ ដល់លោកទាំងឡាយ ចាប់ផ្តើមតាំងពីទុកភារៈដល់ភិក្ខុនោះទៅ ។

បណាមកថា ចប់

# ពណ៌នារឿងរាធព្រាហ្មណ៍

[៨៥] វិនិច្ឆ័យក្នុងរឿងរាធព្រាហ្មណ៍តទៅ ។ ព្រះសារីបុត្តដ៏មានអាយុ រមែងជ្រាបបព្វជ្ជានិងឧបសម្បទា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតដោយត្រៃសរណគមន៍ក្នុងក្រុងពារាណសី សួម្បីដោយពិត; តែថា ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងហាមឧបសម្បទា ក្នុងវេលានោះហើយ ទ្រង់អនុញ្ញាតឧបសម្បទាធ្វើឱ្យរឹងប៉ឹងដោយញត្តិចតុត្ថកម្ម គ្រានោះ ព្រះថេរៈជ្រាបព្រះអធ្យាស្រ័យរបស់ព្រះអង្គ ទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឱ្យព្រាហ្មណ៍នោះ បព្វជ្ជាឧបសម្បទាយ៉ាងណា ?"

ពិតមែន បរិស័ទរបស់ព្រះពុទ្ធទាំងឡាយ រមែងជាអ្នកឆ្លាតក្នុងអធ្យាស្រ័យ ឯព្រះសារីបុត្តដ៏មានអាយុនេះ ជាអ្នកប្រសើរជាកំពូលរបស់ពុទ្ធបរិស័ទ ។

ពណ៌នារឿងរាធព្រាហ្មណ៍ ចប់

# ឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា

[៨៥] ក្នុងពាក្យថា ព្យត្តេន ភិក្ខុនា បដិពលេន : ភិក្ខុអ្នកឆ្លាសប្រតិពល នេះ មានវិនិច្ឆ័យថា វិនយបិដកព្រមទាំងអដ្ឋកថារបស់ភិក្ខុណា ស្ទាត់ជំនាញរត់មាត់ ភិក្ខុនោះចាត់ថា អ្នកឆ្លាត កាលភិក្ខុបែបនោះមិនមាន ពុទ្ធវចនៈ ដោយហោចទៅ សូម្បីត្រឹមតែញត្តិចតុត្ថកម្មវាចានេះ របស់ភិក្ខុណា ជារបស់ដែលចាំបានត្រឹមត្រូវស្ទាត់ជំនាញរត់មាត់ សូម្បីភិក្ខុនេះ ក៏ចាត់ថា ជាអ្នកឆ្លាតក្នុងអត្ថនេះបាន ។ ចំណែកភិក្ខុណា មិនអាចសូធ្យកម្មវាចាដោយបទព្យញ្ជនៈ ដែលរៀបរយ គឺថា ធ្វើព្យញ្ជនៈ ឬបទឱ្យខូច ឬគួរនឹងពោលយ៉ាងនេះទេ បែរជាពោលយ៉ាងដទៃទៅវិញ ព្រោះរោគ មានក្អក រមាស់ និងស្លេស្ម៍ជាដើម ឬព្រោះអវយវៈមានបបូរមាត់ ធ្មេញ និងអណ្ដាតជាដើម យកជាការមិនបាន ឬព្រោះមិនបានធ្វើការសន្សំទុកក្នុងព្រះបរិយត្តិ ភិក្ខុនេះចាត់ថា "ជាអ្នកមិនអាច ភិក្ខុក្រៅពីនោះ គប្បីជ្រាបថា ជាអ្នកអាចក្នុងអត្ថនេះ ។

ពាក្យថា សង្ឃោ ញាបេតព្វោ : ត្រូវផ្ទៀងសង្ឃ មានសេចក្ដីថា សង្ឃដែលភិក្ខុនោះ គប្បីឱ្យជ្រាប ។

ខាងមុខបន្ទាប់ពីនេះ ព្រះមានព្រះភាគ ត្រាស់ពាក្យថា សុណាតុ មេ ភន្តេ ជាដើម ដើម្បីសម្ដែងសេចក្ដីដែលភិក្ខុនោះ គួរឱ្យសង្ឃ

ជ្រាប ។

[៨៦] ពាក្យថា ឧបសម្បន្នសមនន្តរា : តាំងអំពីបាន ឧបសម្បទា មានសេចក្ដីថា ជាអ្នកល្មមឧបសម្បទាហើយ រមែងប្រព្រឹត្ត អនាចារ[១] ក្នុងកាលជាលំដាប់ជាប់តគ្នាទៅ ។

ពាក្យថា អនាចារំ អាចរតិ : ប្រព្រឹត្តល្មើស មានសេចក្ដីថា រមែងធ្វើការល្មើសព្រះបញ្ញត្តិ ។

បទថា ឧល្លុម្បតុ មំ : សូមស្រោចស្រង់នូវខ្ញុំ មានសេចក្ដីថា សូមលើកខ្ញុំព្រះករុណាឡើងផង អធិប្បាយថា សូមឱ្យខ្ញុំព្រះករុណាចេញ ចាកអកុសល ឱ្យតាំងចំពោះក្នុងកុសលផង ឬថា សូមលើកឡើងចាកពី ភាពជាសាមណេរ ឱ្យតាំងចំពោះក្នុងភាពជាភិក្ខុផង ។

ពីរបទថា អនុកម្បំ ឧបាទាយ : ដោយសេចក្ដីអនុគ្រោះ បាន ដល់ អាស្រ័យសេចក្ដីអាណិត អធិប្បាយថា ធ្វើសេចក្ដីអាណិតអាសូរ ដល់ខ្ញុំព្រះករុណាផងចុះ ។

[៨៧] ពីរបទថា អដ្ឋិតា ហោតិ : ផ្ដើមឡើង មានសេចក្ដីថា

---

១. បើ ឧបសម្បន្នោ ហុត្វា ... ...អាចរតិ ជាប្រយោគមួយជាមួយគ្នា ក៏ទីងល្អ ព្រោះកាល ប្រែរួចស្រេចហើយ យក អនាចារំ អាចរតិ មកជាបទ តាំងពន្យល់អត្ថ ម្ដងទៀត ។

ជារបស់ប្រព្រឹត្តទៅជានិច្ច ។

ពីរបទថា ចត្តារោ និស្សយេ : និស្ស័យទាំង ៤ យ៉ាង បានដល់ បច្ច័យបួន ព្រះមានព្រះភាគត្រាស់ហៅថា និស្ស័យ ព្រោះហេតុថា ជាទីអាស្រ័យប្រព្រឹត្តទៅរបស់អត្តភាព ។

ឧបសម្បទាដោយញត្តិចតុត្ថកម្មឧបសម្បទា ចប់

## ឧបជ្ឈាយសទ្ធិវិហារិកកថា

[៩០] ពាក្យថា កិន្តាយំ ភិក្ខុ ហោតិ : ភិក្ខុនេះត្រូវជាអ្វីនឹងអ្នក មានសេចក្តីថា ភិក្ខុនេះ ជាអ្វីនឹងលោក ។

ពាក្យថា អញ្ញេហិ ឱវទិយោ អនុសាសិយោ : អ្នកគួរតែឱ្យភិក្ខុដទៃទូន្មានប្រៀនប្រដៅ មានសេចក្តីថា លោក ដែលភិក្ខុពួកដទៃត្រូវដាស់តឿននិងត្រូវទូន្មាន ។

ពាក្យថា ពាហុល្លាយ អាវត្តោ យទិទំ គណពន្ធិកំ : អ្នកប្រញាប់ប្រញាល់ពេកណាស់ ព្រោះអ្នកប្រព្រឹត្តដើម្បីសេចក្តីល្មោភច្រើន ឯសេចក្តីល្មោភច្រើននេះ បានដល់ការចងជាពួក មានសេចក្តីថា សេចក្តីជាប់ជំពាក់ដោយពួក ភាពជាអ្នកល្មោភច្រើននេះរមែងមាន ហេតុនោះ

ភាពជាអ្នកប្រាជ្ញច្រើននេះ ឈ្មោះថា មានសេចក្ដីជាប់ជំពាក់ដោយពួក មានពាក្យអធិប្បាយថា ភាពជាអ្នកប្រាជ្ញច្រើនដែលឈ្មោះថា មានសេចក្ដីជាប់ជំពាក់ដោយពួកទាំងនេះយ៉ាងណា លោកវិលមកដើម្បីប្រយោជន៍ដល់ភាពជាអ្នកប្រាជ្ញច្រើនយ៉ាងនោះ រហ័សណាស់ ។

[៩១] បទថា អព្យត្តា : មិនឆ្លាស បានដល់ អ្នកប្រាសចាកបញ្ញាជាគ្រឿងឆ្លាត ។

ពីរបទថា អញ្ញាតរោបិ អញ្ញតិត្ថិយបុព្វោ : មានភិក្ខុមួយរូបកាលពីដើមជាតិរ្ថិយដទៃ បានដល់ បរិព្វាជក ឈ្មោះ បសុរៈ ។ បានឮថា គេគិតថា "ទីងលួចធម៌" ទើបបួសក្នុងសំណាក់ព្រះឧទាយីថេរៈ ជាអ្នកដែលមនុស្សទាំងឡាយ ពោលថា នៅដោយត្រឹមត្រូវតាមធម៌ បានលើកវាទៈរបស់លោក ។

ភិក្ខុដែលឆ្លាតក្នុងពាក្យថា អនុជានាមិ ភិក្ខវេ ព្យត្តេន ភិក្ខុនា : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលឆ្លាសប្រតិពល ជាដើម មានលក្ខណៈដូចពោលហើយ ក្នុងអដ្ឋកថានៃភិក្ខុនោវាទកសិក្ខាបទក្នុងកាលមុននោះឯង[១] ។ ចំណែកភិក្ខុដែលអាចធ្វើកិច្ចជាដើមថា ព្យាបាលអន្តេវាសិក ឬសទ្ធិវិហារិកដែលអាពាធ ព្រះមានព្រះភាគទ្រង់ប្រាថ្នាថា

១. សមន្ត. បាចិ. ៤. ២៤ ។

អ្នកអាចក្នុងទីនេះ ។

ពិតមែន ព្រះមានព្រះភាគបានត្រាស់ សូម្បីពាក្យនេះ ទុកថា "ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ គួរឱ្យកុលបុត្រឧបសម្បទា គួរឱ្យនិស្ស័យ គួរឱ្យសាមណេរឧបដ្ឋាកដោយអង្គ ៥ យ៉ាងណា ? ទាំងនេះគឺ ជាអ្នកអាចព្យាបាលដោយខ្លួនឯង ឬឱ្យអ្នកដទៃ ។ ជួយព្យាបាលអន្តេវាសិក ឬសទ្ធិវិហារិកអ្នកអាពាធ, ជាអ្នកអាចរម្ងាប់ដោយខ្លួនឯង ឬឱ្យអ្នកដទៃជួយរម្ងាប់សេចក្តីអផ្សុករបស់អន្តេវាសិក ឬសទ្ធិវិហារិក ជាអ្នកអាចបន្ទោបង់ដោយខ្លួនឯង ឬឱ្យអ្នកដទៃជួយបន្ទោបង់សេចក្តីវង្វៀសដែលកើតឡើងហើយចេញ ដោយធម៌, ជាអ្នកអាចណែនាំក្នុងអភិធម្ម ណែនាំក្នុងអភិវិន័យ[១] ។

ឧបជ្ឈាយ៍សទ្ធិវិហារិកកថា ចប់

១. មើលពាក្យអធិប្បាយទំព័រ ១២៥ ខាងមុខ ។

# អាចរិយន្តេវាសិកកថា

[៩២] បទថា បក្កមន្តេសុ : ទៅកាន់ពួកតិរ្ថិយ បានដល់ ទៅចូលពួកតិរ្ថិយ ។

ពាក្យថា អនុជានាមិ ភិក្ខវេ អាចរិយំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យមានអាចារ្យ មានសេចក្ដីថា តថាគតអនុញ្ញាតអាចារ្យ អ្នកទូន្មានអាចារៈ និងសមាចារៈ ។

ពាក្យទាំងពួងជាដើមថា អាចរិយោ ភិក្ខវេ អន្តេវាសិកម្ហិ : ម្នាលភិក្ខុទាំងឡាយ ឯអាចារ្យត្រូវតាំងចិត្តនឹងអន្តេវាសិក គប្បីជ្រាប ដោយអំណាចពាក្យដែលពោលហើយ ដោយន័យជាដើមថា ឧបជ្ឈាយោ ភិក្ខវេ សទ្ធិវិហារិកម្ហិ : ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវយកចិត្តទុកដាក់ក្នុងសទ្ធិវិហារិក នុ៎ះឯង ។ ព្រោះថា ក្នុងពាក្យថា អាចរិយោ ជាដើម ផ្សេងគ្នាត្រឹមតែឈ្មោះប៉ុណ្ណោះ ។

[៩៥] ចំណែកក្នុងពាក្យថា អន្តេវាសិកា អាចរិយេសុ ន សម្មា វត្តន្តិ : ពួកអន្តេវាសិក មិនប្រព្រឹត្តល្អនឹងពួកអាចារ្យឡើយ នេះ អ្នកសិក្សាគប្បីជ្រាបថា : ជាអាបត្តិដល់និស្សយន្តេវាសិក ដោយលក្ខណៈដែលខ្ញុំព្រះករុណាពោលទុកហើយ ក្នុង( ទំព័រ១០៤-៥ )ខាងដើម នោះឯងថា "ក៏ក្នុងការមិនប្រព្រឹត្តដោយប្រពៃ មានវិនិច្ឆ័យ ដូច្នេះ :

កាលសទ្ធិវិហារិក មិនធ្វើវត្តត្រឹមតែជ្រលក់ចីវរ សេចក្តីសាបសូន្យរមែងមានដល់ឧបជ្ឈាយ៍ ព្រោះហេតុនោះ កាលសទ្ធិវិហារិកដែលផុតនិស្ស័យហើយក្តី មិនទាន់ផុតក្តី មិនធ្វើវត្តនោះ ជាអាបត្តិដូចគ្នា” និងថា “តាំងពីឱ្យបាត្រដល់ភិក្ខុពួកខ្លះទៅ ជាអាបត្តិដល់អ្នកដែលមិនទាន់ផុតនិស្ស័យប៉ុណ្ណោះ”, មិនគប្បីជ្រាបអាបត្តិដល់និស្សយន្តេវាសិក ដោយលក្ខណៈនោះទេ; ព្រោះថា និស្សយន្តេវាសិក គួរធ្វើអាចរិយវត្តទាំងពួងត្រឹមតែវេលាដែលខ្លួននៅអាស្រ័យអាចារ្យ ។ ចំណែកបព្វជន្តេវាសិក ឧបសម្បទន្តេវាសិក និងធម្មន្តេវាសិក សូម្បីផុតនិស្ស័យហើយ ក៏គង់ធ្វើវត្តតាំងពីដើម ដរាបដល់ជ្រលក់ចីវរ តែមិនជាអាបត្តិដល់អន្តេវាសិកទាំងនោះ ព្រោះហេតុមិនសួរមុន ហើយឱ្យបាត្រជាដើម ។ និងក្នុងអន្តេវាសិកទាំងនេះ បព្វជន្តេវាសិក និងឧបសម្បទន្តេវាសិក ជាភារៈរបស់អាចារ្យរហូតដល់អស់ជីវិត និស្សយន្តេវាសិក និងធម្មន្តេវាសិកនៅក្នុងសំណាក់ត្រឹមណា ជាភារៈរបស់អាចារ្យ ត្រឹមនោះតែម្តង ព្រោះហេតុនោះ ចំណែកអាចារ្យទើបត្រូវប្រព្រឹត្តក្នុងអន្តេវាសិកទាំងនោះផង ព្រោះថា អាចារ្យ និងអន្តេវាសិក ចំណែកណា ៗ មិនប្រព្រឹត្តដោយប្រពៃ រមែងជាអាបត្តិដល់ចំណែកនោះ ៗ ។

អាចរិយន្តេវាសិកកថា ចប់

# ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍ និងអាចារ្យ

[៩៧] ក្នុងអន្តជាហេតុរម្ងាប់និស្ស័យចាកពីឧបជ្ឈាយ៍ជាដើមថា ឧបជ្ឈាយោ បក្កន្តោ : ឧបជ្ឈាយ៍ជៀសចេញទៅក្តី មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា បក្កន្តោ : ចៀសចេញទៅ មានសេចក្តីថា ឧបជ្ឈាយ៍ប្រាថ្នានឹងចេញទៅអំពីអាវាសនោះ ជៀសចេញទៅ គឺ ទៅកាន់ទិស ។ ក៏ឯកាលលោកទៅហើយយ៉ាងនោះ ។ បើក្នុងវិហារមានភិក្ខុអ្នកឱ្យនិស្ស័យ ។ ឬសូម្បីក្នុងកាលដទៃ ខ្ទនធ្លាប់កាន់និស្ស័យ ក្នុងសំណាក់ភិក្ខុណា ។ ឬភិក្ខុណាមានសម្ភោគ និងបរិភោគជាមួយគ្នា គប្បីកាន់និស្ស័យក្នុងសំណាក់ភិក្ខុនោះ ។ សូម្បីមួយថ្ងៃក៏ឃុំគ្រងអាបត្តិមិនបាន ។ បើភិក្ខុដូច្នោះមិនមាន ភិក្ខុដទៃដែលជាលជ្ជីមានសីលជាទីស្រឡាញ់មាន កាលជ្រាបថា លោកជាលជ្ជី មានសីលជាទីស្រឡាញ់ គប្បីសូមនិស្ស័យក្នុងថ្ងៃនោះតែម្តង ។ បើលោកឱ្យ ការឱ្យយ៉ាងនោះជាការល្អ តែបើលោកសួរថា ឧបជ្ឈាយ៍របស់លោកនឹងត្រឡប់មកឆាប់ទេ ឬ ? ឯឧបជ្ឈាយ៍ បាននិយាយទុកយ៉ាងនោះ គប្បីឆ្លើយថា "ព្រះករុណាលោកម្ចាស់" បើលោកពោលថា "បើដូច្នោះ ចូរចាំឧបជ្ឈាយ៍មកចុះ" នឹងរង់ចាំឧបជ្ឈាយ៍ត្រឡប់មក ក៏គួរ ។ តែបើដោយប្រក្រតី ជ្រាបមិនបាន

ថា លោកជាអ្នកមានសីលជាទីស្រឡាញ់ គប្បីសង្កេតត្រឹមតែ ៤-៥ ថ្ងៃ ថា ភិក្ខុនោះ នឹងជាសភាគគ្នាឬទេ ហើយឱ្យលោកផ្ញើឱកាស សូមនិស្ស័យ ។ តែបើក្នុងវត្ត មិនមានភិក្ខុអ្នកឱ្យនិស្ស័យ ទាំងឧបជ្ឈាយ៍បានផ្ដាំទុកថា "យើងនឹងទៅត្រឹមតែ ២-៣ ថ្ងៃ ពួកអ្នកកុំព្រួយបារម្ភឡើយ" ដូច្នេះ ទើបទៅ បានសេចក្ដីឃុំគ្រងអាបត្តិ ទម្រាំនឹងលោកត្រឡប់មក ។ បើសូម្បីអ្នកស្រុកក្នុងទីនោះ គេនិមន្តឱ្យលោកនៅលើសជាង វេលាដែលកំណត់ទុក ៥ ថ្ងៃ ឬ ១០ ថ្ងៃសោត, ឧបជ្ឈាយ៍នោះ គប្បីបញ្ជូនដំណឹងទៅកាន់វត្តថា "ពួកភិក្ខុកំលោះកុំព្រួយបារម្ភឡើយ យើងនឹងត្រឡប់ទៅក្នុងថ្ងៃឯណោះ" ។ សូម្បីយ៉ាងនេះ ក៏បានសេចក្ដីឃុំគ្រងអាបត្តិ ។ ខាងក្រោយកល ឧបជ្ឈាយ៍កំពុងត្រឡប់មក មានភាពរារាំងក្នុងចន្លោះ មកដោយទឹកជន់លិចទន្លេ ឬចោរជាដើម ព្រះថេរៈចាំទឹកស្រក ឬ រកសម្លាញ់ បើពួកភិក្ខុកំលោះជ្រាបដំណឹងនោះ បានទូវការឃុំគ្រងអាបត្តិ ទម្រាំតែដល់លោកត្រឡប់មក ។ តែបើលោកបញ្ជូនដំណឹងមកថា "យើងនឹងនៅទីនេះឯង" ដូច្នេះ ឃុំគ្រងអាបត្តិមិនបាន ។ នឹងបាននិស្ស័យក្នុងទីណា គប្បីទៅក្នុងទីនោះ ។ តែកាលឧបជ្ឈាយ៍សឹក ឬមរណភាព ឬទៅចូលអន្យតិរ្ថិយហើយ សូម្បីតែមួយថ្ងៃ ក៏ឃុំគ្រងអាបត្តិមិនបាន ។ នឹងបាននិស្ស័យក្នុងទីណា គប្បីទៅក្នុងទីនោះ ។

បទថា វិព្ភន្តោ : សឹកចេញទៅ បានដល់ ឃ្លាតចាកសាសនា ។ ការបណ្តេញចេញចាកនិស្ស័យ លោកហៅថា អាណត្តិ គឺ បង្គាប់បញ្ជា ។ ព្រោះហេតុនោះ ភិក្ខុណាត្រូវឧបជ្ឈាយ៍ច្រានចេញ ដោយការបណ្តេញចាកនិស្ស័យ ដោយន័យព្រះបាលីនេះថា យើងបណ្តេញអ្នកចេញ ឬថា កុំចូលមកក្នុងទីនេះ ឬថា ចូរជញ្ជូនបាត្រចីវររបស់លោកចៀសចេញទៅ ឬថា លោកមិនត្រូវឧបដ្ឋាកយើងទៀតទេ ដូច្នេះក្តី ដោយន័យផុតពីបាលីជាដើមថា អ្នកកុំបាច់លាយើងចូលស្រុកឡើយ ដូច្នេះក្តី ភិក្ខុនោះ គប្បីសូមឱ្យឧបជ្ឈាយ៍អត់ទោស ។ បើលោកមិនព្រមអត់ទោសឱ្យជាមុនដំបូងទេ, គប្បីព្រមទទួលទណ្ឌកម្មហើយ សូមឱ្យលោកអត់ទោសដោយខ្លួនឯង ៣ ដងសិន, បើលោកមិនព្រមអត់ទោសឱ្យទេ គប្បីអារាធនាព្រះមហាថេរៈ ដែលនៅក្នុងវត្តនោះ ឱ្យជួយសូមខមាទោសជំនួស ។ បើលោកមិនព្រមអត់ទោស គប្បីពឹងភិក្ខុទាំងឡាយដែលនៅក្នុងវត្តជិតខាងឱ្យជួយសូមខមាទោសជំនួស ។ បើធ្វើយ៉ាងនោះហើយ លោកក៏មិនទាន់ព្រមអត់ទោសឱ្យ គប្បីទៅក្នុងទីដទៃហើយនៅក្នុងសំណាក់របស់ភិក្ខុទាំងឡាយ អ្នកជាសភាគដល់ឧបជ្ឈាយ៍ ដោយគិតថា “ធ្វើដូចម្តេចហ្ន៎ ? ឧបជ្ឈាយ៍បានជ្រាបថា នៅក្នុងសំណាក់របស់ភិក្ខុទាំងឡាយ ដែលជាសភាគរបស់យើងនឹងគប្បីអត់ទោសឱ្យខ្លះ” ។ បើធ្វើយ៉ាងនោះហើយ លោកក៏មិនទាន់ព្រមអត់ទោសឱ្យ, គប្បីនៅក្នុងទី

នោះចុះ, បើមិនអាចនៅក្នុងទីនោះបាន ដោយទោសមានស្រុកអត់បាយជាដើម ៗ ទើងមកកាន់វត្តដើមនោះវិញហើយកទ់និស្ស័យនៅក្នុងសំណាក់ភិក្ខុដទៃក៏គួរ ៗ វិនិច្ឆ័យក្នុងការបង្គាប់បញ្ញាប៉ុណ្ណេះ ៗ

បណ្តាអង្គ ៦ ដែលជាហេតុឱ្យនិស្ស័យរម្ងាប់ចាកពីអាចារ្យក្នុងអង្គនេះ គឺ អាចារ្យជៀសចេញទៅក្តី មានវិនិច្ឆ័យថា អាចារ្យអង្គខ្លះពោលលាហើយជៀសចេញទៅ អង្គខ្លះមិនពោលលា ៗ ដល់អន្តេវាសិកក៏ជាយ៉ាងនោះដូចគ្នា ៗ ក្នុងអាចារ្យនិងអន្តេវាសិកទាំង ២ ចំណែកនោះ បើអន្តេវាសិកពោលលាអាចារ្យថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាចង់ទៅកាន់ទីឯណោះ ដោយករណីយ កិច្ចឯណាមួយ" ឯលោកដែលអាចារ្យសួរថា "នឹងទៅកាលណា ?" ទើបឆ្លើយថា "នឹងទៅក្នុងវេលាល្ងាច ឬនឹងក្រោកឡើងទៅក្នុងពេលយប់" ល្មមអាចារ្យទទួលថា "ល្អណាស់លោក" និស្ស័យរម្ងាប់ក្នុងខណៈនោះ ៗ តែបើលោកពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាចង់ទៅទីឯណោះ" អាចារ្យឆ្លើយថា "លោកនឹងត្រាច់បិណ្ឌបាតក្នុងស្រុកឯណោះសិន ខាងក្រោយនឹងដឹង" ឯភិក្ខុនោះទទួលថា "ល្អហើយ" បើលោកទៅពីស្រុកនោះ ជាការទៅដោយល្អ, តែបើមិនទៅ និស្ស័យមិនរម្ងាប់ ៗ បើសូម្បីកាលអន្តេវាសិកពោលថា "ខ្ញុំព្រះករុណានឹងទៅ" តែអាចារ្យបង្គាប់ថា "កុំគប្បីទៅ ពេលយប់នឹងប្រឹក្សាគ្នាហើយ ទើបដឹង" ដូច្នេះ កាលប្រឹក្សាគ្នា

ហើយទើបទៅ ជាការទៅដោយល្អ បើមិនទៅនិស្ស័យមិនរម្ងាប់ ។ តែសម្រាប់អន្តេវាសិកដែលមិនពោលលាអាចារ្យជាមុន ជៀសចេញទៅ និស្ស័យរម្ងាប់ក្នុងកាលកន្លងឧបចារសីមាទៅ, កាលត្រឡប់មកខាងក្នុងឧបចារសីមា និស្ស័យមិនទាន់រម្ងាប់ ក៏បើអាចារ្យពោលលាអន្តេវាសិកថា "យើងនឹងទៅទីឯណោះ", ឯកាលអន្តេវាសិកសួរថា "នឹងទៅកាលណា ?" ឆ្លើយថា "វេលាល្ងាច ឬពេលយប់", កាលអន្តេវាសិកទទួលថា "ល្អហើយ" និស្ស័យរម្ងាប់ភ្លាម ។ តែបើអាចារ្យប្រាប់ថា "ស្អែកនេះយើងនឹងត្រាច់បិណ្ឌបាតហើយហួសទៅ" ចំណែកអន្តេវាសិកទទួលថា "ល្អហើយ" និស្ស័យមិនទាន់រម្ងាប់ នៅរហូតអស់មួយថ្ងៃ លុះដល់ថ្ងៃស្អែក ទើបរម្ងាប់ ។ អាចារ្យប្រាប់ថា "យើងនឹងទៅបិណ្ឌបាតក្នុងស្រុកឯណោះហើយ ទើបដឹងថា ទៅឬមិនទៅ" បើមិនទៅ និស្ស័យមិនរម្ងាប់ ។ បើសូម្បីកាលអាចារ្យប្រាប់ថា "នឹងទៅ" ហើយត្រូវអន្តេវាសិកអង្វរទុកថា "កុំទាន់ទៅ ពេលយប់ប្រឹក្សាគ្នាហើយទើបជ្រាប", សូម្បីប្រឹក្សាគ្នាហើយមិនទៅ និស្ស័យ ក៏មិនរម្ងាប់ ។ បើអន្តេវាសិក និងអាចារ្យទាំង ២ ផ្នែក ចេញក្រៅសីមាទៅ ដោយករណីយកិច្ចយ៉ាងណាមួយ លំដាប់នោះ បើចិត្តគិតនឹងទៅកើតឡើង អាចារ្យមិនទាន់ពោលលាចេញទៅហើយ ត្រឡប់ត្រឹមតែក្នុង២ លេណ្ឌុបាទ ។ និស្ស័យមិនទាន់រម្ងាប់ បើកន្លងផុត ២ លេណ្ឌុបាទទៅហើយ ទើបត្រឡប់, និស្ស័យ

រមែងរម្ងាប់ ។ អាចារ្យ និងឧបជ្ឈាយ៍ នៅក្នុងវត្តជទៃកន្លងផុត ២ លេណ្ឌុបាទទៅ និស្ស័យរម្ងាប់ ។ អាចារ្យពោលលាសិក្ខា មរណភាព ទៅចូលពួកតិរ្ថិយហើយ និស្ស័យរម្ងាប់ភ្លាម ។

ចំណែកក្នុងការបង្គាប់បញ្ញាមានវិនិច្ឆ័យថា បើសូម្បីអាចារ្យជាអ្នកមានប្រាថ្នានឹងលោះបោលពិត ៗ ទើបប្រានចេញដោយការបណ្តេញចាកនិស្ស័យ, តែអន្តេវាសិកជាអ្នកនៅមានអាល័យថា អាចារ្យបណ្តេញយើងចេញក៏ពិត ប៉ុន្តែថា លោកជាអ្នកនៅទោរទន់ដោយទឹកចិត្ត ដូច្នេះ ។ និស្ស័យមិនទាន់រម្ងាប់ ។ បើសូម្បីអាចារ្យមានអាល័យ តែអន្តេវាសិកអស់អាល័យដាក់ធុរៈថា គ្រានេះ យើងនឹងមិននៅអាស្រ័យអាចារ្យនេះសូម្បីយ៉ាងនោះ និស្ស័យរមែងមិនទាន់រម្ងាប់ ។ និងដោយអ្នកទាំង ២ នៅមានអាល័យ និស្ស័យរមែងមិនរម្ងាប់ពិត ។ ក្នុងកាលអ្នកទាំង ២ ដាក់ធុរៈ និស្ស័យទើបរម្ងាប់ ។ អន្តេវាសិកត្រូវបណ្តេញចេញ គួរព្រមទទួលទណ្ឌកម្ម ។ ហើយសូមឱ្យអាចារ្យអត់ទោស ៣ ដង បើលោកមិនអត់ទោសឱ្យ គប្បីបដិបត្តិដោយន័យដែលពោលហើយក្នុងឧបជ្ឈាយ៍ ។ ក្នុងពាក្យថា ឧបជ្ឈាយេន វា សមោធានគតោ : អាចារ្យ បានទៅនៅរួមជាមួយនឹងឧបជ្ឈាយ៍ នេះ គប្បីជ្រាបការជួបគ្នាដោយអំណាចការបានឃើញនិងបានឮ ។ ក៏បើសទ្ធិវិហារិកអាស្រ័យ

នឹងអាចារ្យឃើញឧបជ្ឈាយ៍ថ្វាយបង្គំព្រះចេតិយ ក្នុងវត្តដែលនៅជាមួយគ្នា ឬត្រាច់បិណ្ឌបាតនៅក្នុងស្រុកមួយជាមួយគ្នា និស្ស័យរមែងរម្ងាប់ ។ ឧបជ្ឈាយ៍ឃើញ តែសទ្ធិវិហារិកមិនឃើញ និស្ស័យមិនរម្ងាប់ សទ្ធិវិហារិកឃើញ ឧបជ្ឈាយ៍ធ្វើដំណើរទៅ ឬទៅមកអាកាស គប្បីជ្រាបថា ជាភិក្ខុ ត្រាច់ទៅកាន់ទីឆ្ងាយ តែមិនជ្រាបថា "ឧបជ្ឈាយ៍" និស្ស័យមិនរម្ងាប់ ។ បើជ្រាប និស្ស័យរម្ងាប់ ឧបជ្ឈាយ៍នៅលើប្រាសាទ សទ្ធិវិហារិកនៅខាងក្រោម តែមិនទាន់ឃើញលោក ហុតយាគូហើយចៀសចេញទៅ ឬ មិនទាន់ឃើញលោកដែលអង្គុយក្នុងរោងឆាន់ ឆាន់ក្នុងចំណែកមួយខាងហើយជៀសចេញ ទៅ ឬមិនទាន់ឃើញ លោកសូម្បីអង្គុយក្នុងមណ្ឌបដែលស្តាប់ធម៌ ស្តាប់ធម៌ហើយ គេចចេញទៅ, និស្ស័យមិនរម្ងាប់ ។ គប្បីជ្រាបការជួបគ្នា ដោយអំណាចការឃើញមុន ដោយប្រការដូច្នេះ ។

ចំណែកការជួបគ្នាដោយអំណាចការបានឮ គប្បីជ្រាបដូច្នេះ ៖

បើកាលឧបជ្ឈាយ៍កំពុងពោលធម៌ ឬកំពុងធ្វើអនុមោទនាក្នុងវត្តក្តី ក្នុងចន្លោះស្រុកក្តី សទ្ធិវិហារិកបានឮសំឡេងហើយចាំបានថា សំឡេងឧបជ្ឈាយ៍របស់យើងនិស្ស័យរម្ងាប់ កាលចាំមិនបាន មិនរម្ងាប់ ។ វិនិច្ឆ័យក្នុងការជួបគ្នាប៉ុណ្ណេះ ។

ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍ និងអាចារ្យ ចប់

# ឧបសម្បទេតព្វបញ្ចក ១៦ ដង

[៩៨] លក្ខណៈនៃឧបជ្ឈាយ៍ និងអាចារ្យដោយសង្ខេបយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ទុកខាងដើមថា អនុជានាមិ ភិក្ខវេ ព្យត្តេន ភិក្ខុនា បដិពលេន ទសវស្សេន វា អតិរេកទសវស្សេន វា ឧបសម្បាទេតុំ[១] និស្សយំ ទេតុំ[២] : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលឆ្លាសប្រតិពល មានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ គួរឱ្យឧបសម្បទាដល់កុលបុត្របាន, ឱ្យនិស្ស័យដល់កុលបុត្របាន ដូច្នេះ, ឥឡូវនេះ ដើម្បីសម្តែងលក្ខណៈយ៉ាងនោះដោយពិស្តារ ទើបត្រាស់ពាក្យថា បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតេន : ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ ជាដើម ។

បណ្ដាបទទាំងនោះ ពីរបទថា បញ្ចហិ អង្គេហិ : ដោយអង្គ ៥ បានដល់ អង្គមិនជាគុណ ៥ ។ ពិតមែន ភិក្ខុនោះ ជាអ្នកឈ្មោះថា ប្រកបដោយអង្គមិនជាគុណ ក៏ព្រោះមិនប្រកបដោយអង្គនៃធម៌ ៥ មានកងសីលជាដើម ។

---

១. វិន. មហា. មហាខន្ធក. ៦. ៩១/១៨២ ។ ២. វិន. មហា. មហាខន្ធក. ៦. ៩៦/២១២ ។

ពាក្យថា ន ឧបសម្បាទេតព្វំ : មិនគួរឱ្យឧបសម្បទា បានដល់ មិនគប្បីជាឧបជ្ឈាយ៍ ឱ្យកុលបុត្រឧបសម្បទា ។

ពាក្យថា ន និស្សយោ ទាតព្វោ : មិនគួរឱ្យនិស្ស័យ បានដល់ មិនគប្បីជាអាចារ្យឱ្យនិស្ស័យ ។

ក៏ពាក្យថា អសេក្ខេន ជាដើម ក្នុងអង្គ ៥ នេះ ព្រះមានព្រះភាគត្រាស់ សំដៅយក សីល សមាធិ បញ្ញា ផល និង បច្ចវេក្ខណញ្ញាណនៃព្រះអរហន្ត ។ ក៏បញ្ចកៈទាំង ៣ ខាងដើមនេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃភិក្ខុដែលមិនសមគួរ មិនបានត្រាស់ដោយអំណាចអង្គនៃអាបត្តិទេ ។

ក៏ឯបណ្ដាបញ្ចកៈទាំងនេះ ចំពោះ ៣ បញ្ចកៈ មានពាក្យជាដើមថា **អសេក្ខេន សីលក្ខន្ធេន ១ អត្តនា ន អសេក្ខេន ១ អស្សទ្ធោ ១** ទ្រង់ធ្វើការហាមដោយអំណាចនៃភិក្ខុដែលមិនសមគួរ, ទ្រង់មិនបានធ្វើដោយអំណាចអង្គនៃអាបត្តិទេ ។

ពិតមែន ភិក្ខុណា មិនប្រកបដោយកងធម៌ ៥ របស់ព្រះអសេក្ខៈ មានកងសីលជាដើម ទាំងមិនអាចដឹកនាំអ្នកដទៃ ក្នុងកងធម៌ទាំងនោះ, តែជាអ្នកប្រកបដោយទោសមានអស្សទ្ធិយៈ ជាដើមគ្រប់គ្រងបរិស័ទ, បរិស័ទរបស់ភិក្ខុនោះ រមែងសាបសូន្យចាកគុណទាំងឡាយ មានសីលជា

ដើមពិត រមែងមិនចម្រើន ។ ព្រោះហេតុនោះ ពាក្យជាដើមថា ដែលភិក្ខុនោះ មិនគប្បីឱ្យកុលបុត្រឧបសម្បទា ដូច្នេះ ទើបឈ្មោះថា ត្រាស់ដោយអំណាចនៃភិក្ខុដែលមិនសមគួរ មិនបានត្រាស់ដោយអំណាចអង្គនៃអាបត្តិទេ ។ ក៏ការដែលព្រះខីណាស្រពប៉ុណ្ណោះ ជាឧបជ្ឈាយ៍និងអាចារ្យបាន ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយក៏ទេ បើទ្រង់អនុញ្ញាតចំពោះព្រះខីណាស្រពនោះប៉ុណ្ណោះមែន ព្រះអង្គគង់មិនត្រាស់ពាក្យថា សចេ ឧបជ្ឈាយស្ស អនភិរតិ ឧប្បន្នា ហោតិ : បើសេចក្តីអផ្សុកកើតឡើងដល់ឧបជ្ឈាយ៍”[1] ដូច្នេះ ជាដើម ។ ក៏ព្រោះហេតុ ដែលបរិស័ទរបស់ព្រះខីណាស្រព មិនសាបសូន្យចាកគុណទាំងឡាយ មានសីលជាដើម ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ គួរឱ្យឧបសម្បទា ដូច្នេះ ។

ក្នុងអង្គទាំងឡាយជាដើមថា អធិសីលេ សីលវិបន្នោ : វិបត្តិចាកសីល ក្នុងអធិសីល មានវិនិច្ឆ័យថា ភិក្ខុអ្នកត្រូវអាបត្តិបារាជិក និងសង្ឃាទិសេស ឈ្មោះថា អ្នកវិបត្តិដោយសីលក្នុងអធិសីល ។ អ្នកត្រូវអាបត្តិ៥កង ក្រៅអំពីនេះ ឈ្មោះថា វិបត្តិដោយអាចារៈក្នុងអជ្ឈាចារ ។

១. វិន. មហា. មហាខន្ធក. ៦. ៨១/១៤៧ ។

អ្នកដែលលះបង់សម្មាទិដ្ឋិចេញ ប្រកបដោយអន្តគាហិកមិច្ឆាទិដ្ឋិ ឈ្មោះថា វិបត្តិដោយទិដ្ឋិក្នុងអតិទិដ្ឋិ ។ សុតៈមានប្រមាណប៉ុនណា ដែលភិក្ខុជាអ្នកគ្រប់គ្រងបរិស័ទគប្បីប្រាថ្នា ព្រោះប្រាសចាកសុតៈនោះ ឈ្មោះថាអ្នកមានសុតៈតិច ។ ព្រោះមិនដឹងចំណែកដែលលោកគួរដឹង មានអាបត្តិជាដើម ទើបឈ្មោះថា អ្នកមានបញ្ញាទន់ខ្សោយ ។ ក៏ក្នុងបញ្ចកៈនេះ បីបទខាងដើម ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃភិក្ខុដែលមិនសមគួរប៉ុណ្ណោះ ពីរបទខាងចុងត្រាស់ដោយអំណាចអង្គនៃអាបត្តិ ។

ពាក្យថា **អាបត្តឹ ន ជានាតិ : មិនស្គាល់អាបត្តិ** មានសេចក្តីថា កាលសទ្ធិវិហារិក ឬអន្តេវាសិកប្រាប់ថា កម្មដូច្នេះ ខ្ញុំព្រះករុណាបានធ្វើហើយ ដូច្នេះ លោកមិនជ្រាបថា "ភិក្ខុនេះត្រូវអាបត្តិឈ្មោះនេះ" ។ ពាក្យថា **វុដ្ឋានំ ន ជានាតិ : មិនស្គាល់វិធីចេញចាកអាបត្តិ** មានសេចក្តីថា មិនស្គាល់ថា "សេចក្តីចេញចាកអាបត្តិ ដែលជាវុដ្ឋានគាមិនី ឬទេសនាគាមិនី ជាយ៉ាងនេះ" ។ ក្នុងបញ្ចកៈ នេះ ២ បទខាងដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃភិក្ខុដែលមិនសមគួរ, បីបទខាងចុង ត្រាស់ដោយអំណាចអង្គនៃអាបត្តិ ។

ពាក្យថា **អភិសមាចារិកាយ សិក្ខាយ : ក្នុងអភិសមាចារិកសិក្ខា** មានសេចក្តីថា ជាអ្នកមិនអាចណែនាំក្នុងខន្ធកវត្ត ។

ពាក្យថា អាទិព្រហ្មចរិកាយ : ដោយអាទិព្រហ្មចរិយ មានសេចក្តីថា ជាអ្នកមិនអាចណែនាំក្នុងព្រះបញ្ញត្តិដែលគួរសិក្សា ។

ពាក្យថា អភិធម្មេ : ក្នុងធម៌ដ៏ក្រៃលែង មានសេចក្តីថា ជាអ្នកមិនអាចពន្យល់ណែនាំក្នុងនាមរូបបរិច្ឆេទ ។

ពាក្យថា អភិវិនយេ : ក្នុងវិន័យដ៏ក្រៃលែង មានសេចក្តីថា ជាអ្នកមិនអាចណែនាំក្នុងវិនយបិដកសុទ្ធ ។ ចំណែកពីរបទថា វិនេតុំ ន បដិពលោ មានសេចក្តីថា រមែងមិនអាចឱ្យសិក្សាក្នុងកិច្ចគ្រប់យ៉ាង ។

ពាក្យថា ធម្មេន វិវេចេតុំ : ដើម្បីដោះស្រាយ...ដោយធម៌ មានសេចក្តីថា ដើម្បីឱ្យលះបង់ចេញ ដោយធម៌គឺ តាមហេតុ ។

ក្នុងបញ្ចកៈនេះ ពិន័យអាបត្តិគ្រប់ ៗ បទ ។ សូម្បីក្នុងបញ្ចកៈដែលមានបទជាដើមថា មិនស្គាល់អាបត្តិ ក៏ពិន័យអាបត្តិគ្រប់ ៗបទ ។

ក្នុងបញ្ចកៈនោះ ពាក្យថា ឧភយានិ ខោ បនស្ស បាដិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ : ចេះចាំនូវបាតិមោក្ខទាំងពីរដោយពិស្តារ បានដល់ បាដិមោក្ខ ២ ដែលព្រះមានព្រះភាគត្រាស់ដោយអំណាចឧភតោវិភង្គ ។

បទថា សុវិភត្តានិ : ហើយចែកដោយល្អ បានដល់ ដែលត្រាស់ដោយអំណាចមាតិកាវិភង្គ ។

បទថា សុប្បវត្តីនិ : ប្រព្រឹត្តទៅដោយល្អ បានដល់ ដែលត្រាស់ដោយអំណាចការចាំរត់មាត់ ។

ច្រើនបទថា សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ : វិនិច្ឆ័យដោយល្អ តាមសុត្ត តាមអនុព្យញ្ជនៈ បានដល់ ដែលវិនិច្ឆ័យល្អហើយ ដោយមាតិកានិងវិភង្គ ។ សូម្បីក្នុងបញ្ញកៈដែលមានបទខាងចុងថា មានវស្សាទ្វេះ ១០ ក៏មានន័យដូចគ្នានុ៎ះឯង ។ ៣ បញ្ញកៈខាងដើម ៣ បទក្នុងបញ្ញកៈទី ៤ ពីរបទក្នុងបញ្ញកៈទី ៥ រួមទាំងអស់ជា ៤ បញ្ញកៈ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃភិក្ខុដែលមិនសមគួរ ។ ពីរបទក្នុងបញ្ញកៈទី ៤ បីបទក្នុងបញ្ញកៈទី ៥ បីបញ្ញកៈ គឺ ទី ៦ ទី ៧ ទី ៨ រួមទាំងអស់ជា ៤ បញ្ញកៈ ព្រះមានព្រះភាគត្រាស់ដោយអំណាចអង្គនៃអាបត្តិ ដោយប្រការដូច្នេះ ។ ក្នុងកុសលបក្ខមិនមានអាបត្តិឡើយទាំង ៨ បញ្ញកៈ ដូច្នេះឯង ។

[៩៩] គប្បីជ្រាបវិនិច្ឆ័យក្នុងឆក្កៈទាំងឡាយ ដូច្នេះ ឱនទសវស្សបទជាប្រការពិសេស ។ បទនោះពិន័យអាបត្តិក្នុងគ្រប់ ៗ ពួក ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

ឧបសម្បទេតព្វបញ្ញក ១៦ ដង ចប់

# ពោលអំពីបុគ្គលដែលធ្លាប់ជាតិត្ថិយដទៃ

[១០០] គប្បីជ្រាបវិនិច្ឆ័យក្នុងអញ្ញតិត្ថិយបុព្វវត្ថុតទៅ ៖

បសុរបរិព្វាជកនេះ មិនគួរឱ្យឧបសម្បទា ព្រោះត្រឡប់ទៅចូលអន្យតិរ្ថិយហើយ ។ ចំណែកតិរ្ថិយសូម្បីដទៃអ្នកណា មិនធ្លាប់បួសក្នុងសាសនានេះមក កិច្ចណាគួរធ្វើសម្រាប់តិរ្ថិយនោះ ដើម្បីសម្ដែងកិច្ចនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា យោ ភិក្ខវេ អញ្ញោបិ **: ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលដទៃណាឯទៀត** ជាដើម ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា តស្ស ចត្តារោ មាសេ បរិវាសោ ទាតព្វោ : សង្ឃត្រូវឱ្យបរិវាសដល់បុគ្គលនោះ កំណត់ត្រឹម ៤ ខែ មានសេចក្ដីថា ដែលឈ្មោះថា តិត្ថិយបរិវាសនេះ លោកហៅថា អប្បដិច្ឆន្នបរិវាសខ្លះ ។ ក៏តិរ្ថិយបរិវាសនេះ គួរឱ្យដល់អាជីវក ឬអចេល អ្នកជាបរិព្វាជកអាក្រាតប៉ុណ្ណោះ ។ បើសូម្បីគេស្លៀកសំពត់សាដក ឬបណ្ដាសំពត់វាឡកម្ពលជាដើម សំពត់ដែលជាទង់ជ័យ[១] នៃតិរ្ថិយយ៉ាងណាមួយមក មិនគួរឱ្យបរិវាសដល់គេ ។ មួយទៀត អ្នកបួសដទៃ មានតាបស និងឥសីជាដើម ក៏មិនគួរឱ្យដែរ ។ ព្រះមានព្រះភាគទ្រង់សម្ដែងសាមណេរ

១. គឺ ជាសញ្ញលក្ខណ៍ ។

បព្វជ្ជាសម្រាប់គេមុន ដោយពាក្យជាដើមថា **បឋមំ កេសមស្សុំ : កោរសក់និងពុកមាត់ជាមុន** ដែលភិក្ខុទាំងឡាយ អ្នកនឹងឱ្យបួសយ៉ាងនោះ មិនគប្បីបង្គាប់ភិក្ខុទាំងឡាយថា "លោកចូរបំបួស, លោកចូរជាអាចារ្យ, លោកចូរជាឧបជ្ឈាយ៍" ក្នុងកាលកុលបុត្រដែលធ្លាប់ជាតិត្ថិយនោះ អង្គុយក្នុងកណ្តាលជំនុំសង្ឃរួចសព្វគ្រប់ហើយ ។ ព្រោះភិក្ខុទាំងឡាយ អ្នកត្រូវបង្គាប់យ៉ាងនោះ បើស្អប់ខ្ពើមដោយភាពជាអាចារ្យឧបជ្ឈាយ៍របស់គេនឹងមិនទទួល គ្រានោះកុលបុត្រនោះក្រោធថា "ភិក្ខុទាំងនេះមិនជឿយើង" ហើយគប្បីចេញទៅក៏បាន ព្រោះហេតុនោះ ភិក្ខុទាំងឡាយគប្បីនាំចូលទៅទុកមួយចំណែក ហើយសឹមរកអាចារ្យនិងឧបជ្ឈាយ៍សម្រាប់គេ ។

ដើម្បីសម្តែងបរិវាសវត្តនៃកុលបុត្រធ្លាប់ជាតិត្ថិយនោះ ទើបព្រះមានព្រះភាគទ្រង់តាំងមាតិកានេះថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិត្ថិយដទៃ ឈ្មោះថា ជាអ្នកញ៉ាំងសង្ឃឱ្យត្រេកអរយ៉ាងនេះ", រមែងជាអ្នកមិនញ៉ាំងភិក្ខុទាំងឡាយ ឱ្យត្រេកអរយ៉ាងនេះ ។ ពាក្យថា កថញ្ច ភិក្ខវេ : **ម្នាលភិក្ខុទាំងឡាយ តើដូចម្តេចខ្លះ** ជាដើម ជាវិភង្គនៃមាតិកានោះ ។ តិត្ថិយបរិវាសក្នុងបាលីនោះ គប្បីឱ្យដល់តិត្ថិយជាតិនិគ្រន្ថប៉ុណ្ណោះ មិនគួរឱ្យដល់ពួកដទៃ ។

ពាក្យថា អតិកាលេន[១] គាមំ បវិសតិ : ចូលទៅកាន់ស្រុក ហួសកាលហួសវេលា មានសេចក្តីថា ចូលស្រុកដើម្បីបិណ្ឌបាត ក្នុងវេលាដែលពួកភិក្ខុនាំគ្នាធ្វើវត្ត ។

ពាក្យថា អតិទិវា បដិក្កមតិ : ត្រឡប់មកវិញក្នុងពេលថ្ងៃពេក មានសេចក្តីថា ពោលរឿងជាប់ដោយផ្ទះ ទីងជនមានស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសជាដើម ក្នុងផ្ទះនៃត្រកូលទាំងឡាយ ឆាន់ក្នុងទីនោះឯង ហើយសឹមមកក្នុងកាលភិក្ខុទាំងឡាយរក្សាបាត្រចីវរ ហើយធ្វើកិច្ចមានឧទ្ទេស និងបរិបុច្ឆាជាដើម ឬនៅពួនសម្ងំហើយ មិនធ្វើឧបជ្ឈាយវត្ត និងអាចរិយវត្ត ចូលកាន់ទីនៅហើយដេកលក់ប៉ុណ្ណោះឯង ។

ពាក្យថា ឯវម្បិ ភិក្ខវេ អញ្ញតិត្ថិយបុព្វោ អនារាធកោ ហោតិ : ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា មិនញុំាងសង្ឃឱ្យត្រេកអរបែបនេះក៏មាន មានសេចក្តីថា កុលបុត្រដែលធ្លាប់ជាតិរ្ថិយ សូម្បីកាលធ្វើយ៉ាងនោះ ជាអ្នកមិនឈ្មោះថា ញុំាងបរិវាសវត្តឱ្យដល់ព្រម គឺ ឱ្យពេញ ។ ក្នុងពាក្យថា វេសិយគោចរោ វា : គោចរទៅកាន់សំណាក់ស្រីផ្កាមាសក្តី ជាដើម មានវិនិច្ឆ័យថា ស្ត្រីទាំងឡាយដែលអាស្រ័យរូបចិញ្ចឹមជីវិត មានអជ្ឈាចារដែលបុរសបានងាយ ដោយ

១. ថៃ. អតិកាលេ ។

បន្ថែមឱ្យតម្លៃឈ្នួលត្រឹមតែបន្តិចបន្តួចជាដើម ឈ្មោះថា ស្រីពេស្យា ។ ស្ត្រីទាំងឡាយដែលប្តីស្លាប់ ឬប្តីលែងចោលទៅ ឈ្មោះថា **ស្រីមេម៉ាយ** ។ ស្រីមេម៉ាយទាំងនោះ រមែងប្រាថ្នាសេចក្តីស្និទ្ធស្នាលនឹងប្រុសណាម្នាក់ ។ ពួកក្មេងស្រីដែលចម្រើនវ័យជាក្រមុំហើយ ឬកន្លងវ័យជាក្រមុំទៅហើយ ឈ្មោះថា **ស្រីក្រមុំចាស់** ស្រីក្រមុំចាស់ទាំងនោះ ច្រើនប្រាថ្នា ប៉ុនប៉ងប្រុសត្រាច់ទៅ រមែងប្រាថ្នាសេចក្តីស្និទ្ធស្នាលនឹងអ្នកណាមួយ ។ មនុស្សជាតិដែលមិនមែនប្រុស ឬស្រី មានកិលេសក្រាស់ មានកិលេសជាគ្រឿងក្តៅក្រហាយ ឈ្មោះថា **បណ្ឌក** ។ ពួកបណ្ឌកនោះ ត្រូវកិលេសជាគ្រឿងក្តៅក្រហាយគ្របសង្កត់ហើយ រមែងប្រាថ្នាសេចក្តីស្និទ្ធស្នាលនឹងប្រុសណាមួយ ។ ពួកស្ត្រីអ្នកមានបព្វជ្ជាស្មើគ្នា ឈ្មោះថា **ភិក្ខុនី** ។ ការស្និទ្ធស្នាលនឹងភិក្ខុនីទាំងនោះ រមែងកើតបានយ៉ាងរហ័ស ព្រោះសេចក្តីស្និទ្ធស្នាលគ្នានោះ សីលរមែងធ្លុះធ្លាយ ។ កុលបុត្រដែលធ្លាប់ជាត្តិរិយនោះ ជាអ្នកស្និទ្ធ ស្នាលក្នុងត្រកូលទាំងឡាយនៃពួកស្រីពេស្យា អាងលេសមានត្រាច់បិណ្ឌបាតជាដើម ចូលទៅកាន់សំណាក់ស្រីពេស្យាទាំងនោះ ព្រោះភាពជាអ្នកចង់ជួប និងចរចាគ្នារឿយ ៗ ដោយទឹកចិត្តដែលមានការសរសើរ ដោយសេចក្តីស្រឡាញ់ លោកហៅថា **វេសិយគោចរ** ក្នុងបណ្តាគោចរទាំងនោះ ។ គេរមែងជាអ្នកត្រូវពពួកជននិយាយថា "មិនយូរប៉ុន្មាន នឹងទៅជាមួយស្រីពេស្យាឯណោះហើយ" ។

មានន័យដូច្នេះគ្រប់ ៗ គោចរ ។ ក៏បើស្រីពេស្យាជាដើម និងប្រគេនភត្តមានសលាកភត្តជាដើម, ទៅជាមួយនឹងភិក្ខុទាំងឡាយ ហើយឆាន់ ឬទទួលជាមួយគ្នាហើយត្រឡប់មក រមែងគួរ ។ ពួកភិក្ខុនីអាពាធ ទៅជាមួយនឹងភិក្ខុនីដែលទៅដើម្បីទូន្មាន ឬសម្តែងធម៌ ឬឱ្យឧទ្ទេស និងបរិបុច្ឆាជាដើម រមែងគួរ ។ ចំណែកអ្នកដែលធ្លាប់ជាតិត្ថិយណា មិនបានទៅយ៉ាងនោះ ទៅដោយអំណាចការសរសើរ ដោយការស្និទ្ធស្នាល អ្នកនេះចាត់ថា ជាអ្នកមិនញុំាងភិក្ខុទាំងឡាយឱ្យត្រេកអរ ។

ពីរបទថា **ឧច្ចាវចានិ កិំករណីយានិ : ទាំងអស់ការងារធំតូចទាំងឡាយ** បានដល់ ការងារធំតូចទាំងឡាយ ។ បណ្តាការងារពីរយ៉ាងនោះ ការងារមានបោសសំអាតចេតិយ និងមហាប្រាសាទជាដើម ដែលសង្ឃព្រមព្រៀងគ្នា គប្បីវាយរគាំងប្រជុំគ្នាធ្វើ ចាត់ជាការងារធំ ។ ការងារដែលរាប់ចូលក្នុងខន្ធកៈ មានការបោកគក់និងជ្រលក់ចីវរជាដើម និងអភិសមាចារិកវត្ត មានវត្តដែលភិក្ខុគួរធ្វើក្នុងរោងភ្លើងជាដើម ចាត់ជាការងារតូច ។

ពាក្យថា **តត្ថ ន ទក្ខោ ហោតិ : ក៏មិនបានវាងវៃក្នុងការងារទាំងឡាយនោះឡើយ** មានសេចក្តីថា មិនជាអ្នកឆ្លាត គឺ ហ្វឹកហាត់ដោយល្អក្នុងការងារតូចធំទាំងនោះ ។

បទថា អលសោ : **ជាបុគ្គលខ្ជិល** បានដល់ មិនជាអ្នកដល់ព្រមដោយ សេចក្ដីព្យាយាម គឺ សេចក្ដីប្រឹងប្រែង គឺ បានស្ដាប់ថា ការងាររបស់ភិក្ខុសង្ឃមាន ទើបធ្វើភត្តកិច្ចពីព្រឹកព្រលឹម ហើយចូលទៅខាងក្នុងបន្ទប់ដេកលក់ស្កប់ស្កល់ ហើយចេញមកក្នុងវេលាល្ងាច ។

ពាក្យថា តត្រុបាយាយ : **ជាឧបាយក្នុងការងារនោះ** សេចក្ដីថា ដែលជាឧបាយក្នុងការងារតូចធំទាំងនោះ ។

ពាក្យថា វីមំសាយ : **ដោយបញ្ញាពិចារណា** មានសេចក្ដីថា ជាអ្នកមិនប្រកបដោយបញ្ញាសម្រាប់ពិចារណា ដែលកើតឡើងឆាបរហ័ស គឺ បញ្ញាដែលកើតឡើងក្នុងខណៈនោះថា "នេះគួរធ្វើ, នេះមិនគួរធ្វើ" ។

ពាក្យថា ន អលំ កាតុំ ន អលំ សំវិធាតុំ : **មិនអាចដើម្បីធ្វើបាន មិនអាចដើម្បីចាត់ចែងបាន** មានសេចក្ដីថា ជាអ្នកមិនអាចដើម្បីធ្វើសូម្បីដោយដៃ ទាំងជាអ្នកមិនអាចដើម្បីនឹងចាត់ចែងគឺ មិនអាចដើម្បីញ៉ាំងគ្នានិងគ្នាឱ្យធ្វើ ដោយបង្កើតសេចក្ដីឧស្សាហ៍ ឱ្យកើតយ៉ាងនេះថា "បពិត្រលោកដ៏ចម្រើន រួមដៃជួយគ្នាធ្វើចុះ នៃភិក្ខុរួមដៃជួយធ្វើទាំងអស់គ្នា នៃសាមណេររួមដៃជួយធ្វើទាំងអស់គ្នាចុះ បើពួកលោកនឹងមិនធ្វើ ឬពួកខ្ញុំព្រះករុណានឹងមិនធ្វើទេ អ្នកណាហ្ន៎នឹងធ្វើការងារនេះ" ។ កាលពួកភិក្ខុនិយាយគ្នាថា "ពួកយើងនឹងធ្វើការ" គេរមែងអាងរោគយ៉ាងណាមួយ

កាលពួកភិក្ខុកំពុងធ្វើការ ទើបត្រាច់ទៅជិត ៗ អើតតែក្បាលឱ្យឃើញ សូម្បីអ្នកនេះ ក៏ចាត់ថា ជាអ្នកមិនញ៉ាំងភិក្ខុទាំងឡាយឱ្យត្រេកអរ ។

ពាក្យថា ន តិព្វច្ឆន្ទោ ហោតិ : មិនមានសេចក្តីប្រាថ្នាដ៏ក្លៀវក្លា មានសេចក្តីថា ជាអ្នកមិនមានសេចក្តីពេញចិត្តខ្លាំងក្លា ។

បទថា ឧទ្ទេសេ : ក្នុងបាលី បានដល់ ក្នុងការរៀនបាលី ។

បទថា បរិបុច្ឆាយ : អដ្ឋកថា បានដល់ ក្នុងការអធិប្បាយសេចក្តីនៃបាលី ។

បទថា អធិសីលេ : អធិសីល បានដល់ សីល គឺបាដិមោក្ខ ។

បទថា អធិចិត្តេ : អធិចិត្ត បានដល់ ក្នុងការចម្រើលោកិយសមាធិ ។

បទថា អធិបញ្ញាយ : អធិបញ្ញា បានដល់ ក្នុងការចម្រើនលោកុត្តរមគ្គ ។

ពីរបទថា សង្កន្តោ ហោតិ : បានចេញ(ចាកលទ្ធិតិត្ថិយ) មានសេចក្តីថា ជាអ្នកចូលមកក្នុងសាសនានេះហើយ ។

ពីរបទថា តស្ស សត្ថុនោ : ចំពោះសាស្តានោះ បានដល់ គ្រូជាមេលទ្ធិ ដូចកំពង់ឆ្លងនោះ ។

ពីរបទថា តស្ស ធិដ្ឋិយា : **តាមទិដ្ឋិរបស់សាស្តានោះ** បានដល់ លទ្ធិដែលជារបស់គ្រូនោះ ។ ឥឡូវនេះ លទ្ធិនោះឯង លោកពោលថា សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត សេចក្តីប្រកាន់របស់គ្រូដែលជាម្ចាស់នៃលទ្ធិនោះ ព្រោះហេតុថា ជាទីចូលចិត្ត ជាទីពេញចិត្តរបស់តិត្ថករនោះ និងដែលតិត្ថករនោះ ប្រកាន់យ៉ាងមាំថា "នេះឯង ជាពាក្យពិត" ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា "តាមសេចក្តីគាប់ចិត្ត តាមសេចក្តីពេញចិត្ត និងតាមសេចក្តីប្រកាន់របស់សាស្តានោះ" ។

ពីរបទថា អវណ្ណេ ភញ្ញមានេ : **កាលបើមានគេពោលតិះដៀល** មានសេចក្តីថា កាលពាក្យតិះដៀលដែលអ្នកណាម្នាក់ពោល ។

បទថា អនភិរទ្ធោ : **ឥតត្រេកអរឡើយ** បានដល់ ជាអ្នកមានសេចក្តីត្រិះរិះមិនបរិបូរណ៍ គឺ មានចិត្តមិនបានផ្គងទុក ។

បទថា ឧទគ្គោ : **ជាអ្នកខ្ពស់ឡើង** បានដល់ ជាអ្នកមានកាយនិងចិត្តអណ្តែតឡើងខ្ពស់ក្រៃលែង ។

ពាក្យថា ឥទំ ភិក្ខវេ សង្ឃាតនិកំ អញ្ញតិត្ថិយបុព្វស្ស អនារាធនីយស្មឹ : **ម្នាលភិក្ខុទាំងឡាយ អំពើនេះជាហេតុដំផ្ទើម ក្នុងកិរិយាដែលមិនបានញ៉ាំងសង្ឃឲ្យត្រេកអររបស់បុគ្គលដែលធ្លាប់ជាតិត្ថិយដទៃ** មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកមានចិត្តមិនរីករាយ

ដែលកើតពីកាយវិការ និងវចីវិការថា "ធ្វើដូចម្តេចជនទាំងនេះ ទីងតិះ ដៀលអ្នកដទៃ ?" ដូច្នេះ ក្នុងកាលគេពោលទោសនៃគ្រូនោះ និងលទ្ធិនៃគ្រូនោះឯង និងភាពជាអ្នកមានចិត្តរីករាយ ក្នុងកាលគេពោលទោសនៃព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ។ និងភាពជាអ្នកមានចិត្ត ទាំងមិនរីករាយក្នុងកាលគេសរសើរគុណនៃគ្រូនោះឯង ដោយហេតុនៃព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមផង ។ ៣ ប្រការនេះ ជាគ្រឿងដេញដោលសួរ ក្នុងកម្មដែលមិនទាំឱ្យភិក្ខុទាំងឡាយ ត្រេកអររបស់កុលបុត្រ ដែលធ្លាប់ជាអន្យតិរ្ថិយ ។ មានពាក្យអធិប្បាយថា យ៉ាងនេះជាគ្រឿងសំដៅ, យ៉ាងនេះជាលក្ខណៈ, យ៉ាងនេះជាសេចក្តីពិតប្រាកដ, យ៉ាងនេះជាកម្លាំង, យ៉ាងនេះជាប្រមាណ ក្នុងកម្មដែលមិនធ្វើ បរិវាសវត្តឱ្យពេញ មិនញុំាងភិក្ខុទាំងឡាយឱ្យត្រេកអរ ។

ពាក្យថា ឯវំ អនារាធកោ ខោ ភិក្ខវេ អញ្ញតិត្ថិយបុព្វោ អាគតោ ន ឧបសម្បាទេតព្វោ : ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មិនបានញុំាងសង្ឃឱ្យត្រេកអរយ៉ាងនេះ បើត្រឡប់មកវិញ សង្ឃមិនត្រូវឱ្យឧបសម្បទាឡើយ មានសេចក្តីថា កុលបុត្រដែលធ្លាប់ជាតិរ្ថិយដែលប្រកបដោយអង្គទាំងនេះ សូម្បីអង្គតែមួយ ភិក្ខុមិនគួរឱ្យឧបសម្បទា ។ ពាក្យទាំងពួងក្នុងចំណែកដ៏សេស គប្បីជ្រាបដោយ

សេចក្តីដែលពោលហើយក្នុងសុក្កបក្ខ ។

ពាក្យថា **ឯវំ អារាធកោ ខោ ភិក្ខវេ** : ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិត្ថិយដទៃបានញុំាងសង្ឃឱ្យត្រេកអរយ៉ាងនេះហើយ ជាដើម មានសេចក្តីថា កុលបុត្រដែលធ្លាប់ជាតិត្ថិយ ញុំាងភិក្ខុទាំងឡាយ ឱ្យត្រេកអរ ឱ្យពេញចិត្តដោយការបំពេញតិត្ថិយវត្ត ៨ ប្រការទាំងនេះ គឺ ចូលស្រុកមិនខុសវេលា ត្រឡប់មិនល្ងាចពេក, ភាពជាអ្នកធំមិនមានស្រីពេស្យាជាដើម ជាគោចរ, ជាអ្នកប្រឹងប្រែងក្នុងកិច្ចទាំងឡាយរបស់សម្លាញ់សព្រហ្មចារី, ជាអ្នកមានឆន្ទៈខ្លាំងក្លា ក្នុងឧទ្ទេសជាដើម, ជាអ្នកមានចិត្តរីករាយ ព្រោះការពោលទោសតិះដៀលពួកតិត្ថិយ, ជាអ្នកមានចិត្តមិនរីករាយ ព្រោះការពោលទោសតិះដៀលព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម, ជាអ្នកមានចិត្តមិនរីករាយ ព្រោះការសរសើរគុណតិត្ថិយ, ជាអ្នកមានចិត្តរីករាយ ព្រោះការសរសើរគុណព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម, យ៉ាងនេះ មកហើយ គួរឱ្យឧបសម្បទា, តែបើវត្តណាមួយបែកធ្លាយហើយ សូម្បីក្នុងពេលឧបសម្ប័ទ គប្បីនៅបរិវាសគ្រប់ ៤ ខែទៀត ។ ដូចឧបមាថា សិក្ខាបទនិងសិក្ខាសម្មតិដែលភិក្ខុនីសង្ឃ តែងឱ្យដល់នាងសិក្ខមានាដែលលាសិក្ខាទៀត យ៉ាងណា, វត្តណាមួយ ដែលគប្បីឱ្យដល់កុលបុត្រដែលធ្លាប់ជាតិត្ថិយនេះទៀត រមែងមានយ៉ាងនោះ ក៏

ទេ ។ ការពិត បរិវាសដែលធ្លាប់ឱ្យហើយនុ៎ះឯង ជាបរិវាសរបស់គេ ។ ព្រោះហេតុនោះ គេគប្បីនៅបរិវាសគ្រប់ ៤ ខែទៀត ។ បើកំពុងនៅបរិវាសញ៉ាំងសមាបត្តិ ៨ ឱ្យកើតបានក្នុងចន្លោះសោត ។ ធម្មតាអ្នកបានលោកិយធម៌នៅកម្រើកបានជាពិតប្រាកដ ទើបមិនទាន់គួរឱ្យឧបសម្បទាពិត ។ តែបំពេញវត្តគ្រប់ ៤ ខែ ហើយ ទើបគួរឱ្យឧបសម្បទា ។ ម្យ៉ាងទៀត បើកំពុងនៅបរិវាសកំណត់មហាភូតរូប ៤ បាន, កំណត់ឧបាទាយរូបបាន, កំណត់នាមរូបបាន, ផ្ដើមវិបស្សនាលើកឡើងកាន់ត្រៃលក្ខណ៍ ។ ធម្មតាអ្នកបានលោកិយធម៌ តែងកម្រើកបានជាប្រក្រតី ទើបមិនទាន់គួរឱ្យឧបសម្បទានុ៎ះឯង ។ តែបើចម្រើនវិបស្សនាហើយបាន សោតាបត្តិមគ្គ វត្តជាការបរិបូរណ៍ពិត, ទិដ្ឋិទាំងពួងជាការដែលលោកដកហើយ, ព្រួញ គឺ វិចិកិច្ឆាជាការលោកដកឡើងហើយ គួរឱ្យឧបសម្បទាក្នុងថ្ងៃនោះតែម្ដង ។ បើសូម្បីលោកគង់នៅក្នុងភេទតិរ្ថិយ តែជាសោតាបន្ន កិច្ចដែលនិងត្រូវឱ្យបរិវាស រមែងមិនមាន គួរឱ្យបព្វជ្ជាឧបសម្បទាក្នុងថ្ងៃនោះពិត ។

ពាក្យថា ឧបជ្ឈាយមូលកំ ចីវរំ បរិយេសិតព្វំ : សង្ឃត្រូវស្វែងរកចីវរ មានឧបជ្ឈាយ៍ជាមូលឱ្យ មានសេចក្ដីថា ចីវរសម្រាប់គេ សង្ឃគួរប្រគល់ឱ្យឧបជ្ឈាយ៍ជាធំស្វែងរកមក ។ សូម្បីបាត្រក៏ដូចគ្នា ។

ព្រោះហេតុនោះ បើបាត្រចីវររបស់ឧបជ្ឈាយ៍មាន គប្បីប្រាប់ឧបជ្ឈាយ៍ថា ចូរឱ្យដល់អ្នកនេះ ។ បើមិនមាន ភិក្ខុពួកដទៃជាអ្នកចង់ឱ្យ សូម្បីភិក្ខុពួកដទៃនោះ គប្បីថ្វាយឧបជ្ឈាយ៍នោះឯង ដោយពាក្យថា ចូរធ្វើបាត្រចីវរនេះ ឱ្យជារបស់លោក ហើយឱ្យដល់អ្នកនេះ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះដែលឈ្មោះថា ពួកតិរ្ថិយ រមែងជាសត្រូវនឹងគប្បីនិយាយបានថា "បាត្រ ចីវរ សង្ឃបានឱ្យខ្ញុំព្រះករុណា ខ្ញុំព្រះករុណាមានអ្វីជាប់ទាក់ទងក្នុងពួកលោក" ដូច្នេះ ហើយមិនធ្វើតាមពាក្យជាស់តឿនទូន្មាន ។ ប៉ុន្តែថា ព្រោះគេមានការរស់នៅ ជាប់ជាមួយឧបជ្ឈាយ៍ ទើបជាអ្នកធ្វើតាមពាក្យរបស់លោក ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ចីវររបស់គេ គប្បីឱ្យឧបជ្ឈាយ៍ជាធំស្វែងរកមក ។

បទថា ភណ្ឌុកម្មាយ : ធ្វើភណ្ឌុកម្មឱ្យ គឺ ដើម្បីកោរសក់ ។ ភណ្ឌុកម្មកថា នឹងមកខាងមុខ ។

បទថា អគ្គិកា : ជាអ្នកបូជាភ្លើង បានដល់ អ្នកបម្រើភ្លើង ។

បទថា ជដិលកា : ជាជដិល(អ្នកមានផ្នួងសក់) បានដល់តាបស ។

ច្រើនបទថា ឯតេ ភិក្ខវេ កិរិយវាទិនោ : ម្នាលភិក្ខុទាំង

ឡាយ ព្រោះថា ជនទាំងនេះជាកិរិយវាទី មានសេចក្តីថា ជដិលទាំងនោះ មិនជំទាស់ការធ្វើ គឺ ជាអ្នកមានទិដ្ឋិយ៉ាងនេះថា កម្មមាន វិបាករបស់កម្ម មាន ។ កាលព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់បំពេញនេក្ខម្មបារមី ទ្រង់បាន អាស្រ័យបព្វជ្ជានោះឯងហើយ ទើបទ្រង់បំពេញព្រះបារមី ។ នេក្ខម្មបារមី នោះ សូម្បីយើងក៏បានបំពេញហើយយ៉ាងនោះដែរ ។ ការដែលជដិល ទាំងនេះបួសក្នុងសាសនាមិនជាសត្រូវ ព្រោះហេតុនោះ ទើបគួរឱ្យ ឧបសម្បទាបាន មិនត្រូវឱ្យបរិវាសដល់ពួកគេ ។

ពាក្យថា ឥមាហំ ភិក្ខវេ ញាតីនំ អាវេណិកំ បរិហារំ ទម្មិ : ម្នាលភិក្ខុទាំងឡាយ ត្បិតតថាគតឱ្យការបរិហារនេះ ឱ្យផ្សេងគ្នាដល់ ពួកញាតិ មានសេចក្តីថា តថាគតឱ្យបរិហារជាចំណែកចំពោះ គឺ ជា ចំណែកចំពោះនេះដល់ញាតិទាំងនោះ ។ ហេតុអ្វីទើបត្រាស់យ៉ាងនេះ ? ដែលព្រះញាតិទាំងនោះ សូម្បីបួសហើយក្នុងសំណាក់នៃតិត្ថិយ តែមិនជា អ្នកបន្ទោសដល់ព្រះសាសនា ។ គង់តែជាអ្នកសរសើរគុណថា សាសនានៃព្រះញាតិដ៏ប្រសើររបស់ពួកយើង ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនោះ ដូច្នេះឯង ។

ពោលអំពីបុគ្គលដែលធ្លាប់ជាតិត្ថិយដទៃ ចប់

# អន្តរាយិកធម្មកថា

## អាពាធ ៥ យ៉ាង

[១០១] ពាក្យថា មគធេសុ បញ្ច អាពាធា ឧស្សន្នា ហោន្តិ : អាពាធទាំងឡាយ ៥ យ៉ាង កើតមានច្រើនក្នុងដែនមគធៈ មានសេចក្ដីថា រោគ ៥ ប្រភេទ ជារោគឆ្លងពាសពេញ គឺ រាលដាល បែកខ្ញែកច្រើនដល់ពួកមនុស្ស និងអមនុស្សក្នុងជនបទ មានឈ្មោះថា មគធៈ ។ រឿងពេទ្យជីវកកោមារភច្ច នឹងមានច្បាស់ក្នុងចីវរក្ខន្ធកៈ ។

ពាក្យថា ន ភិក្ខវេ បញ្ចហិ អាពាធេហិ ផុដ្ឋោ បព្វាជេតព្វោ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយ មិនគប្បីបំបួសឡើយ មានសេចក្ដីថា អាពាធ ៥ ប្រភេទ មានរោគឃ្លង់ជាដើមទាំងនោះ បានឆ្លងពាសពេញហើយ, កុលបុត្រដែលអាពាធទាំងនោះ ពាល់ត្រូវហើយ គឺ គ្របសង្កត់ហើយ មិនគួរបំបួស ។ បណ្ដាអាពាធ ៥ ប្រភេទនោះ រោគឃ្លង់ក្រហម ឬរោគឃ្លង់ខ្មៅក៏ដោយ ឈ្មោះថា រោគឃ្លង់ ។

ក្នុងអដ្ឋកថា កុរុន្ទីពន្យល់ថា រោគប្រភេទណាមួយ សូម្បីមានប្រភេទជាដើមថា ឃ្លង់ផេះ ដំណួចពិស រមាស់ កមគ្រិន គ្រប់យ៉ាងលោកហៅថា រោគឃ្លង់ ដូចគ្នា ។ ក៏ឯរោគឃ្លង់នោះ សូម្បីមានខ្នាតប៉ុន

ខ្នងក្រចក តែតាំងនៅក្នុងចំណែកដែលអាចរាលដាលទៅបាន កុលបុត្រនោះ មិនគួរឱ្យបួស ។ តែបើក្នុងទីដែលសំពត់ស្លៀកសំពត់ដណ្តប់បិទទុកដោយប្រក្រតី ជារបស់មានខ្នាតប៉ុនខ្នងក្រចក តាំងនៅក្នុងចំណែកដែលមិនរាលដាលទៅបាន, នឹងឱ្យបព្វជ្ជា ក៏គួរ ។ ចំណែកនៅត្រង់មុខ ឬត្រង់ខ្នងដៃ ត្រង់ខ្នងជើង សូម្បីថា មិនរាលដាលទៅបាន ទោះជាតូចជាងខ្នងក្រចក មិនគួរនឹងបំបួសដូចគ្នា ។ អ្នកដែលជារោគឃ្លង់នោះ សូម្បីឱ្យផ្សំថ្នាំ ព្យាបាលហើយបំបួស ក្នុងកាលដំបៅជាសះស្បើយ ស្និទ្ធហើយនោះឯង ទើបគួរបំបួស ។ សូម្បីអ្នកដែលរាងកាយ រទុះទៅដោយស្នាមអុជ ៗ ស្រដៀងស្បែកទន្សង ក៏មិនគួរបំបួស ។ រោគបូស មានបូស ខ្ទុះខាប់ជាដើម ឈ្មោះថា បូស ។ បូសខ្ទុះខាប់ ឬបូសដទៃប្រភេទណាមួយក៏ដោយ ចូរលើកទុក ។ បើបូសសូម្បីមានខ្នាតប៉ុនគ្រាប់ពទ្រា តាំងនៅក្នុងចំណែកដែលរាលដាលទៅបាន កុលបុត្រនោះ មិនគួរបំបួស ។ តែក្នុងទីដែលបិទបាំង មានទំហំប៉ុនគ្រាប់ពទ្រា តាំងនៅក្នុងចំណែកដែលមិនរាលដាលទៅបាន បំបួសក៏គួរ ។ ក្នុងទីដែលមិនបានបិទបាំង មានមុខជាដើម សូម្បីតាំងនៅក្នុងចំណែកដែលនឹងមិនរាលដាលទៅបានក៏ដោយ ក៏មិនគួរបំបួស ។ កុលបុត្រនោះ ជារោគបូសនោះ សូម្បីឱ្យផ្សំថ្នាំ ព្យាបាលហើយ ធ្វើរាងកាយឱ្យមានសម្បុររាបស្មើ ទើបគួរបំបួស ។

ដែលឈ្មោះថា ក្រម៉ោងស្រដៀងដោះគោ ឬស្រដៀងម្រាមដៃ ជាប់នៅបន្ទោងក្នុងទីនោះ ៗក៏មាន សូម្បីក្រម៉ោងទាំងនេះ ក៏ចាត់ជាបូស ដូចគ្នា កាលនៅមានក្រម៉ោងទាំងនោះ មិនគួរបំបួស ។ គ្រាប់រឹង កាលនៅពីក្មេង ដែលឈ្មោះថា រោគសើស្បែក ដែលមានត្រង់ ផ្ទៃមុខកាលពីនៅកំលោះ កាលសះបាត់អស់ទៅ គ្រាប់រឹងនិងរោគសើស្បែកទាំងនោះ មិនរាប់ជាបូស កាលរោគទាំងនោះមាន បំបួសក៏គួរ ។ ចំណែករោគប្រភេទដទៃ ដែលឈ្មោះថា រោគចាញ់ថ្ងៃ មានតាមខ្លួនប្រភេទដទៃទៀត ដែលឈ្មោះថា កេសរឈូកក៏មាន ប្រភេទដទៃដែលឈ្មោះថា គ្រាប់ស្ពៃមានខ្នាតប៉ុនគ្រាប់ស្ពៃ កន្ទួលពេញខ្លួន ។

គ្រាប់ទាំងអស់នោះ ជាជាតិរោគឃ្លង់ដូចគ្នា កាលនៅមានគ្រាប់ទាំងនោះ មិនគួរបំបួស ។ រោគឃ្លង់មានពណ៌, ស្រដៀងស្លឹកឈូកក្រហម និងឈូកស មិនបែក មិនហូរ ឈ្មោះថា រោគស្រែង រាងកាយជាអវយវៈស្នាមជាំ ដូចក្រហែងក្រចកជើងគោ ដោយរោគឃ្លង់ប្រភេទណា ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងរោគស្រែងនោះ ដោយន័យដែលពោលហើយ ក្នុងរោគឃ្លង់ប្រភេទនេះឯង ។

ជម្ងឺរីងរៃ ឈ្មោះថា សោសៈ រោគរីងរៃ ។ កាលរោគរីងរៃនោះមាន មិនគួរបំបួស ។

រោគឆ្កួតព្រោះប្រម៉ាត់ ឬរោគឆ្កួត ដោយត្រូវខ្មោចស្ដិត ឈ្មោះថា រោគឆ្កួតជ្រូក ៗ ក្នុងរោគឆ្កួតជ្រូក ២ ប្រភេទ បុគ្គលដែលត្រូវអមនុស្សធ្លាប់ជាគូពៀរវេរាគ្នាស្ដិតហើយ រមែងជាអ្នកដែលផ្សំថ្នាំព្យាបាលបានលំបាក ៗ និងកាលរោគឆ្កួតជ្រូកនោះ សូម្បីមានត្រឹមតែបន្តិចបន្តួច ក៏មិនគួរបំបួស ៗ

## បព្វជ្ជានៃរាជអាមាត្យ

[១០២] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងរាជភដតទៅ ៖

ពីរបទថា បច្ចន្តំ ឧច្ចិនថ : ចូរទៅត្រួតមើលស្រុកចុងដែន មានសេចក្ដីថា លោកទាំងឡាយ ចូរញ៉ាំងបច្ចន្តជនបទឱ្យចម្រើន មានពាក្យអធិប្បាយថា លោកទាំងឡាយចូរបណ្ដេញពួកចោរចេញហើយ ចាត់ចែងស្រុក ដែលរួចផុតចោរភ័យឱ្យស្ងប់ស្ងាត់ ចាត់ការរក្សាដោយប្រឹតប្រៀនឱ្យការងារកសិកម្មជាដើមប្រព្រឹត្តទៅ ៗ ចំណែកព្រះរាជា ព្រះអង្គជាព្រះសោតាបន្ន ទើបទ្រង់មិនបង្គាប់ថា ចូរសម្លាប់ ចូរប្រហារពួកចោរ ៗ ពួកអាមាត្រដែលជាអ្នកកាន់ច្បាប់ គិតថា ក្នុងបព្វជ្ជា ឧបជ្ឈាយ៍ជាធំបន្ទាប់ទៅអាចារ្យ បន្ទាប់ចុះទៅគណៈ ទើបនាំគ្នាក្រាបទូលពាក្យទាំងពួងមានជាដើមថា បពិត្រព្រះសម្មតិទេព ត្រូវកាត់សីសៈឧបជ្ឈាយ៍ចេញ ដោយគិតឃើញថា នេះ មកក្នុងសេចក្ដីវិនិច្ឆ័យនៃច្បាប់ ៗ

ក្នុងពាក្យថា ន ភិក្ខវេ រាជភដោ បព្វាជេតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសរាជអាមាត្យទេ នេះ មានវិនិច្ឆ័យថា ទីងជាអាមាត្រ ឬមហាមាត្រ ឬសេវកា ឬអ្នកបានឋានន្តរតូច ឬអ្នកមិនបានក៏ដោយ បុគ្គលណាម្នាក់ ដែលបានទទួលចិញ្ចឹមដោយអាហារ ឬប្រាក់របស់ព្រះរាជា ដល់ការរាប់ថា រាជភដៈទាំងអស់ រាជភដៈនោះ មិនគួរបំបួស ។ ចំណែកបុត្រ បងប្អូនប្រុស និងក្មួយប្រុសជាដើមរបស់រាជភដនោះ មិនបានទទួលអាហារ ឬប្រាក់ឈ្នួលពីព្រះរាជា ទីងឱ្យជនទាំងនោះបួស គួរ ។ ចំណែកអ្នកណា យកភោគៈជាប្រចាំ ឬប្រាក់ខែរាល់ខែ បៀវត្សរាល់ឆ្នាំ ដែលខ្លួនបានទទួលព្រះរាជទាន ថ្វាយសងចំពោះព្រះរាជាវិញ ឬឱ្យបុត្រ និងបងប្អូនប្រុសទទួលតំណែងនោះជំនួស ហើយទូលលាព្រះរាជាថា "ឥឡូវនេះ ទូលព្រះបង្គំឈប់ជាអ្នកបានទទួលចិញ្ចឹមរបស់ទេវរាជហើយ" ។ ឬថា អាហារនិងប្រាក់ឈ្នួលដែលអ្នកណាបានទទួល ព្រោះហេតុនៃរាជការណា, រាជការនោះ ជាកិច្ចដែលខ្លួនធ្វើរួចស្រេចហើយ, ឬអ្នកណាជាអ្នកបានបរមរាជានុញ្ញាតថា "អ្នកឯងបួសចុះ" ទីងឱ្យបុគ្គលនោះបួស គួរ ។

អន្តរាយិកធម្មកថា ចប់

# អភយូវរភាណវារៈ

## ចោរប្រាកដដូចទង់ជ័យ

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងចោរទាំងឡាយ ៖

[១០៣] ពីរបទថា មនុស្សា បស្សិត្វា : មនុស្សទាំងឡាយបានឃើញហើយ មានសេចក្ដីថា ព្រះអង្គុលិមាលនោះ ដែលជនពួកណាធ្លាប់ឃើញក្នុងកាលដែលលោកនៅជាគ្រហស្ថ និងជនពួកណា បានស្ដាប់បន្តពីជនដទៃថា ភិក្ខុនេះ គឺ អង្គុលិមាលនោះ ជនទាំងនោះបានឃើញហើយ រមែងតក់ស្លុតចិត្តខ្លះ រមែងខ្លាចស្ទន់ស្ទោខ្លះ រមែងបិទទ្វារខ្លះ ។ តែលោក រមែងបានភិក្ខាក្នុងផ្ទះរបស់ពួកជនដែលមិនស្គាល់ ។

បទថា ន ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន... មានសេចក្ដីថា ព្រះមានព្រះភាគ ព្រះអង្គជាម្ចាស់នៃធម៌ ព្រោះដូច្នោះ កាលទ្រង់បញ្ញត្តិសិក្ខាបទ ដល់ភិក្ខុទាំងឡាយ ដើម្បីត្រូវការមិនឱ្យធ្វើតទៅ ទើបត្រាស់យ៉ាងនោះ ។ វិនិច្ឆ័យក្នុងពាក្យនោះថា ចោរឈ្មោះថា ធជព័ន្ធ ព្រោះអត្ថវិគ្រោះថា ដូចចងទង់ត្រាច់ទៅ ។ មានពាក្យអធិប្បាយថា ជាមនុស្ស ល្បីល្បាញក្នុងលោក ដូចមូលទេព[១]ជាដើម ។ ព្រោះហេតុ

---

១. ក្នុងព្រះបាលីវិន័យជា ធជពន្ធោ ។ ចំណែកពាក្យថា មូលទេវាទយោ យោជនាពន្យល់អត្ថថា អាទិភូតទេវាទយោ ។ ធជពន្ធោ សំដៅសេចក្ដីទៅ ក្នុងមកមានឈ្មោះ

នោះ អ្នកណាត្រាច់ធ្វើការសម្លាប់អ្នកស្រុកក្តី រុកកួនអ្នកធ្វើដំណើរក្តី ។ ធ្វើកម្មមានកាត់ទីតជាដើមក្នុងក្រុងក្តី មួយទៀត ជនណាដែលមនុស្សទាំងឡាយស្គាល់ឈ្មោះថា “ជនឈ្មោះឯណោះ ធ្វើកម្មនេះ ៗ” ជននោះ មិនគួរបំបួស ។ ចំណែកអ្នកណា ជារាជបុត្រ ប្រាថ្នាជាព្រះរាជា ធ្វើកម្មមានសម្លាប់អ្នកស្រុកជាដើម ។ អ្នកនោះ គួរបំបួស ។ ព្រោះថា កាលរាជបុត្រនោះ ទ្រទ្រង់ព្រះផ្នួសហើយ ព្រះរាជាទាំងឡាយ រមែងពេញព្រះហឫទ័យ តែបើទ្រង់មិនពេញព្រះហឫទ័យ មិនគួរបំបួស ។ ចោរដែលល្បីឈ្មោះក្នុងមហាជន ក្នុងកាលមុន ខាងក្រោយលះបង់ចោរកម្មចេញសមាទានសីល ៥ ។ បើអ្នកស្រុកស្គាល់គេយ៉ាងនោះ គួរបំបួស ។ ចំណែកជនពួកណា ជាអ្នកលួចរបស់តិចតួចមានស្វាយ និងខ្នុរជាដើម ឬជាចោរដែលកាត់ទីតជាដើម ត្រាច់ទៅអែបកំផែងធ្វើការលួច ទាំងខាងក្រោយក៏មិនប្រាកដថា “កម្មនេះ ដែលជនឈ្មោះនេះធ្វើ” នឹងឱ្យជនទាំងនោះបួស ក៏គួរ ។

(ត). ល្បីខាងខូច អាងថា ដូចមូលទេពជាដើម ពាក្យថា មូលទេវោ ភាសាសំស្រ្កិត ជាព្រះនាមរបស់ស្តេចកង្សៈ ក្សត្រិយ៍ទរាជ (ស្តេចឃោឃៅ)នៃដែនមថុរា ទ្រង់សម្លាប់ទារកចោលច្រើនណាស់ គជាគំនរ ។ ព្រោះហោរទាយថា ព្រះអង្គនិងត្រូវកូនប្រុសរបស់ស្រីម្នាក់ផ្តាច់ព្រះជន្ម ដោយសេចក្តីភយ ការណ៍ នេះឯង ប្រជាជនពលក្រុងទើបឃើញថា ស្តេចជាអសុរ ជាយក្ខ ជាមារមូលទេវោ នឹង មកជា ឧបមាក្នុងពាក្យថា មូលទេវោយោ នេះឬយ៉ាងណា ?

## ចោរទម្លាយគុក

[១០៤] ពីរបទថា ការំ ភិន្ទិត្វា : ទម្លាយគុកបានហើយ មានសេចក្តីថា ទម្លាយ ចំណងគឺ រនុកជាដើម ។

ក្នុងបទថា អភយូវរា : ជាអ្នកបានព្រះរាជទានអភ័យ នេះ មានវិនិច្ឆ័យថា ជនពួកណា រមែងជៀសចេញទៅ ព្រោះសេចក្តីខ្លាច ហេតុនោះ ជនទាំងនោះ ឈ្មោះ ភយូវរា អ្នកជៀសចេញទៅ ព្រោះសេចក្តីខ្លាច ចំណែកសមណៈ ទាំងនេះ មិនមែនអ្នកជៀសចេញទៅ ព្រោះសេចក្តីខ្លាច ព្រោះជាអ្នកបានទទួលអភ័យ ព្រោះដូច្នោះ ទើបឈ្មោះ **អភយូវរា** មិនមែន អ្នកជៀសចេញទៅព្រោះសេចក្តីខ្លាច ។ ក៏ឯក្នុងបទថា **អភយូវរា** នេះគប្បីជ្រាបថា ផ្លាស់ ប អក្សរឱ្យជា វ អក្សរ ។

ក្នុងពាក្យថា ន ភិក្ខវេ ការភេទកោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន ... ដែលទម្លាយគុកទេ នេះ មានវិនិច្ឆ័យថា គុក ហៅថា ការៈ តែក្នុងអធិការនេះ ចំណងគឺរនុកក្តី ចំណងគឺខ្នោះឬច្រវាក់ក្តី ចំណងគឺខ្សែក្តី ទីចងគឺស្រុកក្តី ទីចងគឺនិគមក្តី ទីចងគឺទីក្រុងក្តី ការឃុំឃាំងដោយបុរសក្តី ទីចងគឺជនបទក្តី ទីចងគឺទ្វីបក្តី ចូរលើកទុក ។ អ្នកណាទម្លាយ ឬ កាត់ ឬស្រាយ ឬ បើកចំណងប្រភេទណាមួយ ក្នុងបណ្តាគ្រឿងចង

ទាំងនេះ គេចចេញទៅត្រង់មុខ ឬមិនមានអ្នកឃើញ អ្នកនោះ ដល់ការរាប់ថា **ការភេទក** : អ្នកទម្លាយគុក ។

ព្រោះហេតុនោះ ការភេទកចោរទាំងនេះ ទម្លាយទីចង គឺខ្នោះ ទៅកាន់ទ្វីបដទៃហើយក្តី មិនគួរបំបួស ។

ចំណែកអ្នកណាដែលមិនមែនចោរ តែមិនព្រមធ្វើហត្ថកម្មតែម្យ៉ាង ត្រូវឥស្សរជនទាំងឡាយ មានអ្នកកាន់សួយរបស់ព្រះរាជាជាដើមឃុំឃាំងទុក ដោយសំគាល់ថា កាលមានការឃុំឃាំងទុកយ៉ាងនេះ អ្នកនេះនឹងគេចចេញមិនបាន នឹងធ្វើការរបស់យើង ដូច្នេះក្តី អ្នកនោះសូម្បីទម្លាយចំណង គេចចេញទៅ ក៏គួរបំបួស ។

ចំណែកអ្នកណាទទួលចងដាច់ស្រុក និគម និងកំពង់ជាដើម ដោយសួយ មិនបញ្ជូនសួយនោះឱ្យគ្រប់ ត្រូវបញ្ជូនទៅកាន់គុក អ្នកនោះគេចចេញមកហើយ មិនគួរបំបួស ។

សូម្បីអ្នកណារួមរក្សាទ្រព្យទុក ចិញ្ចឹមជីវិតដោយកសិកម្មជាដើម ត្រូវអ្នកណា ៗ សិកសៀតដាក់ទោសថា អ្នកនេះបានរណ្តៅទ្រព្យ ហើយត្រូវឃុំឃាំង នឹងឱ្យអ្នកនោះបួស ក្នុងអាវាសនោះឯង មិនគួរ ។ តែបើគេគេចចេញទៅហើយ នឹងឱ្យបួសក្នុងទីដែលទៅហើយគ្រប់តំបន់ គួរ ។

## ចោរដែលរាជការកត់ឈ្មោះទុកក្នុងបញ្ជី

[១០៥] ក្នុងពាក្យនេះថា ន ភិក្ខវេ លិខិតកោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន ... ដែលរាជការកត់ឈ្មោះទុក ជាដើមនេះ មានវិនិច្ឆ័យថា បុគ្គលដែលឈ្មោះថា ជនអាក្រក់ដែលត្រូវសរសេរទុក និងបានដល់ ជនអាក្រក់ដែលត្រូវសរសេរទុកថា ជួបប្រទះក្នុងទីណា ឱ្យសម្លាប់ចោលក្នុងទីនោះ ដូច្នេះតែម្យ៉ាង ក៏ទេ គឺថា អ្នកណាម្នាក់ដែលធ្វើចោរកម្ម ឬសេចក្ដីខុសក្នុងព្រះរាជាយ៉ាងធ្ងន់ប្រភេទដទៃហើយគេចចេញទៅ និងព្រះរាជាបញ្ជាឱ្យសរសេរឈ្មោះអ្នកនោះចុះក្នុងបញ្ជី ឬស្លឹករឹតថា "ជនឈ្មោះនេះ អ្នកណាជួបប្រទះក្នុងទីណា គប្បីចាប់សម្លាប់ចោលក្នុងទីនោះ" ឬថា "គប្បីកាត់អវយវៈមានដៃ និងជើងជាដើមរបស់វាចេញ" ឬថា "គប្បីឱ្យនាំមកនូវទ្រព្យពិន័យមានប្រមាណប៉ុណ្ណេះ" អ្នកនេះ ឈ្មោះថា ជនអាក្រក់ដែលត្រូវសរសេរទុក ។ អ្នកនោះ មិនគួរបំបួស ។

## ពួកមនុស្សដែលគេបៀតបៀន

[១០៦] ក្នុងពាក្យថា កសាហតោ កតទណ្ឌកម្មោ : មានស្នាមដែលគេវាយដោយរំពាត់ ដែលគេបានធ្វើទណ្ឌកម្មហើយ នេះ មានវិនិច្ឆ័យថា អ្នកណាមិនព្រមធ្វើការ មានឱ្យការ និងព្រមទទួលប្រើជាដើម

ទើបត្រូវដាក់អាជ្ញា អ្នកនោះមិនរាប់ថា អ្នកត្រូវដាក់ទណ្ឌកម្ម ។ ចំណែកអ្នកណាទទួលរក្សាទ្រព្យយ៉ាងណាមួយ ដោយជាសួយ ឬដោយប្រការដទៃហើយស៊ីចាយទ្រព្យនោះ កាលមិនអាចទឹងសង ទើបត្រូវវាយដោយផ្តៅថា "នេះឯង ចូរជាពិន័យរបស់អាឯង" អ្នកនេះឈ្មោះថា អ្នកត្រូវវាយដោយផ្តៅ ត្រូវដាក់ទណ្ឌកម្ម ។ ក៏ឯគេនិងត្រូវវាយដោយផ្តៅ ឬត្រូវដោយឈើអន្លូងជាដើមយ៉ាងណាមួយក៏ដោយ ចូរលើកទុក ដំបៅនៅស្រស់ត្រឹមណា មិនគួរបំបួសត្រឹមនោះ ។ បន្ទាប់ពីធ្វើដំបៅទាំងឡាយឱ្យសះជាប្រក្រតីហើយ ទើបគួរបំបួស ។

មួយទៀត បើអ្នកណាត្រូវគេធ្វើការប្រទូសរ៉ាយ ដោយជើង ឬដោយដៃ ឬដោយផ្លែដូង និងដុំថ្មជាដើម ហើយបញ្ជូនទៅ និងហើមជាំក្នុងរាងកាយរបស់អ្នកនោះនៅប្រាកដ មិនគួរបំបួស ។ អ្នកនោះធ្វើឱ្យបាត់ហើយ កាលហើមជាំយ៉ាងនោះ ស្រករាបទៅហើយ គួរបំបួស ។

[១០៧] ក្នុងពាក្យថា លក្ខណាហតោ កតទណ្ឌកម្មោ : ដែលគេបៀតបៀនឱ្យមានស្នាម ដែលគេធ្វើទណ្ឌកម្មហើយ នេះ មានវិនិច្ឆ័យថា ភាវៈដែលគេធ្វើទណ្ឌកម្ម គប្បីជ្រាបដោយន័យមុននុ៎ះឯង ។ ក៏ស្នាមដំបៅ ដែលត្រូវសង្កត់ដោយដែកក្រហម មានត្រង់ថ្ងាស់ ឬត្រង់អវយវៈទាំងឡាយ មានទ្រូងជាដើមរបស់បុរសណា បើបុរសនោះជាអ្នកជា ដំបៅនៅស្រស់ត្រឹមណា មិនគួរបំបួសត្រឹមនោះ ។ បើសូម្បីដំបៅ

ដែលជាសះស្បើយរបស់គេដុះឡើងរាបស្មើនឹងសម្បុរស្បែកហើយ តែស្នាមដំបៅជាសះនៅប្រាកដ កាលគេស្លៀកហើយដណ្ដប់សំពត់ឆៀងស្មាបិទបាំងរៀបរយគ្រប់ ៣ ប្រការ បើស្នាមដំបៅជានោះនៅ ក្នុងឱកាសដែលបិទបាំងប៉ុណ្ណោះ នឹងបំបួស ក៏សមគួរ, តែបើស្នាមដំបៅជានោះនៅក្នុងឱកាសដែលមិនបានបិទបាំង មិនសមគួរបំបួស ។

## អ្នកជំពាក់បំណុល

[១០៨] ក្នុងពាក្យថា ន ភិក្ខវេ ឥណាយិកោ បព្វាជេតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសមនុស្សដែលជំពាក់បំណុលគេទេ ជាដើម មានវិនិច្ឆ័យថា បំណុលដែលបិតានិងជីតារបស់បុរសណាខ្ចីយកទៅក្ដី បំណុលដែលបុរសណាខ្ចីដោយខ្លួនឯងក្ដី ទ្រព្យយ៉ាងណាមួយ ដែលមាតាបិតាប្រគល់បុត្រណា ទុកនៅប្រចាំហើយខ្ចីយកទៅក្ដី បុរសនោះឈ្មោះថា កូនបំណុល បុរសនោះត្រូវទទួលបំណុលនោះរបស់ជនពួកដទៃ ព្រោះដូច្នោះ ទើបឈ្មោះថា កូនបំណុល តែញាតិដទៃ ៗ ប្រគល់បុត្រណាទុកនៅប្រចាំហើយ ខ្ចីទ្រព្យយ៉ាងណាមួយទៅ បុរសនោះមិនចាត់ថា ជាកូនបំណុល ។ ព្រោះថា ញាតិដទៃ ៗ នោះ មិនជាធំក្នុងការប្រគល់បុរសនោះ ប្រចាំទុកបាន, ព្រោះហេតុនោះ នឹងឲ្យបុរសនោះបួស សមគួរ ។ នឹងឲ្យបុរសក្រៅពីនេះបួស មិនគួរ ។ តែបើញាតិសា

លោហិតទាំងឡាយរបស់គេទទួលសងបំណុលជំនួសថា "ពួកខ្ញុំព្រះករុណា នឹងធានាសង សូមលោកមេត្តាបំបួសចុះ" ឬថា ជនដទៃណាមួយ ដែលឃើញអាចារសម្បត្តិរបស់គេហើយពោលថា "សូមលោកមេត្តាបំបួសចុះ ខ្ញុំព្រះករុណា នឹងសងបំណុលជំនួស" ដូច្នេះ សមគួរបំបួសបាន ។ បើញាតិសាលោហិតទាំងនោះ មិនមាន ភិក្ខុគប្បីប្រាប់ដល់ឧបដ្ឋាកបែបនោះ ក៏បាន ថា "អ្នកនេះជាបុគ្គលមានកុសលកម្មជាហេតុ តែបួសមិនទាន់បាន ព្រោះកង្វល់ដោយបំណុល" ។ បើគេទទួលចាត់ការ គប្បីបំបួស ។ បើសូម្បីកប្បិយភណ្ឌៈរបស់ខ្លួនមាន គប្បីតាំងចិត្តថា "យើងនឹងយក កប្បិយភណ្ឌៈនោះសង ហើយបំបួស" ។ តែបើជនទាំងឡាយ មានញាតិជាដើមមិនទទួលចាត់ការ, ទ្រព្យរបស់ខ្លួន ក៏មិនមាន មិនសមគួរបំបួស ដោយធ្វើក្នុងចិត្តថា "យើងនឹងបំបួសហើយនឹងត្រាច់ភិក្ខាដោះបំណុលចេញ"; បើបំបួស ត្រូវអាបត្តិទុក្កដ ។ សូម្បីបុរសនោះគេចចេញទៅ ភិក្ខុនោះ ក៏ត្រូវនាំមកសងវិញ ។ បើមិនសងទេ បំណុលទាំងអស់ រមែងជាសំណង ។ កាលភិក្ខុមិនជ្រាបបំបួសមិនជាអាបត្តិ ។ តែកាលឃើញហើយ ត្រូវនាំមកសងឱ្យដល់ពួកម្ចាស់បំណុល ។ មិនជាសំណងដល់ភិក្ខុដែលមិនឃើញ ។

បើបុរសជាកូនបំណុលទៅប្រទេសដទៃហើយ សូម្បីកាលភិក្ខុសាកសួរ ក៏ឆ្លើយថា "ខ្ញុំព្រះករុណាមិនត្រូវទទួលបំណុលណា ៗ របស់

អ្នកណា ៗ ហើយបួស ចំណែកម្ចាស់បំណុល កាលបន្តស្វែងរកខ្លួនគេ ទើបទៅក្នុងទីនោះ ៗ ភិក្ខុកំលោះឃើញម្ចាស់ បំណុលនោះចូលមក ទើបគេចចេញទៅគេចូលទៅរកព្រះថេរៈ ស្រែកឆ្លើយប្រាប់ថា “លោកម្ចាស់ ភិក្ខុរូបនេះអ្នកណាបំបួស ? លោកកាន់យកទ្រព្យ មានប្រមាណប៉ុណ្ណេះរបស់ខ្ញុំព្រះករុណា ហើយគេចចេញទៅ” ព្រះថេរៈគប្បីឆ្លើយថា “ឧបាសក លោកប្រាប់ថា ខ្ញុំព្រះករុណាមិនមានទ្រព្យបំណុល អាត្មាទើបឱ្យគេបួស ៗ ឥឡូវនេះ អាត្មានឹងធ្វើយ៉ាងណា ? លោកចូរឃើញវត្ថុកំណត់ ប្រមាណថា បាត្រចីវររបស់អាត្មាចុះ” នេះជាសាមីចិកម្មក្នុងរឿងនោះ ៗ បើកាលភិក្ខុនោះ គេចចេញទៅសំណាង រមែងមិនមាន ៗ តែបើម្ចាស់បំណុលជួបភិក្ខុនោះ ចំពោះមុខព្រះថេរៈ ហើយពោលថា “ភិក្ខុនេះជាកូនបំណុលរបស់ខ្ញុំព្រះករុណា” ព្រះថេរៈគប្បីឆ្លើយថា “លោកចូរដឹងកូនបំណុល របស់លោកដោយខ្លួនឯងចុះ” សូម្បីយ៉ាងនេះ រមែងមិនជាសំណាង ៗ បើសូម្បីគេពោលថា “ឥឡូវនេះ ភិក្ខុនេះបួសហើយ នឹងចេញទៅណា” ព្រះថេរៈទើបឆ្លើយថា លោកចូរដឹងដោយខ្លួនឯងចុះ” សូម្បីយ៉ាងនេះ កាលភិក្ខុនេះ គេចចេញទៅ រមែងមិនជាសំណាង ដល់ព្រះថេរៈនោះ ៗ តែបើព្រះថេរៈពោលថា “ឥឡូវនេះ ភិក្ខុនេះនឹងចេញទៅណា លោកចូរនៅក្នុងទីនេះចុះ” បើភិក្ខុនោះគេចចេញទៅ រមែងជាសំណាង ៗ បើលោកជាអ្នក មានកុសលកម្មជាហេតុដល់ព្រមដោយ

វត្ត ។ ព្រះថេរៈគប្បីពោលថា ភិក្ខុនេះ ប្រាកដដូច្នេះ ។ បើម្ចាស់បំណុលព្រមលះបង់ថា "ល្អណាស់" យ៉ាងនេះ ជាការល្អ ។ ក៏បើគេឆ្លើយថា សូមលោកចូរសងឱ្យបន្តិចបន្តួចចុះ ព្រះថេរៈគប្បីសង ។ ចំពោះសម័យដទៃ ភិក្ខុនោះជាអ្នកញ៉ាំងព្រះថេរៈ ឱ្យពេញចិត្តក្រៃលែងឡើង សូម្បីកាលម្ចាស់បំណុលគេទាមទារថា លោកចូរសងទាំងអស់ ព្រះថេរៈគួរសងវិញពិត ។ និងបើលោកជាអ្នកឆ្លាតក្នុងឧទ្ទេស និងបរិបុច្ឆាជាដើម មានឧបការៈច្រើនដល់ភិក្ខុទាំងឡាយ ព្រះថេរៈនឹងគប្បីស្វែងរកដោយភិក្ខាចារវត្តក៏បាន សងបំណុលចុះ ដូច្នេះ ។

## បុគ្គលដែលជាខ្ញុំគេ

[១០៩] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ ទាសោ បព្វាជេតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសមនុស្សដែលជាខ្ញុំគេ នេះថា ទាសមាន ៤ ពួក គឺទាសៈកើតខាងក្នុង១ ទាសៈដែលលោះមកដោយទ្រព្យ ១ ទាសៈដែលគេនាំមកជាឈ្លើយ ១ បុគ្គលដែលព្រមជាទាសៈដោយខ្លួនឯង ១ ។

បណ្តាទាសៈ ទាំង ៤ នោះ កូនទាងទាសីក្នុងផ្ទះជាទាសៈដោយកំណើត ឈ្មោះថា **ទាសៈកើតខាងក្នុង** ។ បុត្រដែលគេលោះមកពីសំណាក់មាតាក្តី ទាសដែលគេលោះមកពីសំណាក់ម្ចាស់ប្រាក់បំណុលក្តី

បុគ្គលដែលគេសងទ្រព្យជំនួសហើយលើកឡើងកាន់ចារឹកនៃទាសៈប្តូរយកទៅក្តី ឈ្មោះថា **ទាសៈដែលលោះមកដោយទ្រព្យ** ។ ទាសៈទាំងពីរពួកនេះមិនគួរបំបួសកាលនឹងបំបួស ត្រូវធ្វើឱ្យជាអ្នកមិនមែនទាសៈដោយអំណាចចារឹកក្នុងទីជនបទនោះ ៗហើយ ទើបគួរបំបួស ។

ទាសៈដែលឈ្មោះថា **គេនាំមកជាឈ្លើយ** គឺ ព្រះរាជាទាំងឡាយទ្រង់ធ្វើការច្បាំងក្រៅព្រំដែន ឬបង្គាប់ឱ្យបញ្ចុះបញ្ចូលផ្តុំគ្នាជាក្រុម យកទាំងពួកមនុស្សដែលជាអ្នកគ្មានបំណុលទាំងឡាយ មកពីខាងក្រៅព្រំដែនក្តី ព្រះរាជាបង្គាប់ឱ្យរឹបយកស្រុកតំបន់ខ្លះ ដែលធ្វើខុសខាងក្នុងព្រំដែនទុំះឯង រាជបុរសទាំងឡាយ ប្រមូលផ្តុំទាំងពួកមនុស្សមកពីស្រុកនោះក្តី បណ្តាពួកមនុស្សទាំងនោះ មនុស្សប្រុសទាំងអស់ជាទាសៈ មនុស្សស្រីទាំងអស់ជាទាសី បុគ្គលបែបនេះចាត់ជាទាសៈដែលគេនាំមកជាឈ្លើយ ។ ទាសៈនេះ កាលនៅក្នុងសំណាក់ជនទាំងឡាយ ដែលនាំខ្លួនមក ឬត្រូវឃាំងទុកក្នុងគុក ឬដែលបុរសទាំងឡាយនៅឃុំគ្រង មិនគួរបំបួស ។ តែគេគេចចេញទៅហើយ គប្បីបំបួសក្នុងទីដែលគេទៅបាន ។ កាលព្រះរាជាទ្រង់ពេញព្រះហឫទ័យ ទ្រង់ធ្វើការស្រាយចាកពីចំណងដោយត្រាស់ថា “ចូរដោះលែងពួកទាសៈ ដែលនាំមកជាឈ្លើយ” ឬ ដោយន័យជាសព្វសាធារណៈ គប្បីបំបួសចុះ ។

បុគ្គលដែលព្រមជាទាសៈ ដោយខ្លួនឯងតែម្តងថា “ខ្ញុំជាទាសៈ

របស់លោក” ដូច្នេះ ព្រោះហេតុនៃជីវិតក៏ដោយ ព្រោះហេតុនៃសេចក្តីឃុំគ្រងក៏ដោយ ឈ្មោះថា **អ្នកព្រមជាទាសៈដោយខ្លួនឯង** ដូចអ្នកចិញ្ចឹមដំរី សេះ គោ និងក្របីជាដើម របស់ព្រះរាជាទាំងឡាយ ទាសៈ ដូច្នោះ មិនគួរបំបួស ។

បុត្រទាំងឡាយរបស់ពួកនាងវណ្ណទាសីនៃព្រះរាជា ដូចជាបុត្រអាមាត្រ ។ សូម្បីបុត្រទាំងនោះ ក៏មិនគួរបំបួសដូចគ្នា ។ ពួកស្រីដែលជាអ្នកគ្មានបំណុល មិនមានអ្នកណាគ្រប់គ្រង ហាមឃាត់ ទើបត្រាច់ទៅជាមួយពួកនាងវណ្ណទាសី នឹងឱ្យបុត្រទាំងឡាយរបស់ស្រីទាំងនោះបួសក៏គួរ ។ បើពួកស្រីទាំងនោះ ចុះឈ្មោះដោយខ្លួនឯង មិនសមគួរឱ្យបុត្រទាំងឡាយរបស់ស្រី ទាំងនោះបួស សូម្បីពួកទាសៈរបស់គណៈទាំងឡាយ មានគណៈភទ្ទិបុត្តកៈជាដើម ដែលគណៈជនទាំងនោះ មិនព្រមឱ្យក៏មិនគួរបំបួស ។

ដែលឈ្មោះថា ទាសៈសម្រាប់អារាម ដែលព្រះរាជាព្រះរាជទានទុកក្នុងវត្តទាំងឡាយ យ៉ាងដទៃណាមួយដែលមាន នឹងឱ្យទាសៈសូម្បីទាំងនោះបួស រមែងមិនសមគួរ តែជួយឱ្យជាអ្នកជាហើយបំបួស សមគួរ ។

ក្នុងមហាបច្ចរីអដ្ឋកថាពោលថា ជនទាំងឡាយនាំទាសៈ កើតខាងក្នុងនិងទាសៈដែលលោះមកដោយទ្រព្យ មកថ្វាយដល់ភិក្ខុសង្ឃថា “ខ្ញុំ

ព្រះករុណាថ្វាយអាភមិកទាសៈ” ទាសៈទាំងនោះ រមែងដូចគ្នានឹងទាសៈដែលគេស្រោចខ្លាញ់លើសីសៈនុ៎ះឯង នឹងបំបួស ក៏គួរ ។ ចំណែកអដ្ឋកថាកុរុន្ទីពោលថា គេថ្វាយដោយកប្បិយ វោហារថា “ខ្ញុំព្រះករុណាទាំងឡាយថ្វាយអាភមិកទាសៈ” ទាសៈនោះ ដែលគេថ្វាយហើយ ដោយវោហារយ៉ាងណាមួយក៏ដោយ មិនគួរបំបួសពិត ពួកមនុស្សទុគ៌តគិតថា នឹងអាស្រ័យព្រះសង្ឃចិញ្ចឹមជីវិត ទើបជាកប្បិយករកនៅក្នុងវត្តដែលខ្លួននៅ នឹងឱ្យមនុស្សទុគ៌តទាំងនោះបួស គួរ ។

បិតាមាតារបស់បុត្រណាជាទាសៈ ឬមាតាប៉ុណ្ណោះ ជាទាសីបិតាមិនជាទាសៈ មិនគួរឱ្យបុរសនោះបួស ។ ញាតិ ឬ ឧបដ្ឋាករបស់ភិក្ខុថ្វាយទាសៈថា សូមលោកឱ្យបុរសនេះបួស គេនឹងធ្វើការខ្វល់ខ្វាយដល់លោក ឬថា ទាសៈចំណែករបស់ភិក្ខុនោះ មានទាសៈនោះ ភិក្ខុធ្វើឱ្យជាអ្នកគ្មានបំណុលជាមុនសិន សឹមគួរបំបួស ។

ក្នុងអដ្ឋកថាកុរុន្ទីពោលថា ពួកចៅហ្វាយនាយថ្វាយទាសៈថា “សូមលោកឱ្យបុរសនេះបួស បើគេនឹងត្រេកអរក្រៃលែងក្នុងសាសនា, គេនឹងមិនជាទាសៈ បើគេនឹងសឹក គេនឹងគង់ជាទាសៈរបស់ពួកខ្ញុំព្រះករុណា” ដូច្នេះ ឈ្មោះថា ទាសៈ( គេឱ្យ )ខ្ចី មិនគួរឱ្យគេបួស ។ បុរសណាជាទាសៈមិនមានចៅហ្វាយនាយ សូម្បីបុរសនោះ ដែលភិក្ខុឱ្យជាអ្នកគ្មានបំណុលជាមុនសិន ទើបគួរបំបួស ។

ភិក្ខុមិនជ្រាបឱ្យបព្វជ្ជាឬឧបសម្បទាហើយ ទើបជ្រាបខាងក្រោយ គួរធ្វើឱ្យជាអ្នកគ្មានបំណុលដូចគ្នា ។ និងដើម្បីប្រកាសសេចក្ដីនេះ ព្រះបុរាណាចារ្យទាំងឡាយ ទើបពោលរឿងនេះថា ៖

ដូចបានឮមកថា នាងកុលទាសីម្នាក់និងបុរសម្នាក់ គេចចេញពីអនុរាធបុរីទៅនៅក្នុងរោហនជនបទ មានបុត្រម្នាក់ ។ បុត្រនោះ ក្នុងវេលាដែលបព្វជ្ជាឧបសម្បទាហើយ ជាភិក្ខុលជ្ជី ច្រើនវង្វៀស ។ ខាងក្រោយថ្ងៃមួយ លោកសួរមាតាថា “ឧបាសិកា បងប្អូនប្រុស ឬបងប្អូនស្រីរបស់ឧបាសិកា មិនមានទេ ឬ ? ម៉េចក៏អាត្មាមិនឃើញញាតិណា ៗ សោះ” មាតាឆ្លើយថា “លោកម្ចាស់ ខ្ញុំព្រះករុណាជាកុលទាសីក្នុងអនុរាធបុរី រត់គេចចេញមកនៅទីនេះ ជាមួយបិតារបស់លោកម្ចាស់” ភិក្ខុដែលមានសីល បានសេចក្ដីសង្វេគថា “បានឮថា បព្វជ្ជារបស់យើងមិនបរិសុទ្ធិ” ទើបសួរមាតាដល់ឈ្មោះ និងគោត្ររបស់ត្រកូលនោះ ហើយមកកាន់អនុរាធបុរី បានឈរត្រង់ទ្វារផ្ទះរបស់ត្រកូលនោះ ។ សូម្បីគេប្រាប់លោកថា “មេត្តានិមន្តទៅខាងមុខចុះ លោកម្ចាស់” ក៏មិនទៅឡើយ ។ ពួកគេទើបនាំគ្នាមកសួរថា “មានធុរៈអ្វី ? លោកម្ចាស់” លោកទើបសួរថា “ទាសីឈ្មោះនេះរបស់ពួកលោកដែលគេចចេញទៅមានទេ ?” “មានលោកម្ចាស់” “អាត្មាជាបុត្ររបស់ទាសីនោះ បើពួកលោកអនុញ្ញាតឱ្យអាត្មា អាត្មានឹងបួស ពួកលោកជាចៅហ្វាយនាយរបស់

អាត្មា” ។ ពួកគេជាអ្នករីករាយត្រេកអរ លើកលោកជាអ្នកគ្មានបំណុលថា “ព្រះករុណា សូមបព្វជ្ជារបស់លោកម្ចាស់បរិសុទ្ធិចុះ” ហើយនិមន្តឱ្យនៅក្នុងមហាវិហារ ទំនុកបម្រុងដោយបច្ច័យ ៤ ព្រះថេរៈនៅអាស្រ័យត្រកូលនោះប៉ុណ្ណោះ បានសម្រេចព្រះអរហត្ត ។

## ភណ្ឌុកម្មកថា

[១១០] បទថា កម្មារភណ្ឌុ : ទារកជាកូនជាងមាស បានដល់ កូនជាងមាសដែលមានសិសៈ ត្រងោលទុកជុក មានពាក្យអធិប្បាយថា ក្មេងជំទង់មានសក់ទុកជុក ៥ អន្លើ[១] ។

ពាក្យថា សង្ឃំ អបលោកេត្វា ភណ្ឌុកម្មាយ : ភិក្ខុអបលោកប្រាប់សង្ឃហើយសឹមធ្វើភណ្ឌុកម្ម មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុប្រាប់សង្ឃ ដើម្បីប្រយោជន៍ដល់ភណ្ឌុកម្ម ។ អាបុច្ឆនវិធី ក្នុងភណ្ឌុកម្មាធិការនោះ ដូច្នេះ ។ គប្បីនិមន្តភិក្ខុទាំងឡាយ អ្នករាប់បញ្ចូល

---

១. តាមន័យយោជនា ភាគ២ គួរទឹងប្រែថា បទថា កម្មារភណ្ឌុ បានដល់ ក្មេងប្រុសមានក្បាលត្រងោលកូនជាងមាស មានពាក្យអធិប្បាយថា ក្មេងជំទង់បុត្ររបស់ជាងមាសមានសក់ទុកនៅ ៥កញ្ចុំ ។ (តុលាធារោ ក៏គឺ សុវណ្ណការោ) ។ ចំណែកបាលីថា កម្មារភណ្ឌុក្នុងព្រះបាលីនោះ ប្រែយកសេចក្តីថា បុត្រជាងមាសសិសៈត្រងោល ។

ក្នុងសីមាឱ្យប្រជុំគ្នាហើយនាំបព្វជ្ជាបេក្ខៈទៅក្នុងសីមានោះហើយ ប្រាប់ ៣ ដង ឬ ២ ដង ឬម្ដងក៏បាន ថា "លោកម្ចាស់ ខ្ញុំព្រះករុណាប្រាប់ភណ្ឌុកម្មរបស់ក្មេងនេះចំពោះសង្ឃ" ។ មួយទៀត ក្នុងអធិការពោលអំពីការកោរសក់នេះ នឹងប្រាប់ថា "ខ្ញុំព្រះករុណាប្រាប់ភណ្ឌុកម្មរបស់ក្មេងនេះ" ដូច្នេះក្តី ថា "ខ្ញុំព្រះករុណាប្រាប់សមណករណ៍របស់ទារកនេះ" ដូច្នេះក្តី ថា "ទារកនេះចង់បួស" ដូច្នេះក្តី គួរទាំងអស់ ។ បើមានស្ថាននៃភិក្ខុដែលជាសភាគគ្នា គឺឱកាសជាទីកំណត់ប្រាកដថា "ភិក្ខុ១០រូប ឬ២០ ឬ៣០រូប នៅជាមួយគ្នា" នឹងទៅកាន់ឱកាសដែលភិក្ខុទាំងនោះឈរហើយ ឬឱកាសដែលអង្គុយហើយ ប្រាប់ដោយន័យមុននោះឯង ក៏បាន ។

សូម្បីនឹងពឹងពាក់ពួកភិក្ខុកំលោះ ឬពួកសាមណេរ តែរៀបបព្វជ្ជាបេក្ខៈចេញ ឱ្យ ប្រាប់ដោយន័យជាដើមថា "លោកម្ចាស់មានបព្វជ្ជាបេក្ខៈម្នាក់ ពួកខ្ញុំព្រះករុណាប្រាប់ភណ្ឌុកម្មរបស់គេ" ដូច្នេះ ក៏គួរ បើភិក្ខុពួកខ្លះចូលកាន់សេនាសនៈ ឬគុម្ពឈើជាដើម លង់លក់ក្តី ធ្វើសមណធម៌ក្តី ចំណែកភិក្ខុ សាមណេរអ្នកប្រាប់ សូម្បីត្រាច់តាមរក ក៏មិនជួប ទើបមានសេចក្តីសម្គាល់ថា យើងប្រាប់អស់គ្រប់រូបហើយ

ដែលឈ្មោះថា បព្វជ្ជាជាកម្មស្រាល ព្រោះហេតុនោះ បព្វជ្ជាបេក្ខៈនោះ បួសហើយ ជាការបួសដោយល្អពិត មិនជាអាបត្តិ សូម្បីដល់ឧបជ្ឈាយ៍ដែលបំបួស ។ តែបើវត្តធំជាទីនៅរបស់ភិក្ខុច្រើនពាន់ សូម្បីនិមន្តភិក្ខុទាំងអស់ឱ្យប្រជុំគ្នា ក៏ធ្វើបានលំបាក មិនចាំត្រូវពោលដល់ប្រាប់តាមលំដាប់ត្រូវនៅក្នុងខណ្ឌសីមា ឬទៅកាន់ទន្លេ ឬសមុទ្រជាដើមហើយ សឹមបំបួស ។ ចំណែកអ្នកណា ជាអ្នកកោរសក់ថ្មី ឬសឹកចេញទៅ ឬជាអ្នកណាមួយ ក្នុងពួកអ្នកបួសមាននិគ្រន្ថជាដើម មានសក់ត្រឹមតែ ២ ធ្នាប់[១] ឬខ្វះជាង ២ ធ្នាប់ កិច្ចដែលនឹងត្រូវកោរសក់របស់អ្នកនោះមិនមាន ព្រោះហេតុនោះ សូម្បីនឹងមិនប្រាប់ភណ្ឌុកម្ម ឱ្យបុគ្គលដូច្នោះបួសក៏គួរ ។ ចំណែកអ្នកណា មានសក់វែងជាង ២ ធ្នាប់ ដោយហោចទៅ សូម្បីទុកសក់ត្រឹមតែមួយជុក អ្នកនោះ ភិក្ខុត្រូវប្រាប់ភណ្ឌុកម្មមុន ទើបបំបួសបាន ។

[១១១] ឧបាលិវត្ថុមានន័យដូចពោលហើយក្នុងមហាវិភង្គនុ៎ះឯង ។

អភយូវរភាណវារៈ ចប់

១. បើកោរចេញ ក៏ល្អ ព្រោះវែងជិតលើសហើយ ។

# រឿងត្រកូលធ្វើមរណកាលដោយអហិវាតករោគ

[១១២] បទថា អហិវាតករោគេន : ដោយរោគកើតអំពីខ្យល់មានពិសដូចពស់ពិស បានដល់ មារព្យាធិ ។ ពិតមែន រោគនោះកើតឡើងក្នុងត្រកូលណា ត្រកូលនោះ ព្រមទាំងសត្វជើងពីរ និងសត្វជើងបួន រមែងស្លាប់អស់ ។ អ្នកណាទម្លាយជញ្ជាំងផ្ទះឬដំបូលគេចចេញទៅ ឬទៅនៅខាងក្រៅស្រុកជាដើម អ្នកនោះទើបផុត ។ ចំណែកបិតានិងបុត្រក្នុងត្រកូលនេះ ក៏ផុតហើយដោយប្រការយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលពាក្យថា បិតានិងបុត្រនៅសល់ ដូច្នេះ ។

[១១៣] បទថា គាគុដ្ឋេបកំ : ដែលអាចបង្អើលក្អែកឱ្យហើរទៅបាន មានសេចក្ដីថា ក្មេងណាកាន់ដុំដីដោយដៃឆ្វេងអង្គុយហើយអាចដើម្បីដេញក្អែកទាំងឡាយ ដែលនាំគ្នាមកបរិភោគអាហារដែលដាក់ទុកខាងមុខ ឱ្យហើរទៅបាន ក្មេងនេះចាត់ថា អ្នកដេញក្អែកទៅ នឹងឱ្យក្មេងនោះបួស ក៏គួរ ។

រឿងត្រកូលធ្វើមរណកាលដោយអហិវាតករោគ ចប់

# រឿងភិក្ខុនៅជាប់និស្ស័យ

[១១៥] បទថា ឥត្តរោ : បានតែបន្តិចបន្តួច មានសេចក្តីថា ការនៅប្រមាណតិច គឺ ២-៣ ថ្ងៃប៉ុណ្ណោះ នឹងមាន ។

បទថា ឱគណោន : មានពួកតិច បានដល់ មានពួកថយតិចទៅ, អធិប្បាយថា ភិក្ខុសង្ឃមានប្រមាណតិច ។

ក្នុងពាក្យថា អព្យត្តេន យាវជីវំ : ភិក្ខុដែលមិនឆ្លាស ត្រូវនៅដរាបដល់អស់ជីវិត នេះ មានវិនិច្ឆ័យថា ៖

បើភិក្ខុដែលមិនឆ្លាតនេះ នឹងមិនបានអាចារ្យដែលចាស់ជាងទេ, ទោះជាលោកមានវស្សា ៦០ ឬវស្សា ៧០ តាំងពីឧបសម្បទាក៏ដោយ លោកគប្បីអង្គុយ ប្រហោង ផ្គងអញ្ជលីពោល ៣ ដង យ៉ាងនេះថា "អាចរិយោ មេ អាវុសោ ហោហិ អាយស្មតោ និស្សាយ វច្ឆាមិ : លោកដ៏មានអាយុ សូមលោកជាអាចារ្យរបស់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងនៅអាស្រ័យលោក" ដូច្នេះ កាន់និស្ស័យក្នុងសំណាក់របស់ភិក្ខុសូម្បីខ្ញុំជាង តែជាអ្នកឆ្លាត ភិក្ខុនោះ សូម្បីកាលនឹងលាចូលស្រុក គប្បីនឹងអង្គុយប្រហោង ផ្គងអញ្ជលីពោលថា "លោកអាចារ្យ ខ្ញុំព្រះករុណាលាចូលស្រុក" ក្នុងការពោលលាគ្រប់យ៉ាងក៏ន័យនេះ ក៏ក្នុងពួក ៥ និងពួក ៦ ក្នុងអធិការនេះ សូត្រប្រមាណប៉ុននឹងភិក្ខុដែលផុតនិស្ស័យហើយ

គប្បី ប្រាជ្ញាខ្ញុំព្រះករុណា ពោលហើយក្នុងវណ្ណនានៃភិក្ខុនោវាទកសិក្ខាបទ បណ្ឌិតគប្បីជ្រាបថា ជាអប្បស្សុតបុគ្គល ព្រោះសូត្រនោះមិនមាន និងជាពហុស្សូតបុគ្គល ព្រោះសូត្រនោះមាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

*រឿងភិក្ខុនៅជាប់និស្ស័យ*

## រាហុលសាមណេរបព្វជ្ជា

[១១៨] ក្នុងពាក្យថា យេន កបិលវត្ថុ តេន ចារិកំ បក្កាមិ **:** ទ្រង់យាងសំដៅទៅកាន់ចារិកឯក្រុងកបិលវត្ថុ នេះ គប្បីជ្រាបអនុបុព្វីកថា ដូចតទៅនេះ ៖

បានឮថា ចាប់តាំងពីថ្ងៃដែលព្រះពោធិសត្វ ស្ដេចចេញអភិនេស្រ្កមណ៍ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ផ្ទៀងព្រះសោតចាំស្ដាប់ដំណឹងថា "កូនយើងចេញទៅដោយទិសដៅថា នឹងបានត្រាស់ជាព្រះពុទ្ធ តើត្រាស់ជាព្រះពុទ្ធហើយ ឬនៅហ្ន៎ ?" ទ្រង់ស្ដាប់ការបំពេញព្យាយាមសេចក្ដីត្រាស់ដឹងនោះឯង និង ពុទ្ធកិច្ចទាំងឡាយ មានញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅជាដើម របស់ព្រះមានព្រះភាគ ទ្រង់បានស្ដាប់ថា "បានឮថាឥឡូវនេះ កូនយើងនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ" ទើបត្រាស់បង្គាប់

អាមាត្រម្នាក់ថា "យើងចាស់ជរាហើយណាំះបា ល្អណាស់ អ្នកឯងចូរសម្តែងបុត្រដល់យើង ទាន់ពេលដែលយើងនៅរស់" គេទទួលសាធុហើយ មានបុរស ១.០០០ នាក់ជាបរិវារ ទៅកាន់ក្រុងរាជគ្រឹះ ថ្វាយបង្គំព្រះបាទព្រះមានព្រះភាគហើយអង្គុយ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ធម្មកថាដល់គេ គេជ្រះថ្លា ទូលសូមបព្វជ្ជា និងឧបសម្បទាក្នុងទីនោះ ព្រះមានព្រះភាគឱ្យគេឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា ភិក្ខុនោះព្រមទាំងបរិស័ទសម្រេចព្រះអរហត្តហើយ បាននៅសោយសុខកើតអំពីផលសមាបត្តិក្នុងទីនោះឯង ។ សូម្បីព្រះរាជាទ្រង់បញ្ជូនទូតដទៃ ៨ នាក់ ទៅទៀត ដោយឧបាយនោះឯង ។ សូម្បីពួកទូតទាំងអស់នោះព្រមទាំងបរិស័ទ បានសម្រេចព្រះអរហត្តហើយនៅ ក្នុងទីនោះឯងយ៉ាងនោះដូចគ្នា ។ មិនមានអ្នកណា ៗក្រាបទូល សូម្បីត្រឹមតែដំណឹងដល់ព្រះរាជាថា "ទូតទាំងនោះមិនត្រឡប់មកវិញទេ ព្រោះហេតុយ៉ាងនេះ ៗ"

គ្រានោះព្រះរាជាមានបំណងបញ្ជូនអាមាត្យឈ្មោះ កាឡុទាយី ដែលកើតក្នុងថ្ងៃជាមួយនឹងព្រះពោធិសត្វ ទើបទ្រង់អង្វរតាមន័យមុននោះឯង ។ គេក្រាបទូលថា "បើទូលបង្គំទៅហើយ នឹងបានបួសទូលបង្គំនឹងសម្តែង" ព្រះរាជាទ្រង់បញ្ជូនគេទៅថា "សូម្បីបាឯងបួសហើយ ចូរសម្តែងបុត្រដល់យើង" សូម្បីគេក៏មានបរិវារមួយពាន់ទៅហើយ ព្រម

ទាំងបរិស័ទបានសម្រេចអរហត្តយ៉ាងនោះដែរ ។ ថ្ងៃមួយកាឡុទាយីភិក្ខុនោះ កាលស្រូវទាំងឡាយ ទាំងពួងសម្រេចរៀបរយល្អហើយ មនុស្សក្នុងជនបទទាំងឡាយ បញ្ឈប់ការងារអស់ហើយ ផ្កាឈើដែលកើតលើគោក កើតក្នុងទឹករីកស្គុះស្គាយហើយ ក៏បានពណ៌នាគុណនៃការយាងក្នុងមគដ៏សមគួរ ដែលទ្រង់នឹងត្រូវធ្វើដំណើរ ដោយគាថាប្រមាណ ៦០ គត់, ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា "យ៉ាងម៉េចហ្នឹង" ទើបកាឡុទាយីភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជជាព្រះបិតារបស់ព្រះអង្គ បានបញ្ជូនខ្ញុំព្រះអង្គមកថា យើងចាស់ជរាហើយ បាឯងចូរសម្តែងបុត្រដល់យើងទាន់ពេលដែលយើងនៅរស់នេះឯង" ដូច្នេះ, ជាការល្អណាស់ព្រះអង្គ សូមព្រះមានព្រះភាគទ្រង់ធ្វើនូវសេចក្តីអនុគ្រោះព្រះញាតិទាំងឡាយផង, ឥឡូវនេះ ជាកាលដែលទ្រង់យាងទៅបាន" ព្រះមានព្រះភាគត្រាស់ថា "បើដូច្នោះ លោកចូរប្រាប់សង្ឃភិក្ខុទាំងឡាយនឹងញ៉ាំងគមិកវត្តឱ្យបរិបូណ៌" ។ ព្រះថេរៈទូលថា សាធុភន្តេ : ហើយធ្វើតាមព្រះតម្រាស់ ។ ព្រះមានព្រះភាគទ្រង់ហែហមហើយដោយព្រះខីណាស្រពទាំងអស់ ពីរម៉ឺនរូប គឺ កុលបុត្រក្នុងដែនអង្គៈ និងមគធៈ មួយម៉ឺនរូប កុលបុត្រក្នុងក្រុងកបិលភស្តុមួយម៉ឺនរូប ។ ស្តេចចេញចាកក្រុងរាជគ្រឹះជៀសចេញចារិកទៅ ដោយមិនប្រញាប់រួសរាន់ ដោយទ្រង់ធ្វើក្នុងព្រះហឫទ័យថា "យើងកាលធ្វើដំណើរ

មួយថ្ងៃ ១ យោជន៍ ២ ខែ នឹងដល់ក្រុងកបិលភស្តុ ដែលមានចម្ងាយមក ៦០ យោជន៍អំពីក្រុងរាជគ្រឹះ” ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា យេន កបិលវត្ថុ តេន ចារិកំ បក្កាមិ ដូច្នេះ ។ ក៏កាលព្រះមានព្រះភាគទ្រង់ចេញទៅហើយយ៉ាងនោះ ព្រះឧទាយីថេរៈ ធ្វើភត្តកិច្ចក្នុងព្រះនិវេសន៍របស់ព្រះបាទសុទ្ធោទនមហារាជ ចាប់ផ្តើមតាំងពីថ្ងៃដែលព្រះមានព្រះភាគទ្រង់យាងចេញ ។ ព្រះរាជាទ្រង់អង្គាសព្រះថេរៈហើយ ទ្រង់អប់បាត្រដោយខ្លឹមចន្ទន៍ និងដាក់ព្រះក្រយាហារយ៉ាងប្រសើរបំផុតដរាបពេញ ប្រគេនក្នុងដៃព្រះថេរៈថា “សូមលោកម្ចាស់ថ្វាយដល់ព្រះមានព្រះភាគ” សូម្បីព្រះថេរៈរមែងធ្វើតាមតម្រាស់ទាំងអស់នោះ ។ ព្រះមានព្រះភាគសោយបិណ្ឌបាតរបស់ព្រះរាជាប៉ុណ្ណោះ ក្នុងចន្លោះមក ដោយប្រការដូច្នេះ ។

ចំណែកព្រះថេរៈ ក្នុងវេលាសម្រេចភត្តកិច្ចរាល់ថ្ងៃ បានទូលព្រះរាជាថា ថ្ងៃនេះព្រះមានព្រះភាគយាងមកប៉ុណ្ណេះ និងបានបង្កើតជំនឿក្នុងព្រះមានព្រះភាគ ឱ្យកើតឡើងដល់ស្តេចសក្យៈទាំងឡាយ ដោយកថាបដិសំយុត្តដោយពុទ្ធគុណ ។

ព្រោះហេតុនោះឯង ព្រះមានព្រះភាគទ្រង់តាំងព្រះថេរៈទុកក្នុងឯតទគ្គស្ថានថា “ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញ៉ាំងត្រកូលឱ្យជ្រះថ្លា

ដែលជាសាវករបស់ព្រះតថាគត កាឡុទាយិប្រសើរជាងគេ"[១] ដូច្នេះ ។

ចំណែកពួកស្តេចសក្យៈ កាលព្រះមានព្រះភាគទ្រង់មិនទាន់មកដល់ ទើបមានបំណងក្នុងព្រះទ័យថា "យើងទាំងឡាយ នឹងចូលគាល់ព្រះញាតិដ៏ប្រសើររបស់ពួកយើង" ទើបប្រជុំគ្នា កាលជ្រើសរើសរកទីលំនៅសម្រាប់ព្រះមានព្រះភាគ ក៏ទ្រង់កំណត់ថា "អារាមរបស់សក្កៈឈ្មោះនិគ្រោធ គួរជាទីរីករាយ" ទើបឱ្យធ្វើការចាត់ចែងជួសជុល វិធីទាំងពួងក្នុងអារាមនោះ មានរបស់ក្រអូប និងផ្កាឈើក្នុងដៃ កាលនឹងធ្វើការទទួល ក៏បានបញ្ជូនក្មេងប្រុសកំលោះ និងក្មេងស្រីក្រមុំក្នុងព្រះនគរដែលប្រដាប់ដោយអលង្ការគ្រប់យ៉ាងទៅមុន បន្ទាប់ពីនោះ បញ្ជូនរាជកុមារនិងរាជកុមារីទាំងឡាយទៅ ហើយខ្លួនឯងក៏ទៅតាមលំដាប់នៃពួករាជកុមារនិងរាជកុមារីទាំងនោះ បូជាដោយសក្ការៈមានផ្កាឈើ និងលំអិតក្រអូបជាដើម បានអារាធនាព្រះមានព្រះភាគទៅកាន់និគ្រោធារាមតែម្តង ។

ព្រះមានព្រះភាគ មានព្រះខីណាស្រព ២ ម៉ឺនហែហមប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេតាំងត្រៀមទុក ក្នុងនិគ្រោធារាមនោះ ។ ពួកសក្យរាជ ជាអ្នកមានទូវមានះប្រកាន់ខ្លួនខ្លាំងណាស់ ។ ពួកសក្យរាជទាំងនោះ ទ្រង់ត្រិះរិះថា "សិទ្ធត្ថកុមារនៅក្មេងជាងពួកយើង, ជាព្រះ

---

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។

កនិដ្ឋៈ, ជាព្រះភាគិនេយ្យ, ជាព្រះឱរស, ជាព្រះនត្តានៃពួកយើង” ទើបបង្គាប់ឱ្យរាជកុមារកំលោះ ៗថា “ពួកអ្នកចូរថ្វាយបង្គំ ពួកខ្ញុំនឹងអង្គុយខាងក្រោយពួកអ្នក” ។ គ្រាកាលសក្យរាជទាំងនោះ គង់ប្រថាប់យ៉ាងនោះ ហើយព្រះមានព្រះភាគ ទ្រង់សម្លឹងមើលអធ្យាស្រ័យរបស់ពួកស្តេចទាំងនោះ ហើយទ្រង់ត្រិះរិះថា “ពួកព្រះញាតិមិនព្រមថ្វាយបង្គំយើងឡើយចុះ ឥឡូវនេះ យើងនឹងឱ្យព្រះញាតិទាំងនោះ ថ្វាយបង្គំ” ដូច្នេះ ហើយទ្រង់ចូលចតុត្ថឈានជាបាទនៃអភិញ្ញា ចេញហើយហោះឡើងកាន់អាកាសដោយឫទ្ធិ ទ្រង់បានធ្វើបាដិហារ្យ ដូចយមកបាដិហារ្យត្រង់គល់នៃគណ្ឌាមព្រឹក្ស ហាក់ដូចជាថា ទ្រង់រោយធូលីដែលជាប់ព្រះបាទ ចុះលើសិរសានៃព្រះញាតិទាំងនោះ ។ ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ទើបត្រាស់ថា “បពិត្រព្រះមានព្រះភាគ កាលព្រះអង្គដែលព្រះភីលៀងនាំចូលទៅ ដើម្បីសំពះព្រាហ្មណ៍ក្នុងថ្ងៃមង្គល ខ្ញុំព្រះអង្គបានឃើញព្រះបាទរបស់ព្រះអង្គ បែរជាទៅប្រតិស្ឋានលើក្បាលជាន់ជដារបស់ព្រាហ្មណ៍ ទើបថ្វាយបង្គំព្រះអង្គ នេះជាការថ្វាយបង្គំដំបូងរបស់ខ្ញុំព្រះអង្គ ។ ក្នុងថ្ងៃវប្បមង្គល (ច្រត់ព្រះនង្គ័ល) កាលព្រះអង្គផ្ទុំលើព្រះសយនាដ៏មានសិរី ក្រោមម្លប់ដើមព្រីង ខ្ញុំព្រះអង្គឃើញស្រមោលដើមព្រីងមិនបាន

ជ្រះទៅ ទើបថ្វាយ បង្គំព្រះបាទ នេះជាការថ្វាយបង្គំទីពីររបស់ខ្ញុំព្រះអង្គ, សូម្បីឥឡូវនេះ ខ្ញុំព្រះអង្គក៏បានឃើញបាដិហារ្យដែលមិនធ្លាប់ឃើញនេះ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គនេះ ជាការថ្វាយបង្គំទីបីរបស់ខ្ញុំព្រះអង្គ” ។

ក៏កាលព្រះបាទសុទ្ធោទនមហារាជ ថ្វាយបង្គំព្រះមានព្រះភាគហើយ សូម្បីសក្យៈអង្គណាមួយដែលថា មិនថ្វាយបង្គំមិនមាន, បានថ្វាយបង្គំទាំងអស់គ្នា ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះញាតិទាំងឡាយ ឱ្យថ្វាយបង្គំហើយ ក៏ទ្រង់ចុះចាកពីអាកាស ប្រថាប់លើអាសនៈដែលគេក្រាលទុក ។ គ្រាព្រះមានព្រះភាគគង់ប្រថាប់ហើយ ព្រះញាតិសមាគម បានជាអ្នកដល់ទីបំផុត គឺ អស់មានះ ព្រះញាតិទាំងពួងមានព្រះហឫទ័យតម្កល់មាំអង្គុយប្រជុំគ្នាហើយ ។

លំដាប់នោះ មហាមេឃបង្អុរភ្លៀងបោក្ខរពស័, ឱ្យធ្លាក់ចុះមក ។ ទឹកមានពណ៌ក្រហមហូរហៀរទៅខាងក្រោម[១] ទឹកសូម្បីមួយតំណក់នឹងធ្លាក់ចុះលើសរីរៈរបស់អ្នកណា ៗ ក៏មិនមាន ។ ព្រះញាតិទាំងពួង បានឃើញហេតុនោះហើយ ក៏កើតសេចក្តីអស្ចារ្យក្នុងចិត្ត ។

១. វិរវន្តំ គច្ឆតិ ។

ព្រះមានព្រះភាគត្រាស់ថា "ភ្លៀងបោក្ខរពស្សិធ្លាក់ក្នុងសមាគមញាតិរបស់យើង មិនមែនតែក្នុងកាលនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ក៏បានធ្លាក់ចុះហើយ" ដូច្នេះ ហើយត្រាស់វេស្សន្តរជាតក[១] ព្រោះកើតហេតុនេះឡើង ។

ព្រះញាតិទាំងពួង ស្តាប់ព្រះធម្មទេសនាហើយ ស្តេចក៏ក្រោកឡើងថ្វាយបង្គំ ធ្វើប្រទក្សិណហើយជៀសចេញទៅ ។ សូម្បីបុគ្គលម្នាក់ គឺព្រះរាជា ឬរាជមហាមាត្យដែលនឹងទូលថា "ស្អែកនេះ សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ" ហើយទើបទៅ មិនមាន ។

ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគមានភិក្ខុ ២ ម៉ឺនជាបរិវារ ស្តេចចូលទៅបិណ្ឌបាតនៅក្រុងកបិលភស្តុ ។ អ្នកណា ៗ នឹងក្រោកទទួលហើយនិមន្ត ឬបានទទួលបាត្រ ក៏មិនមាន ។ ព្រះមានព្រះភាគប្រថាប់ឈរត្រង់សសរឥន្ទខិល (សសរខឿន)[២] ទ្រង់នឹកថា "ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ទ្រង់ត្រាច់បិណ្ឌបាតក្នុងនគរនៃត្រកូលយ៉ាងណាហ្ន៎ ? តើទ្រង់ទៅកាន់ផ្ទះរបស់ពួកឥស្សរជនដោយខុសលំដាប់ ឬថា ទ្រង់ត្រាច់ចារិកទៅតាមលំដាប់ប្រកមក" ។

---

១. ខុទ្. ជាត. វេស្សន្តរ. ៦៣. ២១២/៩៤ ។ ២. បង្គោលដែលបោះទុកកណ្តាលទ្វារ សម្រាប់ការពារសន្ទឹកទ្វារទាំងពីរខាង ក្នុងវេលាបិទ ។

លំដាប់នោះ ទ្រង់មិនបានឃើញការទៅខុសលំដាប់ សូម្បីនៃព្រះពុទ្ធមួយអង្គ ទើបទ្រង់រំពឹងថា "ឥឡូវនេះ វង្សនិងប្រពៃណីនេះ សូម្បីតថាគតក៏គួរលើកតម្កើង និងតទៅដល់សាវកទាំងឡាយរបស់តថាគតកាលកំណត់តាមតថាគត នឹងញុំាងបិណ្ឌចារិកវត្តឱ្យបរិបូណ៌បាន" ហើយក៏ទ្រង់យាងបិណ្ឌបាតតាមលំដាប់ច្រកមក ចាប់ផ្តើមតាំងពីផ្ទះដែលទ្រង់ចូលទៅគ្រាចុងបង្អស់ ។

មហាជនបានស្តាប់ដំណឹងថា "បានឮថា ព្រះសិទ្ធត្ថកុមារទ្រង់យាងបិណ្ឌបាត" ទើបបើកបង្អួចក្នុងប្រាសាទបួនជាន់ជាដើម ជាអ្នកប្រញាប់ប្រញាល់ដើម្បីនឹងឃើញ ។

ចំណែកព្រះទេវី ជាមាតាព្រះរាហុលទ្រង់ចិន្តាថា "បានឮថា ព្រះអយ្យបុត្រទ្រង់ទៅដោយព្រះយាន មានសុវណ្ណសិវិកា ជាដើម ដោយព្រះរាជានុភាពធំ ក្នុងព្រះនគរនេះឯង ឥឡូវនេះ ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុចេញ ទ្រង់សំពត់កាសាវពស្ត្រ មានអម្បែងក្នុងព្រះហស្ត ស្តេចយាងបិណ្ឌបាត ។ តើព្រះអង្គនឹងទ្រង់ស្រស់ស្អាត ឬថា ទ្រង់មិនស្រស់ស្អាតទេហ្ន៎ ។" ទើបព្រះនាងបើកព្រះសីហបញ្ជរទតព្រះនេត្រ ទ្រង់ឃើញព្រះមានព្រះភាគដែលល្អស្រស់ដោយព្រះពុទ្ធសិរី ទ្រង់ញុំាងនគរវិថីទាំងឡាយ ឱ្យឱភាសដោយព្រះសរីរៈរស្មីដ៏រុងរឿង ដោយរស្មីនានា,

ទើបទ្រង់សរសើរព្រះឆោម ចាប់ផ្ដើមតាំងពីព្រះឧណ្ហិស្សរហូតដល់ផ្ទៃព្រះបាទ ដោយ ៨ គាថា ដែលមានឈ្មោះថា **នរសីហគាថា**[១] ។ ហើយស្ដេចទៅគាល់ព្រះរាជា ក្រាបបង្គំទូលចំពោះព្រះរាជាថា "ព្រះបុត្រារបស់ព្រះអង្គ ទ្រង់យាងបិណ្ឌបាត" ។ ព្រះរាជាទ្រង់ស្ដាប់ដំណឹងនោះ ទ្រង់ស្លុតព្រះហឫទ័យ ទ្រង់ចាត់ព្រះភូសាឱ្យឋិតនៅ ព្រមដោយព្រះហស្ត ស្ដេចប្រញាប់ប្រញាល់ចេញទៅដោយរហ័ស ប្រថាប់ខាងមុខព្រះភ័ក្ត្រព្រះមានព្រះភាគ ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច ទើបទ្រង់ញ៉ាំងខ្ញុំព្រះអង្គឱ្យបានខ្មាសគេហ្ន៎ ព្រះអង្គស្ដេចយាងបិណ្ឌបាត ដើម្បីប្រយោជន៍អ្វី ? ព្រះអង្គមានសេចក្ដីសម្គាល់យ៉ាងនេះថា ភិក្ខុមានប្រមាណប៉ុណ្ណោះ មិនអាចបានភត្តឬ ?"

ព្រះមានព្រះភាគត្រាស់ថា "មហាបពិត្រ ការត្រាច់បិណ្ឌបាតនេះ ជាចារីកសម្រាប់វង្សរបស់តថាគត" ។

ព្រះរាជាទូលសួរថា "បពិត្រព្រះអង្គ ដែលឈ្មោះថា មហាសម្មតិខត្តិយវង្ស ជាវង្សរបស់ពួកយើង មិនមែនឬ ? ក៏ឯក្នុងខត្តិយវង្សនោះ សូម្បីក្សត្រិយ៍ត្រឹមមួយអង្គ ឈ្មោះថា អ្នកត្រាច់ភិក្ខា រមែងមិនមាន" ។

ព្រះមានព្រះភាគត្រាស់តបថា "មហាបពិត្រ ឈ្មោះថា រាជវង្ស

---

១. អដ្ឋ. ជាត. សន្តិកេនិទានកថា ។

ជាវង្សរបស់មហាបពិត្រ តែដែលឈ្មោះថា ពុទ្ធវង្សជាវង្សរបស់តថាគត, ព្រះពុទ្ធគ្រប់ ៗ ព្រះអង្គ ទ្រង់តែងយាងបិណ្ឌបាត” ដូច្នេះ គង់ប្រថាប់ឈរក្នុងផ្លូវថ្នល់នោះឯង បានត្រាស់ព្រះគាថានេះថា ៖

“បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឱ្យជាសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង”[១] ។

ព្រះរាជាទ្រង់បានធ្វើឱ្យច្បាស់នូវសោតាបត្តិផល ក្នុងកាលដែលចប់នៃព្រះគាថា និងទ្រង់បានស្តាប់ព្រះគាថា នេះថា ៖

បុគ្គលគួរប្រព្រឹត្តធម៌ឱ្យជាសុចរិត មិនគួរប្រព្រឹត្តធម៌នោះ ឱ្យជាទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង[២] ។

ដូច្នេះហើយ ទ្រង់តាំងនៅក្នុងសកទាគាមិផល ទ្រង់បានស្តាប់ធម្មបាលជាតក[៣] ហើយទ្រង់តាំងនៅក្នុងអនាគាមិផល, ក្នុងមរណសម័យស្តេចផ្ទំលើព្រះក្រឡាបន្ទំដ៏មានសិរីខាងក្រោមនៃស្វេតឆត្រនុ៎ះឯង ទើប

---

១-២. ខុទ្ទ. ធម្ម. លោកវគ្គ. ៥២. ២៣/៥៧ ។

៣. ខុទ្ទ. ជាត. ៥៩. ៧០៨-៧១៩/១៨៦-៩ ។

ទ្រង់សម្រេចព្រះអរហត្ត ។ កិច្ចដែលនិងត្រូវប្រឹងប្រែងប្រកបសេចក្ដីព្យាយាម ក្នុងអរញ្ញវាស( ព្រៃ )មិនមានដល់ព្រះរាជា ។ ក៏ការដែលទ្រង់ធ្វើឱ្យច្បាស់នូវសោតាបត្តិផលនុ៎ះឯង ទើបទ្រង់ទទួលបាត្ររបស់ព្រះមានព្រះភាគហើយ អារាធនាព្រះមានព្រះភាគ ព្រមទាំងបរិស័ទ ឡើងកាន់ព្រះមហាប្រាសាទ ទ្រង់អង្គាសដោយខាទនីយភោជនិយៈដ៏ប្រណីត ។

ក្នុងវេលាសម្រេចភត្តកិច្ច នាងស្នំកំណាន់ទាំងពួង វៀរព្រះមាតាព្រះរាហុលបានមកថ្វាយបង្គំព្រះមានព្រះភាគ ចំណែកព្រះនាងនោះសូម្បីដែលជនជាបរិវារទូលថា សូមព្រះម៉ែម្ចាស់ ស្ដេចយាងទៅថ្វាយបង្គំព្រះអយ្យបុត្ត ក៏បានមានព្រះសុវន្ទីថា "បើសេចក្ដីល្អរបស់យើងមានប្រាកដ ព្រះអយ្យបុត្តនឹងស្ដេចយាងមកដោយព្រះអង្គឯងតែម្ដង យើងនឹងថ្វាយបង្គំព្រះអង្គដែលយាងមកហើយ" ដូច្នេះ ទើបព្រះនាងមិនបានយាងទៅ ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះរាជាឱ្យកាន់បាត្រហើយ ព្រមដោយព្រះអគ្គសាវកទាំង ២ ស្ដេចទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជធីតា ត្រាស់ថា "ព្រះរាជធីតាចូរថ្វាយបង្គំតាមពេញចិត្តចុះ កុំពោលឃាត់ព្រះនាងឡើយ" ហើយប្រថាប់លើព្រះបល្ល័ង្កដែលគេតែងតាំងទុក ព្រះនាងស្ដេចយាងមកដោយរហ័ស ទ្រង់ចាប់ត្រង់កព្រះបាទ ញក់ញីព្រះសិរសាលើខ្នងព្រះបាទ ថ្វាយបង្គំតាមព្រះអធ្យាស្រ័យ ។

ព្រះរាជាទូលដល់គុណសម្បត្តិរបស់ព្រះរាជធីតា ដែលមានព្រះស្នេហានិងសេចក្ដីរាប់អានច្រើនក្នុងព្រះមានព្រះភាគ ។

ព្រះមានព្រះភាគត្រាស់ថា “មហាបពិត្រ មិនទាន់អស្ចារ្យ ក្នុងការដែលព្រះរាជធីតា ដែលមានព្រះបរមបពិត្រទ្រង់នៅឃុំគ្រង ទើបរក្សាខ្លួនព្រះនាងទុកបានក្នុងកាលឥឡូវនេះ ដែលព្រះញាណចាស់ក្លាហើយ, កាលពីមុន មហាបពិត្រមិនជាអ្នកឃុំគ្រង ត្រាច់ទៅក្បែរជើងភ្នំ រក្សាខ្លួនព្រះនាងទុកបានក្នុងកាលព្រះញាណមិនទាន់ចាស់ក្លា” ដូច្នេះហើយ ត្រាស់ចន្ទកិន្នរីជាតក[១] ។

ថ្ងៃនោះឯង ព្រះនន្ទរាជកុមារ មានមហាមង្គល ៥ យ៉ាង គឺ ស្រាយព្រះកេសា[២] ចងព្រះសុវណ្ណបដ្ដ[៣] ឃរមង្គល[៤] អាវាហមង្គល ឆត្តមង្គល ។

ព្រះមានព្រះភាគ ទ្រង់ញាំងព្រះនន្ទកុមារឱ្យកាន់បាត្រ ហើយត្រាស់

---

១. ខុទ្. ជាត. ៦០. ១២/៤, ក្នុងទីនោះជា ចន្ទកិន្នរជាតក ។ ២. សារត្ថទីបនី : កេសវិសជ្ជនន្តិ កុលមរិយាទវសេន កេសោរោបនន្តិ ។ វិមតិវិនោទនី : រាជមោលិពន្ធនត្ថំ កុមារកាលេ ពន្ធិតសិខាវេណិមោចនំ ។ តំ កិរ ករោន្តា មង្គលំ ករោន្តីតិ ។ ៣. សារត្ថ : បដ្ដពន្ធោតិ យុវរាជបដ្ដពន្ធោតិ ។ វិមតិ : អសុករាជាតិ នលាដេសុវណ្ណបដ្ដពន្ធនន្តិ ។ ៤. សារត្ថ : អភិនវឃរបវេសនមហោ ឃរមង្គលន្តិ ។ វិមតិ : អភិនវបាសាទប្បវេសមង្គលំ ឃរមង្គលន្តិ ។

មង្គល ស្តេចក្រោកចាកពីទីប្រថាប់ជៀសចេញទៅ ។

គ្រានោះ នាងជនបទកល្យាណី ឃើញព្រះកុមារកំពុងយាងទៅ ទើបទូលថា "បពិត្រព្រះអយ្យបុត្ត សូមព្រះអយ្យបុត្តប្រញាប់ត្រឡប់មកវិញ" ហើយ (ព្រះនន្ទ)ផាកកក្រឡេកមើល ។ សូម្បីព្រះនន្ទកុមារនោះ កាលមិនអាចទូលព្រះមានព្រះភាគថា "សូមព្រះអង្គទទួលបាត្រចុះ" ទើបត្រូវយាងទៅដរាបដល់វត្ត ។

ព្រះមានព្រះភាគ ទ្រង់ញុំាងព្រះនន្ទកុមារនោះ ដែលមិនមានបំណងនឹងបួសសោះឡើយ ។ ព្រះមានព្រះភាគស្តេចមកកាន់កបិលភស្តុបុរី ញុំាងព្រះនន្ទកុមារឱ្យបួសក្នុងថ្ងៃទី ២ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ ព្រះមាតារបស់រាហុល ទ្រង់តាក់តែងព្រះកុមារបញ្ជូនទៅកាន់សំណាក់ ព្រះមានព្រះភាគដោយទ្រង់បង្គាប់ថា "នែកូន កូនឯងចូរមើលសមណៈនោះ ដែលមានសម្បុរដូចសម្បុរនៃមាស មានព្រះរូបឆោមដូចព្រហ្ម មានសមណៈពីរម៉ឺនហែហម ព្រះសមណៈនេះ ជាព្រះបិតារបស់កូនឯង ព្រះសមណៈនោះ មានកំណប់ទ្រព្យដ៏ធំ ចាប់តាំងពីវេលាដែលស្តេចយាងចេញទៅ មាតាមិនបានឃើញសោះ កូនចូរទៅទូលសូមមត៌កនឹងព្រះបិតាថា បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាកុមារនឹងលើកឆត្រឡើងហើយបានជាស្តេចចក្រពត្តិ ។ ខ្ញុំព្រះអង្គត្រូវការទ្រព្យ មេត្តា

ប្រទានទ្រព្យដល់ខ្ញុំព្រះអង្គចុះ ព្រោះថា បុត្ររមែងជាម្ចាស់ទ្រព្យរបស់បិតា” ។

ព្រះកុមារ គ្រាន់តែចូលទៅកាន់សំណាក់ព្រះមានព្រះភាគ ក៏ត្រឡប់បានសេចក្ដីស្រឡាញ់ព្រះបិតា ជាអ្នកមានព្រះហឫទ័យរីករាយត្រេកអរ ទូលថា “បពិត្រព្រះសមណៈ ម្លប់បុណ្យរបស់ព្រះអង្គសុខស្រួលណាស់” ហើយបានឈរទូលពាក្យដ៏សមគួរដល់ខ្លួន សូម្បីដទៃជាច្រើន ។

ព្រះមានព្រះភាគទ្រង់សម្រេចភត្តកិច្ចហើយ ធ្វើអនុមោទនា ស្ដេចក្រោកចាកពីទីប្រថាប់ជៀសចេញទៅ ។

ចំណែកព្រះកុមារ ទ្រង់បានតាមទូលព្រះមានព្រះភាគថា “បពិត្រព្រះសមណៈ សូមព្រះអង្គប្រទានទ្រព្យមត៌កដល់ខ្ញុំព្រះអង្គចុះ, សូមព្រះសមណៈ ប្រទានទ្រព្យមរតកដល់ខ្ញុំព្រះអង្គចុះ” ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យ ពោលពាក្យថា អនុបុព្វេន ចារិកញ្ចរមានោ យេន កបិលវត្ថុ ។បេ ។ ទាយជ្ជំ មេ សមណ ទេហិ : ត្រាច់ទៅតាមលំដាប់ ៗហើយ ទ្រង់បានយាងទៅដល់ក្រុងកបិលវត្ថុនោះឯង ។ល ។ ហើយទូលថា បពិត្រព្រះសមណៈ សូមព្រះអង្គទ្រង់ទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ ដូច្នេះ ។

ពាក្យថា អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ :

លំដាប់នោះព្រះមានព្រះភាគត្រាស់ហៅសារីបុត្រដ៏មានអាយុមកហើយ មានសេចក្តីថា ព្រះមានព្រះភាគទ្រង់មិនឱ្យព្រះកុមារត្រឡប់ហើយ ទាំងជនជាបរិវារ ក៏មិនអាចញុំាងព្រះកុមារដែលយាងទៅជាមួយនឹងព្រះមានព្រះភាគ ឱ្យស្តេចត្រឡប់បាន ។

គ្រានោះ ព្រះមានព្រះភាគស្តេចទៅកាន់អារាម ហើយទ្រង់ត្រិះរិះថា "រាហុលនេះប្រាថ្នាទ្រព្យរបស់បិតាណា ទ្រព្យនោះ ជាប់ដោយវដ្តៈ ប្រព្រឹត្តទៅប្រកបដោយសេចក្តីចង្អៀតចង្អល់ នឹងធ្វើលោកឱ្យជាម្ចាស់របស់មត៌ក ដែលជាលោកុត្តរៈ" ដូច្នេះ ហើយទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមក ។

ក៏ឯគ្រាព្រះសារីបុត្តមកហើយត្រាស់ថា "សារីបុត្ត បើដូច្នោះ លោកចូរញុំាងរាហុលកុមារឱ្យបួសចុះ" ។ អធិប្បាយថា រាហុលកុមារនេះសូមទ្រព្យមរតក ព្រោះហេតុនោះ លោកចូរឱ្យរាហុលកុមារបួស ដើម្បីបាននូវទ្រព្យមត៌កដែលជាលោកុត្តរៈ ។ បព្វជ្ជានិងឧបសម្បទាដោយត្រៃសរណគមន៍ណា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតក្នុងក្រុងពារាណសីនោះ បណ្តាបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍នោះ ទ្រង់ហាមឧបសម្បទា ទ្រង់លើកទុកក្នុងភាពជារបស់ធ្ងន់ហើយ ទើបទ្រង់អនុញ្ញាត ឧបសម្បទាដោយញត្តិចតុត្ថកម្ម ។ ចំណែកបព្វជ្ជាទ្រង់មិនបានហាមឡើយ តែទ្រង់មិនបានអនុញ្ញាតទៀត ព្រោះហេតុនោះ សេចក្តី

សង្ស័យនឹងកើតឡើងដល់ភិក្ខុទាំងឡាយ ក្នុងអនាគតថា "ឈ្មោះថាបព្វជ្ជានេះ ដូចនឹងឧបសម្បទាក្នុងកាលមុន ៗ សូម្បីក្នុងកាលឥឡូវនេះ បព្វជ្ជាដែលយើងទាំងឡាយ គប្បីធ្វើដោយកម្មវាចាទុ៎ះឯង ដូចឧបសម្បទាឬហ្ន៎ ឬថា គប្បីធ្វើដោយត្រៃសរណគមន៍" ដូច្នេះ ៗ ក៏កាលព្រះមានព្រះភាគទ្រង់ជ្រាបសេចក្ដីនេះហើយ ទ្រង់ប្រាថ្នានឹងអនុញ្ញាតសាមណេរបព្វជ្ជា ដោយត្រៃសរណគមន៍ទៀត ព្រោះហេតុនោះ ព្រះធម្មសេនាបតីជ្រាបព្រះអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ប្រាថ្នានឹងញុំាងព្រះមានព្រះភាគ ឱ្យទ្រង់អនុញ្ញាតបព្វជ្ជាទៀត ទើបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបំបួសរាហុលកុមារ ដោយវិធីដូចម្ដេច"

ពាក្យថា អថខោ អាយស្មា សារីបុត្តោ រាហុលកុមារំ បព្វាជេសិ : ព្រះសារីបុត្រដ៏មានអាយុ ក៏បំបួសរាហុលកុមារក្នុងខណៈនោះឯង មានសេចក្ដីថា ព្រះមហាមោគ្គល្លានត្ថេរ កោរព្រះកេសារបស់ព្រះកុមារហើយថ្វាយសំពត់កាសាយៈ ព្រះសារីបុត្តបានឱ្យសរណៈ ៗ ព្រះមហាកស្សបត្ថេរ បានជាឱវាទាចារ្យ ៗ ក៏បព្វជ្ជានិងឧបសម្បទាមានឧបជ្ឈាយ៍ជាមូល ឧបជ្ឈាយ៍ប៉ុណ្ណោះជាធំ ក្នុងបព្វជ្ជានិងឧបសម្បទានោះ អាចារ្យមិនជាធំ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុ ញុំាងព្រះរាហុលកុមារឱ្យទ្រង់ព្រះ

ផ្នួសហើយ ដូច្នេះ ។ ដោយប្រការយ៉ាងនេះ ពាក្យទាំងពួងដែលអ្នកសិក្សាគប្បីពោលថា គ្រានោះឯង ព្រះបាទសុទ្ធោទនសក្យរាជ ទ្រង់កើតសេចក្តីស្លុតព្រះហឫទ័យ ព្រោះទ្រង់ស្តាប់ថា ព្រះកុមារបួសហើយ ក្នុងកាលព្រះរាជាពោលថា "ខ្ញុំព្រះករុណាសូមពរម្យ៉ាង" ដូច្នេះ ដោយមិនបញ្ជាក់ដូចជាពាក្យថា "ចូរសូម" ជាពាក្យមិនសមគួរដល់បព្វជិត ដែលចិញ្ចឹមជីវិតដោយឧញ្ឆាចរិយា[១] ទាំងព្រះពុទ្ធទាំងឡាយ ក៏ទ្រង់មិនប្រព្រឹត្ត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ទុកក្នុងព្រះបាលីនោះថា "បពិត្រមហារាជជាគោតមគោត្រ ព្រះតថាគតទាំងឡាយ មានពរកន្លងហើយ" ។

ពាក្យថា យញ្ច ភន្តេ កប្បតិ យញ្ច អនវជ្ជំ : ព្រះបាទសុទ្ធោទនរាជ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពរណាដែលគួរ ពរណាដែលមិនមានទោស មានសេចក្តីថា ពរណាសមគួរដល់ព្រះអង្គនឹងប្រទានបានផង ជាពរដែលមិនមានទោសផង គឺ ជាពរដែលវិញ្ញូជនទាំងឡាយមិនគប្បីតិះដៀល ព្រោះកិរិយាដែលទទួលរបស់ខ្ញុំព្រះអង្គជាបច្ច័យផង ខ្ញុំព្រះអង្គសូមនូវពរនោះ ។

ពាក្យថា តថា នន្ទេ អធិមត្តំ រាហុលេ : កាលដែលនន្ទនិងរាហុលមកបួស ក៏ខ្ញុំព្រះករុណាកើតទុក្ខខ្លាំងណាស់ដែរ មានសេចក្តីថា

---

១. សូមទានចិញ្ចឹមជីវិត ។

បានឮថា ហោរទាំងឡាយបានទាយព្រះពោធិសត្វក្នុងថ្ងៃមង្គលថា “នឹងជាស្តេចចក្រពត្តិ” យ៉ាងណា ក៏បានទាយទាំងព្រះនន្ទៈ ទាំងព្រះរាហុលក្នុងថ្ងៃមង្គលថា “នឹងជាស្តេចចក្រពត្តិ” យ៉ាងនោះដែរ ។ គ្រានោះ ព្រះរាជាទ្រង់កើតព្រះឧស្សាហ៍ថា “យើងនឹងឃើញចក្រពត្តិសិរីរបស់បុត្របាន” ទ្រង់ក៏ដល់នូវការអស់សង្ឃឹមយ៉ាងខ្លាំង ព្រោះព្រះមានព្រះភាគទ្រង់ព្រះផ្នួស ។ ទើបទ្រង់ញ៉ាំងព្រះឧស្សាហ៍ឱ្យកើតថា “យើងនឹងឃើញចក្រពត្តិសិរីរបស់នន្ទៈ” ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងព្រះនន្ទៈ សូម្បីនោះឱ្យបួសហើយ ។ ក៏ទ្រង់អត់ទ្រាំទុក្ខសូម្បីនោះចេញបាន ទ្រង់ញ៉ាំងព្រះឧស្សាហ៍ឱ្យកើតថា “ឥឡូវនេះ យើងនឹងបានឃើញចក្រពត្តិសិរីរបស់ចៅរាហុល” ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ញ៉ាំងព្រះរាហុលនោះ ឱ្យបួសទៀត ។ ព្រោះដូច្នោះ សេចក្តីទុក្ខទើបបានកើតដល់ព្រះរាជាយ៉ាងក្រៃលែងថា “ឥឡូវនេះ សូម្បីកុលវង្សដាច់ខ្សែអស់ហើយ ចក្រពត្តិសិរីនឹងមានមកពីណាហ្ន៎” ។ ព្រោះហេតុនោះ ព្រះបាទសុទ្ធោទនៈជាសក្យរាជ ទើបទូលថា ឥជា ណន្ទេ អធិមត្តំ រាហុលេ ដូច្នេះ ។

ចំណែកការសម្រេច អនាគាមិផលរបស់ព្រះរាជា អ្នកសិក្សាគប្បីជ្រាបថា ក្រោយពីកាលដែលព្រះរាហុល ទ្រង់ព្រះផ្នួសនេះ ។ តើហេតុអ្វី បានជាព្រះរាជាត្រាស់ពាក្យថា សាធុ ភន្តេ អយ្យា អននុញ្ញាតំ មាតាបិតូហិ

បុត្តំ ន បព្វាជេយ្យុំ : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំសូមអង្វរ លោកម្ចាស់ទាំងឡាយ កុំបំបួសកូនដែលមាតាបិតាមិនបានអនុញ្ញាតឡើយ យ៉ាងនេះ ? ។

បានឮថា ព្រះរាជាទ្រង់ត្រិះរិះថា "សូម្បីថា យើងជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ក៏ពិតមែន តែកាលបុត្រដែលបិតារបស់ខ្លួនបំបួសនោះ ក៏មិនអាចនឹងអត់ទ្រាំញាតិវិយោគទុក្ខបាន ។ ជនពួកដទៃនឹងអត់ទ្រាំបានយ៉ាងណា ក្នុងកាលបុត្រ និងចៅទាំងឡាយរបស់ខ្លួនបួស ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ពាក្យនេះដោយទ្រង់ធ្វើព្រះហឫទ័យថា "ទុក្ខបែបនេះ កុំឱ្យមានដល់ជនពួកដទៃឡើយ" ។ ព្រះមានព្រះភាគទ្រង់ធ្វើធម្មកថាថា ព្រះរាជាត្រាស់ហេតុជាគ្រឿងនាំចេញក្នុងសាសនាហើយ ទ្រង់បញ្ញត្តសិក្ខាបទថា "ម្នាលភិក្ខុទាំងឡាយ បុត្រដែលមាតានិងបិតាមិនបានអនុញ្ញាត ភិក្ខុមិនគប្បីបំបួសឡើយ" ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាតាបិតូហិ : មាតាបិតា** ព្រះមានព្រះភាគត្រាស់សំដៅយកព្រះជននី និងព្រះជនក ។ បើមានទាំង ២ ត្រូវលាទាំង ២ ។ បើបិតាឬមាតាស្លាប់ទៅហើយ អ្នកណានៅរស់ត្រូវលាអ្នកនោះ ។ មាតាបិតាសូម្បីបួសហើយ ក៏គួរលាពិត ។ ភិក្ខុកាលនឹងពោលលា គប្បីទៅពោលលាដោយខ្លួនឯងក៏បាន បញ្ជូនអ្នកដទៃទៅជំនួសក៏បាន បញ្ជូនកុលបុត្រនោះឯងទៅថា "លោកចូរទៅលាមាតាបិតា

ហើយសិន សឹមមក” ដូច្នេះក៏បាន ។ បើកុលបុត្រនោះប្រាប់ថា “ខ្ញុំព្រះករុណា ជាអ្នកដែលមាតាបិតាអនុញ្ញាតហើយ” កាលជឿគប្បីបំបួសបិតាបួសដោយខ្លួនឯងហើយ ជាអ្នកប្រាថ្នា នឹងឱ្យបុត្របួសខ្លះ ចូរប្រាប់មាតាហើយ សឹមបំបួស ។ ឬថា មាតាប្រាថ្នានឹងឱ្យធីតាបួស ចូរប្រាប់បិតាជាមុនហើយ សឹមឱ្យបួស ។ បិតាមិនមានសេចក្ដីត្រេកអរ ដោយបុត្រភរិយា គេចចេញទៅ មាតាប្រគល់បុត្រដល់ភិក្ខុទាំងឡាយថា “សូមលោកម្ចាស់ទាំងឡាយឱ្យបុរសនេះបួសចុះ” កាលភិក្ខុពោលថា “បិតារបស់គេទៅណា ?” គេប្រាប់ថា “គេចចេញទៅ ដើម្បីលេងក្នុងចិត្តគេលី[១] បាត់ទៅហើយ” សមគួរឱ្យបុរសនោះ បួសបាន, មាតាជៀសចេញទៅជាមួយប្រុសខ្លះហើយ ។ ចំណែកបិតាប្រគល់ឱ្យថា “សូមលោកម្ចាស់ទាំងឡាយបំបួសចុះ” ។ សូម្បីក្នុងបុត្រនេះ ក៏ន័យនោះ ។

ក្នុងអដ្ឋកថាកុរុន្ទីពន្យល់ថា បិតាលែងលះ( ពីប្រពន្ធនិងចោលកូន ) ទៅហើយ មាតាអនុញ្ញាតថា “លោកម្ចាស់ចូរបំបួសកូនរបស់ខ្ញុំព្រះករុណាចុះ” កាលភិក្ខុពោលថា “បិតារបស់គេទៅណា ?” គេពោលថា “លោកម្ចាស់នឹងត្រូវការអ្វី ដោយបិតា គេនោះ ខ្ញុំព្រះករុណា នឹងជ្រាប” ដូច្នេះ; គួរបំបួសបាន ។ មាតាបិតាស្លាប់ ទារកចម្រើនក្នុងសំណាក់ញាតិទាំង

១. ការលេងផ្សេង ៗ ដែលធ្វើឱ្យចិត្តភ្លើតភ្លើន ។

ឡាយ មានម្តាយម៉ឹងជាដើម កាលទារកនោះ ដែល ភិក្ខុបំបួស ញាតិទាំងឡាយអាស្រ័យទារកនោះហើយ នឹងបង្កការឈ្លោះ ឬទាំគ្នា តិះដៀល; ព្រោះហេតុនោះ ដើម្បីកាត់ការវិវាទចេញ ភិក្ខុគប្បីប្រាប់ជាមុនសិន សឹមបំបួស ។ តែកាលបំបួស ទោះជាមិនប្រាប់មុន ក៏មិនមានអាបត្តិ ។

ជនអ្នកទទួលយកមកចិញ្ចឹម តាំងពីនៅវ័យក្មេង ក៏ចាត់ជាមាតាបិតាបាន ។ សូម្បីក្នុងមាតាបិតាប្រភេទនោះ ក៏មានន័យដូចគ្នា ។ បុត្រអាស្រ័យខ្លួន គឺ ភិក្ខុរស់នៅ មិនបានអាស្រ័យមាតាបិតា ។ បើសូម្បីបុត្រនោះជាព្រះរាជា ភិក្ខុក៏ត្រូវប្រាប់មាតាបិតាជាមុនសិន សឹមបំបួស ។ បុត្រដែលមាតាបិតាអនុញ្ញាតឱ្យ បួសហើយត្រឡប់សឹក ។ បើសូម្បីគេបួសហើយសឹកទាំង ៧ ដង ភិក្ខុគួរសួរហើយសួរទៀត ក្នុងវេលាដែលគេមកហើយ ៗ សឹមបំបួស ។ បើមាតាបិតាពោលយ៉ាងនេះថា កូននេះសឹកហើយមកផ្ទះ មិនធ្វើការងាររបស់យើង គេបួសហើយនឹងមិនញ៉ាំងវត្តរបស់លោកទាំងឡាយឱ្យពេញ កិច្ចដែលនឹងត្រូវពោលលា សម្រាប់កូននេះ មិនមាន លោកទាំងឡាយគប្បីញ៉ាំងគេដែលមកហើយឱ្យបួសចុះដូច្នេះ សូម្បីនឹងមិនលាទៀត បំបួសកុលបុត្រដែលមាតាបិតាបោះបង់ចោលហើយយ៉ាងនេះ ក៏គួរ ។

សូម្បីបុត្រណា ដែលមាតាបិតាប្រគល់ឱ្យក្នុងវេលាដែលនៅក្មេងយ៉ាងនេះថា "ក្មេងនេះខ្ញុំព្រះករុណា ប្រគេនលោកម្ចាស់ លោកម្ចាស់គប្បី

បំបួសក្នុងវេលាដែលលោកម្ចាស់ប្រាថ្នាចុះ” ដូច្នេះ សូម្បីបុត្រនោះ មកហើយ ៗ ភិក្ខុគប្បីប្រាប់ទៀតនោះឯង សឹមបំបួស ។ ចំណែកបុត្រណាមាតាបិតាអនុញ្ញាតក្នុងកាលដែលនៅក្មេងថា “បពិត្រលោកម្ចាស់ លោកម្ចាស់គប្បីឱ្យក្មេងនេះបួសចុះ” ក្រោយក្មេងនោះដល់សេចក្ដីចម្រើនត្រឡប់ជាមិនអនុញ្ញាត ។ បុត្រនេះ ភិក្ខុមិនទាន់បានប្រាប់មាតាបិតា មិនគប្បីបំបួស ។ បុត្រម្នាក់ត្រាច់ទៅជាមួយមាតាបិតាមកពោលថា “សូមលោកម្ចាស់បំបួសនូវខ្ញុំព្រះករុណាចុះ” ។ កាលភិក្ខុពោលថា “អ្នកចូរលា( មាតាបិតា ) ហើយសឹមមក” ទើបគេពោលថា “ខ្ញុំព្រះករុណាមិនទៅទេ, បើលោកម្ចាស់ មិនបំបួសខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងដុតវិហារចោល; ឬនឹងសម្លាប់ពួកលោកម្ចាស់ដោយសស្ត្រា; ឬនឹងបង្កើតសេចក្ដីវិនាស ដោយការបំផ្លាញសួនជាដើមរបស់ញាតិ និងឧបដ្ឋាកទាំងឡាយរបស់ពួកលោកម្ចាស់”; ឬថា “ខ្ញុំព្រះករុណា នឹងលោតទម្លាក់ពីលើដើមឈើឱ្យស្លាប់, ឬនឹងចូលទៅកាន់ទីលំនៅចោរ, ឬនឹងទៅប្រទេសដទៃ” ដូច្នេះ; សមគួរឱ្យគេបួស ដើម្បីត្រូវការរក្សាជីវិតទុកប៉ុណ្ណោះ ។ បើមាតាបិតារបស់គេមក និយាយថា ហេតុអ្វីបានជាឱ្យបុត្ររបស់ខ្ញុំព្រះករុណាបួស ? ភិក្ខុគប្បីប្រាប់សេចក្ដីនោះ ដល់គេទាំងឡាយ ហើយគប្បីពោលថា “អាត្មាភាពឱ្យគេបួស ដើម្បីនឹងការពារទុកអ្នកទាំងឡាយ ចូរសាកសួរបុត្រនោះ មើលចុះ” ។

មួយទៀត សមគួរពិត ដែលបំបួសនូវអ្នកគិតថា "យើងនឹងលោតទម្លាក់ពីលើដើមឈើឱ្យស្លាប់" ហើយឡើងទៅលែងដៃនិងជើង ។ បុត្រម្នាក់ទៅកាន់ប្រទេសដទៃហើយសូមបួស ។ បើគេលាហើយទើបទៅ គប្បីបំបួសបាន ។ បើមិនបានលា គប្បីបញ្ជូនភិក្ខុកំលោះ ទៅឱ្យពោលលាហើយ សឹមបំបួស ។ បើប្រទេសដទៃនោះជាទីឆ្ងាយពេក ។ សូម្បីនឹងបំបួសហើយ បញ្ជូនទៅបង្ហាញមួយអន្លើដោយភិក្ខុទាំងឡាយ ក៏គួរ ។

តែក្នុងអដ្ឋកថាកុរុន្ទីពោលថា បើប្រទេសដទៃជាស្ថានឆ្ងាយផង មកកន្តារច្រើនផង នឹងបំបួសដោយតាំងចិត្តថា "យើងនឹងទៅប្រាប់" ដូច្នេះ ក៏គួរ ។ តែបើមាតាបិតាមានបុត្រច្រើន គេបានពោលយ៉ាងនេះថា "លោកម្ចាស់បណ្តាក្មេងទាំងនេះ លោកម្ចាស់ប្រាថ្នានឹងឱ្យអ្នកណាបួស គប្បីឱ្យអ្នកនោះបួសចុះ" ភិក្ខុគប្បីត្រួតមើលក្មេងទាំងឡាយហើយ ប្រាថ្នាក្មេងណា គប្បីឱ្យក្មេងនោះបួស បើសូម្បីត្រកូល ឬស្រុកទាំងអស់អនុញ្ញាតទុកថា "លោកម្ចាស់ ក្នុងត្រកូល ឬ ក្នុងស្រុកនេះ លោកប្រាថ្នានឹងឱ្យអ្នកណាបួស គប្បីឱ្យអ្នកនោះបួសចុះ" ដូច្នេះ ។ ភិក្ខុប្រាថ្នាអ្នកណា គប្បីឱ្យអ្នកនោះបួសបាន ។

រាហុលសាមណេរបព្វជ្ជា ចប់

# វិន័យរបស់សាមណេរ

## សិក្ខាបទ ១០ របស់សាមណេរ

[១១៩] ប្រើនបទថា យាវតកេ វា បន ឧស្សហតិ : ម្យ៉ាងវិញទៀត បើភិក្ខុនោះអាច មានសេចក្ដីថា រមែងអាចជាស់តឿនទូន្មានសាមណេរ មានប្រមាណប៉ុនណា ។

[១២០] ក្នុងសិក្ខាបទ ១០ សេចក្ដីល្មើស ៥ សិក្ខាបទខាងដើម ជាវត្ថុនៃនាសនា, សេចក្ដីល្មើស ៥ សិក្ខាបទខាងចុងជាវត្ថុនៃទណ្ឌកម្ម ។

## រឿងទណ្ឌកម្មពួកសាមណេរ

[១២១] បទថា អប្បតិស្សា : មិនកោតក្រែង មានសេចក្ដីថា មិនតាំងភិក្ខុទុកក្នុងឋានៈដ៏ចម្រើន គឺក្នុងតំណែងជាធំ ។

បទថា អសភាគវុត្តិកា : មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នា មានសេចក្ដីថា មិនជាអ្នករស់នៅស្មើគ្នា អធិប្បាយថា ជាអ្នករស់នៅមិនត្រូវគ្នា ។

ពាក្យថា អលាភាយ បរិសក្កតិ : សាមណេរព្យាយាមដើម្បីនឹងឱ្យសាបសូន្យលាភ មានសេចក្ដីថា ភិក្ខុទាំងឡាយ នឹងមិនបានលាភដោយប្រការណា លោករមែងព្យាយាមដោយប្រការនោះ ។

បទថា អនត្ថាយ : ដើម្បីមិនឱ្យជាប្រយោជន៍ បានដល់ ដើម្បីឧបទ្រវៈ ។

បទថា អនាវាសាយ : ដើម្បីនឹងមិនឱ្យបានលំនៅ មានសេចក្តីថា លោករមែងព្យាយាមថា "ធ្វើដូចម្តេចហ្ន៎ ភិក្ខុទាំងនោះ មិនគប្បីនៅក្នុងអាវាសនេះ" ។

ពីរបទថា អក្កោសតិ បរិភាសតិ : ជេរគម្រាម មានសេចក្តីថា លោករមែងជេរប្រទេច និងគម្រាមកំហែងដោយសម្តែងភ័យ ។

បទថា ភេទេតិ : ឱ្យបែក មានសេចក្តីថា លោករមែងរករឿងស៊កសៀតឱ្យបែកគ្នា ។

ពីរបទថា អាវរណំ ករោតុ : ធ្វើការហាមប្រាម មានសេចក្តីថា ដើម្បីធ្វើការហាមថា "លោកកុំចូលមកក្នុងទីនេះ" ។

ច្រើនបទថា យត្ថ វា វសតិ យត្ថ វា បដិក្កមតិ : សាមណេរធ្លាប់នៅក្នុងទីណា ឬធ្លាប់ចូលទៅក្នុងទីណា មានសេចក្តីថា លោកនៅក្តី ចូលទៅក្តី ក្នុងទីណា ។ បរិវេណរបស់ខ្លួន និងសេនាសនៈដែលដល់តាមលំដាប់វស្សា ព្រះមានព្រះភាគត្រាស់ហើយសូម្បីដោយបទទាំង ២ ។

ច្រើនបទថា មុខទ្វារិកំ អាហារំ អាវរណំ ករោន្តិ : ធ្វើការ

ហាមប្រាមចំពោះអាហារដែលបរិភោគតាមទ្វារមាត់ មានសេចក្តីថា ភិក្ខុទាំងឡាយ រមែងហាមយ៉ាងនេះថា ថ្ងៃនេះ លោកទាំងឡាយ កុំទំពារ កុំឆាន់ ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីនេះថា ន ភិក្ខវេ មុខទ្វារិកោ អាហារោ អាវរណំ កាតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើការហាមប្រាមចំពោះអាហារដែលបរិភោគតាមទ្វារមាត់ឡើយ នេះដូច្នេះ ៖

កាលភិក្ខុពោលថា "លោកកុំទំពារ កុំឆាន់" ដូច្នេះក្តី វក្សាបាត្រចីវរទុកខាងក្នុងដោយតាំងចិត្តថា "យើងនឹងហាមអាហារ" ដូច្នេះក្តី ត្រូវទុក្កដគ្រប់ ៗ ប្រយោគ ។ តែនឹងធ្វើទណ្ឌកម្មដល់សាមណេរដែលប្រដៅក្រ មិនមានអាចារៈ នឹងសម្តែងយាគូ ឬ ភត្ត ឬបាត្រ និងចីវរ ពោលថា "កាលទណ្ឌកម្ម មានប្រមាណប៉ុណ្ណេះ ដែលលោកព្រមទទួល លោកនឹងបានវត្ថុនេះ" ដូច្នេះ សមគួរ ។

ពិតមែន ទណ្ឌកម្ម ក៏គឺ ការហាម ដែលព្រះមានព្រះភាគត្រាស់ហើយ ចំណែកព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា សូម្បីការឱ្យនាំនូវទឹក ឬខុស ឬឱ្យពូចជាដើម លួមសមគួរដល់កំហុស ភិក្ខុក៏គួរធ្វើបាន ។ ព្រោះហេតុនោះ សូម្បីការឱ្យជងទឹកជាដើមនោះ ដែលភិក្ខុគប្បី

ធ្វើ ។ ក៏ទណ្ឌកម្មនោះឯង ដែលភិក្ខុគប្បីដាក់ដោយសេចក្តីអាណិតថា លោកនឹងវៀរ នឹងឈប់ មិនគប្បីដាក់ដោយអធ្យាស្រ័យដ៏លាមក ដែលប្រព្រឹត្តទៅដោយន័យជាដើមថា "លោកនឹងសាបសូន្យ លោកនឹងសឹកចេញទៅ" ។ ដោយគិតថា "យើងនឹងដាក់ទណ្ឌកម្ម នឹងឱ្យលោកដេកលើថ្មដ៏ក្តៅ ឬនឹងឱ្យលោកទូលដុំថ្ម និងឥដ្ឋជាដើមទុកលើសីសៈ ឬនឹងឱ្យលោកចុះត្រាំទឹក" រមែងមិនគួរ ។

សិក្ខាបទ ១០ របស់សាមណេរ ចប់

## អនាបុច្ឆាវរណវត្ថុអាទិកថា

[១២២] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ ឧបជ្ឈាយំ អនាបុច្ឆា : ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនទាន់ប្រាប់ពួកឧបជ្ឈាយ៍ នេះដូច្នេះ ៖

កាលខ្លួនប្រាប់គ្រប់ ៣ ដងថា "សាមណេររបស់លោក មានកំហុសយ៉ាងនេះ លោកចូរដាក់ទណ្ឌកម្មដល់សាមណេរនោះ" បើឧបជ្ឈាយ៍មិនដាក់ទណ្ឌកម្ម នឹងដាក់ដោយខ្លួនឯង ក៏គួរ បើឧបជ្ឈាយ៍ប្រាប់ទុកតាំងពីដំបូងថា "កាលពួកសាមណេររបស់ខ្ញុំព្រះករុណាមានទោស លោកទាំងឡាយទុំះឯង ចូរដាក់ទណ្ឌកម្ម" ដូច្នេះ សមគួរនឹងដាក់

ពិត ៗ និងចូរដាក់ទណ្ឌកម្ម សូម្បីដល់ពួកភិក្ខុជាសទ្ធិវិហារិកនិងអន្តេវាសិក ដូចសាមណេរទាំងឡាយ ក៏គួរ ។

[១២៣] បទថា អបលាឡេន្តិ : ប្រលោមយក មានសេចក្តីថា រមែងបញ្ចុះបញ្ចូល ដើម្បីធ្វើឧបដ្ឋាកដល់ខ្លួនថា "ពួកខ្ញុំព្រះករុណានឹងឱ្យបាត្រ នឹងឱ្យចីវរដល់ពួកលោក" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ អញ្ញស្ស បរិសា អបលាឡេតព្វា : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីប្រលោមយកបរិស័ទរបស់ភិក្ខុដទៃឡើយ នេះ ដូច្នេះ ៖

ទោះជាសាមណេរ ឬឧបសម្បន្នក៏ដោយ ដែលភិក្ខុនឹងញុះញង់ទទួលយកជនដែលជាបរិស័ទរបស់អ្នកដទៃ ដោយហោចទៅ សូម្បីជាភិក្ខុដែលទ្រុស្តសីល រមែងមិនគួរ តែសមគួរនឹងសម្តែងទោសថា "ការដែលលោកធ្វើការនៅអាស្រ័យនឹងអ្នកទ្រុស្តសីលហើយ ក៏ដូចការដែលជនមកដើម្បីនឹងផ្លូតទឹក តែបែរទៅជាលាបដោយលាមក" ដូច្នេះ ។ បើលោកជ្រាបទៅដោយខ្លួនឯង ទើបសូមឧបជ្ឈាយ៍ ឬនិស្ស័យ ភិក្ខុនឹងឱ្យក៏គួរ ។

## នាសនង្គ ១០ របស់ពួកសាមណេរ

[១២៤] បណ្ដានាសនា ៣ ដែលពោលហើយក្នុងវណ្ណនានៃកណ្ឋកសិក្ខាបទ[១] លិង្គនាសនាប៉ុណ្ណោះ ប្រាថ្នាក្នុងពាក្យថា អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុញុំាងសាមណេរដែលប្រកបដោយអង្គទាំងឡាយ ១០ នេះឱ្យវិនាស នេះ; ព្រោះហេតុនោះ ក្នុងកម្មទាំងឡាយមានបាណាតិបាតជាដើម សាមណេរណា រមែងធ្វើកម្ម សូម្បីម្យ៉ាង សាមណេរនោះ ដែលភិក្ខុគប្បីឱ្យវិនាស ដោយលិង្គនាសនា ដូចថា "ភិក្ខុទាំងឡាយ រមែងត្រូវអាបត្តិផ្សេងគ្នា ព្រោះតែកម្មទាំងឡាយ មានបាណាតិបាតជាដើម យ៉ាងណា, សាមណេរទាំងឡាយ នឹងមិនបានជាយ៉ាងនោះទេ ។ ព្រោះថា សាមណេរញុំាងស្រមោចខ្មៅ ស្រមោចក្រហមឱ្យស្លាប់ក្ដី ញៀចពងសង្កើចក្ដី រមែងដល់ភាពជាអ្នកគួរឱ្យវិនាសតែម្ដង ។ សរណគមន៍ ការកាន់ឧបជ្ឈាយ៍ និងការកាន់សេនាសនៈរបស់លោក រមែងរម្ងាប់ភ្លាម ។ លោករមែងមិនបានលាភសង្ឃ, នៅសល់តែវត្ថុមួយ គឺ ភេទប៉ុណ្ណោះ, បើលោកជាអ្នកមានទោស ប្រទូស្តប្រទ្សំ នឹងមិនតាំងនៅក្នុងសំវរៈតទៅ គប្បីកម្ចាត់ចេញ បើលោកខុសភ្លាំងភ្លាត់ទៅ

១. សមន្ត. បាចិ. ៤. ៤៦៥ ។

ហើយ ព្រមទទួលថា “អំពើអាក្រក់ខ្ញុំព្រះករុណាបានធ្វើហើយ” ដូច្នេះ ជាអ្នកប្រាថ្នានឹងតាំងនៅក្នុងសំវរៈទៀត កិច្ចគឺ លិង្គនាសនា រមែងមិនមាន, គប្បីឱ្យសរណៈទាំងឡាយ គប្បីឱ្យឧបជ្ឈាយ៍ដល់លោកដែលនៅស្លៀកដណ្ដប់ដូចដើមតែម្ដង ។ ចំណែកសិក្ខាបទទាំងឡាយ រមែងសម្រេចដោយសរណគមន៍នុ៎ះឯង, ពិតមែន សរណគមន៍របស់សាមណេរទាំងឡាយ ក៏ដូចជាកម្មវាចាក្នុងឧបសម្បទារបស់ភិក្ខុទាំងឡាយ ព្រោះហេតុនោះ សីលទាំង ១០ នោះ សូម្បីសាមណេរនេះ ក៏ឈ្មោះថាបានសមាទានហើយពិត ដូចចតុបារិសុទ្ធិសីល ដែលភិក្ខុសមាទានហើយដូច្នោះ, សូម្បីជាយ៉ាងនេះក៏ដោយ សីល ១០ ក៏គួរឱ្យទៀត ដើម្បីធ្វើឱ្យរឹងមាំ គឺ ដើម្បីញ៉ាំងលោកឱ្យតាំងនៅក្នុងសំវរៈតទៅ បើសរណៈទាំងឡាយ ដែលលោកទទួលទៀត ក្នុងវស្សូបនាយិកាខាងដើម លោកនឹងបានសំពត់ចំណាំវស្សា ក្នុងវស្សូបនាយិកាក្រោយ ។ បើលោកទទួលសរណៈ ក្នុងវស្សូបនាយិកាក្រោយ លាភគឺ សង្ឃគប្បីអបលោកន៍ឱ្យ ។

សាមណេរ រមែងមិនមែនជាសមណៈ គឺ រមែងដល់ភាព ជាអ្នកគួរនាសនាចេញ ព្រោះអទិន្នាទាន ដោយវត្ថុសូម្បីត្រឹមតែស្មៅ ១ សរសៃ ព្រោះអព្រហ្មចរិយៈ ដោយបដិបត្តិខុសក្នុងមគ្គទាំង ៣ ណាមួយ, ព្រោះមុសាវាទ កាល ខ្លួនពោលកុហក សូម្បីដោយភាពជាអ្នកប្រាថ្នានឹងសើចលេង ចំណែកក្នុងការផឹកទឹកស្រវឹង ជាអាបត្តិបាចិត្តិយ

ដល់ភិក្ខុសូម្បីមិនដឹង ផឹកទឹកស្រវឹងចាប់ផ្ដើមតាំងពីដាក់ពូជសុរា ។ ចំណែកសាមណេរ ដឹងហើយផឹក ទើបត្រូវសីលភេទ បើមិនដឹង មិនត្រូវ ។ ចំណែកសិក្ខាបទទាំងឡាយ ៥ ក្រៅពីនេះ ពួកណា របស់សាមណេរនោះ កាលសិក្ខាបទទាំងនោះបែកធ្លាយហើយ លោកដែលភិក្ខុមិនត្រូវឱ្យសឹក គប្បីដាក់ទណ្ឌកម្ម ។ ឯកាលសិក្ខាបទដែលភិក្ខុបានឱ្យទៀតក្ដី មិនទាន់បានឱ្យក្ដី នឹងដាក់ទណ្ឌកម្ម រមែងគួរ ។ ប៉ុន្តែថា គប្បីទូន្មានដោយទណ្ឌកម្ម ហើយសឹមឱ្យសិក្ខាបទ ដើម្បីប្រយោជន៍ដល់ការតាំងនៅក្នុងសំវរៈតទៅ ។ ការផឹកទឹកស្រវឹងរបស់ពួកសាមណេរជាសចិត្តកៈ ទើបជាវត្ថុនៃបារាជិក ។ សេចក្ដីប្លែកគ្នាប៉ុណ្ណោះ ។

ក៏ឯវិនិច្ឆ័យក្នុងអវណ្ណភាសនៈ គប្បីជ្រាបដូច្នេះ ៖

ក្នុងអដ្ឋកថាកុរុន្ទីពន្យល់ថា សាមណេរដែលពោលទោសព្រះពុទ្ធដោយអំណាចនៃពាក្យជាសត្រូវដល់ពុទ្ធគុណ ជាដើមថា **អរហំ សម្មាសម្ពុទ្ធោ**ក្ដី ពោលទោសព្រះធម៌ ដោយអំណាចនៃពាក្យជាសត្រូវដល់ធម្មគុណជាដើមថា **ស្វាក្ខាតោ** ក្ដី ពោលទោសព្រះសង្ឃ ដោយអំណាចនៃពាក្យជាសត្រូវដល់សង្ឃគុណជាដើមថា **សុបដិបន្នោ** ក្ដី បានដល់ និន្ទា គឺ តិះដៀលព្រះរតនត្រ័យ ដែលភិក្ខុទាំងឡាយមានអាចារ្យ និងឧបជ្ឈាយ៍ជាដើម គប្បីសម្ដែងទោសក្នុងការពោលទោស ហាមប្រាមថា លោកកុំពោលយ៉ាងនោះ បើភិក្ខុទាំងឡាយ ពោលប្រដៅលោក ដល់ ៣ ដង

នៅតែមិនលះបង់ ភិក្ខុទាំងឡាយគប្បីឱ្យវិនាស ដោយកណ្ដកនាសនា ។

ចំណែកក្នុងមហាអដ្ឋកថាពោលថា បើភិក្ខុទាំងឡាយ ពោលប្រដៅលោកយ៉ាងនោះ ហើយព្រមលះបង់លទ្ធិនោះ គប្បីឱ្យធ្វើទណ្ឌកម្ម ហើយសម្ដែងទោស ដែលប្រព្រឹត្តកន្លង ។ បើមិនព្រមលះបង់ នៅតែប្រកាន់លើកតម្កើងជាប់រហូតយ៉ាងនោះឯង គប្បីឱ្យវិនាសដោយលិង្គនាសនា ។

ពាក្យនៃមហាអដ្ឋកថា នោះប្រពៃ ។ ព្រោះថា នាសនានេះប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់ប្រាថ្នាក្នុងអធិប្បាយនេះ ។ សូម្បីក្នុងសាមណេរដែលជាមិច្ឆាទិដ្ឋិ ក៏ន័យនេះឯង ។ សាមណេរមាននូវសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិប្រភេទណាមួយ បើសាមណេរដែលភិក្ខុទាំងឡាយ មានអាចារ្យជាដើម ដាស់តឿន បើលះបង់ចេញបាន គប្បីឱ្យធ្វើទណ្ឌកម្ម ហើយឱ្យសម្ដែងទោស កាលមិនព្រមលះបង់នុ៎ះឯង គប្បីឱ្យវិនាស ដូច្នេះឯង ។

អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានថា អង្គទី១០ ដទៃ គឺ ភិក្ខុនីទូសកោ នេះ ដែលព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្ដែងសេចក្ដីនេះថា ពិតមែន បណ្ដានាសនង្គៈទាំង ១០ នេះ សាមណេរជាអ្នកប្រទូស្តនាងភិក្ខុនី ដែលព្រះអង្គទ្រង់កាន់យកដោយអព្រហ្មចារីសព្ទ ក៏ពិតមែនហើយ, តែក៏សមគួរនឹងឱ្យសរណៈ ហើយឱ្យឧបសម្បទា អព្រហ្មចារីសា

មណេរ ដែលប្រាថ្នានឹងតាំងនៅក្នុងសំវរៈតទៅ ។ សាមណេរដែលប្រទូស្តនាងភិក្ខុនី សូម្បីប្រាថ្នា នឹងតាំងនៅក្នុងសំវរៈតទៅ រមែងមិនបាន សូម្បីនូវបព្វជ្ជា មិនចាំបាច់ពោលដល់ឧបសម្បទានោះឡើយ ។

វិន័យរបស់សាមណេរ ចប់

## មនុស្សខ្ទើយ

[១២៥] ពីរបទថា ឧហារេ ឧហារេ : កំលោះ ៗ បានដល់ភិក្ខុក្មេង ៗ ។

បទថា មោលិគល្លេ បានដល់ ចូឡសីរេ : អ្នកដែលមានសរីរៈធាត់ ។

ពីរបទថា ហត្ថិភណ្ឌេ អស្សភណ្ឌេ : ពួកគង្វាលដំរី ពួកគង្វាលសេះ បានដល់ អ្នកចិញ្ចឹមដំរី និងអ្នកចិញ្ចឹមសេះ ។

ក្នុងពាក្យថា បណ្ឌកោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ខ្ទើយជាដើមនេះ មានវិច្ឆ័យថា បណ្ឌក មាន ៥ ប្រភេទ គឺ អាសិត្តបណ្ឌក ១ ឧសូយបណ្ឌក ១ ឱបក្កមិយបណ្ឌក ១ បក្ខបណ្ឌក ១ នបុំសកបណ្ឌក ១ ។

បណ្ដាបណ្ឌកទាំង ៥ ប្រភេទនោះ បណ្ឌកណា យកមាត់បៀមអង្គជាតិរបស់ពួកប្រុសដទៃ ត្រូវទឹកអសុចិស្រោចហើយ សេចក្ដីអន្ទះអន្ទែង ទើបស្ងប់រម្ងាប់ទៅ បណ្ឌកនេះ ឈ្មោះថា អាសិត្តបណ្ឌក ។

ចំណែកបណ្ឌកណា ឃើញអជ្ឈាចាររបស់ពួកជនដទៃ កាលសេចក្ដីឫស្យាកើតឡើងហើយ សេចក្ដីក្ដៅក្រហាយ ទើបស្ងប់រម្ងាប់ទៅ បណ្ឌកនេះ ឈ្មោះថា ឧសុយ្យបណ្ឌក ។

បណ្ឌកណាមានអវយវៈ ដូចពូជទាំងឡាយ ត្រូវនាំទៅ ប្រាសចាកហើយ គឺ ត្រូវគេក្រៀវចេញហើយ ដោយសេចក្ដីព្យាយាម[1] បណ្ឌកនេះ ឈ្មោះថា ឱបក្កមិយបណ្ឌក ។

ចំណែកអ្នកណា ខាងរនោចជាបណ្ឌក ដោយអានុភាពនៃអកុសលវិបាក តែខាងខ្នើត សេចក្ដីក្ដៅក្រហាយរបស់គេ រមែងស្ងប់រម្ងាប់ទៅ នេះឈ្មោះថា បក្ខបណ្ឌក ។

ចំណែកបណ្ឌកណា កើតមកមិនមានភេទ មិនមានភាវរូបក្នុងបដិសន្ធិតែម្ដង គឺមិនប្រាកដជា ប្រុស ឬស្រីតាំងពីកំណើត បណ្ឌកនេះ ឈ្មោះថា នបុំសកបណ្ឌក ។

---

១. ភាសាសំស្ក្រិត ឧបក្រម (ឧបក្កម) សំដៅសេចក្ដីថា ចិកិត្សា (តិកិច្ឆា) ក៏បាន ដូច្នេះ ឧបក្កម ក្នុងទីនេះ ទើបគួរនឹងសំដៅសេចក្ដីទៅផ្នែកខាងវិធីពេទ្យ ដូចការផ្សំថ្នាំព្យាបាលវះកាត់ជាដើម ។

ក្នុងអដ្ឋកថាកុរុន្ទីពន្យល់ថា ក្នុងបណ្ឌក ៥ ប្រភេទនោះ អាសិត្តបណ្ឌក និងឧសូយបណ្ឌក មិនហាមបព្វជ្ជា, ៣ ប្រភេទ ក្រៅពីនេះ ហាម ក្នុងបណ្ឌក ៣ ប្រភេទនោះ សម្រាប់បក្ខបណ្ឌក ហាមបព្វជ្ជាដល់គេចំពោះតែបក្ខដែលជាបណ្ឌក ប៉ុណ្ណោះ ។ ក៏ក្នុងបណ្ឌាបណ្ឌក ៣ ប្រភេទនោះ បណ្ឌកណា ដែលទ្រង់ហាមបព្វជ្ជា ព្រះមានព្រះភាគទ្រង់បំណងយកបណ្ឌកនោះ ត្រាស់ពាក្យនេះថា ឧបសម្បន្នោ នាសេតព្វោ : បើជាឧបសម្បន្នហើយ ត្រូវឱ្យវិនាសចេញ ។ បណ្ឌកសូម្បីនោះ ភិក្ខុគប្បីឱ្យវិនាសដោយលិង្គនាសនាតែម្តង ។ ខាងមុខបន្ទាប់ពីនេះ សូម្បីក្នុងពាក្យដែលពោលថា គប្បីឱ្យវិនាស ក៏មាននន័យនេះដូចគ្នា ។

មនុស្សខ្ទើយ ចប់

## មនុស្សលួចសំវាស

[១២៦] បទថា បុរាណកុលបុត្តោ : កុលបុត្រចាស់ បានដល់ បុត្ររបស់ត្រកូលចាស់ គឺ ដល់សេចក្តីព្រាត់ប្រាស់ដោយលំដាប់ ។

បទថា ខីណកោលញ្ញោ : ជាបុគ្គលគ្មានញាតិសាលោហិត មានអត្ថវិគ្រោះថា ញាតិទាំងឡាយដែលស្គាល់គ្នាក្នុងត្រកូល ។

ចំណែកមាតានិងចំណែកបិតារបស់គេ អស់ហើយ សាបសូន្យ

ហើយ គឺស្លាប់ហើយ ហេតុនោះ គេឈ្មោះថា **ទិណកោលញ្ញោ** អ្នកមានញាតិដែលស្គាល់គ្នាក្នុងត្រកូលអស់ទៅហើយ ។

បទថា អនធិគតំ **: មិនទាន់បាន** បានដល់ នៅមិនទាន់ដល់ ។

ពីរបទថា ជាតី កាតុំ **: ឱ្យរីតតែចម្រើន** បានដល់ ដើម្បីឱ្យចម្រើន ។ សព្ទថា ឥច្ឆ ជាឧបយោជនត្ថនិបាត ។

បទថា អនុយុញ្ជិយមានោ **: កាលជម្រះសួរ** មានសេចក្តីថា កុលបុត្រនោះ ដែលព្រះឧបាលីបាននាំទៅក្នុងចំណែកខាងម្ខាងហើយ សួរដល់ការកោរសក់ និងពុកមាត់ ការទទួលសំពត់កាសាយៈ ការដល់សរណៈ ការកាន់ឧបជ្ឈាយ៍ កម្មវាចា និងធម៌ជាទីអាស្រ័យ ។

ពីរបទថា ឯតមត្ថំ អារោចេសិ **: តំណាលរឿងនុ៎ះប្រាប់តាមត្រង់** មានសេចក្តីថា ប្រាប់សភាពដែលខ្លួនបួសដោយខ្លួនឯងនោះ ចាប់ផ្តើមតាំងពីដើម ។

ក្នុងពាក្យថា ថេយ្យសំវាសកោ ភិក្ខវេ **: ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាអ្នកលួចសំវាស** នេះ មានវិនិច្ឆ័យថា បុគ្គលថេយ្យសំវាសមាន ៣ ប្រភេទ គឺ បុគ្គលលួចភេទ ១ បុគ្គលលួចសំវាស ១ បុគ្គលលួចទាំង ២ យ៉ាង ១ ។

បណ្តាបុគ្គលទាំង ៣ ប្រភេទនោះ បុគ្គលណាបួសដោយខ្លួនឯង

ហើយទៅកាន់វត្ត មិនរាប់វស្សានៃភិក្ខុ មិនត្រេកអរការ សំពះតាមលំដាប់ភិក្ខុចាស់ មិនហាមដោយអាសនៈ ។ មិនចូលក្នុងសង្ឃកម្មមានឧបោសថ និងបវារណាជាដើម; បុគ្គលនេះ ឈ្មោះថា បុគ្គលលួចភេទ ព្រោះគេលួចត្រឹមតែភេទប៉ុណ្ណោះ ។

ចំណែកអ្នកណា ជាសាមណេរដែលបួសអំពីភិក្ខុទាំងឡាយ ហើយទៅកាន់ប្រទេសដទៃ ពោលកុហកពរាប់វស្សាភិក្ខុថា "ខ្ញុំព្រះករុណាមានវស្សា ១០" ឬថា "ខ្ញុំព្រះករុណាមានវស្សា ២០" ត្រេកអរការថ្វាយបង្គំតាមលំដាប់ភិក្ខុចាស់, ហាមអាសនៈចូលទៅក្នុងសង្ឃកម្ម មានឧបោសថនិងបវារណាជាដើម; បុគ្គលនេះ ឈ្មោះថា បុគ្គលលួចសំវាស ព្រោះគេលួចត្រឹមតែសំវាសប៉ុណ្ណោះ ។

សេចក្តីផ្សេងគ្នានៃកិរិយាស្មុម្បីទាំងពួង មានរាប់វស្សានៃភិក្ខុជាដើម អ្នកសិក្សាគួរជ្រាបថា សំវាស ក្នុងអត្ថនេះ ។ ស្មុម្បីក្នុងបុគ្គលលាសិក្ខាហើយ បដិបត្តិយ៉ាងនោះ ដោយគិតថា "អ្នកណា ៗ រមែងដឹងការសឹករបស់យើង" ក៏មានន័យដូចគ្នា ។

ចំណែកបុគ្គលណា បួសដោយខ្លួនឯង ហើយទៅកាន់វត្តរាប់វស្សានៃភិក្ខុ ត្រេកអរក្នុងការសំពះតាមលំដាប់ចាស់វស្សា ហាមដោយអាសនៈ ចូលក្នុងសង្ឃកម្មមានឧបោសថ និងបវារណាជាដើម; បុគ្គលនេះ ឈ្មោះថា បុគ្គលលួចទាំង ២ ព្រោះហេតុដែលខ្លួនលួចទាំងភេទ

លួចទាំងសំវាស ។

បុគ្គលថេយ្យសំវាសទាំង ៣ ប្រភេទនេះ ជាអនុបសម្បន្ន មិនគួរឱ្យឧបសម្បទាជាឧបសម្បន្ន គួរឱ្យវិនាសចេញ; ទោះបីសូមបួសទៀតក៏មិនគួរបំបួស ។ ទឹងដើម្បីមិនច្រឡំក្នុងថេយ្យសំវាសកាធិការនេះ គប្បីជ្រាបបទបកិណ្ណកៈនេះថា ៖

ជនណាកាន់ភេទក្នុងព្រះសាសនានេះ ព្រោះរាជភ័យ ទុព្ភិក្ខភ័យ កន្តារភ័យ រោគភ័យ និងវេរីភ័យក្តី ដើម្បីនឹងនាំចីវរមកក្តី ជននោះមានចិត្តបរិសុទ្ធិ មិនទាន់ទទួលសំវាសត្រឹមណា ជននោះបណ្ឌិតមិនទាន់ពោលថា ជាបុគ្គលថេយ្យសំវាសត្រឹមនោះ ។

គប្បីជ្រាបន័យពិស្តារក្នុងគាថានោះ ដូច្នេះ ៖

ព្រះរាជាក្នុងលោកនេះ រមែងក្រោធចំពោះបុរសខ្លះ ។ បុរសនោះគិតថា សេចក្តីសួស្តីនឹងមានដល់យើងដោយឧបាយយ៉ាងនេះ ហើយកន់យកភេទដោយខ្លួនឯងតែម្តង គេចចេញទៅ ។ ជនទាំងឡាយជួបគេហើយ ក្រាបទូលចំពោះព្រះរាជា ។ ព្រះរាជាទ្រង់បន្ទោបង់សេចក្តីខឹងក្រោធក្នុងគេចេញ ដោយទ្រង់ព្រះតម្រិះថា "បើបួសហើយ យើងមិនបានដើម្បីនឹងធ្វើអ្វីគេ", តែគេមិនទាន់ចូលទៅកាន់ជំនុំសង្ឃ គេកាន់យកភេទជាគ្រហស្ថហើយ ក៏ចូលមកដោយគិតថា "រាជភ័យរបស់យើងស្ងប់ហើយ" ភិក្ខុទាំងឡាយ គួរឱ្យបួស; សូម្បីគេ(មិនផ្លាស់ភេទ)កើត

សេចក្តីសង្វេគថា “យើងអាស្រ័យព្រះសាសនា ទើបរក្សាជីវិតទុកបានណ្ហើយចុះ ឥឡូវនេះ យើងនឹងបួស” ដូច្នេះ មកដោយភេទនោះឯង, តែមិនត្រេកអរអាគន្តុកវត្ត ដែលភិក្ខុទាំងឡាយសួរហើយក៏ដោយ មិនសួរក៏ដោយ បានសម្តែងប្រាប់នូវខ្លួនតាមសេចក្តីពិតហើយ សូមបព្វជ្ជា; ភិក្ខុទាំងឡាយគប្បីឱ្យផ្លាស់ភេទហើយ សឹមបំបួស ។ តែបើថា គេត្រេកអរវត្ត សម្តែងអាកប្បកិរិយាដូចបព្វជិត បដិបត្តិវិធីផ្សេង ៗ មានរាប់វស្សាជាដើម ដែលពោលហើយខាងដើម ទាំងអស់; បុគ្គលនេះមិនគួរបំបួស ។

មួយទៀត បុគ្គលខ្លះក្នុងលោកនេះ មិនអាចនឹងរស់នៅបានក្នុងកាលទុព្ភិក្ខភ័យ ទើបកាន់យកភេទដោយខ្លួនឯង បរិភោគអាហារដែលគេចាត់ទុក ដើម្បីអ្នកបួសអ្នកមេលទ្ធិទាំងពួង គ្រាទុព្ភិក្ខភ័យកន្លងផុតទៅហើយ មិនទាន់បានចូលកាន់កណ្តាលសង្ឃ បន្ទាប់ពីកាន់ភេទគ្រហស្ថហើយ ទើបមក; ពាក្យពោលដូច្នេះទាំងអស់ ដូចនឹងពាក្យដែលពោលមកមុននុ៎ះឯង ។

ម្នាក់ទៀត ជាអ្នកប្រាថ្នានឹងឆ្លងកន្តារធំ និងឈ្មួញរទេះ រមែងនាំបព្វជិតទាំងឡាយទៅ ។ គេគិតថា ដោយឧបាយយ៉ាងនេះ ឈ្មួញរទេះនឹងនាំយើងទៅ ទើបកាន់យកភេទដោយខ្លួនឯង រួមនឹងឈ្មួញរទេះឆ្លងមកកន្តារ ដល់តំបន់ជាទីក្សេមក្សាន្ត តែមិនទាន់បានចូលកាន់កណ្តាលសង្ឃ

បន្ទាប់ពីកាន់ភេទគ្រហស្ថហើយ ទើបមក; ពាក្យពោលដូច្នេះទាំងពួង ដូចនឹងពាក្យដែលពោលមកមុនន៎ុះឯង ។

ម្នាក់ទៀត កាលភ័យ គឺ រោគកើតឡើង មិនអាចនឹងរស់នៅបាន ទើបកាន់យកភេទដោយខ្លួនឯង បរិភោគអាហារដែលគេចាត់ទុកដើម្បីអ្នកបួស អ្នកមេលទ្ធិទាំងពួង ។ កាលភ័យគឺ រោគស្ងប់ហើយ មិនទាន់បានចូលកាន់កណ្តាលសង្ឃជាមុនទេ តែកាលកាន់ភេទគ្រហស្ថហើយ ទើបមក ពាក្យពោលដូច្នេះទាំងអស់ ដូចគ្នានឹងពាក្យដែលពោលមកមុនន៎ុះឯង ។

បុគ្គលគួពៀរវេរាម្នាក់របស់បុរសម្នាក់ទៀត ជាអ្នកក្រោធប៉ងនឹងសម្លាប់គេត្រាច់ទៅ, គេគិតថា ដោយឧបាយយ៉ាងនេះ សេចក្តីសួស្តីនឹងមានដល់យើង ទើបកាន់យកភេទដោយខ្លួនឯង ហើយគេចចេញទៅ អ្នកជាគូពៀរវេរា តាមដានរកឱ្យដឹងថា គេទៅណា បានឮថា គេបួសហើយ គេចចេញទៅ ទើបបន្ទោបង់សេចក្តីក្រោធចំពោះគេចេញ ដោយគិតថា "គេបួសហើយ យើងក៏ធ្វើអ្វីគេមិនបាន" គេមិនទាន់បានចូលកាន់ជំនុំសង្ឃទេ កាន់ភេទគ្រហស្ថហើយ ទើបមកដោយគិតថា វេរីភ័យរបស់យើងស្ងប់ហើយ ពាក្យពោលដូច្នេះទាំងអស់ ដូចនឹងពាក្យដែលពោលមកមុនន៎ុះឯង ។

ម្នាក់ទៀតទៅកាន់ត្រកូលញាតិ លាសិក្ខាជាគ្រហស្ថហើយ បានធ្វើ

ក្នុងចិត្តថា "ចីវរទាំងនេះនឹងវិនាសក្នុងទីនេះ; បើថា យើងកាន់ទៅវិហារ ដោយភេទគ្រហស្ថនេះ ក្នុងចន្លោះមក ជនទាំងឡាយ នឹងចាប់យើងថា ជាចោរ បើដូច្នោះ យើងគប្បីធ្វើឱ្យជារបស់ដែលកាយគប្បីរក្សាទុក សិនសឹមទៅ" ដូច្នេះ ដើម្បីនាំចីវរមក ទើបស្លៀកនិងដណ្ដប់ហើយទៅ កាន់វត្ត ពួកសាមណេរ និង ភិក្ខុកំលោះទាំងឡាយ ឃើញលោកមកពី ឆ្ងាយហើយ នាំគ្នាចូលទៅទទួលសម្ដែងវត្ត ។ លោកមិនត្រេកអរប្រាប់ នូវសភាពនៃខ្លួនតាមការពិត ។ បើភិក្ខុទាំងឡាយពោលថា "ពេលនេះ ពួកយើងនឹងមិនបញ្ជូន លោកទៅទេ" ជាអ្នកប្រាជ្ញនឹងបំបួសដោយ ពលការ លោកដែលភិក្ខុទាំងឡាយ គប្បីដោះសំពត់កាសាយៈហើយ សឹមបំបួសទៀតចុះ ។ តែបើលោកគិតថា "ភិក្ខុទាំងនេះ មិនដឹងយើង ដែលត្រឡប់មកដើម្បីភាពជាហីនភេទឡើយ" ដូច្នេះ ទើបមានបដិញ្ញាភាព ជាភិក្ខុនោះឯង បដិបត្តិវិធីផ្សេងដោយរាប់វស្សាជាដើម តាមដែលពោល ហើយក្នុងកាលមុនទាំងអស់ អ្នកនេះ មិនគួរបំបួស ។

សាមណេរមាឌធំ មួយរូបទៀត ទៅកាន់ត្រកូលញាតិ សឹកហើយ ជាអ្នកនឿយណាយដោយការធ្វើការងារ ទើបគិតថា "ឥឡូវនេះ យើង នឹងជាសមណៈ ទៀតនោះឯង សូម្បីព្រះថេរៈ រមែងមិនជ្រាបនូវយើង ដែលសឹកហើយ" ទើបកាន់យកបាត្រនិងចីវរនោះឯង ទៅវិហារ មិន ប្រាប់សេចក្ដីនោះដល់ភិក្ខុទាំងឡាយ ប្ដេជ្ញាភាពជាសាមណេរ ។ អ្នកនេះ

ជាថេយ្យសំវាសដូចគ្នា រមែងមិនបានបួស ។

បើសូម្បីក្នុងវេលាកាន់ភេទ គេមានសេចក្ដីរំពឹងយ៉ាងនេះថា យើងនឹងមិនប្រាប់ដល់អ្នកណា ៗ ដូច្នេះ តែគេទៅវិហារហើយ រមែងប្រាប់ ។ ដោយការកាន់ (ភេទ) នុ៎ះឯង គេជាបុគ្គលថេយ្យសំវាស ។

បើក្នុងវេលាកាន់ (ភេទ) គេមានសេចក្ដីគិតកើតឡើងថា "យើងនឹងប្រាប់" តែទៅវិហារហើយ អ្នកណា ៗ ប្រាស្រ័យថា អ្នកមានអាយុលោកទៅណាមកណា គិតថា "ឥឡូវនេះ ជនទាំងនេះមិនដឹងយើង" ទើបបញ្ឆោត មិនប្រាប់; សូម្បីអ្នកនេះ ក៏ឈ្មោះថា បុគ្គលថេយ្យសំវាសពិត ព្រមទាំងដាក់ធុរៈថា "យើង នឹងមិនប្រាប់" ។ តែបើក្នុងវេលាកាន់ (ភេទ) គេមានសេចក្ដីគិតកើតឡើងថា "យើងនឹងប្រាប់" ទៅវិហារហើយក៏ប្រាប់; អ្នកនេះ រមែងបានបព្វជ្ជាទៀត ។

ក៏ឬថា សាមណេរកំលោះដទៃទៀត ជាមនុស្សធំ តែល្ងង់មិនឆ្លាតលោកសឹកហើយដោយន័យមុននុ៎ះឯង មិនចង់ធ្វើកិច្ចមានមើលគោជាដើមក្នុងផ្ទះញាតិទាំងឡាយឱ្យគេនោះ ស្លៀកដណ្ដប់សំពត់កាសាយៈទាំងនោះឯង ហើយឱ្យភាជនៈឬបាត្រក្នុងដៃ ដេញចេញចាកពីផ្ទះថា អ្នកនេះសឹកហើយបួសដោយខ្លួនឯងទៀត ទាំងខ្លួនឯងក៏មិនជ្រាបថា "អ្នកណាបួសយ៉ាងនោះ អ្នកនោះ រមែងជាអ្នកដែលឈ្មោះថា ថេយ្យសំវាស" ។

បើភិក្ខុទាំងឡាយ ឱ្យឧបសម្បទាគេដែលមានវស្សាគ្រប់ ២០ គេ

ក៏ជាការឧបសម្បទាល្អហើយ ។ តែបើក្នុងវេលាដែលខ្លួន នៅជាអនុបសម្បន្ននុ៎ះឯង កាលការវិនិច្ឆ័យវិន័យប្រព្រឹត្តទៅ គេបានស្តាប់ថា អ្នកណាបួសយ៉ាងនោះ អ្នកនោះ រមែងជាអ្នកដែលឈ្មោះថាថេយ្យសំវាស គេគប្បីប្រាប់ដល់ភិក្ខុទាំងឡាយថា "ខ្ញុំឥព្រះករុណាបានធ្វើយ៉ាងនោះ" ដោយប្រការយ៉ាងនេះ គេរមែងបានបព្វជ្ជាទៀត ។ បើមិនប្រាប់ដោយគិតថា "ឥឡូវនេះ អ្នកណា ៗ មិនដឹងឡើយ" ល្មមដាក់ធុរៈ គេរមែងជាបុគ្គលថេយ្យសំវាស ។

ភិក្ខុលាសិក្ខា លះបង់ភេទហើយ ធ្វើកម្មគឺការទ្រុស្តសីលក្តី មិនធ្វើក្តី បដិបត្តិវិធីមានការរាប់វស្សាជាដើម ដែលពោលហើយក្នុងកាលមុនទាំងអស់; រមែងជាបុគ្គលថេយ្យសំវាស ។

មិនបានលាសិក្ខា តាំងនៅក្នុងភេទរបស់ខ្លួន សេពមេថុន ប្រើវិធីផ្សេងដោយរាប់វស្សាជាដើម មិនជាបុគ្គលថេយ្យសំវាស ។ រមែងបានត្រឹមតែបព្វជ្ជា ។ តែក្នុងអន្ធកដ្ឋកថាពោលថា អ្នកនេះ ជាបុគ្គលថេយ្យសំវាស ពាក្យនោះ មិនគួរកាន់យក ។

ភិក្ខុមួយរូប នៅមានឧស្សាហៈក្នុងសំពត់កាសាយៈ ស្លៀកសំពត់សសេពមេថុន ហើយត្រឡប់ស្លៀកសំពត់កាសាយៈទៀត ប្រើវិធីទាំងពួងផ្សេងដោយរាប់វស្សាជាដើម សូម្បីភិក្ខុនេះ រមែងមិនជាបុគ្គលថេយ្យសំវាស រមែងបានត្រឹមតែបព្វជ្ជា ។

តែបើដាក់ធុរៈក្នុងសំពត់កាសាយៈហើយ ស្លៀកសសេពមេថុន ត្រឡប់ស្លៀកសំពត់កាសាយៈទៀត ប្រើវិធីទាំងពួងមានការរាប់វស្សាជាដើម; គេរមែងជាអ្នកថេយ្យសំវាស ។

សាមណេរតាំងនៅក្នុងភេទរបស់ខ្លួន សូម្បីកន្លងធម៌ ធ្វើឱ្យជាបុគ្គលមិនមែនសមណៈ មានមេថុនជាដើមហើយ រមែងមិនជាបុគ្គលថេយ្យសំវាស សូម្បីបើថា នៅមានឧស្សាហ៍ក្នុងសំពត់កាសាយៈ តែដោះចេញសេពមេថុនហើយ ត្រឡប់ស្លៀកសំពត់កាសាយៈទៀត; មិនជាបុគ្គលថេយ្យសំវាសដូចគ្នា, តែបើដាក់ធុរៈក្នុងសំពត់កាសាយៈហើយ ជាអ្នកអាក្រាត ឬស្លៀកសជាអ្នកមិនមែនសមណៈ ដោយការសេពមេថុនជាដើម ហើយត្រឡប់ស្លៀកសំពត់កាសាយៈ គេជាបុគ្គលថេយ្យសំវាស ។

បើសាមណេរប្រាថ្នាភាពជាគ្រហស្ថ ទើបស្លៀកសំពត់ដូចគ្រហស្ថ ធ្វើសំពត់កាសាយៈចងក្បែនក្ដី ដោយអាការយ៉ាងដទៃក្ដី ដើម្បីសាកល្បងមើលថា ភេទគ្រហស្ថរបស់យើងស្អាត ឬមិនស្អាត នៅរក្សាទុកសិន, តែព្រមទទួលថា ស្អាតហើយត្រឡប់ត្រេកអរភេទទៀត រមែងជាបុគ្គលថេយ្យសំវាស ។ សូម្បីក្នុងការស្លៀកសំពត់សសាកល្បងមើល និងព្រមទទួល ក៏មានន័យ ដូចគ្នានុ៎ះឯង ។ បើស្លៀកសំពត់ស ខាងក្រៅសំពត់កាសាយៈស្លៀកហើយ សាកល្បងក៏ដោយ ព្រមទទួលក៏ដោយ

នៅរក្សាពិត ។ សូម្បីភិក្ខុនី ក៏ន័យនេះឯង ។

សូម្បីនាងភិក្ខុនីនោះ ប្រាថ្នាជាគ្រហស្ថ បើស្លៀកសំពត់កាសាយៈ ដូចជាគ្រហស្ថ ដើម្បីសាកល្បងមើលថា "ភេទគ្រហស្ថរបស់យើងនឹងស្អាតឬមិនស្អាត" នៅរក្សាទុកសិន, បើព្រមទទួលថា "ស្អាត" មិនអាចរក្សាទុកបាន ។ ក្នុងការស្លៀកសំពត់សសាកល្បងមើល និងព្រមទទួល ក៏ន័យនេះឯង ។

ចំណែកអ្នកស្លៀក សំពត់សខាងក្រៅ សំពត់កាសាយៈដែលខ្លួនស្លៀកហើយ នឹងសាកល្បងមើលក៏ដោយព្រមទទួលក៏ដោយ នៅរក្សាពិត ។ បើសាមណេររូបខ្លះបួសក្នុងវ័យចាស់ មិនរាប់វស្សា មិនឈរនៅសូម្បីក្នុងជួរមកមកម្ខាង កាលដុំបាយក្នុងភាជន៍ធំជាដើម ដែលគេយកវែកដួសឡើង ហុចបាត្រចូលទៅទទួលយកទៅ ដូចសត្វខ្លែងឆាបយកដុំសាច់ទៅ ដូច្នោះ មិនទាន់ជាបុគ្គលថេយ្យសំវាស ។ តែកាលរាប់វស្សាភិក្ខុទទួលយក ចាត់ថា ជាបុគ្គលថេយ្យសំវាស ។

សាមណេរនោះឯង កាលរាប់វស្សាកោង ដោយលំដាប់របស់សាមណេរទទួលយកទៅ មិនជាថេយ្យសំវាស ។

ភិក្ខុកាលរាប់វស្សាកោង ដោយលំដាប់របស់ភិក្ខុទទួលយកទៅ គប្បីពិន័យតាមតម្លៃនៃភណ្ឌៈ ។

មនុស្សលួចសំវាស ចប់

# មនុស្សចូលពួកតិត្ថិយ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា តិត្ថិយបក្កន្តោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាអ្នកចូលតិរ្ថិយ ជាដើមនេះដូច្នេះ ៖

កុលបុត្រដែលឈ្មោះថា ចូលតិរ្ថិយ ព្រោះអត្ថវិគ្រោះថា ជៀសចេញទៅ គឺទៅចូលពួកតិរ្ថិយ ។ កុលបុត្រនោះ មិនគួរឱ្យឧបសម្បទាតែម្យ៉ាង ក៏ទេ, តែតាមការពិត មិនគួរឱ្យទាំងបព្វជ្ជាផងដោយប្រការយ៉ាងនេះឯង ។

វិនិច្ឆ័យក្នុងពាក្យនោះ គប្បីជ្រាបដូចតទៅនេះ ៖

ឧបសម្បន្នភិក្ខុគិតថា យើងនឹងជាតិរ្ថិយ ហើយទៅកាន់សំណាក់នៃតិរ្ថិយទាំងនោះ ទាំងភេទតែម្តង ជាអាបត្តិទុក្កដគ្រប់ ៗ ជំហាន, កាលភេទនៃតិរ្ថិយនោះ ត្រឹមតែថា ដែលខ្លួនកាន់យកហើយ រមែងចាត់ថា ជាអ្នកចូលតិរ្ថិយ ។

សូម្បីភិក្ខុណា គិតថា "យើងនឹងជាតិរ្ថិយដោយខ្លួនឯង" ទើបស្លៀកសំពត់ស្បូវភ្លាំងជាដើម ភិក្ខុនោះ ឈ្មោះថា ជាអ្នកចូលតិរ្ថិយដូចគ្នា ។

ចំណែកភិក្ខុណា កាលអាក្រាតកាយងូតទឹកក្រលេកមើលខ្លួនថា "ការដែលយើងជាអាជីវកនឹងល្អឬ យើងនឹងជាអាជីវកចុះ" ដូច្នេះហើយ

មិនកាន់យកសំពត់កាសាយៈ ទៅកាន់សំណាក់ពួកអាជីវកទាំងអាក្រាតកាយ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ ជំហាន ។ តែបើក្នុងចន្លោះមក ហិរិឱត្តប្បៈកើតឡើងដល់លោក លោកសម្ដែងអាបត្តិទុក្កដហើយ រមែងផុត ។

សូម្បីទៅដល់សំណាក់ពួកអាជីវកទាំងនោះហើយ ត្រូវពួកអាជីវកទូន្មាន ឬសូម្បីឃើញថា "បព្វជ្ជារបស់ជនទាំងនេះ ជាទុក្ខក្រៃលែងណាស់" ហើយត្រឡប់ ដោយខ្លួនឯង រមែងផុតបានដូចគ្នា ។ មួយទៀត បើលោកសួរថា "អំពើអ្វី ជាអំពើប្រសើរខ្ពង់ខ្ពស់នៃបព្វជ្ជារបស់ពួកលោក ?" គេឆ្លើយថា "ការដកសក់ និងពុកមាត់" ជាដើម ហើយឱ្យដកសូម្បីសក់តែមួយសរសៃ កាន់វត្តមានសេចក្ដីព្យាយាមដោយការប្រហោងដើងជាដើមក្ដី ស្លៀកសំពត់កន្ទុយក្ងោកជាដើមក្ដី ឈ្មោះថា កាន់ភេទនៃអាជីវកទាំងអស់ ឈ្មោះថា ព្រមទទួលភាពជាលទ្ធិប្រសើរថា បព្វជ្ជានេះប្រសើរ លោករមែងមិនផុត ចាត់ថា **ជាអ្នកចូលតិរ្ថិយ** ។

មួយទៀត បើលោកសាកល្បងមើលថា "ការបួសជាតិរ្ថិយសម្រាប់យើងទាំងនឹងល្អ ឬមិនល្អ" ទើបស្លៀកសំពត់ស្បូវក្ដាំងជាដើម ឬថាចងជដា ឬថា ចាប់យកអម្រែកបរិក្ខារ មិនទាន់ព្រមទទួលត្រឹមណា លទ្ធិរមែងរក្សាលោកទុកត្រឹមនោះ, កាលភេទត្រឹមតែថា លោកព្រមទទួលហើយ រមែងចាត់ថា ជាអ្នកចូលតិរ្ថិយ ។

ចំណែកភិក្ខុដែលចោរដណ្តើមយកចីវរទៅ ទើបស្លៀកសំពត់ស្បូវ ភ្លាំងជាដើមក្តី កាន់ភេទតិរ្ថិយ ព្រោះភ័យមានរាជភ័យជាដើមក្តី មិនចាត់ថា ជាអ្នកចូលតិរ្ថិយឡើយ ព្រោះមិនមានលទ្ធិ ។

តែក្នុងអដ្ឋកថាកុរុន្ទីពោលថា ដែលឈ្មោះថា បុគ្គលអ្នកចូលតិរ្ថិយនេះ លោកពោលអំពីឧបសម្បន្នភិក្ខុ ។ ព្រោះហេតុនោះ សាមណេរស្មូគ្រីទៅកាន់តិត្ថាយតនៈ ហើយព្រមទាំងភេទ រមែងបានបព្វជ្ជា និងឧបសម្បទាទៀត ។

ចំណែកបុគ្គលថេយ្យសំវាសខាងដើម លោកពោលអំពីអនុបសម្បន្ន ព្រោះហេតុនោះ ឧបសម្បន្ន ស្មូគ្រីរាប់វស្សាកោង ទឹងចាត់ថា ជាអ្នកមិនមែនសមណៈ ក៏ទេ ភិក្ខុនៅមានឧស្សាហ៍ក្នុងភេទស្មូគ្រីត្រូវបារាជិកហើយ រាប់វស្សានៃភិក្ខុជាដើម ក៏មិនទាន់ចាត់ថា ជាបុគ្គលថេយ្យសំវាស ។

មនុស្សចូលពួកតិត្ថិយ ចប់

# រឿងនាគ

[១២៧] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **នាគយោនិយា អដ្ដិយតិ : នឿយណាយក្នុងកំណើតរបស់នាគ** នេះ ដូច្នេះ ៖

នាគនោះ ក្នុងបវត្តិកាលតែងបានសោយឥស្សរិយសម្បត្តិ ដូចទេវសម្បត្តិដោយកុសលវិបាកក៏ពិតហើយ តែថា សរីរៈនៃនាគដែលបដិសន្ធិដោយអកុសលវិបាក មានប្រក្រតីត្រាច់ទៅក្នុងទឹក មានកង្កែបជាអាហារ រមែងមានប្រាកដ ដោយការសេពមេថុនទឹងនាងនាគជាតិរបស់ខ្លួន គឺ មានជាតិស្មើគ្នា និងដោយការដេកលក់ ព្រោះហេតុនោះ នាគនោះ ទើបធុញទ្រាន់ចំពោះកំណើតនាគនោះ ។

បទថា **ហរាយតិ : ខ្ពើម** បានដល់ រមែងខ្មាស ។

បទថា **ជិគុច្ឆតិ : រអើម** គឺ រមែងស្អប់ខ្ពើមអត្តភាព ។

ប្រើនបទថា **តស្ស ភិក្ខុនោ និក្ខន្តេ : កាលដែលភិក្ខុនោះចេញទៅហើយ** មានសេចក្ដីថា កាលភិក្ខុនោះចេញទៅហើយ ។ ម្យ៉ាងទៀត សេចក្ដីថា ក្នុងវេលាដែលភិក្ខុនោះចេញទៅ ។

ពាក្យថា **វិស្សដ្ឋោ និទ្ទំ ឱក្កមិ : នាគនោះក៏ដេកលក់ស្និទ្ធទៅ** មានសេចក្ដីថា កាលភិក្ខុនោះ មិនទាន់ចេញ នាគនោះ មិនលះបង់សតិ

ឱ្យលង់លក់ ដោយអំណាចនៃការលក់ដូចជាស្វាន់ះឯង ព្រោះខ្លាចនូវសំឡេងស្រែកគ្រាភិក្ខុនោះចេញទៅហើយ ទើបលះបង់សតិដាក់ចិត្ត គឺអស់សេចក្ដីរង្កៀស ដំណើរទៅកាន់សេចក្ដីលង់លក់យ៉ាងពេញទី ។

ពីរបទថា **វិស្សរមកាសិ : ហើយធ្វើសំឡេងដ៏ប្លែក** មានសេចក្ដីថា ភិក្ខុនោះ ដោយអំណាចការខ្លាច លះសមណសញ្ញាចេញបានធ្វើសំឡេងខ្លាំងហួស ។

ពីរបទថា តុម្ហេ ខ្វត្ថ កាត់បទថា តុម្ហេ ខោ អត្ថ បទ នោះលោកមិនបានធ្វើការលុប អ អក្សរពោលទុក ។ សេចក្ដីសង្ខេបក្នុងពាក្យនេះ អ្នកសិក្សាគប្បីជ្រាបដូច្នេះថា លោកទាំងឡាយនោះឯង ជានាគ ឈ្មោះថា ជាអ្នកមានធម៌មិនរីកចម្រើន គឺ មិនជាអ្នកមានធម៌ដែលរីកចម្រើនក្នុងធម្មវិន័យនេះ ព្រោះជាអ្នកមិនគួរដល់ឈានវិបស្សនា និងមគ្គផល ។

បទថា **សជាតិយា : មានជាតិស្មើគ្នា** បានដល់ នាងនាគន៉ុះឯង ។ ប៉ុន្តែថា កាលណានាគនោះ សេពមេថុនជាមួយភេទ មានមនុស្សស្រីជាដើម កាលនោះ រមែងប្រាកដដូចជាទេវបុត្រ ។ ចំណែកពាក្យថា បច្ច័យ ២ យ៉ាងក្នុងព្រះបាលីនេះ ព្រះមានព្រះភាគត្រាស់ហើយ

ដោយការបង្ហាញកម្មដែលប្រាកដតាមសភាពរឿយ ៗ ក្នុងបវត្តិកាល ។ និងកម្មដែលប្រាកដតាមសភាព រមែងមានដល់នាគក្នុង៥ កាល គឺ វេលាបដិសន្ធិ១ វេលាសកសំណក១ វេលាសេពមេថុនជាមួយនាងនាគជាតិរបស់ខ្លួន គឺ មានជាតិស្មើគ្នា១ វេលាដេកលក់១ វេលាចុតិ ១ ។

ក្នុងពាក្យថា **តិរច្ឆានគតោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆាន** ជាដើមនេះ មានវិនិច្ឆ័យថា ទោះជានាគ ឬទោះជាសត្វពិសេសណាមួយ មានសុបណ្ណមាណពជាដើមក៏ដោយ ។ អ្នកណាមួយដែលមិនមែនមនុស្សជាតិ ដោយហោចទៅ សូម្បីស្តេចសក្កទេវរាជបណ្តាមានទាំងអស់នោះឯង គប្បីជ្រាបថា ជាតិរច្ឆាន ក្នុងអត្ថនេះ អ្នកនោះ ដែលភិក្ខុទាំងឡាយ មិនគួរឱ្យឧបសម្បទា មិនគួរឱ្យបព្វជ្ជា សូម្បី (បព្វជ្ជា )ឧបសម្បទាហើយ ក៏គួរឱ្យវិនាសចេញ ។

រឿងនាគ ចប់

## បុគ្គលដែលសង្ឃមិនត្រូវឱ្យឧបសម្បទា ៥២ ចំពូក

## មនុស្សសម្លាប់មាតាបិតា

[១២៨] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងបុគ្គលអ្នកសម្លាប់មាតាជាដើមតទៅ ៖

ពីរបទថា និក្ខន្តិ ករេយ្យំ : អញនឹងជីកវំលើងចោលចេញ មានសេចក្ដីថា យើងគប្បីធ្វើកិរិយាចេញ គឺការជៀសចេញទៅ ការជម្រះដោះស្រាយបញ្ហា ។

ក្នុងពាក្យថា មាតុឃាតកោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលសម្លាប់មាតា នេះ មានវិនិច្ឆ័យថា មាតាបង្កើត ជាមនុស្សស្រី ដែលបុគ្គលណា សូម្បីខ្លួនឯង ក៏ជាជាតិមនុស្សដូចគ្នា ក្លែងផ្ដាច់ជីវិត បុគ្គលនេះជាអ្នកសម្លាប់មាតា ដោយអនន្តរិយមាតុឃាតកម្ម ។ បព្វជ្ជា និងឧបសម្បទានៃបុគ្គលនោះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហាមហើយ ។

ចំណែកមាតាដែលចិញ្ចឹមថែទាំក្ដី ម្ដាយធំក្ដី ម្ដាយមីងក្ដី ដែលមិនមែនអ្នកឱ្យកំណើត សូម្បីជាមនុស្សស្រី ឬមាតាបង្កើតដែរ តែមិនមែនមនុស្សស្រី ដែលបុគ្គលណាសម្លាប់ហើយ បព្វជ្ជារបស់បុគ្គលនោះ ព្រះ

មានព្រះភាគទ្រង់មិនហាម និងគេមិនជាអ្នកមានអនន្តរិយកម្ម ។

ខ្លួនឯងជាសត្វតិរច្ឆាន សម្លាប់មាតាជាមនុស្សស្រីហើយ សូម្បីអ្នកនោះ មិនជាអនន្តរិយកម្ម ។ ចំណែកបព្វជ្ជារបស់គេជាការដែលទ្រង់ហាមដែរ ព្រោះគេជាសត្វតិរច្ឆាន ។ ពាក្យដ៏សេសជាពាក្យងាយយល់ទាំងអស់ ។ សូម្បីក្នុងបុគ្គលដែលសម្លាប់បិតា ក៏ន័យនេះឯង ។

បើសូម្បីបុរសជាកូនស្រីពេស្យា មិនជ្រាបថា អ្នកនេះជាបិតារបស់យើង គេកើតដោយទឹកសម្ភពរបស់ប្រុសណា គេសម្លាប់ប្រុសនោះហើយ រមែងដល់ការរាប់ថា ជាអ្នកសម្លាប់បិតាផង រមែងត្រូវអនន្តរិយកម្មផង ។ សូម្បីបុគ្គលសម្លាប់ព្រះអរហន្ត គប្បីជ្រាបដោយអំណាចព្រះអរហន្តជាមនុស្សដូចគ្នា ។

វិនិច្ឆ័យក្នុងអរហន្តឃាតកវត្ថុនេះ គប្បីជ្រាបដូច្នេះថា ដែលបុគ្គលកាលក្លែងផ្តាច់ជីវិតព្រះខីណាស្រពជាជាតិមនុស្ស ដោយហោចទៅ សូម្បីមិនមែនបព្វជិត ជាទារកក៏ដោយ ជាទារិកាក៏ដោយ, រមែងជាអ្នកឈ្មោះថា ព្រះអរហន្តពិត; រមែងត្រូវអនន្តរិយកម្មផង និងបព្វជ្ជារបស់អ្នកនោះដែលព្រះមានព្រះភាគទ្រង់ហាមផង ។ ចំណែកបុគ្គលសម្លាប់ព្រះអរហន្តដែលមិនមែនជាតិមនុស្ស ឬព្រះអរិយបុគ្គលដ៏សេស សូម្បីជាជាតិមនុស្សមិនទាន់ជាអនន្តរិយកម្ម សូម្បីបព្វជ្ជារបស់គេ ក៏ទ្រង់មិនហាម ។ ប៉ុន្តែថា កម្មជារបស់ខ្លាំងក្លា ។ តិរច្ឆានសូម្បីសម្លាប់ព្រះអរហន្ត ដែលជាជាតិ

មនុស្ស ក៏មិនជាអ្នកមានអនន្តរិយកម្ម ប៉ុន្តែថា ជាកម្មដ៏ធ្ងន់ ។

## មនុស្សដែលសម្លាប់ព្រះអរហន្ត

[១៣០] ច្រើនបទថា គេ វធាយ ឱនីយន្តិ : គេក៏នាំទៅដើម្បីនឹងសម្លាប់ មានសេចក្ដីថា ចោរទាំងនោះដែលពួករាជបុរស រមែងនាំទៅ ដើម្បីប្រយោជន៍ដល់ការសម្លាប់ ។ អធិប្បាយថា នាំទៅដើម្បីប្រហារជីវិត ។

ក៏ពាក្យណា ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលទុកក្នុងបាលីថា សចា ច មយំ សេចក្ដីនៃពាក្យនោះប៉ុណ្ណោះឯងថា សចេ មយំ ។ ពិតមែន ក្នុងព្រះបាលីនេះ លោកពោលនិបាតនេះថា សចេ ច ក៏មាន ។ ក្នុង២ ស័ព្ទនោះ ស័ព្ទថា សចេ ជាសម្ភាវនត្ថនិបាត ។ ស័ព្ទថា ច ជានិបាតប្រើក្នុងអត្ថកំណត់ប្រមាណថា ជាគ្រឿងធ្វើបទឱ្យពេញ ។ បាឋៈថា សចជ្ជ មយំ ខ្វះ សេចក្ដីនៃបាឋៈនោះថា សចេ អជ្ជ មយំ : ប្រសិនណាជាយើងទាំងឡាយ (ត្រូវគេចាប់) ក្នុងថ្ងៃនោះ ។

# មនុស្សដែលប្រទូស្តចំពោះភិក្ខុនី

[១៣១] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា ភិក្ខុនីទូសកោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលទ្រូស្តភិក្ខុនី ជាដើម ដូច្នេះ ៖

បុរសណាប្រទូស្តនាងភិក្ខុនី ដែលមានខ្លួនជាប្រក្រតី ក្នុងបណ្តាមគ្គ ៣ មគ្គណាមួយ បុរសនេះ ឈ្មោះថា ភិក្ខុនីទូសកៈ ។ បព្វជ្ជានិងឧបសម្បទារបស់បុរសនោះ ព្រះមានព្រះភាគទ្រង់ហាមហើយ ។ ចំណែកបុរសណា ញ៉ាំងភិក្ខុនីឱ្យដល់សីលវិបត្តិ ដោយកាយសំសគ្គៈ បព្វជ្ជានិងឧបសម្បទានៃបុរសនោះ ទ្រង់មិនហាម ។ សូម្បីបុរសដែលធ្វើនាងភិក្ខុនីឱ្យស្លៀកសំពត់សហើយ ប្រទូស្តចំពោះនាងដែលមិនយល់ព្រមឡើយតែម្តង ដោយពលការ ឈ្មោះថា ភិក្ខុនីទូសកៈពិត ។

ចំណែកបុរសដែលនាំភិក្ខុនីឱ្យស្លៀកសដោយពលការហើយ ប្រទូស្តនាងដែលយល់ព្រម មិនឈ្មោះថា ភិក្ខុនីទូសកៈ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះនាង( ភិក្ខុនី )នោះ រមែងមិនមែនជាភិក្ខុនី ក្នុង

កាលភាពជាគ្រហស្ថកំណត់ប្រមាណថា ដែលខ្លួនព្រមទទួលតែម្តង ។

ចំណែកបុរសអ្នកប្រទូស្តនាងភិក្ខុនីក្រោយពេលដែលនាងខូចសីលម្តងហើយ និងប្រព្រឹត្តខុសក្នុងសិក្ខមានា និងសាមណេរីទាំងឡាយមិនបាត់ថា ភិក្ខុនីទូសកៈដូចគ្នា; រមែងបានទាំងបព្វជ្ជាទាំងឧបសម្បទា ។

ក្នុងពាក្យថា សង្ឃភេទកោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលបំបែកសង្ឃ ជាដើមនេះ មានវិនិច្ឆ័យថា អ្នកណាធ្វើព្រះសាសនាឱ្យជារបស់ក្រៅធម៌ក្រៅវិន័យ ទម្លាយសង្ឃដោយអំណាចនៃកម្ម ៤ យ៉ាងណាមួយ ដូចភិក្ខុទេវទត្ត, អ្នកនេះ ឈ្មោះថា សង្ឃភេទកៈ អ្នកបំបែកសង្ឃ បព្វជ្ជា និងឧបសម្បទានៃបុគ្គលនោះ ទ្រង់ហាម ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យនេះថា លោហិតុប្បាទកោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលធ្វើលោហិតុប្បាទ ជាដើមដូច្នេះ ៖

អ្នកណាមានចិត្តប្រទូស្តគិតចង់សម្លាប់ ញុំាងព្រះលោហិតក្នុងព្រះសរីរៈដែលនៅរស់របស់ព្រះតថាគត សូម្បីល្មមរុយតូចផឹកបាន ឱ្យពុះពងឡើង ដូចភិក្ខុទេវទត្ត អ្នកនេះ ឈ្មោះថា អ្នកធ្វើលោហិតុប្បាទ ។ បព្វជ្ជានិងឧបសម្បទានៃបុគ្គលនោះ ទ្រង់ហាម ។

ចំណែកអ្នកណា ប្រើកាំបិតវះកាត់យកសាច់ចេញ និងលោហិត

បេញធ្វើឱ្យទ្រង់សប្បាយដូចហ្មជីវក បានធ្វើដើម្បីឱ្យព្រះរោគស្ងប់ទៅ អ្នកនោះ រមែងប្រសព្វបុណ្យច្រើន ដូច្នេះ ។

## មនុស្សឧភតោព្យញ្ជនក

[១៣២] បទថា ឧភតោព្យញ្ជនកោ : មនុស្សមានភេទពីរ មានអត្ថវិគ្រោះថា និមិត្តគ្រឿងប្រាកដដែលតាំងឡើង ដោយកម្ម ២ យ៉ាង គឺ ដោយកម្មជាហេតុញ៉ាំងឥត្ថីនិមិត្តឱ្យកើតឡើង ១ ដោយកម្មជាហេតុញ៉ាំងបុរិសនិមិត្តឱ្យកើតឡើង ១ របស់បុគ្គលនោះមាន ហេតុនោះ អ្នកនោះ ឈ្មោះថា ឧភតោព្យញ្ជនកៈ ។

បទថា ករោតិ : ធ្វើខ្លួនឯង មានសេចក្តីថា រមែងធ្វើខ្លួនឯងឱ្យប្រព្រឹត្តល្មើសដោយអំណាចមេថុនក្នុងស្ត្រីទាំងឡាយ ដោយបុរិសនិមិត្ត(របស់ខ្លួន) ។

បទថា ការាបេតិ : ប្រើគេឱ្យធ្វើនឹងខ្លួន មានសេចក្តីថា រមែងបបួលបុរសដទៃឱ្យធ្វើសេចក្តីល្មើស ដោយអំណាចមេថុន ក្នុងឥត្ថីនិមិត្តរបស់ខ្លួន ។

ឧភតោព្យញ្ជនកៈនោះ មាន ២ ប្រភេទ គឺ ស្ត្រីឧភតោព្យញ្ជនកៈ ១ ។ បុរសឧភតោព្យញ្ជនកៈ ១ ។

ក្នុង២ ប្រភេទនោះ ឥត្ថីនិមិត្តរបស់ស្ត្រីឧភតោព្យញ្ជនកៈប្រាកដ

បុរិសនិមិត្តជារបស់បិទបាំង; បុរិសនិមិត្តរបស់បុរសឧភតោព្យញ្ជនកៈ ប្រាកដ ឥត្ថីនិមិត្តជារបស់បិទបាំង ។ កាលស្រីឧភតោព្យញ្ជនកៈ ធ្វើនាទីរបស់បុរសក្នុងស្ត្រីទាំងឡាយ ឥត្ថីនិមិត្ត រមែងជារបស់បិទបាំង, បុរិសនិមិត្តប្រាកដ; កាលបុរសឧភតោព្យញ្ជនកៈចូលដល់ភាពជាស្ត្រីសម្រាប់ពួកបុរស បុរិសនិមិត្ត ជារបស់បិទបាំង, ឥត្ថីនិមិត្តប្រាកដ ។

ហេតុដែលធ្វើឱ្យផ្សេងគ្នានៃឧភតោព្យញ្ជនកៈ ២ ប្រភេទនោះ ដូច្នេះ គឺ ស្ត្រីឧភតោព្យញ្ជនកៈ មានគភ៌ដោយខ្លួនឯងផង, ឱ្យស្ត្រីដទៃមានគភ៌បានផង; ចំណែកបុរសឧភតោព្យញ្ជនកៈ ខ្លួនឯង មិនមានគភ៌ តែឱ្យស្ត្រីដទៃមានគភ៌បាន ។

តែក្នុងអដ្ឋកថាកុរុន្ទីលោកពន្យល់ថា បើភេទប្រុសកើតក្នុងកំណើត គឺ បដិសន្ធិកាល ភេទស្រីរមែងកើតតែកាលមានតម្រេកដែលប្រព្រឹត្តទៅក្នុងបុរស[១] បើភេទស្រីកើតក្នុងកំណើត គឺ បដិសន្ធិកាល ភេទប្រុសរមែងកើតតែកាលមានតម្រេកក្នុងស្ត្រីប្រព្រឹត្តទៅ[២] ។

លំដាប់នៃពិចារណាក្នុងការកើតឡើងនៃភេទ ២ នោះ បណ្ឌិតគប្បីជ្រាបពិស្តារក្នុងអដ្ឋកថាធម្មសង្គណី ឈ្មោះអដ្ឋសាលិនី[៣] ។

ចំណែកក្នុងបព្វជ្ជាធិការនេះ គប្បីជ្រាបសន្និដ្ឋានសូម្បីនេះថា បព្វជ្ជាឧបសម្បទានៃឧភតោព្យញ្ជនកៈទាំង ២ ប្រភេទនេះ មិនមានឡើយ ។

១-២. បវត្តេ គួរទើងសំដៅសេចក្តីថា ក្នុងបវត្តិកាល ។
៣. អដ្ឋសាលិនី. ៤៦៧-៤៧០ ។

# សាមណេរដែលគ្មានឧបជ្ឈាយ៍ជាដើម

[១៣៣] ប្រើនបទថា តេន ខោ បន សមយេន : សម័យនោះឯង មានសេចក្តីថា សម័យណា សិក្ខាបទដែលព្រះមានព្រះភាគមិនទាន់ទ្រង់បានបញ្ញត្តហើយ សម័យនោះ ។

បទថា អនុបជ្ឈាយកំ : សាមណេរដែលគ្មានឧបជ្ឈាយ៍ មានសេចក្តីថា វៀរចាកឧបជ្ឈាយ៍ គ្រប់ ៗ យ៉ាង ព្រោះមិនឱ្យកាន់ឧបជ្ឈាយ៍ ។

កុលបុត្រទាំងឡាយ ដែលឧបសម្បទាហើយយ៉ាងនោះ រមែងមិនបានសេចក្តីសង្គ្រោះដោយធម៌ ដោយអាមិស គេរមែងសាបសូន្យប៉ុណ្ណោះ រមែងមិនចម្រើន ។

ប្រើនបទថា ន ភិក្ខវេ អនុបជ្ឈាយកោ : ម្នាលភិក្ខុទាំងឡាយ សាមណេរដែលគ្មានឧបជ្ឈាយ៍ ភិក្ខុមិន... ជាដើម មានសេចក្តីថា កុលបុត្រឈ្មោះថា អ្នកមិនមានឧបជ្ឈាយ៍ ព្រោះមិនឱ្យកាន់ឧបជ្ឈាយ៍ មិនគប្បីឱ្យឧបសម្បទា ។ ជាអាបត្តិដល់ភិក្ខុដែលឱ្យឧបសម្បទាដោយអាការយ៉ាងនោះ ចាប់ផ្តើមតាំងពីទ្រង់បញ្ញត្តសិក្ខាបទថា "យោ ឧបសម្បាទេយ្យ អាបត្តិ ទុក្កដស្ស : ភិក្ខុណាឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ" ។

ចំណែកកម្មមិនកម្រើកទេ ។ អាចារ្យពួកខ្លះពោលថា កម្រើក ពាក្យរបស់អាចារ្យពួកនោះ មិនគួរកាន់យក ។

សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា សទ្ធេន ឧបជ្ឈាយេន : ដោយមានសង្ឃជាឧបជ្ឈាយ៍ ជាដើម មានឧភតោព្យញ្ជនកៈជាឧបជ្ឈាយ៍ជាទីបំផុត ក៏ន័យនេះឯង ។

## មនុស្សគ្មានបាត្រនិងចីវរ

[១៣៤] ពាក្យថា អបត្តកា ហត្ថេសុ បិណ្ឌាយ ចរន្តិ : ភិក្ខុដែលគ្មានបាត្រទាំងនោះ ត្រាច់ទៅបិណ្ឌបាតនឹងដៃទាំងឡាយ មានសេចក្តីថា ភិក្ខុទាំងឡាយ ដែលមិនមានបាត្រ រមែងត្រាច់ទៅ ដើម្បីប្រយោជន៍ដល់បិណ្ឌបាតដែលខ្លួននឹងបានក្នុងដៃទាំង ២ ។

ពាក្យថា សេយ្យថាបិ តិត្ថិយា : ដូចពួកតិរ្ថិយ មានសេចក្តីថា ដូចពួកតិរ្ថិយដែលមានឈ្មោះថា អាជីវក ។ ពិតមែន តិរ្ថិយទាំងនោះរមែងឆាន់បិណ្ឌបាតដែលខ្លួនលាយច្របល់ដោយសម្ល ហើយនឹងទុកដាក់ក្នុងដៃទាំង ២ នោះឯង ។

ពីរបទថា អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ មានសេចក្តីថា ជាអាបត្តិដល់ភិក្ខុ ដែលឱ្យឧបសម្បទាដោយអាការយ៉ាងនោះប៉ុណ្ណោះ ។

ចំណែកកម្មមិនកម្រើក សូម្បីក្នុងវត្ថុថា **អចីវរកា : កុលបុត្រគ្មានចីវរ** ជាដើម ក៏ន័យនេះឯង ។

បទថា **យាចិតកេន : ដែលខ្ចីគេ** មានសេចក្តីថា ដោយបាត្រជារបស់ខ្ចីដែលឧបសម្បទាបេក្ខៈអង្វរខ្ចីមកថា "សូមលោកឱ្យខ្ញុំព្រះករុណា ក្នុងរយៈពេលដែលខ្ញុំព្រះករុណាឧបសម្បទារួចហើយចុះ" ។

ពិតមែន រមែងជាអាបត្តិដល់ភិក្ខុដែលឱ្យឧបសម្បទាដោយបាត្រ ឬចីវរ ឬទាំងបាត្រទាំងចីវរ ដូច្នេះ តែកម្មមិនកម្រើក ។

ព្រោះហេតុនោះ កុលបុត្រដែលមានបាត្រចីវរគ្រប់ប៉ុណ្ណោះ ទើបគួរឱ្យឧបសម្បទា ។

បើបាត្រចីវររបស់កុលបុត្រនោះមិនមាន ហើយអាចារ្យ ឧបជ្ឈាយ៍ប្រាថ្នាដើម្បីឱ្យដល់កុលបុត្រនោះ, ឬពួកភិក្ខុដទៃប្រាថ្នា នឹងឱ្យ (អាចារ្យ និងឧបជ្ឈាយ៍ ឬភិក្ខុពួកដទៃនោះ) ជាអ្នកមិនស្តាយ គប្បីលះបង់ឱ្យបាត្រនិងចីវរដែលគួរអធិដ្ឋានបាន ។ តែនឹងឱ្យបព្វជ្ជាបេក្ខៈ ដែលជាបណ្ឌុបលាសបួស ដោយបាត្រនិង ចីវរ សូម្បីដែលខ្ចីមក សមគួរ, សូម្បីកាន់យកដោយវិស្សាសៈ ក្នុងទីនៃភិក្ខុដែលជាសភាគគ្នាហើយបំបួសក៏គួរ ។ តែបើបណ្ឌុបលាសនោះ ជាអ្នកកាន់បាត្រដែលមិនទាន់បានដុត និងសំពត់ ដែលគួរដល់ចីវរមក, បាត្រនៅដុត និងចីវរនៅធ្វើត្រឹមណា គួរ នឹងឱ្យអនាមដ្ឋបិណ្ឌបាតដល់បណ្ឌុបលាស ដែលនៅក្នុង

វិហារត្រឹមនោះ ។ បណ្ណបលាសនោះ នឹងបរិភោគក្នុងបាត្រក៏គួរ ។

ក្នុងវេលាមុនឆាន់អាហារ ចំណែកនៃអាមិសប៉ុនទឹងចំណែករបស់សាមណេរដែលភិក្ខុជាភត្តុទ្ទេសក៍សមគួរនឹងឱ្យ ។

ចំណែកការកាន់សេនាសនៈនិងភត្តផ្សេង ៗ មានសលាកភត្តឧទ្ទេសភត្ត និងនិមន្តនភត្តជាដើម មិនសមគួរឱ្យ ។

សូម្បីក្នុងវេលាខាងក្រោយអាហារ ចំណែកនៃភេសជ្ជៈមានប្រេងទឹកឃ្មុំ និងស្ករអំពៅជាដើមប៉ុនទឹងចំណែករបស់សាមណេរដែលភិក្ខុដែលជាភត្តុទ្ទេសកៈសមគួរនឹងឱ្យ ។

បើគេមានជម្ងឺ ភិក្ខុទាំងឡាយគួរនឹងធ្វើថ្នាំឱ្យគេ និងគួរធ្វើការប្រណិបត្តិទាំងពួងដល់គេ ដូចធ្វើដល់សាមណេរ ដូច្នេះឯង ។

បុគ្គល ២០ ចំពូកដែលសង្ឃមិនគប្បីឱ្យឧបសម្បទា ចប់

## ពួកមនុស្ស ៣២ ចំពូក មានដាច់ដៃជាដើម

[១៣៩] គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងមនុស្សកំបុតដៃជាដើមតទៅ ៖

ដៃតែម្ខាង ឬទាំង ២ ខាង របស់អ្នកណា ជាអវយវៈដាច់ទៅត្រង់បាតដៃក្តី ត្រង់កដៃក្តី ត្រង់ដើមដៃក្តី ផ្នែកណាមួយ អ្នកនោះ

ឈ្មោះថា មនុស្សដាច់ដៃ ។

ជើងតែម្ខាងឬទាំង ២ ខាងរបស់អ្នកណា ជាអវយវៈដាច់ទៅត្រង់ចុងជើងក្តី ត្រង់កជើងក្តី ត្រង់ស្នូនជើងក្តី ផ្នែកណាមួយ អ្នកនោះ ឈ្មោះថា មនុស្សដាច់ជើង ។

ក្នុងដៃនិងជើងទាំង ៤ ដោយប្រការដូចពោលហើយនុ៎ះឯង ដៃនិងជើងរបស់អ្នកណា ២ ឬ ៣ ឬទាំងអស់ ជាអវយវៈដាច់ទៅ អ្នកនោះ ឈ្មោះថា មនុស្សដាច់ទាំងដៃទាំងជើង ។

ត្រចៀករបស់អ្នកណា តែម្ខាងឬទាំង ២ ខាង ជាអវយវៈដាច់ទៅត្រង់គុម្ពត្រចៀកក្តី ត្រង់ស្លឹកត្រចៀកក្តី អ្នកនោះ ឈ្មោះថា មនុស្សដាច់ត្រចៀក ។ តែត្រចៀករបស់អ្នកណា រហែកត្រង់ក្រវិលនៃត្រចៀកជាអវយវៈដែលអាចនឹងតឱ្យជាប់គ្នាបាន អ្នកនោះ គប្បីតត្រចៀកឱ្យជាប់សិន សឹមបំបួស ។

ច្រមុះរបស់អ្នកណា ជាអវយវៈដែលដាច់កញ្ឆុតទៅត្រង់ក្តោងច្រមុះក្តី ត្រង់រន្ធច្រមុះតែម្ខាងក្តី រន្ធច្រមុះទាំង ២ ក្តី ផ្នែកណាមួយ អ្នកនោះ ឈ្មោះថា មនុស្សកំបុតច្រមុះ ។ តែច្រមុះរបស់អ្នកណា ជាអវយវៈដែលអាចតឱ្យជាប់គ្នាបាន ។ អ្នកនោះគប្បីធ្វើច្រមុះនោះឱ្យជាសះស្បើយសិន សឹមបំបួស ។

បុគ្គលដែលឈ្មោះថា មនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ

គប្បីជ្រាបដោយអំណាចនៃអវយវៈទាំង ២ ។

ម្រាមរបស់អ្នកណា តែមួយឬច្រើនម្រាម ជាអវយវៈដាច់ទៅ មិនមានក្រចកនៅសល់ អ្នកនោះ ឈ្មោះថា **មនុស្សកំបុតម្រាមដៃ** តែក្រចករបស់អ្នកណាមានប្រាកដ សូម្បីនៅសល់ប្រមាណប៉ុនសរសៃអំបោះ ទឹងឱ្យអ្នកនោះបួស គួរ ។

ក្នុងមេដៃ មេជើង និងម្រាមទាំង ៤ មេដៃនិងមេជើងរបស់អ្នកណា តែ មួយ ឬច្រើនម្រាម ជាអវយវៈដាច់ទៅ តាមន័យដែលពោលហើយ ក្នុងម្រាមដៃ អ្នកនោះ ឈ្មោះថា **មនុស្សកំបុតមេដៃ មេជើង** ។

សរសៃធំ ដែលឈ្មោះថា កណ្ឌរៈ របស់អ្នកណា ជាអវយវៈដាច់ទៅ ខាងមុខក្តី ខាងក្រោយក្តី អ្នកនោះ ឈ្មោះថា **មនុស្សដាច់សរសៃធំ** បុគ្គលរមែងឈានដើរដោយចុងជើងខ្លះ ដោយកែងជើងខ្លះ ឬមិនអាចដាក់ជើងចុះត្រង់ ៗ បាន ក៏ព្រោះក្នុងសរសៃធំទាំងនោះ សូម្បីសរសៃមួយដាច់ទៅ ។

ម្រាមដៃរបស់អ្នកណា ជារបស់ជាប់គ្នាដូចស្លាបប្រចៀវ អ្នកនោះឈ្មោះថា **មនុស្សមានម្រាមដៃជាប់គ្នា** ។ ភិក្ខុដែលប្រាថ្នានឹង ឱ្យបុគ្គលនោះបួស គប្បីវះស្បែកដែលមានក្នុងចន្លោះម្រាម យកស្បែកក្នុងចន្លោះចេញទាំងអស់ ព្យាបាលឱ្យសះហើយ សឹមបំបួស ។ សូម្បីអ្នកណាមានម្រាម ៦ ភិក្ខុអ្នកប្រាថ្នានឹងឱ្យអ្នកនោះបួស គប្បីកាត់ម្រាមដែលលើ

លចេញ ព្យាបាលឱ្យសះហើយ សឹមបំបួស ។

អ្នកណាចាត់ថា មានរាងកាយគម ព្រោះទ្រូង ឬខ្នង ឬឆ្អឹងជំនីកោង អ្នកនោះ ឈ្មោះថា មនុស្សគម ។ តែអវយវៈតូចធំខ្លះរបស់អ្នកណា កោងទៅបន្តិចបន្តួច នឹងឱ្យអ្នកនោះបួស សមគួរ ។ ព្រោះថា មហាបុរសប៉ុណ្ណោះ មានព្រះកាយត្រង់ដូចកាយព្រហ្ម សត្វដ៏សេស ឈ្មោះថា អ្នកមិនគម រមែងមិនមាន ។

អ្នកមានជើងខ្វីក្តី មានចង្កេះខ្វីក្តី ខ្វីទាំង ២ ក្តី ឈ្មោះថា មនុស្សតឿ ។

ដែលហៅថា អ្នកមានជើងខ្វី គឺ កាយកំណាត់ក្រោមតាំងពីចង្កេះចុះមក មានប្រវែងខ្វី ឯកាយកំណាត់លើបរិបូរណ៍ ។

ដែលហៅថា អ្នកមានចង្កេះខ្វី គឺ កាយកំណាត់លើតាំងពីចង្កេះឡើងទៅ មានប្រវែងខ្វី ឯកាយកំណាត់ក្រោមបរិបូណ៌ ។

ដែលហៅថា អ្នកខ្វីទាំង ២ គឺ កាយទាំង ២ កំណាត់ មានប្រវែងខ្វី ។ រាងកាយ រមែងមូលជុំវិញស្រដៀងឆ្នាំងមានក្អែងធំ ដូចរាងកាយនៃភូតទាំងឡាយ ព្រោះកាយទាំង ២ កំណាត់ ពួកណា ជារបស់ខ្វី នឹងឱ្យជនទាំង ៣ ប្រភេទនោះ បួស រមែងមិនគួរ ។

ត្រង់កនៃអ្នកណា មានពកដូចផ្លែឃ្លោក អ្នកនោះឈ្មោះថា មនុស្សពកក ។ និងពាក្យនេះត្រឹមតែសម្តែង តែកាលមានពកត្រង់

ប្រទេសណាមួយ ក៏មិនគួរបំបួស ។

វិនិច្ឆ័យក្នុងពាក្យថា **គលគណ្ឌី** : មនុស្សពកក នោះ គប្បីជ្រាបតាមន័យ ដែលពោលហើយក្នុងពាក្យនេះថា "**ន ភិក្ខវេ បញ្ចហិ អាពាធេហិ ផុដ្ឋោ បព្វាជេតព្វោ** : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយ មិនគប្បីបំបួសឡើយ"[១] នុ៎ះឯង ។

ពាក្យណា ដែលទឹងគប្បីពោលក្នុងអ្នកមានស្នាមដំបៅ ជាអ្នកត្រូវវាយដោយផ្តៅ និងអ្នកដែលរាជការកត់ឈ្មោះទុក ពាក្យនោះខ្ញុំព្រះករុណាបានពោលហើយ ក្នុងពាក្យទាំងឡាយ មានពាក្យថា "**ន ភិក្ខវេ លក្ខណាហតោ** : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ត្រូវបំបួស)មនុស្សដែលគេបៀតបៀនឱ្យមានស្នាម"[២] ជាដើមនុ៎ះឯង ។

អ្នកមានជើងស្ទុក លោកហៅថា មនុស្សជើងស្ទុក ។ ជើងរបស់អ្នកណាហើមប៉ោងកើតជាពករីង អ្នកនោះមិនគួរបំបួស តែជើងរបស់អ្នកណា មិនទាន់ចាប់រឹង ជារបស់ដែលអាចចងរឹត ត្រាំទឹកទុកក្នុងរណ្តៅទឹក លុបដោយខ្សាច់សើមទឹកឱ្យពេញ ឱ្យស្រកស្វិតចុះដរាបសរសៃប្រាកដ និងស្ទងក៏ដូចជាបំពង់ប្រេង ទឹងធ្វើជើងរបស់អ្នកនោះឱ្យជាសះស្បើយដូច្នេះ ហើយឱ្យគេបួស គួរ ។

១. វិន. មហា. មហាខន្ធក. ៦. ១០១/២៤៣ ។    ២. វិន. មហា. មហាខន្ធក. ៦. ១០៧/២៥១ ។

បើពកនោះរីកធំឡើងទៀត សូម្បីកាលនឹងឱ្យឧបសម្បទា គប្បីធ្វើយ៉ាងនោះសិន សឹមឱ្យឧបសម្បទា ។

អ្នកគួរស្អប់ មិនគួរពេញចិត្ត មានសេចក្តីក្តៅក្រហាយជានិច្ច មានរោគដែលរក្សាមិនជាសះ ដោយរោគប្រភេទណាមួយ ក្នុងបណ្តារោគឫសដូងដុះ ឫសដូងពោះវៀន រោគប្រម៉ាត់ រោគសេម្ហៈ រោគក្អករោគហឺតជាដើម ឈ្មោះថា **មនុស្សមានរោគ អាក្រក់** សូម្បីបុគ្គលនេះក៏មិនគួរបំបួស ។

អ្នកណា រមែងប្រទូស្តបរិស័ទ ព្រោះតែខ្លួនមានរូប ប្លែកអ្នកនោះឈ្មោះថា **មនុស្សទ្រុស្តបរិស័ទ** គឺ ជាអ្នកខ្ពស់ពេក មានទីនៃផ្ចិតខ្ពស់ស្មើនឹងក្បាលពួកជនដទៃខ្លះ ។ តឿពេក ដូចរូបនៃភូតតឿទាំង ២ កំណាត់ខ្លះ ។ ខ្មៅពេក ស្រដៀងដង្គត់ឈើតាមស្រែ ត្រូវភ្លើងឆេះខ្លះ ។ សពេក មានពណ៌ស្រដៀងបាត្រ ទង់ដែងដែលខាត់ដោយទឹកសាច់ជូរនិងប្រេងជាដើមខ្លះ ។ ស្គមពេក មានសាច់ និងឈាមតិច ដូចជារាងកាយដែលមានតែឆ្អឹង សរសៃ និងស្បែកខ្លះ ។ ធាត់ពេក មានសាច់តាំងហាប មានដុះក្បាលពោះកំប៉ោង ដូចនឹងមហាភូតខ្លះ ។ មានក្បាលធំពេក ដូចទូលល្អីលើក្បាលខ្លះ ។ មានក្បាលតូចពេក គឺប្រកប ដោយក្បាល

តូចណាស់ មិនសមខ្លួនខ្លះ ។ មានក្បាលជាអន្លាញ់ ៗ គឺ ប្រកបដោយក្បាល ដូចទឹកធ្លាយនៃផ្លែត្នោតខ្លះ ។ មានក្បាលវៀវស្រួច គឺ ប្រកបដោយក្បាលដែលស្តួចឡើងទៅដោយលំដាប់ខ្លះ ។ មានក្បាលដូចដើមឫស្សី ជាបំពង់ គឺ ប្រកបដោយក្បាល ដូចទឹកបំពង់ឫស្សីយ៉ាងធំទ្រេទ្រេសខ្លះ ។ មានក្បាលជាបន្ទាបខ្លះ ។ មានក្បាលជាចំពាម គឺ ប្រកបដោយក្បាល ដែលខុបចុះ បណ្តាទាំង ៤ ខាងណាមួយខ្លះ ។ មានក្បាលកើតដំបៅខ្លះ មានក្បាលស្អុយខ្លះ ។

មានសក់រួញ ៗ គឺ ជាអ្នកមានសក់ដែលដុះឡើងក្នុងទីនោះ ៗ ដូចទឹកសន្ទូងក្នុងស្រែដែលសត្វស៊ីខ្លះ ។ មានក្បាលតម្ពែកមិនមានសក់ខ្លះ ។ មានសក់រឹងកំព្រើសគឺ ជាអ្នកមានសក់ដូចទឹកជក់ត្នោតខ្លះ ។ មានសក់ស គឺជាសក់ដែលស្កូវពីកំណើតខ្លះ ។ មានសក់ក្រហមជាប្រក្រតី គឺ ជាអ្នកមានសក់ដូចអណ្តាតភ្លើងខ្លះ ។ មានសក់លើក្បាលវិល គឺ ជាអ្នកមានសក់ក្រយៅទាំងឡាយ មានចុងបះឡើងខាងលើ ដូចទឹកក្រយៅលើខ្លួនគោខ្លះ ។

មានរោមចញ្ចើមជាប់គ្នានឹងសក់លើក្បាល គឺ ជាអ្នកមានថ្ងាសដូចដណ្តប់ដោយសំណាញ់ខ្លះ, មានចញ្ចើមជាប់គ្នាខ្លះ, មិនមានរោមចញ្ចើមខ្លះ, មានចញ្ចើមដូចស្វាខ្លះ ។

មានភ្នែកធំពេកខ្លះ, មានភ្នែកតូចពេកខ្លះ, គឺ ជាអ្នកមានភ្នែកទាំង

២ ដូច នឹងប្រហោងក្នុងស្បែកក្របី ដែលគេចាក់ដោយចុងកាំបិតខ្លះ, មានភ្នែកស្រលៀង គឺ ជាអ្នកមានភ្នែកធំម្ខាង តូចម្ខាងខ្លះ, មានរង្វង់ភ្នែកខៀវមិនស្មើ គឺ ជាអ្នកមាន រង្វង់ភ្នែកខៀវ មិនស្មើគ្នាយ៉ាងនេះ គឺ ម្ខាងខ្ពស់ ម្ខាងទាបខ្លះ, អ្នកភ្នែកស្រលៃវខ្លះ, អ្នកមានភ្នែកលឹប គឺ មានគ្រាប់ភ្នែកប្រាកដដូចក្រពេញទឹកក្នុងអណ្តូងដែលជ្រៅខ្លះ, អ្នកមានភ្នែកលៀនចេញ (គឺ មានគ្រាប់ភ្នែកលៀនចេញ ដូចភ្នែកក្តាម) ខ្លះ ។

មានត្រចៀកដូចដំរី គឺ ជាអ្នកមានស្លឹកត្រចៀកធំខ្លះ, មានត្រចៀកដូចកណ្តុរ ឬមានត្រចៀកដូចជ្រើង គឺ ជាអ្នកមានស្លឹកត្រចៀកតូចខ្លះ, អ្នកមានតែរន្ធត្រចៀក គឺ ប្រាសចាកស្លឹកត្រចៀក មានតែប្រហោងត្រចៀកប៉ុណ្ណោះខ្លះ, អ្នកមានត្រចៀកបោះធំខ្លះ, តែជនជាតិយោនកមិនចាត់ជាអ្នកទ្រុស្តបរិស័ទ ព្រោះថា ការបោះត្រចៀកធំនោះ ជាប្រពៃណីរបស់គេដោយចំពោះ[១] ។ អ្នកកើតរោគដួងក្នុងត្រចៀក គឺ ជាអ្នកមានត្រចៀកដែលស្អុយជានិច្ចខ្លះ, អ្នកមានត្រចៀកមានទឹកថ្លង់ គឺ ជាអ្នកមានត្រចៀក មានខ្ទុះហូរចេញគ្រប់កាលខ្លះ, អ្នកមានស្លឹកត្រចៀកត្រង់ គឺ ជាអ្នកមានស្លឹកត្រចៀកដូចនឹងចុងបំពង់[២]សម្រាប់បញ្ចុកអាហារគោខ្លះ ។

អ្នកមានភ្នែកលឿងពេកខ្លះ តែនឹងឱ្យអ្នកមានភ្នែកលឿង ដូចទឹកឃ្មុំបួស សមគួរ, អ្នកមិនមានរោមភ្នែកខ្លះ, អ្នកមានភ្នែកមានទឹកភ្នែកហូរខ្លះ, អ្នកមានភ្នែករហែកចេញខ្លះ, អ្នកមានភ្នែកប្រកបដោយរោគ

១. តាមន័យយោជនា ប្រែថា ពិតមែន ត្រចៀកដូច្នោះ ជាសភាពដោយចំពោះរបស់ជនជាតិ យោនកនោះ ។ ២. គោភត្តនាឡិកាយ ។

ញ៉ាំងភ្នែកឱ្យក្រហមទុំ គឺ អ្នកមានភ្នែកជាំ មានអាចម៍ភ្នែកក្តាំងខ្លះ ។

អ្នកមានប្រមុះធំពេកខ្លះ, មានប្រមុះតូចពេកខ្លះ, អ្នកមានប្រមុះកំពិតខ្លះ, អ្នកមានប្រមុះវៀចទៅម្ខាង មិនតាំងនៅត្រង់កណ្តាលខ្លះ, អ្នកមានប្រមុះវែង គឺ ជាអ្នកមានប្រមុះដូចជ្រូកដែលអាចលិទ្ធដោយអណ្តាតបានខ្លះ, អ្នកមានប្រមុះមាន សម្បោរហូរចេញជានិច្ចខ្លះ ។

អ្នកមានមាត់ធំ គឺ មានរង្វាសនៃមាត់ប៉ុណ្ណោះធំដូចមាត់នៃកង្កែបមាត់ធំ ចំណែកផ្ទៃមុខតូច ដូចនឹងឃ្លោកខ្លះ, អ្នកមានមាត់ហាប្រេហខ្លះ, អ្នកមានមាត់ខ្វិខ្លះ ។

អ្នកមានបបូរមាត់ធំ គឺ ជាអ្នកមានបបូរមាត់ដូចនឹងកណ្តាប់មាត់ឆ្នាំងបាយខ្លះ, អ្នកមានបបូរមាត់ខ្វី គឺ ជាអ្នកមានបបូរមាត់ដែលមិនអាចនឹងបិទធ្មេញជិត ដូចនឹងស្បែកពាសស្គរខ្លះ, អ្នកមានបបូរមាត់ក្រោមក្រាស់ខ្លះ, អ្នកមានបបូរមាត់ឆែបខ្លះ ។

អ្នកមានទឹកមាត់ហូរជានិច្ចខ្លះ, អ្នកមានមាត់ក្រហមទុំពេកខ្លះ, អ្នកមានមាត់ដូចស័ង្ខ គឺ ជាអ្នកមានបបូរមាត់ខាងក្រៅស ខាងក្នុងក្រហមផាំងខ្លះ, អ្នកមានមាត់ស្អុយ ដូចសាកសពខ្លះ ។

អ្នកមានធ្មេញធំ គឺ ជាអ្នកមានធ្មេញដូចនឹងសត្វមានធ្មេញ ៨ ខ្លះ,

អ្នកមានធ្មេញដូចអសូរ គឺ មានធ្មេញក្រោម ឬធ្មេញលើចេញមកក្រៅមាត់ខ្លះ, ចំណែកធ្មេញរបស់អ្នកណាអាចបិទដោយបបូរមាត់បាន កាលនិយាយប៉ុណ្ណោះ ទើបប្រាកដ កាលមិននិយាយមិនប្រាកដ ទើងឱ្យអ្នកនោះបួសសមគួរ ។ អ្នកមានធ្មេញស្អុយខ្លះ, អ្នកមិនមានធ្មេញខ្លះ, តែក្នុងចន្លោះធ្មេញរបស់អ្នកណា មានធ្មេញតូចដូចធ្មេញកង្កែន ទើងឱ្យអ្នកនោះបួសសមគួរ ។

អ្នកមានចង្កាធំ គឺ ជាអ្នកមានចង្កាដូចចង្កានៃគោខ្លះ, អ្នកមានចង្កាវែងខ្លះ, អ្នកមានចង្កាតូច គឺ ជាអ្នកមានចង្កាដែលខ្លីពេក ដូចលឹបចូលក្នុងបាត់ខ្លះ, អ្នកមានចង្កាបាក់ខ្លះ, អ្នកមានចង្កាខ្លីខ្លះ ។

អ្នកមិនមានពុកមាត់និងពុកចង្កា គឺ មានមុខស្រដៀងភិក្ខុនីខ្លះ ។

អ្នកមានកវែង គឺ ប្រកបដោយកដូចនឹងកសត្វកុកខ្លះ, អ្នកមានកខ្លីគឺ ប្រកបដោយកដូចរួញចូលខាងក្នុងខ្លះ, អ្នកមានកធ្លាក់ចុះខ្លះ ។

អ្នកមានចង្កេះស្មាដែលធ្លាក់ខ្លះ, អ្នកមិនមានដៃខ្លះ, អ្នកមានដៃតែម្ខាងខ្លះ, អ្នកមានដៃខ្លីពេក, អ្នកមានដៃវែងហួសខ្លះ ។ អ្នកមានទ្រូងបាក់ខ្លះ, អ្នកមានខ្នងបាក់ខ្លះ, អ្នកមានខ្លួនកើតកមក្រិនខ្លះ, មានខ្លួនកើតរមាស់ខ្លះ, មានខ្លួនកើតដំណួចពិសខ្លះ, មានខ្លួនដូចទន្សងគឺ មានកម្ទេចជ្រុះពីខ្លួនដូចសត្វទន្សងខ្លះ ។ ក៏ឯពាក្យថា មានខ្លួនកើតកមក្រិនជាដើមទាំងអស់ខ្ញុំព្រះករុណា សំដៅយករោគដែលធ្វើកាយឱ្យប្រែប្រួល ពោលហើយ

ដោយអំណាចនៃបរិសុទ្ធសកសត្ត ដែលមានសេចក្តីទូលំទូលាយ ។

ចំណែកវិនិច្ឆ័យក្នុងពាក្យនេះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលហើយក្នុងពាក្យនេះថា "**ន ភិក្ខវេ បញ្ចហិ អាពាធេហិ ផុដ្ឋោ** ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយ មិនគប្បីបំបួសឡើយ" នុ៎ះឯង ។

អ្នកមានចង្កេះបាក់ខ្លះ, អ្នកមានត្រគាកធំ គឺ ប្រកបដោយសាច់ត្រគាកខ្ពស់ពេក ដូចទីងមុំបង្រ្កានខ្លះ, អ្នកមានក្លៀកធំខ្លះ, អ្នកមានអណ្ឌៈធំខ្លះ, អ្នកមានជង្គង់ធំខ្លះ, អ្នកមានជង្គង់ កកិតគ្នាខ្លះ, អ្នកមានស្មងវែង គឺមានស្មងដូចទីងឈើប្រត់ខ្លះ ។ អ្នកមានជើងខុសប្រក្រតី (គឺទៅដោយទទឹង) ខ្លះ[១], អ្នកមានជើងកែកទៅខាងក្រោយខ្លះ[២] អ្នកមានកំភួនជើងជាត្រយូងចេកខ្ពស់ខ្លះ[៣], អ្នកមានកំភួនជើងជាត្រយូងចេកខ្ពស់នោះមាន ២ ប្រភេទ គឺ ប្រកបដោយកំភួនជើងធំ ដុះសំយុងចុះខាងក្រោមក៏មាន ប៉ោងធំឡើងខាងលើក៏មាន អ្នកមានស្មងធំខ្លះ អ្នកមានជុំសាច់ត្រង់ស្មងក្រាស់ខ្លះ, អ្នកមានជើងធំខ្លះ, អ្នកមានកែងធំខ្លះ, អ្នកមានចុងជើងនឹងកែង (ប្រវែង) ស្មើគ្នា គឺមានស្មងតាំងឡើងអំពីកណ្តាលជើងខ្លះ, អ្នកមានជើងវៀច ខ្លះ, អ្នកមានជើងវៀចនោះមាន ២ ប្រភេទ គឺ មានជើងវៀចចូលទៅក្នុងក៏មាន វៀចចេញក្រៅក៏មាន ។ អ្នកមានម្រាមក្ងិកក្ងង់ គឺប្រកបដោយម្រាម ដូចទីងស្មែងខ្វីខ្លះ, អ្នកមានក្រចកខ្មៅ គឺ ប្រកប

១.២.៣. អ្នកមានជើងវែកចេញប្រឆាំងខ្លះ អ្នកមានជើងកស្ទិតរួមចូលខ្លះ អ្នកមានកំភួនស្មងប៉ោង ខ្លះ ក៏បាន ។

ដោយក្រចកស្អុយមានពណ៌ខ្មៅខ្លះ, សូម្បីអ្នកទាំងអស់នេះ ក៏ជាអ្នកប្រទូស្តបរិស័ទ, អ្នកប្រទូស្តបរិស័ទ បែបនេះ មិនគួរបំបួស ។

បទថា កាណោ : **អ្នកមានភ្នែកខ្វាក់** មានសេចក្តីថា អ្នកមានភ្នែកងងឹត ឬ អ្នកមានចក្ខុប្រសាទដែលឈាមជាដើមកម្ចាត់ចេញ ក៏ដោយ អ្នកណាមើលមិនឃើញដោយភ្នែកទាំង ២ ឬតែម្ខាង អ្នកនោះមិនគួរបំបួស ។

តែក្នុងមហាបច្ចរីអដ្ឋកថាពោលថា អ្នកខ្វាក់ភ្នែកតែម្ខាង ហៅថា កាណៈ, អ្នកខ្វាក់ភ្នែក ២ ខាង សង្គ្រោះដោយអន្ធៈ អ្នកងងឹតភ្នែក ។

ក្នុងមហាអដ្ឋកថាពោលថា មនុស្សខ្វាក់ពីកំណើត ហៅថា អន្ធៈ ព្រោះហេតុនោះ ពាក្យសូម្បីទាំង ២ ត្រឹមត្រូវដោយបរិយាយ ។

មនុស្សក្ងែងដៃក្តី មនុស្សក្ងែងជើងក្តី, មនុស្សក្ងែងម្រាមក្តី ឈ្មោះថា មនុស្សក្ងែង ។ បណ្តាអវយវៈទាំងឡាយ មានដៃជាដើមទាំងនោះ ចំណែកណាមួយរបស់អ្នកណា ងប្រោកជ អ្នកនោះ ឈ្មោះថា មនុស្សក្ងែង ។

អ្នកមានជង្គង់បត់ក្តី, អ្នកបាក់ស្មងក្តី, អ្នកមានផតបាតជើង វៀចព្រោះមានជើងបាក់ត្រង់កណ្តាល គឺ ដើរដោយកណ្តាលខ្នងជើងក្តី, អ្នក

មានចុងជើងបត់ ព្រោះមានជើងបាក់ចុង គឺដើរដោយចុងខ្នងជើងក្តី, អ្នកដើរចំទើតដោយចុងជើងក្តី, អ្នកដើរ ចំទើតដោយកែងជើងក្តី, អ្នកដើរទ្វើក ៗ ដោយចំណែកក្រៅនៃជើងក្តី, អ្នកដើរទ្វើក ៗ ដោយចំណែកក្នុងនៃជើងក្តី, អ្នកដើរទ្វើក ៗ ដោយខ្នងជើងទាំងអស់ ព្រោះមានថ្នាំងកជើងទាំង ២ បាក់ផ្នែកលើក្តី, ឈ្មោះថា មនុស្សមានដំណើរខ្ចក, មនុស្ស ៤ ប្រភេទនេះសូម្បីទាំងអស់ ជាមនុស្សខ្ចកពិត មិនគួរបំបួស ។

ដៃម្ខាងក្តី ជើងម្ខាងក្តី មួយចំហៀងខ្លួនក្តី របស់អ្នកណា មិននាំសេចក្តីសុខមកឱ្យ អ្នកនោះឈ្មោះថា អ្នកស្លឹកម្ខាង ។

មនុស្សខ្វិន ហៅថា មនុស្សមានឥរិយាបថដាច់ ។

អ្នកទុព្វល ព្រោះភាពជាអ្នកជរា មិនអាចនឹងធ្វើសូម្បីនូវកម្ម មានជ្រលក់ចីវររបស់ខ្លួនជាដើម ឈ្មោះថា អ្នកមានកម្លាំងខ្សោយព្រោះជរា ។ ចំណែកអ្នកណាជាអ្នកចាស់តែនៅមានកម្លាំងអាចទំនុកបំរុងខ្លួន អ្នកនោះគួរបំបួស ។

អ្នកខ្វាក់ភ្នែកពីកំណើត ហៅថា មនុស្សខ្វាក់ ។

ការបញ្ចេញវាចារបស់អ្នកណា ប្រព្រឹត្តទៅមិនបាន អ្នកនោះឈ្មោះថា មនុស្សគ ។ សូម្បីរបស់អ្នកណាប្រព្រឹត្តទៅបាន តែមិនអាចពោលសរណគមន៍ឱ្យបរិបូណ៌, នឹងឱ្យអ្នកនិយាយមិនច្បាស់[១] សូម្បីដូច្នោះបួស រមែងមិនគួរ ។ ចំណែកអ្នកណា អាចពោលត្រឹមតែ

១. និយាយជជិត ។ បូរាណថា មានពាក្យជាជជិតនិយាយវែងក់រងឹន ពោលមិនត្រូវ ។ សរណគមន៍ឱ្យបរិបូណ៌បាន នឹងឱ្យអ្នកនោះ បួស រមែងគួរ ។

អ្នកណា ស្តាប់មិនឮដោយប្រការទាំងពួង អ្នកនោះឈ្មោះថា មនុស្សថ្លង់ ។ ចំណែកអ្នកណាស្តាប់សំឡេងខ្លាំងឮ នឹងឱ្យអ្នកនោះបួស រមែងគួរ ។ មនុស្សពិការ មានមនុស្សខ្វាក់ និងគជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃទោសពីរជាន់ ។

ក៏បព្វជ្ជារបស់ជនពួកណា ដែលព្រះមានព្រះភាគទ្រង់ហាម សូម្បីឧបសម្បទារបស់ជនទាំងនោះ ក៏ទ្រង់ហាមផងដែរ, តែបើសង្ឃឱ្យអ្នកទ្រុស្តបរិស័ទទាំងនោះឧបសម្បទា អ្នកមានអវយវៈខ្វះខាតទាំងអស់ មានអ្នកដៃដាច់ជាដើម ក៏ជាការឧបសម្បទាដោយល្អ តែការសង្ឃនិងអាចារ្យព្រមទាំងឧបជ្ឈាយ៍ មិនផុតពីអាបត្តិ ។

ពិតមែន ដូចន័យដែលខ្ញុំព្រះករុណាបានអាងបាលីថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនទាន់ដល់ឱសារណាកម្មនៅឡើយ បើសង្ឃហៅបុគ្គលនោះចូល បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅចូលដោយល្អ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅចូលដោយអាក្រក់"[១] ។

សេចក្តីនៃព្រះបាលីនោះ នឹងមានច្បាស់ក្នុងអនាគតស្ថាននោះឯងដោយប្រការដូច្នេះ ។

បុគ្គលដែលសង្ឃមិនត្រូវឱ្យឧបសម្បទា ចប់

១. វិន. មហា. ចម្មេយ្យក្ខន្ធកៈ. ៨. ១០១/២២២ ។

## និស្សយវិធី

[១៣៦] ក្នុងពាក្យថា អលជ្ជីនំ និស្សាយ វសន្តិ : នៅអាស្រ័យនឹងអលជ្ជីភិក្ខុទាំងឡាយ នេះ ៖

បទថា អលជ្ជីនំ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ សេចក្ដីថា ភិក្ខុទាំងឡាយអាស្រ័យបុគ្គលជាអលជ្ជីទាំងឡាយ ។

ពាក្យថា យាវ ភិក្ខុសភាគតំ ជានាមិ : អញនឹងដឹងជាសភាគភិក្ខុ មានសេចក្ដីថា យើងនឹងជ្រាបសេចក្ដីដែលភិក្ខុឱ្យនិស្ស័យជាអ្នកត្រូវចំណែក នឹងភិក្ខុទាំងឡាយ គឺ ភាពជាអ្នកមានសេចក្ដីខ្មាស ត្រឹមណា ។ ព្រោះហេតុនោះ ភិក្ខុដែលដល់ឋានៈថ្មី សូម្បីដែលភិក្ខុណា ៗ ពោលថា "ភិក្ខុលោកចូរមកកាន់និស្ស័យ" ដូច្នេះ គប្បីពិចារណានូវភិក្ខុដែលឱ្យនិស្ស័យ ជាអ្នកមានសេចក្ដីខ្មាស ៤-៥ ថ្ងៃ ហើយ សឹមកាន់និស្ស័យ ។ បើបានស្ដាប់ក្នុងសំណាក់នៃភិក្ខុទាំងឡាយថា "ព្រះថេរៈជាលជ្ជី" ជាអ្នកប្រាថ្នានឹងកាន់ក្នុងថ្ងៃដែលខ្លួនមកតែម្ដង ចំណែកព្រះថេរៈពោលថា "លោកចូររង់ចាំសិន លោកនឹងបានដឹង" ដូច្នេះ ហើយត្រូតមើលអាចារៈ ២-៣ ថ្ងៃហើយ ទើបឱ្យនិស្ស័យករធ្វើយ៉ាងនេះ រមែងគួរ ។

ដោយប្រក្រតី ភិក្ខុដែលទៅកាន់ស្ថានជាទីកាន់និស្ស័យ ត្រូវកាន់និស្ស័យក្នុងថ្ងៃនោះតែម្តង ។ សូម្បីតែមួយថ្ងៃ ក៏រក្សាមិនបាន ។ បើក្នុងបឋមយាម អាចារ្យមិនមានឱកាស កាលមិនបានឱកាស ក៏សឹងដោយតាំងចិត្តទុកថា "យើងនឹងកាន់ក្នុងវេលាជិតភ្លឺ" ដល់អរុណរះហើយមិនដឹង មិនជាអាបត្តិ ។ តែបើមិនធ្វើការតាំងចិត្តថា "យើងនឹងកាន់" ហើយដេក ក្នុងវេលាអរុណរះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុទៅកាន់ស្ថានទីមិនធ្លាប់ទៅ ប្រាថ្នានឹងសម្រាក ២-៣ ថ្ងៃហើយទៅ មិនត្រូវនៅកាន់និស្ស័យ ក៏បាន ។ តែកាលធ្វើសេចក្តីអាល័យថា យើងនឹងសម្រាក ៧ ថ្ងៃ ត្រូវកាន់និស្ស័យ ។ បើព្រះថេរៈនិយាយថា នឹងមានប្រយោជន៍អ្វីដោយនិស្ស័យសម្រាប់អ្នកនៅអស់ ៧ ថ្ងៃ ។ លោកជាការបានបរិហារចាប់ផ្តើមតាំងពីកាលដែលព្រះថេរៈហាមទៅ ។

[១៣៧] បទថា និស្សយករណីយោ : មានកិច្ចដោយនិស្ស័យ មានសេចក្តីថា យើងជាអ្នកមានការកាន់និស្ស័យជាកិច្ចគួរធ្វើ អធិប្បាយថា និស្ស័យដែលយើងគប្បីធ្វើ គឺ គប្បីកាន់ ។

ពីរបទថា និស្សយំ អលភមានេន : ដែលមិនទាន់បាននិស្ស័យ មានសេចក្តីថា កាលមិនមានភិក្ខុដែលឱ្យនិស្ស័យ ដែលធ្វើដំណើរទៅជាមួយខ្លួន លោកឈ្មោះថា រមែងមិនបាននិស្ស័យ ដែលភិក្ខុមិនបានយ៉ាងនោះ មិនត្រូវកាន់និស្ស័យទៅបានអស់សូម្បីច្រើនថ្ងៃ បើចូលទៅកាន់ទី

អាវាសណាមួយ ដែលខ្លួនធ្លាប់នៅកាន់និស្ស័យក្នុងកាលមុន សូម្បីនឹងសម្រាកតែមួយយប់ ក៏ត្រូវកាន់និស្ស័យ ។ សម្រាកក្នុងចន្លោះ មកឬនៅរកពួកក្រុម ២-៣ ថ្ងៃ មិនជាអាបត្តិ ។ តែខាងក្នុងវស្សា ត្រូវនៅជាប់ជានិច្ច និងត្រូវកាន់និស្ស័យ ។ តែមិនជាអាបត្តិ ដល់ភិក្ខុដែលទៅដោយទូក តែមិនបាននិស្ស័យ ក្នុងកាលរដូវភ្លៀង ដែលមកហើយ ។

[១៣៨] បទថា **យាចិយមានេន : បើភិក្ខុឈឺសូម** មានសេចក្តីថា ភិក្ខុ (អ្នករក្សាជម្ងឺ)ដែលភិក្ខុមានជម្ងឺនោះអង្វរ បើភិក្ខុមានជម្ងឺសូម្បីលោកប្រាប់ថា "ចូរលោកសូមចំពោះយើង" ដូច្នេះ តែមិនព្រមអង្វរ ព្រោះមានះលោកគប្បីទៅ ។

ពីរបទថា **ផាសុ ហោតិ : បានសេចក្តីសប្បាយ** មានសេចក្តីថា សេចក្តីសប្បាយ មានដោយអំណាចនៃការបានចំពោះនូវសមថៈ និងវិបស្សនា ។ ការពិត ព្រះសោតាបន្ន រមែងមិនបាននូវបរិហារនេះឡើយ ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្ត ក៏មិនបាន បុគ្គលអ្នកមានប្រក្រតីបានសមាធិ ឬវិបស្សនាដែលចាស់ក្លាហើយ រមែងមិនបានបរិហារនេះ ។ ពាក្យដែលនឹងគប្បីពោល រមែងមិនមានក្នុងពាលបុថុជ្ជនជាអ្នកលះកម្មដ្ឋានចោលពិត ។ ប៉ុន្តែថា សមថៈក្តី វិបស្សនាក្តី របស់ភិក្ខុណា នៅជាគុណជាតិទន់ខ្ចី ភិក្ខុនេះ រមែងបានបរិហារនេះ ។ សូម្បីការបវារណាសង្គ្រោះ[១] ព្រះមានព្រះភាគទ្រង់បានអនុញ្ញាតដល់ភិក្ខុដែល

១. ទ្រង់អនុញ្ញាតឱ្យពន្យាបវារណា ទៅធ្វើក្នុងថ្ងៃពេញបូណ៌មីខែកត្តិក ជាចុងក្រោយ ។

មានសមថៈ និងវិបស្សនានៅទន់ខ្ចីនេះប៉ុណ្ណោះ ។ ព្រោះហេតុនោះ បុគ្គលនេះ សូម្បីកាលអាចារ្យបវារណាហើយទៅហើយដោយកន្លង ៣ ខែ នឹងធ្វើការតាំងចិត្តថា “កាលណា ភិក្ខុដែលឱ្យនិស្ស័យដ៏សមគួរ នឹងមកកាលនោះ យើងនឹងនៅអាស្រ័យភិក្ខុនោះ” ហើយមិនកាន់និស្ស័យ នៅដរាបដល់ថ្ងៃអាសាឡ្ហបុណ្ណមី តិថីពេញបូណ៌មីខែ ៨ ទៀតក៏គួរ ។ តែបើក្នុងខែអាសាឡ្ហ អាចារ្យមិនមក គួរទៅក្នុងទីដែលខ្លួននឹងបាននិស្ស័យ ។

[១៣៩] ពីរបទថា គោត្តេនបិ អនុស្សាវេតុំ ៖ ឱ្យភិក្ខុសូធ្យអនុស្សាវនាដោយគោត្រនាមក៏បាន មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុបញ្ជាក់គោត្រ សូធ្យប្រកាសយ៉ាងនេះថា “អ្នកមានឈ្មោះនេះ សម្លឹង ឧបសម្បទាដល់ព្រះមហាកស្សបៈ” ។

[១៤០] ពីរបទថា ទ្វេ ឯកានុស្សាវនេ ៖ ភិក្ខុសូធ្យអនុស្សាវនាតែម្តង ចំពោះឧបសម្បទាបេក្ខៈពីរនាក់បាន មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុធ្វើការសូធ្យប្រកាសឧបសម្បទាបេក្ខៈ ២ នាក់រួមគ្នាបាន ។ អធិប្បាយថា តថាគតអនុញ្ញាតឱ្យអាចារ្យ ២ រូបយ៉ាងនេះ គឺ អាចារ្យ ១ រូប សម្រាប់ឧបសម្បទាបេក្ខៈម្នាក់ អាចារ្យដទៃសម្រាប់ឧបសម្បទាបេក្ខៈម្នាក់ទៀត ឬអាចារ្យតែមួយរូប សូធ្យកម្មវាចាប្រកាស

ឱ្យឧបសម្បទាក្នុងខណៈជាមួយគ្នាបាន ។

ពាក្យថា ទ្វេ តយោ ឯកានុស្សាវនេ កាតុំ តញ្ច ខោ ឯកេន ឧបជ្ឈាយេន : ភិក្ខុសូធ្យអនុស្សាវនាជាមួយគ្នា ចំពោះឧបសម្បទាបេក្ខៈពីររូប បីរូបបាន មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុធ្វើការសូធ្យប្រកាសជន ២ នាក់ ឬ ៣ នាក់រួមគ្នា ដោយន័យមុននុ៎ះឯង ។ និងតថាគតអនុញ្ញាតអនុស្សាវនកិរិយានោះឯង ដោយឧបជ្ឈាយ៍តែមួយរូប, ព្រោះហេតុនោះ ឧបសម្បទាបេក្ខៈ ២ នាក់ ឬ ៣ នាក់ ដែលអាចារ្យតែមួយរូប, គប្បីសូធ្យប្រកាសកម្មវាចា ២ ឬ ៣, ដែលអាចារ្យ ២ រូបឬ ៣ រូប គប្បីសូធ្យដោយព្រមគ្នាតែម្តងយ៉ាងនេះ គឺ អាចារ្យមួយរូប គប្បីសូធ្យដល់ឧបសម្បទាបេក្ខៈមួយរូប ញែកគ្នាទៅ ។ តែបើអាចារ្យក៏ផ្សេងគ្នា ឧបជ្ឈាយ៍ក៏ផ្សេងគ្នា គឺ ព្រះតិស្សត្ថេរសូធ្យប្រកាសសទ្ធិវិហារិករបស់ព្រះសុមនត្ថេរ ឯព្រះសុមនត្ថេរសូធ្យក៏ប្រកាសសទ្ធិវិហារិករបស់ព្រះតិស្សត្ថេរ ហើយក៏ជាគណបូរកៈរបស់គ្នានិងគ្នាផង យ៉ាងនេះ គួរ ។ និងបើឧបជ្ឈាយ៍ផ្សេងគ្នា អាចារ្យតែមួយយ៉ាងនេះឈ្មោះថា មិនគួរ ព្រោះព្រះមានព្រះភាគទ្រង់ហាមទុកថា តែតថាគតមិនអនុញ្ញាតដោយឧបជ្ឈាយ៍ផ្សេងគ្នាឡើយ ដូច្នេះ ពិតមែន ការហាមនេះ សំដៅយកពាក្យបាលីនេះ ។

និស្សយវិធី ចប់

## ពណ៌នាឧបសម្បទាយត្តវិធី

[១៨២] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា បឋមំ ឧបជ្ឈំ គាហាបេតព្វោ : ភិក្ខុត្រូវឱ្យឧបសម្បទាបេក្ខៈនោះ កាន់យកឧបជ្ឈាយ៍ជាមុន នេះតទៅ ភិក្ខុណា រមែងសម្លឹងមើល ទោសតូច និងទោសធំ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា ឧបជ្ឈាយ៍ ។ ឧបសម្បទាបេក្ខៈនោះ ដែលភិក្ខុគប្បីឱ្យពោលកាន់ឧបជ្ឈាយ៍នោះ យ៉ាងនេះថា "សូមលោកម្ចាស់ជាឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាចុះ" ។

បទថា វិត្ថាយន្តិ : នៅតែរឹងខ្លួន មានសេចក្តីថា ឧបសម្បទាបេក្ខៈទាំងឡាយ រមែងជាអ្នកមានខ្លួននៅទ្រឹង ។

ពីរបទថា ឧល្លុម្បតុ មំ : សូមស្រោចស្រង់នូវខ្ញុំ មានសេចក្តីថា សូមសង្គ្រោះលើកខ្ញុំព្រះករុណាឡើងផង ។

[១៨៣] សជ្ជុ តាវទេវ : ក្នុងខណៈនោះ មានសេចក្តីថា ក្នុងវេលាជាប់ត ទីងវេលាដែលឧបសម្បទាបេក្ខៈ ឧសម្បទាហើយតែម្តង ។

ពាក្យថា ឆាយា មេតព្វា : ត្រូវវាស់ស្រមោល មានសេចក្តីថា គប្បី វាស់ស្រមោលថា ចម្ងាយមួយជួរបុរស ឬថា ចម្ងាយពីរជួរបុរស ។

ពាក្យថា **ឧតុប្បមាណំ អាចិក្ខិតព្វំ : ត្រូវប្រាប់រដូវ** មានសេចក្ដីថា គប្បីប្រាប់ប្រមាណរដូវយ៉ាងនេះថា "រដូវភ្លៀង រដូវត្រជាក់ រដូវក្ដៅ" និងរដូវទុំះឯង ឈ្មោះប្រមាណនៃរដូវក្នុងពាក្យនេះ បើរដូវទាំងឡាយមានរដូវភ្លៀងជាដើមមិនទាន់ពេញ រដូវណា របស់ឧបសម្បន្នណា មិនទាន់ពេញដោយថ្ងៃមានប្រមាណប៉ុន្មាន, គប្បីកំណត់ថ្ងៃ ទាំងនោះ នៃរដូវនោះ ហើយប្រាប់ចំណែកនៃថ្ងៃ ដល់ឧបសម្បន្ននោះ ។ មួយប្រការទៀត គប្បីប្រាប់ប្រមាណរដូវយ៉ាងនេះថា "រដូវឈ្មោះនេះ ទាំងរដូវនោះឯងពេញ ឬមិនទាន់ពេញ" គប្បីប្រាប់ចំណែកនៃថ្ងៃយ៉ាងនេះថា "ព្រឹក ឬល្ងាច" ។

បទថា **សង្គីតិ : ត្រូវប្រាប់ការរួបរួម** ជាដើម មានសេចក្ដីថា គប្បីប្រមាណការប្រាប់ទាំងអស់ មានប្រាប់កំណត់ស្រមោលជាដើមនេះឯង ចូលរួមគ្នាប្រាប់យ៉ាងនេះថា បើអ្នកណា ៗ សួរលោកថា លោកបានរដូវអ្វី ? ស្រមោលរបស់លោកចម្ងាយប៉ុនណា ? ប្រមាណរដូវរបស់លោកយ៉ាងណា ? ចំណែកនៃថ្ងៃរបស់លោកប៉ុនណា ? ដូច្នេះ គប្បីពោលថា ខ្ញុំព្រះករុណាបានរដូវឈ្មោះនេះ គឺ រដូវភ្លៀងក៏ដោយ រដូវត្រជាក់ក៏ដោយ រដូវក្ដៅក៏ដោយ ស្រមោលរបស់ខ្ញុំព្រះករុណាចម្ងាយប៉ុណ្ណេះ ប្រមាណរដូវប៉ុណ្ណេះ ចំណែកនៃថ្ងៃប៉ុណ្ណេះ ។

[១៨៤] បទថា ឱហាយ : ហើយចោល បានដល់ បោះបង់ចោលហើយ ។

ពីរបទថា ធុតិយំ ធាតុំ : ឱ្យភិក្ខុជាគ្នីគ្នា មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យភិក្ខុជាសម្លាញ់ នឹងភិក្ខុដែលឧបសម្បទាថ្មី ដែលចេញពីរោងឧបសម្បទា ទៅកាន់បរិវេណ និងឱ្យប្រាប់អករណីយកិច្ច ៤ យ៉ាងផង ។

បទថា បណ្ឌុបលាសោ : ស្លឹកឈើទុំ បានដល់ ស្លឹកឈើមានពណ៌លឿង ។

ពីរបទថាពន្ធនា បមុត្តោ : ដែលជ្រុះហើយចាកទង បានដល់ធ្លាក់ចុះអំពីទងហើយ ។

ពីរបទថា អភព្វោ ហរិតត្ថាយ : មិនគួរមានពណ៌ខៀវ មានសេចក្ដីថា មិនអាចជារបស់ខៀវស្រស់ទៀតបានទេ ។

ពីរបទថា បុថុសិលា : ថ្មក្រាស់ បានដល់ សិលាធំ ។

[១៨៥] ពាក្យថា អលព្ភមានាយ សាមគ្គិយា អនាបត្តិ សម្ភោគេ សំវាសេ : កាលបើមិនបានសេចក្ដីព្រមព្រៀងទេ មិនមានអាបត្តិព្រោះបរិភោគរួម នៅរួម មានសេចក្ដីថា ការព្រមព្រៀង ដើម្បីប្រយោជន៍ ដល់ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះ ដែលភិក្ខុមិនទាន់បាន

ត្រឹមណា មិនជាអាបត្តិព្រោះការបរិភោគរួម ( ដោយអាមិសនិងដោយធម៌ ) និងនៅរួមដោយការធ្វើឧបោសថ និងបវារណាជាដើមជាមួយនឹងភិក្ខុនោះ ត្រឹមនោះ ។

ពាក្យដ៏សេសគ្រប់កន្លែងរាប់ថា ប្រាកដហើយពិត ព្រោះជាពាក្យដែលនឹងគប្បីជ្រាបបានងាយ ដោយទំនងដែលពោលទុក ហើយក្នុងមហាវិភង្គ ដោយប្រការដូច្នេះ ។

ពណ៌នាឧបសម្បទាយត្តវិធី ចប់

ពាក្យអធិប្បាយសេចក្តីនៃមហាខន្ធកៈ ដែលប្រដាប់ដោយរឿង ១៧២ រឿង មានមកត្រឹមតែប៉ុណ្ណេះ ។

**មហាខន្ធកវណ្ណនា ចប់ ។**

# ២. ឧបោសថក្ខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងឧបោសថក្ខន្ធកៈ

### ការស្តាប់ធម៌

[១៤៧] ក្នុងបទថា អញ្ញតិត្ថិយា : លទ្ធិដទៃ នេះ មានវិគ្រោះថា លទ្ធិ លោកឱ្យឈ្មោះថា តិត្ថៈ ប្រែថា កំពង់, កំពង់ដទៃ ឈ្មោះថា អញ្ញតិត្ថៈ, កំពង់ដទៃរបស់ជនទាំងនោះ មានហេតុនោះ ជនទាំងនោះ ទើបឈ្មោះថា តិរ្ថិយ មានពាក្យអធិប្បាយថា អ្នកមានលទ្ធិដទៃអំពីលទ្ធិក្នុងសាសនានេះ ។

ពីរបទថា ធម្មំ ភាសន្តិ : និយាយធម៌ មានសេចក្តីថា រមែងចង្អុលបង្ហាញដល់វត្ថុដែលគួរធ្វើនិងមិនគួរធ្វើរបស់ពួកតិរ្ថិយនោះ ។

ពីរបទថា តេ លភន្តិ : ក៏បានបក្ខពួក គឺ មនុស្សទាំងនោះរមែងបាន ។

[១៤៨] បទថា មូគសូករា : ដូចជាជ្រូកធាត់ គឺ ដូចជ្រូកដែលមានខ្លួនធាត់ ។

### និទានុទ្ទេសវិភត្តិ

[១៥០] ក្នុងពាក្យថា អនជ្ឈាបន្នោ វា ហោតិ អាបជ្ជិត្វា វា

វុដ្ឋិតោ : ភិក្ខុមិនបានត្រូវអាបត្តិណាក្តី ត្រូវអាបត្តិណាហើយចេញចាកអាបត្តិក្តី នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ភិក្ខុមិនត្រូវអាបត្តិណា ឬត្រូវហើយ តែចេញហើយ អាបត្តិនេះឈ្មោះថា អសន្តី : អាបត្តិមិនមាន ។

ពាក្យថា សម្បជានមុសាវាទោ កឹ ហោតិ : ត្រូវសម្បជានមុសាវាទ ជាអាបត្តិអ្វី មានសេចក្តីថា សម្បជានមុសាវាទ ដែលព្រះមានព្រះភាគត្រាស់ថា "សម្បជានមុសាវាទស្ស ហោតិ : ភិក្ខុនោះ ត្រូវសម្បជានមុសាវាទ" នេះ ពោលដោយអាបត្តិ តើជាអាបត្តិអ្វី ? គឺ ជាអាបត្តិប្រភេទណា ?

ពាក្យថា ទុក្កដំ ហោតិ : សម្បជានមុសាវាទ ជាអាបត្តិទុក្កដ គឺ ទុក្កដាបត្តិ ហោតិ : ជាអាបត្តិទុក្កដ ។ ក៏អាបត្តិទុក្កដនោះឯងអ្នកសិក្សាកុំយល់ថា ជាអាបត្តិតាមលក្ខណៈនៃមុសាវាទ តែគួរជ្រាបថា ជាអាបត្តិ មានការមិនធ្វើក្នុងវចីទ្វារជាសមុដ្ឋាន តាមព្រះវាចារបស់ព្រះមានព្រះភាគ ។ ពិតមែន សូម្បីព្រះឧបាលីថេរៈ ក៏បានពោលដែរថា ៖

ភិក្ខុកាលមិនចរចានឹងមនុស្សណាមួយ មួយទៀត កាលនឹងបញ្ចេញវាចា ក៏មិនបានពោលចំពោះអ្នកដទៃឡើយ តែភិក្ខុនោះ ត្រឡប់ត្រូវអាបត្តិប្រកបដោយវាចា មិនត្រូវអាបត្តិប្រកបដោយកាយ ប្រស្នានេះ ពួកលោកអ្នកឈ្លាស

វៃ បានគិតមកហើយ[1] ។

បទថា អន្តរាយិកោ គឺ អន្តរាយករោ : ធ្វើអន្តរាយ ។

ពាក្យថា កិស្ស ផាសុ ហោតិ : ជាការស្រួលដើម្បីអ្វី មានសេចក្តីថា សេចក្តីសប្បាយ រមែងមានដើម្បីប្រយោជន៍អ្វី ?

ពាក្យថា បឋមស្ស ឈានស្ស អធិគមាយ : ជាការស្រួលដើម្បីបានបឋមជ្ឈាន មានសេចក្តីថា សេចក្តីសប្បាយ រមែងមាន គឺ សេចក្តីសុខ រមែងមានដល់ភិក្ខុនោះ ដើម្បីប្រយោជន៍ដល់ការសម្រេចបឋមជ្ឈាន ។ ន័យក្នុងគុណវិសេសទាំងពួង មានទុតិយឈានជាដើម ក៏ដូចគ្នា ។ ព្រះមានព្រះភាគទ្រង់សម្តែងបាតិមោក្ខុទ្ទេសជាដំបូង ទាំងឧទ្ទេស និងនិទ្ទេស ដោយប្រការដូច្នេះ ។

[១៥១] បទថា ទេវសិកំ : រាល់ថ្ងៃ បានដល់ គ្រប់ ៗថ្ងៃ

ច្រើនបទថា ចាតុទ្ទសេ វា បណ្ណរសេ វា : ក្នុងថ្ងៃទី ១៤ ក្តី ទី ១៥ ក្តី មានសេចក្តីថា ក្នុងថ្ងៃចាតុទ្ទសី ២ ដង គឺ ក្នុងបក្ខទី ៣ និងទី ៧ នៃរដូវមួយ ។ ក្នុងថ្ងៃបណ្ណរសី ៦ ដង ក្នុងបក្ខដ៏សេសយ៉ាង នេះជាអត្ថមួយ ជាមុន ។ និងអត្ថនេះ ពោលដោយអំណាចចារិតតាមប្រក្រតី ។ តែកាលបច្ច័យបែបនោះមាន ក៏សមគួរនឹងសូធ្យក្នុងថ្ងៃចាតុ

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៨៩/៤០៣ ។

ទុសី ឬថ្ងៃបណ្ណរសី ថ្ងៃណាមួយ ក៏បាន តាមព្រះបាលីថា សកឹ បក្ខស្ស ចាតុទ្ទសេ វា បណ្ណរសេ វា : ១ បក្ខម្តង គឺ ក្នុងថ្ងៃទី ១៤ ក្តី ទី ១៥ ក្តី ។ ក៏សេចក្តីនេះ បណ្ឌិតគប្បីជ្រាប សូម្បីដោយព្រះបាលីថា "បើថ្ងៃទី ១៤ ជាថ្ងៃ (ឧបោសថ) របស់ពួកអាវាសិកភិក្ខុ, ថ្ងៃទី ១៥ ជាថ្ងៃរបស់ពួកអាគន្តុកភិក្ខុ ។ បើអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុ ប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញចុះ"[១] ។

វិនិច្ឆ័យក្នុងឧបោសថក្ខន្ធកៈ ចប់

## ការសន្មតសីមា

[១៥៤] ពាក្យថា បឋមំ និមិត្តា កិត្តេតព្វា : ដើមដំបូងត្រូវភិក្ខុកំណត់និមិត្តទាំងឡាយ នោះ មានសេចក្តីថា ព្រះវិន័យធរគប្បីសាកសួរថា "ក្នុងទិសបូព៌ាមានអ្វីជានិមិត្ត ?" កាលអ្នកណាម្នាក់ ឆ្លើយថា "ភ្នំ លោកម្ចាស់" ព្រះវិន័យធរគប្បីបញ្ជាក់ទៀតថា "ភ្នំនោះ ជានិមិត្ត" ។ គប្បីកំណត់និមិត្តមុនយ៉ាងនេះ ។ តែនឹងកំណត់យ៉ាងនេះថា "យើងទាំងឡាយ នឹងធ្វើភ្នំនោះ ជានិមិត្ត, នឹងធ្វើភ្នំនោះជានិមិត្ត, ធ្វើភ្នំ

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៩៧/៤២៧ ។

នោះជានិមិត្តហើយ, ភ្នំនោះ ចូរជានិមិត្ត ជានិមិត្តហើយ នឹងជានិមិត្ត”[១] ដូច្នេះប្រើមិនបាន ។ សូម្បីក្នុងនិមិត្តទាំងឡាយមានថ្មជាដើម មានន័យដូចគ្នា ក៏ព្រះវិន័យធរសួរនិមិត្តទៅដោយលំដាប់យ៉ាងនេះថា “ក្នុងទិសអាគ្នេយ៍ ក្នុងទិសទក្សិណ ក្នុងទិសនិរតី ក្នុងទិសបស្ចិម ក្នុងទិសពាយព្យ ក្នុងទិសឧត្តរ ក្នុងទិសឦសាន អ្វីជានិមិត្ត ? កាលអ្នកណាម្នាក់ ឆ្លើយថា ទឹក លោកម្ចាស់ កាលខ្លួនបញ្ជាក់ថា “ទឹកនោះជានិមិត្ត” ហើយកុំឈប់ក្នុងទិសនេះ គប្បីសួរដដែលទៀតថា ក្នុងទិសបូព៌ាមានអ្វីជានិមិត្ត ? កាលអ្នកណាម្នាក់ឆ្លើយថា “ភ្នំ លោកម្ចាស់” គប្បីបញ្ជាក់ថា “ភ្នំនោះជានិមិត្ត”; គប្បីកំណត់និមិត្តដែលបានកំណត់ទុកជាដំបូងយ៉ាងនេះហើយសីមឈប់ ។ ពិតមែន ដោយការកំណត់យ៉ាងនេះ និមិត្តនឹងនិមិត្តទើបចាត់ថា ជាប់តគ្នា ។ គ្រាកំណត់និមិត្តយ៉ាង នេះហើយ លំដាប់នោះគប្បីសន្មតសីមាដោយកម្មវាចា ដែលព្រះមានព្រះភាគ ត្រាស់ទុកជាលំដាប់ទៅ ។ ក្នុងទីបំផុតនៃកម្មវាចាផ្ទៃដីខាងក្នុងនិមិត្តទាំងឡាយ រមែង

---

១. ហោហិតិ ភវិស្សតិ ទាំង ២ ពាក្យនេះ ស្រដៀង ៗ នឹងថា ប្រើពាក្យណា ក៏បានលោកប្រើតាមភាសារបស់លោកដោយសប្បាយ គ្រាមកប្រែជាភាសា ក៏លំបាក ក្រៅចាកពីនឹងប្រែសូមទៅទីល្មមបានសេចក្តី ឬមិនដូច្នោះ ក៏លើកពាក្យបាលីនោះមកឱ្យឃើញក្នុងពាក្យប្រែថា ...និមិត្តំ ហោហិតិ ភវិស្សតិ ព្រោះផ្សេងក៏ជាកិរិយាក្នុងសេចក្តីថា មានថា ជារូបអនាគតជាមួយគ្នា ។

ជាសីមានិមិត្តទាំងឡាយនៅខាងក្រៅសីមា, និមិត្តទាំងឡាយក្នុងសីមានោះ សូម្បីកំណត់មួង ក៏ជាការកំណត់ទុកល្អហើយពិត ។ តែក្នុងអន្ធកអដ្ឋកថាពោលថា "កាលទីងចងមណ្ឌលសីមា ត្រូវកំណត់និមិត្ត ៣ ដង" ។ និងឧបសម្បន្នក៏បាន អនុបសម្បន្នក៏បាន ចូរឆ្លើយយ៉ាងនេះថា "ភ្នំ លោកម្ចាស់ ។ល ។ ទឹក លោកម្ចាស់" ទាំងនោះ គួរ ។

## វិនិច្ឆ័យនិមិត្ត ៨ ប្រភេទ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិមិត្តទាំងឡាយ មានបព្វតនិមិត្តជាដើមយ៉ាងនេះ ៖

### ១. បព្វតនិមិត្ត

ភ្នំមាន ៣ ប្រភេទ គឺ ភ្នំដីសុទ្ធ១ ភ្នំថ្មសុទ្ធ១ ភ្នំថ្មលាយដី១ ។ ភ្នំនោះ ប្រើបានទាំង ៣ ប្រភេទ ។ តែគំនរខ្សាច់ប្រើ(ជានិមិត្ត)មិនបានទេ ។ ភ្នំទាំង ៣ នោះ ទីងតាំងពីទំហំប៉ុនដំរីដល់ភ្នំសិណេរុ ក៏ប្រើ(ជានិមិត្ត)បាន ។ បើមានភ្នំ ៤ ជួរ ក្នុងទិសទាំង ៤ ឬមាន ៣ ជួរ ក្នុងទិសទាំង ៣ សូម្បីទីងសន្មតសីមាដោយបព្វតនិមិត្តទាំង ៤ ឬ ៣ នោះ ក៏គួរ ។ តែទីងសន្មតដោយនិមិត្ត ត្រឹមតែ២ ឬត្រឹមតែ១ មិនគួរ[១] ។

១. ឯកិស្សាឯវ បន ទិសាយ បិតេហិ នតោ ពហូហិបិ សម្មន្និតុំ ន វដ្ដតិ ។ ទ្វីហិ បនទ្វីសុ ទិសាសុ បិតេហិបិ វដ្ដតីតិ វិមតិវិនោទនី ។

សូម្បីក្នុងបាសាណនិមិត្តជាដើមក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។ ព្រោះហេតុនោះ កាលទីផ្ញើភ្នំឱ្យជានិមិត្តគួរសួរថា ជាប់គ្នា ឬ មិនជាប់គ្នាទេ បើជាប់គ្នា, មិនគួរប្រើ ។ ត្បិតថា សូម្បីកំណត់ ភ្នំនោះ ជានិមិត្តទាំង ៤ ទិស ឬទាំង ៨ ទិស រមែងជាការកំណត់ហើយ ត្រឹមតែនិមិត្តមួយប៉ុណ្ណោះ ។ ព្រោះហេតុនោះ ភ្នំដែលតាំងព័ទ្ធជុំវិញវត្ត ដោយសណ្ឋានដូចកង់រទេះ យ៉ាងនោះ គួរកំណត់តែក្នុងទិសមួយ ក្នុងទិសដទៃ ៗ គប្បីធ្វើភ្នំនោះទុកខាងក្រៅ កំណត់និមិត្តប្រភេទដទៃខាងក្នុងភ្នំនោះចូលមក, បើប្រាថ្នានឹងធ្វើ ភ្នំមួយចំហៀង ឬ ពាក់កណ្ដាលទុកខាងក្នុងសីមា ។ កុំកំណត់ភ្នំប្រាថ្នានឹងធ្វើប្រទេសប៉ុនណាទុកខាងក្នុង ។ គប្បីកំណត់និមិត្តប្រភេទណាមួយ មានដើមឈើនិងដំបូកជាដើម ដែលកើតក្នុងភ្នំនោះឯងខាងក្រៅនៃប្រទេសប៉ុណ្ណោះ, បើប្រាថ្នាយកភ្នំទាំងអស់ប្រមាណ ១ យោជន៍ ឬ ២ យោជន៍ទុកខាងក្នុង ។ គប្បីកំណត់ដើមឈើឬដំបូកជាដើម ដែលកើតលើផ្ទៃផែនដីខាងក្រៅភ្នំជានិមិត្ត ។

## ២. បាសាណនិមិត្ត

សូម្បីដុំដែក ក៏រាប់ថា ថ្មបានដូចគ្នា ។ ព្រោះហេតុនោះ ថ្មប្រភេទណាមួយ ក៏គួរ ។ តែកាលពោលទំហំ ទំហំប៉ុនដំរីរាប់ថា ជាភ្នំ, ព្រោះហេតុនោះ ថ្មទំហំប៉ុនដំរីនោះ ទើបមិនគួរ (ជាបាសាណ

និមិត្ត ) ។ ចំណែកថ្មប៉ុនគោធំ និងក្របីធំ ៗ ប្រើបាន ។ ដោយកំណត់យ៉ាងទាប ខ្នាតប៉ុនដុំស្ករអំពៅទម្ងន់ ៣២ បល:[1] ក៏ប្រើជានិមិត្តបាន ថ្មតូចជាងនោះ ឬសូម្បីឥដ្ឋខ្នាតធំ ក៏ប្រើជានិមិត្តមិនបាន ។ សូម្បីគំនរ ថ្មទាំងឡាយ ដែលមិនចូលទៅកាន់និមិត្ត ក៏មិនគួរទៅហើយ មិនចាំបាច់ពោលដល់គំនរដី គំនរខ្សាច់ ។ ថ្មដាដែលរាបស្មើផ្ទៃផែនដីប្រាកដស្មើដោយមណ្ឌលនៃលានក្តី, ថ្មដាដែលតាំងឡើងខ្ពស់ផុតពីផ្ទៃផែនដី ដូចជង្គត់ឈើក្តី សូម្បីថ្មនោះ បើបានខ្នាត ប្រើបាន, ថ្មដាសូម្បីធំពេក រមែងរាប់ថា ជាថ្មផង ។ ព្រោះដូច្នោះ បើប្រាថ្នានឹងធ្វើប្រទេសមួយនៃថ្មដាធំទុកខាងក្នុងសីមា, កុំកំណត់ថ្មដានោះ ជានិមិត្ត គប្បីកំណត់ថ្មដទៃលើថ្មដានោះ បើធ្វើវិហារនៅលើថ្មដាមានសភាពយ៉ាងនេះ ប្រើមិនបាន, ឬថ្មដាហុចចូលទៅពាក់កណ្តាលវិហារ ថ្មដាមានសភាពបែបនេះ ប្រើមិនបាន, ព្រោះថា បើកំណត់ថ្មដានោះជានិមិត្ត វត្តរមែងនៅលើនិមិត្ត ឯ ធម្មតានិមិត្តត្រូវនៅខាងក្រៅសីមា សូម្បីវត្តក៏ត្រូវនៅ ខាងក្រៅសីមា ។ ថ្មដាតាំង នៅព័ទ្ធជុំវិញវិហារ គួរកំណត់ជានិមិត្ត ក្នុងទិសតែមួយ កុំកំណត់ក្នុងទិសដទៃ ។

---

១. ទម្ងន់ប្រមាណ ១ គីឡូ ។

## ៣. វននិមិត្ត

ព្រៃស្មៅ ឬព្រៃឈើមានត្នោតនិងដូងជាដើម ឈើដែលមានសំបករឹង ប្រើមិនបាន តែពួកឈើមានខ្លឹមខាងក្នុងជាដើមថា ឈើសាកៈ និងឈើសាលៈ (ផ្ចឹករាំង) ឬពួកឈើដុះលាយឈើដែលមានខ្លឹមខាងក្នុងក៏ប្រើបាន ក៏ព្រៃឈើ នោះឯង ដោយកំណត់យ៉ាងតិច សូម្បីត្រឹមតែ ៤-៥ ដើម ក៏ប្រើបានតិចជាងនោះ ប្រើមិនបាន ច្រើនជាងនោះ សូម្បីតាំងអំពី ១០០ យោជន៍ ក៏ប្រើបាន, បើធ្វើវត្តទុកកណ្តាលព្រៃ មិនគួរកំណត់ព្រៃជានិមិត្ត, សូម្បីប្រាថ្នានឹងកាន់យកព្រៃមួយចំណែកទុកខាងក្នុងសីមា កុំកំណត់ព្រៃជានិមិត្ត គប្បីកំណត់ដើមឈើឬថ្មជាដើមក្នុងព្រៃនោះ ជានិមិត្ត ។ ព្រៃដែលនៅជុំវិញវត្ត គប្បីកំណត់ជានិមិត្តក្នុងទិសតែមួយ កុំកំណត់ក្នុងទិសដទៃ ។

## ៤. រុក្ខនិមិត្ត

ដើមឈើមានសំបករឹង ដូចដើមត្នោតដើមដូងជាដើមប្រើមិនបាន ។ ដើមឈើមានខ្លឹមខាងក្នុងនៅរស់ ដោយហោចទៅ មានកម្ពស់ត្រឹមតែ ៨ ធ្នាប់ ។ វាស់ដោយជុំវិញ សូម្បីដើមប៉ុនម្ជុល[1] ក៏ប្រើ

---

១. ក្នុងវិន័យមុខ ភាគ ៣ ថា ដើមប៉ុនម្ជុល ។ ក្នុងដីកាសារត្ថទីបនី ភាគ ៤ ថា សូចិទណ្ឌកប្បមាណោតិ សីហលទីបេ លេខនទណ្ឌប្បមាណោតិ វទន្តិ ។ សោ ច

បាន ៗ តូចជាងនោះ ប្រើមិនបាន ធំជាងនោះឡើងទៅ សូម្បីដើមជ្រៃដែលលូតលាស់ល្អចម្ងាយ ១២ យោជន៍ ក៏គួរ ។ ដើមឈើដែលគេបន្ទុះពូជឱ្យដុះល្អ ក្នុងភាជន៍ទាំងឡាយ មានបំពង់និង ផើងជាដើម សូម្បីបានខ្នាត ក៏ប្រើមិនបាន តែយកចេញអំពីបំពង់ និងផើងជាដើមនោះដាំចុះ ក្នុងផែនដី សូម្បីក្នុងខណៈនោះ ហើយធ្វើចំណារចារជុំវិញស្រោចទឹកកំណត់ជានិមិត្ត ក៏គួរ ។ ការបែកឫស និងមែកថ្មីមិនមែនជាហេតុ តែការបែកឫសនិងមែកនោះ រមែងសមគួរសម្រាប់ដើមឈើដែលគេកាត់ដើមយកមកបណ្តុះ ដែលព្រះវិន័យធរកាលកំណត់នឹងបញ្ជាក់ថា “ដើមឈើ” ឬថា “ដើមសាកៈ” ឬថា “ដើមសាលៈ” ដូច្នេះ ក៏ប្រើបាន ។ តែកំណត់ដើមឈើដែលជាប់បន្តគ្នា ប្រាកដស្មើដូចដើមជ្រៃដែលលូតលាស់ល្អ ជានិមិត្តក្នុងទិសមួយហើយ នឹងកំណត់ក្នុងទិសដទៃទៀត មិនគួរ ។

---

(ត) កនិដ្ឋង្គុលិបរិមាណោតិ ទដ្ឋព្វំ; ដោយន័យដីកា នេះ ក៏គឺ ជង់ដែកចារ ៗ ស័ព្ទថា សូចិទណ្ឌ នេះ មានក្នុងសេនាសនក្ខន្ធកវណ្ណនា ទំព័រ ២៦០ ទៀតថា អដ្ឋង្គុលិសូចិ ទណ្ឌមត្តោ បិ វេឡុ ... ។ អដ្ឋង្គុលសូចិទណ្ឌមត្តោបិ ទារុភណ្ឌកោ ដែលសំដៅសេចក្តីថា ជង់ដែកចារទាំងអស់ ។ សមជាម្ជុលដេរបាវស្រូវ ។

# ៥. មគ្គនិមិត្ត

មគ៌ទាំងឡាយ មានមគ៌ជាទីទៅកាន់ព្រៃ ស្រែ ស្ទឹង និងមគ៌ទៅកាន់បឹងជាដើម ប្រើមិនបាន ។ មគ៌ថ្មើរជើង ឬមគ៌រទេះ ដែលឆ្លងទៅចម្ងាយ ២-៣ ស្រុក ទើបប្រើបាន, ចំណែកមគ៌ថ្មើរជើងណា បែកចេញពីមគ៌រទេះ ហើយត្រឡប់ជួបនឹងមគ៌រទេះនុ៎ះឯងទៀតក្តី មគ៌ថ្មើរជើង និងមគ៌រទេះឯណាដែលគេមិនបានប្រើប្រាស់ក្តី មគ៌ទាំងនោះ ប្រើមិនបាន ។ មគ៌ទាំងឡាយដែលពួកឈ្មួញធ្វើដំណើរថ្មើរជើង និងឈ្មួញរទេះនៅប្រើប្រាស់ គឺធ្វើដំណើរជានិច្ច ទើបប្រើបាន ។

បើមគ៌បែកជា ២ ចេញពីគ្នាទៅហើយ ខាងក្រោយជាមគ៌ជួបគ្នាវិញ ដូចទូករទេះសោត មគ៌នោះគប្បីកំណត់ត្រង់កន្លែងបែកជា ២ ឬកន្លែងដែលជួបគ្នាវិញ ជានិមិត្តម្តងហើយ កុំកំណត់ទៀត ។ ព្រោះនិមិត្តនោះ ជានិមិត្តតែមួយ ។ បើមគ៌បែកជា ៤ អមជុំវិញវត្តហើយចែកទៅក្នុងទិសទាំង ៤ កំណត់មគ៌មួយត្រង់កណ្តាលហើយ នឹងកំណត់មគ៌មួយទៀត មិនគួរ ។ ព្រោះនិមិត្តនោះ ជានិមិត្តជាប់គ្នាតែមួយ ។ តែនឹងកំណត់មគ៌ដែលឆ្លងកាត់បញ្ឆិតជ្រុងទៅ ជានិមិត្តក្នុងទិសដទៃ គួរ ។ ចំណែកមគ៌ដែលកាត់ពាក់កណ្តាលវត្តទៅ មិនគួរកំណត់ ។ កាលកំណត់ហើយ វត្តរមែងនៅលើនិមិត្ត ។ បើភិក្ខុទាំងឡាយនឹងធ្វើមគ៌កង់ខាងក្នុងនៃមគ៌រទេះជានិមិត្ត មគ៌រមែងនៅខាងក្រៅសីមា, បើធ្វើមគ៌កង់ខាងក្រៅ

ជានិមិត្ត មកកន្លែងខាងក្រៅនោះឯង រមែងនៅខាងក្រៅសីមា ។ មកដ៏សេសរាប់បញ្ចូលខាងក្នុងសីមា ។ កាលព្រះវិន័យធរបំណាងនឹងកំណត់មកជានិមិត្ត គួរកំណត់ដោយឈ្មោះយ៉ាងណាមួយ ក្នុងឈ្មោះថា មគ្គោ, បន្ថោ បថោ, បជ្ជោ ជាដើម ។ មកដែលទៅបានជុំវិញវត្ត ដោយសណ្ឋានដូចគ្នូ កំណត់ជានិមិត្តក្នុងទិសមួយហើយ នឹងកំណត់ក្នុងទិសដទៃមិនគួរ ។

## ៦. វម្មិកនិមិត្ត

ដំបូក ដោយកំណត់យ៉ាងតូចបំផុត សូម្បីកើតក្នុងថ្ងៃនោះ កំពស់ ៨ ធ្នាប់ ខ្ពស់ប៉ុនស្នែងគោ ក៏ប្រើបាន ។ តូចជាងនោះ ប្រើមិនបាន ធំជាងនោះឡើងទៅ សូម្បីប៉ុនភ្នំហិមពាន្ត ប្រើបាន ។ តែកំណត់ដំបូកដែលជាប់គ្នា តាំងព័ទ្ធជុំវិញវត្តជានិមិត្តក្នុងទិសមួយហើយ នឹងកំណត់ក្នុងទិសដទៃទៀត មិនគួរ ។

## ៧. នទីនិមិត្ត

ក្នុងសម័យនៃព្រះរាជាដែលទ្រទ្រង់ធម៌ កាលភ្លៀងធ្លាក់ជាប់ ៗ គ្នាយ៉ាងនេះគឺ គ្រប់កន្លះខែ គ្រប់ ១០ ថ្ងៃ គ្រប់ ៥ ថ្ងៃ ល្មមភ្លៀងរាំងហើយ ដាច់ខ្សែទឹកហូរ សូម្បីស្ងួតនេះ មិនរាប់ជាស្ងួត ។ តែក្នុង

កាលភ្លៀងដូច្នេះ ក្រសែនៃទឹកស្ទឹងណាហូរមិនដាច់រហូតដល់អស់រដូវភ្លៀង ៤ ខែ ជម្រៅល្មមនឹងសើមអន្តរវាសកៈរបស់ភិក្ខុនី ដែលស្លៀកដណ្តប់បានបរិមណ្ឌល ៣ លុយឆ្លង ក្នុងឯកទេសកន្លែងណាមួយ, ស្ទឹងនេះរាប់ថា ជាស្ទឹង, កាលចងនទីសីមាជានិមិត្តបាន ៗ ក្នុងការទៅកាន់ត្រើយស្ទឹងរបស់ភិក្ខុនីក្តី ក្នុងការធ្វើសង្ឃកម្មមានឧបោសថជាដើមក្តី ក្នុងការសន្មតនទីបារសីមាក្តី ប្រាថ្នាស្ទឹងប្រភេទនេះឯង ក៏ស្ទឹងណាព័ទ្ធជុំវិញវត្ត ដោយសណ្ឋានដូចជាទូករទេះក្តី ដោយសណ្ឋានដូចគូក្តី ដូចមក, កំណត់ស្ទឹងនោះ ជានិមិត្តក្នុងទិសមួយហើយ នឹង កំណត់ក្នុងទិសដទៃមិនគួរ ៗ សូម្បីក្នុងស្ទឹង ៤ ខ្សែ ដែលឆ្លងកាត់គ្នានិងគ្នាទៅ ក្នុង៤ទិសនៃវត្ត ក៏មានន័យដូចគ្នា ៗ តែនឹងកំណត់ស្ទឹងទាំង ៤ ខ្សែ ដែលមិនជាប់តគ្នាជានិមិត្ត ប្រើបាន បើជនទាំងឡាយបោះបង្គោលរៀងគ្នា ដូចធ្វើរបងការពារក្រសែទឹក ដោយវល្លិនិងចំបើងជាដើម និងទឹកជន់ហៀរលិចទំនប់ ហូរទៅបាន នឹងធ្វើឱ្យជានិមិត្ត គួរ, កាលគេធ្វើទំនប់មិនឱ្យទឹកហូរ ស្ទឹងដែលមិនហូរ មិនគួរធ្វើឱ្យជានទីនិមិត្ត; ក្នុងទីដែលទឹកហូរ ធ្វើឱ្យជានទីនិមិត្ត, ក្នុងទីដែលទឹកមិនហូរ ធ្វើឱ្យជាឧទកនិមិត្តគួរ ៗ តែស្ទឹងដែលមិនហូរ ព្រោះដាច់ទឹក ក្នុងកាលរាំងភ្លៀង ឬក្នុងរដូវក្តៅ ប្រើបាន ៗ ជនទាំងឡាយ ជីកប្រឡាយ បង្ហូរទឹកមកពីស្ទឹងធំ

ប្រឡាយនោះ ដូចគ្នានឹងស្ទឹងតូច នៅហូរជានិច្ច ឱ្យសម្រេចសន្ទូង ៣ ជង សូម្បីទឹកហូរទៅក៏ពិត មែនហើយ តែក៏មិនគួរធ្វើជានិមិត្ត ។ ចំណែកប្រឡាយណាក្នុងជំនាន់ពីដើម សូម្បីគេជីកនាំមកពីស្ទឹងធំ ក្នុងកាលដទៃបាក់ប្រាំងក្លាយជាស្ទឹង ហូរទៅបានដោយខ្លួនឯង តាមមកដែលគេជីកនាំមកនុ៎ះឯង កាលតទៅ ពាសពេញទៅដោយសត្វទឹក មានក្រពើជាដើម ជាស្ទឹងដែលនឹងគប្បីសញ្ចរទៅបានដោយទូកជាដើម នឹងធ្វើប្រឡាយនោះ ដែលក្លាយជាស្ទឹងហើយ ឱ្យជានិមិត្តសមគួរ ។

## ៨. ឧទកនិមិត្ត

ក្នុងទីដែលមិនមានទឹក នឹងជងទឹកដាក់ឱ្យពេញក្នុងទូកក្តី ក្នុងឆ្នាំងក្តី ក្នុងភាជនៈមានអាងជាដើមក្តី ហើយកំណត់ឱ្យជាឧទកនិមិត្ត មិនគួរ ។ ទឹកដែលដល់ផែនដីប៉ុណ្ណោះ ទើបប្រើបាន ។ ក៏ទឹកដល់ផែនដីនុ៎ះឯង ជាទឹកមិនហូរឃាំងនៅក្នុងទីទាំងឡាយមានអណ្តូងជាតស្រះ និងលោណសមុទ្រជាដើម ។ ចំណែកទឹកក្នុងស្ទឹងជ្រៅនិងអូរបង្ហូរទឹកជាដើមដែលហូរ ប្រើមិនបាន ។ តែក្នុងអដ្ឋកថា ពន្យល់ថា ទឹកដែលជន់ឡើងក្នុងទីដ៏ជ្រៅទាំងឡាយ មានអណ្តូងជាដើម មិនគួរធ្វើជានិមិត្ត ។ ពាក្យនោះ លោកពោលមិនប្រពៃត្រឹមតែជាការឃើញរបស់ខ្លួន

ប៉ុណ្ណោះ ៗ ទឹកដែលឃាំងនៅ ដោយហោចទៅ សូម្បីក្នុងថ្លុកដែលជ្រកឈូសទុកក្តី ក្នុងរណ្តៅសម្រាប់លេងរបស់ក្មេងអ្នកស្រុកក្តី ទឹកដែលគេជីករណ្តៅក្នុងផែនដីហើយ យកឆ្នាំងដួសមកដាក់ឱ្យពេញក្នុងខណៈនោះក្តី បើឋិតនៅដរាបដល់សូធ្យកម្មវាចាចប់បាន ទោះជាតិចឬច្រើនក៏ដោយ រមែងគួរ ៗ និងគួរធ្វើគំនរ ថ្មនិងគំនរខ្សាច់ជាដើម ឬសសរថ្ម ឬសសរឈើទុកក្នុងទីនោះ ដើម្បីធ្វើការចំណាំនិមិត្ត ភិក្ខុនឹងធ្វើដោយខ្លួនឯង ឬប្រើអ្នកដទៃ ឱ្យធ្វើគំនរថ្មជាដើមនោះ ក៏គួរ ៗ តែក្នុងលាភសីមា មិនគួរធ្វើ ៗ ចំណែកសមានសំវាសកសីមា រមែងមិនធ្វើសេចក្តីបៀតបៀន អ្នកណា ៗ រមែងឱ្យសម្រេចចំពោះវិន័យកម្មរបស់ភិក្ខុទាំងឡាយតែម៉្យាង ; ព្រោះដូច្នោះ ក្នុងសមានសំវាសកសីមានេះ ទើបគួរធ្វើដោយខ្លួនឯង ឬឱ្យអ្នកដទៃធ្វើគំនរថ្មជាដើម បាន ៗ

## វិធីចងមហាសីមា

ក៏ឯសណ្ឋានទីងសន្ទតិសីមា ដោយនិមិត្ត ៨ យ៉ាងនេះ មិនលាយចម្រុះគ្នាក្តី លាយចម្រុះគ្នាក្តី គួរទាំងអស់ ៗ សីមានោះ ដែលសន្ទតចង យ៉ាងនោះ មិនជាការចង ដោយនិមិត្តតែមួយ ឬនិមិត្ត ២ ៗ ចំណែកសីមាដែលចងដោយនិមិត្ត មានប្រការដូចពោលហើយ តាំងពី ៣ ឡើង

ទៅដល់ ១០០ និមិត្ត ក៏ឈ្មោះថា ចង, សីមាដែលចងដោយនិមិត្ត ៣ នោះ មានសណ្ឋានដូចក្រចាប់, សីមាដែលចងដោយនិមិត្ត ៤ ជាបួនជ្រុងខ្លះ មានសណ្ឋានដូចក្រចាប់, ព្រះចន្ទពាក់កណ្តាលនិងសម្ភោរជាដើមខ្លះ ដែលចងដោយនិមិត្តច្រើនជាងនោះ មានសណ្ឋានផ្សេង ៗ គ្នាខ្លះ ។

ព្រះមហាសុមត្ថេរពោលថា ដែលភិក្ខុទាំងឡាយអ្នកប្រាថ្នា នឹងចងសីមានោះ គប្បីសួរភិក្ខុទាំងឡាយ ក្នុងវត្តជិតខាងគ្នាទាំងឡាយ ដល់ខេត្តកំណត់សីមានៃវត្តនោះ ៗ តម្កល់ទុកនូវសីមន្តរិកនៃសីមា របស់វត្តទាំងឡាយដែលចងសីមា វៀរឧបចារនៃសីមារបស់វត្តទាំងឡាយដែលមិនបានចងសីមាចេញ គប្បីចងសម័យមិនជាទីត្រាច់ទៅរបស់ភិក្ខុទាំងឡាយអ្នកត្រាច់ទៅកាន់ទិស, បើប្រាថ្នានឹងចងសីមាក្នុងគាមខេត្តមួយ, វត្តទាំងឡាយណា ក្នុងគាមខេត្តនោះ ចងសីមាហើយ គប្បីបញ្ជូនដំណឹងដល់ភិក្ខុទាំងឡាយ ក្នុងវត្តទាំងនោះថា យើងទាំងឡាយនឹងចងសីមាក្នុងថ្ងៃនេះ លោកទាំងឡាយ កុំចេញចាកខេត្តសីមារបស់ខ្លួន ៗ ។

វត្តពួកណា ក្នុងគាមខេត្តនោះ មិនបានចងសីមា គប្បីនិមន្តភិក្ខុទាំងឡាយ ក្នុងវត្តទាំងនោះ ឱ្យប្រជុំរួមជាពួកតែមួយ គប្បីឱ្យនាំឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈមក, បើប្រាថ្នានឹងធ្វើគាមខេត្តសូម្បីដទៃទុកខាងក្នុងសីមានោះ ភិក្ខុពួកណានៅក្នុងគាមខេត្តទាំងនោះ

សូម្បីភិក្ខុទាំងនោះត្រូវមក កាលមិនមកត្រូវនាំឆន្ទៈមក ។

ចំណែកព្រះមហាបទុមត្ថេរពោលថា ដែលឈ្មោះថា គាមខេត្ត ផ្សេង ៗ រមែងប្រាកដដូចគ្នានឹងសីមា ដែលចងជាផ្នែកផ្សេងគ្នា, ឆន្ទៈ និងបារិសុទ្ធិ រមែងមិនមកពីគាមខេត្តនោះ ៗ, តែភិក្ខុទាំងឡាយដែលនៅខាងក្នុងនិមិត្តត្រូវមក ដូច្នេះ ។ ហើយពោលបន្ថែមទៀតថា ក្នុងវេលាសន្មតសមានសំវាសកសីមា ការមកក៏ដោយ មិនមកក៏ដោយ របស់ភិក្ខុទាំងនោះ រមែងគួរ ។ តែក្នុងវេលាសន្មតអវិប្បវាសសីមា ភិក្ខុទាំងឡាយដែលនៅខាងក្នុងនិមិត្ត ត្រូវមក, កាលមិនមក ត្រូវនាំឆន្ទៈមក ។ ក៏ឯកាលភិក្ខុទាំងឡាយប្រជុំគ្នាហើយ ឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈបាន នាំមកហើយ យ៉ាងនោះ គប្បីដាក់អារាមិកជន និងសាមណេរធំ ៗ ទុកក្នុងមកទាំងនោះ និងក្នុងទីទាំងឡាយមានកំពង់ទឹកនិងទ្វារស្រុកជាដើម ដើម្បីនាំភិក្ខុអាគន្តុកៈមកចូលហត្ថបាសឆាប់ ៗ និងដើម្បីធ្វើទុកខាងក្រៅសីមា ហើយគប្បីវាយស្គរជាសញ្ញា ឬផ្លុំស័ង្ខជាសញ្ញា ហើយចងសីមាដោយកម្មវាចាថា សុណាតុ មេ ភន្តេ សង្ឃោ ជាដើម ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងលំដាប់នៃការកំណត់និមិត្ត ។ ក្នុងវេលាដែលចប់កម្មវាចាទាំងឯង និមិត្តទាំងឡាយនៅខាងក្រៅ, សីមា រមែងធ្លាក់ចុះជ្រៅទៅខាងក្រោមដល់ទឹកទ្រផែនដីជាទីបំផុត ។

# វិធីចងខណ្ឌសីមា

ភិក្ខុទាំងឡាយដែលនឹងសន្មតសមានសំវាសកសីមានេះ គួរចងខណ្ឌសីមាជាមុន ដើម្បីធ្វើសង្ឃកម្មទាំងឡាយ មានបព្វជ្ជា និងឧបសម្បទាជាដើមបានស្រួល, ក៏ឯកាលទីនឹងចងខណ្ឌសីមានោះ ត្រូវស្គាល់វត្ត ។ ក៏បើនឹងចងក្នុងវត្តដែលទាយកកសាង ឱ្យប្រតិស្ឋានវត្ថុទាំងពួង មានដើមពោធិព្រឹក្ស ចេតិយ និងសាលាឆាន់ជាដើមរួចស្រេចហើយ កុំចងត្រង់កណ្តាលវត្តដែលជាស្ថានទីប្រជុំរបស់ជនច្រើន គប្បីចងក្នុងឱកាសដែលស្ងាត់បំផុតខាងចុងវត្ត ។ កាលទីនឹងចងក្នុងវត្តដែលទាយកមិនបានកសាង គប្បីកំណត់ទីទុកសម្រាប់វត្ថុទាំងពួង មានដើមពោធិព្រឹក្ស និងចេតិយជាដើមទុកហើយ កាលប្រតិស្ឋានវត្ថុទាំងឡាយស្រេចហើយ ខណ្ឌសីមានឹងនៅក្នុងឱកាសដ៏ស្ងាត់ខាងចុងបង្អស់នៃវត្ត ដោយប្រការណា គប្បីចងដោយប្រការនោះចុះ ។ ខណ្ឌសីមានោះ ដោយកំណត់យ៉ាងទាបបំផុត បើចុះភិក្ខុបាន ២១ រូប ប្រើបាន ។ តិចជាងនោះ ប្រើមិនបាន, ទីធំសូម្បីចុះភិក្ខុចំនួនមួយពាន់ ក៏ប្រើបាន ។ កាលទីនឹងចងខណ្ឌសីមានោះ គប្បីតម្កល់ថ្មដែលគួរជានិមិត្តបាន ទុកជុំវិញរោងដែលត្រូវចងសីមា ។ កុំឈរនៅក្នុងខណ្ឌសីមាចងមហាសីមា, កុំឈរនៅក្នុងមហាសីមាចងខណ្ឌសីមា ។ តែត្រូវឈរនៅក្នុងខណ្ឌសីមា ចងខណ្ឌសីមា, ត្រូវឈរនៅក្នុងមហាសីមាចងមហាសីមា ។

## វិធីចងសីមា ២ ជាន់

ក្នុងសីមា ២ ប្រភេទនោះ មានវិធីចង ដូចតទៅនេះ ៖

គប្បីកំណត់និមិត្តទាំងឡាយ ដោយជុំវិញយ៉ាងនេះថា "ថ្មនោះជានិមិត្ត" ហើយចងសីមាដោយកម្មវាចា ។ លំដាប់នោះ គប្បីធ្វើអវិប្បវាសកម្មវាចាដដែលចុះ ដើម្បីធ្វើខណ្ឌសីមានោះឯងឱ្យរឹងមាំ ។ ពិតមែន កាលធ្វើយ៉ាងនោះហើយភិក្ខុទាំងឡាយ ដែលមកដោយគិតថា "យើងទាំងឡាយនឹងដកសីមា" នឹងមិនអាចដកបាន ។ កាលសន្មតសីមាហើយ គប្បីដាក់ថ្មចំណាំសីមន្តរិកទុកខាងក្រៅ ។ សីមន្តរិក ពោលដោយផ្នែកតូចបំផុត ប្រមាណ ១ ហត្ថ ទើបគួរ ។ ក្នុងកុរុន្ទីថា សូម្បីប្រមាណ ១ ចំអាម ក៏គួរ ។ ក្នុងមហាបច្ចរីថា សូម្បីប្រមាណ ៤ ធ្នាប់ ក៏គួរ ។ ក៏បើវត្តធំ គួរចងខណ្ឌសីមាទុក ២ កន្លែងក៏បាន ៣ កន្លែងក៏បាន ច្រើនជាងនោះក៏បាន ។ កាលសន្មតខណ្ឌសីមាយ៉ាងនោះហើយ ក្នុងវេលានឹងសន្មតមហាសីមា គប្បីចេញពីខណ្ឌសីមា ឈរក្នុងមហាសីមា កំណត់ថ្មចំណាំសីមន្តរិក ដើរវិលទៅដោយជុំវិញ, បន្ទាប់ពីនោះ គប្បីកំណត់និមិត្តទាំងឡាយ ដ៏សេសអំពីថ្មសីមន្តរិកទាំងឡាយនោះ ហើយកុំលះហត្ថបាសគ្នា គប្បីសន្មតសមានសំវាសកសីមាដោយកម្មវាចា ហើយធ្វើអវិប្បវាស កម្មវាចាផង ដើម្បីធ្វើសមានសំវាសកសីមានោះ

ឱ្យរឹងមាំ ។

ពិតមែន កាលធ្វើយ៉ាងនោះហើយ ភិក្ខុទាំងឡាយដែលមកដោយគិតថា យើងទាំងឡាយនឹងដកសីមា នឹងមិនអាចដកបាន ។ តែបើកំណត់និមិត្តនៃខណ្ឌសីមាហើយ លំដាប់នោះ ទើបកំណត់និមិត្តត្រង់សីមន្តរិក ហើយកំណត់និមិត្តនៃមហាសីមា, កាលកំណត់និមិត្តក្នុង៣ ស្ថានយ៉ាងនេះហើយ, ប្រាថ្នានឹងចងសីមាណា, នឹងចងសីមានោះមុន ក៏គួរ ។ សម្បីដូច្នោះ ក៏គួរចង តាំងពីខណ្ឌសីមាទៅ ដោយន័យតាមដែលពោលហើយ ។

ក៏បណ្ដាសីមាទាំងឡាយដែលសង្ឃចងយ៉ាងនោះ ភិក្ខុទាំងឡាយអ្នកស្ថិតនៅក្នុងខណ្ឌសីមា រមែងមិនធ្វើឱ្យខូចកម្មរបស់ពួកភិក្ខុដែលធ្វើកម្មក្នុងមហាសីមា, ឬអ្នកស្ថិតនៅក្នុងមហាសីមា រមែងមិនធ្វើឱ្យខូចកម្មរបស់ពួកភិក្ខុដែលធ្វើកម្មក្នុងខណ្ឌសីមា ។ មួយទៀត ភិក្ខុដែលស្ថិតនៅក្នុងសីមន្តរិក រមែងមិនធ្វើឱ្យខូចកម្មរបស់ពួកភិក្ខុទាំង ២ ពួក តែបើភិក្ខុស្ថិតក្នុងសីមន្តរិក រមែងធ្វើឱ្យខូចកម្មរបស់ពួកភិក្ខុ ដែលធ្វើកម្មក្នុងគាមខេត្ត; ពិតមែន សីមន្តរិក រមែងរាប់ជាគាមខេត្ត ។[១]

---

១. តាមន័យយោជនាប្រែថា ... រមែងដល់ភាពជាគាមខេត្ត ។

# វិធីចងសីមាលើថ្មដាជាដើម

សេចក្ដីពិត ធម្មតាសីមានោះ ដែលភិក្ខុសង្ឃចងហើយ លើផែនដី តែមិនមែនផែនដីម្យ៉ាងប៉ុណ្ណោះទេ ដែលចាត់ថា ជាការចងសីមា, តាមពិត សីមាដែលភិក្ខុសង្ឃចងទុកលើថ្មដាក្ដី ក្នុងផ្ទះគឺ កុដិក្ដី ក្នុងកុដិជាទីពួនសម្ងំក្ដី ក្នុងប្រាសាទក្ដី លើកំពូលភ្នំក្ដី ក៏ចាត់ថា ចងហើយដូចគ្នាទាំងនោះ ។

ក្នុងស្ថានទីទាំងនោះ កាលភិក្ខុទាំងឡាយនឹងចងលើថ្មដា កុំឆូតស្នាមឬជីករណ្ដៅដូចត្បាល់ លើខ្នងថ្មធ្វើឱ្យជានិមិត្ត ។ គួរតម្កល់ថ្មដែលត្រូវខ្នាត ជានិមិត្តហើយកំណត់ឱ្យជានិមិត្ត, សន្មតដោយកម្មវាចា ។ ក្នុងវេលាចប់កម្មវាចាសីមា រមែងធ្លាក់ចុះទៅដល់ទឹកទ្រផែនដីជាទីបំផុត, ថ្មដែលជានិមិត្តនឹងមិនឋិតនៅក្នុងទីដើម ព្រោះដូច្នោះ គួរធ្វើស្នាមឱ្យប្រាកដដោយជុំវិញ ឬឆូតបោះថ្មត្រង់មុំទាំង ៤ ឬចារឹកអក្សរទុកថា ត្រង់នេះជាដែនកំណត់សីមា ក៏បាន ។ ភិក្ខុពួកខ្លះឬស្សាអុជភ្លើងឡើង ដោយគិតថា នឹងដុតសីមាចេញ រមែងឆេះតែថ្ម មិនឆេះសីមាទេ ។

កាលនឹងចងក្នុងផ្ទះគឺ កុដិសោត កុំកំណត់ជញ្ជាំងជានិមិត្ត គួរតម្កល់ថ្មជានិមិត្ត ក្នុងស្ថានទីល្មមចុះភិក្ខុ ២១ រូប ទុក ខាងក្នុងហើយសន្មតសីមាចុះ ។ រួមក្នុងជញ្ជាំងប៉ុណ្ណោះ រមែងជាសីមា ។ បើខាងក្នុងជញ្ជាំងមិនមានទីល្មមចុះភិក្ខុបាន ២១ រូប គួរតម្កល់ថ្ម និមិត្តត្រង់យ៉មុខ

ក៏បាន ហើយសន្មតសីមា ។ បើសូម្បីយ៉ាងមុខនោះមិនល្អ គួរតម្កល់និមិត្តទាំងឡាយក្នុងទីដែលទឹកធ្លាក់ចុះអំពីរងស្បូវ ខាងក្រៅ ហើយសឹមសន្មតសីមា, ក៏កាលសន្មតសីមាយ៉ាងនោះ ផ្ទះគឺ កុដិទាំងអស់ ឈ្មោះថាតាំងនៅក្នុងសីមាពិត ។

កាលទឹងចងក្នុងកុដិជាទីពួនសម្ងំ ដែលមានជញ្ជាំង ៤ ផ្នែក កុំកំណត់ជញ្ជាំងជានិមិត្ត គួរកំណត់តែថ្ម ។ កាលខាងក្នុងមិនមានទីតម្កល់ គួរតម្កល់និមិត្តទាំងឡាយទុកត្រង់យ៉មុខ ក៏បាន ។ បើយ៉មុខមិនល្អ គួរតម្កល់ថ្មនិមិត្តទាំងឡាយ ទុកក្នុងទីដែលទឹកធ្លាក់ចុះអំពីសំយាបផ្ទះខាងក្រៅ ហើយកំណត់និមិត្តសន្មតសីមា ។ កាលចងយ៉ាងនេះ រមែងជាសីមាទាំងខាងក្នុងទាំងខាងក្រៅកុដិជាទីពួនសម្ងំ ។

កាលទឹងចងលើប្រាសាទសោត កុំកំណត់ជញ្ជាំងជានិមិត្ត គប្បីតម្កល់ថ្មទាំងឡាយទុកខាងក្នុងហើយ សឹមសន្មតសីមាចុះ ។ បើខាងក្នុងប្រាសាទមិនល្អ គប្បីតម្កល់ថ្មទាំងឡាយត្រង់យ៉មុខ ហើយសន្មតចុះ ។ សីមាដែលសន្មតយ៉ាងនេះ រមែងតាំងនៅតែលើប្រាសាទប៉ុណ្ណោះ, មិនធ្លាក់ចុះទៅដល់ខាងក្រោម តែបើប្រាសាទដែលធ្វើតែត្រង់ស្នាមក្នុងសសរច្រើនដើម ជញ្ជាំងជាន់ក្រោមខ្ពស់ឡើងទៅជាប់នឹងឈើរតទាំងឡាយ ដោយប្រការដែលមានខាងក្នុងនៃនិមិត្តទាំងឡាយ សីមារមែងធ្លាក់ចុះដល់ខាងក្រោម ។ ចំណែកសីមាដែលចងលើផ្ទៃប្រាសាទសសរតែ

មួយ បើលើចុងសសរ មានឱកាសល្មមចុះភិក្ខុ ២១ រូបបាន រមែងធ្លាក់ចុះដល់ខាងក្រោម ។ បើតម្កល់ថ្មទាំងឡាយក្នុងទីជាដើមថា ក្តាររបៀងដែលលយចេញពីជញ្ជាំងប្រាសាទទៅ ហើយចងសីមាជញ្ជាំងប្រាសាទ រមែងនៅខាងក្នុងសីមា, ចំណែកទីសីមានោះ នឹងធ្លាក់ចុះដល់ខាងក្រោម ឬមិនធ្លាក់ចុះទៅ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។ កាលនឹងកំណត់ និមិត្តខាងក្រោមប្រាសាទសោត កុំកំណត់ជញ្ជាំង និងសសរឈើជានិមិត្ត តែនឹងកំណត់សសរសិលាដែលទប់ជញ្ជាំងទុកគួរ ។ សីមាដែលកំណត់យ៉ាងនេះ រមែងមានតែខាងក្នុងនៃសសរ ជើងរៀងដោយជុំវិញខាងក្រោមប្រាសាទ ។ តែបើជញ្ជាំងខាងក្រោម ប្រាសាទ ជារបស់ជាប់ដល់ផ្ទៃជាន់លើសីមា រមែងឡើងទៅដល់ជាន់លើប្រាសាទផង បើធ្វើនិមិត្តក្នុងទីដែលទឹកធ្លាក់ចុះអំពីសំយាបផ្ទះខាងក្រៅប្រាសាទ ប្រាសាទទាំងអស់តាំងនៅក្នុងសីមា ។

បើផ្ទៃខាងលើកំពូលភ្នំជាទីគួរដល់ឱកាស ល្មមចុះភិក្ខុ ២១ រូបបាន ចងសីមាលើផ្ទៃនោះ ដូចការចងលើថ្មដា; សូម្បីខាងក្រោមភ្នំសីមារមែងធ្លាក់ចុះទៅដល់ ដោយកំណត់នោះដូចគ្នា ។ សូម្បីលើភ្នំដែលមានសណ្ឋានដូចគល់ដើមត្នោត សីមាដែលចងទុកខាងលើ រមែងធ្លាក់ចុះទៅដល់ខាងក្រោមដូចគ្នា ។ ចំណែកភ្នំណា មានសណ្ឋានដូចផ្សិត ខាងលើមានឱកាសល្មមចុះភិក្ខុ ២១ រូបបាន ខាងក្រោមមិនមាន សីមា

ដែលចងលើភ្នំនោះ មិនធ្លាក់ចុះទៅខាងក្រោម ។ ដោយប្រការយ៉ាងនេះ ភ្នំមានសណ្ឋានដូចសម្ពោរ ឬមានសណ្ឋានដូចស្គរក៏ដោយ ខាងក្រោម ឬផ្ទៃកណ្តាលនៃភ្នំណា មិនមានផ្ទៃដីប៉ុនទំហំសីមា សីមាដែលចងលើភ្នំនោះ មិនធ្លាក់ចុះខាងក្រោម, ចំណែកភ្នំណាមានកំពូល ២ តាំងនៅជិតគ្នា លើកំពូលសូម្បីមួយ មិនល្មមជាប្រមាណនៃសីមា គួរកសាង ឬបំពេញត្រង់ចន្លោះកំពូលនៃភ្នំនោះឱ្យពេញ ធ្វើឱ្យជាប់ជាផែនដីតែមួយហើយ សីមសន្មតសីមាខាងលើ, កូនភ្នំមួយស្រដៀងពពារពស់ ខាងលើភ្នំនោះ ចងសីមាបាន ព្រោះ មានឱកាសបានប្រមាណ ជាសីមា; បើខាងក្រោមភ្នំនោះ មានជ្រោយអាកាស សីមាមិនធ្លាក់ចុះទៅ, តែបើត្រង់កណ្តាលជ្រោយអាកាសនោះ មានថ្មប្រហោង ប៉ុនខ្នាតសីមា សីមារមែងធ្លាក់ចុះទៅដល់ ។ ទាំងថ្មនោះ ក៏ជារបស់តាំងនៅក្នុងសីមាពិត, បើសូម្បីជញ្ជាំងនៃទីពួនសម្ងំខាងក្រោមភ្នំនោះ តាំងទល់ដល់កំពូល សីមារមែងធ្លាក់ចុះដល់ ទាំងខាងក្រោម ទាំងខាងលើ រមែងជាសីមាទាំងអស់ ។ តែបើផ្ទៃកក្នុងទីពួនសម្ងំខាងក្រោម នៅខាងក្រៅជួរនៃដែនជាទីកំណត់សីមា ទីនៅខាងលើសីមា មិនទៅដល់ខាងក្រៅ (នៃទីពួនសម្ងំ) បើសូម្បីផ្ទៃកក្រៅទីពួនសម្ងំ នៅខាងក្នុងជួរនៃដែនជាទីកំណត់សីមា ដែលនៅខាងលើនោះ សីមាមិនធ្លាក់ទៅដល់ខាងក្នុង (នៃទីពួនសម្ងំ) បើសូម្បីខាងលើភ្នំនោះ មានឱកាសជាទីកំណត់សីមាតូច ខាងក្រោមមានទីពួនសម្ងំ

ធំជាងឱកាសកំណត់សីមា សីមារមែងមានតែខាងលើប៉ុណ្ណោះ មិនធ្លាក់ចុះទៅដល់ខាងក្រោម តែបើទីពួនសម្ងំតូច ទំហំប៉ុនសីមាខ្នាតតូចបំផុត សីមាខាងលើធំ ។ សីមាដែលតាំងគ្របលើទីពួនសម្ងំទុកនោះ រមែងធ្លាក់ចុះទៅដល់ ។ បើទីពួនសម្ងំតូចពេកទៅ មិនបានខ្នាតសីមា សីមាក៏មានតែខាងលើប៉ុណ្ណោះ មិនធ្លាក់ចុះទៅខាងក្រោម, បើភ្នំមានសណ្ឋានដូចពពារពស់នោះ ធ្លាក់ចុះទៅឯង ពាក់កណ្ដាល ស្រួបបើបានប្រមាណសីមា ចំណែកដែលធ្លាក់ទៅខាងក្រៅ មិនជាសីមា ។ ចំណែកដែលមិនធ្លាក់ចុះទៅ បើបានប្រមាណសីមា ឋិតនៅជាសីមា ។

ខណ្ឌសីមាជាផ្ទៃដីទំនាប បំពេញ ( ដី ) ខណ្ឌសីមានោះ ធ្វើឱ្យមានផ្ទៃដីខ្ពស់ឡើង គង់ជាសីមាដូចដើម, ជនទាំងឡាយធ្វើផ្ទះក្នុងសីមា ផ្ទះនោះក៏នៅក្នុងសីមាផង, ជីកស្រះបោក្ខរណី ក្នុងសីមាសីមានោះ ក៏គង់ជាសីមានៅទុំះឯង ។ អន្លង់ទឹកហូរជន់លិចមណ្ឌលសីមាទៅ នឹងចង់ពានធ្វើសង្ឃកម្មក្នុងសីមា ក៏គួរ ។ ស្ទឹងមានឧម្មង្គនៅខាងក្រោមសីមា ភិក្ខុដែលមានឫទ្ធិ អង្គុយនៅក្នុងស្ទឹងមានឧម្មង្គនោះ បើស្ទឹងនោះហូរទៅមុនសីមាចង់ខាងក្រោយ, មិនញ៉ាំងកម្មឱ្យខូច ។ បើចង់សីមាមុន, ស្ទឹងហូរទៅខាងក្រោយ, ភិក្ខុនោះញ៉ាំងកម្មឱ្យខូច ។ មួយទៀត ភិក្ខុដែលស្ថិតនៅក្នុងខាងក្រោមផ្ទៃផែនដី រមែងញ៉ាំងកម្មឱ្យខូចដូចគ្នា ។ ក៏ដើមជ្រៃមាននៅក្នុងលានខណ្ឌសីមា ។ មែកនៃដើមជ្រៃនោះ ឬពួរជ្រៃដែល

លយចេញអំពីដើមជ្រៃនោះ ចាក់ចូលក្នុងផ្ទៃផែនដីនៃមហាសីមាក្តី ចាក់ចូលដើមឈើជាដើមដែលកើតក្នុងមហាសីមានោះក្តី, គប្បីជម្រះមហាសីមាឲ្យហ្មត់ចត់ហើយ សឹមធ្វើកម្ម ឬកាត់មែកនិងពួរជ្រៃទាំងនោះចេញធ្វើឲ្យតាំងនៅខាងក្រៅក៏បាន ។ ភិក្ខុដែលឡើងទៅលើមែកឈើជាដើមដែលមិនចាក់ចូលគ្នា គួរនាំមកចូលហត្ថបាស ។ ដោយប្រការយ៉ាងនោះ មែកនៃដើមឈើដែលកើតក្នុងមហាសីមាក្តី ពួរជ្រៃក្តី រមែងតាំងនៅក្នុងលានៃខណ្ឌសីមា តាមន័យដែលពោលហើយនុ៎ះឯង ។ គប្បីជម្រះសីមាឲ្យហ្មត់ចត់ហើយ សឹមធ្វើកម្ម ឬកាត់មែកនិងពួរជ្រៃទាំងនោះចេញធ្វើឲ្យតាំងនៅខាងក្រៅក៏បាន តាមន័យដែលពោលហើយនុ៎ះឯង ។ បើថា កាលសង្ឃកំពុងធ្វើកម្មក្នុងខណ្ឌសីមា ភិក្ខុរូបខ្លះអង្គុយនៅលើមែកឈើ ដែលឋិតនៅលើអាកាសលយចូលទៅក្នុងសីមា ជើងរបស់លោកដល់ផ្ទៃផែនដីក្តី ស្បង់ចីវររបស់លោកប៉ះត្រូវផ្ទៃផែនដីក្តី, មិនសមគួរធ្វើកម្ម ។ តែឲ្យលោកលើកជើងទាំង ២ និងស្បង់ចីវរឡើងចេញហើយធ្វើកម្ម គួរ ។ លក្ខណៈ នេះ បណ្ឌិតគប្បីជ្រាបសូម្បីតាមន័យមុន ។ ចំណែកសេចក្តីដែលប្លែកគ្នា មានដូចតទៅនេះ ៖

ឲ្យលោកលើកឡើងហើយ ធ្វើកម្មក្នុងខណ្ឌសីមានោះ មិនគួរត្រូវនាំមកចូលហត្ថបាសពិត ។ បើភ្នំដែលតាំងនៅខាងក្នុងសីមាខ្ពស់ឡើងទៅ ភិក្ខុដែលស្ថិតនៅលើភ្នំនោះត្រូវនាំមកចូលហត្ថបាស ។ សូម្បី

ក្នុងភិក្ខុដែលចូលទៅខាងក្នុងភ្នំដោយឫទ្ធិ ក៏មានន័យដូចគ្នា ។ ពិតមែន សីមាដែលសង្ឃចងប៉ុណ្ណោះ មិនគ្រប់ដណ្ដប់ដល់ប្រទេសដែលមិនបាន ប្រមាណ វត្ថុមិនរើសថា ប្រភេទណាដែលកើតក្នុងពទ្ធសីមា ចូលដោយ ការទាក់ទងជាមួយគ្នា ក្នុងទីណាទីមួយ រមែងរាប់ថា ជាសីមាទាំង អស់ ។

[១៥៥] វិនិច្ឆ័យក្នុងបទថា **តិយោជនបរមំ : ទំហំ ៣ យោជន៍យ៉ាងធំ** នេះថា សីមា ឈ្មោះថា មានទំហំ ៣ យោជន៍ យ៉ាងធំ ព្រោះមាន ៣ យោជន៍ ជាប្រមាណយ៉ាងធំ ។ ដែលសីមាមាន ៣ យោជន៍ យ៉ាងធំនោះ ។ សីមានោះ ភិក្ខុដែលនឹងសន្មតត្រូវស្ថិតនៅ កណ្ដាល សន្មតឱ្យមានចម្ងាយមួយយោជន៍កន្លះ ៗ ក្នុងទិសទាំង ៤ គឺ វាស់ពីទីដែលខ្លួនស្ថិតនោះចេញទៅ ។ តែបើស្ថិតនៅត្រង់ កណ្ដាល ហើយ វាស់ចេញទៅមួយទិស ៗ ៣ យោជន៍ ។ រមែងរួមជា ៦ យោជន៍ ។ ដូច្នេះ ប្រើមិនបាន ។ ភិក្ខុនឹងសន្មតសីមា ៤ ជ្រុងប៉ុនគ្នា ឬ៣ ជ្រុង គប្បីសន្មតឱ្យវាស់ពីមុំមួយទៅមុំមួយ បានចម្ងាយ ៣ យោជន៍ ។ ក៏បើឱ្យទីបំផុត ជុំវិញកន្លែងណាមួយលើស ៣ យោជន៍ទៅ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិផង មិនឈ្មោះថា សីមា ផង ។

## នទីបារសីមា

[១៥៦] វិនិច្ឆ័យក្នុងបទថា នទីបារំ : ត្រើយស្ទឹង នេះតទៅ ៖

ដែលហៅថា ប្រាំង ព្រោះហេតុថា បាំងទុក, សួរថា បាំងទុកនូវអ្វី ? ឆ្លើយថា បាំងទុកនូវស្ទឹង, ប្រាំងនៃស្ទឹង ឈ្មោះថា នទីបារា សេចក្តីថា ដែលសីមាគ្របដណ្តប់ប្រាំងស្ទឹងនោះ[១] ។ ក៏លក្ខណៈនៃស្ទឹងក្នុងបទថា នទីបារំ នេះ មានន័យដូចពោលហើយ ក្នុងនទីនិមិត្តនុ៎ះឯង ។

ពាក្យថា យត្ថស្ស ធុវនាវា វា : ស្ទឹងណា មានទូកទៅមកជានិច្ច មានសេចក្តីថា ក្នុងស្ទឹងណា មានទូកសញ្ចរទៅមកជានិច្ច ត្រង់កំពង់ទាំងឡាយ ដែលនៅកន្លែងចងសីមា, ទូកណា ដោយកំណត់យ៉ាងតូចបំផុត ល្មមនាំមនុស្សទៅបាន ៣ នាក់ទាំងអ្នកអុំ ក៏បើទូកនោះ គេ

---

១. ដីកានិងយោជនាពន្យល់ បារយតិ ថា អជ្ឈោត្ថរតិ និងថា ដែលជាបារា មិនមែនបារំ ដែលសំដៅយកត្រើយឯណោះ ក៏ព្រោះសម្លឹងយកសីមាសព្ទ ដូច្នោះ គួរប្រែថា សីមាឈ្មោះថា ឆ្លងកាត់ ក៏ព្រោះតែងឆ្លងកាត់ សួរថា តែងឆ្លងកាត់អ្វី ? ឆ្លើយថា តែងឆ្លងកាត់ស្ទឹង ។ សីមាឆ្លងកាត់ស្ទឹង ឈ្មោះនទីបារសីមា ។ នូវនទីបារសីមានោះ, អធិប្បាយថា នូវសីមាដែលឆ្លងកាត់ស្ទឹង ។ មួយទៀត បាលីត្រង់នេះជា នទីបារសីមំ ប៉ុន្តែ យុ. និងសី. ជា នទីបារំ សីមំ ដូចក្នុងអដ្ឋកថា ។

នាំទៅខាងលើ ឬខាងក្រោម ដោយករណីយកិច្ចយ៉ាងណាមួយ ដើម្បី

ត្រូវការនឹងត្រឡប់មកទៀតក្តី ត្រូវពួកចោរលួចទៅ តែគប្បីបានត្រឡប់មក ដោយពិតប្រាកដក្តី មួយទៀត ទូកណា ត្រូវព្យុះដាច់ខ្សែរលេកបន្សាត់ចេញទៅកណ្តាលស្ទឹង គប្បីនាំត្រឡប់មកវិញបានពិតប្រាកដក្តី ទូកនោះរមែងជាធុវនាវាដោយពិត ។ ទូកគេអូសឡើងគោក ទុកក្នុងកាលទឹកស្រកចុះក្តី ទូកដែលគេយកវត្ថុជាដើមថា កំបោរស និងជ័រផ្ទុកពេញចតទុកក្តី ចាត់ជាធុវនាវាបាន ។ បើជាទូកបែក ឬមានបន្ទះក្តារបែកចេញ រមែងមិនគួរ ។ តែព្រះមហាបទុមត្ថេរពោលថា សូម្បីបើថា ភិក្ខុទាំងឡាយខ្ចីទូកគេមកម្តងម្កាល ចតទុកក្នុងទីចងសីមា ហើយកំណត់និមិត្តទូកនោះចាត់ជាធុវនាវាដូចគ្នា ។

ក្នុងបទថា ធុវនាវា : **មានទូកទៅមកជានិច្ច** នោះ ព្រះមហាសុមត្ថេរពន្យល់ថា និមិត្តក្តី សីមាក្តី រមែងទៅដោយកម្មវាចា មិនបានទៅដោយទូកទេ, តែព្រះមានព្រះភាគទ្រង់អនុញ្ញាតធុវនាវាទុក, ព្រោះដូច្នោះ ត្រូវជាទូកប្រចាំជានិច្ច ទើបនឹងសមគួរ ។

ពាក្យថា ធុវសេតុ វា : **ឬមានស្ពានតាំងនៅជានិច្ច** មានសេចក្តីថា ស្ទឹងណា មានស្ពាន សម្រាប់ពួកមនុស្សធ្វើដំណើរច្នើរជើង ដែលធ្វើសម្រេចដោយឈើឃ្នាបគងគ្នា ឬរៀបដោយផែនក្តារក្តី មានស្ពានធំគួរដល់ការសញ្ចរនៃសត្វពាហនៈ មានដំរី និងសេះជាដើមក្តី ដោយហោចទៅ សូម្បីស្ពានដែលតូច ល្មមមនុស្សដើរទៅបានតែម្នាក់ ដែលគេ

កាត់ឈើធ្វើល្អមឱ្យជាមកឆ្លងទៅមករបស់មនុស្សទាំងឡាយ ក្នុងខណៈនោះឯង ក៏រាប់ថា មានស្ពានតាំងនៅជានិច្ចដែរ ។ តែបើសូម្បីយកដៃតោងផ្តៅនិងវល្លិជាដើម ដែលចងទុកខាងលើ ហើយនៅតែមិនអាចឆ្លងទៅតាមស្ពាននោះបាន, មិនគួរ ។

ពាក្យថា **ឯវរូបំ នទីបារសីមំ សម្មន្និតុំ : តថាគតអនុញ្ញាតឱ្យសន្មតស្ទឹងមានសភាពយ៉ាងនោះ ជានទីបារសីមាបាន** មានសេចក្តីថា ក្នុងស្ទឹងណាមានទូកប្រចាំ ឬស្ពានថាវរ មានប្រការដូចពោលហើយនេះ ក្នុងកំពង់ត្រង់ចំគ្នានោះឯង តថាគតអនុញ្ញាតឱ្យសន្មតនទីបារសីមាបែបនោះក្នុងស្ទឹងនោះបាន ។ បើទូកប្រចាំក្តី ស្ពាននៅប្រចាំក្តី មិនមានក្នុងកំពង់ត្រង់គ្នា ឡើងទៅខាងលើ ឬចុះទៅខាងក្រោម បន្តិច ទើបមាន សូម្បីយ៉ាងនេះ ក៏គួរ ។ តែព្រះករវិកតិស្សត្ថេរពោលថា សូម្បីក្នុងចម្ងាយត្រឹមតែមួយគាវុត មានទូកប្រចាំ ឬ ស្ពាននៅជាប្រចាំ ក៏គួរ ។

ក៏ឯភិក្ខុទាំងឡាយ កាលសន្មតនទីបារសីមានេះ គប្បីឈរត្រង់ប្រាំងមួយ កំណត់និមិត្តត្រង់ត្រើយស្ទឹងមកលើទឹក ហើយវិលទៅជុំវិញខនតាំងពីនិមិត្តនោះ គប្បីកំណត់និមិត្តត្រង់ត្រើយស្ទឹង ខាងក្រោមទឹក ក្នុងទីបំផុតនៃដែនកំណត់ប៉ុនទីដែលត្រូវការហើយកំណត់និមិត្តត្រង់ត្រើយស្ទឹង ក្នុងទីដែលត្រង់ចំគ្នានឹងត្រើយឯណោះ ។ តាំងពីនោះទៅ គប្បីកំណត់រៀង (លំដាប់គ្នា) ទៅ ដរាបដល់និមិត្តត្រង់ត្រើយស្ទឹង ដែលត្រង់ចំគ្នានឹង

និមិត្តដែលកំណត់ទុកជាដំបូងខាងលើទឹក ដោយអំណាចដែនកំណត់ប៉ុនទីដែលត្រូវការ ហើយត្រឡប់មកភ្ជាប់នឹងនិមិត្តដែលកំណត់ទុកដំបូង ។ លំដាប់នោះ គប្បីឱ្យភិក្ខុទាំងឡាយដែលស្ថិតនៅខាងក្នុងនិមិត្តទាំងពួងចូលហត្ថបាសហើយសន្មតសីមា ដោយកម្មវាចា ភិក្ខុដែលស្ថិតនៅក្នុងស្ទឹង សូម្បីមិនមក ក៏មិនធ្វើ ឱ្យខូចកម្ម ។ ក្នុងខណៈដែលសន្មតរួចស្រេច វៀរលែងតែស្ទឹងចេញ ទីខាងក្នុងនៃនិមិត្តទាំងឡាយ រមែងជាសីមាតែមួយ ទាំងត្រើយខាងនាយនិងត្រើយខាងអាយ ។ ចំណែកស្ទឹងមិនរាប់ថា ជាពទ្ធសីមា ព្រោះថា ស្ទឹងនោះ ជានទីសីមាផ្សេកមួយហើយ ។ បើថា ខាងក្នុងស្ទឹង មានកោះ ប្រាថ្នានឹងធ្វើកោះនោះទុកខាងក្នុងសីមា គប្បីកំណត់និមិត្តទាំងឡាយ ត្រង់ត្រើយដែលខ្លួនស្ថិតនៅ តាមន័យមុនទុំះឯង ហើយកំណត់និមិត្តត្រង់ចុងកោះ ទាំងត្រើយខាងនាយនិងត្រើយខាងអាយ លំដាប់នោះ គប្បីកំណត់និមិត្តត្រង់ត្រើយខាងនាយក្នុងទីដែលត្រង់គ្នានឹងនិមិត្តត្រង់ត្រើយខាងអាយនៃស្ទឹង តាំងពីនោះទៅគប្បីកំណត់រៀងលំដាប់គ្នាទៅដរាបដល់និមិត្ត ដែលត្រង់គ្នានឹងនិមិត្តដែលកំណត់ទុកជាដំបូងខាងលើទឹក តាមន័យមុនទុំះឯង លំដាប់នោះគប្បីកំណត់ និមិត្តត្រង់ចុងកោះទាំងត្រើយខាងនាយ និងត្រើយខាងអាយហើយត្រឡប់មកភ្ជាប់នឹងនិមិត្តដែលកំណត់ទុកជាទីមួយ លំដាប់នោះគប្បីឱ្យភិក្ខុទាំងឡាយត្រង់ត្រើយទាំង ២ និងក្នុងកោះចូលហត្ថបាសគ្នា

ទាំងអស់ហើយសន្មត សីមាដោយកម្មវាចា ។

ភិក្ខុដែលស្ថិតនៅក្នុងស្ទឹង សូម្បីមិនមក ក៏មិនធ្វើឱ្យខូចកម្ម ។ ក្នុងខណៈ ដែលសន្មតរួចស្រេច វៀរតែស្ទឹងចេញ, រួមមកខាងក្នុងនៃនិមិត្តទាំងឡាយនៃត្រើយទាំង២ និងស្ទឹង ព្រមទាំងកោះ រមែងជាសីមាតែមួយ ។ ចំណែកស្ទឹងនៅជានទីសីមា ។ ក៏ឯបើកោះវែងលើសជាងដែនកំណត់សីមានៃវត្តទៅខាងលើទឹក ឬខាងក្រោម ទឹកកាលជាដូច្នោះ គប្បីកំណត់និមិត្តចុងកោះត្រើយក្នុងដែលត្រង់ចំគ្នានឹងនិមិត្តនៃដែនកំណត់សីមាតាំងពីនោះទៅ កាលនឹងព័ទ្ធជុំវិញក្បាលកោះ ត្រូវកំណត់និមិត្តចុងកោះត្រើយក្រៅ ដែលត្រង់គ្នានឹងនិមិត្តចុងកោះត្រើយក្នុងទៀត ។ តពីនោះទៅ គប្បីចាប់ផ្តើមតាំងពីនិមិត្តដែលនៅត្រង់ចំមុខគ្នានឹងត្រើយខាងនាយ, កំណត់និមិត្តត្រង់ត្រើយខាងនាយ និងនិមិត្តចុងកោះទាំងត្រើយក្រៅនិងត្រើយក្នុងរួចស្រេចតាមន័យមុននុ៎ះឯង ហើយសឹមធ្វើការភ្ជាប់នឹងនិមិត្ត ដែលកំណត់ទុកជាទីមួយ សីមាដែលកំណត់និមិត្តសន្មតយ៉ាងនេះ រមែងមានសណ្ឋានដូចភ្នំ ។ តែបើកោះវែងលើសជាងដែនកំណត់ សីមានៃវិហារ ទាំងខាងលើទឹក ទាំងខាងក្រោមទឹកសោត, កាលកំណត់និមិត្តព័ទ្ធជុំវិញក្បាលកោះទាំង ២ តាមន័យមុននុ៎ះឯង ហើយសឹមធ្វើការភ្ជាប់និមិត្ត ។ សីមាដែលកំណត់សន្មតយ៉ាងនេះ រមែងមានសណ្ឋានដូចសម្ភោរ ។ បើជាកោះតូចនៅខាងក្នុងនៃដែនកំណត់សីមាវិហារ គប្បី

កំណត់និមិត្តទាំងឡាយ តាមន័យដំបូងនៃន័យទាំងពួង ។ សីមាដែលកំណត់សន្ធតយ៉ាងនោះ រមែងមានសណ្ឋានដូចស្គរ ។

ការសន្ធតសីមា ចប់

## ការសន្ធតរោងនូវឧបោសថជាដើម

[១៥៧] បទថា អនុបរិវេណិយំ : រាល់ ៗបរិវេណ បានដល់បរិវេណនោះ ៗ ក្នុងវត្តមួយកន្លែង ។

បទថា អសង្កេតេន : ដោយមិនបានកំណត់ទី បានដល់ មិនធ្វើទីសង្កេតទុក ។

[១៥៨] ពីរបទថា ឯកំ សមូហនិត្វា : ឱ្យដករោងឧបោសថមួយចេញ បានដល់ ដកចេញដោយកម្មវាចា ។

ពាក្យថា យតោ បាដិមោក្ខំ សុណាតិ : ស្តាប់បាតិមោក្ខក្នុងទីណា មានសេចក្តីថា ភិក្ខុអង្គុយក្នុងហត្ថបាសរបស់ភិក្ខុទាំងឡាយ ស្តាប់បាតិមោក្ខ ព្រោះហេតុណា ព្រោះហេតុនោះ ឧបោសថជាការដែលលោកធ្វើហើយពិត ។

ក៏ពាក្យថា យតោ បាដិមោក្ខំ សុណាតិ នេះ ព្រះមានព្រះភាគ

ត្រាស់ទុកជាប់នឹងរឿង ។ ដល់កាលភិក្ខុអង្គុយហើយ ក្នុងហត្ថបាសសូម្បីមិនស្តាប់ឧបោសថក៏ជាការធ្វើហើយ ។

[១៥៩] ពាក្យថា **និមិត្តា កិត្តេតព្វា : ត្រូវកំណត់និមិត្តទាំងឡាយជាមុន** មានសេចក្តីថា នឹងកំណត់និមិត្ត ប្រភេទណាមួយ មានថ្មឥដ្ឋ កំណាត់ឈើ និងបង្គោលជាដើម តូចក្តី ធំក្តី ធ្វើឱ្យជាគ្រឿងសំគាល់នៃរបៀងនៃរោងឧបោសថ ទុកកណ្តាលវាល ឬក្នុងទីណាមួយ មានរោងមូលជាដើម រមែងគួរ ។

ម្យ៉ាងទៀត ពាក្យថា **និមិត្តា កិត្តេតព្វា** មានសេចក្តីថា គប្បីកំណត់វត្ថុទាំងឡាយ ដែលប្រើជានិមិត្តបានក៏ដោយ ដែលប្រើជានិមិត្តមិនបានក៏ដោយ ជានិមិត្តដើម្បីដឹងដែនកំណត់ ។

[១៦០] ក្នុងពាក្យថា **ថេរេហិ ភិក្ខូហិ បឋមតរំ សន្និបតិតុំ : ឱ្យភិក្ខុទាំងឡាយជាថេរៈប្រជុំគ្នាមុន** នេះ មានវិនិច្ឆ័យថា បើថា ព្រះមហាថេរៈមិនមកមុន លោកក៏ត្រូវអាបត្តិទុក្កដ ។

[១៦១] ក្នុងពាក្យថា **សព្វេហេវ ឯកជ្ឈំ សន្និបតិត្វា ឧបោសថោ កាតព្វោ : ត្រូវភិក្ខុទាំងឡាយទាំងអស់នោះប្រជុំគ្នាធ្វើឧបោសថជាមួយគ្នា** នេះ មានវិនិច្ឆ័យថា បើអាវាសចាស់ មាននៅត្រង់កណ្តាលវត្ត ។ និងក្នុងអាវាសចាស់នេះ មានទីអង្គុយល្មម ដល់ភិក្ខុទាំង

ឡាយ គប្បីប្រជុំគ្នាធ្វើឧបោសថក្នុងអាវាសនោះ ។ បើអាវាសចាស់ទ្រុឌទ្រោមផង ចង្អៀតផង អាវាសដទៃដែលសាងក្រោយមិនចង្អៀត គប្បីធ្វើឧបោសថក្នុងអាវាសនោះ ។

សូម្បីក្នុងពាក្យថា យត្ថ វា បន ថេរោ ភិក្ខុ វិហរតិ : តែថា ភិក្ខុជាថេរៈ នៅក្នុងទីណា ត្រូវសង្ឃប្រជុំគ្នាធ្វើឧបោសថក្នុងទីនោះនេះ មានវិនិច្ឆ័យថា បើវត្តរបស់ព្រះថេរៈល្មមដល់ភិក្ខុទាំងពួង ជាទីសប្បាយ គប្បីធ្វើឧបោសថក្នុងវត្តនោះ ។ តែបើវត្តនោះនៅក្នុងប្រទេសដែលមិនរៀបរយខាងចុងដែន, គប្បីប្រាប់ដល់ព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន វត្តរបស់លោកជាវត្តដែលមិនសប្បាយទីនេះ មិនមានឱកាសសម្រាប់ភិក្ខុទាំងអស់ ទីវត្តឯណោះមានឱកាស លោកសមគួរនឹងទៅទីវត្តនោះ" ។ បើថា ព្រះថេរៈមិនមក គប្បីនាំឆន្ទៈនិងបារិសុទ្ធិរបស់លោកមក ហើយធ្វើឧបោសថ ក្នុងស្ថានទីសប្បាយល្មមដល់ភិក្ខុទាំងពួង ។

[១៦២] បទថា អន្ធកវិន្ទំ : ជាវត្តដែលបានជួបមនុស្សខ្វាក់ មានសេចក្តីថា វត្តឈ្មោះអន្ធកវិន្ទៈ ឆ្ងាយពីក្រុងរាជគ្រឹះប្រមាណ ៣ គាវុតប៉ុណ្ណោះ ព្រះថេរៈអាស្រ័យនៅក្នុងវត្តនោះ មកអំពីអន្ធកវិន្ទវិហារនោះ កាន់ក្រុងរាជគ្រឹះ ដើម្បីធ្វើឧបោសថ ។ អធិប្បាយថា ពិតមែនមហាវិហារ ១៨ កន្លែង ជុំវិញក្រុងរាជគ្រឹះមានសីមាតែមួយរួមគ្នាទាំង

អស់សីមា នៃមហាវិហារទាំងនោះ ព្រះធម្មសេនាបតីចង់ ព្រោះហេតុនោះ ព្រះមហាកស្សបត្ថេរ ទើបត្រូវមក ដើម្បីឱ្យសាមគ្គីដល់សង្ឃក្នុងវេឡុវ័ន ។

ពីរបទថា នទី តរន្តោ : ឆ្លងស្ទឹង បានដល់ ឆ្លងនូវស្ទឹងឈ្មោះសិប្បិនិយៈ ។

ពាក្យថា មនំ វុឡ្ហោ អហោសិ : ត្រូវទឹកកួចទៅបន្តិច មានសេចក្ដីថា បានជាអ្នកមានភាវៈដែលទឹកគួចទៅបន្តិច ។

បានឮថា ស្ទឹងនោះហូរចុះមកអំពីភ្នំគិជ្ឈកូដ ហូរទៅដោយក្រសែដែលហូរត្របាញ់ ព្រះថេរៈមិនទាន់ដាក់ចិត្តដល់ទឹកក្នុងស្ទឹងនោះដែលកំពុងហូរត្របាញ់ ទើបបានជាអ្នកត្រូវទឹកផាត់ទៅបន្តិច តែមិនអណ្ដែតទេ ចីវរទាំងឡាយរបស់លោកត្រូវទឹកបន្សាត់ ទើបសើម ។

កម្មវាចាមុន រមែងមិនគួរដល់ភិក្ខុទាំងឡាយ ចាប់ផ្ដើមតាំងពីកាលដែលកើតកម្មវាចានេះថា សម្មតា សីមា សង្ឃេន តិចីវរេន អវិប្បវាសោ ឋបេត្វា គាមញ្ច គាមូបចារញ្ច : សង្ឃបានសន្មតសីមានេះ ឱ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុក និងឧបចាររបស់ស្រុកចេញហើយ ។ កម្មវាចាក្រោយនេះប៉ុណ្ណោះ រមែងជារបស់ថាវរៈ (មាំមួន) ។ តែកម្មវាចាក្រោយនេះ មិនគួរដល់ នាង

ភិក្ខុនីទាំងឡាយទេ កម្មវាចាមុនប៉ុណ្ណោះ ទើបគួរ ។ ព្រោះហេតុអ្វី ? ព្រោះថា ភិក្ខុនីសង្ឃរមែងនៅខាងក្នុងស្រុក ។ បើថា គប្បីជាដូច្នោះសោត, ភិក្ខុនីសង្ឃនោះ មិនគប្បីបានសេចក្ដីបរិហារត្រៃចីវរ ដោយកម្មវាចាក្រោយនោះ, តែការបរិហារ របស់ភិក្ខុសង្ឃនោះមាន ព្រោះហេតុនោះ កម្មវាចាមុននុ៎ះឯង រមែងគួរ ។ ពិតមែន សីមាទាំង ២ រមែងបានដល់ ភិក្ខុនីសង្ឃ ។ ក្នុងសីមានៃភិក្ខុនីសង្ឃនោះ ភិក្ខុនី ទាំងឡាយនឹងសន្មតសីមាគ្របលើសីមារបស់ភិក្ខុសង្ឃទាំងឡាយក្ដី នឹងសន្មត ទុកខាងក្នុងសីមារបស់ភិក្ខុទាំងឡាយនោះក្ដី រមែងគួរ ។ សូម្បីក្នុងការដែលភិក្ខុទាំងឡាយ សន្មតសីមាគ្របលើសីមារបស់ភិក្ខុនី ក៏មានន័យដូចគ្នា ។

ព្រោះថា ភិក្ខុនិងភិក្ខុនី ២ ចំណែកនោះ ជាគណៈបូរកៈ ក្នុងកម្មរបស់គ្នានិងគ្នាមិនបាន មិនធ្វើកម្មវាចាឱ្យជាពួក ។ ក៏ក្នុងពាក្យថា **ឋបេត្វា គាមញ្ច គាមូបចារញ្ច** នេះ បណ្ឌិតគប្បីជ្រាបថា សូម្បីនិគមនិងនគរក៏សង្គ្រោះដោយ **គាម** ស័ព្ទនុ៎ះឯង ។

ឧបចារស្រុកនោះ បានដល់ របងនៃស្រុកដែលព័ទ្ធជុំវិញ ។ ឱកាសនៃរបងរបស់ស្រុកដែលឥតរបង ។ ភិក្ខុដែលទ្រទ្រង់ត្រៃចីវរ រមែងមិនបានបរិហារអធិដ្ឋានក្នុងឧបចារស្រុកទាំងនោះ ។ អវិប្បវាសសីមារបស់ភិក្ខុទាំងឡាយ រមែងមិនគ្របលើស្រុក និងឧបចារស្រុកដោយប្រការដូច្នេះ ។ សមានសំវាសកសីមាប៉ុណ្ណោះ រមែងគ្របដណ្ដប់

ដល់ ។ ក៏បណ្តាសីមា ២ យ៉ាងនេះ សមានសំវាសកសីមា រមែងទៅតាមធម្មតារបស់ខ្លួន ។ ចំណែកអវិប្បវាសសីមា រមែងទៅចំពោះក្នុងទីដែលសមានសំវាសកសីមាទៅដល់ ។ ទាំងការកំណត់និមិត្តរបស់អវិប្បវាសសីមានោះ នឹងមានតែមួយផ្នែក ក៏ទេ ។ ក្នុងសីមា ២ ប្រភេទនោះ បើក្នុងវេលាសន្មតអវិប្បវាសសីមា មានស្រុក, អវិប្បវាសសីមានោះ រមែងមិនគ្របដណ្តប់ដល់ស្រុកនោះ ។ មួយទៀត បើសន្មតសីមាហើយ ស្រុកទើបតាំងនៅជាខាងក្រោយ សូម្បីស្រុកនោះ ដូចស្រុកដែលតាំងចុះខាងក្រោយ រមែងរាប់ថា ជាសីមាផង យ៉ាងណា សូម្បីប្រទេសនៃស្រុកដែលតាំងចុះមុន ពង្រីកទំហំចេញទៅក្នុងខាងក្រោយ រមែងរាប់ជាសីមាផង ក៏យ៉ាងនោះ ។ សូម្បីបើក្នុងវេលាសន្មតសីមា ផ្ទះទាំងឡាយគេធ្វើទុករួចស្រេចហើយ ទាំងសេចក្តីចងចិត្តថា យើងទាំងឡាយនឹងចូលទៅ ក៏មាន តែមនុស្សទាំងឡាយមិនចូលទៅក្តី បោលស្រុកចាស់ព្រមទាំងផ្ទះផង ទៅក្នុងទីដទៃចេញក្តី ។ ស្រុកនោះមិនចាត់ជាស្រុកឡើយ សីមារមែងគ្របដណ្តប់ដល់ ។ តែបើសូម្បីត្រកូលមួយដែលចូលទៅហើយក្តី ដែលមកហើយក្តី មាន ស្រុកនោះគង់ជាស្រុក សីមារមែងមិនគ្របដណ្តប់ដល់ ។

## វិធីដកសីមា

[១៦៣] វិនិច្ឆ័យក្នុងពាក្យថា ឯវញ្ច បន ភិក្ខវេ តិចីវរេន អវិប្បវាសោ សម្មន្និតព្វោ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យដកយ៉ាងនេះ នេះតទៅ ៖

ភិក្ខុដែលប្រាថ្នានឹងដកគប្បីស្គាល់វត្ត ។ វត្តក្នុងការដកនោះដូច្នេះ ភិក្ខុដែលឈរនៅក្នុងខណ្ឌសីមា មិនគប្បីដកអវិប្បវាសសីមា, ឈរក្នុងអវិប្បវាសសីមា មិនគប្បីដកសូម្បីនូវខណ្ឌសីមាដូចគ្នា ។ តែត្រូវឈរក្នុងខណ្ឌសីមា ដកខណ្ឌសីមានោះឯង ។ ត្រូវឈរក្នុងសីមាក្រៅពីនេះ ដកសីមាក្រៅពីនេះ ដូចគ្នា ។

ភិក្ខុទាំងឡាយ រមែងដកសីមាដោយហេតុ ២ ប្រការ គឺ ដើម្បីនឹងធ្វើសីមា ដែលតូចតាមប្រក្រតីឱ្យធំឡើងទៀត ដើម្បីប្រយោជន៍ដល់ការពង្រីកអាវាសចេញទៅខ្លះ ។ ដើម្បីបង្រួមសីមាដែលធំដោយប្រក្រតីឱ្យតូចចុះទៀត ដើម្បីប្រយោជន៍ដល់ការឱ្យឱកាសនៃវិហារដល់ភិក្ខុពួកដទៃខ្លះ ។

បណ្ដាសីមា ២ ប្រភេទនោះ បើភិក្ខុទាំងឡាយស្គាល់ទាំងខណ្ឌសីមា និងអវិប្បវាសសីមាសោត លោកនឹងអាចដើម្បីដក និងដើម្បីចង ។ មួយទៀត ស្គាល់ខណ្ឌសីមា សូម្បីមិនស្គាល់ អវិប្បវាសសីមា នឹងអាចដើម្បីដក និងដើម្បីចង ។ មិនស្គាល់ខណ្ឌសីមា ស្គាល់តែ

អវិប្បវាសសីមាប៉ុណ្ណោះ ទឹងឈរក្នុងទីដែលប្រាសចាកសេចក្ដីរង្កៀស មានលានចេតិយ លានពោធិព្រឹក្ស និងរោងឧបោសថជាដើមហើយ ទីខ្លះក៏អាចដើម្បីដកបាន ។ តែទឹងមិនអាចដើម្បីចងវិញបានឡើយ ។ បើទឹងគប្បីចងសោត ទឹងគប្បីធ្វើការទម្លាយសីមា ធ្វើវត្តឱ្យប្រើការមិនបាន ព្រោះហេតុនោះ ភិក្ខុដែលមិនស្គាល់ មិនគប្បីដក ។ ចំណែកភិក្ខុពួកណាមិនស្គាល់សីមាទាំង ២, ភិក្ខុទាំងនោះ មិនអាចដើម្បីដក និងមិនអាចដើម្បីចង ដោយពិត ។ ពិតមែន ដែលឈ្មោះថា សីមានេះ រមែងមិនជាសីមាដោយកម្មវាចាខ្លះ ដោយសេចក្ដីសាបសូន្យនៃសាសនាខ្លះ និងភិក្ខុទាំងឡាយអ្នកមិនស្គាល់សីមា មិនអាចធ្វើកម្មវាចា ព្រោះដូច្នោះ ភិក្ខុដែលមិនស្គាល់សីមា មិនគប្បីដកសីមា ។ សីមានោះ ដែលភិក្ខុស្គាល់ល្អប៉ុណ្ណោះ គប្បីដកផង គប្បីចងផង ។

វិធីដកសីមា ចប់

# ពណ៌នាអពទ្ធសីមា

[១៦៤] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសមានសំវាស និងភាពជាអ្នកមានឧបោសថតែមួយរួមគ្នា ជាប់ដោយពទ្ធសីមាយ៉ាងនេះហើយ ឥឡូវនេះ ទឹងទ្រង់សម្ដែងសមានសំវាស និងភាពជាអ្នកមានឧបោសថតែមួយរួមគ្នានោះ ក្នុងឱកាសទាំងឡាយ សូម្បីដែលមិនបានចងសីមា ទើបត្រាស់ពាក្យថា "អសម្មតាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ យា តស្ស គាមស្ស វា គាមសីមា និគមស្ស វា និគមសីមា អយំ តត្ថ សមានសំវាសា ឯកុបោសថា : ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលទៅអាស្រ័យស្រុកណាក្ដី និគមណាក្ដី ហើយនៅក្នុងសីមាដែលសង្ឃមិនបានសន្មត មិនបានតាំងទុកហើយ សីមាណា ដែលជាគាមសីមារបស់ស្រុកនោះក្ដី សីមាណាដែលជានិគមសីមារបស់និគមនោះ សីមានេះ ហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងស្រុកឬនិគមនោះ" ។

វិនិច្ឆ័យក្នុងពាក្យនោះ បទថា អដ្ឋបិតាយ : មិនបានតាំងទុកហើយ បានដល់ មិនបានកំណត់ ។ ក៏សូម្បីនគរ រមែងជាការទ្រង់កាន់

យកហើយ ដោយ គាម ស័ព្ទ ក្នុងពាក្យថា គាមំ វា និគមំ វា : ស្រុកណាក្តី និគមណាក្តី នេះ ។

បណ្តាគាមសីមានិងនិគមសីមានោះ លោកអ្នកគ្រប់គ្រងស្រុកនោះ រមែងបានពលីក្នុងប្រទេសប៉ុនណា ប្រទេសប៉ុណ្ណោះ ទោះតូចឬធំក៏ដោយ រមែងដល់ការរាប់ថា គាមសីមាទាំងអស់ ។ សូម្បីក្នុងនគរសីមា និងនិគមសីមា ក៏ន័យនេះឯង ។

ព្រះរាជាទ្រង់កំណត់ប្រទេសឯណាមួយ ក្នុងគាមខេត្តមួយប៉ុណ្ណោះ ថា នេះចូរជាវិសុំគាម ព្រះរាជទានដល់បុគ្គលខ្លះ ប្រទេសសូម្បីនោះ រមែងជាវិសុំគាមសីមាពិត ។ ព្រោះហេតុនោះ វិសុំគាមសីមានោះផង គាមសីមា នគរសីមា និង និគមសីមាតាមប្រក្រតីក្រៅនេះផង រមែងប្រាកដដូចគ្នានឹងពទ្ធសីមាដែរ ។ តែសីមាទាំងនេះ គ្រាន់តែមិនបានឃុំគ្រងការនៅប្រាសចាកត្រៃចីវរតែម៉្យាងប៉ុណ្ណោះ ។

ពណ៌នាអពទ្ធសីមា ចប់

## ពណ៌នាសត្តព្ភន្តរសីមា

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកំណត់សីមា ដល់ភិក្ខុដែលនៅក្នុងស្រុកយ៉ាងនេះហើយ ឥឡូវនេះ នឹងទ្រង់សម្តែង សូម្បីដល់ភិក្ខុដែល

នៅក្នុងព្រៃ ទើបត្រាស់ពាក្យថា **អគាមកេ ចេ** ជាដើម ។

វិនិច្ឆ័យក្នុងពាក្យនោះ បទថា **អគាមកេ ចេ : មិនមែនស្រុក** បានដល់ ប្រទេសនៃព្រៃដែលមិនបានកំណត់ដោយគាមសីមា និគមសីមា និងនគរសីមា ។

មួយទៀត បទថា **អគាមកេ ចេ** មានសេចក្តីថា ភិក្ខុរមែងនៅក្នុងព្រៃស្រោង ដូចព្រៃឈ្មោះថា វិជ្ឈាដវី, គ្រានោះ ៧ អព្ភន្តរដោយជុំវិញ អំពីឱកាសដែលភិក្ខុនោះឈរ ជាសមានសំវាសកសីមា ។ សីមានេះ រមែងបានរក្សាការនៅ ប្រាសចាកត្រៃចីវរផង ។

បណ្តា ៧ សត្តព្ភន្តរនោះ អព្ភន្តរ ១ ប្រមាណ ២៨ ហត្ថ ។ ៧ អព្ភន្តរដោយជុំវិញ នៃសង្ឃដែលតាំងនៅត្រង់កណ្តាល ក៏ត្រូវជា ១៤ អព្ភន្តរ ដោយវាស់កាត់បន្ទូត (ពីជាយសងខាងសីមា) ។ បើសង្ឃ ២ ពួកធ្វើវិន័យ កម្មផ្សេងគ្នា ត្រូវវៀរ ៧ អព្ភន្តរមួយផ្សេងទៀត ទុកក្នុងចន្លោះនៃ ៧ អព្ភន្តរទាំង ២ ដើម្បីប្រយោជន៍ដល់ឧបចារៈ ។

សត្តព្ភន្តរសីមាកថាដ៏សេស គប្បីកាន់យកតាម ន័យដែលពោលហើយក្នុងវណ្ណនានៃឧទ្ទោសិតសិក្ខាបទ ក្នុងមហាវិភង្គ ។

ពណ៌នាសត្តព្ភន្តរសីមា ចប់

# ពណ៌នាឧទកុក្ខេបសីមា

ពាក្យថា សព្វា ភិក្ខវេ នទី អសីមា : ម្នាលភិក្ខុទាំងឡាយ ស្ទឹងទាំងអស់មិនមែនជាសីមា មានសេចក្តីថា ស្ទឹងប្រភេទណាមួយ ដែលបានលក្ខណៈនៃស្ទឹង សូម្បីភិក្ខុកំណត់និមិត្តធ្វើហើយដោយតាំងចិត្តថា យើងទាំងឡាយធ្វើស្ទឹង នេះឱ្យជាពទ្ធសីមា ដូច្នេះ រមែងមិនជាសីមាឡើយ ។ តែស្ទឹងនោះ ក៏ដូចគ្នានឹងពទ្ធសីមា ដោយសភាពរបស់ខ្លួនប៉ុណ្ណោះ ទីងធ្វើសង្ឃកម្ម ទាំងពួងក្នុងស្ទឹងនេះ រមែងគួរ សូម្បីក្នុងសមុទ្រ និងជាតស្រះ ក៏មានន័យដូចគ្នា ។

ក៏បណ្តាសមុទ្រនិងជាតស្រះនេះ ដែលឈ្មោះថា ជាតស្រះជាទីដែលអ្នកណាម្នាក់មិនបានជីកទុក ជាបឹងដែលកើតឯង ពេញដោយទឹកដែលមកបានជុំវិញ ។

ព្រះមានព្រះភាគកាលទ្រង់ហាមនូវស្ទឹង សមុទ្រ និងជាតស្រះ ជាពទ្ធសីមាយ៉ាងនោះហើយ កាលនឹងទ្រង់សម្តែងកំណត់នៃអពទ្ធសីមាក្នុងស្ទឹង សមុទ្រ និងជាតស្រះទាំងនោះទៀត ទើបត្រាស់ពាក្យថា នទិយា វា ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ក្នុងទីមានស្ទឹងជាដើម ជាដើម ។

វិនិច្ឆ័យក្នុងពាក្យនោះ ។ ពាក្យថា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា : ទីណាដែលបុគ្គលកំណត់ ដោយសាចទឹករបស់មជ្ឈិមបុរសដោយជុំវិញ មានសេចក្តីថា ស្ថានទីណា កំណត់ដោយក្បង់ទឹក សាចដោយជុំវិញនៃបុរសដែលមានកម្លាំងកណ្តាល គឺ បុរសដែលមានកម្លាំងកណ្តាល ក៏ទឹកដែលភិក្ខុនឹងគប្បីក្បង់សាច យ៉ាងណា ? អ្នកលេងអន្ទាក់បោះគ្រាប់អន្ទាក់ យ៉ាងណា មជ្ឈិមបុរស គប្បីយកដៃក្បង់ទឹក ឬក្តាប់ខ្សាច់បាចទៅ ដោយកម្លាំងទាំងអស់ ដូច្នោះ ។ ទឹកឬខ្សាច់ដែលបាចទៅ យ៉ាងនោះ ធ្លាក់ចុះក្នុងឱកាសណា ឱកាសនេះ ជាឧទកុក្ខេប ១ ។ ភិក្ខុដែលលះហត្ថបាស តាំងនៅខាងក្នុងឧទកុក្ខេបនោះ រមែងធ្វើកម្មឱ្យខូច ។ បរិស័ទពង្រីកចេញត្រឹមណា សូម្បីសីមា រមែងពង្រីកចេញទៅត្រឹមនោះ ។ ចំពោះតែឧទកុក្ខេប ១ អំពីទីបំផុតដោយជុំវិញនៃបរិស័ទជាប្រមាណ ។

សូម្បីក្នុងជាតស្រះនិងសមុទ្រ ក៏ន័យនេះឯង ក៏ឯបណ្តាស្ទឹង ជាតស្រះ និងសមុទ្រទាំងនេះ បើស្ទឹងមិនវែងពេកទេ សង្ឃអង្គុយនៅក្នុងទីទាំងពួង តាំងពីដើមទឹកដរាបដល់ចុងទឹក ដែលឈ្មោះថា ការធ្វើសីមាដោយឧទកុក្ខេប រមែងមិនមាន, សូម្បីស្ទឹងទាំងអស់ រមែងល្មមគ្រប់គ្រាន់ដល់ភិក្ខុទាំងនោះហើយ ។

ក៏ពាក្យណា ដែលព្រះមហាសុមត្ថេរពោលថា ស៊ឹងដែលហូរត្រឹមតែ ១ យោជន៍ ៗ សូម្បីក្នុងស៊ឹងនោះ ត្រូវលះកន្លះយោជន៍ខាងលើចេញ ធ្វើកម្មក្នុងកន្លះយោជន៍ខាងក្រោម ទើបគួរ ដូច្នេះ ៗ ពាក្យនោះព្រះមហាបទុមត្ថេរជំទាស់ហើយ ៗ

ក្នុងមហាអដ្ឋកថា ពោលថា ទីប្រមាណនៃស៊ឹង ព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា “ភិក្ខុនីបិទបាំងមណ្ឌល ៣ ហើយឆ្លងឡើងក្នុងទីណាមួយ ស្បង់នៃភិក្ខុនីនោះទទឹកបានទីនោះ ហៅថា ស៊ឹង”[១] តែ ១ យោជន៍ ឬកន្លះយោជន៍ មិនបានត្រាស់ទុកទេ ព្រោះហេតុនោះ ស៊ឹងណាមានលក្ខណៈដូចពោលហើយក្នុងកាលមុន ដោយអំណាចនៃសូត្រនេះនឹងធ្វើសង្ឃកម្មតាំងពីដើម ទឹកនៃស៊ឹងនោះ រមែងគួរ ៗ តែបើភិក្ខុច្រើនសន្ទឹកសន្ទប់នឹងបែកគ្នា ធ្វើកម្មក្នុងស៊ឹងនេះសោត, លោកទាំងពួងគប្បីវៀរឧទកុក្ខេបដទៃ ទុកក្នុងចន្លោះដែនកំណត់នៃឧទកុក្ខេបរបស់ខ្លួន និងរបស់ភិក្ខុពួកដទៃ ដើម្បីប្រយោជន៍ដល់សីមន្តរិក វៀរទុកលើសជាងឧទកុក្ខេប ១ នោះ គួរពិត ៗ តែតិចជាងនោះ មិនគួរ ៗ

ក្នុងជាតស្រះ និងសមុទ្រ ក៏ន័យនេះឯង ក៏ឯភិក្ខុទាំងឡាយនាំគ្នាទៅដោយគិតថា យើងនឹងធ្វើសង្ឃកម្មក្នុងស៊ឹង បើស៊ឹងជន់ឡើងពេញស្មើមាត់ច្រាំង នឹងត្រូវស្លៀកសំពត់ងូតទឹក ក៏បាន គប្បីធ្វើកម្មក្នុងស៊ឹងនុ៎ះឯង ៗ បើមិនអាច, គ្រាន់តែស្ថិតនៅក្នុងទូកក៏បាន ធ្វើចុះ តែមិនគួរធ្វើ

ក្នុងទូកដែលកំពុងរសាត់អណ្តែត ។ ព្រោះហេតុអ្វី ? ព្រោះថា ប្រវែង

១. វិន. ភិក្ខុនី. សង្ឃាទិសេស. ៥. ៤៤/៥៤ ។

ឧទកុក្ខេបមួយប៉ុណ្ណោះ ជាប្រមាណនៃសីមា ទូករមែងនាំសង្ឃទុំះឯង ឱ្យកន្លងហួសសីមានោះទៅ; កាលជាដូច្នោះ ញត្តិទឹងនៅក្នុងសីមាមួយ អនុស្សាវនាទឹងនៅក្នុងសីមាមួយទៀត ព្រោះហេតុនោះ គប្បីចតទូកទុកទឹងបង្គោល ឬបោះដែកយុថ្កា ឬចងត្រង់ដើមឈើដែលកើតខាងក្នុងស្ទឹង ធ្វើកម្ម ។ ស្ថិតនៅលើរានដែលចងឡើងខាងក្នុងស្ទឹងក្តី លើដើមឈើដែលកើតក្នុងខាងក្នុងស្ទឹងក្តី ធ្វើកម្មក៏គួរ ។ តែបើមែកនៃដើមឈើក្តី ពួរដែលចេញពីដើមឈើនោះក្តី ចាក់ចូលនៅត្រង់វិហារសីមា ឬត្រង់គាមសីមា ក្រៅច្រាំងស្ទឹង ត្រូវជម្រះសីមាឱ្យរៀបរយ ឬកាត់មែកឈើចេញហើយសីមធ្វើកម្ម ។ ទឹងចងទូកត្រង់មែកនៃដើមឈើ ដែលដុះនៅលើមាត់ច្រាំង ដែលលយចុះទៅក្នុងស្ទឹង ឬត្រង់ពួរជ្រៃហើយធ្វើកម្ម មិនគួរ ។ កាលទឹងធ្វើត្រូវជម្រះសីមាឱ្យរៀបរយ ឬត្រូវកាត់ចេញ ឱ្យមែកឈើ ឬពួរជ្រៃដែលជាប់នៅខាងក្រៅនោះ ដាច់ចេញពីគ្នា ។ មួយទៀតទឹងបោះបង្គោលត្រង់ច្រាំងស្ទឹងហើយ ធ្វើកម្មក្នុងទូកដែលចងត្រង់បង្គោលនោះ ក៏មិនគួរដូចគ្នា ។ ជនទាំងឡាយធ្វើស្ពានទុកក្នុងស្ទឹង, បើតួស្ពាន ឬជើងស្ពាននៅខាងក្នុងស្ទឹងប៉ុណ្ណោះ, ទឹងស្ថិតនៅលើស្ពានធ្វើ

កម្ម ក៏គួរ ។ តែបើតួស្ពាន ឬជើងស្ពាន តាំងនៅលើប្រាំង, នឹងស្ថិតនៅលើស្ពាននោះធ្វើកម្ម មិនគួរ ។ ត្រូវជម្រះសីមាឲ្យរៀបរយហើយទើបធ្វើកម្ម ។ បើជើងស្ពាន តាំងនៅក្នុងស្ទឹង ចំណែកតួស្ពានលើកខ្ពស់ឋិតនៅក្នុងអាកាស លើប្រាំងទាំង ២ រមែងគួរ ។ ថ្មឬកោះ មាននៅខាងក្នុងស្ទឹង, ក្នុង៤ ខែនៃរដូវភ្លៀងចំពោះកាលភ្លៀងតាមប្រក្រតី មានប្រការដូចពោលហើយក្នុងកាលមុន ទឹកជន់លិចប្រទេសប៉ុនណានៃថ្ម ឬកោះនោះ, ប្រទេសប៉ុណ្ណោះ រាប់ជាស្ទឹងដូចគ្នា ។ តែមិនគួរ កាន់យកឱកាសដែលអន្លង់ទឹកជន់លិច ក្នុងកាលភ្លៀងច្រើនពេក ។ ព្រោះថាឱកាសនោះ រមែងដល់ការរាប់ថា ជាគាមសីមាផង ។

ជនទាំងឡាយ កាលនឹងបង្ហូរទឹកអំពីស្ទឹងចូលប្រឡាយ រមែងធ្វើទំនប់ក្នុងស្ទឹង, និងទឹកជន់លិច ឬព្រោះទម្លាយទំនប់នោះហូរទៅ នឹងធ្វើកម្មក្នុងទីដែលទឹកហូរគ្រប់កន្លែង រមែងគួរ តែបើក្រសែទឹក ដាច់ខ្សែទំនប់ការពារក្តី ដោយត្រូវចាក់ពូនបន្ថែមធ្វើស្ពានក្តី[1] ទឹករមែងមិនហូរ នឹងធ្វើកម្មក្នុងទីដែលទឹកមិនហូរ មិនគួរ ។ នឹងធ្វើសូម្បីលើទំនប់ ក៏មិន

១. បាលីក្នុងអដ្ឋកថាថា អាវរណេន វា កោដ្ឋកពន្ធនេន វា ។ យោជនាពន្យល់ថា អាវរណេន វាតិ ទារុអាទី និក្ខនិត្វា ឧទកនីវារណេន ។ កោដ្ឋលសម្ពន្ធេន វាតិ មត្តិកាទីហិ បូរេត្វា កតសេតុពន្ធេន សូម្បីអក្សរនឹងផ្លាស់ទៅខ្លះក៏ដោយ សេតុពន្ធ សំដៅ

សេចក្ដីថា ធ្វើ ស្ពានតាមការនិយមរបស់ភាសា ដូចក្នុងមង្គលត្ថទីបនី ត្រង់អនវជ្ជកម្មកថា ភាគ៣ ទំព័រ២៤៣ មាននិយាយពីឧបាសកម្នាក់ ធ្វើនូវទឹកន្លែងដែលមិនរាបស្មើ ... ។ ឧទកកាលេ មកតិកាសុ សេតុំ ពន្ធតិ ។ ដូច្នោះ អាស្រ័យន័យយោជនា ទើបបានប្រែដូច្នេះ ឱ្យបានសេចក្ដីច្បាស់ទៅទៀត ។

គួរ ។ បើប្រទេសនៃទំនប់កន្លែងខ្លះ ទឹកជន់លិច ដូចប្រទេសនៃថ្ម និងកោះដែលពោលហើយ ក្នុងកាលមុន, នឹងធ្វើកម្មក្នុងប្រទេសនៃទំនប់ដែលទឹកជន់លិចដល់នោះ រមែងគួរ ។ ព្រោះថា ប្រទេសនៃទំនប់នោះ រមែងដល់ការរាប់ថា ស្ទឹងដូចគ្នា ។ ជនទាំងឡាយនឹងទប់ស្ទឹង ធ្វើឱ្យជាបឹង, សាងខឿនទុកត្រង់ចុងទឹក ទឹកហូរមកឃាំងនៅពេញបឹង នឹងធ្វើកម្មក្នុងបឹងនេះ មិនគួរ ។ ទឹកដែលគេចោលចេញក្នុងទីដែលហូរ ខាងលើនិងខាងក្រោមនៃបឹងនោះ រមែងគួរ ចាប់តាំងពីកន្លែងដែលហៀរហើយហូរចុះកាន់ស្ទឹង ។ ក្នុងកាលភ្លៀងមិនធ្លាក់ ក្នុងកាលរាំងភ្លៀង ឬក្នុងរដូវក្ដៅនិងក្នុងរដូវត្រជាក់ សូម្បីធ្វើកម្មក្នុងស្ទឹងដែលស្ងួត រមែងគួរ ។ ក្នុងប្រឡាយដែលគេនាំចេញពីស្ទឹង មិនគួរ ។ បើប្រឡាយនោះ បាក់ប្រាំងក្លាយជាស្ទឹងក្នុងកាលដទៃ រមែងគួរ ។ ស្ទឹងខ្លះជន់ឡើងលិច គាមសីមា និងនិគមសីមាហូរ ទៅតាមរដូវកាល, ស្ទឹងនោះ រមែងជាស្ទឹងដូចគ្នា សមគួរធ្វើកម្មបាន ។ តែបើជន់លិចវិហារ សីមារមែងដល់ការរាប់ថា "វិហារសីមា" ។ កាលភិក្ខុទាំងឡាយនឹងធ្វើកម្ម សូម្បីក្នុងសមុ

ទ្រសោត ទឹកដែលឡើងយ៉ាងខ្ពស់ រមែងលិចប្រទេសណា ឬរលកតាមប្រក្រតីមកដោយកម្លាំងខ្យល់ រមែងលិចប្រទេសណា មិនគួរ ធ្វើកម្មក្នុងប្រទេសនោះ តែរលកតាមប្រក្រតីកើតឡើងហើយ ឈប់នៅត្រឹមប្រទេសណា ប្រទេសនោះចាប់ផ្ដើមតាំងពីជាយទឹកចុះទៅ ចាត់ជាខាងក្នុងសមុទ្រ ភិក្ខុទាំងឡាយ គប្បីតាំងនៅក្នុងប្រទេសនោះ ធ្វើកម្មចុះ បើកម្លាំងរលកបៀតបៀន គប្បីស្ថិតនៅលើទូក ឬរានធ្វើកម្ម ។

វិនិច្ឆ័យក្នុងទូកនិងរានទាំងនោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងស្ទឹងនុ៎ះឯង ។ ថ្មជាមាននៅក្នុងសមុទ្រ ។ ពេលខ្លះ រលកមកលិចថ្មជានោះ ពេលខ្លះមិនលិច មិនគួរធ្វើកម្មលើថ្មជានោះ ។ ព្រោះថាថ្មជានោះ រមែងរាប់ជាគាមសីមាផង ។ តែបើកាលរលកផ្កាត្រែងមកក្ដីមិនមកក្ដី ថ្មជានោះ ដែលទឹកតាមប្រក្រតីនោះឯងជន់លិចនៅប្រចាំរមែងគួរ ។

កោះឬភ្នំ មាន, បើកោះឬភ្នំនោះ នៅក្នុងតំបន់ឆ្ងាយមិនជាមកទៅរបស់ពួកអ្នកប្រមង់(នេសាទ) កោះឬភ្នំនោះ រមែងរាប់ចូលជាអរញ្ញសីមានុ៎ះឯង ។ ចំណែករួមក្នុងនៃចុងមកជាទីប្រព្រឹត្តទៅរបស់ពួកអ្នកប្រមង់ទាំងនោះ រាប់ជាគាមសីមា ។ មិនជម្រះគាមសីមាឱ្យរៀបរយហើយ ធ្វើកម្មលើកោះភ្នំនោះ មិនគួរ ។ សមុទ្រជន់លិចគាមសីមាឬនិគមសីមាតាំងនៅ គង់ជាសមុទ្រ; នឹងធ្វើកម្មក្នុងសមុទ្រនោះ រមែង

គួរ ។ តែបើជន់លិចវិហារសីមា រមែងដល់ការរាប់ថា "វិហារសីមា" ។

កាលភិក្ខុទាំងឡាយធ្វើកម្មក្នុងជាតស្រះសោត ក្នុងវស្សានកាល មានប្រការដូចពោលហើយក្នុងកាលមុន ល្មមភ្លៀងដាច់ ទឹកក្នុងស្រះណា ស្ងួតអស់ មិនគ្រប់គ្រាន់ដល់ការផឹក ឬងូត ឬលាងដៃ និងជើង; ស្រះនេះមិនចាត់ជាជាតស្រះ ដល់ការរាប់ថា ជាគាមខេត្ត ទុំះឯង; មិនគួរធ្វើកម្មក្នុងស្រះនោះ ។ តែក្នុងវស្សានកាល មានប្រការដូចពោលហើយ ទឹកឃាំងនៅក្នុងស្រះណា ស្រះនេះឯង ចាត់ជាជាតស្រះ ។ រហូតដល់អស់ ៤ ខែ នៃរដូវភ្លៀងទឹកឃាំងនៅ ក្នុងប្រទេសប៉ុនណានៃជាតស្រះនោះ សមគួរធ្វើកម្មក្នុងប្រទេស ប៉ុណ្ណោះបាន ។ បើទឹកជ្រៅ នឹងចងរានហើយតាំងនៅលើរាននោះក្តី តាំងនៅលើរានដែលចងទុកលើដើមឈើ ដែលកើតខាងក្នុងជាតស្រះក្តី ធ្វើកម្ម រមែងគួរ ។

ចំណែកវិនិច្ឆ័យក្នុងបង្កជានិងកោះ ក្នុងជាតស្រះនេះ ដូចដែលពោលហើយក្នុងស្ទឹងទុំះឯង ។ មួយទៀត ជាតស្រះដែលមានទឹកល្មមប្រើ ក្នុងកាលដែលភ្លៀងធ្លាក់ជានិច្ច ។ សូម្បីបើថា ក្នុងកាលរាំងភ្លៀង ឬរដូវក្តៅនិងរដូវត្រជាក់ នឹងស្ងួត មិនមានទឹក; នឹងធ្វើសង្ឃកម្មក្នុងជាតស្រះនោះ ក៏គួរ ។

មិនគួរជឿតាមពាក្យ ដែលលោកពោលទុកក្នុងអន្ធកអដ្ឋកថាថា "ជាតស្រះទាំងពួងដែលស្ងួតមិនមានទឹក រមែងចាត់ចូលជាគាមខេត្តទុំះ

ឯង” តែបើជនទាំងឡាយ ជីកអណ្តូង ឬស្រះបោក្ខរណីជាដើម ដើម្បីត្រូវការទឹក ក្នុងជាតស្រះនេះ ស្ពាននោះ មិនជាជាតស្រះ ។ រាប់ជាគាមសីមា សូម្បីក្នុងការដាំឃ្លោកនិងឡឹកជាដើមដែលគេធ្វើ ក្នុងជាតស្រះនោះ ក៏មានន័យដូចគ្នា ។

មួយទៀត បើជនទាំងឡាយ បំពេញជាតស្រះនោះឱ្យពេញ ធ្វើឱ្យគោកក្តី សាងខឿនក្នុងទិសាភាគណាមួយ ធ្វើជាតស្រះទាំងអស់នោះឱ្យជាបឹងធំក្តី មិនជាជាតស្រះសូម្បីទាំងអស់, រាប់ជាគាមសីមាទាំងឯង ។ សូម្បីលោណសមុទ្រ ក៏ចាត់ជាជាតស្រះដូចគ្នា ។ នឹងធ្វើកម្មក្នុងឱកាសជាទីយំងទឹករហូតអស់ ៤ ខែនៃរដូវភ្លៀង គួរ ដូច្នេះឯង ។

ពណ៌នាឧទកុក្ខេបសីមា ចប់

# ការទម្លាយសីមា

[១៦៥] ពាក្យថា **សីមាយ សីមំ សម្ភិន្ទន្តិ : ទម្លាយសីមាដោយសីមា** មានសេចក្តីថា ពួកភិក្ខុឆព្វគ្គិយបង់សីមារបស់ខ្លួន ទម្លាយពទ្ធសីមារបស់ភិក្ខុពួកដទៃ ។ ក៏បើថា ក្នុងទិសខាងកើតនៃវត្តចាស់ មានដើមឈើ ២ ដើម គឺ ស្វាយ ១ ដើម ព្រីង ១ ដើម មានបន្ទាបពាក់គ្នា, បណ្តាដើមស្វាយ និងដើមព្រីងនោះ ដើមព្រីងនៅក្នុងទិសខាងលិចរបស់ដើមស្វាយ និងវត្តមានសីមា ជាដែនដែលភិក្ខុកាន់យក ដើម

ព្រីងទុកខាងក្នុងកំណត់ដើមស្វាយជានិមិត្តចងទុក បើថា កាលជាខាងក្រោយភិក្ខុទាំងឡាយ នឹងចងសីមាធ្វើវត្តក្នុងទិសខាងកើតនៃវត្តនោះ ទើបកាន់យកដើមស្វាយនោះ ទុកខាងក្នុងកំណត់ដើមព្រីង ជានិមិត្តចង, សីមានឹងសីមា រមែងទម្លាយគ្នា ។ ពួកភិក្ខុឆព្វគ្គិយ បានធ្វើយ៉ាងនេះ ។

ព្រោះហេតុនេះ ព្រះឧបាលីថេរៈ ទើបពោលថា សីមាយ សីមំ សម្ភិន្ទន្តិ ប្រែថា ទម្លាយសីមាដោយសីមា ។

ពាក្យថា សីមាយ សីមំ អជ្ឈោត្ថរន្តិ : គ្រប់សង្កត់សីមាដោយសីមា មានសេចក្តីថា ពួកភិក្ខុឆព្វគ្គិយគ្របពទ្ធសីមារបស់ភិក្ខុពួកដទៃ ដោយសីមារបស់ខ្លួន គឺ ចងសីមារបស់ខ្លួន យកពទ្ធសីមារបស់ភិក្ខុពួកដទៃទាំងអស់ ឬចំណែកខ្លះនៃពទ្ធសីមានោះ ទុកខាងក្នុងសីមារបស់ខ្លួន ។

ក្នុងពាក្យថា សីមន្តរិកំ ឋបេត្វា សីមំ សម្មន្និតុំ : ឱ្យតម្កល់ទុកនូវសីមន្តរិក ហើយសីមសន្មតិសីមា នេះ មានវិនិច្ឆ័យថា បើសីមានៃវិហារ ដែលធ្វើទុកមុនជាដែនដែលមិនបានសន្មត គប្បីវៀរឧបចារនៃសីមាទុក ។ បើជាដែនដែលសន្មត គប្បីវៀរសីមន្តរិកទុកប្រមាណមួយហត្ថ ដោយកំណត់យ៉ាងទាបបំផុត ។

ក្នុងកុរុន្ទីពោលថា សូម្បីត្រឹមតែមួយចំអាម ក៏គួរ ។ ក្នុងមហាបច្ចរីពោលថា សូម្បីត្រឹមតែ ៤ ធ្នាប់ ក៏គួរ ។

មួយទៀត សូម្បីដើមឈើតែមួយដើមជានិមិត្តនៃសីមា ២ និង ដើមឈើនោះកាលធំឡើង រមែងធ្វើសីមាឱ្យសង្ករៈ(លាយចូល)គ្នា; ព្រោះហេតុនោះ មិនគួរធ្វើ ។

ពណ៌នាសីមាសម្មេទ ចប់

## ឧបោសថមានពីរ

[១៦៦] ក្នុងឧបោសថពីរ[១]នេះ គឺ ឧបោសថថ្ងៃទី ១៤ និង ឧបោសថថ្ងៃទី ១៥ កាលធ្វើបុព្វកិច្ចនៃឧបោសថថ្ងៃទី ១៤ ហើយគប្បីប្រាប់ថា អជ្ជុបោសថោ ចាតុទ្ទសោ : ឧបោសថមានក្នុងតិថីទី ១៤ ។

វិនិច្ឆ័យក្នុងឧបោសថកម្ម ៤ មានពាក្យថា អធម្មេន វគ្គំ : ឧបោសថកម្មជាពួក មិនត្រូវតាមធម៌ ជាដើម ។ បើថា ក្នុងវត្តជាមួយគ្នា កាលភិក្ខុនៅជាមួយគ្នា ៤ រូប ភិក្ខុ ៣ រូប នាំឆន្ទៈ និងបារិសុទ្ធិរបស់ភិក្ខុមួយរូបមកហើយ ធ្វើបារិសុទ្ធិឧបោសថ ឬកាលភិក្ខុនៅជាមួយគ្នា ៣ រូប, ភិក្ខុ ២ រូប នាំឆន្ទៈ និងបារិសុទ្ធិរបស់ភិក្ខុមួយរូបមកហើយសូធ្យបាតិមោក្ខ, ឧបោសថកម្ម រមែងជាពួកមិនត្រូវតាមធម៌, តែបើភិក្ខុទាំង ៤ រូប ប្រជុំគ្នាធ្វើបារិសុទ្ធិ ឧបោសថ, ភិក្ខុ ៣ រូប ឬ ២ រូប សូធ្យបាតិមោក្ខ; ឧបោសថកម្ម ឈ្មោះថា ព្រមព្រៀងដោយអធម៌ ។ បើភិក្ខុនៅជាមួយគ្នា ៤ រូប, ភិក្ខុ ៣ រូប នាំបារិសុទ្ធិរបស់

ភិក្ខុមួយរូបមកហើយ សូធ្យបាតិមោក្ខ, ឬនៅជាមួយគ្នា ៣ រូប ភិក្ខុ ២ រូប នាំបារិសុទ្ធិរបស់ភិក្ខុ ១ រូប មកហើយ ធ្វើបារិសុទ្ធិឧបោសថ,

---

១. តែក្នុងយោជនា : ឯត្ថ យោគវចនេ និងជាអាធារក្នុងវត្តពុំ ។

ឧបោសថកម្ម ឈ្មោះថា ជាពួកត្រូវតាមធម៌ ។ តែបើភិក្ខុ ៤ រូបនៅក្នុងវត្តតែមួយប្រជុំគ្នាទាំងអស់ សូធ្យបាតិមោក្ខ, ៣ រូបធ្វើបារិសុទ្ធិឧបោសថ, ២ រូប ធ្វើបារិសុទ្ធិដល់គ្នានិងគ្នា, ឧបោសថកម្ម ឈ្មោះថា ព្រមព្រៀងត្រូវតាមធម៌ ។

ឧបោសថមានពីរ ចប់

## ការសម្តែងបាតិមោក្ខមាន ៥ យ៉ាង

[១៦៧] ពាក្យថា និទានំ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ : ភិក្ខុត្រូវសម្តែងនូវនិទានហើយសូធ្យនូវឧទ្ទេសដ៏សេសសល់ដោយសុត្តបទ មានសេចក្តីថា កាលសូធ្យនិទាននេះថា សុណាតុ មេ ភន្តេ សង្ឃោ ។បេ ។ អាវិកាតា ហិស្ស ផាសុ ហោតិ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា ។ល ។ ដ្បិតភិក្ខុ

នោះរមែងមានសេចក្ដីសប្បាយ ព្រោះការសម្ដែងអាបត្តិនោះ ហើយគប្បីពោលថា ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ ។ តត្ថាយស្មន្តេ បុច្ឆាមិ ។ កច្ចិត្ថ បរិសុទ្ធា, ទុតិយម្បិ បុច្ឆាមិ ។បេ។ ឯវមេតំ ធារយាមិ : បពិត្រលោកអ្នកមានអាយុទាំងឡាយ និទានខ្ញុំព្រះករុណាសម្ដែងរួចហើយ ។ ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងនិទាននេះ លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរដងទៀត ។ល។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ[១] ហើយគប្បីសូធ្យ ៤ ឧទ្ទេសដ៏សេស ដោយសុតបទយ៉ាងនេះថា សុតា ខោ បនាយស្មន្តេហិ ចត្តារោ បារាជិកា ធម្មា ។បេ។ អវិវទមានេហិ សិក្ខិតព្វំ បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង ៤ ខ្ញុំព្រះករុណាសូធ្យរួចហើយ ។ល។ កុំវិវាទទាស់តែងគ្នា គប្បីសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បាតិមោក្ខុទ្ទេស ៤ ដ៏សេស គប្បីជ្រាបតាមន័យនេះ ។

សញ្ចារភ័យនោះ បានដល់ ភ័យកើតដល់មនុស្សដែលដើរទៅក្នុងព្រៃ ។

វិនិច្ឆ័យក្នុងអន្តរាយ ១០ មាន រាជន្តរាយជាដើម ។ បើកាល

ភិក្ខុទាំងឡាយគិតថា យើងនឹងធ្វើឧបោសថ អង្គុយប្រជុំគ្នាហើយ ព្រះរាជាស្តេចមក នេះឈ្មោះថា រាជន្តរាយ ។ ពួកចោរនាំគ្នាមក នេះឈ្មោះ

១. និទានុទ្ទេស មិនគួរនឹងត្រូវសួរ, មើលអធិប្បាយក្នុងវិន័យមុខ ភាគ២ កណ្ឌទី១៧ ។

ថា ចោរន្តរាយ ។ ភ្លើងព្រៃរាលមក ឬភ្លើងកើតឡើង ក្នុងអាវាស នេះឈ្មោះថា អគ្យន្តរាយ ។ ភ្លៀងធ្លាក់ ឬទឹកជន់មក នេះឈ្មោះថា ឧទកន្តរាយ ។ មនុស្សនាំគ្នាមកច្រើន នេះឈ្មោះថា មនុស្សន្តរាយ ។ យក្សចូលភិក្ខុ នេះឈ្មោះថា អមនុស្សន្តរាយ ។ សត្វកាចមានខ្លាជាដើមមក នេះឈ្មោះថា វាឡន្តរាយ ។ សត្វមានពិសមានពស់ជាដើមខាំភិក្ខុ នេះឈ្មោះថា សិរឹសបន្តរាយ ។ ភិក្ខុអាពាធ ឬធ្វើកាលកិរិយា ឬពួកអ្នកមានពៀរនឹងគ្នា ប្រាថ្នានឹងសម្លាប់ ចាប់ភិក្ខុនោះ នេះឈ្មោះថា ជីវិតន្តរាយ ។ មនុស្សប្រាថ្នាឱ្យភិក្ខុ តែមួយរូប ឬច្រើនរូបឃ្លាតចាកព្រហ្មចរិយ ចាប់យកទៅ នេះ ឈ្មោះថា ព្រហ្មចរិយន្តរាយ ។

ក្នុងអន្តរាយបែបនេះ គប្បីសូធ្យបាតិមោក្ខសង្ខេបបាន ។ នឹងគប្បីសូធ្យឧទ្ទេសទី១ ឬសូធ្យ ២ ឧទ្ទេស ។ ៣ ឧទ្ទេស, ៤ ឧទ្ទេសខាងដើមក៏ដោយ ។ ក្នុងឧទ្ទេសទាំងនេះ មានឧទ្ទេសទី ២ ជាដើម កាលឧទ្ទេសណាសូធ្យមិនទាន់ចប់ មានអន្តរាយ សូម្បីឧទ្ទេសនោះ គប្បី

សូធ្យដោយសុតបទតែម្តង ។

ការសម្តែងបាតិមោក្ខមាន ៥ យ៉ាង ចប់

## អជ្ឈេសនា

### ការសន្មតខ្លួន ការសន្មតភិក្ខុដទៃ

[១៦៨] បទថា អនជ្ឈិដ្ឋា : មិនមានគេអារាធនា បានដល់ មិនបានទទួលបង្គាប់ ឬមិនបានទទួលអារាធនា ។

ក៏ក្នុងអជ្ឈេសនាធិការនេះ ការអារាធនាជាប់ដោយភិក្ខុដែលអារាធនាសម្តែងធម៌ ដែលសង្ឃសន្មតក៏មាន ជាប់ដោយព្រះសង្ឃត្ថេរក៏មាន ។ កាលភិក្ខុដែលអារាធនាសម្តែងធម៌នោះមិនមាន ភិក្ខុប្រាប់ព្រះសង្ឃត្ថេរហើយ ឬដែលព្រះសង្ឃត្ថេរអារាធនាហើយ រមែងបានដើម្បីពោលធម៌ ។

ឯព្រះសង្ឃត្ថេរ បើក្នុងវត្តមានព្រះធម្មកថិកច្រើន, គប្បីបង្គាប់តាមលំដាប់វារៈ ។ ភិក្ខុណាដែលលោកបង្គាប់ថា "លោកចូរសូធ្យធម៌" ក្តី ថា "លោកចូរសម្តែងធម៌"ក្តី ថា "លោកចូរឱ្យធម្មទាន"ក្តី គប្បីពោលធម៌បានទាំង ៣ វិធី តែភិក្ខុដែលបានទទួលពាក្យបង្គាប់ថា "ចូរ

សូធ្យ" រមែងបានដើម្បីសូធ្យប៉ុណ្ណោះ អ្នកបានទទួលពាក្យបង្គាប់ថា "ចូរសម្តែង" រមែងបានដើម្បីសម្តែងប៉ុណ្ណោះ អ្នកបានទទួលពាក្យបង្គាប់ថា "ចូរសូធ្យសរភញ្ញៈ" រមែងបានដើម្បីសូធ្យសរភញ្ញៈប៉ុណ្ណោះ ។

ចំណែកព្រះថេរៈសោត អ្នកអង្គុយលើអាសនៈខ្ពស់ជាង រមែងមិនបានដើម្បីអារាធនា ។ បើព្រះសង្ឃត្ថេរជាឧបជ្ឈាយ៍ និងព្រះធម្មកថិកជាសទ្ធិវិហារិក និងព្រះឧបជ្ឈាយ៍អង្គុយលើអាសនៈខ្ពស់ បង្គាប់សិទ្ធិវិហារិកនោះថា "លោកចូរសូធ្យ" ។ គប្បីតាំងចិត្តស្វាធ្យាយហើយសូធ្យចុះ ។ តែបើក្នុងសំណាក់ឧបជ្ឈាយ៍នេះ មានភិក្ខុកំលោះច្រើន, គប្បីតាំងចិត្តថា យើងសូធ្យដល់ភិក្ខុទាំងនោះ ហើយសូធ្យចុះ ។

បើព្រះសង្ឃត្ថេរក្នុងវត្ត ឱ្យតែនិស្សិតរបស់ខ្លួនប៉ុណ្ណោះសូធ្យ, មិនអារាធនាភិក្ខុពួកដទៃដែលសូធ្យពីរោះខ្លះ, ភិក្ខុពួកដទៃគប្បីទូលលោកថា "លោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណា សូមឱ្យភិក្ខុឈ្មោះ..... ឯណោះសូធ្យ" ។ បើលោកតបថា "សូធ្យចុះ" ឬលោកនៅស្ងៀម សមគួរឱ្យសូធ្យបាន; តែបើលោកហាម មិនគួរឱ្យសូធ្យ ។

បើថា ផ្តើមធម្មសវនៈ តែកាលព្រះសង្ឃត្ថេរមិនទាន់បានមក, កាលលោកមកដល់ពាក់កណ្តាល កិច្ចដែលនិងត្រូវឈប់ សូមឱកាសមិនមាន ។

មួយទៀត កាលសូធ្យហើយនឹងអធិប្បាយសេចក្តី គប្បីសូម

ឱកាសលោកហើយ ទើបអធិប្បាយក៏បាន ។ មិនឈប់សោះ អធិប្បាយតែម្តងក៏បាន សូម្បីក្នុងព្រះសង្ឃត្រូវដែលមក ដល់ពាក់កណ្តាល កាលកំពុងអធិប្បាយ ក៏មានន័យដូចគ្នា ។ សូម្បីក្នុងឧបនិសិន្នកថា ព្រះសង្ឃត្រូវជាធំ, ព្រោះដូច្នោះ ព្រះសង្ឃត្រូវនោះ គប្បីពោលដោយខ្លួនឯង, ឬបង្គាប់ភិក្ខុដទៃថា "លោកចូរពោល" ក៏ឯព្រះថេរៈអង្គុយខ្ពស់ជាង មិនគួរបង្គាប់ ។ ប៉ុន្តែថា នឹងបង្គាប់ដល់ជនទាំងឡាយថា "លោកចូរពោល" គួរ, ជនទាំងឡាយសួរភិក្ខុដែលស្គាល់ខ្លួន ភិក្ខុនោះគប្បី សូមឱកាសព្រះថេរៈមុនសិន សឹមឆ្លើយ ។ បើព្រះថេរៈ ដែលភិក្ខុសួរថា "លោកម្ចាស់ដ៏ចម្រើន ជនទាំងនេះសួរបញ្ហាចំពោះខ្ញុំព្រះករុណា" ដូច្នេះ ហើយបង្គាប់ថា "ឆ្លើយចុះ"ក្តី នៅស្ងៀមក្តី នឹងឆ្លើយ ក៏គួរ ។

សូម្បីក្នុងការអនុមោទនាជាដើម ក្នុងចន្លោះផ្ទះ ក៏ន័យនេះឯង បើថា ព្រះសង្ឃត្រូវអនុញ្ញាតថា "លោកគប្បីពោលក្នុងវត្ត ឬក្នុងចន្លោះផ្ទះចុះ" មិនត្រូវប្រាប់ខ្ញុំព្រះករុណាទេណ៎ះ ជាការបាននូវសេចក្តីអាង, សមគួរពោលបានក្នុងទីទាំងពួង ។ សូម្បីកាលនឹងធ្វើការស្វាធ្យាយ ក៏ត្រូវសូមឱកាសព្រះថេរៈដូចគ្នា ។ កាលសូមឱកាស អង្គ ១ ហើយកំពុងស្វាធ្យាយ អង្គដទៃមកទៀត កិច្ចដែលនឹងត្រូវសូមឱកាសទៀត រមែងមិនមាន ។ បើថា កាលតាំងចិត្តថា "យើងនឹងសម្រាក" ហើយឈប់ព្រះថេរៈមក, កាលផ្តើមទៀត ត្រូវសូមឱកាស សូម្បីកាលកំពុង

ស្វាធ្យាយធម៌ ដែលខ្លួនផ្ដើមទុកហើយ តែកាលព្រះសង្ឃត្ថេរមិនទាន់មកក៏ន័យនេះឯង ។ ព្រះសង្ឃត្ថេរមួយអង្គ អនុញ្ញាតហើយថា "មិនត្រូវសូមឱកាសខ្ញុំព្រះករុណាទេណ៎ះ សូធ្យតាមសប្បាយចុះ" ដូច្នេះ សមគួរស្វាធ្យាយ តាមសប្បាយ តែកាលព្រះសង្ឃត្ថេរអង្គដទៃមក ត្រូវសូមឱកាសលោកមុនសិន សឹមស្វាធ្យាយ ។

[១៦៩] ពាក្យថា អត្តនា វា[១] អត្ថានំ សម្មន្និតព្វំ : ត្រូវសន្មតខ្លួនដោយខ្លួនឯងក៏បាន មានសេចក្ដីថា គប្បីសន្មតិខ្លួនដោយខ្លួនឯងក៏បាន ។ តែកាលនឹងសួរ ត្រូវរមិលមើលបរិស័ទ បើឧបទ្រវៈមិនមានដល់ខ្លួន; គប្បីសួរវិន័យ ។

[១៧០] ពាក្យថា កតេបិ ឱកាសេ បុគ្គលំ តុលយិត្វា : **កាលបើភិក្ខុដទៃបើកឱកាសឱ្យហើយមែន** មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យភិក្ខុ សូម្បីកាលខ្លួនសូមឱកាសហើយ ត្រូវពិចារណាយ៉ាងនេះថា "ឧបទ្រវៈកើតពីបុគ្គលនេះ នឹងមានដល់យើងឬមិនមានហ្ន៎" ដូច្នេះហើយសឹមចោទដោយអាបត្តិ ។

បទថា បុរម្ហាកំ : **គង់តែឱ្យយើង...ជាមុន** បានដល់ គង់តែឱ្យយើងទាំងឡាយ (បើកឱកាស) ជាដំបូងសិន ។

បទថា បដិកច្ចេវ : **ជាមុន** បានដល់ មុនអំពីនោះ ។ កម្មមិន

ត្រូវតាមធម៌ មានន័យដូចពោលហើយនុ៎ះឯង ។

១. បាលីបិដកខ្មែរ វ : ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, ត្រឹមតែ, ដដែល, ដូចដែល, តែម្យ៉ាង, ភ្លាម ។ ភូមាថា វា ប្រែថា ឬ ក្តី ខ្វះ, ពាក្យនេះត្រូវជាង ។ ពាក្យបន្ទាប់ថា បវេន វា បវេ ។

ពាក្យថា បុគ្គលំ តុលយិត្វា ឱកាសំ កាតុំ : ភិក្ខុពិនិត្យមើលបុគ្គលហើយសិន សឹមឱ្យគេបើកឱកាស មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុពិចារណាយ៉ាងនេះថា "អ្នកនេះនឹងពោល អាបត្តិដែលពិតប៉ុណ្ណោះ ឬនឹងពោលមិនពិតហ្ន៎" ដូច្នេះហើយ សឹមឱ្យឱកាស ។

## ការធ្វើកម្មមិនមែនជាធម៌ជាដើម

[១៧១] បទថា បដិក្កោសិតុំ : ហាមឃាត់ បានដល់ ដើម្បីហាម ។

ពាក្យថា ទិដ្ឋិម្បិ អាវិកាតុំ : ប្រកាសសេចក្តីយល់ឃើញក៏បាន មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុប្រកាសសេចក្តីឃើញរបស់ខ្លួន ក្នុងសំណាក់ភិក្ខុដទៃយ៉ាងនេះថា "កម្មនេះ មិនជាធម៌មិនគាប់ចិត្តខ្ញុំព្រះករុណា" ។

ពាក្យថា ៤ រូប ៥ រូប ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បី

ត្រូវការមិនឱ្យមានអន្តរាយដល់ភិក្ខុទាំងនោះ ។

[១៧២] ពាក្យថា សញ្ចិច្ច ន សាវេន្តិ : ក៏ក្លែងធ្វើមិនឱ្យឮច្បាស់ មានសេចក្ដីថា ក្លែងសូធ្យខ្សឹប ៗ ដោយតាំងចិត្តថា ភិក្ខុពួកដទៃនឹងមិនបានឮ ដោយប្រការណា យើងនឹងសូធ្យដោយប្រការនោះ ។

[១៧៤] បទថា ថេរាធិកំ : មានព្រះថេរៈជាធំ មានសេចក្ដីថា តថាគតអនុញ្ញាតការសម្ដែងបាតិមោក្ខ ឱ្យមានព្រះថេរៈជាប្រធាន អធិប្បាយថា ដើម្បីជាកិច្ច ជាប់ដោយព្រះថេរៈ ។

បាលីថា ថេរាធេយ្យំ ក៏មាន ប្រែថា ឱ្យមានព្រះថេរៈអធិបតី ។ ព្រោះហេតុនោះ ព្រះថេរៈគប្បីសូធ្យដោយខ្លួនឯងក៏បាន គប្បីអារាធនាភិក្ខុដទៃក៏បាន ។

ក្នុងអធិការពោលអំពីការអារាធនានូវបាតិមោក្ខនេះ វិធីអារាធនាមានន័យដូចពោលហើយក្នុងការអារាធនាធម៌នុ៎ះឯង ។

[១៧៥] វិនិច្ឆ័យក្នុងពាក្យថា សោ ន ជានាតិ ឧបោសថំ វា : ភិក្ខុជាថេរៈនោះ មិនដឹងឧបោសថ ឬឧបោសថកម្ម ជាដើម ដូច្នេះ ៖

ព្រះថេរៈនោះ មិនស្គាល់ឧបោសថ ២ យ៉ាង គឺ ចាតុទ្ទសិកឧបោសថ បណ្ណរសិកឧបោសថ និងមិនស្គាល់ឧបោសថ ៩ យ៉ាង ដែលផ្សេងគ្នាដោយសង្ឃឧបោសថ ជាដើម, មិនដឹងឧបោសថកម្ម ៤

យ៉ាង, មិនដឹងបាតិមោក្ខ ២ យ៉ាង, មិនដឹងបាតិមោក្ខុទ្ទេស ៩ យ៉ាង ។

ក្នុងពាក្យថា យោ តត្ថ ភិក្ខុ ព្យត្តោ បដិពលោ : ស្រេចលើភិក្ខុដែលឆ្លាសប្រតិពលក្នុងអាវាសនោះ នេះ មានវិនិច្ឆ័យថា បាដិមោក្ខព្រះមានព្រះភាគទ្រង់អនុញ្ញាតដល់ភិក្ខុដែលឆ្លាត សូម្បីនៅកំលោះក៏ពិតមែន, តែថា ក្នុងសេចក្តីនេះ គួរជ្រាបអធិប្បាយដូច្នេះ ៖

បើបាដិមោក្ខុទ្ទេស ៥ ឬ ៤ ឬ ៣ របស់ព្រះថេរៈចាំមិនបានចំណែក ២ ឧទ្ទេសជារបស់មិនខ្វះខាត ជំនាញល្អ ស្ទាត់រត់មាត់ បាតិមោក្ខគង់ជាប់ដោយព្រះថេរៈ ។ តែបើសូម្បីត្រឹមតែប៉ុណ្ណេះ លោករមែងមិនអាចដើម្បីធ្វើឱ្យជំនាញបាន រមែងជានាទីរបស់ព្រះភិក្ខុដែលឆ្លាតនោះឯង ។

[១៧៦] ពីរបទថា សាមន្តា អាវាសា : អាសវាសដែលមាននៅជិតខាង បានដល់ អាសវាសជិតគ្នា ។

បទថា សជ្ជុកំ : ក្នុងថ្ងៃនោះឯង មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការមកក្នុងថ្ងៃនោះឯង ។

វិនិច្ឆ័យក្នុងពាក្យថា នវកំ ភិក្ខុំ អាណាបេតុំ : ឱ្យបង្គាប់ភិក្ខុថ្មីបាន នេះថា ភិក្ខុណាអាចដើម្បីរៀនបាន គប្បីបង្គាប់ភិក្ខុបែបនោះ កុំបង្គាប់ ភិក្ខុល្ងង់ ។

[១៧៧] ក្នុងបទថា កតមី[1] ភន្តេ បក្ខស្ស : បពិត្រលោកដ៏ចម្រើន តិថីនៃបក្ខបានប៉ុន្មាន នេះ មានអធិប្បាយថា តិថីជាទីពេញនៃតិថីទាំងឡាយប៉ុន្មាន ឈ្មោះថា តិថីនៃបក្ខបាន ប៉ុន្មានហើយ គឺ ប៉ុន្មាន

១. ព្រះបាលីវិន័យជា កតិមី, ដីកាវិមតិនោទនីក៏ជា កតិមី ។

ថ្ងៃ ៗ មនុស្សទាំងឡាយសំដៅយកកុសលកម្ម ដែលជាប់ដោយលោកម្ចាស់ សួរថា “លោកម្ចាស់ តើភិក្ខុមានប្រមាណប៉ុនណា ?”

ពាក្យថា សលាកំ វា គាហេតុំ : ឬឱ្យកាន់យកស្លាកក្នុងថ្ងៃឧបោសថនោះ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុកាន់យក គឺ រួមស្លាកហើយរាប់ ៗ

[១៧៨] បទថា កាលវតោ : ដោយកាល បានដល់ ចំពោះកាលតែម្តង សេចក្តីថា អំពីព្រឹកតែម្តង ៗ

ក្នុងពាក្យថា យំ កាលំ សរតិ : ឱ្យភិក្ខុនោះរលឹកឃើញកាលណា នេះ មានសេចក្តីថា សូម្បីក្នុងវេលាល្ងាច នឹងប្រាប់ថា ថ្ងៃនេះឧបោសថ លោកទាំងឡាយ ចូរមកប្រជុំ ក៏គួរ ៗ

[១៧៩] សូម្បីក្នុងពាក្យថា ថេរេន ភិក្ខុនា នវំ ភិក្ខុំ អាណាបេតុំ : ឱ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុថ្មី នេះ មានវិនិច្ឆ័យថា ភិក្ខុថ្មីកម្មយ៉ាងណាមួយក្តី ភិក្ខុដែលជួយភារៈយ៉ាងណាមួយសព្វកាលជានិច្ចក្តី

ភិក្ខុដែលពោលដោយសំឡេងនិងធម្មកថិកជាដើមរូបណាមួយក្តី ព្រះថេរៈ មិនគួរបង្គាប់ដើម្បីបោសពេងឧបោសថ ចំណែកភិក្ខុដ៏សេស គប្បីបង្គាប់តាមវារៈ គឺ ផ្លាស់ប្តូរគ្នា បើថា ភិក្ខុដែលបានទទួល ពាក្យបង្គាប់ហើយ នឹងមិនបានឈើបោស សូម្បីជារបស់ខ្ទីសោត គប្បីពឹងពាក់កប្បិយការកៈ កាច់មែកឈើធ្វើឱ្យគួរ ហើយបោស, កាលលោកមិនបានសូម្បីនូវកប្បិយការកនោះ ជាការបានអាង ។ សូម្បីក្នុងការបង្គាប់ដើម្បីឱ្យក្រាលអាសនៈ ក៏គប្បីបង្គាប់តាមន័យដែលពោលហើយនុ៎ះឯង ។

ចំណែកភិក្ខុដែលទទួលពាក្យបង្គាប់ហើយ បើអាសនៈក្នុងរោងឧបោសថមិនមាន គប្បីនាំមកពីសង្ឃិកាវាស ( អាវាសរបស់សង្ឃ ) ក្រាលហើយ ត្រូវនាំទៅវិញ ។ កាលអាសនៈមិនមាននឹងក្រាលកន្ទេលផែងក្តី កន្ទេលទន់ក្តី រមែងគួរ ។ សូម្បីកាលកន្ទេលទន់មិនមាន ក៏គប្បីពឹងពាក់កប្បិយការក ឱ្យជួយកច់មែកឈើធ្វើឱ្យគួរ ហើយក្រាលចុះ កាលលោកមិនបានកប្បិយការក ជាការបានអាង ។

ក្នុងការអុជប្រទីបសោត ព្រះថេរៈក៏គប្បីបង្គាប់តាមន័យ ដែលពោលហើយនោះឯង ។ ក៏កាលនឹងបង្គាប់ ត្រូវប្រាប់ថា ប្រេង ឬប្រឆេះ ឬចង្កៀង មាននៅក្នុងឱកាសឯណោះ លោកចូរកាន់យកវត្ថុនោះ ៗ មកអុជប្រទីប ។ បើប្រេងជាដើមមិនមាន ភិក្ខុដែលទទួលពាក្យបង្គាប់ត្រូវស្វែងរកមក កាលស្វែងរកហើយមិនបាន ជាការបាន

អាង ។ ម្យ៉ាងទៀត នឹងគប្បីដុតភ្លើងឱ្យឆេះលើក្បៀង ក៏បាន ។

[១៨០] ពាក្យថា **សង្គហេតព្វោ : សង្គ្រោះ** មានសេចក្ដីថា ភិក្ខុដែលជាពហុស្សូតនោះ ដែលភិក្ខុទាំងឡាយគប្បីសង្គ្រោះ ដោយពាក្យដែលពីរោះយ៉ាងនេះថា "លោកមកហើយ ជាការល្អណាស់ ព្រះករុណា ទីនេះភិក្ខាហាររកបានងាយ សម្លនិងបាយក៏មាន កុំចាំបាច់កង្វល់ឡើយ និមន្តនៅចុះ" គប្បីអនុគ្រោះជាប់ដោយការនិយាយចរចាគ្នារឿយ ៗ គប្បីបញ្ចុះបញ្ចូលឱ្យលោកព្រមឆ្លើយថា "ករុណា ខ្ញុំព្រះករុណានឹងនៅ" ។

មួយទៀត គប្បីសង្គ្រោះនិងអនុគ្រោះដោយបច្ច័យ ៤ គប្បីបញ្ចុះបញ្ចូលដោយពាក្យដ៏ពីរោះ អធិប្បាយថា គប្បីចរចាឱ្យពីរោះត្រចៀក គប្បីឱ្យទំនុកបម្រុងដោយវត្ថុផ្សេង ៗ មានលំអិតជាដើម ។

ពាក្យថា **អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ** មានសេចក្ដីថា បើសង្ឃ សូម្បីទាំងអស់មិនធ្វើសោត, ត្រូវអាបត្តិទុក្កដទាំងអស់ ។ ក្នុងអធិការនេះ ព្រះថេរៈទាំងឡាយក៏មិនផុត ពួកភិក្ខុកំលោះ ក៏មិនផុត ។ ភិក្ខុទាំងពួងគប្បីឱ្យផ្លាស់វារៈគ្នាទំនុកបម្រុង ជាអាបត្តិដល់ភិក្ខុដែលមិនទំនុកបម្រុងក្នុងវារៈរបស់ខ្លួន ។ តែភិក្ខុដែលជាពហុស្សូតនោះ កុំគប្បីត្រេកអរវត្ត មានការបោសបរិវេណនិងឱ្យឈើស្ទន់ជាដើមរបស់ព្រះមហាថេរៈទាំងឡាយ ។ សូម្បីកាលមានហេតុយ៉ាងនេះ លោកមិនបានត្រេកអរ

ព្រះមហាថេរៈទាំងឡាយ ក៏គួរមកកាន់ទីទំនុកបម្រុងទាំងព្រឹកល្ងាច ។ តែភិក្ខុជាពហុស្សូតនោះ ដឹងការមករបស់ពួកលោកហើយ គប្បីទៅកាន់ទីទំនុកបម្រុងរបស់ព្រះមហាថេរៈ ទាំងឡាយជាមុន ។ បើភិក្ខុជាអ្នករួមដំណើរ ដែលជាឧបដ្ឋាក របស់លោកមានហើយ លោកគប្បីហាមឃាត់ថា "ឧបដ្ឋាករបស់ខ្ញុំព្រះករុណាមាន សូមលោកទាំងឡាយ ជាអ្នកខ្វល់ខ្វាយតិចចុះ" ។ សូម្បីបើថា ភិក្ខុដែលរួមដំណើររបស់លោកមិនមាន ។ តែភិក្ខុមួយរូប ឬ ២ រូប ជាអ្នកដល់ព្រម ដោយវត្តក្នុងវត្តនុ៎ះឯង ពោលថា "ខ្ញុំព្រះករុណា នឹងធ្វើកិច្ចដែលគួរធ្វើដល់ព្រះថេរៈខ្លួនឯង ភិក្ខុដ៏សេសចូរនៅជាសុខចុះ" មិនជាអាបត្តិដល់ភិក្ខុទាំងពួង ។

ពាក្យថា សោ អាវាសោ គន្តព្វោ **:** ត្រូវភិក្ខុនោះ ទៅកាន់អាវាសនោះ មានសេចក្តីថា អាវាសនោះ ដែលភិក្ខុទាំងឡាយអ្នកល្ងង់ខ្លៅ មិនឆ្លាត គប្បីទៅរាល់កន្លះខែ ដើម្បីប្រយោជន៍ដល់ការធ្វើឧបោសថ ក៏អាវាសនោះឯង (គឺភិក្ខុនោះ) គួរទៅក្នុងហេមន្តរដូវនិងគិម្ហន្តរដូវប៉ុណ្ណោះ តែព្រះមានព្រះភាគ ត្រាស់ពាក្យជាដើមថា "អ្នកល្ងង់ មិនឆ្លាសនៅចាំវស្សា" ដូច្នេះ ក៏ដើម្បីសម្តែងកិច្ចដែលគួរធ្វើក្នុងរដូវភ្លៀង ។

ក្នុងព្រះបាលី ពាក្យថា ន ភិក្ខវេ តេហិ ភិក្ខូហិ តស្មឹ អាវាសេ វស្សំ វសិតព្វំ **:** ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុទាំងនោះ

នៅចាំវស្សាក្នុងអាវាសនោះទេ មានសេចក្ដីថា ក្នុងការចូលវស្សាដំបូង កុំចាំវស្សាប្រាសចាកភិក្ខុដែលចេះសូធ្យបាដិមោក្ខ ។ បើថា បណ្ដាភិក្ខុទាំងឡាយចូលចាំវស្សាហើយ ភិក្ខុដែលចេះសូធ្យបាតិមោក្ខនោះជៀសចេញទៅក្ដី សឹកក្ដី ធ្វើកាលកិរិយាក្ដី កាលភិក្ខុដទៃ (ដែលសូធ្យបាន)មានទុំៈ ឯង ទើបគួរចាំវស្សាក្រោយ ក្នុងកាលចូលវស្សាខាងក្រោយ កាលមិនមាន ត្រូវទៅក្នុងអាវាសដទៃ កាលមិនទៅត្រូវអាបត្តិទុក្កដ ។ តែបើភិក្ខុដែលសូធ្យបាតិមោក្ខនោះ ជៀសចេញទៅក្ដី សឹកក្ដី ធ្វើកាលកិរិយាក្ដី ក្នុងការចូលវស្សាក្រោយ គប្បីនៅក្នុងទីនោះ រហូតដល់អស់ ២ ខែ ។

ពណ៌នាអជ្ជេសនា ចប់

## ពណ៌នាបារិសុទ្ធិនិងឆន្ទៈ

[១៨១] ពាក្យថា កាយេន វិញ្ញាបេតិ : បញ្ជាក់ដោយកាយ មានសេចក្ដីថា ភិក្ខុអាពាធ រមែងឱ្យដឹង គឺ រមែងឱ្យជ្រាបការឱ្យបារិសុទ្ធិដោយអវយវៈតូចធំយ៉ាងណាមួយ ក៏កាលអាចបញ្ចេញវាចា រមែងឱ្យដឹងដោយវាចា កាលអាចទាំង ២ ប្រការ រមែងឱ្យដឹងទាំងកាយវាចា ។

ពាក្យថា សចេ្លន តត្ថ គន្តា ឧបោសថោ កាតព្វោ : ត្រូវ

សង្ឃទៅធ្វើឧបោសថក្នុងទីនោះ មានសេចក្តីថា បើភិក្ខុដែលអាពាធដូច្នោះ មានច្រើន សង្ឃគប្បីតាំងនៅតាមលំដាប់ ធ្វើភិក្ខុដែលអាពាធទាំងពួងទុកក្នុងហត្ថបាស ។ បើភិក្ខុដែលអាពាធមានក្នុងទីឆ្ងាយ ៗ, សង្ឃមិនល្មម ថ្ងៃនោះ មិនត្រូវធ្វើឧបោសថ

កាលសង្ឃបែកជាពួក មិនគប្បីធ្វើឧបោសថពិត ។

ពាក្យថា តត្ថេវ បក្កមតិ : ចៀសចេញចាកទីនោះទៅ មានសេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិ មកកាន់ កណ្តាលជុំនុំសង្ឃហើយ ទៅក្នុងទីណាមួយអំពីទីនោះវិញ ។

ពាក្យថា សាមណេរោ បដិជានាតិ : ប្តេជ្ញាខ្លួនជាសាមណេរ មានសេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិ ប្តេជ្ញាយ៉ាងនេះថា "ខ្ញុំព្រះករុណាជាសាមណេរ" ឬប្រាប់សេចក្តីដែលខ្លួនជាសាមណេរពិត ៗ ឬតាំងនៅក្នុងភូមិនៃសាមណេរក្នុងកាលខាងក្រោយ ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។

ពាក្យថា សង្ឃប្បត្តោ បក្កមតិ : ទៅដល់សង្ឃហើយចៀសចេញទៅ មានសេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិដល់ហត្ថបាសរបស់ភិក្ខុ ៤ រូប ដោយកំណត់យ៉ាងទាបបំផុត អ្នកប្រជុំគ្នាដើម្បីប្រយោជន៍ដល់ឧបោសថហើយ ជៀសចេញទៅ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។

ក៏ឯវិនិច្ឆ័យក្នុងការនាំបារិសុទ្ធិនេះ គប្បីជ្រាបដូច្នេះ ៖

បារិសុទ្ធិរបស់ភិក្ខុច្រើនរូប ដែលភិក្ខុ ១ រូបនាំមកហើយ ជាការនាំមកហើយពិត ៗ តែបើភិក្ខុដែលនាំនោះ ជួបភិក្ខុដទៃក្នុងទីពាក់កណ្ដាលមក ទើបឱ្យបារិសុទ្ធិរបស់ភិក្ខុទាំងឡាយ ដែលខ្លួនទទួលមកផង បារិសុទ្ធិរបស់ខ្លួនផង បារិសុទ្ធិរបស់ភិក្ខុដែលនាំនោះ ប៉ុណ្ណោះរមែងមក ចំណែកបារិសុទ្ធិក្រៅពីនេះបាត់ ជាបារិសុទ្ធិ ដូចប្រវាក់បង្ហា បារិសុទ្ធិនោះ រមែងមិនមក ៗ

ពាក្យថា សុត្តោ ន អារោចេតិ **: ដេកលក់មិនបានប្រាប់** មានសេចក្ដីថា ភិក្ខុដែលនាំបារិសុទ្ធិនោះ មកហើយសឹងលក់ មិនប្រាប់ថា "បារិសុទ្ធិ គឺភិក្ខុ (ឈ្មោះ....)ឯណោះឱ្យហើយ" ៗ

វិនិច្ឆ័យក្នុងពាក្យថា **បារិសុទ្ធិហារកស្ស អនាបត្តិ : មិនមានអាបត្តិដល់ភិក្ខុអ្នកនាំបារិសុទ្ធិទេ** នេះ គប្បីជ្រាបដូច្នេះ ៖

បើភិក្ខុដែលនាំបារិសុទ្ធិ ក្លែងមិនប្រាប់ លោកត្រូវទុកដូច ចំណែកបារិសុទ្ធិជាការនាំមកហើយពិត ៗ តែមិនជាអាបត្តិដល់លោក ព្រោះមិនបានក្លែង មិនប្រាប់ និងឧបោសថរបស់លោកទាំង ២ រូប ជាការធ្វើហើយដូចគ្នា ៗ

[១៨២] ឯវិនិច្ឆ័យក្នុងការឱ្យឆន្ទៈនោះ ក៏ដូចគ្នានឹងវិនិច្ឆ័យ

ដែលពោលហើយក្នុងការឱ្យបារិសុទ្ធិនុ៎ះឯង ។

វិនិច្ឆ័យក្នុងពាក្យថា បារិសុទ្ធឹ ទេន្តេន ឆន្ទម្បិ ទាតុំ : ភិក្ខុដែលឱ្យបារិសុទ្ធិក្នុងថ្ងៃឧបោសថនោះ ឱ្យឆន្ទទៀតបាន នេះ គប្បីជ្រាបដូច្នេះ ៖

បើថា ភិក្ខុអាពាធឱ្យតែបារិសុទ្ធិប៉ុណ្ណោះ មិនឱ្យឆន្ទៈ ឧបោសថរមែងជាការសង្ឃធ្វើហើយ តែសង្ឃធ្វើកម្មដទៃណា កម្មនោះ ជាកម្មដែលសង្ឃមិនបានធ្វើ ។ ភិក្ខុអាពាធឱ្យតែឆន្ទៈប៉ុណ្ណោះ មិនឱ្យបារិសុទ្ធិ ទាំងឧបោសថទាំងកម្មរបស់ភិក្ខុសង្ឃជាការសង្ឃធ្វើហើយពិត តែឧបោសថរបស់ភិក្ខុដែលឱ្យឆន្ទៈ មិន ចាត់ថា លោកបានធ្វើឡើយ ។ បើសូម្បីភិក្ខុរូបខ្លះ អធិដ្ឋានឧបោសថក្នុងស្ទឹង ឬក្នុងសីមាហើយទើបមក លោករមែងមិនបានដើម្បីនៅ ដោយគិតថា "យើងធ្វើឧបោសថហើយ" ត្រូវឱ្យសាមគ្គី ឬ ឆន្ទៈ ។

[១៨៤] ពាក្យថា សរេតិបិ ឧបោសថំ នបិ សរេតិ : រលឹកឧបោសថបានខ្លះ មិនបានខ្លះ មានសេចក្តីថា ពេលខ្លះក៏រលឹកបាន ពេលខ្លះក៏រលឹកមិនបាន ។

ពាក្យថា អត្ថិ នេវ សរេតិ : រលឹកមិនបានសោះក៏មាន មានសេចក្តីថា ភិក្ខុឆ្កួតរូបណា រលឹកមិនបានឡើយ ដោយចំណែកមួយ កិច្ច

ដែលនឹងត្រូវឱ្យសន្មតដល់ភិក្ខុឆ្កួតរូបនោះ រមែងមិនមាន ។ សូម្បីភិក្ខុឆ្កួតនោះ មិនមក កម្មក៏មិនកម្រើក ។

[១៨៥] ប្រើនបទថា សោ ទេសោ សម្មជ្ជិតព្វោ : ត្រូវភិក្ខុនោះបោសប្រទេសនោះហើយ បានដល់ គប្បីបោសប្រទេសនោះ ។ ពីរបទថា សោ ទេសោ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។

ពាក្យថា បានីយំ បរិភោជនីយំ : ទឹកឆាន់ ទឹកប្រើប្រាស់ ជាដើម មានសេចក្ដីជាក់ច្បាស់ហើយ ។ ក៏ព្រោះហេតុអ្វីហ្ន៎ ទើបព្រះមានព្រះភាគត្រាស់ពាក្យនោះទុក ? ដើម្បីសម្ដែងកិច្ចមានបុព្វករណៈជាដើមនៃឧបោសថ ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ៖

"ការបោសសំអាត អុជប្រទីប តាំងទឹកឆាន់ ទឹកប្រើប្រាស់ ព្រមទាំងក្រាលអាសនៈទាំងនេះ ហៅថា បុព្វករណៈរបស់ឧបោសថ" ។

កម្ម ៤ យ៉ាងនេះ លោកហៅថា បុព្វករណៈ ដោយប្រការដូច្នេះ ។

នាំឆន្ទៈ បារិសុទ្ធិ ប្រាប់រដូវ រាប់ភិក្ខុ ទូន្មានទាងភិក្ខុនីទាំងនេះ ហៅថា បុព្វកិច្ចនៃឧបោសថ ។

កម្ម ៥ យ៉ាងនេះ លោកពោលថា បុព្វកិច្ច ព្រោះនឹងត្រូវធ្វើខាងក្រោយបុព្វករណៈ ។

ថ្ងៃឧបោសថ ១ ភិក្ខុដែលចូលធ្វើកម្ម មានចំនួនប៉ុនណា ១ សភាគាបត្តិមិនមាន ១ បុគ្គលគួរវៀរមិនមានក្នុងហត្ថបាសសង្ឃនោះ ១ រួមហៅថា បត្តកល្លៈ ប្រែថា មានសេចក្តីព្រមព្រៀងដ៏សមគួរ ។

លក្ខណៈ ៤ ប្រការនេះ លោកហៅថា បត្តកល្លៈ ។

ពាក្យថា តេហិ សទ្ធឹ : ជាមួយនឹងភិក្ខុទាំងឡាយនោះ មានសេចក្តីថា គប្បីធ្វើបុព្វករណៈជាដើមទាំងនេះ ហើយធ្វើឧបោសថជាមួយភិក្ខុទាំងឡាយ ដែលមកហើយទាំងអស់នោះ ។

វិនិច្ឆ័យក្នុងពាក្យថា អជ្ជ មេ ឧបោសថោ : ថ្ងៃនេះ ជាថ្ងៃឧបោសថរបស់អញ នេះ គប្បីជ្រាបដូច្នេះ ៖

បើជាថ្ងៃ១៥ នឹងអធិដ្ឋានថា អជ្ជ មេ ឧបោសថោ បណ្ណរសោ : ថ្ងៃនេះ ជាថ្ងៃឧបោសថទី ១៥ របស់អញ ដូច្នេះខ្លះ ក៏គួរ ។ សូម្បីក្នុងឧបោសថ ថ្ងៃ ១៤ ក៏ន័យនេះឯង ។

[១៨៦] ពាក្យថា ភគវតា បញ្ញត្តំ : ព្រះមានព្រះភាគ ទ្រង់បញ្ញត្តហើយថា "សាបត្តិកេន ឧបោសថោ កាតព្វោ : មិនត្រូវ ភិក្ខុប្រកបដោយអាបត្តិធ្វើឧបោសថទេ" នេះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា សេចក្តីនោះ ព្រះអង្គទ្រង់បញ្ញត្តហើយ ដោយពាក្យជាដើមថា យស្ស សិយា អាបត្តិ : លោកអង្គណាមានអាបត្តិ( លោកអង្គនោះត្រូវសម្តែង

បេញ្ញ)១ ដោយបញ្ញត្តិការឱ្យបារិសុទ្ធិ១ ដោយបញ្ញត្តិបារិសុទ្ធិ ឧបោសថ១ ។

ពណ៌នាបារិសុទ្ធិនិងឆន្ទៈ ចប់

# ពណ៌នាការសម្តែងអាបត្តិ

ពាក្យថា ឥត្ថន្នាមំ អាបត្តឹ : ខ្ញុំត្រូវអាបត្តិឈ្មោះនេះ មានសេចក្តីថា បណ្តាអាបត្តិ មានអាបត្តិថុល្លច្ច័យជាដើម គប្បីបញ្ចេញឈ្មោះអាបត្តិ១ ពោលយ៉ាងនេះថា ថុល្លច្ចយំ អាបត្តិំ, ទុក្កដំ អាបត្តឹ ។

ពាក្យថា តំ បដិទេសេមិ : ខ្ញុំសូមសម្តែងនូវអាបត្តិនោះ នេះសូម្បីពោលថា តំ តុម្ហមូលេ បដិទេសេមិ : ខ្ញុំព្រះករុណាសម្តែងនូវអាបត្តិនោះ ក្នុងសំណាក់លោក ដូច្នេះ រមែងជាការពោលប្រពៃ ដូចគ្នា ។

ចំណែកពាក្យថា បស្សសិ : លោកឃើញឬ នេះ ភិក្ខុចាស់គប្បីពោលចំពោះភិក្ខុអ្នកសម្តែងយ៉ាងនេះថា បស្សសិ អាវុសោ តំ អាបត្តឹ : លោកដ៏មានអាយុឃើញអាបត្តិនោះឬ ? ភិក្ខុនីគប្បីពោលចំពោះភិក្ខុ

ចាស់អ្នកសម្តែងយ៉ាងនេះថា បស្សថ ភន្តេ តំ អាបត្តឹ : លោកម្ចាស់ឃើញអាបត្តិនោះឬ ?

ក៏ពាក្យថា អាម បស្សាមិ : ករុណា ខ្ញុំឃើញ នេះ សូម្បីភិក្ខុទីអ្នកសម្តែងឆ្លើយយ៉ាងនេះថា អាម ភន្តេ បស្សាមិ : ករុណាលោកម្ចាស់ ខ្ញុំព្រះករុណាឃើញ ។ ភិក្ខុចាស់ឆ្លើយថា អាម អាវុសោ បស្សាមិ ករុណាអ្នកមានអាយុ ខ្ញុំព្រះករុណាឃើញ, រមែងជាពាក្យពោលប្រពៃហើយដូចគ្នា ។

ចំណែកវិនិច្ឆ័យក្នុងពាក្យថា អាយតឹ សំវរេយ្យាសិ : លោកគប្បីសង្រួមតទៅ នេះ គប្បីជ្រាបដូច្នេះ ៖

បើភិក្ខុអ្នកសម្តែងចាស់ជាង ភិក្ខុអ្នកទទួលអាបត្តិគប្បីពោលថា អាយតឹ សំវរេយ្យាថ : សូមលោកម្ចាស់ សង្រួមតទៅ ។

ចំណែកអ្នកសម្តែងបានទទួលតបយ៉ាងនោះហើយ គប្បីពោលថា សាធុ សុដ្ឋុ សំវរិស្សាមិ : ល្អណាស់ ខ្ញុំព្រះករុណា នឹងសង្រួមដោយល្អ ដូច្នេះ ។

វិនិច្ឆ័យក្នុងពាក្យថា យទា ឆិព្វេមតិកោ : កាលណាអស់

សង្ស័យ នេះ គប្បីជ្រាប ដូច្នេះ ៖

ក្នុងអនុកអដ្ឋកថា លោកឆ្លើយថា បើជាអ្នកមិនអស់សេចក្តីសង្ស័យ សូម្បីនឹងសម្តែងបញ្ចេញវត្ថុ ក៏គួរ វិធីសម្តែងក្នុងអាបត្តិដែលសង្ស័យនោះដូច្នេះ ៖

កាលព្រះអាទិត្យត្រូវពពកបាំង ភិក្ខុឆាន់បណ្តើរមានសេចក្តីសង្ស័យថា "នេះនឹងជាកាលឬវិកាលហ្ន៎ ?" ភិក្ខុនោះគប្បីបញ្ជាក់វត្ថុយ៉ាងនេះថា "លោកដ៏ចម្រើន ខ្ញុំព្រះករុណាមានសេចក្តីសង្ស័យ ឆាន់ហើយ បើជាកាលគួរ ខ្ញុំព្រះករុណាត្រូវទុក្កដច្រើន បើមិនមែនជាកាលគួរ ខ្ញុំព្រះករុណាត្រូវអាបត្តិបាចិត្តិយច្រើន" ដូច្នេះហើយ គប្បីពោលថា "លោកដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវអាបត្តិពួកណា ត្រូវអាបត្តិទុក្កដច្រើនក្តី ត្រូវអាបត្តិបាចិត្តិយច្រើនក្តី ព្រោះវត្ថុនោះ ខ្ញុំព្រះករុណាសម្តែងអាបត្តិទាំងនោះ ក្នុងសំណាក់លោក" ។ ក្នុងអាបត្តិទាំងពួងក៏ន័យនេះ ។

[១៨៧] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ សភាគាបត្តិ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ត្រូវសម្តែង)អាបត្តិស្មើភាគគ្នាទេ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុទាំង ២ រូប ត្រូវអាបត្តិណា ដោយវត្ថុរួមគ្នា មានវិកាលភោជនជាដើម, អាបត្តិបែបនោះ លោកហៅថា វត្ថុសភាគ ចំណែកភិក្ខុដែលត្រូវអាបត្តិ ព្រោះវិកាលភោជនជាបច្ច័យ សមគួរដើម្បីសម្តែងក្នុងសំណាក់របស់ភិក្ខុដែលត្រូវអាបត្តិ ព្រោះអនតិរិត្តភោជនជាបច្ច័យ ។

ក៏អាបត្តិដែលមានវត្ថុរួមគ្នានេះសោត ដែលភិក្ខុសម្តែងហើយ ជាការសម្តែង ហើយដោយល្អតែម្តង, តែលោកទាំង ២ រមែងត្រូវអាបត្តិទុក្កដដទៃ គឺ អ្នកសម្តែងត្រូវព្រោះការសម្តែង និងអ្នកទទួលត្រូវព្រោះការទទួល, អាបត្តិទុក្កដដែលត្រូវព្រោះសម្តែងនិងទទួលនោះ ជាអាបត្តិមានវត្ថុផ្សេងគ្នា, ព្រោះដូច្នោះ សមគួរសម្តែងដល់គ្នានិងគ្នាបាន ។

[១៨៨] វិនិច្ឆ័យក្នុងពាក្យថា សាមន្តោ ភិក្ខូ ឯវមស្ស វចនីយោ : **គប្បីនិយាយនឹងភិក្ខុ(អង្គុយ)ជិតខាងយ៉ាងនេះ** នេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងអន្ធកអដ្ឋកថាថា គប្បីប្រាប់ភិក្ខុដែលជាសភាគគ្នាប៉ុណ្ណោះ ។ ពិតមែន កាលប្រាប់ដល់ភិក្ខុដែលជាវិសភាគគ្នា សេចក្តីទាស់ទែង ការឈ្លោះ និងការបែកគ្នានៃសង្ឃជាដើម រមែងកើតបាន ព្រោះហេតុនោះ

ទើបមិនគួរប្រាប់ដល់លោក តែគប្បីធ្វើសេចក្តីតាំងចិត្តថា "យើងចេញចាកទីនេះហើយនឹងសម្តែង" ដូច្នេះហើយ ធ្វើឧបោសថចុះ ។

ពណ៌នាការសម្តែងអាបត្តិ ចប់

## ពណ៌នាការធ្វើឧបោសថមិនត្រូវអាបត្តិ ១៥ យ៉ាងជាដើម

[១៩១] វិនិច្ឆ័យក្នុងអនាបត្តិបណ្ណរសកៈគប្បីជ្រាបដូច្នេះ ៖

ពាក្យថា តេ ន ជានន្តិ : ភិក្ខុនោះ មិនដឹង មានសេចក្តីថា អាវាសិកភិក្ខុទាំងនោះ មិនដឹងថា ភិក្ខុទាំងឡាយចូលសីមាហើយ ឬមិនដឹងថា កំពុងចូល ។

ពាក្យថា អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ : ពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងវេលានោះ មានសេចក្តីថា ពួកអាវាសិកភិក្ខុដទៃ ទៅកាន់ស្រុក ឬព្រៃដោយករណីយកិច្ច យ៉ាងណាមួយហើយមកកាន់ស្ថានទីដែលភិក្ខុទាំងនោះ អង្គុយហើយ ។

ពាក្យថា វគ្គា សមគ្គសញ្ញិនោ : ជាពួកសម្គាល់ថា ព្រមព្រៀងគ្នា មានសេចក្តីថា ពួកអាវាសិកភិក្ខុ ឈ្មោះថា ជាពួក ព្រោះពួកភិក្ខុដទៃនោះ ឈានកន្លងសីមាចូលមក តែពួកលោក ឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ថា ព្រមព្រៀង ព្រោះមិនជ្រាបនូវពួកភិក្ខុដទៃនោះ

ដែលឈានកន្លងសីមាចូលមក ។

[១៩២] វិនិច្ឆ័យក្នុងវគ្គាសមគ្គសញ្ញិនោបណ្ណរសកៈ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា តេ ជានន្តិ : ភិក្ខុនោះដឹង មានសេចក្ដីថា ពួកអាវាសិកភិក្ខុស្ថិតនៅលើភ្នំ ឬលើគោក ឃើញពួកភិក្ខុដទៃឈានកន្លងសីមាចូលមកហើយ ឬកំពុងឈានកន្លងចូលមកតែពួកលោកអ្នកមាន សេចក្ដីសម្គាល់ថា "ព្រមព្រៀង" ព្រោះមិនដឹង ឬព្រោះសម្គាល់ថា "ទីនេះជាអ្នកនាំគ្នាមកហើយ" ។ វេមតិកបណ្ណរសកៈ មានអត្ថងាយយល់ទាំងអស់ ។

[១៩៤] វិនិច្ឆ័យក្នុងកុក្កុច្ចបកតបណ្ណរសកៈ គប្បីជ្រាបដូច្នេះ ៖

បុគ្គលអ្នកត្រូវសេចក្ដីចង់គ្របសង្កត់ហើយ លោកពោលថា "អ្នកដែលចំណាន់រូបរឹតទុកហើយ" យ៉ាងណា ភិក្ខុទាំងឡាយនោះ សូម្បីធ្វើសេចក្ដីសន្និដ្ឋានក្នុងកាលខាងដើមហើយនៅ តែមានសេចក្ដីវង្វៀសពោលគឺ ភាពជាអ្នកមានសេចក្ដីសម្គាល់ថា ជាការគួរ ក្នុងការមិនគួរគ្របសង្កត់[១], ក្នុងខណៈធ្វើ គប្បីជ្រាបថា "អ្នកដែលសេចក្ដីវង្វៀសរូបរឹតទុកហើយ" យ៉ាងនោះ ។

---

១. ពួកភិក្ខុទាំងនោះ សំគាល់ថា "គួរធ្វើឧបោសថ" ទាំងដែលដឹងថា "មានពួកអាវាសិកភិក្ខុដទៃ មិនទាន់មកដល់" ដែលមិនគួរធ្វើ, សេចក្តីសំគាល់ខុសនេះ បានគ្របសង្កត់ពួកលោកហើយ ។ ច្បាប់ភូមា និងថៃខ្លះ សសេរប្រែឡំថា អកប្បិយេ អកប្បិយសញ្ញិតាសន្នាតេន ។ ចូរមើលបិដក

[១៩៥] ក្នុងភេទបុរេក្ខារបណ្ណរសកៈ (មានបំណាងទីងបំបែក ១៥ ប្រការ) លោកពិន័យថុល្លច្ច័យ ព្រោះហេតុដែលអកុសលចិត្តខ្លាំងក្លា ។

[១៩៦] ក្នុងអាវាសិកេន អាគន្តុកបេយ្យាល (ដោយបំព្រួញពួកអាគន្តុកនឹងអាវាសិក) គប្បីជ្រាបពាក្យជាដើមថា តេ ន ជានន្តិ អត្ថញ្ញេ អាគន្តុកា : ភិក្ខុទាំងនោះមិនដឹងថា ពួកអាគន្តុកដទៃ ដូចពាក្យដែលបានពោលហើយក្នុងអាវាសកេន អាវាសិកបេយ្យាលៈ ដែលមានមកមុនថា តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ជាដើម ។

ចំណែកក្នុងអាគន្តុកេន អាវាសិកបេយ្យាលៈ គប្បីថែមពាក្យថា អាគន្តុកាភិក្ខូ សន្និបតន្តិ ដូចពាក្យដែលមកក្នុង បុរិមបេយ្យាលៈថា អាវាសិកា ភិក្ខូសន្និបតន្តិ តែក្នុងអាគន្តុកេន អាគន្តុកបេយ្យាលៈ គប្បីប្រកប ដោយអំណាចភិក្ខុអាគន្តុកៈ ក្នុងបទទាំង ២ ដូច្នេះឯង ។

[១៩៧] វិនិច្ឆ័យក្នុងពាក្យថា អាវាសិកានំ ភិក្ខូនំ ចាតុទ្ទសោ ហោតិ, អាគន្តុកានំ បណ្ណរសោ : បើក្នុងថ្ងៃទី ១៤ ជាថ្ងៃរបស់ពួក អាវាសិកភិក្ខុថ្ងៃទី ១៥ ជាថ្ងៃរបស់ពួកអាគន្តុកភិក្ខុ នេះ គប្បីជ្រាប ដូច្នេះ ៖

ឧបោសថរបស់អាគន្តុកៈពួកណា ជាថ្ងៃ ១៥ គប្បីជ្រាបថា អាគន្តុកៈទាំងនោះ មកហើយចាកពីក្រៅព្រំដែន ឬបានធ្វើឧបោសថដែលកន្លងទៅហើយជាថ្ងៃ ១៤ ។

ពាក្យថា អាវាសិកានំ អនុវត្តិតព្វំ : ប្រព្រឹត្តតាមអាវាសិកភិក្ខុ មានសេចក្តីថា កាលពួកអាវាសិកភិក្ខុ ធ្វើបុព្វកិច្ចថា អជ្ជុបោសថោ ចាតុទ្ទសោ ឧបោសថថ្ងៃនេះ ១៤, ពួកភិក្ខុអាគន្តុកៈ គប្បីស្របតាម គឺមិនត្រូវជំទាស់ ។

ពាក្យថា ឆាកាមា ធាតព្វា : មិនប្រាថ្នា មិនត្រូវឱ្យ មានសេចក្តីថា សាមគ្គីដែលពួកអាវាសិកភិក្ខុ មិនគប្បីឱ្យដល់ពួកភិក្ខុអាគន្តុកៈ ដោយសេចក្តីមិនពេញចិត្ត ។

[១៩៨] បទថា អាវាសិកាការំ : អាការរបស់អាវាសិកភិក្ខុ បានដល់ អាការ អធិប្បាយថា អាចារៈរបស់អាវាសិកភិក្ខុ ។ ក្នុងបទ

ទាំងពួង ក៏ន័យនេះ ។

សភាពជាគ្រឿងចាប់អាចារសណ្ឋាន របស់អាបត្តិកភិក្ខុទាំងនោះ ថា ភិក្ខុទាំងនេះ ជាអ្នកដល់ព្រមដោយវត្ថុឬទេ ? ឈ្មោះថា អាការ ។

ធម្មជាតិដែលស១ឱ្យដឹងអាបត្តិកភិក្ខុទាំងនោះ ដែលពួនសម្ងំនៅក្នុងទីនោះ ៗ អធិប្បាយថា ដែលឱ្យដឹងបាន សូម្បីមើលមិនឃើញ, ឈ្មោះថា លិង្គ ។

ធម្មជាតិជាទីឃើញហើយដឹងនូវអាបត្តិកភិក្ខុទាំងនោះថា "មាន" ឈ្មោះថា និមិត្ត ។

សភាពជាគ្រឿងបង្ហាញនូវអាបត្តិកភិក្ខុទាំងនោះថា "ជាអ្នកមានបរិក្ខារដូច្នេះ" អធិប្បាយថា ជាហេតុបានអាងដូច្នោះ ឈ្មោះថា ឧទ្ទេស ។

ពាក្យថា អាការនោះជាដើមទាំងអស់ ជាឈ្មោះរបស់សេនាសនបរិក្ខារផ្សេង ៗ មានគ្រែនិងតាំងដែលចាត់តាំងទុកជាការល្អជាដើម និងជាឈ្មោះរបស់សំឡេងជើងជាដើម ក៏ឯពាក្យថា **អាការជាដើម** នោះ គប្បីប្រកបតាមដែលគួរប្រកប សូម្បីក្នុងអាការរបស់ភិក្ខុអាគន្តុកៈជាដើម

១. ដីកានិងយោជនា ពន្យល់ គមយតិ ថា ពោធេតិ ដោយន័យនេះ ក៏ប្រែថា ធម្មជាតិដែល ឱ្យដឹង ។ វចនានុក្រមស្តេចជួនណាតថា សម្ដែងអាការឱ្យឃើញច្បាស់, បញ្ចេញបែបឱ្យឃើញ ជាក់ : សសេចក្តី សហេតុ ។ ហែកកេរ្តិ៍ : សកេរ្តិ៍ សកេរ្តិ៍ សគល់ ។ ឬនិយាយថា "សឱ្យឃើញ" គឺ បញ្ជាក់ឱ្យដឹង ។
ក៏ន័យនេះឯង ។

បណ្ដាបទទាំងនោះ បទថា អញ្ញាតកំ : ដែលខ្លួនមិនស្គាល់ បានដល់ ជារបស់នៃភិក្ខុពួកដទៃ ។

បីបទថា ធាធានំ ធោតំ ឧទកនិស្សេកំ : ទឹកសម្រាប់លាងជើង ទឹកសម្រាប់ស្រោចជើង បានដល់ ស្ថានទីស្រោចទឹកនៃជើងទាំងឡាយ ដែលលាងហើយ ។ ឯកវចនៈ ក្នុងបទថា ធោតំ : លាង គប្បីជ្រាបក្នុងអត្ថនៃពហុវចនៈ ។

ម្យ៉ាងទៀត បាឋៈថា ធាធានំ ធោតឧទកនិស្សេកំ ។ មានសេចក្តីថា ស្ថានជាទីស្រោចទឹកសម្រាប់លាងជើងទាំងឡាយ ។

[១៩៩] វិនិច្ឆ័យក្នុងនានាសំវាសកាទិវត្ថុ គប្បីជ្រាបដូច្នេះ ៖

បទថា សមានសំវាសកទិដ្ឋី : ឃើញថាជាអ្នកមានសំវាសស្មើគ្នា បានដល់ សេចក្តីឃើញថា អាវាសិកភិក្ខុទាំងនេះ មានសំវាសស្មើគ្នា ។

បទថា ន បុច្ឆន្តិ : ហើយក៏មិនបានសួរ បានដល់ មិនសួរដល់លទ្ធិរបស់អាវាសិកភិក្ខុទាំងនោះ គឺ មិនសួរជាមុន ធ្វើវត្តនិងវត្តអាស្រ័យ (គឺវត្តធំវត្តតូច) ហើយ ធ្វើឧបោសថរួមគ្នា ។

បទថា នាភិវិតរន្តិ : ក៏មិនអាចគ្របសង្កត់បាន បានដល់ មិនអាចទឹងញាំញី គឺ មិនអាចគ្របសង្កត់នូវសភាពដែលជានានាសំវាសគ្នាបាន អធិប្បាយថា ឱ្យអាវាសិកភិក្ខុទាំងនោះ លះបង់ទិដ្ឋិនោះ មិនបាន ។

[២០០] ពាក្យថា សភិក្ខុកា អាវាសា : ពីអាវាសដែលមានភិក្ខុ មានសេចក្តីថា ភិក្ខុទាំងឡាយជាអ្នកធ្វើឧបោសថ មាននៅក្នុងអាវាសណា ភិក្ខុមិនអាចចេញចាកអាវាសនោះ ទៅកាន់អាវាសណាក្នុងថ្ងៃនោះ, អាវាសនោះ នៅមិនទាន់បានធ្វើឧបោសថ មិនគួរទៅ ។

ពីរបទថា អញ្ញត្រ សង្ឃេន : វៀរលែងតែសង្ឃ បានដល់ វៀរចាកភិក្ខុទាំងឡាយ ដែលគ្រប់ចំនួនជាសង្ឃ ។

ពីរបទថា អញ្ញត្រ អន្តរាយា : វៀរលែងតែអន្តរាយ បានដល់ វៀរអន្តរាយ ១០ យ៉ាងដែលពោលហើយក្នុងកាលមុនចេញ ។ ប៉ុន្តែថា កាលមានអន្តរាយ ក៏គួរទឹងទៅជាមួយនឹងសង្ឃ ។ មានខ្លួនជាគម្រប់ ៤

ដោយកំណាត់យ៉ាងទាបបំផុត ។

ទឹកទន្លេណាមួយ មានសាលានវកម្មជាដើម ឈ្មោះថា អនាវាស ។ ដូចជាថា អាវាសជាដើមភិក្ខុមិនគួរទៅ យ៉ាងណា បើភិក្ខុទាំងឡាយធ្វើឧបោសថរួមគ្នាក្នុងវត្ត, សីមាក្តី ស្រុកក្តី ដែលភិក្ខុមិនគួរទៅដើម្បីអធិដ្ឋានឧបោសថ ក៏យ៉ាងនោះ តែបើមានភិក្ខុខ្លះ នៅក្នុងសីមានិងស្រុកនេះសោត នឹងទៅកាន់សំណាក់ភិក្ខុនោះ គួរ ។ នឹងចេញពីអាវាសទៅ សូម្បីលះឧបោសថចេញហើយ គួរ ។ ភិក្ខុណាទៅហើយយ៉ាងនោះ រមែងបានសូម្បីដើម្បីអធិដ្ឋានដែលភិក្ខុសូម្បីនៅព្រៃ ក្នុងថ្ងៃឧបោសថ ត្រាច់បិណ្ឌបាតក្នុងស្រុកហើយ ត្រូវត្រឡប់ទៅវត្តរបស់ខ្លួនប៉ុណ្ណោះ ។ បើចូលទៅកាន់វត្តដទៃ ត្រូវធ្វើឧបោសថក្នុងវត្តនោះមុនសិនសឹមទៅ, មិនធ្វើជាមុនទេ ហើយចេញទៅ មិនគួរ ។

ពាក្យថា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុំ : ទាំងដឹងថាអាវាសណាដែលខ្លួនអាចទៅទាន់ក្នុងថ្ងៃនេះបានជាប្រាកដ មានសេចក្តីថា ភិក្ខុគប្បីជ្រាបនូវអាវាសណាថា យើងអាចទៅទីនោះបាន ក្នុងថ្ងៃនេះឯងអាវាសបែបនោះគួរទៅ ។ ពិតមែន ភិក្ខុនេះ សូម្បីធ្វើឧបោសថជាមួយនឹងភិក្ខុទាំងឡាយក្នុងអាវាសនោះ នឹងជាអ្នកមិនធ្វើអន្តរាយដល់ឧបោសថ

ឡើយ ដូច្នេះឯង ។

[២០១] ការចូលកាន់ហត្ថបាសប៉ុណ្ណោះ ជាប្រមាណ ក្នុងពាក្យថា ភិក្ខុនិយា និសិន្នបរិសាយ : ភិក្ខុនីបរិស័ទដែលអង្គុយ ជាដើម ។

[២០២] ពាក្យថា អញ្ញត្រ អវុដ្ឋិតាយ បរិសាយ : វៀរលែងតែបរិស័ទមិនទាន់ក្រោកចេញ មានសេចក្ដីថា ពិតមែន ដែលឈ្មោះថា ការឱ្យបារិវាសិយបារិសុទ្ធិ (មានបរិស័ទក្រោកចេញទៅហើយ) នេះ រមែងមិនគួរ ចាប់តាំងពីបរិស័ទ ក្រោកចេញទៅ, តែកាលបរិស័ទមិនទាន់ក្រោកចេញទៅ រមែងគួរ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "វៀរលែងតែបរិស័ទមិនទាន់ក្រោកចេញទៅ" ។ លក្ខណៈនៃបារិវាសិយបារិសុទ្ធិនោះ គប្បីកាន់យកអំពីវណ្ណនានៃបារិវាសិយឆន្ទទានសិក្ខាបទក្នុងភិក្ខុនីវិភង្គ[១] ។

[២០៣] ពាក្យថា អនុបោសថេ : ថ្ងៃដែលមិនមែនជាថ្ងៃឧបោសថ នោះ បានដល់ ថ្ងៃដទៃក្រៅអំពីថ្ងៃឧបោសថ ២ ថ្ងៃនេះ គឺ ថ្ងៃឧបោសថ ទី ១៤ មួយ ថ្ងៃឧបោសថ ទី ១៥ មួយ ។

[២០៤] ពាក្យថា អញ្ញត្រ សង្ឃសាមគ្គិយា : វៀរសង្ឃសាមគ្គីបែបនោះចេញ មានសេចក្ដីថា កាលសង្ឃបែកគ្នាហើយសង្ឃ

សាមគ្គីយ៉ាងណា ដែលសង្ឃត្រឡប់ ធ្វើបានទៀត ដូចសង្ឃសាមគ្គី–

១. សមន្ត. បាចិ. ៤. ៤៣៥ ។

របស់ភិក្ខុកោសម្ពី វៀរសង្ឃសាមគ្គីបែបនោះចេញ ។ ក៏ឯក្នុងកាលនោះ សង្ឃគប្បីធ្វើឧបោសថសូធ្យថា សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ សាមគ្គី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា ថ្ងៃនេះជាថ្ងៃឧបោសថព្រមព្រៀងគ្នា ។

មួយទៀត ភិក្ខុពួកណា កាលមានវិវាទគ្នាបន្តិចបន្តួច មិនជាសំខាន់ ទើបវៀរឧបោសថចេញហើយ ត្រឡប់ជាអ្នកព្រមព្រៀងគ្នាទៀត ភិក្ខុទាំងនោះ ត្រូវធ្វើឧបោសថពិត ដូច្នេះឯង ។

ពណ៌នាការធ្វើឧបោសថមិនត្រូវអាបត្តិ ១៥ យ៉ាងជាដើម ចប់

## ឧបោសថក្ខន្ធកវណ្ណនា ចប់ ២

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### មហាវគ្គ

## បឋមភាគ

## ៦

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### មហាវគ្គ

## ទុតិយភាគ

## ៧

# ៣. វស្សូបនាយិកក្ខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងរឿងវស្សូបនាយិកក្ខន្ធកៈ

[១] វិនិច្ឆ័យក្នុងរឿងវស្សូបនាយិកក្ខន្ធកគប្បីជ្រាបដូច្នេះ ៖

បទថា អបញ្ញត្តោ : មិនទាន់បានបញ្ញត្ត បានដល់ ទ្រង់មិនទាន់បានអនុញ្ញាត ឬថា ទ្រង់មិនទាន់បានចាត់ ។

ពីរបទថា តេន ភិក្ខូ : ភិក្ខុទាំងនោះ បានដល់ ភិក្ខុទាំងឡាយនោះ ឥធ សុទំ ត្រឹមតែជានិបាត ។

សត្វទាំងឡាយអ្នកអាចទៅក្នុងអាកាសឈ្មោះថា បក្សី ។

បទថា សង្កាសយិស្សន្តិ : ហើយនឹងសម្ងំឈប់សម្រាកនៅចាំវស្សាដែរ សេចក្ដីថា បក្សីទាំងឡាយ ក៏នឹងខ្វល់ខ្វាយតិចនៅចាំទីកន្លែង ។

ពីរបទថា សង្ឃាតំ អាបាទេន្តា : ឱ្យដល់នូវសេចក្ដីស្លាប់ បានដល់ វិនាសំ អាបាទេន្តា : ឱ្យដល់នូវសេចក្ដីវិនាស ។

[២] ច្រើនបទថា វស្សានេ វស្សំ ឧបគន្តុំ : ភិក្ខុចូលវស្សាក្នុងវស្សានរដូវ សេចក្ដីថា ដើម្បីចូលចាំវស្សារហូតដល់អស់ ៣ ខែក្នុងរដូវភ្លៀង ។

ច្រើនបទថា កតិ នុ ខោ វស្សូបនាយិកា : ថ្ងៃចូលវស្សា តើមានប៉ុន្មានហ្ន៎ សេចក្តីថា ថ្ងៃចូលចាំវស្សាមានប៉ុនណាហ្ន៎ ?

វិនិច្ឆ័យក្នុងពាក្យថា អបរជ្ជុគតាយ អាសាឡ្ហិយា : ក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញបូណ៌មីខែអាសាឍ គប្បីជ្រាបដូច្នេះ ៖

ថ្ងៃ ១ នៃតិថីពេញបូណ៌មីខែអាសាឡ្ហៈនោះ ដែលកន្លងទៅហើយ ព្រោះហេតុនោះ តិថីពេញបូណ៌មីខែអាសាឡ្ហៈនោះ ទើបឈ្មោះថា ថ្ងៃបន្ទាប់ពីថ្ងៃពេញបូណ៌មីខែអាសាឡ្ហៈ, កាលតិថីពេញបូណ៌មីខែអាសាឡ្ហៈនោះ កន្លងទៅហើយ គឺឈានកន្លងហើយ ១ ថ្ងៃ អធិប្បាយថា ក្នុងថ្ងៃ ១ កេច ។ សូម្បីក្នុងន័យទី ២ ក៏មានសេចក្តីថា ១ ខែ នៃតិថីពេញបូណ៌មីខែអាសាឡ្ហៈនោះ ដែលកន្លងទៅហើយ ព្រោះហេតុនោះ តិថីពេញបូណ៌មីខែ អាសាឡ្ហៈនោះ ទើបឈ្មោះថា មាន ១ ខែកន្លងទៅហើយ ។ កាលតិថីពេញបូណ៌មីខែអាសាឡ្ហៈនោះ កន្លងទៅហើយ គឺកន្លងទៅ ១ ខែ ហើយ ។ អធិប្បាយថា កាល ១ ខែ ពេញបរិបូណ៌ ។ ព្រោះហេតុនោះ ក្នុងថ្ងៃ ១ កេច ដែលបន្ទាប់អំពីថ្ងៃពាក់កណ្តាលខែ ៨ ឬក្នុងថ្ងៃ ១ កេច ដែលបន្ទាប់ពីថ្ងៃពាក់កណ្តាលខែ ៩ បន្ទាប់ពីថ្ងៃពេញបូណ៌មីខែ ៨ ទុំះឯង ដែលភិក្ខុបំណងនឹងចាំវស្សា គប្បីចាត់ចែងវិហារ ហើយតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ គប្បីធ្វើសាមី

ចិកម្ម មានក្រាបថ្វាយបង្គំព្រះចេតិយជាដើមទាំងអស់ ឱ្យរួចស្រេចហើយ គប្បីបញ្ចេញវាចាថា ឥមស្មឹ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ : យើងទាំងឡាយនៅចាំវស្សាអស់បីខែនេះ ក្នុងអាវាសនេះ ដូច្នេះ ១ដង ឬ ២ដង ឬ ៣ដង ហើយចាំវស្សាចុះ ។

[៣] វិនិច្ឆ័យក្នុងពាក្យថា យោ បក្កមេយ្យ : ភិក្ខុណាចៀសចេញទៅ នេះ គប្បីជ្រាបដូច្នេះ ៖

គប្បីជ្រាបថា ត្រូវអាបត្តិ ព្រោះមិនអាល័យ ឬព្រោះឱ្យអរុណរះក្នុងទីដទៃ ។

[៤] វិនិច្ឆ័យក្នុងពាក្យថា យោ អតិក្កមេយ្យ : ភិក្ខុណាចេញដើរទៅ

នេះ គប្បីជ្រាបដូច្នេះ ៖

គប្បីជ្រាបថា ជាអាបត្តិច្រើនដោយរាប់ចំនួនវត្ត ។

ក៏បើថា ក្នុងថ្ងៃនោះ លោកចូលទៅកាន់ឧបចារវត្ត ១០០ ហើយកន្លងទៅគប្បីជ្រាបថា ជាអាបត្តិ ១០០ ក៏ប្រសិនបើកនូវឧបចារវត្តទៅហើយ នៅមិនទាន់ចូលឧបចារវត្តដទៃ ត្រឡប់មកវិញ គប្បីជ្រាបថា ត្រូវអាបត្តិតែមួយប៉ុណ្ណោះ ។ ភិក្ខុដែលមិនចាំវស្សាដើមព្រោះអន្តរាយឯណានីមួយ ត្រូវចាំវស្សាក្រោយ ។

[៥] ពីរបទថា វស្សំ ឧក្កឌ្ឍិតុកាមោ : ទ្រង់មានសេចក្តីប្រាថ្នាដើម្បីនឹងលើកខែ សេចក្តីថា មានព្រះបំណងនឹងបន្ថិតខែដើមនៃរដូវភ្លៀងចេញទៅ អធិប្បាយថា មានព្រះបំណងនឹងមិនរាប់ខែ ៩ នឹងឱ្យរាប់ជាខែ ៨ ទៀត ។

ពីរបទថា អាគមេ ជុណ្ហេ : ក្នុងខែខាងមុខ មានអធិប្បាយថា ក្នុងខែអធិកមាស ។

វិនិច្ឆ័យក្នុងពាក្យថា អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យប្រព្រឹត្តទៅតាមស្តេចទាំងឡាយចុះ នេះគប្បីជ្រាបដូច្នេះ ៖

ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដើម្បីអនុវត្តតាម ដោយទ្រង់ធ្វើក្នុងព្រះហឫទ័យថា ឈ្មោះថា សេចក្តីសាបសូន្យត្រឹមតែបន្តិចបន្តួចរមែងមិនមានដល់ភិក្ខុទាំងឡាយ ព្រោះបន្ថិតកាលភ្លៀងចេញទៅ ។ ព្រោះដូច្នោះ ភិក្ខុគួរអនុវត្តតាម ក្នុងកម្មដែលជាធម៌យ៉ាងដទៃបាន តែមិនគួរអនុវត្តតាមដល់អ្នកណា ៗ ក្នុងកម្មដែលមិនជាធម៌ដូច្នេះឯង ។

# កិរិយាធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ

[៦] វិនិច្ឆ័យក្នុងសត្តាហករណីយ៍ទាំងឡាយ គប្បីជ្រាបដូចតទៅនេះ ៖

ពីរបទថា សត្តាហករណីយេន គន្តុំ : ភិក្ខុទៅដោយកិច្ចដែលគួរធ្វើ បាន ៧ ថ្ងៃ មានសេចក្តីថា កិច្ចណាដែលភិក្ខុគប្បីធ្វើខាងក្នុង៧ថ្ងៃ កិច្ចនោះ ឈ្មោះថា សត្តាហករណីយ៍ តថាគតអនុញ្ញាត ដើម្បីទៅដោយសត្តាហករណីយកិច្ចនោះ ជាហេតុ ។

ពីរបទថា បហិតេ គន្តុំ : បញ្ជូនបម្រើមកហើយ មានសេចក្តីថា កាលបើទូត គឺ ជនទាំង ៧ ពួក មានភិក្ខុជាដើមនេះ បញ្ជូនទៅហើយពិត តថាគតអនុញ្ញាតដើម្បីទៅបាន ។

ច្រើនបទថា សត្តាហំ សន្និវត្តោ កាតព្វោ : ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង ៧ ថ្ងៃ មានសេចក្តីថា ភិក្ខុគប្បីត្រឡប់មកវិញក្នុង៧ ថ្ងៃប៉ុណ្ណោះ អធិប្បាយថា ភិក្ខុមិនគប្បីឱ្យអរុណទី ៨ រះឡើងក្នុងទីនោះទេ ។

តាំងពីពាក្យថា ភិក្ខុនីសង្ឃំ ឧទ្ទិស្ស : ចំពោះភិក្ខុនីសង្ឃ ជាដើមទៅ រមែងមានសេចក្តីសាបសូន្យរហូតដល់អស់ទៅ ៣ យ៉ាង គឺ វច្ចកុដិ ១ រោងភ្លើង ១ សាលារោងភ្លើង ១ ។

ពេលរក្សាវត្តជាដើម ខ្ញុំព្រះករុណា បានពោលទុកហើយ ក្នុង សិក្ខាបទ ទាំងឡាយ មានឧទ្ទោសិតសិក្ខាបទជាដើម ។

ក៏ពេលភត្ត ព្រះមានព្រះភាគត្រាស់នៅក្នុងវស្សូបនាយិកក្ខន្ធកៈនេះ ថា **រសវតី : ពេលចំអិនអាហារ** ។

ពាក្យថា **វារេយ្យំ : ការដណ្តឹង** ខ្ញុំព្រះករុណាបានពោលក្នុង សញ្ចរិតសិក្ខាបទហើយ ។

ប្រើនបទថា **បុរាយំ សុត្តន្តោ ន បលុជ្ជតិ : កុំឱ្យសូត្រនេះ សាបសូន្យទៅឡើយ** សេចក្តីថា ដរាបប៉ុនដែលព្រះសុត្តន្តៈនេះនឹងមិន វិនាសសាបសូន្យ ។

ប្រើនបទថា **អញ្ញតរំ វា បនស្ស កិច្ចំ ហោតិ ករណីយំ វា : ម្យ៉ាងទៀត ឧបាសកនោះ មានកិច្ចឯណានីមួយក្តី មានកិច្ចត្រូវធ្វើក្តី** សេចក្តីថា កិច្ចណាមួយដែលឧបាសកនោះ គួរជួសជុល រមែងជាកិច្ចគួរ ធ្វើ គួរសង្គ្រោះយកបាន ។ ក៏ក្នុងទូតដែលគេបញ្ជូនមកទាំងពួង កាល បើឧបាសកនោះ បញ្ជូនអ្នកបម្រើដោយកប្បិយ ពាក្យនេះថា "ខ្ញុំព្រះ ករុណា ប្រាថ្នានឹងថ្វាយទានផង" គួរភិក្ខុទៅបាន ឬដោយវេវចនៃ កប្បិយពាក្យទាំងនោះ ក៏បាន ។ ក៏អ្នកសិក្សាគប្បីជ្រាបលំដាប់នៃ បេយ្យាលយ៉ាងនេះ ពាក្យថា ឧបាសកឱ្យគេកសាងវិហារជាដើម ចំពោះ

ភិក្ខុសង្ឃ ចំពោះភិក្ខុច្រើនរូប ចំពោះភិក្ខុមួយរូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនីមួយរូប សិក្ខមានាច្រើនរូប សិក្ខមានាមួយរូប សាមណេរច្រើនរូប សាមណេរមួយរូប សាមណេរីច្រើនរូប ចំពោះសាមណេរីមួយរូប ឧបាសកឱ្យគេសាងលំនៅដើម្បីប្រយោជន៍ខ្លួន ដែលព្រះលោកនាថសម្តែងហើយយ៉ាងណា អ្នកសិក្សាគប្បីពោលពាក្យទាំងពួងថា គឺ ឧបាសិកា ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ គឺ សាមណេរី ... ចំពោះសង្ឃ ក៏យ៉ាងនោះដែរ ក្នុងករណីមានបការ ៧ នោះ កាលបើអ្នកទាំងអស់នោះ បញ្ជូនបម្រើមកហើយ ភិក្ខុគួរទៅបាន ។

[៧-៨] ពាក្យថា **បញ្ចន្នំ សត្តាហករណីយេន : ៥ ពួក ... ដោយករណីយកិច្ច** សេចក្តីថា សូម្បីកាលសហធម្មិកមិនបានបញ្ជូនទូតមកនិមន្ត ភិក្ខុក៏គួរទៅ ដោយហេតុដែលព្រះមានព្រះភាគ ទ្រង់សម្តែងទុកពិស្តារខាងមុខ ដោយន័យជាដើមយ៉ាងនេះថា "អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ (ដល់សហធម្មិកទាំង ៥ មានភិក្ខុជាដើមទាំងនោះ) ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ" ។ ចាំបាច់ពោលទៅថ្វីដល់អ្នកទាំងនោះបញ្ជូនទូតមក ភិក្ខុគប្បីទៅកាន់សំណាក់ភិក្ខុដោយហេតុទាំងឡាយ ១០ នេះ គឺ ភិក្ខុមាន ជម្ងឺ មានសេចក្តីមិនសប្បាយកើតឡើង មានសេចក្តីសង្ស័យ

កើតឡើង មានទិដ្ឋិអាក្រក់កើតឡើងដល់ភិក្ខុ ភិក្ខុត្រូវគរុធម៌ គួរដល់បរិវាស គួរដល់មូលាយបដិកស្សនា (ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ) គួរដល់មានត្ត គួរដល់អព្ភាន សង្ឃមានប្រាថ្នាដើម្បីនឹងធ្វើកម្ម ឬថា កម្មនោះជាកម្មដែលសង្ឃធ្វើហើយ ។ ភិក្ខុគប្បីទៅកាន់សំណាក់ភិក្ខុនី ដោយហេតុទាំង ៩ ទៅកាន់សំណាក់សិក្ខមានា ដោយហេតុ ៦ គឺ ដោយហេតុ ៤ ខាងដើមព្រមទាំងសិក្ខាកម្រើក និងសិក្ខមានាមានបំណងនឹងឧបសម្បទា ដូច្នេះ ។ សូម្បីទៅកាន់សំណាក់នៃសាមណេរ ដោយហេតុ ៦ គឺ ដោយហេតុ ៤ ខាងដើម និងសាមណេរមាន បំណងនឹងសួរវស្សា មានប្រាថ្នាដើម្បីឧបសម្បទា ដូច្នេះ ។ ដោយហេតុទាំង ៥ ជាមួយនឹងហេតុនោះ គឺ សង្ឃមានប្រាថ្នាដើម្បីផ្ចាស់នូវឧបសម្បទារបស់សាមណេររបស់សាមណេរីចេញ ហើយឱ្យនូវសិក្ខាបទ ។ សូម្បីក្នុងទីនៃមាតាបិតា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកហើយខាងមុខ ក៏ន័យដូចគ្នា ។

តែក្នុងអន្ធកអដ្ឋកថា ឆ្លើយថា ជនទាំងឡាយពួកណា ជាឧបដ្ឋាករបស់មាតានិងបិតា ដែលជាញាតិក្តី មិនមែនញាតិក្តី សូម្បីកាលជនទាំងនោះ មិនបានបញ្ជូនទូតមកនិមន្ត ភិក្ខុនឹងទៅ ក៏គួរ ។ ពាក្យនោះលោកមិនបានពោលទុកឡើយ ទាំងក្នុងអដ្ឋកថា និងបាលី ព្រោះដូច្នោះ មិនគួរនឹងកាន់យក ។

បទថា ភិក្ខុភតិកោ ៖ អ្នកធ្វើការឈ្នួល បានដល់ បុរសអ្នកនៅជាមួយភិក្ខុទាំងឡាយក្នុងវត្តជាមួយគ្នា ។

[៩] បទថា ឧទ្រិយតិ ៖ បាក់បែកទ្រុឌទ្រោម បានដល់ រង្គោះរបូតជ្រុះ ។

ពីរបទថា ភណ្ឌំ ឆេទាបីតំ ៖ កាប់យកគ្រឿងឈើ បានដល់ គ្រឿងសម្ភារៈ ដែលគេឱ្យកាត់ទុកហើយ ។

បទថា អវហាបេយ្យុំ ៖ ឱ្យគេនាំយកទៅបាន គឺ គប្បីឱ្យជញ្ជូនមក ។

បទថា ឧជ្ជាហំ កាត់បទជា ទជ្ជេ អហំ ប្រែថា ខ្ញុំព្រះករុណានឹងប្រគេន

វិនិច្ឆ័យក្នុងពាក្យថា សង្ឃករណីយេន ៖ ដោយកិច្ចការដែលសង្ឃត្រូវធ្វើ នេះ គប្បីជ្រាបដូច្នេះ ៖

កិច្ចការឯណានីមួយ ដែលភិក្ខុគប្បីធ្វើក្នុងសេនាសនៈទាំងឡាយ មានរោងឧបោសថជាដើមក្តី ក្នុងស្ថានដែលទ្រង់អនុញ្ញាត មានឆត្រនិងទីកន្លែងនៃព្រះចេតិយជាដើមក្តី ដោយហោចទៅ សូម្បីជាសេនាសនៈជារបស់ភិក្ខុគ្រប់យ៉ាង ជាកិច្ចដែលសង្ឃគប្បីធ្វើទាំងអស់, ព្រោះដូច្នោះ ដើម្បីឱ្យកិច្ចនោះសម្រេច ភិក្ខុគួរទៅ ដើម្បីជញ្ជូនសម្ភារៈជាដើមមក ឬ

ដើម្បីឱ្យវេយ្យាវច្ចករ ឱ្យតម្លៃឈ្នួលនិងវេទ្ធាន់ជាដើម ដល់ជនទាំងឡាយ មានជាងឈើជាដើម ។

វិនិច្ឆ័យក្នុងវត្តប្បទេសដែលផុតពីបាលី ក្នុងសត្តាហករណីយាធិការ គប្បីជ្រាបដូចតទៅនេះ ៖

ចំណែកភិក្ខុដែលគេមិនបាននិមន្ត ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ មិនសមគួរទៅ ។ តែបើថា ភិក្ខុបានធ្វើការកំណត់គ្នា ទុកមុនហើយ ក្នុងអាវាសធំមួយថា យើងទាំងឡាយគប្បីប្រជុំគ្នា ក្នុងថ្ងៃឯណោះ ដូច្នេះ ក៏ឈ្មោះថា ជាអ្នកដែលគេនិមន្តហើយ គួរនឹងទៅបាន ។ នឹងទៅដោយគិតថា "យើងនឹងបោកគត់ចីវរ" មិនគួរ ។ តែបើអាចារ្យនិងឧបជ្ឈាយ៍ ប្រើទៅគួរ ។ វត្តនៅក្នុងទីមិនឆ្ងាយទេ លោកទៅវត្តនោះដោយតាំងចិត្តថា យើងនឹងត្រឡប់មក ថ្ងៃនេះឯង តែមិនអាចនឹងមកឱ្យទាន់បាន គួរ ។ រមែងមិនបានដើម្បីទៅ សួម្បីដើម្បីប្រយោជន៍ដល់ឧទ្ទេស និងបរិបុច្ឆាជាដើម ។ តែរមែងបានដើម្បីទៅដោយគិតថា "យើងនឹងសួរសុខទុក្ខអាចារ្យ" បើថាអាចារ្យពោលនឹងលោកថា "លោកកុំទៅ ក្នុងថ្ងៃនេះឡើយ" ដូច្នេះ នឹងមិនត្រឡប់ ក៏គួរ ។ ទៅដើម្បីសួរសុខទុក្ខត្រកូលឧបដ្ឋាក ឬត្រកូលញាតិ រមែងមិនបាន ។

កិរិយាធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ចប់

# អន្តរាយទាំងឡាយកើតដល់ពួកភិក្ខុ

[១០] បទថា បរិបាតេន្តិបិ : ចោមរោមបង្អើលភិក្ខុទាំងនោះក្តី សេចក្តីថា ម្រឹគកាច ៗ ទាំងឡាយ មកហើយដោយជុំវិញ រមែងធ្វើឱ្យគេបចេញទៅខ្លះ ញុំាងសេចក្តីខ្លាចឱ្យកើតឡើងខ្លះ ផ្តាច់ជីវិតខ្លះ ។

បទថា អាវិសន្តិ : បីសាចទាំងនោះចូលទៅ គឺ បីសាចទាំងឡាយ រមែងចូលស្ថិតសរីរៈ ។

[១១] វិនិច្ឆ័យក្នុងពាក្យថា យេន គាមោ តេន គន្តុំ : ស្រុកជាទីគោចរមានក្នុងទីណា ជាដើម គប្បីជ្រាបដូច្នេះ ៖

បើអ្នកស្រុកគេទៅតាំងនៅមិនឆ្ងាយ ភិក្ខុគប្បីត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះហើយ ត្រឡប់មកកាន់វត្ត ចាំវស្សាចុះ ។ បើអ្នកស្រុកទៅឆ្ងាយ ក៏គប្បីទទួលអរុណក្នុងវត្តដោយវារៈ ៧ ថ្ងៃ បើមិនអាចទទួលអរុណក្នុងវត្តដោយវារៈ ៧ ថ្ងៃបាន ក៏គប្បីនៅក្នុងទីនៃភិក្ខុដែលជាសភាគគ្នាក្នុងស្រុកនោះចុះ ។

បើមនុស្សទាំងឡាយ ថ្វាយសលាកភត្តជាដើមតាមដែលធ្លាប់មក គប្បីប្រាប់ ដល់គេថា យើងមិនបាននៅក្នុងវត្តនោះទេ ។ តែកាលគេសម្រាក ក៏ពោលថា "ខ្ញុំព្រះករុណាទាំងឡាយ មិនបានថ្វាយដល់វត្ត ឬដល់ប្រាសាទ លោកម្ចាស់នៅក្នុងទីណាមួយ របស់លោកម្ចាស់ ក៏និមន្ត

ឆាន់ចុះ” ដូច្នេះ ភិក្ខុគប្បីឆាន់បានតាមសប្បាយ ភត្តនោះរមែងដល់ពួកលោកពិត ។ ក៏កាលទាយកគេពោលថា “លោកម្ចាស់ទាំងឡាយ ចូរចែកគ្នាឆាន់ក្នុងទីនៅរបស់លោកម្ចាស់ចុះ” ដូច្នេះ ភិក្ខុនៅក្នុងទីណា គប្បីនាំទៅក្នុងទីនោះ ហើយគប្បីចែកគ្នាតាមលំដាប់វស្សា ឆាន់ចុះ ។

បើពួកទាយកថ្វាយសំពត់ចំណាំវស្សា ក្នុងវេលាដែលភិក្ខុបវារណារួចហើយ ប្រសិនបើថា ភិក្ខុទាំងឡាយទទួលអរុណ ដោយវារៈ ៧ ថ្ងៃ គប្បីទទួលចុះ ។ តែភិក្ខុដែលដាច់វស្សា គប្បីប្រាប់ថា “យើងទាំងឡាយ មិនបានចាំវស្សាក្នុងវត្តនោះ យើងដាច់វស្សា” បើគេពោលថា “សេនាសនៈរបស់ពួកខ្ញុំព្រះករុណា លោកម្ចាស់ឱ្យដល់លោកម្ចាស់ពួកណា លោកម្ចាស់ពួកនោះ ចូរទទួលចុះ” ដូច្នេះ ភិក្ខុគួរទទួល ។

ចំណែករបស់គួរចែកគ្នាបាន មានចីវរជាដើម ដែលភិក្ខុបួរមកនៅក្នុងស្ថានទីថ្មីនេះដោយគិតថា “រក្សាទុកក្នុងវត្តនឹងវិនាស” គួរទៅអបលោកន៍ចែកគ្នាក្នុងវត្តពីដើមនោះ ។

ន័យសូម្បីក្នុងរបស់សង្ឃ ដែលកើតឡើងក្នុងវត្តនោះ ជាដើមថា ស្រែនិងសួន ដែលទាយកប្រគល់ទុកដាក់ដល់កប្បិយការកៈទាំងឡាយថា “លោកទាំងឡាយចូរថ្វាយបច្ច័យ ៤ ដល់លោកម្ចាស់ទាំងឡាយ ដោយតម្លៃដែលកើតអំពីស្រែ និងសួននេះ” ក៏ន័យនេះដូចគ្នា ។

ក៏របស់សង្ឃដែលគួរចែកគ្នាបាន នឹងនៅខាងក្នុងវត្ត ឬខាងក្រៅ

សីមាក៏ដោយ របស់ដែលគួរចែកគ្នាបាននោះ មិនគួរអបលោកន៍ ចែកដល់ភិក្ខុដែលតាំងនៅខាងក្រៅសីមា ។ តែរបស់សង្ឃដែលជារបស់គួរចែកគ្នាបាន ដែលតាំងនៅក្នុងខេត្តទាំង ២ សមគួរពិតដែល នឹងអបលោកន៍ ចែកដល់ភិក្ខុដែលតាំងនៅខាងក្នុងសីមា ។

អន្តរាយទាំងឡាយកើតដល់ពួកភិក្ខុ ចប់

## ការបំបែកសង្ឃកើតដល់ពួកភិក្ខុ

[១២] វិនិច្ឆ័យក្នុងពាក្យថា សង្ឃោ ភិន្នោ : សង្ឃមុខជានឹងបែកគ្នា នេះ គប្បីជ្រាបដូច្នេះ ៖

កាលសង្ឃបែកគ្នាហើយ កិច្ចដែលគួរទៅធ្វើ រមែងមិនមាន តែពាក្យថា បែកគ្នាព្រះមានព្រះភាគត្រាស់សំដៅយកសង្ឃដែលភិក្ខុសង្ស័យថា នឹងបែកគ្នា ។

វិនិច្ឆ័យក្នុងពាក្យថា សម្ពហុលាហិ ភិក្ខុនីហិ សង្ឃោ ភិន្នោ : សង្ឃមុខជានឹងបែកគ្នា ព្រោះភិក្ខុនីច្រើនរូប នេះ គប្បីជ្រាបដូច្នេះ ៖

បណ្ឌិតមិនគប្បីឃើញថា សង្ឃដែលភិក្ខុនីទាំងឡាយបំបែកហើយ ។ ពិតមែន ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា "ម្នាលឧបាលី ភិក្ខុនីមិនឈ្មោះថា បំបែកសង្ឃទេ"[១] ។ មានសេចក្តីសង្ស័យថា

---

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៦៨/៧៨ ។

ដែលភិក្ខុទាំងឡាយគប្បីអាស្រ័យភិក្ខុនីទាំងនោះ ធ្វើពួកលោកឱ្យជាកម្លាំងឧបត្ថម្ភហើយ គប្បីទម្លាយសង្ឃពួកណា ។ ព្រះមានព្រះភាគទ្រង់សំដៅយកសង្ឃពួកនោះ ត្រាស់ពាក្យនេះថា "ភិក្ខុនីច្រើនរូបព្យាយាមបំបែកសង្ឃ" ។

ការបំបែកសង្ឃកើតដល់ពួកភិក្ខុ ចប់

## ការចាំវស្សាក្នុងលំនៅរបស់គង្វាលគោ

[១៣] ស្ថានទីនៅរបស់នាយគោបាលទាំងឡាយ ឈ្មោះថា លំនៅរបស់ពួកគង្វាលគោ ។

វិនិច្ឆ័យក្នុងពាក្យថា យេន វជោ : លំនៅគង្វាលគោ ក្នុងទីណា នេះ គប្បីជ្រាបដូច្នេះ ៖

កាលភិក្ខុទៅនឹងពួកហ្វូងគោ មិនត្រូវអាបត្តិ ព្រោះដាច់វស្សា ។

បទថា ឧបកដ្ឋាយ : កាន់តែជិតហើយ គឺ ជិតចូលមកហើយ ។

វិនិច្ឆ័យក្នុងពាក្យថា សត្ថេ វស្សំ ឧបគន្តុំ : ភិក្ខុចូលចាំវស្សាក្នុងពួកឈ្មួញបាន នេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងថ្ងៃចូលវស្សា ភិក្ខុនោះគប្បីប្រាប់ពួកឧបាសកថា “អាត្មាបានខ្ទមទើបគួរ” ។

បើឧបាសកធ្វើថ្វាយ គប្បីចូលទៅក្នុងខ្ទមនោះ ហើយពោលថា ឥធ វស្សំ ឧបេមិ : **យើងចូលវស្សាក្នុងទីនេះ** ដូច្នេះ ៣ ដង ។

បើគេមិនធ្វើថ្វាយសោត គប្បីចូលចាំវស្សាក្នុងខាងក្រោមរទេះដែលតាំងនៅដោយអាការដូចរោង ។ កាលមិនបាន សូម្បីកន្លែងបែបនោះ គប្បីធ្វើសេចក្ដីអាល័យចុះ ។ តែនឹងចូលចាំវស្សាក្នុងពួករទេះ មិនគួរ ។ ត្រឹមតែចិត្តុប្បាទដែលគិតថា យើងនឹងចាំវស្សាក្នុងទីនេះ ក៏ចាត់ថា អាល័យ ។

បើថា ពួករទេះធ្វើដំណើរទៅ ដល់ថ្ងៃបវារណា គប្បីបវារណាក្នុងពួករទេះនោះឯង ។

បើពួករទេះដល់កន្លែងដែលភិក្ខុប្រាថ្នាហើយ តែនៅក្នុងវស្សានៅឡើយហើយហួសទៅ ភិក្ខុគប្បីនៅក្នុងទីដែលខ្លួនប្រាថ្នា ហើយបវារណានឹងភិក្ខុទាំងឡាយក្នុងទីនោះចុះ ។

បើសូម្បីពួករទេះឈប់ក្នុងស្រុកមួយកន្លែងក្ដី បែកគ្នាទៅក្ដី ក្នុងចន្លោះមកខាងក្នុងវស្សានោះឯង ក៏គប្បីនៅនឹងភិក្ខុទាំងឡាយក្នុងស្រុកនោះឯង ហើយបវារណាចុះ ។ នៅមិនទាន់បានបវារណា នឹងទៅអំពីទីនោះតទៅទៀត មិនគួរ ។

សម្ពន្ធីកាលនឹងចាំវស្សាក្នុងទូក ក៏គួរចូលចាំក្នុងជំបូលដូចគ្នា កាលរកជំបូលមិនបាន គប្បីធ្វើសេចក្ដីអាល័យចុះ ។

បើទូកនៅក្នុងសមុទ្ររហូតអស់ ៣ ខែ ក៏គប្បីបវារណា ក្នុងទូកនោះចុះ ។

លំដាប់នោះ បើទូកចូលដល់មាត់ច្រាំង ចំណែកភិក្ខុនេះជាអ្នកត្រូវការបន្តដំណើរទៅទៀត នឹងទៅមិនគួរ ។ គប្បីនៅក្នុងស្រុកដែលទូកចតនោះឯង ហើយបវារណានឹងភិក្ខុទាំងឡាយចុះ ។

បើសម្ពន្ធីថា ទូកនឹងទៅក្នុងទីដទៃតាមមាត់ច្រាំងប៉ុណ្ណោះ តែបើភិក្ខុចង់នៅក្នុងស្រុកដែលទូកចូលដល់ជំបូងនោះឯង ទូកចូរទៅចុះ ភិក្ខុគប្បីនៅក្នុងស្រុកនោះឯង ហើយបវារណានឹងភិក្ខុទាំងឡាយចុះ ។

បណ្ដាស្ថានទាំង ៣ គឺ ក្នុងពួកហ្វូងគោ ក្នុងពួករទេះ ក្នុងទូកមិនមានអាបត្តិព្រោះដាច់វស្សា ទាំងបានដើម្បីបវារណា ដោយបវារណាដូច្នេះឯង ។

ចំណែកក្នុងរឿងទាំងឡាយ មានរឿងថា ភិក្ខុទាំងឡាយ ជាអ្នកក្ដៅក្រហាយដោយសត្វបៀតបៀនជាដើម មានសង្ឃភេទជាទីបំផុតដែលមានមកហើយខាងដើម មិនត្រូវអាបត្តិតែម្យ៉ាង តែភិក្ខុមិនបានដើម្បីបវារណា ។

ការចាំវស្សាក្នុងលំនៅរបស់គង្វាលគោ ចប់

## ពួកភិក្ខុចូលចាំវស្សាក្នុងទីវាលជាដើម

[១៤] បទថា បិសាចិល្លិកា : ពួកបីសាច គឺ បិសាចទាំងឯង ឈ្មោះថា បីសាចិល្លិកា ។

វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ រុក្ខសុសិរេ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ចូលវស្សា)ក្នុងរូងឈើទេ នេះ គប្បីជ្រាបដូច្នេះ ៖

ទីងចាំវស្សាក្នុងរូងឈើសុទ្ធប៉ុណ្ណោះ មិនគួរ ។ តែទីងធ្វើកុដិប្រក់បាំងដោយផែនក្តារ ភ្ជាប់ទ្វារសម្រាប់ចូលចេញខាងក្នុងពោងរូងឈើធំហើយ នៅចាំវស្សា គួរ ។ សូម្បីទីងកាត់ដើមឈើ (ចាំងសំអាតក្រាលរៀបរយទុក) ធ្វើខ្ទមមានក្តារប្រក់បាំងលើដង្គត់ឈើហើយចាំវស្សា ក៏គួរដូចគ្នា ។

វិនិច្ឆ័យសូម្បីក្នុងពាក្យថា រុក្ខវិដភិយា : បង្គាបឈើ នេះ គប្បីជ្រាបដូច្នេះថា ៖

ទីងចាំវស្សាត្រឹមតែថា លើបង្គាបឈើសុទ្ធមិនគួរ ។ ប៉ុន្តែថា គប្បីចងជាពានលើបង្គាបឈើដែលធំ ហើយធ្វើឱ្យជាបន្ទប់ប្រក់បាំងដោយក្តារលើពាននោះ ហើយចាំវស្សាចុះ ។

[១៥] បទថា អសេនាសនិកេន : ឥតមានទីសេនាសនៈ សេចក្តីថា សេនាសនៈដែលប្រក់ហើយដោយគ្រឿងប្រក់ ៥ ប្រភេទ

ណាមួយ[១] ភ្ជាប់ទ្វារសម្រាប់បើកបិទបានរបស់ភិក្ខុណាមិនមាន ភិក្ខុនោះមិនគួរចាំវស្សា ។

វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ ឆវកុដិកាយ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ចូលចាំវស្សា)ក្នុងខ្ទមខ្មោចទេ នេះ គប្បីជ្រាប ដូច្នេះ ៖

ខ្ទមប្រភេទផ្សេង ៗ មានគ្រែ មានមេគ្រែជាដើម ឈ្មោះថាខ្ទមខ្មោច ។ ទីងចាំវស្សាក្នុងខ្ទមខ្មោចនោះ មិនគួរ ។ ក៏ប៉ុន្តែថា បើធ្វើខ្ទមប្រភេទដទៃក្នុងព្រៃជាទីចោលសាកសពហើយចាំវស្សា គួរ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យថា ន ភិក្ខវេ ឆត្តេ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ចូលចាំវស្សា)ក្នុងឆត្រទេ នេះ ដូច្នេះ ៖

ទីងបោះឆត្រទុកត្រង់កណ្តាលសសរ ៤ ធ្វើជញ្ជាំងជុំវិញជាប់ចម្រឹងទុក ហើយចាំវស្សា ក៏គួរ ។ កុដិនោះ ឈ្មោះថា កុដិឆត្ត ។

វិនិច្ឆ័យសូម្បីក្នុងបទថា ចាដិយា : ពាងទឹក នេះ គប្បីជ្រាប ដូច្នេះ ៖

ទីងធ្វើកុដិដោយក្បៀងយ៉ាងធំ តាមន័យដែលពោលហើយ ក្នុងរឿងឆត្រចាំវស្សា ក៏គួរ ។

---

១. សារត្ថ. បញ្ចន្នំ ឆទនានន្តិ តិណបណ្ណឥដ្ឋកសិលាសុធាសង្ខាតានំ បញ្ចន្នំ ឆទនានំ ។

## សង្ឃប្ដេជ្ញាគ្នាមិនបំបួសក្នុងកណ្ដាលវស្សា

[១៦] សេចក្ដីសូម្បីក្នុងពាក្យថា ឯវរូបា កតិកា : កតិកាមានសភាពបែបយ៉ាងនេះ នេះ មានដូច្នេះ : កតិកាសូម្បីដទៃដែលមិនជាធម៌ដូច្នេះ យ៉ាងណា កតិកានោះ មិនគួរធ្វើ ។ លក្ខណៈនៃកតិកានោះ ដែលព្រះមានព្រះភាគត្រាស់ទុកហើយក្នុងមហាវិភង្គ ។
(ចតុត្ថបារាជិក វិនីតវត្ថុ ១. ២៩៤/៣៥៩) ។

## និទានឧបនន្ទសក្យបុត្រ

[១៧] ពាក្យថា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ : ទទួលប្ដេជ្ញាថា នឹងនៅចាំវស្សាដោយបុរិមិកាវស្សា មានសេចក្ដីថា ព្រះឧបនន្ទសក្យបុត្រ បានធ្វើប្ដេជ្ញាថា "យើងនឹងចាំវស្សាក្នុងថ្ងៃចូលវស្សាដើម ក្នុងអាវាសរបស់លោកទាំងឡាយ" ។

ពាក្យថា បុរិមិកា ច ន បញ្ញាយតិ : បុរិមិកាវស្សារបស់ភិក្ខុនោះ មិនប្រាកដផង សេចក្ដីថា ការចាំវស្សាក្នុងអាវាសដែលបានប្ដេជ្ញាទុក មិនប្រាកដទេ ។

វិនិច្ឆ័យក្នុងពាក្យថា បដិស្សវេ ច អាបត្តិ ទុក្កដស្ស : ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង នេះ គប្បីជ្រាប

ដូច្នេះ ៖

រមែងជាអាបត្តិព្រោះទទួលពាក្យនេះថា លោកទាំងឡាយ ចូរចាំវស្សាក្នុងទីនេះរហូតដល់អស់ ៣ ខែនេះ ដូច្នេះតែម៉្យាងប៉ុណ្ណោះក៏ទេ, រមែងជាអាបត្តិទុក្កដ ព្រោះទទួលពាក្យនោះ ៗ សូម្បីដោយន័យជាដើមយ៉ាងនេះថា លោកទាំងឡាយចូរទទួលភិក្ខារហូតដល់អស់ ៣ ខែនេះ ខ្ញុំព្រះករុណាសូម្បីទាំង ២ នឹងនៅក្នុងទីនេះ នឹងឱ្យសម្តែងរួមគ្នា ។ ក៏បដិស្សវទុក្កដ (ទុក្កដព្រោះទទួលបេ្តជ្ញា) នោះឯង រមែងមានព្រោះហេតុគឺ ក្លែងពោលឱ្យខុសជាខាងក្រោយរបស់ភិក្ខុដែលមានចិត្តបរិសុទ្ធិពីខាងដើម ។ តែសម្រាប់ភិក្ខុដែលមានចិត្តមិនបរិសុទ្ធពីខាងដើម គួរពិន័យអាបត្តិទុក្កដ និងអាបត្តិបាចិត្តិយ គឺ ទុក្កដ ព្រោះទទួលពាក្យ, បាចិត្តិយព្រោះក្លែងពោលឱ្យខុស ។

វិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានពាក្យថា សោ តទហេវ អករណីយោ : ភិក្ខុនោះ ឥតកិច្ចការអ្វី ក៏ចៀសចេញទៅក្នុងថ្ងៃនោះជាដើម គប្បីជ្រាបដូច្នេះ ៖

បើថា ភិក្ខុមិនចូលចាំវស្សា ជៀសចេញទៅក្តី ចូលចាំវស្សាហើយញាំង ៧ ថ្ងៃឱ្យកន្លងទៅខាងក្រៅអាវាសក្តី ថ្ងៃចូលវស្សាដើមរបស់លោកមិនប្រាកដផង, លោកត្រូវអាបត្តិ ព្រោះទទួលពាក្យផង ។ ប៉ុន្តែថា មិនជាអាបត្តិដល់ភិក្ខុដែលចូលវស្សាហើយ មិនទាន់ឱ្យអរុណរះ

ឡើង សូម្បីជៀសចេញទៅដោយសត្តាហករណីយ៍ក្នុងថ្ងៃនោះតែម្តង ត្រឡប់មកខាងក្នុង៧ ថ្ងៃ ក៏នឹងបាច់ពោលទៅថ្វី នឹងគប្បីមានដល់ភិក្ខុដែលចាំវស្សាហើយ ២-៣ ថ្ងៃ ទៅដោយសត្តាហករណីយ៍ហើយត្រឡប់មកខាងក្នុង៧ ថ្ងៃ ។

វិនិច្ឆ័យសូម្បីក្នុងពាក្យថា ទ្វិហតិហំ វសិត្វា : ភិក្ខុនោះនៅអស់ពីរបីថ្ងៃ នេះ គប្បីជ្រាបដូច្នេះ ៖

គប្បីជ្រាបថា ដាច់វស្សាព្រោះកន្លងឧបចារៈទៅដោយដាច់អាល័យចេញទៅមិនគិតត្រឡប់ប៉ុណ្ណោះ ។ បើនៅមានសេចក្តីអាល័យថា យើងនឹងនៅក្នុងទីនេះ តែមិនចូលវស្សា ព្រោះរលឹកមិនបាន សេនាសនៈដែលលោកកាន់យកហើយ ក៏ជាការកាន់យកដោយល្អ លោកមិនដាច់វស្សារមែងបានដើម្បីបវារណាពិត ។

វិនិច្ឆ័យក្នុងពាក្យថា សត្តាហំ អនាគតាយ បវារណាយ : កាលបើនៅខ្វះ ៧ ថ្ងៃទៀតនឹងដល់ថ្ងៃបវារណា នេះ គប្បីជ្រាបដូច្នេះ ៖

រមែងគួរដើម្បីនឹងទៅ ចាប់ផ្តើមតាំងពីថ្ងៃ ៩ កើត នឹងត្រឡប់មកក៏ដោយ មិនត្រឡប់មកក៏ដោយ មិនជាអាបត្តិ ។ ពាក្យដ៏សេសជាពាក្យងាយយល់ទាំងអស់ ដូច្នេះឯង ។

## **វស្សូបនាយិកក្ខន្ធកវណ្ណនា ចប់**

# ៤. បវារណាខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងបវារណាខន្ធកៈ

[២០] វិនិច្ឆ័យក្នុងពាក្យថា នេវ អាលបេយ្យាម ន សល្លបេយ្យាម : បើយើងមិននិយាយគ្នា មិនចរចាគ្នា នេះ គប្បីជ្រាបដូច្នេះ ៖

ពាក្យដំបូង ឈ្មោះថា ពាក្យសាកសួរ, ពាក្យក្រោយ ៗ ឈ្មោះថា ពាក្យប្រាស្រ័យ ។

បទថា ហត្ថវិលង្ឃកេន : ដោយអាការបោយដៃ បានដល់ដោយការជួយគ្នាប្រើដៃលើក ។

[២២] បទថា បសុសំវាសំ : នៅដូចជាការនៅរបស់ចិញ្ចឹម គឺការនៅរួមគ្នា ដូចការនៅរួមរបស់ពួកបសុសត្វ ។ ពិតមែន សូម្បីពួកបសុសត្វ រមែងមិនប្រាប់សេចក្តីសុខ និងទុក្ខ ដែលកើតឡើងក្នុងខ្លួនដល់គ្នានិងគ្នា មិនធ្វើការបដិសណ្ឋារៈ យ៉ាងណា សូម្បីភិក្ខុទាំងនោះ ក៏បានធ្វើយ៉ាងនោះ ។ ព្រោះហេតុនោះ ការនៅរួមគ្នារបស់ភិក្ខុទាំងនោះទើបព្រះមានព្រះភាគត្រាស់ថា "នៅដូចជាការនៅរួមរបស់ពួកបសុសត្វ (សត្វចិញ្ចឹម)" ន័យក្នុងបទទាំងពួងដូចគ្នា ។

ពាក្យថា ន ភិក្ខវេ មូគវត្តំ តិត្ថិយសមាទានំ : ម្នាលភិក្ខុ

ទាំងឡាយ មិនត្រូវភិក្ខុសមាទានមូគវត្ត ជាដើម មានសេចក្តីថា ភិក្ខុមិនគប្បីធ្វើការសមាទានវត្តដូច្នេះថា យើងទាំងឡាយមិនគប្បីនិយាយគ្នាវហូតដល់អស់ត្រៃមាសនេះ ។ ព្រោះថា នោះជាកតិកាដែលមិនត្រឹមត្រូវតាមធម៌ ។

ការដែលភិក្ខុមកពាក់ទាក់និយាយរកគ្នានិងគ្នា ឈ្មោះថា អញ្ញមញ្ញានុលោមតា : ជាការអនុលោមដើម្បីពោលប្រដៅនូវគ្នានឹងគ្នា ។ ពិតមែន ភិក្ខុ រមែងជាអ្នកអាចថា អាចពោលអ្វី ៗ ចំពោះភិក្ខុដែលនិយាយទុកថា "សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំព្រះករុណា (កាលខ្ញុំព្រះករុណាឃើញនឹងធ្វើតាម)", តែមិនអាចពោលប្រដៅភិក្ខុក្រៅអំពីនេះទេ ការញ៉ាំងគ្នានិងគ្នា ឱ្យចេញចាកអាបត្តិទាំងឡាយ ឈ្មោះថា អាបត្តិវុដ្ឋានតា, ការដែលភិក្ខុមកតាំងព្រះវិន័យទុកជាគោលប្រព្រឹត្ត ឈ្មោះថា វិនយបុរេក្ខារតា : ជាការធ្វើវិន័យឱ្យជាប្រធាន ។

ពិតមែន ភិក្ខុដែលពោលថា "សូមលោកដ៏មានអាយុពោលប្រដៅខ្ញុំព្រះករុណាចុះ" ដូច្នេះ ព្រះមានព្រះភាគត្រាស់ថា "វិនយញ្ច បុរក្ខត្វា វិហរិស្សតិ : ជាការចេញចាកអាបត្តិ ជាការធ្វើព្រះវិន័យឱ្យជាប្រធាននឹងប្រាកដដល់អ្នកទាំងឡាយ" ។

# បវារណាវិធី

ញត្តិដែលបានទាមថា សព្វសង្គាហិកានេះថា សុណាតុ មេ ភន្តេ សង្ឃោ, អជ្ជ បវារណា, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ បវារេយ្យ : ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំព្រះករុណា ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណាកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ដូច្នេះ ។ ក៏កាលសូធ្យប្រកាសយ៉ាងនេះហើយ សង្ឃនឹងបវារណា ៣ ដង, ២ ដង, និងម្តង, ក៏គួរ; តែនឹងបវារណាឱ្យភិក្ខុមានវស្សាស្មើគ្នា បវារណាព្រមគ្នាប៉ុណ្ណោះ មិនគួរ ។ មួយទៀត កាលសូធ្យប្រកាសថា តេវាចិកំ បវារេយ្យ : សង្ឃគប្បីបវារណា ៣ ដង ដូច្នេះ ត្រូវបវារណា ៣ ដង ប៉ុណ្ណោះ ទើបគួរ នឹងបវារណាយ៉ាងដទៃ មិនគួរទេ ។ កាលសូធ្យប្រកាសថា ទ្វេវាចិកំ បវារេយ្យ : សង្ឃគប្បីបវារណា ២ ដង ដូច្នេះ នឹងបវារណា ២ ដង ឬ ៣ ដង ក៏គួរ តែនឹងបវារណាត្រឹមតែម្តង នឹងបវារណាមានវស្សាស្មើ

គ្នា មិនគួរទេ ។ ក៏កាលសូធ្យប្រកាសថា ឯកាវាចិកំ បវារេយ្យ : សង្ឃគប្បីបវារណាម្ដង ដូច្នេះ ទឹងបវារណាម្ដង ២ ដង ឬ ៣ ដង ក៏គួរ ។ តែទឹងបវារណាមានវស្សាស្មើគ្នាប៉ុណ្ណោះ មិនគួរទេ ។ កាលសូធ្យប្រកាសថា សមានវស្សិកំ បវារេយ្យ ប្រែថា គប្បីបវារណាមានវស្សាស្មើគ្នា ដូច្នេះ រមែងគួរគ្រប់វិធី ។

[២៣] បទថា អច្ឆន្តិ : នៅ គឺ ជាអ្នកនៅអង្គុយទុំះឯង មិនក្រោកឡើងទេ ។

បទថា តទនន្តរា : ក្នុងពេលដែលខ្លួនកំពុងបវារណា គឺ រហូតដល់អស់កាលចន្លោះ បវារណានោះ អធិប្បាយថា រហូតដល់អស់រយៈកាលប៉ុនដែលខ្លួន ទឹងបវារណានោះ ។

[២៤] វិនិច្ឆ័យក្នុងពាក្យថា ចាតុទ្ទសិកា ច បណ្ណរសិកា ច : ថ្ងៃទីដប់បួន ១ ថ្ងៃទីដប់ប្រាំ ១ នេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងតិថីទី ១៤ គប្បីធ្វើបុព្វកិច្ចយ៉ាងនេះថា អជ្ជ បវារណា ចាតុទ្ទសី : បវារណាថ្ងៃនេះទី ១៤, ក្នុងតិថីទី ១៥ គប្បីធ្វើបុព្វកិច្ច

យ៉ាងនេះថា **អជ្ជ បវារណា បណ្ណរសី** : បវារណាថ្ងៃនេះទី ១៥ ។

## បវារណាកម្ម

វិនិច្ឆ័យក្នុងបវារណាកម្ម គប្បីជ្រាបដូច្នេះ ៖

បើថា កាលភិក្ខុ ៥ រូប នៅក្នុងវត្តមួយជាមួយគ្នា, ភិក្ខុ៤ រូប នាំបវារណារបស់ភិក្ខុមួយរូបមក ហើយបវារណាដោយតាំងគណញត្តិ, កាល ភិក្ខុ ៤ រូប ឬ ៣ រូប នៅក្នុងវត្តមួយជាមួយគ្នា, ភិក្ខុ ៣ រូប ឬ ២ រូប នាំបវារណារបស់ភិក្ខុមួយរូបមក តាំងសង្ឃញត្តិ ហើយ បវារណា, នេះចាត់ថា **បវារណាកម្មជាពួក មិនត្រូវតាមធម៌ទាំងអស់** ។ ក៏បើថា ភិក្ខុ ៥ រូប ប្រជុំព្រមគ្នាទាំងអស់ តាំងគណញត្តិ ហើយ បវារណា; កាលភិក្ខុនៅជាមួយគ្នា ៤ រូប ឬ ៣រូប ឬ ២ រូប ប្រជុំព្រមគ្នាតាំងសង្ឃញត្តិហើយ បវារណា; នេះចាត់ថា **បវារណាកម្មព្រមព្រៀងមិនត្រូវតាមធម៌ទាំងអស់** ។ បើថា កាលភិក្ខុនៅជាមួយគ្នា ៥ រូប ៤ រូប នាំ បវារណារបស់ភិក្ខុមួយរូបមក តាំងសង្ឃញត្តិហើយ បវារណា; កាលភិក្ខុនៅជាមួយគ្នា ៤ រូប ឬ ៣ រូប, ៣ រូប ឬ ២ រូប នាំបវារណារបស់ភិក្ខុមួយរូបមក តាំងគណញត្តិហើយបវារណា; នេះចាត់ថា **បវារណាកម្មជាពួកត្រូវតាមធម៌ទាំងអស់** ។ តែបើថា ភិក្ខុ ៥ រូប ប្រជុំព្រមគ្នាសូម្បីទាំងអស់ តាំងសង្ឃញត្តិហើយ បវារណា ៤ រូប ឬ ៣ រូប ប្រជុំព្រមគ្នាតាំងគណញត្តិហើយ បវារណា ២ រូប បវារណាដល់គ្នានិងគ្នា នៅតែមួយរូប ធ្វើអធិដ្ឋានបវារណា នេះចាត់ថា

បវារណាកម្មព្រមព្រៀងត្រូវតាម ធម៌ទាំងអស់ ។

## ការឱ្យបវារណា

[២៥] វិនិច្ឆ័យក្នុងពាក្យថា ទិន្នា ហោតិ បវារណា : ឈ្មោះថា ភិក្ខុឈឺឱ្យបវារណា នេះ គប្បីជ្រាបដូច្នេះ ៖

កាលភិក្ខុអាពាធ ឱ្យបវារណាយ៉ាងនេះហើយ ភិក្ខុដែលនាំបវារណាមក គប្បីចូលទៅរកសង្ឃ បវារណាយ៉ាងនេះថា តិស្សោ ភន្តេ ភិក្ខុ សង្ឃំ បវារេតិ ទិដ្ឋេនវា សុតេន វា បរិសង្កាយ វា, វទតុ តំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិក្ករិស្សតិ ។ ទុតិយម្បិ ភន្តេ ។បេ ។ តតិយម្បិ ភន្តេ តិស្សោ ភិក្ខុ សង្ឃំ បវារេតិ ។បេ ។ បស្សន្តោ បដិក្ករិស្សតិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ភិក្ខុឈ្មោះតិស្សៈ បវារណាចំពោះសង្ឃ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី សូមសង្ឃអាស្រ័យសេចក្តីករុណា ពោលនឹងលោក, លោកឃើញហើយនឹងធ្វើតាម ។ បពិត្រព្រះសង្ឃដ៏ចម្រើន ជាគម្រប់ពីរដងផង ។ល ។ បពិត្រព្រះសង្ឃដ៏ចម្រើន ជាគម្រប់បីដងផង ភិក្ខុឈ្មោះតិស្សៈ បវារណាចំពោះសង្ឃ ។ល ។ លោកឃើញនឹងធ្វើតាម ។ តែបើភិក្ខុដែលឱ្យបវារណាជាអ្នកចាស់ជាង ភិក្ខុអ្នកនាំគប្បីពោលថា "អាយស្មា ភន្តេ តិស្សោ : បពិត្រព្រះសង្ឃដ៏ចម្រើន លោកម្ចាស់តិស្សៈ" ដូច្នេះ ។ ដោយអាការយ៉ាងនេះឯង ជាការភិក្ខុដែលនាំបវារណា បានបវារណាហើយ ដើម្បី

ប្រយោជន៍ដល់ភិក្ខុដែលឱ្យបវារណានោះ ។

## ការឱ្យឆន្ទៈ

វិនិច្ឆ័យក្នុងពាក្យថា បវារណំ ទេន្តេន ឆន្ទម្បិ ទាតុំ : ភិក្ខុកាលដែលឱ្យបវារណាហើយ ត្រូវឱ្យឆន្ទៈផង នេះ គប្បីជ្រាបដូច្នេះ ៖

ការប្រគល់ឆន្ទៈ គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងឧបោសថក្ខន្ធកៈចុះ ។ និងសូម្បីក្នុងបវារណាខន្ធកៈនេះ ការឱ្យឆន្ទៈរមែងមានដើម្បីប្រយោជន៍ដល់សង្ឃកម្មដ៏សេស ព្រោះដូច្នោះ បើថាកាលឱ្យបវារណា រមែងឱ្យឆន្ទៈផង កាលបវារណាបាននាំមកហើយប្រាប់ហើយ តាមន័យដែលពោលហើយនោះឯង ។ ទាំងភិក្ខុនោះ ទាំងសង្ឃរមែងជាការបានបវារណាហើយពិត ។ បើភិក្ខុឱ្យតែបវារណាប៉ុណ្ណោះ មិនបានឱ្យឆន្ទៈទេ កាលបវារណារបស់លោកបានប្រាប់ហើយ និងសង្ឃបានបវារណារួចស្រេចហើយ រមែងជាការភិក្ខុទាំងពួងបវារណាល្អហើយ តែកម្មយ៉ាងដទៃ រមែងកម្រើក ។ តែបើភិក្ខុឱ្យតែឆន្ទៈប៉ុណ្ណោះ មិនឱ្យបវារណា បវារណានិងកម្មដ៏សេសរបស់សង្ឃ មិនកម្រើកទេ ចំណែកភិក្ខុនោះ មិនចាត់ថា បានបវារណា ។ ក៏ក្នុងថ្ងៃបវារណា សូម្បីភិក្ខុដែលអធិដ្ឋានបវារណា ក្នុងខាងក្រៅសីមាហើយទើបមក ក៏គួរឱ្យឆន្ទៈបវារណាកម្មរបស់សង្ឃ ទើបនឹងមិនកម្រើកព្រោះលោក ។

# អធិដ្ឋានបវារណា

[២៧] វិនិច្ឆ័យក្នុងពាក្យថា អជ្ជ មេ បវារណា : ថ្ងៃនេះជាថ្ងៃបវារណារបស់អញ នេះ គប្បីជ្រាបដូច្នេះ ៖

បើថ្ងៃបវារណាជាថ្ងៃទី ១៤ ភិក្ខុនៅតែមួយរូប គប្បីអធិដ្ឋានយ៉ាងនេះថា អជ្ជ មេ បវារណា ចាតុទ្ទសី ប្រែថា បវារណារបស់យើងថ្ងៃនេះទី ១៤, បើជាថ្ងៃ ១៥ គប្បីអធិដ្ឋានយ៉ាងនេះថា អជ្ជ មេ បវារណា បណ្ណរសី ប្រែថា បវារណា របស់យើងថ្ងៃនេះទី ១៥ ។

[២៨] ពាក្យថា តទហុបវារណាយ អាបត្តឹ : ត្រូវអាបត្តិក្នុងថ្ងៃបវារណានោះ ជាដើម មានន័យដូចពោលហើយនុ៎ះឯង ។

[២៩] ពាក្យថា បុន បវារេតព្វំ : បវារណាម្ដងទៀត មានសេចក្ដីថា គប្បីធ្វើបុព្វកិច្ច ហើយតាំងញត្តិបវារណា តាំងពីព្រះសង្ឃត្ថេរចុះមកទៀត ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងឧបោសថក្ខន្ធកវណ្ណនានោះចុះ ។

# ថ្ងៃបវារណារបស់ពួកអាវាសិកភិក្ខុ និងអាគន្តុកភិក្ខុផ្សេងគ្នា

[៣៥] វិនិច្ឆ័យក្នុងពាក្យថា អាគន្តុកេហិ អាវាសិកានំ អនុវត្តិតព្វំ : ត្រូវពួកអាគន្តុកប្រព្រឹត្តតាមអាវាសិកភិក្ខុ គប្បីជ្រាបដូច្នេះ ៖

ពួកភិក្ខុជាម្ចាស់ទីកន្លែង គប្បីធ្វើបុព្វកិច្ចថា អជ្ជ បវារណា ចាតុទ្ទសី : បវារណាថ្ងៃទី ១៤ នោះឯង ។ សូម្បីក្នុងបវារណាថ្ងៃទី ១៥ ក៏មានន័យដូចគ្នា ។

ក្នុងបទទីបំផុតនៃព្រះបាលីនោះថា អាវាសិកេហិ និស្សីមំ គន្ត្វា បវារេតព្វំ : ត្រូវពួកអាវាសិកភិក្ខុទៅកាន់ទីក្រៅសីមា ហើយបវារណាចុះ មានវិនិច្ឆ័យក្រៅបាលី ដូច្នេះ ៖

បើថា ភិក្ខុ ៥ រូបចាំវស្សាក្នុងវស្សូបនាយិកាដើម, ៥ រូបទៀតចាំវស្សាក្នុងវស្សូបនាយិកាក្រោយ កាលភិក្ខុពួកដំបូងតាំងញត្តិបវារណាហើយ ពួកភិក្ខុចាំវស្សាក្រោយ គប្បីធ្វើបារិសុទ្ធិ ឧបោសថក្នុងសំណាក់

របស់លោក កុំគប្បីតាំងញត្តិ ២ យ៉ាង ក្នុងរោងឧបោសថតែមួយ ។ សូម្បីបើថា មានភិក្ខុ ៤ រូប ៣ រូប ២ រូប ឬតែមួយរូបក៏ដោយ ចាំវស្សាក្នុងវស្សូបនាយិកក្រោយ មានន័យដូចគ្នា ។ បើថា ភិក្ខុដែលចាំវស្សាដើម ៤ រូប, សូម្បីថ្ងៃចូលវស្សាក្រោយនិងមាន ៤ រូប ៣ រូប ឬតែមួយរូបក៏ដោយ មានន័យដូចគ្នា ។ សូម្បីថា ក្នុងថ្ងៃចូលវស្សាដើម មាន ៣ រូប សូម្បីក្នុងថ្ងៃចូលវស្សាក្រោយ មាន ៣ រូប ២ រូប ឬ តែមួយរូបក៏ដោយ មានន័យដូចគ្នា ។

ក៏នេះជាលក្ខណៈក្នុងបវារណាធិការនេះ ៖

បើថា ភិក្ខុដែលចាំវស្សា ក្នុងថ្ងៃចូលវស្សាក្រោយ តិចជាងភិក្ខុដែលចាំវស្សាក្នុងថ្ងៃចូលវស្សាដើម ឬស្មើគ្នា និងឱ្យគ្រប់គណៈសង្ឃបវារណាបាន គប្បីតាំងញត្តិដោយអំណាចសង្ឃបវារណា មួយទៀត បើក្នុងវស្សូបនាយិកាដើម មានភិក្ខុ ៣ រូប ក្នុងវស្សូបនាយិកាក្រោយ មានភិក្ខុត្រឹមតែមួយរូប រួមគ្នាចូលជា ៤ រូប ។ ភិក្ខុ ៤ រូបទឹងតាំងញត្តិហើយបវារណា មិនគួរទេ ។ តែភិក្ខុដែលចាំវស្សាក្រោយនោះ ជាគណបូរកៈ របស់គណញត្តិបាន ។ ព្រោះដូច្នោះ ភិក្ខុដែលចាំវស្សាដើម ៣ រូប គប្បីតាំងញត្តិហើយបវារណាជាគណៈ ភិក្ខុក្រៅនោះ គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងសំណាក់របស់ភិក្ខុទាំងនោះ ។ ក្នុងវស្សូបនា

យិកាដើមមាន ២ រូប ក្នុងវស្សូបនាយិកាក្រោយមាន ២ ឬ តែមួយរូប ក៏មានន័យដូចគ្នា ។ ក្នុងវស្សូបនាយិកាដើម មានភិក្ខុតែមួយរូប ក្នុងវស្សូបនាយិកាក្រោយក៏មានភិក្ខុតែមួយរូប, មួយរូប គប្បីបវារណាក្នុងសំណាក់របស់មួយរូបទៀត ចំណែកភិក្ខុមួយរូបទៀត គប្បីធ្វើបារិសុទ្ធិឧបោសថ ។ បើថា ភិក្ខុដែលចូលវស្សាក្រោយមានច្រើនជាងភិក្ខុចូលវស្សាដើម សូម្បីត្រឹមតែមួយរូប ចំណែកភិក្ខុពួកខាងដើមតិចជាង គប្បីសូធ្យបាតិមោក្ខមុន ហើយបវារណាក្នុងសំណាក់របស់ភិក្ខុចំណែកខាងច្រើនជាងជាខាងក្រោយ ។ ចំណែកក្នុងថ្ងៃបវារណា ដែលគ្រប់ ៤ ខែ ក្នុងខែ ១២ បើថា ភិក្ខុចូលវស្សាក្រោយច្រើនជាងភិក្ខុដែលចាំវស្សាដើមដែលបានបវារណាហើយក្នុងថ្ងៃមហាបវារណា ឬមានចំនួនស្មើគ្នា ពួកភិក្ខុអ្នកចាំវស្សាក្រោយ គប្បីតាំងបវារណា ញត្តិហើយបវារណា ។ កាលពួកលោកបានបវារណាគ្នារួចស្រេចហើយ, ចំណែកពួកភិក្ខុដែលចាំវស្សាដើម គប្បីធ្វើបារិសុទ្ធិ ឧបោសថក្នុងសំណាក់របស់ពួកលោកជាខាងក្រោយ ។ បើភិក្ខុដែលបវារណាហើយ ក្នុងថ្ងៃមហាបវារណាមានច្រើន ភិក្ខុដែលចាំវស្សាក្រោយមានតិច ឬមានតែមួយរូប កាលពួកភិក្ខុដែលចាំវស្សាដើមសូធ្យបាតិមោក្ខរួចស្រេចហើយ ភិក្ខុដែលចាំវស្សាក្រោយនោះ គប្បីបវារណាក្នុងសំណាក់របស់ពួកលោក ។

# សាមគ្គីបវារណា

[៣៩] វិនិច្ឆ័យក្នុងពាក្យថា ន ច ភិក្ខវេ អប្បវារណាយ បវារេតព្វំ អញ្ញត្រ សង្ឃសាមគ្គិយា : ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងថ្ងៃមិនមែនថ្ងៃបវារណាទេ វៀរលែងតែសង្ឃសាមគ្គីបវារណាចេញ នេះ គប្បីជ្រាបដូច្នេះ ៖

សេចក្តីព្រមព្រៀងគប្បីជ្រាបថា ដូចគ្នានឹងសេចក្តីព្រមព្រៀងរបស់ភិក្ខុនៅក្រុងកោសម្ពីចុះ ។ ក៏គប្បីធ្វើបុព្វកិច្ច ក្នុងកាលនៃសាមគ្គីបវារណានេះ យ៉ាងនេះថា អជ្ជ បវារណា សាមគ្គី ប្រែថា បវារណាថ្ងៃនេះ ជាគ្រាព្រមព្រៀងគ្នា ។ ចំណែកភិក្ខុពួកណា វៀរបវារណាចេញ ព្រោះហេតុបន្តិចបន្តួច ដែលមិនជាធំដុំអ្វី ហើយជាអ្នកព្រមព្រៀងគ្នាបាន, ភិក្ខុទាំងនោះ គប្បីធ្វើបវារណា ក្នុងថ្ងៃបវារណាប៉ុណ្ណោះ ។ ចំណែកភិក្ខុទាំងឡាយ ដែលនឹងធ្វើសាមគ្គីបវារណា គប្បីវៀរថ្ងៃបឋមបវារណាចេញ គប្បីធ្វើក្នុងចន្លោះនេះ គឺ តាំងពីថ្ងៃ ១ រោច ទៅដរាបដល់ពាក់កណ្តាលខែ ១២ ( ១៥ កើតខែកត្តិក ) ដែលជាថ្ងៃគ្រប់ ៤ ខែនៃវស្សានរដូវ

នឹងធ្វើខាងក្រោយ ឬមុនកំណត់នោះ មិនគួរ ។

## ញត្តិវិធាន

[៤០] វិនិច្ឆ័យក្នុងពាក្យថា ទ្វេវាចិកំ បវារេតុំ : ភិក្ខុបវារណាជាទ្វេវាចិកាបវារណា (ពោលតែ២ដង)បាន នេះ គប្បីជ្រាបដូច្នេះ ៖

ចំពោះភិក្ខុដែលតាំងញត្តិ គប្បីពោលថា យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ទ្វេវាចិកំ បវារេយ្យ : បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ជាទ្វេវាចិកាបវារណា ។

ក្នុងការបវារណាតែមួយដង គប្បីពោលថា ឯកវាចិកំ បវារេយ្យ : ភិក្ខុបវារណាជាឯកវាចិកាបវារណា (ពោលតែម្តង)បាន ។

ចំពោះក្នុងការបវារណាមានវស្សាស្មើគ្នា គប្បីពោលថា សមានវស្សិកំ បវារេយ្យ : ភិក្ខុបវារណាជាសមានវស្សិកាបវារណាបាន ប្រែថា គប្បីបវារណាមានវស្សាស្មើគ្នា ក៏ក្នុងការបវារណាមានវស្សា

ស្មើគ្នានេះ ភិក្ខុដែលមានវស្សាស្មើគ្នា សម្បូរច្រើនរូប រមែងបានដើម្បីបវារណាព្រមគ្នា ។

## ការឃាត់បវារណា

[៤២] វិនិច្ឆ័យក្នុងពាក្យថា ភាសិតាយ លបិតាយ អបរិយោសិតាយ : បានសូធ្យហើយ បានពោលហើយ បានបញ្ចប់ហើយ នេះ គប្បីជ្រាបដូច្នេះ ៖

ការឃាត់បវារណា ២ យ៉ាង គឺ ឃាត់ដោយការសង្គ្រោះទូទៅមួយយ៉ាង ឃាត់ជាចំពោះបុគ្គលមួយយ៉ាង ។

ការឃាត់បវារណា ២ យ៉ាងនោះ ក្នុងការឃាត់ដោយសង្គ្រោះទូទៅ មានវិនិច្ឆ័យថា កម្មវាចាដែលសូធ្យរឿយ ៗទៅតាំងពី សុ អក្សរ ដរាបដល់ រេ អក្សរ ថា សុណាតុ មេ ភន្តេ សង្ឃោ, ។បេ ។ សង្ឃោ តេវាចិកំ បវារេ ដូច្នេះ បវារណានៅមិនទាន់ពោលថា ចប់ ។

ក្នុងរវាងនេះ កាលភិក្ខុឃាត់ទុកសម្បូរក្នុងបទមួយ បវារណា ជាការឃាត់ ។ ចំពោះកាលដល់ យ អក្សរហើយ បវារណាជាការចប់ ព្រោះហេតុនោះ កាលភិក្ខុឃាត់ទុកតាំងពី យ អក្សរនោះទៅ បវារណា

មិនចាត់ថា បានឃាត់ ។

ចំណែកក្នុងការឃាត់ ជាចំពោះបុគ្គល មានវិនិច្ឆ័យថា ពាក្យបវារណាដែលភិក្ខុពោលរឿយ ៗទៅតាំងពី សំ អក្សរ ដរាបដល់ ដិ អក្សរ ដែលនៅខាងចុងនៃអក្សរទាំងពួងនេះថា សង្ឃំ ភន្តេ បវារេមិ ។បេ ។ ទុតិយម្បិ ។បេ ។ តតិយម្បិ ភន្តេ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា ។បេ ។ បស្សន្តោ បដិ ដូច្នេះ, បវារណាមិនទាន់ចាត់ថា ចប់ ។ ក្នុងចន្លោះនេះ កាលភិក្ខុឃាត់ទុកសូម្បីក្នុងបទមួយ បវារណា រមែងជាការឃាត់ ។ តែក្នុងកាលពោលបទថា ករិស្សាមិ ហើយ, បវារណាជាការចប់ហើយពិត, ក៏ព្រោះហេតុអ្វី កាលពោលបទថា ករិស្សាមិ ហើយ, បវារណា ទើបឈ្មោះថា ជាការចប់ហើយពិត ព្រោះហេតុនោះ កាលដល់បទមួយថា ករិស្សាមិ ហើយ, បវារណាដែលភិក្ខុឃាត់ទុក មិនចាត់ថា ជាការឃាត់ឡើយ ដោយប្រការដូច្នេះ ។

ក្នុងទ្វេវាចិកា ឯកវាចិកា និង សមានវស្សិកា មានន័យដូចគ្នា ។ ពិតមែន អក្សរមាន ដិ ជាទីបំផុត ចាប់ផ្តើមតាំងពី សំ មកតែម្តង រមែងជាខេត្រដែននៃការឃាត់ក្នុងបវារណា សូម្បីទាំងនេះ ដូច្នេះឯង ។

[៤៣] បទថា អនុយុញ្ជិយមានោ : កាលបើមានគេចោទសួរ មានសេចក្ដីថា ភិក្ខុនោះ ដែលភិក្ខុទាំងឡាយធ្វើការសាកសួរហើយ តាមន័យដែលត្រាស់ទុកខាងមុខថា "លោកឃាត់បវារណានោះ ព្រោះហេតុអ្វី" ។

បទថា ឱមទ្ទិត្វា : សង្រួបសង្រួមហើយ មានសេចក្ដីថា សង្ឃគប្បីពោលពាក្យទាំងនេះថា "នៃភិក្ខុ កុំឡើយ លោកកុំធ្វើការបង្កហេតុ" ដូច្នេះជាដើម ហាមប្រាមហើយ សឹមបវារណា ។ ពិតមែន ការហាមប្រាម ដោយពាក្យ ដែលព្រះមានព្រះភាគទ្រង់ប្រាថ្នាហើយថា ឱមទ្ទនា ក្នុងបទថា ឱមទ្ទិត្វា នេះ ។

ពីរបទថា អនុទ្ធំសិតំ បដិជានាតិ : ប្ដេជ្ញាចំពោះភិក្ខុដែលខ្លួនតាមកម្ចាត់ មានសេចក្ដីថា ភិក្ខុដែលអ្នកចោទនោះ ប្ដេជ្ញាយ៉ាងនេះថា ភិក្ខុនេះ ខ្ញុំព្រះករុណាតាមកម្ចាត់ គឺ ចោទហើយ ដោយអាបត្តិបារាជិក មិនមានមូល ។

បទថា យថាធម្មំ : ឱ្យភិក្ខុនោះធ្វើតាមធម៌ មានសេចក្ដីថា សង្ឃគប្បីឱ្យពិន័យអាបត្តិបាចិត្តិយ ព្រោះតាមកម្ចាត់ដោយអាបត្តិសង្ឃាទិសេស គប្បីឱ្យពិន័យទុក្កដ ព្រោះតាមកម្ចាត់ដោយវិតិក្កមៈក្រៅអំពីនេះ ។

បទថា ឆាសេត្វា : នាសនកម្ម ( ចំពោះភិក្ខុនោះ ) មានសេចក្ដី

ថា សង្ឃគប្បីនាសនាភិក្ខុជាប់ចោទចេញដោយលិង្គនាសនា ។

[៤៤] ភិក្ខុជាប់ចោទនោះ ដែលសង្ឃគប្បីបង្គាប់ត្រឹមតែប៉ុណ្ណេះថា "អាបត្តិនោះ គប្បីជាទោសដែលលោកសម្តែងតាមធម៌" ហើយគប្បីពោលថា "លោកទាំងឡាយចូរបវារណាចុះ" តែកុំគប្បីពោលពាក្យនេះថា "អាបត្តិឈ្មោះឯណោះ" ព្រោះថា ពាក្យនោះ រមែងជាមកនៃសេចក្តីវិវាទ ។

[៤៥] វិនិច្ឆ័យក្នុងពាក្យថា ឥធំ វត្ថុំ បញ្ញាយតិ ន បុគ្គលោ : វត្ថុនេះប្រាកដ តែបុគ្គលមិនប្រាកដ នេះ គប្បីជ្រាបដូច្នេះ ៖

បានឮថា ពួកចោរចាប់ត្រីទាំងឡាយអំពីស្រះបោក្ខរណី ក្នុងវត្តអាំងស៊ីហើយទៅ ភិក្ខុនោះ ឃើញសភាពប្លែក ៗនោះ កំណត់ទុកថា "កម្មនេះ គប្បីជារបស់ភិក្ខុ" ទើបពោលយ៉ាងនោះ ។

ក្នុងពាក្យថា វត្ថុំ ឋបេត្វា សង្ឃោ បវារេយ្យ : សង្ឃគប្បីឃាត់វត្ថុទុក ហើយសឹមបវារណា នេះ មានសេចក្តីដូច្នេះថា "យើងទាំងឡាយនឹងស្គាល់បុគ្គលនោះ ក្នុងវេលាណានឹងចោទបុគ្គលនោះក្នុងវេលានោះ តែពេលឥឡូវនេះ សង្ឃចូលបវារណាចុះ" ។

ពាក្យថា ឥធានេវ ណំ វទេហិ : ចូរអ្នកប្រាប់វត្ថុនោះ ឥឡូវនេះកុំខាន បើលោករង្កៀសបុគ្គលណាមួយ ដោយវត្ថុនេះ ។ លោកចូរ

បញ្ឈាក់បុគ្គលនោះ ក្នុងពេលឥឡូវនេះឯង ។ បើលោកបញ្ឈាក់, សង្ឃគប្បីសាកសួរបុគ្គលនោះហើយ ទើបបវារណា; បើលោកមិនបញ្ឈាក់, សង្ឃគប្បីពោលថា "យើងនឹងពិចារណាហើយនឹងដឹង" ដូច្នេះ បវារណាចុះ ។

វិនិច្ឆ័យក្នុងពាក្យថា អយំ បុគ្គលោ បញ្ញាយតិ ន វត្ថុំ : **បុគ្គលនេះប្រាកដ តែវត្ថុមិនប្រាកដទេ** នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុមួយរូប បូជាព្រះចេតិយដោយរបស់ក្រអូប និងគ្រឿងលាបស្រទាបក្តី, ឆាន់ថ្នាំអរិដ្ឋៈក្តី, ខ្លួនរបស់លោកមានក្លិនប្រាកដ ដូចក្លិនវត្ថុទាំងនោះ ភិក្ខុនោះ សំដៅយកក្លិននោះ កាលប្រកាសវត្ថុថា "ក្លិនរបស់ភិក្ខុនេះ" ទើបពោលយ៉ាងនោះ ។

ពាក្យថា បុគ្គលំ ឋបេត្វា សង្ឃោ បវារេយ្យ : **សូមសង្ឃឃាត់នូវបុគ្គលហើយសឹមបវារណា** មានសេចក្តីថា សង្ឃចូរវៀរបុគ្គលនោះចេញ បវារណាចុះ ។

ពាក្យថា ឥទានេវ នំ វទេហិ : **ចូរអ្នកប្រាប់នូវបុគ្គលនោះឥឡូវនេះ កុំខាន** មានសេចក្តីថា លោកចូរវៀរបុគ្គលណា ចូរពោលទោសរបស់បុគ្គលនោះ ក្នុងពេលឥឡូវនេះឯង ។ បើភិក្ខុនោះពោលថា "ទោសរបស់បុគ្គលនោះជាយ៉ាងនេះ" សង្ឃគប្បីជម្រះបុគ្គលនោះ ឱ្យ

រៀបរយហើយ សឹមបវារណា; តែបើលោកពោលថា ខ្ញុំព្រះករុណាមិនជ្រាប សង្ឃគប្បីពោលថា “យើងនឹង ពិចារណាហើយនឹងដឹង” ដូច្នេះ បវារណាចុះ ។

ពាក្យថា ឥទំ វត្ថុញ្ច បុគ្គលោ ច បញ្ញាយតិ : វត្ថុនេះក្តី បុគ្គលក្តី ក៏ប្រាកដ មានសេចក្តីថា ភិក្ខុនោះបានឃើញកន្លែងដែលពួកចោរចាប់ត្រីអាំងស៊ី និងស្ពានទីងូតដោយរបស់ក្រអូបជាដើម តាមន័យមុននុ៎ះឯង កាលសម្គាល់ថា
“នេះគង់ជាកម្មរបស់បព្វជិត” ទើបពោលយ៉ាងនោះ ។

ពាក្យថា ឥទានេវ នំ វទេហិ : ចូរលោកប្រាប់នូវវត្ថុនិងបុគ្គលនោះ ឥឡូវនេះមក មានសេចក្តីថា លោកនឹងប្រាប់នូវបុគ្គលដែលលោករង្កៀសដោយវត្ថុនោះ ក្នុងពេលឥឡូវនេះឯង ។ ក៏ឯចាប់តាំងពីពេលបានឃើញហើយ ព្រោះឃើញវត្ថុនិងបុគ្គលគ្រប់ទាំងពីរនេះ សង្ឃត្រូវវិនិច្ឆ័យជាមុន ទើបបវារណាបាន ។

ពីរបទថា កាល្លំ វចនាយ : គួរនឹងចោទបាន មានសេចក្តីថា សមគួរចោទ ដោយពាក្យចោទដ៏សមគួរ[១] ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះវត្ថុនៅមិនទាន់បានវិនិច្ឆ័យមុនអំពីបវារណា និង

១, បាឋៈក្នុងអដ្ឋកថាជា កល្លចោទនាយ ចោទេតុំ វដ្ដតិ តែគួរទើងជា កល្លំ ចោទនាយ ចោទេតុំ វដ្ដតិ : សមគួរដើម្បីការចោទ គឺគួរចោទ ។ ព្រោះបុគ្គលដែលបានឃើញហើយ ត្រូវចោទខាងក្រោយអំពីបវារណា ។

ពាក្យថា ឧក្កោដនកំ ឲ្យចិត្តិយំ : ត្រូវអាបត្តិបាចិត្តិយ ព្រោះការសើរើ មានសេចក្ដីថា ពិតមែន ភិក្ខុទាំងឡាយឃើញវត្ថុ និងបុគ្គលគ្រប់ទាំងពីរនេះហើយ វិនិច្ឆ័យ រួចស្រេចជាមុនហើយ ទើបបវារណា ព្រោះដូច្នោះ ទើបជាអាបត្តិ ដល់ភិក្ខុដែលសើរើបវារណានោះទៀត ។

[៤៦] វិនិច្ឆ័យក្នុងពាក្យថា ទ្វេ តយោ ឧបោសថា ចាតុទ្ទសិកា កាតុំ : ធ្វើចាតុទ្ទសីឧបោសថពីរបីឧបោសថ នេះគប្បីជ្រាបដូច្នេះ ៖

ឧបោសថ ២ គឺ ទី ៤ និងទី ៥ ជាចាតុទ្ទសី ។ មួយទៀត ឧបោសថទី ៣ សូម្បីតាមប្រក្រតី រមែងជាចាតុទ្ទសីដែរ ដូច្នេះឯង ។ ព្រោះហេតុនោះ ឧបោសថ ២ គឺ ទី ៣ និងទី ៤ ឬ ឧបោសថ ៣ គឺ ទី ៣ ទី ៤ ទី ៥ គួរធ្វើឲ្យជាចាតុទ្ទសី ។ បើថា កាលធ្វើឧបោសថទី ៤ ដែលជាបណ្ណរសីឧបោសថ ភិក្ខុដែលបន្ទ សេចក្ដីទាស់ទែងនោះស្ដាប់ដែរ, គប្បីធ្វើឧបោសថទី ៥ ឲ្យជាចាតុទ្ទសី ។ ឧបោសថ ២ រមែងជាចាតុទ្ទសី សូម្បីដោយប្រការយ៉ាងនេះ ។ កាលធ្វើយ៉ាងនោះ អាវាសិកភិក្ខុទាំងនេះ ទឹងបវារណាសម្រាប់បណ្ណរសីបវារណាក្នុងថ្ងៃ ១៣ ឬ

១៤ របស់ភិក្ខុដែលបង្កសេចក្ដីទាស់ទែងគ្នា ។ ក៏បើកាលទីងបវារណាយ៉ាងនោះ គប្បីដាក់ពួកសាមណេរទុកខាងក្រៅសីមា បានស្ដាប់ថា "ភិក្ខុបង្កសេចក្ដីទាស់ទែងគ្នាទាំងនោះនាំគ្នាមក" គប្បីប្រញាប់ប្រជុំគ្នាបវារណាជាមុនឱ្យរហ័ស ដើម្បីសម្ដែងសេចក្ដីនេះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុធ្វើសេចក្ដីប្រកួតប្រកាន់គ្នា ធ្វើសេចក្ដីប្រកែកគ្នា ធ្វើសេចក្ដីទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ (នាំគ្នា) មកកាន់អាវាស, ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុអ្នកនៅក្នុងអាវាសទាំងនោះ ប្រជុំគ្នាបវារណា ភ្លាម ៗចុះ, លុះបវារណាហើយ ត្រូវនិយាយថា នែអាវុសោ យើងទាំងឡាយបវារណារួចហើយ ពួកលោកសម្គាល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ" ។

បទថា **អសំវិហិតា : មិនដឹងរឿងអ្វីសោះ** មានសេចក្ដីថា អ្នកមិនបានចាត់ចែង គឺ មិនបានធ្វើការត្រៀមដើម្បីត្រូវការ នឹងឱ្យជ្រាបការមក អធិប្បាយថា ជាអ្នកដែលពួកម្ចាស់ទីកន្លែងមិនទាន់ដឹងទេ ។

ពីរបទថា **តេសំ វិក្ខិត្វា : ត្រូវបំភាន់ភិក្ខុនោះ** មានសេចក្ដីថា ពួកអាវាសិកភិក្ខុ គប្បីធ្វើឱ្យរម្ងាប់ចិត្តបានស្ងប់សិន ដោយន័យជាដើមថា "ពួកលោកជាអ្នកនឿយហត់ណាស់ ចូរសម្រាកមួយភ្លែតសិនចុះ" ។ ហើយលបចេញទៅបវារណាខាងក្រៅសីមា ។

បទថា នោ ចេ លភេថ : បើមិនអាចបានទេ មានសេចក្តីថា បើថា មិនគប្បីបានដើម្បីចេញទៅក្រៅសីមាសោត ។ ជាអ្នកត្រូវពួកសាមណេរ និងភិក្ខុកំលោះ របស់ពួកភិក្ខុដែលបន្តសេចក្តីទាស់ទែងគ្នាដើរតាមជាប់ទៅមិនបានដាច់ ។

ពីរបទថា អាគមេ ជុណ្ហេ : ក្នុងកាឡបក្ខ គឺ ក្នុងរនោចដែលមកដល់ មានសេចក្តីថា ភិក្ខុទាំងឡាយសំដៅយកជុណ្ហបក្ខ ដែលនឹងមកដល់ណា តាំងញត្តិថា "យើងទាំងឡាយត្រូវបវារណាក្នុងជុណ្ហបក្ខ ដែលមកដល់" ដូច្នេះ ក្នុងជុណ្ហបក្ខដែលនឹងមកដល់នោះ ។

ពាក្យថា កោមុទិយា ចាតុមាសិនិយា អកាមា បវារេតព្វំ : ត្រូវភិក្ខុទាំងនោះនាំគ្នាបវារណាដោយខានមិនបានក្នុងតិថីជាគម្រប់ ៤ ខែនៃវស្សានរដូវ ជាទីរីកផ្កាកុមុទ មានសេចក្តីថា អាវាសិកភិក្ខុទាំងនោះត្រូវបវារណា ពិតប្រាកដ នឹងកន្លងហួសថ្ងៃពេញបូណ៌មីជាគម្រប់ ៤ ខែ បវារណា រមែងមិនបានឡើយ ។

ច្រើនបទថា តេហិ ចេ ភិក្ខវេ ភិក្ខូហិ បវារិយមានេ : ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែបវារណា មានសេចក្តីថា កាលសង្ឃដែលភិក្ខុទាំងនោះបវារណា ក្នុងថ្ងៃពេញបូណ៌មីជាគម្រប់ ៤ ខែ យ៉ាងនោះ ។

## ការធ្វើបវារណាសង្គហៈនៃពួកភិក្ខុអ្នកព្រមព្រៀងគ្នាជាដើម

[៤៧] ពីរបទថា អញ្ញតរោ ជាសុវិហារោ : ធម៌យ៉ាងដែលជាគ្រឿងនៅជាសុខ បានដល់ សមថៈទន់ខ្ចី ឬវិបស្សនាទន់ខ្ចី ។

ពាក្យថា បរិពាហិរា ភវិស្សាម : យើងទាំងឡាយមុខជានឹងឃ្លាត មានសេចក្ដីថា យើងទាំងឡាយ កាលមិនអាចឱ្យភាវនានុយោគសម្រេចព្រមបាន ព្រោះការបែកសែកគ្នាទៅកន្លែងសម្រាកពេលយប់និងកន្លែងសម្រាកពេលថ្ងៃជាដើម ដែលមិននៅប្រចាំកន្លែង នឹងជាអ្នកឃ្លាតឆ្ងាយ (ពីធម៌ជាគ្រឿងនៅសប្បាយនេះ) ។

ព្រះមានព្រះភាគទ្រង់ហាមការឱ្យឆន្ទៈ ដោយពាក្យនេះថា ត្រូវភិក្ខុទាំងអស់ប្រជុំក្នុងកន្លែងជាមួយគ្នា ។ ព្រះមានព្រះភាគត្រាស់ពាក្យថា តេហិ ចេ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ ជាដើម ក៏ដើម្បីសម្ដែងថា "ពិតមែន ការឱ្យឆន្ទៈ រមែងមិនគួរក្នុងឋានៈទាំង ៣ នេះ ក្នុងកាលដែលធ្វើសេចក្ដីព្រមព្រៀងនៃសង្ឃដែលបែកគ្នា ១ ក្នុងកាលរម្ងាប់អធិករណ៍ដោយតិណវត្ថារកវិន័យ១ ក្នុងបវារណាសង្គហៈនេះ១ ។

ក៏ដែលឈ្មោះថា បវារណាសង្គហៈនេះ មិនគួរឱ្យដល់ភិក្ខុដែលលះបង់កម្មដ្ឋាន មួយពួក ភិក្ខុដែលមានសមថៈ និងវិបស្សនាចាស់ក្លាហើយ មួយពួក ភិក្ខុដែលជាអរិយបុគ្គល មានសោតាបន្នជាដើម មួយពួក ក៏ភិក្ខុដែលបានសមថៈទន់ខ្វី និងវិបស្សនាទន់ខ្វី ទឹងមានទាំងអស់ ឬមានចំនួនពាក់កណ្តាល ឬមានបុគ្គលតែមួយក៏ដោយ បវារណាសង្គហៈនោះ គួរឱ្យពិតដោយអំណាចនៃភិក្ខុសូម្បីមួយរូប កាលសង្ឃឱ្យបវារណាសង្គហៈហើយ មានបរិហាររហូតដល់អស់ខាងក្នុងកាលនៃរដូវភ្លៀងដោយពិត ភិក្ខុអាគន្តុកៈ រមែងមិនបានដើម្បីកាន់យកសេនាសនៈរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះមិនគប្បីជាអ្នកដាច់វស្សាផង ក៏ឯកាលបវារណាហើយ រមែងបានដើម្បីជៀសចេញទៅកាន់ទីចារិកក្នុងចន្លោះផង" ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

## បវារណាខន្ធកវណ្ណនា ចប់ ។

# ៥. ចម្មក្ខន្ធកវណ្ណនា

## រឿងព្រះសោណកោលិវិសត្ថេរ

[៤៩] បទថា ឥស្សរាធិបច្ចំ : ជាឥស្សរាធិបតី បានដល់ប្រកបដោយឥស្សរភាព និងភាពជាអធិបតី ។

បទថា រជ្ជំ : សោយរាជ្យ បានដល់ ភាពជាព្រះរាជា ឬកិច្ចដែលព្រះរាជាទ្រង់គប្បីធ្វើ ។

វិនិច្ឆ័យក្នុងពាក្យថា សោណោ នាម កោលិវិសោ : ឈ្មោះសោណ ជាកោឡិវិសគោត្ត នេះ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា សោណៈ ជាឈ្មោះរបស់សេដ្ឋីបុត្រនោះ, ពាក្យថា កោលិវិសៈ ជាគោត្រ ។

ពីរបទថា បាទតលេសុ លោមានិ : មានរោមជាច្រើនត្រង់បាទជើង មានសេចក្តីថា ត្រង់ផ្ទៃបាតជើងទាំងពីររបស់សេដ្ឋីបុត្រនោះក្រហមមានរោមដ៏ល្អិតទន់មានពណ៌ស្រដៀងផ្កាអញ្ចាន ស្រស់ល្អដូចជាងបានតាក់តែងហើយ ។

បានឮថា ក្នុងកាលមុន សោណសេដ្ឋីបុត្រនោះ បានជាប្រធានរបស់បុរស ៨ ម៉ឺននាក់ ព្រមដោយបុរសទាំងនោះ ជួយគ្នាសាងបណ្ណសាលា ក្នុងស្ថានទីនៅរបស់ព្រះបច្ចេកពុទ្ធ ហើយដាក់សំពត់

បាវាររោមសត្វយ៉ាងល្អរបស់ខ្លួន ធ្វើឱ្យជាសំពត់ជូតជើង ក្នុងស្ថានជាទីជាន់ដោយជើងរបស់ព្រះបច្ចេកពុទ្ធ ។ និងគ្រប់ ៗគ្នា បានឧបដ្ឋាកព្រះបច្ចេកពុទ្ធរហូតដល់អស់ត្រៃមាស ។ នេះជាសេចក្តីប្រកបបុព្វកម្មរបស់សោណសេដ្ឋីបុត្រនោះ ជាមួយនឹងបុរស ៨ ម៉ឺននាក់ប៉ុណ្ណោះ ។

បទថា **គាមិកសហស្សានិ** : ពួកអ្នកស្រុកទាំង(៨០)ពាន់ បានដល់ កុលបុត្រ ៨ ម៉ឺន ដែលនៅក្នុងស្រុកទាំងនោះ ។

ពីរបទថា **កេនចិទេវ ករណីយេន** មានសេចក្តីថា ដូចនឹងមានរាជកិច្ចអ្វី ៗដែលគួរធ្វើ ។ តែរាជកិច្ចបន្តិចបន្តួចដែលគួរធ្វើរបស់ស្តេច ក៏មិនមានក្រៅអំពីដើម្បីត្រូវការទតមើលខ្លួនគេ ។

បានឮថា ព្រះរាជាកាលនឹងឱ្យកុលបុត្រទាំង ៨ ម៉ឺននោះ ប្រជុំគ្នា បានឱ្យប្រជុំគ្នាហើយដោយទ្រង់ឃើញឧបាយថា ដោយឧបាយយ៉ាងនេះ សោណៈកាលមិនសង្ស័យនឹងមក ។

ពីរបទថា **ធិដ្ឋធម្មិកេ អត្ថេ** : ក្នុងប្រយោជន៍ជាបច្ចុប្បន្ន មានសេចក្តីថា ព្រះបាទពិម្ពិសារទ្រង់អនុសាសន៍(ណែនាំ)នូវប្រយោជន៍ដែលសមគួរក្នុងលោកនេះ ដោយន័យមានជាដើមយ៉ាងនេះថា "ការងារទាំងឡាយ មានកសិកម្មនិងពាណិជ្ជកម្មជាដើម គួរធ្វើតាមធម៌ មាតាបិតាគួរចិញ្ចឹមតាមធម៌" ។

បីបទថា សោ នោ ភគវា : ព្រះមានព្រះភាគនោះ ... ដល់អ្នកទាំងឡាយ មានសេចក្ដីថា ព្រះមានព្រះភាគរបស់យើងទាំងឡាយនោះ នឹងទ្រង់ទូន្មានលោកទាំងឡាយ ក្នុងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ។

ពីរបទថា ភគវន្តំ បដិវេទេមិ : ចាំអាត្មាភាពក្រាបទូលព្រះមានព្រះភាគសិន មានសេចក្ដីថា យើងនឹងទូលព្រះមានព្រះភាគឱ្យទ្រង់ជ្រាប ។

ពីរបទថា ធាដិកាយ និម្មុជ្ជិត្វា : ជ្រែកចុះត្រង់ផែនថ្ម មានសេចក្ដីថា មុជចុះ ក្នុងថ្មស្រដៀងអង្ក្លបទ្ធ ខាងក្រោមនៃជណ្ដើរ ។

ច្រើនបទថា យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតិ : បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគរមែងជ្រាបនូវកាលគួរជាប្រយោជន៍ ក្នុងកាលឥឡូវនេះ មានសេចក្ដីថា សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវកាលនៃប្រយោជន៍ ដើម្បីធ្វើសេចក្ដីអនុគ្រោះណា ដល់អ្នកស្រុកទាំងនោះ ។

បទថា វិហារបច្ឆាយាយំ : ត្រង់ម្លប់វិហារ បានដល់ ក្នុងម្លប់ខាងចុងវិហារ ។

បទថា សមន្នាហរន្តិ : ឱបអរពាក់ទាក់ បានដល់ ធ្វើទុកក្នុងចិត្ត

រឿយ ៗ ដោយអំណាចសេចក្តីជ្រះថ្លា ។

ពីរបទថា ភិយ្យោសោ មត្តាយ : ឱ្យក្រៃលែងឡើងទៅទៀត មានសេចក្តីថា លោកចូរសម្តែងឥទ្ធិបាដិហារ្យវិសេសជាងនោះទៀត ដោយប្រមាណក្រៃលែងចុះ ។

បទថា អន្តរធាយតិ : បាត់ខ្លួនទៅ បានដល់ ជារូបដែលមើលមិនឃើញ ។

[៥០] ពីរបទថា លោហិតេន ផុដ្ឋោ[១] : ប្រឡាក់ដោយឈាម បានដល់ ជាទីចង្រ្កមដែលប្រលាក់ឈាម ។

បទថា គវាឃាតនំ : ទីដែលសម្រាប់សម្លាប់គោ មានសេចក្តីថា ហាក់ដូចជាស្ថានទីសម្លាប់គោទាំងឡាយ ។

បទថា កុសលោ : ជាអ្នកឆ្លាស បានដល់ អ្នកឆ្លាតក្នុងការដេញពិណ ។

ពីរបទថា វីណាយ តន្តិស្សរេ : ក្នុងសូរសំឡេងខ្សែពិណ បានដល់ សំឡេងនៃខ្សែពិណ ។

បទថា អច្ចាយិកា : តឹងពេកទៅ បានដល់ ជាខ្សែដែលតឹងពេក គឺ មូលរែតតឹងពេក ។

១. ភូមាថា. ផុដោ ។

បទថា សរវតី : មានសំឡេង បានដល់ ដល់ព្រមដោយសំឡេង ។

បទថា កម្មញ្ញា : គួរដល់ការងារ បានដល់ កម្មក្ខម្មា : សមគួរដល់ការងារទាំងឡាយ ។

បទថា អតិសិថិលា : ធូរពេក បានដល់ ជាខ្សែដែលធូរពេក ។

បទថា សមេ គុណេ បតិដ្ឋិតា : តាំងនៅក្នុងគុណដ៏ល្មម បានដល់ តឹងល្មមឱ្យសំឡេងជាកណ្ដាល ៗ ។

ពីរបទថា វីរិយសមថំ អធិដ្ឋាហិ : ចូរតាំងសេចក្ដីព្យាយាមឱ្យស្មើ មានសេចក្ដីថា លោកចូរអធិដ្ឋានសមថៈ ដែលសម្បយុត្តដោយសេចក្ដីព្យាយាម, អធិប្បាយថា "ចូរប្រកបដោយសេចក្ដីស្ងប់ ជាប់ដោយសេចក្ដីព្យាយាម" ។

បីបទថា ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈ : ត្រូវប្រើឥន្ទ្រិយទាំង ៥ ឱ្យស្មើគ្នាផង មានសេចក្ដីថា ចូរជ្រាបនូវឥន្ទ្រិយទាំងឡាយមានសទ្ធាជាដើម ដែលត្រូវជារបស់ស្មើ ៗ គ្នា គឺ ប៉ុន ៗ គ្នា គឺ ចូរយល់ដល់ឥន្ទ្រិយទាំងឡាយដែលខ្វនប្រកបនោះ បណ្ដាឥន្ទ្រិយទាំងនោះ សទ្ធាជាមួយបញ្ញា និងបញ្ញាជាមួយសទ្ធា សេចក្ដីព្យាយាមជាមួយសមាធិ និង

សមាធិជាមួយសេចក្តីព្យាយាម ត្រូវសមល្មមស្មើគ្នា ។

ពាក្យថា តត្ថ ច និមិត្តំ គណ្ហាហិ : កាន់យកនូវនិមិត្តក្នុងសមថៈនោះឯង មានសេចក្តីថា កាលសេចក្តីស្មើគ្នានោះមាន, និមិត្តណាដែលដូចជាស្រមោលក្នុងកញ្ចក់គប្បីកើតឡើង, ចូរលោកកាន់យកនិមិត្តនោះ គឺសមថនិមិត្ត វិបស្សនានិមិត្ត មគ្គនិមិត្ត ផលនិមិត្ត សេចក្តីថា ចូរឱ្យនិមិត្តនោះកើត ។

[៥១] ពីរបទថា អញ្ញំ ព្យាករេយ្យំ : សម្តែងគុណ គឺអរហត្តផល មានសេចក្តីថា យើងគប្បីឱ្យព្រះមានព្រះភាគទ្រង់ជ្រាបថា យើងជាអរហន្ត ។

បទថា ឆដ្ឋានានិ : ហេតុទាំង ៦ យ៉ាង បានដល់ ហេតុ ៦ ប្រការ ។

ពីរបទថា អធិមុត្តោ ហោតិ : ជាអ្នកមានអធ្យាស្រ័យបង្អោនទៅ មានសេចក្តីថា ជាអ្នកត្រាស់ដឹង គឺ ធ្វើឱ្យប្រចក្សហើយតាំងនៅ ។

បទទាំងពួងថា នេក្ខម្មាធិមុត្តោ : មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្ម ជាដើម ព្រះសោណកោលិវិសៈពោលដោយអំណាចព្រះអរហត្ត ។ ពិតមែន ព្រះអរហត្ត ហៅថា នេក្ខម្មៈ ព្រោះចេញចាកកិលេសទាំងពួង, ហៅថា វិវេក ព្រោះស្ងាត់ចាកកិលេសទាំងនោះឯង,

ហៅថា ការមិនបៀតបៀន ព្រោះមិនមានការបៀតបៀន, ហៅថា ការអស់តណ្ហា ព្រោះកើតឡើងក្នុងទីបំផុតនៃការអស់តណ្ហា, ហៅថា ការអស់ឧបាទាន ព្រោះកើតក្នុងទីបំផុតនៃការអស់ឧបាទាន, ហៅថា សេចក្តីមិនវង្វេង ព្រោះមិនមានសេចក្តីវង្វេង ។

ពីរបទថា កេវលំ សទ្ធាមត្តកំ : គ្រាន់តែសេចក្តីជឿប៉ុណ្ណោះឯង មានសេចក្តីថា លោកដ៏មានអាយុនេះ អាស្រ័យគុណទាំងមូលក៏ដោយសទ្ធាសុទ្ធ ៗ ប្រាសចាកបដិវេធ គឺ មិនលាយដោយបញ្ញាជាគ្រឿងត្រាស់ដឹង ។

បទថា បដិចយំ : នូវសេចក្តីចម្រើននៃកិច្ច បានដល់ ចម្រើនដោយការធ្វើដដែល ៗ ។

បទថា វីតរាគត្តា : ព្រោះប្រាសចាករាគៈ បានដល់ ជាអ្នកត្រាស់ដឹងព្រះអរហត្តពោលគឺ នេក្ខម្មៈ ហើយតាំងនៅ ព្រោះរាគៈជាកិលេសទៅប្រាស ចាកហើយដោយត្រាស់ដឹងមគ្គនុ៎ះឯង អធិប្បាយថា នៅដោយធម៌ជាគ្រឿងនៅ គឺ ផលសមាបត្តិ គឺ ជាអ្នកមានចិត្តបង្អោនទៅក្នុងផលសមាបត្តិនោះ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា លាភសក្ការសិលោកំ : លាភសក្ការៈ និងសេចក្តីសរសើរ បានដល់ ការបានបច្ច័យបួន ១ ការដែលបច្ច័យបួនទាំងនោះ

ឯង គេធ្វើល្អចំពោះ ១ ការពោលសរសើរ ១ ។

បទថា និកាមយមានោ : ជាអ្នកប្រាថ្នា បានដល់ ត្រូវការ គឺចង់បាន ។

បទថា បវិវេកាធិមុត្តោ : មានអធ្យាស្រ័យបង្អោនទៅក្នុងទីស្ងាត់ មានសេចក្ដីថា ព្យាករណ៍អរហត្តយ៉ាងនេះថា "ខ្ញុំព្រះករុណាបង្អោនទៅក្នុងវិវេក" ។

បទថា សីលព្វតបរាមាសំ : សេចក្ដីប្រកាន់សីលប្រកាន់វត្ត បានដល់ ត្រឹមតែសេចក្ដីប្រកាន់ដែលស្ទាបអង្អែលនូវសីលនិងវត្ត ។

បទថា សារតោ បច្ចាគច្ឆន្តោ : កាលត្រឡប់មក... ដោយសភាវៈថ្លៃថ្លា បានដល់ ជ្រាបនៅដោយភាពជាខ្លឹមសារ ។

បទថា អព្យាបជ្ឈាធិមុត្តោ : មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្ដីមិនព្យាបាទ មានសេចក្ដីថា ព្យាករណ៍អរហត្តដែលមិនមានសេចក្ដីបៀតបៀន ។ សេចក្ដីក្នុងវារៈទាំងពួង គប្បីជ្រាបដោយន័យនេះ ។

បទថា កុសា : ក្រៃលែង, ដ៏ខ្លាំងក្លា បានដល់ ពលវន្តោ : មានកម្លាំង ។

ប្រើនបទថា នេវស្ស ចិត្តំ បរិយាទិយន្តិ : ក៏មិនបាន

គ្របសង្កត់ចិត្តរបស់ភិក្ខុនោះឡើយ មានសេចក្ដីថា អារម្មណ៍ទាំងនោះ មិនអាចនឹងគ្របចិត្តរបស់ព្រះវីណាស្រេពនោះ តាំងនៅបាន ។

បទថា អមិស្សីកតំ : មិនធ្វើឱ្យប្រឡំដោយកិលេស មានសេចក្ដីថា ចិត្តរបស់លោកដែលអារម្មណ៍ធ្វើឱ្យលាយដោយកិលេសមិនបាន ។ អធិប្បាយថា អារម្មណ៍ទាំងឡាយ រមែងធ្វើចិត្តឱ្យជាធម្មជាតិលាយដោយកិលេសទាំងឡាយ ព្រោះមិនមានកិលេសទាំងនោះ ចិត្តរបស់លោក ទើបឈ្មោះថា ដែលអារម្មណ៍ធ្វើឱ្យលាយដោយកិលេសមិនបាន ។

បទថា ឋិតំ : នៅខ្ជាប់ខ្ជួន បានដល់ តាំងនៅមាំ ។

បទថា អនេញ្ជប្បត្តំ : ឥតមានកម្រើកដោយតណ្ហាហើយ បានដល់ ដល់សេចក្ដីមិនញាប់ញ័រ ។

បទថា វយញ្ចស្សានុបស្សតិ : ពិចារណាឃើញនូវសេចក្ដីកើតឡើងសេចក្ដីរលត់ទៅ បានដល់ ឃើញទាំងការកើត ទាំងសេចក្ដីរលត់នៃចិត្តនោះ ។

[៥២] ពីរបទថា នេក្ខម្មំ អធិមុត្តស្ស : មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្ម បានដល់ ត្រាស់ដឹងព្រះអរហត្តតាំងនៅ ។ ព្រះអរហត្តនុះឯង ព្រះសោណកោលិវិសត្ថេរពោលហើយ សូម្បីដោយបទ

ដ៏សេសទាំងឡាយ ។

បទថា ឧបាទានក្ខយស្ស ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ប្រែថា កាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទាន ។

ពីរបទថា អសម្មោហញ្ច ចេតសោ : សេចក្តីមិនវង្វេងនៃចិត្តផង បានដល់ សេចក្តីមិនវង្វេងនៃចិត្តផង, ភិក្ខុនោះបង្អោនទៅហើយផង ។

ពីរបទថា ទិស្វា អាយតនុប្បាទំ : ព្រោះឃើញនូវសេចក្តីកើតឡើង (សេចក្តីវិនាស )នៃអាយតនៈ បានដល់ ឃើញសេចក្តីកើតនិងសេចក្តីរលត់នៃអាយតនៈទាំងឡាយ ។

ប្រើនបទថា សម្មា ចិត្តំ វិមុច្ចតិ : កាលភិក្ខុនោះមានចិត្តផុតស្រឡះហើយដោយប្រពៃ មានសេចក្តីថា ចិត្តរមែងរួចផុតដោយអំណាចផលសមាបត្តិ ព្រោះគោលបដិបត្តិជាគ្រឿងឃើញច្បាស់នេះ ដោយប្រពៃគឺ តាមហេតុតាមន័យ បានដល់ បង្អោនទៅក្នុងនិព្វានជាអារម្មណ៍ ។

បទថា សន្តចិត្តស្ស : មានចិត្តស្ងប់ហើយ បានដល់ និព្វុតចិត្តស្ស : មានចិត្តរលត់កិលេសហើយ (ឬមានចិត្តត្រជាក់ ) ។

បទថា នាធិនោ : ភិក្ខុជាតាទិបុគ្គល គឺ ចាត់ថា អ្នកទីពឹងពឹង ព្រោះមិនញាប់ញ័រ ដោយសេចក្ដីត្រេកអរ ប្រទូសរ៉ាយ ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

(៥៣) ពីរបទថា អញ្ញំ ព្យាករោន្តិ : តែងប្រកាសគុណ បាន ដល់ ព្យាករណ៍អរហត្ត ។

ពីរបទថា អត្ថោ ច វុត្តោ : បានប្រកាសសេចក្ដីនៃបុគ្គលដទៃ ជាអរហន្តផង មានសេចក្ដីថា ខ្លួនដែលអ្នកដទៃទីពឹងជ្រាបថា ជាអរហន្ត ដោយសេចក្ដីណា សេចក្ដីនោះ ដែលកុលបុត្រទាំងឡាយពោលហើយ ។ ចំណែកសេចក្ដីនៃសូត្រ គប្បីកាន់យកអំពីវណ្ណនានៃសុត្តន្ត:ចុះ ។

ពីរបទថា អត្តា ច អនុបនីតោ : មិនបង្អោនខ្លួនទៅដោយ អំនួតថា ខ្លួនជាព្រះអរហន្តផង មានសេចក្ដីថា ទាំងមិនបង្អោនខ្លួនចូល ទៅ ដោយអំណាចព្យញ្ជនៈយ៉ាងនេះថា "ខ្ញុំជាព្រះអរហន្ត" ។

ប្រើនបទថា អថ ច បនិធេកច្ចេ មោឃបុរិសា : ម្យ៉ាងទៀត ក្នុងលោកនេះ មានពួកមោឃបុរសខ្លះ មានសេចក្ដីថា ចំណែកពួកបុរស ទទេដទៃ ធ្វើដូចជាសប្បាយរីករាយ ព្យាករណ៍អរហត្តផលដែលមិនមាន សោះ ធ្វើឱ្យមានដោយហេតុត្រឹមតែពោលពាក្យ ។

# ស្បែកជើង

បទថា ឯកបលាសិកំ : ១ ជាន់ បានដល់ តែមួយសន្ទឹក (ឬ១បន្ទះ) ។

វិនិច្ឆ័យក្នុងពាក្យថា អសីតិសកដវាហេ : ចំនួយ ៨០ រទេះធំ នេះ គប្បីជ្រាប ដូច្នេះ ៖

ពីររទេះ គប្បីជ្រាបថា ជាមួយវាហ: ។

វិនិច្ឆ័យក្នុងពាក្យថា សត្តហត្ថិកញ្ច អនីកំ : នូវពួកសេនា ប្រកបដោយដំរី ៧ ផង នេះ គប្បីជ្រាបដូច្នេះ ៖

បរិមាណនេះគឺ ដំរីញី ៦ នឹងដំរីឈ្មោល ១ ជាអនីក:មួយ, ៧ អនីក: ដូច្នេះ ឈ្មោះថា សត្តហត្ថិកអនីក: ។

បទថា ទិគុណា : ២ ជាន់ បានដល់ ស្បែកពីរសន្ទឹក(ឬ ២បន្ទះ) ។

បទថា តិគុណា : ៣ ជាន់ បានដល់ ស្បែកបីសន្ទឹក(ឬ ៣បន្ទះ) ។

ស្បែកជើងមានជាន់ តាំងពី ៤ ជាន់ឡើងទៅ ព្រះមានព្រះភាគ ត្រាស់ថា គណង្គណុបាហនា : ស្បែកជើងច្រើនជាន់ ។

[៥៤] បទថា សព្វនីលិកា : ខៀវទាំងអស់ បានដល់ ខៀវ

សុទ្ធតែម្តង ។ សូម្បីក្នុងពណ៌ផ្សេង ៗ មានលឿងសុទ្ធជាដើម ក៏មានន័យដូចគ្នា ។ ក៏បណ្តាស្បែកជើងពណ៌ទាំងនោះ ស្បែកជើងខៀវចាស់ មានពណ៌ស្រដៀងពណ៌ផ្កាត្រកៀត ស្បែកជើងលឿង មានពណ៌ស្រដៀងផ្កាកណ្ណិការ ស្បែកជើងក្រហម មានពណ៌ស្រដៀងផ្កាច្បារ ស្បែកជើងក្រហមខ្ចី គឺ ក្រហមស្រទន់ មានពណ៌ស្រដៀងចំបើង ស្បែកជើងខ្មៅ មានពណ៌ស្រដៀងពណ៌ផ្លែផ្គាំ ស្បែកជើងក្រហមក្រម៉ៅ មានពណ៌ស្រដៀងខ្នងក្អែប ស្បែកជើងក្រហមព្រឿង ៗ មានពណ៌លាយគ្នាស្រដៀងពណ៌ស្លឹកឈើទុំ, តែក្នុងកុរុន្ទីថា មានពណ៌ស្រដៀងផ្កាឈូក ។ បណ្តាស្បែកជើងទាំងនេះ ភិក្ខុបានប្រភេទណាមួយហើយ យកសំពត់ជូតទឹកថ្នាំទម្លាយពណ៌ចេញ ហើយពាក់ គួរ ។ សូម្បីទម្លាយពណ៌ចេញត្រឹមតែបន្តិច ក៏គួរដែរ ។

បទថា **នីលវទ្ធិកា : មានខ្សែខៀវ** បានដល់ ស្បែកជើងដែលមានពណ៌ខៀវតែខ្សែប៉ុណ្ណោះ ។ សូម្បីក្នុងពណ៌ទាំងពួងមានពណ៌លឿងជាដើម មានន័យដូចគ្នា ។ សូម្បីស្បែកជើងដែលមានខ្សែខៀវជាដើមទាំងនោះ ក៏គប្បីទម្លាយពណ៌ចេញហើយ ទើបគួរពាក់ ។

បទថា **ខល្លកពទ្ធា : បិទកែង** បានដល់ ស្បែកជើងដែលធ្វើជាប់ផ្ទាំងស្បែកតាំងពីផ្ទៃបាតឡើងមកដើម្បីបិទកែង ។ ស្បែកជើងរបស់អ្នកយោនក ហៅថា ស្បែកជើងឃ្លុប បានដល់ ស្បែកជើងដែលបិទ

ជើងទាំងអស់ដរាបដល់ស្មង ។

បទថា ចាលិគុណ្ឋិមា : ដែលគេក្រងជារបៀបបិទខ្នងជើង បានដល់ ស្បែកជើងដែលគ្របខ្នងជើង បិទត្រឹមតែលើខ្នងប៉ុណ្ណោះ មិនបិទស្មង ។

បទថា តូលបុណ្ណិកា : ដែលញាត់ដោយគ បានដល់ ស្បែកជើងដែលធ្វើញាត់ដោយសំឡីគ ។

បទថា តិត្តិរបត្តិកា : មានខ្សែដូចស្លាបទទា បានដល់ ស្បែកជើងដែលមានខ្សែដែលគេវិចិត្រហើយ ដូចគ្នានឹងស្លាបសត្វទទា ។

បទថា មេណ្ឌវិសាណវទ្ធិកា : មានខ្សែដូចស្នែងកែះ បានដល់ ស្បែកជើងដែលធ្វើប្រកបខ្សែ មានសណ្ឋានស្រដៀងស្នែងកែះ ត្រង់ចុងជើងងបះឡើង សូម្បីក្នុងស្បែកជើងដែលមានខ្សែដូចស្នែងពពែជាដើមក៏ន័យនេះឯង ។

បទថា វិច្ឆិកាឡិកា : មានខ្សែដូចកន្ទុយខ្ទួយ បានដល់ ស្បែកជើងដែលធ្វើប្រកបខ្សែមានសណ្ឋានដូចកន្ទុយសត្វខ្ទួយ ត្រង់ចុងជើងបះនោះឯង ។

បទថា មោរបិញ្ឆបរិសិព្វិតា : ដែលស្រេះដោយព្រុយកន្ទុយក្ងោក បានដល់ ស្បែកជើងដែលដេរត្រង់ផ្ទៃក្តី ត្រង់ខ្សែក្តី ដោយ

ព្រយកន្ទុយក្រោក ប្រាកដដូចអំបោះ ។

បទថា ចិត្រា : ដ៏វិចិត្រ បានដល់ ស្បែកជើងដែលស្រស់ល្អ ផ្សេង ៗ សូម្បីក្នុងស្បែកជើងទាំងនេះ ភិក្ខុបានប្រភេទណាមួយហើយ បើអាចយកវត្ថុដែលមិនគួរទាំងនោះ ជាដើមថា ស្បែកបិទកែងចេញបាន គប្បីយកចេញហើយប្រើចុះ ។ តែកាលវត្ថុដែលមិនគួរ មានស្បែកបិទកែងជាដើមនោះនៅមាន, ភិក្ខុអ្នកប្រើ ត្រូវអាបត្តិទុក្កដ ។ ស្បែកជើងដែលធ្វើប្រកបស្បែករាជសីហ៍ ត្រង់ជាយដោយជុំវិញ ដូចជាប់អនុវាទក្នុងចីវរ ឈ្មោះថា ស្បែកជើងដេរភ្ជាប់ជាយដោយស្បែករាជសីហ៍ ។

បទថា ឧលូកចម្មបរិក្ខតា : ដែលចំជាយដោយស្បែកមៀម បានដល់ ស្បែកជើងដែលដេរភ្ជាប់ជាយដោយស្បែកសត្វមៀម សូម្បីក្នុងស្បែកជើងទាំងនេះ ប្រភេទណាមួយ គប្បីយកស្បែកនោះចេញហើយពាក់ចុះ ។

[៩៥] បទថា ឱមុក្កំ : ដែលគេពាក់ហើយដោះមកប្រគេន បានដល់ ពាក់ហើយដោះចេញ ។

បទថា នវា : ថ្មី បានដល់ មិនទាន់បានប្រើ ។

[៩៦] បទថា អភិជីវនិកស្ស : មានការចិញ្ចឹមជីវិតស្មើគ្នា មានសេចក្តីថា គ្រហស្ថទាំងឡាយ រមែងរស់នៅចំពោះ គឺ សម្រេចការ

ចិញ្ចឹមជីវិតដោយមុខវិជ្ជាណា មានសេចក្តីគោរពក្នុងអាចារ្យ ព្រោះហេតុនៃមុខវិជ្ជានោះ ។

ក្នុងពាក្យថា ឥធ ខោ តំ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ នេះ ។ បទថា តំ ត្រឹមតែជានិបាត សេចក្តីថា ម្នាលភិក្ខុទាំងឡាយ... គប្បីប្រព្រឹត្តល្អក្នុងធម្មវិន័យនេះឯង ។

ពីរបទថា យំ តុម្ហេ បានដល់ យេ តុម្ហេ ម៉្យាងទៀត មានពាក្យអធិប្បាយថា យទិ តុម្ហេ ពិតមែន និបាត គឺ យំ ប្រើក្នុងអត្ថនៃ យទិ ស័ព្ទ ។

វិនិច្ឆ័យក្នុងពាក្យថា អាចរិយេសុ : ក្នុងអាចារ្យ ជាដើម ចំពោះអាចារ្យទាំង ៤ នេះ គឺបព្វជ្ជាចារ្យ ឧបសម្បទាចារ្យ និស្សយាចារ្យ ឧទ្ទេសាចារ្យ ចាត់ជាអាចារ្យពិត ក្នុងបទថា អាចរិយេសុ នេះ ។ ភិក្ខុមានវស្សា ៦ ល្មមជាអាចារ្យរបស់ភិក្ខុដែលមិនមានវស្សាបាន ។ ដោយថា ភិក្ខុដែលមិនមានវស្សានោះ នឹងអាស្រ័យលោក នៅក្នុងកាលដែលខ្លួនមានវស្សា ៤, ដោយប្រការយ៉ាងនេះ សូម្បីភិក្ខុទាំងនេះ ចាត់ថា អ្នកល្មមជាអាចារ្យបានពិត គឺ ភិក្ខុដែលមានវស្សា ៧ ល្មមជាអាចារ្យរបស់ភិក្ខុវស្សា ១ បាន, អ្នកមានវស្សា ៨ ល្មមជាអាចារ្យរបស់អ្នកមានវស្សា ២ បាន, អ្នកមាន វស្សា ៩ ល្មមជាអាចារ្យរបស់អ្នកមានវស្សា ៣

បាន, អ្នកមាន វស្សា ១០ ល្មមជាអាចារ្យរបស់អ្នកមានវស្សា ៤ បាន, ចំណែក ភិក្ខុជាមិត្រដែលជួបគ្នាម្តងម្កាល ឬមិត្រមាំមួន (ជិតដិត) របស់ឧបជ្ឈាយ៍ក្តី, ភិក្ខុ ពួកណាមួយ ដែលច្រើនជាង ១០ វស្សាក្តី ភិក្ខុទាំងអស់នោះ ឈ្មោះថា អ្នកល្មមជាឧបជ្ឈាយ៍; កាលភិក្ខុទាំងឡាយ មាន ប្រមាណប៉ុណ្ណេះ មិនពាក់ស្បែកជើងដើរចង្ក្រម រមែងជាអាបត្តិ ដល់ភិក្ខុអ្នកពាក់ស្បែកជើងដើរចង្ក្រម ។

[៥៧] ដែលឈ្មោះថា **រោគដំបៅលេចនៅបាតជើង** បានដល់ សាច់ដូចខ្នាយ ជាសាច់លៀនចេញអំពីផ្ទៃបាតជើង ។

## ទ្រនាប់ជើង

[៦០] បទថា **តិណបាទុកា** : ទ្រនាប់ជើងស្មៅ បានដល់ ទ្រនាប់ជើងដែលធ្វើដោយស្មៅប្រភេទណាមួយ ។

បទថា **ហិន្តាលបាទុកា** : ទ្រនាប់ជើងសន្ទុះទន្សែ បានដល់ ទ្រនាប់ជើងដែលធ្វើដោយស្លឹកផ្អាវ ទ្រនាប់ជើងដែលធ្វើហើយ សូម្បី ដោយស្លឹកទន្សែ មិនគួរដូចគ្នា ។

បទថា **កមលបាទុកា** : ទ្រនាប់ជើងស្មៅពណ៌ដូចផ្កាឈូក បានដល់ ទ្រនាប់ជើងដែលធ្វើដោយស្មៅ ដែលឈ្មោះថា កមលវណ្ណ

ព្រះអាចារ្យពួកខ្លះពោលថា ទ្រនាប់ជើងដែលធ្វើពីស្បូវរណ្ដាល ដូច្នេះ ក៏មាន ។

បទថា កម្ពលបាទុកា : ទ្រនាប់ជើងរោមសត្វ បានដល់ ទ្រនាប់ជើងដែលធ្វើដោយរោមចៀម ។

បទថា អសង្កមនីយា : ទ្រនាប់ជើងសម្រាប់បន្ទោបង់ បានដល់ ទ្រនាប់ជើងដែលតម្កល់ទុកយ៉ាងល្អលើផែនដីមិនកម្រើក មិនឃ្លាតចាកទី ។

## យាន

[៦១] ពីរបទថា អង្គជាតំ ឆុបន្តិ : ស្ទាបអង្គជាត បានដល់ ពាល់ត្រូវអង្គជាតិដោយអង្គជាតិនោះឯង ។

ពីរបទថា ឱគាហេត្វា មារេន្តិ : ចាប់ជ្រមុជកូនគោទៅក្នុងទឹកឱ្យស្លាប់ បានដល់ ចាប់ទុកយ៉ាងមាំឱ្យស្លាប់ខាងក្នុងទឹក ។

[៦២] បទថា ឥត្ថីយុត្តេន : ដោយប្រកបទឹងស្រី បានដល់ ទឹមដោយគោញី ។

បទថា បុរិសន្តរេន : ដោយលំដាប់នៃបុរស បានដល់ មានបុរសជាសារថី ។

បទថា បុរិសយុត្តេន ដោយប្រកបទឹងប្រុស បានដល់

ទឹមដោយគោឈ្មោល ។

បទថា ឥត្ថន្តរេន : ដោយលំដាប់នៃស្ត្រី បានដល់ មានស្ត្រីជាសារថី ។

បទថា គច្ឆាមហិយាយ : ក្នុងទន្លេគង្គានិងទន្លេមហី បានដល់ការលេងក្នុងទន្លេគង្គា និងទន្លេមហី ។

វិនិច្ឆ័យក្នុងពាក្យថា បុរិសយុត្តំ ហត្ថវដ្ដកំ នេះ គប្បីជ្រាបដូច្នេះ ៖

យានដែលទឹមដោយគោឈ្មោល ទឹងមានស្ត្រីជាសារថី ឬ មានបុរសជាសារថីក៏ដោយ, គួរ ។ ចំណែកយានដែលអូសទៅដោយដៃស្ត្រីអូស ឬបុរសអូសក៏ដោយ, គួរដូចគ្នា ។

បទថា យានុគ្ឃាតេន : ព្រោះទង្គិចទង្គុកដោយយាន មានសេចក្ដីថា កាយទាំងពួងរបស់ភិក្ខុនោះ រមែងញ័ររញ្ជួយ ព្រោះការរលាក់នៃយាន សេចក្ដីមិនសប្បាយ រមែងចាក់សៀតព្រោះបច្ច័យនោះ ។

បទថា សិវិកំ : គ្រែស្នែង បានដល់ គ្រែស្នែងមានតាំងអង្គុយ ។

បទថា បាដង្គី : អង្រឹងស្នែង បានដល់ ជាសំពត់ដែលគេចងជាប់នឹងឈើស្នែង ។

# ឧច្ចាសយនៈ និងមហាសយនៈ

[៦៣] វិនិច្ឆ័យក្នុងពាក្យថា ឧច្ចាសយនមហាសយនានិ : គ្រែកន្លងហួសប្រមាណ កម្រាលមិនគួរ អាសនខ្ពស់ហួសប្រមាណ នេះ គប្បីជ្រាបដូច្នេះ ៖

ទីជេកខ្ពស់នោះ បានដល់ គ្រែដែលហួសប្រមាណ; ទីជេកធំនោះ បានដល់ កម្រាលជាអកប្បិយ ។

ក្នុងអាសន្ទិជាដើម អាសន្ទិ នោះ បានដល់ ទីអង្គុយដែលហួសប្រមាណបល្ល័ង្កនោះ បានដល់ ទីអង្គុយដែលគេធ្វើរូបសត្វកាចសាហាវភ្ជាប់ទុកត្រង់ជើង ។

គោណកៈនោះ បានដល់ សំពត់ព្រំផ្ទាំងធំមានរោមវែង ។ បានឮថា រោមនៃព្រំនោះ វែងហួសបួនធ្នាប់ ។

ចិត្តកៈនោះ បានដល់ កម្រាលដែលធ្វើដោយរោមកែះដែលវិចិត្រដោយរូបសត្វសាហាវ ។

បដិកានោះ បានដល់ កម្រាលស ធ្វើដោយរោមកែះ ។

បដលិកានោះ បានដល់ កម្រាលធ្វើដោយរោមកែះ មានលាយផ្កាឈើសូម្បីជាប់គ្នា គេហៅថា សំពត់អាមលកៈ ។

តូលិកានោះ បានដល់ ពូកដែលញាត់សំឡីតាមប្រក្រតីទុំះឯង ។

វិកតិកានោះ បានដល់ កម្រាលធ្វើដោយរោមកែះ វិចិត្រដោយរូប

រាជសីហ៍និងខ្លាធំជាដើម ។

ឧទ្ធលោមីនោះ បានដល់ កម្រាលធ្វើដោយរោមកែះ មានរោមប្រាងឡើងតែម្ខាង ។ បាឋៈថា ឧទ្ធំលោមី ក៏មាន ។

ឯកន្តលោមីនោះ បានដល់ កម្រាលធ្វើដោយរោមកែះមានរោមប្រាងឡើងទាំងពីរខាង ។

កដិស្សៈនោះ បានដល់ កម្រាលដេកដែលត្បាញ ដោយឱទមាសលាយផ្សំដោយសូត្រ ហើយចាក់ស្រែះដោយរតនៈ ។

កោសេយ្យៈនោះ បានដល់ កម្រាលធ្វើដោយសសៃសូត្រចាក់ស្រែះដោយរតនៈ; តែជាសូត្រសុទ្ធទើបប្រើបាន ។

កុត្តកៈនោះ បានដល់ គ្រឿងក្រាលដេកដែលធ្វើដោយរោមកែះ ជំលួមស្រីរបាំ ១៦ នាក់ឈររាំបាន ។

ហត្ថត្ថរៈ និង អស្សត្ថរៈ បានដល់ កម្រាលលើខ្នងដំរី និងខ្នងសេះនុ៎ះឯង ។ និងក្នុងរថត្ថរៈ ក៏មានន័យដូចគ្នា ។

អជិនបវេណិនោះ បានដល់ កម្រាលដែលធ្វើជាជាន់ដែលដេរត្រួតគ្នាដោយស្បែកខ្លា ដោយទំហំប៉ុនទីងគ្រែ ។

កទលីមិគបវរបច្ចត្ថរណៈ នោះ បានដល់ កម្រាលដេកយ៉ាងល្អបំផុត ។ បានឮថា ជនទាំងឡាយ ភ្ជាប់ស្បែកឈ្លូសលើសំពត់សហើយដេរជាប់គ្នា ធ្វើជាកម្រាលនោះ ។

សឧត្តរច្ឆទំនោះ បានដល់ ទីដេកដែលមានពិតាន ខាងលើព្រម អធិប្បាយថា ទីដេកដែលព្រមដោយពិតានក្រហមដែលភ្ជាប់ទុកខាងលើ ។ សូម្បីមានពិតានស កាលមានកម្រាលដែលជាអកប្បិយនៅខាងក្រោម មិនគួរទេ, តែកាលបើមិនមាន គួរ ។

ឧភតោលោហិតកុបធានៈ នោះ បានដល់ ទីដេកមានខ្នើយក្រហមពីរខាងនៃគ្រែ គឺខ្នើយសីសៈមួយ ខ្នើយជើងមួយ ទីដេកប្រភេទនេះ មិនគួរ ។ ប៉ុន្តែថា កូនខ្នើយណាមួយប៉ុណ្ណោះ ត្រង់ខាងទាំងពីរ មានពណ៌ក្រហមក៏ដោយ មានពណ៌ដូចផ្កាឈូក ក៏ដោយ ដែលវិចិត្រក៏ដោយ បើប្រកបដោយប្រមាណខ្នើយនោះ រមែងគួរ ។ ចំណែកខ្នើយធំ ទ្រង់ហាម ។

[៦៥] ទីបិច្ឆាបោ បានដល់ ទីបិបោតកោ : កូនខ្លាដំបង ។

[៦៦] បទថា ឱគុម្ផិយន្តិ : បានចងរុំ មានសេចក្តីថា ជនទាំងឡាយ យកខ្សែស្បែកចងត្រង់ទីទ្រជញ្ជាំងជាដើម ។

បទថា អភិនិសីទិតុំ : ឱ្យភិក្ខុអង្គុយលើវិហារ មានសេចក្តីថា (តថាគតអនុញ្ញាត)ឱ្យភិក្ខុអង្គុយសង្កត់ គឺផ្អែកបាន ។

[៦៧] វិនិច្ឆ័យក្នុងពាក្យថា គិលានេន ភិក្ខុនា សឧបាហនេន : ភិក្ខុដែលឈឺពាក់ស្បែកជើង នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុណាចាត់ថា មានអាពាធ មិនពាក់ស្បែកជើង មិនអាចចូលស្រុកបាន ។

# រឿងព្រះសោណកុដិកណ្ណៈ

[៦៨] បទថា កុររឃរេ បានដល់ ក្នុងក្រុងមានឈ្មោះយ៉ាងនោះ, គោចរគ្រាមរបស់ព្រះមហាកច្ចាយនៈនោះ ព្រះធម្មសង្គាហកាចារ្យពោលដោយបទថា កុររឃរេ នោះ ។

ពីរបទថា បបាតេ បព្វតេ បានដល់ លើភ្នំបបាត ។ ស្ថានជាទីនៅរបស់លោក, ព្រះធម្មសង្គាហកាចារ្យពោលដោយពីរបទថា បបាតេ បព្វតេ នោះ ។

ពាក្យថា សោណោ ជាឈ្មោះរបស់ឧបាសកនោះ ។ ក៏ឧបាសកនោះ ទ្រទ្រង់គ្រឿងប្រដាប់ត្រចៀកមានតម្លៃមួយកោដិ ។ ព្រោះដូច្នោះ ទើបគេហៅថា កុដិកណ្ណៈ សេចក្តីថា កោដិកណ្ណៈ ។

បទថា ឯកសេយ្យំ : ការដេកម្នាក់ឯង បានដល់ ការដេករបស់បុគ្គលម្នាក់, សេចក្តីថា ព្រហ្មចរិយៈ ប្រកបដោយភាពជាទីតាំងនៃសេចក្តីព្យាយាមរឿយ ៗ ។

បទថា បាសាទិកំ : ជាទីនាំមកនូវជ្រះថ្លា បានដល់ ឱ្យកើតសេចក្តីជ្រះថ្លា ។

បទថា បសាទនីយំ : គួរជ្រះថ្លា នេះ ជាពាក្យវេវចនៈរបស់បទ

ថា បាសាទិកំ នោះឯង ។

បទថា ឧត្តមទមថសមថំ : បាននូវការទូន្មាន និងស្ងប់រម្ងាប់ដ៏ប្រសើរ បានដល់ ការទូន្មានផង ការស្ងប់ផង គឺ បញ្ញាសម្រាប់ទូន្មាន និងសមាធិសម្រាប់រម្ងាប់ដ៏ឧត្តម, សេចក្តីថា សេចក្តីស្ងប់កាយ និងស្ងប់ចិត្ត ដូច្នេះ ក៏បាន ។

បទថា ទន្តំ : ទូន្មានព្រះអង្គហើយ មានសេចក្តីថា ឈ្មោះថាអ្នកទូន្មានហើយ ព្រោះកិលេសជាគ្រឿងក្តៅក្រហាយ ដែលជាសឹកសត្រូវទាំងពួង ជារបស់កាត់ផ្តាច់ហើយ, អធិប្បាយថា អ្នកអស់កិលេសហើយ ។

បទថា គុត្តំ : បានរក្សាព្រះអង្គហើយ បានដល់ អ្នកគ្រប់គ្រងហើយ ដោយការរវាំង គឺ សេចក្តីប្រុងប្រយ័ត្ន ។

បទថា យតិន្ទ្រិយំ : បានឈ្នះឥន្ទ្រិយហើយ បានដល់ ទ្រង់មានឥន្ទ្រិយរម្ងាប់ហើយ ។

បទថា នាគំ : ប្រសើរ (ឬអ្នកមិនធ្វើអំពើអាក្រក់-លាមក) បានដល់ អ្នកវៀរចាកបាប, សេចក្តីថា អ្នកប្រាសចាកកិលេស ។

ច្រើនបទ តិណ្ណំ មេ វស្សានំ អច្ចយេន : ខ្ញុំព្រះអង្គ... លុះ

**តែកន្លង ៣ ឆ្នាំទៅហើយ** មានសេចក្តីថា ដោយការកន្លងទៅបីឆ្នាំ ចាប់តាំងពីថ្ងៃបព្វជ្ជារបស់ខ្ញុំព្រះអង្គ ។

ពីរបទថា ឧបសម្បទំ អលត្ថំ : **ហើយបានឧបសម្បទា** សេចក្តីថា ខ្ញុំព្រះអង្គ ទើបបានឧបសម្បទា ។

បទថា កណ្ហុត្តរា : **មានផែនដីខ្មៅ** បានដល់ មានដីខ្មៅក្រៃលែង, សេចក្តីថា មានដីខ្មៅជាដុំទួលឡើង ។

បទថា គោកណ្ដកហតា : **ដោយស្នាមជើងគោ** គឺ ជាផ្ទៃផែនដីដែលត្រូវធ្វើឱ្យខូចដោយក្រហែងក្រចកគោ ដែលតាំងឡើងអំពីផែនដីដែលត្រូវក្រចកគោជាន់ ។ បានឮថា ស្បែកជើងមួយជាន់មិនអាចការពារក្រហែងក្រចកគោទាំងនោះបាន, ផ្ទៃផែនដីជារបស់រើង ៗ ដោយប្រការដូច្នេះ ។

តិណជាតិមានប្រាកដ ៤ យ៉ាងនេះ គឺ ឯរគុ គឺ ស្មៅជើងក្អែក ១ មោរគុ គឺ ស្មៅកន្ទុយសត្វក្ងោក ១ មជ្ជារុ គឺ ស្មៅពុកមាត់ឆ្មា ១ ជន្តុ គឺ ស្មៅកន្ទុយដំរី ១ ជនទាំងឡាយ រមែងធ្វើកន្ទេលរើង និងកន្ទេលទន់ដោយស្មៅទាំងនេះ ។

បណ្ដាតិណជាតិ ៤ ប្រភេទនោះ ស្មៅឯរគុនោះ បានដល់ ស្មៅ

ជើងក្អែក, ស្បៅជើងក្អែកនោះ ជារបស់គ្រោតគ្រាត; ស្បៅមោរគុមានចុង ពណ៌ក្រហមល្អិតទន់ មានសម្ផស្សស្រួល; កន្ទេលដែលធ្វើដោយស្បៅ មោរគុនោះ កាលដេកហើយល្មមក្រោកឡើង ជារបស់ប៉ោងឡើងទៀត បាន ។ ជនទាំងឡាយ រមែងធ្វើសូម្បីនូវសំពត់សាដក ដោយស្បៅ មជ្ជារុ; ស្បៅជន្ទុមានពណ៌ស្រដៀងកែវមណី ។

ពីរបទថា សេនាសនំ បញ្ញាបេសិ មានសេចក្ដីថា ព្រះអានន្ទ ដ៏មានអាយុបានក្រាលពូក ឬកន្ទេលរឹង ។ ក៏ឯកាលក្រាលហើយ ទើប ប្រាប់ដល់ព្រះសោណៈ ថា "អ្នកមានអាយុ ព្រះសាស្ដាមានព្រះប្រាថ្នា នឹងនៅក្នុងទីប្រកបិទបាំងជាមួយនឹងលោក, សេនាសនៈ សម្រាប់លោក យើងក្រាលទុកហើយ ក្នុងព្រះគន្ធកុដិនុ៎ះឯង" ។

[៦៩](*) ច្រើនបទថា បដិភាតុ តំ ភិក្ខុ ធម្មោ ភាសិតុំ : នៃភិក្ខុ អ្នកគួរនឹងសម្ដែងធម៌បន្តិចទៅ មានសេចក្ដីថា ធម៌ចូរមាន ចំពោះមុខនៃញាណ ពោលគឺ បដិភាណដើម្បីសូធ្យ ។

បទថា អដ្ឋកវគ្គិកានិ : ក្នុងអដ្ឋកវគ្គ មានសេចក្ដីថា ព្រះ

---

* [៦៩]នេះ មិនមានក្នុងសមន្តបាលី ព្រោះជាសេចក្ដីនៃព្រះសូត្រ មិនមានសេចក្ដីនៃ ព្រះវិន័យ, មានក្នុងរឿងសោណកុដិកណ្ណត្ថេរ អដ្ឋកថានៃឯតទគ្គ. ថេរគាថា. ឧទាន ។

សោណៈដ៏មានអាយុបានសូធ្យព្រះសូត្រ ១៦ សូត្រ មានកាមសូត្រជាដើម ដែលមានក្នុងអដ្ឋកវគ្គ[១] ទាំងនោះ ។

បទថា វិស្សជ្ជាយ : ដ៏ពីរោះក្បោះក្បាយ គឺ មានអក្ខរដែលពីរោះរណ្តំ ។

បទថា អនេលគលាយ : ប្រាសចាកទោស មានសេចក្តីថា ភាពជាវាចាប្រកបដោយទោស រមែងមិនមាន ។

ពីរបាទគាថាថា អរិយោ ន រមតី បាបេ, បាបេ ន រមតី សុចិ : ជាព្រះអរិយ រមែងមិនត្រេកអរក្នុងបាប ជាបុគ្គលស្អាត រមែងមិនត្រេកអរក្នុងបាប មានសេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ព្រះអរិយៈរមែងមិនត្រេកអរក្នុងបាប ដើម្បីសម្តែងសេចក្តីវិសេសថា ពិតមែន បុគ្គលណា ប្រកបដោយគុណធម៌ជាគ្រឿងស្អាតមកកាយ វាចា និងចិត្ត, បុគ្គលនោះ រមែងមិនត្រេកអរក្នុងបាប; ព្រោះដូច្នោះ ចំពោះព្រះអរិយៈ ឈ្មោះថា មិនត្រេកអរក្នុងបាប ។

[៧០] ច្រើនបទថា អយំ ខ្វស្ស កាលោ : កាលនេះជាកាលគួរ សេចក្តីថា វេលានេះឯង គប្បីជាកាល ។

---

១. ខុទ្ទ. សុត្ត. អដ្ឋកវគ្គ. ៥៤. ៩៥-១១០/២៦៥-៣២៣ ។

បទថា បរិធំសិ្ស : ពាក្យបណ្ដាំ បានដល់ បន្ទាប់មកហើយ ។

ក្នុងពាក្យនេះថា អយំ ខ្វស្ស កាលោ ... បរិធំសិ្ស មាន ពាក្យអធិប្បាយដូច្នេះថា ឧបជ្ឈាយ៍របស់យើង បានផ្ញើពាក្យបណ្ដាំយ៉ាងណាមកថា "ចូរលោកក្រាបទូលរឿងនេះផង រឿងនេះផង( យ៉ាងនេះ )", វេលានេះ គប្បីជាកាលគួរនឹង ទូលនូវពាក្យបណ្ដាំនោះ, ណ្ហើយចុះ យើងនឹងទូលនូវពាក្យបណ្ដាំនោះ ក្នុងពេលឥឡូវនេះ ។

[៧១] បទថា វិនយធរបញ្ចមេន : មានវិន័យធរជាគម្រប់ ៥ គឺ មាន (គណៈសង្ឃរួមនឹង )អាចារ្យអ្នកសូធ្យប្រកាសជាគម្រប់ ៥ ។

វិនិច្ឆ័យក្នុងពាក្យថា អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ គណង្គណូបាហនំ : ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទ ទាំងអស់ តថាគតអនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ នេះ គប្បីជ្រាបដូច្នេះ ៖

ស្បែកជើងដែលធ្វើដោយស្បែកប្រភេទណាមួយ វៀរស្បែក មនុស្សចេញ រមែងគួរសូម្បីក្នុងថង់ស្បែកជើង ស្រោមកាំបិតនិងស្រោម កូនសោ ក៏ន័យនេះឯង ។

## ស្បែក

ក៏ឯវិនិច្ឆ័យក្នុងពាក្យថា ចម្មានិ អត្ថរណានិ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុទីងក្រាលស្បែកកេះ និងស្បែកពពែណាទីមួយ ហើយដេក ឬអង្គុយ ក៏គួរ ។

វិនិច្ឆ័យក្នុងស្បែកម្រឹគ គប្បីជ្រាបដូច្នេះ ៖

ស្បែកនៃម្រឹគជាតិ គឺ សត្វទ្រាយ ស្ពាន់ ក្តាន់ ឈ្លូស ប្រើស រមាំង ទាំងនេះប៉ុណ្ណោះ គួរ ។ ចំណែកស្បែកនៃសត្វពួកដទៃ មិនគួរ ។

ស្វា ខ្លាឃ្មុំ សរភៈ សំពោច, និងសត្វដែលកាចសាហាវណាទីមួយ, ស្បែករបស់សត្វទាំងនោះ មិនគួរ ។

ក្នុងសត្វទាំងនោះ ដែលឈ្មោះថា សត្វកាចសាហាវ បានដល់ រាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ។ តែនឹងមិនគួរចំពោះសត្វទាំងនេះមួយពួកប៉ុណ្ណោះ ក៏ទេ; ស្បែករបស់សត្វ ពួកណា ព្រះមានព្រះភាគត្រាស់ថា "មិនគួរ" វៀរសត្វទាំងនោះចេញ សត្វទាំងឡាយដ៏សេសដោយហោចទៅ សូម្បីគោ ក្របី ទន្សាយ ឆ្មាជាដើម រួមទាំងអស់ គប្បីជ្រាបថា សត្វកាចដូចគ្នា ក្នុងអត្ថនេះ ។ ពិតមែន ស្បែករបស់

សត្វគ្រប់ ៗ ប្រភេទ មិនគួរ ។

ពាក្យថា ន តំ តាវ គណនូបគំ, យាវ ន ហត្ថំ គច្ឆតិ : ចីវរមិនទាន់មកដល់ដៃដរាបណា ចីវរនោះភិក្ខុមិនត្រូវរាប់តាមកំណត់ថ្ងៃ ដរាបនោះ មានសេចក្តីថា ចីវរដែលជនទាំងឡាយនាំមកហើយ តែមិនទាន់បានប្រគេនក្តី, ចីវរដែលគេផ្ញើទៅឱ្យ តែមិនទាន់បានប្រាប់ថា ចីវរកើតឡើងដល់លោកហើយ ដូច្នេះក្តី ត្រឹមណា; ចីវរនោះ មិនត្រូវរាប់ថ្ងៃ, គឺមិនគួរដើម្បីអធិដ្ឋាន, អធិប្បាយថា មិនទាន់ចូលដល់ការកាន់យកដែលគួរអធិដ្ឋានត្រឹមនោះ ។ តែចីវរដែលគេនាំមកប្រគេនហើយក្តី, ចីវរដែលគេផ្ញើ ទៅឱ្យនិងប្រាប់ហើយក្តី, ចីវរដែលភិក្ខុបានស្តាប់ថា កើតហើយក្តី ក្នុងកាលណា; ចាប់ផ្តើមតាំងពីកាលនោះទៅ ភិក្ខុរមែងបានបរិហារ ១០ ថ្ងៃ ប៉ុណ្ណោះ ដូច្នេះឯង ។

**ចម្មក្ខន្ធកវណ្ណនា ចប់ ។**

# ៦. ភេសជ្ជក្ខន្ធកវណ្ណនា

## ភេសជ្ជវិនិច្ឆ័យ

[៧៣] ក្នុងភេសជ្ជក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា សារទិកេន អាពាធេន : ភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាល បានដល់ អាពាធមានប្រម៉ាត់ជាសមុដ្ឋាន កើតឡើងក្នុងសរទកាល[១] ពិតមែន ក្នុងកាលនោះ ភិក្ខុទាំងឡាយ រមែងសើមដោយទឹកភ្លៀងខ្លះ រមែងជាន់ភក់ខ្លះ កម្តៅថ្ងៃ រមែងក្តៅឡើងក្នុងចន្លោះ ៗ ខ្លះ ព្រោះហេតុនោះ ប្រម៉ាត់របស់ភិក្ខុទាំងនោះ រមែងជារបស់ជ្រាបចូលទៅក្នុងពោះវៀន ។

ពីរបទថា អាហារត្ថញ្ច ផរេយ្យ : វត្ថុដែលផ្សាយទៅសម្រាប់ជាអាហារ មានសេចក្តីថា វត្ថុគប្បីញុំាងប្រយោជន៍ ដោយអាហារឱ្យសម្រេច ។

[៧៤] បទថា នច្ឆាទេន្តិ : ក៏មិនត្រូវមាត់ មានសេចក្តីថា រមែងមិនរលាយទៅ, គឺ មិនអាចនឹងរម្ងាប់រោគខ្យល់បាន ។

បទថា សិនេសិកានិ : ភោជនដ៏ស្និទ្ធ បានដល់ ភោជន

១. ពោលតាមរដូវ ៦ ក្នុងគម្រា(ក្បួនច្បាប់)ពេទ្យ, សារទរដូវ បានដល់ ខែ ១១ និងខែ ១២ និងថា ជាជម្ងឺដើម្បីខ្យល់ ។

ដ៏ឆ្ងាញ់ ( បបរខាប់ បបរគ្រឿង ) ។

បទថា ភត្តច្ឆាទកេន : ដែលមិនរលួយ គឺ ការមិនរលួយនៃអាហារ ។

[៧៥] វិនិច្ឆ័យក្នុងបទថា អច្ឆរសំ : ខ្ទាញ់ខ្ទាឃ្មុំ ជាដើម គប្បីជ្រាបដោយន័យដែលពោលក្នុងអដ្ឋកថានៃនិស្សគ្គិយកណ្ឌ[១]នុ៎ះឯង ។

ក្នុងពាក្យថា កាលេ បដិគ្គហិតំ : ទទួលក្នុងកាលគួរ ជាដើម មានសេចក្ដីថា ទទួលប្រគេន ចម្អិន ត្រង ក្នុងកាលថ្ងៃត្រង់មិនទាន់កន្លងទៅ ។

ពីរបទថា តេលបរិភោគេន បរិភុញ្ជិតុំ : សម្រាប់ឱ្យភិក្ខុប្រើប្រាស់ដោយវិធីប្រើប្រាស់ដូចប្រេង មានសេចក្ដីថា ដើម្បីបរិភោគដូចការបរិភោគប្រេង ដែលជាសត្តាហកាលិក ។

[៧៦] សូម្បីវិនិច្ឆ័យក្នុងមូលភេសជ្ជៈជាដើម ក៏បានពោលហើយក្នុងខុទ្ទកវណ្ណនា[២]ដូចគ្នា ព្រោះហេតុនោះ ពាក្យណា ៗ ដែលមិនបានពោលហើយក្នុងកាលមុន ខ្ញុំព្រះករុណានឹងពណ៌នាចំពោះពាក្យនោះ ៗ ក្នុងទីនេះ ។

បទថា វចត្តំ : មើមប្រស់ បានដល់ ប្រទាលដ៏សេស ។

១. សមន្ត. និស្ស. ១៤១/ ។ ២. សមន្ត. បាចិ. ១២៧/២៧១_២ ។

ពីរបទថា និសធំ និសធធ្មោតំ : ថ្មកិន និងកូនថ្មកិន បានដល់ត្បាល់កិន និង កូនត្បាល់កិន ។

[៧៧] ឈ្មោះថា បត្តវៈ (បណ្តូលពេជ្រ)នោះ ជាវុក្ខជាតិវល្លិ៍ ។

បទថា ឆត្តមាលំ បានដល់ ករញ្ជ : ទន្លាប្ញថ្ងាន់ ។

[៨០] ហិង្គុ ហិង្គុជតុ និងហិង្គុសិបាដិកា ក៏គឺជាតិនៃហិង្គុនុំះឯង ។ តកៈ (ជ័រចេញពីត្រួយ) តកបត្តិ (ជ័រចេញពីស្លឹក) និងតកបណ្ណិយៈ(ជ័រធ្វើពីស្លឹក) ក៏គឺ ជាតិមែកនុំះឯង ។

[៨១] អំបិលសមុទ្ទនោះ បានដល់ អំបិលដែលកើតតាមឆ្នេរសមុទ្រ ដូចខ្សាច់ ។

អំបិលកាឡលោណៈនោះ បានដល់ អំបិលតាមប្រក្រតី (មានពណ៌ខ្មៅ) ។

អំបិលសិន្ធវៈនោះ បានដល់ អំបិលមានពណ៌ស កើតលើភ្នំ ។

អំបិលឧព្ភិទៈនោះ បានដល់ អំបិលដែលជាពន្លកដុះចេញពីផែនដី ។

អំបិលពិលៈនោះ បានដល់ អំបិលមានពណ៌ក្រហមដែលគេស្លជាមួយនឹងគ្រឿងផ្សំទាំងពួង ។

[៨២] ពីរបទថា **កាយោ វា ទុគ្គន្ធោ** : និងកាយមានក្លិនស្អុយ មានសេចក្តីថា ក្លិនខ្លួនរបស់ភិក្ខុរូបខ្លះ ដូចក្លិននៃសត្វមានសេះជាដើម លំអិតនៃដើមប្រែសនិងផ្កាសុម្ភៈជាដើម ឬលំអិតនៃគ្រឿងក្រអូបគ្រប់យ៉ាង គួរដល់ភិក្ខុនោះ ។

បទថា ឆកានំ : **អាចម៍សត្វទាំងឡាយ មានសេះជាដើម** បានដល់ **គោមយំ** : អាចម៍គោ ។

បទថា រជននិប្បក្កំ បានដល់ រជនកសដំ : កាកគ្រឿងជ្រលក់ ។ ភិក្ខុនឹងបុកនូវលំអិតទាំងនុ៎ះ ហើយត្រាំទឹកផ្ទូត(ជាប្រក្រតី) ក៏គួរ ។ សូម្បីលំអិតតាមប្រក្រតីនោះ រមែងដល់ការរាប់ថា កាកគ្រឿងជ្រលក់ដូចគ្នា ។

[៨៤] អមនុស្សស៊ីសាច់ឆៅ និងហុតឈាមស្រស់ ព្រោះហេតុនោះ ភិក្ខុទើបឈ្មោះថា មិនបានឆាន់សាច់ឆៅ និងហុតឈាមស្រស់នោះទេ ។ អមនុស្ស កាលស៊ីនិងហុតហើយបានចេញទៅ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា អាពាធកើតអំពីអមនុស្សនោះរបស់លោក រមែងរម្ងាប់ ។

[៨៥] ពាក្យថា អញ្ជនំ : **ថ្នាំបន្តក់ភ្នែក** នេះ ជាពាក្យពោលយកថ្នាំបន្តក់ភ្នែកទាំងអស់ ។

បទថា កាឡញ្ជនំ : ថ្នាំបន្តក់ភ្នែកមានពណ៌ខ្មៅ បានដល់ ជាតិនៃថ្នាំបន្តក់ភ្នែក១ប្រភេទ ឬថ្នាំបន្តក់ភ្នែកដែលស្ងោរដោយគ្រឿងផ្សំគ្រប់យ៉ាង ។

បទថា រសញ្ជនំ : ថ្នាំបន្តក់ភ្នែកធ្វើពីបារទ បានដល់ ថ្នាំបន្តក់ភ្នែកដែលធ្វើដោយគ្រឿងផ្សំផ្សេង ៗ ។

បទថា សោតញ្ជនំ : ថ្នាំបន្តក់ភ្នែកដែលកើតក្នុងខ្សែទឹក បានដល់ ថ្នាំបន្តក់ភ្នែកដែលកើតក្នុងក្រសែទឹកជាដើម ។

សុវណ្ណគេរុកោ : ហរិតាល, ត្របកមាស ឈ្មោះថា គេរុកំ : ជ័រវង់ ។

ឈ្មោះថា កបល្លៈ : ធ្យូង នោះ បានដល់ ម្រែងភ្លើងដែលយកមកពីអណ្តាតប្រទីប ។

ឈ្មោះថា ខ្លឹមចន្ទន៍ បានដល់ ចន្ទន៍ប្រភេទណាមួយ មានចន្ទន៍ក្រហមជាដើម ។ គ្រឿងថ្នាំបន្តក់ភ្នែកទាំងឡាយ មានក្រឹស្នាជាដើមប្រាកដហើយ ។ គ្រឿងថ្នាំ សូម្បីពួកដទៃ មានឧប្បលខៀវជាដើមរមែងគួរដូចគ្នា ។

បទថា អញ្ជនុបបឹសនេហិ : វត្ថុដែលយកមកលាយជាមួយគ្នានឹងថ្នាំបន្តក់ភ្នែក បានដល់ គ្រឿងថ្នាំទាំងឡាយដែលនឹងគប្បីកិនផ្សំនឹង

ថ្នាំបន្តក់ភ្នែក ។ តែគ្រឿងកិនថ្នាំបន្តក់ភ្នែកណា ៗ នឹងមិនគួរ ក៏ទេ ។

បទថា អគ្គិមយំ : ក្លាក់ធ្វើដោយឆ្អឹង មានសេចក្តីថា ក្លាក់ថ្នាំបន្តក់ភ្នែកដែលធ្វើដោយឆ្អឹងដ៏សេសវៀរឆ្អឹងមនុស្ស ។

បទថា ទន្តមយំ : ក្លាក់ធ្វើដោយភ្លុក បានដល់ ក្លាក់ថ្នាំបន្តក់ភ្នែកដែលធ្វើដោយភ្លុកគ្រប់យ៉ាង មានភ្លុកដំរីជាដើម ។

ឈ្មោះថា ក្លាក់ដែលមិនគួរ រមែងមិនមានក្នុងក្លាក់ដែលធ្វើដោយស្នែងឡើយ ។ ក្លាក់ថ្នាំបន្តក់ភ្នែក ដែលធ្វើដោយបបុសជាដើម ជារបស់គួរដោយចំណែកតែមួយពិត ។

បទថា សលាកោធានិយំ : បំពង់សម្រាប់ដាក់ចង្កឹះ មានសេចក្តីថា ជនទាំងឡាយ រមែងរក្សាចង្កឹះថ្នាំបន្តក់ភ្នែកក្នុងទីរក្សាយ៉ាងណា តថាគតអនុញ្ញាតទីរក្សាយ៉ាងនោះ ជាក្លាក់ក៏ដោយ ជាថង់ក៏ដោយ ។

បទថា អំសវទ្ធកំ : ខ្សែយោគ នោះ បានដល់ ខ្សែយោគ (ខ្សែសម្រាប់ស្ពាយ) នៃថង់ថ្នាំបន្តក់ភ្នែក ។

[៨៦] ពីរបទថា យមកំ នត្ថុករណឹ : បំពង់សម្រាប់បញ្ចូកទៅតាមច្រមុះជាគូ បានដល់ បំពង់ថ្នាំនត្ថុតែម្យ៉ាងជាបំពង់គូ មានរន្ធប៉ុនគ្នា ។

[៨៧] ពាក្យថា អនុជានាមិ ភិក្ខវេ តេលបាកំ : ម្នាលភិក្ខុ

ទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុស្លប្រេងបាន មានសេចក្តីថា ការស្លប្រេងគ្រប់ប្រភេទ ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឱ្យដាក់គ្រឿងថ្នាំឯណាទីមួយចុះបានពិត ។

បទថា អតិបក្កិត្តមជ្ជានិ : ស្លប្រេងលាយទឹកស្រវឹងច្រើនពេក មានសេចក្តីថា មានទឹកស្រវឹងដែលខ្លួនដាក់ច្រើនហួស, អធិប្បាយថា ផ្សំដាក់ទឹកស្រវឹងខ្លាំងពេក ។

ខ្យល់ក្នុងអវយវៈតូច-ធំ ឈ្មោះថា អង្គវាតៈ ។

បទថា សម្ភារសេទំ : ឆ្អងដោយស្លឹកឈើ និងមែកឈើផ្សេង ៗ បានដល់ ការចូលឆ្អងដោយស្លឹកឈើដែលទឹងគប្បីកាច់បានមានប្រភេទផ្សេង ៗ ។

បទថា មហាសេទំ : ឆ្អងធំ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យឆ្អងរាងកាយ ដោយដាក់រងើកភ្លើងឱ្យពេញរណ្តៅ ប្រមាណមួយជំហរហើយ បិទរណ្តៅនោះដោយអាចម៍ដីនិងខ្សាច់ជាដើម ក្រាលស្លឹកឈើប្រភេទផ្សេង ៗ ដែលបំបាត់រោគខ្យល់បាន លើរណ្តៅនោះ ហើយដេកត្រឡប់ទៅត្រឡប់មកលើស្លឹកឈើនោះ ដោយខ្លួនដែលលាបប្រេងហើយ ។

បទថា ភង្គោទកំ : លាយទឹក បានដល់ ទឹកដែលស្ងោរក្តៅ

ដោយស្លឹកឈើផ្សេង ៗ ដែលគួរកាច់បាន ។ គប្បីស្រោចខ្លួនដោយស្លឹកឈើទាំងនោះនឹងទឹក ចូលផ្តួង ។

បទថា ឧទកោដ្ឋកំ : បន្ទប់ទឹក បានដល់ ស៊ុំទឹក, សេចក្តីថា តថាគតអនុញ្ញាតឱ្យប្រើធុងឬស្នូក ដែលពេញដោយទឹកក្តៅ ហើយចូលក្នុងបន្ទប់ទឹកនោះ ធ្វើការផ្តួងឱ្យបេញញើស ។

[៨៨] ពីរបទថា បព្វវាតោ ហោតិ : កើតខ្យល់ក្នុងសន្លាក់ មានសេចក្តីថា ខ្យល់រមែងចេញតាមសន្លាក់ ៗដៃជើងជាដើម ។

ពីរបទថា លោហិតំ មោចេតុំ : ធ្វើឈាមឱ្យហូរចេញ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុបញ្ចេញលោហិតដោយកាំបិត ។

[៨៩] ពីរបទថា មជ្ជំ អភិសង្ខរិតុំ : តាក់តែងទឹកស្រវឹង មានសេចក្តីថា ជើងដែលបែកហើយ ទឹងសះស្បើយជាប្រក្រតីបានដោយទឹកស្រវឹងណា តថាគតអនុញ្ញាតឱ្យភិក្ខុដាក់ថ្នាំផ្សេង ៗ ចុះក្នុងត្រឡោកដូងជាដើមផ្សំទឹកស្រវឹងនោះ គឺឱ្យស្លថ្នាំលាបជាទីសប្បាយដល់ជើងទាំងពីរ ។

[៩០] ពីរបទថា តិលកក្កេន អត្ថោ : ត្រូវការដោយម្សៅ មានសេចក្តីថា ត្រូវការដោយល្ងទាំងឡាយ ដែលកិនហើយ ។

បទថា កពឡិកំ : ត្រូវការដោយដុំសដូវ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុបំពោកម្សៅត្រង់មុខដំបៅ ។[១]

បទថា សាសបកុឌ្ឌេន : លាងដោយម្សៅគ្រាប់ស្ពៃ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុលាងជម្រះដោយម្សៅគ្រាប់ស្ពៃ ។

បទថា វឌ្ឍមំសំ : សាច់ដំបៅក៏ដុះលៀនចេញមក បានដល់សាច់ដែលដុះឡើងដូចខ្នាយ ។

ពីរបទថា លោណសក្ខរិកាយ ឆិន្ទតុំ : យកទឹកលាយនឹងអំបិលមកបន្ទាត់ តថាគតអនុញ្ញាតឱ្យកាត់ដោយកាំបិទកោរ ។

បទថា វិកាសិកំ : សំពត់សម្រាប់បិទប្រេង បានដល់ សំពត់ចាស់សម្រាប់ការពារប្រេង ។

ពីរបទថា សព្វំ វណបដិកម្មំ : ថ្នាំរក្សាដំបៅទាំងអស់ មានសេចក្តីថា ដែលឈ្មោះថា ការរក្សាដំបៅគ្រប់យ៉ាង តថាគតអនុញ្ញាតទាំងអស់ ។

[៩១] ពីរបទថា សាមំ គហេត្វា : កាន់យកដោយខ្លួនឯង

១. វិមតិវិនោទនី. កពឡិកាតិ. អបនាហភេសជ្ជន្តិ : ថ្នាំសម្រាប់បំពោក ។

មានសេចក្តីថា ថ្នាំមហាវិកដ៍នេះ មិនមែនភិក្ខុត្រូវពស់ខាំតែម្យ៉ាងប៉ុណ្ណោះ ដែលគួរកាន់យកឆាន់ដោយខ្លួនឯងទេ, សូម្បីកាលពិសដែលសត្វខាំហើយយ៉ាងដទៃ ភិក្ខុក៏គប្បីកាន់យកឆាន់ដោយខ្លួនឯងបាន តែក្នុងហេតុទាំងឡាយដទៃ ទទួលប្រគេនហើយប៉ុននោះ ទើបគួរ ។

ពាក្យថា កាលោ ន បន បដិគ្គាហាបេតព្វោ : មិនបាច់ទទួលប្រគេនទៀតទេ មានសេចក្តីថា បើលាមកធ្លាក់ដល់ផែនដីហើយ ត្រូវទទួលប្រគេន តែទឹងកាន់យកដោយខ្លួនឯង នូវលាមកដែលនៅមិនធ្លាក់ដល់ផ្ទៃផែនដី គួរ ។

[៩២] រោគដែលកើតឡើងអំពីទឹកដែលស្ត្រីឱ្យ ដើម្បីធ្វើឱ្យនៅក្នុងអំណាច ឈ្មោះថា អាពាធកើតអំពីថ្នាំស្នេហ៍ដែលស្រីមេផ្ទះឱ្យ ។

បទថា សិតាលោឡឹ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុផឹកទឹកលាយដោយអាចម៍បំណាស់ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុយកដីដែលជាប់ផាលរបស់អ្នកភ្ជួរស្រែដោយនង្គ័ល លាយទឹកផឹក ។

បទថា ទុដ្ឋគហណិកោ : ខូចធាតុភ្លើង មានសេចក្តីថា អ្នកខូចធាតុភ្លើងសម្រាប់រំលាយអាហារ អធិប្បាយថា ឧច្ចារៈចេញលំបាក(រោគមួល) ។

បទថា អាមិសខារំ : ទឹកក្បុង មានសេចក្តីថា តថាគត

អនុញ្ញាតឱ្យ ភិក្ខុដុតបាយដែលហាលស្ងួតឱ្យឆេះ ហើយផឹកទឹកក្បួនដែលហូរចេញពីផេះនោះ ។

បទថា មុត្តហរីដកំ : សម៉ត្រាំដោយនោម បានដល់ សម៉ដែលត្រាំដោយមូត្រគោ ។

បទថា អភិសន្នកាយោ : កាយប្រកបដោយរោគទល់ បានដល់ មានកាយប្រកបដោយទោសច្រើន ។

បទថា អច្ឆកញ្ជិកំ : ទឹកបាយថ្លា[១] បានដល់ ទឹកអង្ករថ្លា ។

បទថា អកដយូសំ : ទឹកសណ្តែកបាយស្ងោរដែលគេមិនបានធ្វើឱ្យស្អិត បានដល់ ទឹកសណ្តែកបាយស្ងោរតែមិនខាប់ ។

បទថា កដាកដំ : ទឹកសណ្តែកបាយស្ងោរដែលគេធ្វើឱ្យស្អិត[២] បានដល់ ទឹកសណ្តែកបាយស្ងោរនោះឯង តែខាប់បន្តិច ។

បទថា បដិច្ឆាទនីយេន : សាច់ដែលមានឱជារស[៣] បានដល់ រសនៃសាច់ ។

---

១.២. មតិខ្លះយល់ថា ទ្រង់អនុញ្ញាតឱ្យឆាន់ទឹកបបរ ទឹកសណ្តែក ពេលល្ងាចបាន ។
៣. បើយ៉ាងនោះ តើរសនៃសាច់គួរក្នុងពេលល្ងាចដែរឬ ។ ចូរស្វែងរកសួស្តីចុះ ។

# ការចម្អិនក្នុងកុដិជាដើម

[៩៦] ពាក្យថា សចេ ភិក្ខវេ បក្កាបិ មគ្គា ជាយន្តិ : បើសណ្តែកបាយដែលគេចម្អិនហើយនៅតែដុះឡើងខ្លះទៀត មានសេចក្តីថា សណ្តែកបាយដែលស្ងោរហើយ បើសូម្បីដុះឡើងបាន សណ្តែកបាយទាំងនោះ ភិក្ខុគប្បីឆាន់បានតាមសប្បាយ ព្រោះថា សណ្តែកបាយទាំងនោះ នឹងជាកប្បិយពិត ព្រោះជារបស់ស្ងោរហើយ ។

[៩៧] បទថា អន្តោ វុត្ថំ : ទុកខាងក្នុង បានដល់ រក្សាទុកនៅក្នុងអកប្បិយកុដិ ។

វិនិច្ឆ័យក្នុងពាក្យថា សាមំ បក្កំ : ចម្អិនដោយខ្លួនឯង នេះគប្បីជ្រាបដូច្នេះ ៖

ភិក្ខុចម្អិនអាមិសឯណានីមួយដោយខ្លួនឯង មិនគួរ កម្តៅអាមិសដែលឆ្អិនហើយ គួរ ។

សូម្បីជនទាំងឡាយដាក់ស្លឹកជីក្តី ខ្ទឹក្តី អំបិលក្តី ចុះក្នុងបបរដែលក្តៅសម្រាប់ភិក្ខុនោះ ភិក្ខុនឹងកូរសូម្បីនូវបបរនោះ រមែងមិនគួរ តែនឹងកូរដោយគិតថា "នឹងឱ្យបបរត្រជាក់" គួរ សូម្បីបានបាយពងបង្អួយហើយនឹងគ្របទុក រមែងមិនគួរ ។ តែបើជនទាំងឡាយគ្របហើយប្រគេនមកនឹងគ្របទុក គួរ ឬនឹងគ្របទុកដោយគិតថា "បាយចូរកុំ

ត្រជាក់” គួរ ។

មួយទៀត ក្នុងទឹកដោះស្រស់ និងទឹកដោះជូរឡើងពពុះ ជាដើម ដែលគេស្ងោរក្តៅមួយជងហើយ ភិក្ខុនឹងបង្កាត់ភ្លើង គួរ ព្រោះការធ្វើឱ្យឆ្អិនទៀត ព្រះមានព្រះភាគទ្រង់អនុញ្ញាត ។

[៩៩] ពីរបទថា **ឧក្កបិណ្ឌកាបិ ខាទន្តិ** : ពួកសត្វតូច ៗ មានសេចក្តីថា ឆ្មា កណ្តុរ ទន្សោង និងស្ការ រមែងស៊ី ។

បទថា **ធមកា** : ពួកជនអ្នកស៊ីដែល បានដល់ អ្នកស៊ីដែល (ស៊ីសំណល់) ។

[១០១] ពីរបទថា **តតោ នីហដំ** : ដែលនាំមកអំពីទីនោះ បានដល់ ភោជនដែលទាយកនាំចេញអំពីទីដែលភិក្ខុទទួលនិមន្តឆាន់ ។

[១០៣] ពីរបទថា **វនដ្ឋំ បោក្ខរដ្ឋំ** : ដែលតាំងនៅក្នុងព្រៃ តាំងនៅក្នុងគុម្ពឈូក មានសេចក្តីថា កើតក្នុងព្រៃ និងក្នុងគុម្ពបទុម ។

[១០៤] បទថា **អពីជំ** : ផ្លែឈើដែលគ្មានពូជ បានដល់ ផ្លែឈើដែលនៅខ្ចី មានគ្រាប់មិនអាចនឹងដុះពន្លកបាន ។

បទថា **និព្វដ្ដពីជំ** : ផ្លែឈើដែលគួរបន្ទេចគ្រាប់ចេញបាន បានដល់ ផ្លែស្វាយនិងខ្នុរជាដើម ដែលនឹងគប្បីពន្ទេចគ្រាប់ចេញហើយឆាន់ ។

# ការវះកាត់ក្នុងទីចង្អៀតជាដើម

[១០៥] ពីរបទថា ទុរោបយោ វណោ : មានដំបៅសះបាន ដោយក្រ មានសេចក្ដីថា ដំបៅរមែងផុះលំបាក ; គឺថា សះស្បើយជាប្រក្រតីបានដោយលំបាក ។

ពីរបទថា ទុប្បរិហារំ សត្ថំ : កម្រមបុគ្គលនឹងយកកាំបិទទៅវះក្នុងទីចង្អៀតបាន មានសេចក្ដីថា ក្នុងទីចង្អៀត លំបាកនឹងប្រុងប្រយ័ត្នកាំបិត ។

ពីរបទថា សត្ថកម្មំ វា វត្ថិកម្មំ វា : ធ្វើសត្ថកម្ម ឬវត្ថិកម្ម មានសេចក្ដីថា ក្នុងឱកាសតាមដែលកំណត់ហើយ មិនគួរធ្វើការកាត់ ឬការវះ ឬការចោះ ឬការឆូត ដោយរបស់មានមុខឯណានីមួយ ជាកាំបិតក្ដី មូលក្ដី បន្ទាក្ដី លំពែងក្ដី អំបែងថ្មក្ដី ក្រចកក្ដី ព្រោះកម្មមានការកាត់ជាដើមទាំងអស់នោះ រមែងជាសត្ថកម្មពិត ។

មួយទៀត មិនគួរធ្វើសូម្បីនូវការចងរឹតក្បាលឫសដូងបាត ដោយរបស់ឯណានីមួយ ជាស្បែកក្ដី សំពត់ក្ដី ព្រោះការចងរឹតទាំងអស់នោះជាវត្ថិកម្មដូចគ្នា ។

ក៏ក្នុងព្រះបាលីនេះ ពាក្យថា ពីរធ្នាប់ដោយជុំវិញនៃទីចង្អៀតនេះ ត្រាស់សំដៅយកចំពោះសត្ថកម្ម ។ ចំណែកវត្ថិកម្ម ទ្រង់ហាមតែក្នុងទីចង្អៀតប៉ុណ្ណោះ ។ តែនឹងបន្តក់ទឹកក្បួងក្ដី នឹងចងរឹតដោយខ្សែយ៉ាងណា

មួយក្តី ត្រង់ឫសដូងបាតនោះ គួរ ។ បើឫសដូងបាតនោះ ដាច់ចេញ ដោយទឹកក្បួន ឬខ្សែនោះ ជាការដាច់ដោយល្អ ។
ទោះជារោគអណ្ឌៈធំ ក៏មិនគួរធ្វើសត្ថកម្ម ព្រោះហេតុនោះ មិនគួរ ធ្វើសត្ថកម្មដោយគិតថា យើងនឹងវះអណ្ឌៈ ក្រេះយកគ្រាប់ចេញធ្វើឱ្យជា រោគ ។ តែក្នុងការអាំងដោយភ្លើង និងលាបថ្នាំ មិនមានការហាម ។
ក្នុងទ្វារធ្ងន់ កន្ទោងស្លឹកឈើ និងបំពង់ឬស្សីដែលលាបថ្នាំហើយក្តី បំពង់ឫស្សីក្តី ដែលសម្រាប់បន្តក់ទឹកក្បួន និង ប្រេង មែងគួរ ។

# ពណ៌នាសាច់ដែលគួរនិងមិនគួរ

[១០៦] បទថា បវត្តមំសំ : សាច់សត្វដែលគេសម្លាប់ស្រាប់ បានដល់ សាច់របស់សត្វដែលស្លាប់ហើយនោះឯង ។
បទថា មាឃាតោ : គ្មានគេសម្លាប់សត្វ មានសេចក្តីថា ថ្ងៃ នោះ អ្នកណា ៗ មិនបានសម្លាប់នូវជីវិតសត្វណាមួយឡើយ ។
កាំបិតសម្រាប់កាត់សាច់ ហៅថា បោត្ថនិក : កាំបិត ។
បទថា កឹ បនិមាយ គប្បីកាត់ថា កិម្បិ ឥមាយ : ឧបាសិ កានេះ ... ដូចម្តេចបាន ។
ពាក្យថា ន ភគវា ឧស្សហាតិ : បពិត្រព្រះមានព្រះភាគ នាងសុប្បិយាមិនហ៊ាននឹងមកបានទេ មានសេចក្តីថា បពិត្រព្រះមានព្រះ

ភាគ ព្រះនាងមិនអាចទទឹងមកបាន ។

បទថា យត្រ ហិ ឆាម មានសេចក្ដីថា ឈ្មោះថា ព្រោះហេតុអ្វី ? (គ្រាន់តែព្រះអង្គទ្រង់បានទតឃើញមួយរំពេច ដំបៅដែលធំដល់ម៉្លោះក៏ដុះសាច់ស៊ះជាមានសម្បុរល្អមានរោមដុះពេញឡើងវិញ)

[១០៧] បទថា បដិវេក្ខិ : បានពិចារណាដែរឬទេ បានដល់ វីមំសិ ប្រែថា លោកពិចារណាហើយឬ មានពាក្យអធិប្បាយថា លោកសាកសួរហើយឬ ?

បទថា អប្បដិវេក្ខិត្វា : មិនបានពិចារណាទេ បានដល់ អប្បដិបុច្ឆិត្វា ប្រែថា មិនសាកសួរហើយ ។ ក៏បើភិក្ខុដឹងថា នេះជាសាច់ឈ្មោះឯណោះ កិច្ចដែលទទឹងសាកសួរ រមែងមិនមាន តែកាលមិនដឹង ត្រូវសួរជាមុនសិន សឹមឆាន់ ។

[១០៨] វិនិច្ឆ័យក្នុងពាក្យថា សុនខមំសំ : សាច់ឆ្កែ នេះគប្បីជ្រាបដូច្នេះ ៖

ឆ្កែព្រៃ រមែងដូចជាឆ្កែស្រុក ។ សាច់ឆ្កែព្រៃនោះគួរ ។ (១)

ចំណែកឆ្កែណា កើតពីមេឆ្កែស្រុកទទឹងបាឆ្កែព្រៃផ្សំគ្នា ឬដោយមេឆ្កែព្រៃជាមួយទទឹងបាឆ្កែស្រុកផ្សំគ្នា សាច់របស់ឆ្កែនោះ មិនគួរ, ព្រោះ

---

១. ពាក្យថា តរច្ឆំ : ខ្លារខិន តែបិដកខ្មែរប្រែខុសថា ឆ្កែព្រៃ; អដ្ឋកថា អរញ្ញកោកា : ឆ្កែព្រៃ ។

ឆ្កែនោះ ដល់នូវការរាប់បញ្ចូលថា ជាឆ្កែទាំងពីរប្រភេទ ។

បទថា **អហិមំសំ : សាច់ពស់** មានសេចក្ដីថា សាច់នៃទីឃជាតិដែលមិនមានជើងប្រភេទណាមួយ មិនគួរ ។ សាច់រាជសីហ៍ជាដើមជារបស់ជាក់ច្បាស់ហើយទាំងអស់នោះ ។

ក៏បណ្ដាអកប្បិយមំសៈទាំងនោះ សាច់មនុស្ស ដែលព្រះមានព្រះភាគទ្រង់ហាម ក៏ព្រោះមនុស្សមានជាតិដូចខ្លួន សាច់ដំរី និងសេះ ដែលទ្រង់ហាមក៏ព្រោះ ជារាជពាហនៈ សាច់ឆ្កែ និងសាច់ពស់ដែលទ្រង់ហាម ក៏ព្រោះជារបស់ស្មោគគ្រោក, សាច់ ៥ យ៉ាង មានរាជសីហ៍ជាដើម ដែលទ្រង់ហាម ក៏ដើម្បីត្រូវការ សេចក្ដីមិនមានអន្តរាយដល់ខ្លួន ដូច្នេះឯង ។

សាច់ក្ដី ឆ្អឹងក្ដី ឈាមក្ដី ស្បែកក្ដី រោមក្ដី នៃសត្វ ១០ ប្រភេទ មានមនុស្សជាដើមទាំងនេះ មិនគួរទាំងអស់ ដោយប្រការដូច្នេះ ។

កាលភិក្ខុដឹងក្ដី មិនដឹងក្ដី ឆាន់សាច់ឯណានីមួយ គង់ជាអាបត្តិពិត ដឹងកាលណា គប្បីសម្ដែងកាលនោះ ។ មិនសួរមុន ទទួលដោយតាំងចិត្តថា "យើងនឹងឆាន់" ត្រូវទុក្កដ សូម្បីព្រោះទទួល ។ ទទួលដោយតាំងចិត្តថា នឹងសួរមុនទើបឆាន់ មិនជាអាបត្តិ ។

មួយទៀត ជាអាបត្តិដល់ភិក្ខុដែលដឹងហើយឆាន់សាច់ដែលជាឧទ្ទិស្សមំសៈ លោកដឹងជាខាងក្រោយ មិនគួរពិន័យ អាបត្តិ ។

# ពណិយាគូជាដើម

[១០៩] បទថា ឯកកោ[១] : តែម្នាក់ឯង មានសេចក្តីថា យើងមិនមានសម្លាញ់ជាគម្រប់ពីរ ។

ពាក្យថា បហូតំ យាគុញ្ច មធុគោឡកញ្ច បដិយាទាបេត្វា : តាក់តែងបបរនិងនំមានរសផ្អែមជាច្រើន ក៏បង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគហើយ មានសេចក្តីថា បានឮថា ព្រាហ្មណ៍នោះ ឱ្យតាក់តែងយាគូជាដើម ប្រើឱ្យគេចាត់ចែងទ្រព្យអស់ទៅមួយសែន ។

[១១០] ក្នុងទីបំផុតនៃអនុមោទនាគាថា គប្បីធ្វើការភ្ជាប់នឹងបទថា បត្ថយតំ : ប្រាថ្នា, ឥច្ឆតំ : ចង់បាន, ដោយពាក្យថា អលមេវ ទាតុំ : គួរឱ្យពិត នេះ រួបរួមសេចក្តីប្រែថា ក្នុងការឱ្យដល់បដិគ្គាហកទាំងឡាយ ដែលប្រាថ្នាចង់បាន ជាការគួរពិត ។

ក៏បើ បាឋៈថា បត្ថយតា ឥច្ឆតា មាននៅសោត បាឋៈនោះឯងគប្បីកាន់យក ។

[១១២] បទថា ភោជ្ជយាគុំ : បបរភោជ្ជ បានដល់ យាគូដែលញ៉ាំង ការឃ្លានឱ្យកើត ។

បទថា យេនគ្គេន : ដោយចំណែកណា មានសេចក្តីថា ធ្វើ

១. ភូមា. ឯកត្តកោ ។

យាគូណាឱ្យជាដើម ។

ច្រើនបទថា សគ្គា តេ អារទ្ធា : ឈ្មោះថា អ្នកឯងប្រារព្ធយកបានសួគ៌ហើយ មានសេចក្តីថា បុណ្យជាហេតុឱ្យកើតក្នុងសួគ, លោកបានសន្សំហើយ ។

ពីរបទថា យថាធម្មោ ការេតព្វោ : ត្រូវវិន័យធរឱ្យភិក្ខុនោះធ្វើតាមធម៌ (គឺឱ្យសម្តែងអាបត្តិចេញ) មានសេចក្តីថា ភិក្ខុនោះ គប្បីឱ្យធ្វើតាមធម៌ ដោយបរម្បរភោជនសិក្ខាបទ ព្រោះថា ការហាម (ភោជន) រមែងមាន ព្រោះយាគូដែលគួរឆាន់ ។

[១១៣] ពីរបទថា ឆាហន្តំ កច្ចាន : ម្នាលកច្ចានតថាគតមិនដែល មានសេចក្តីថា បានឮថា ទេវតាទាំងឡាយថែមឱជៈដ៏ល្អិត ចុះក្នុងស្ករអំពៅ ដ៏សេសនោះ ស្ករអំពៅដ៏សេសនោះ រមែងមិនរលាយទៅបាន សម្រាប់ជនពួកដទៃ; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។

[១១៤] បទថា គិលានស្ស គុឡំ : ស្ករអំពៅដល់ភិក្ខុអាពាធ មានសេចក្តីថា តថាគតអនុញ្ញាតស្ករអំពៅខាងក្រោយភត្ត ដល់ភិក្ខុដែលអាពាធ ដោយរោគបែបនោះ ។

[១១៥] បទថា សព្វសន្ថរឹ : គ្រឿងកម្រាលសព្វគ្រប់ មាន

សេចក្តីថា អាវសថាគារ (ផ្ទះជាទីនៅសម្រាក) ទីងជាស្ថានដែលក្រាល សព្វកន្លែង ដោយប្រការណា បានក្រាលហើយដោយប្រការនោះ ។

[១១៩] បទថា សុនីធវស្សការា : សុនីធៈវស្សការៈ បាន ដល់ ព្រាហ្មណ៍ ២ នាក់ គឺ សុនីធៈ ១ វស្សការៈ ១ ជាមហាអាមាត្យ របស់ព្រះបាទមគធ ។[១]

ពីរបទថា វជ្ជីនំ បដិពាហាយ : ដើម្បីការពារពួករាជត្រកូល ក្នុងដែនវជ្ជី សេចក្តីថា ដើម្បីត្រូវការកាត់មកចម្រើននៃរាជត្រកូលដែន វជ្ជីចេញ ។

បទថា វត្ថូនិ : ទីកន្លែង បានដល់ ទីសាងផ្ទះ ។

ច្រើនបទថា ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ : បង្អោន ចិត្តទៅដើម្បីនឹងសាងលំនៅ មានសេចក្តីថា បានឮថា ទេវតាទាំងនោះ ចូលស្ថិតនៅក្នុងសរីរៈ របស់ជនទាំងឡាយ អ្នកដឹងទំនាយជ័យភូមិ ហើយ បង្អោនចិត្តទៅយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះទេវតាទាំងឡាយនោះ នឹងធ្វើសក្ការៈតាមសមគួរ ដល់យើងទាំងឡាយ ។

១. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ៨២/១៨៧ មានសេចក្តីពិស្តារ ។

បទថា តាវតឹសេហិ : ក្នុងស្ថានតាវត្តិង្ស មានសេចក្តីថា បានឮថា សំឡេងដែលថា "បណ្ឌិតទាំងឡាយក្នុងជាន់តាវត្តិង្ស" សំដៅយកស្តេចសក្កទេវរាជ និងព្រះវិស្សុកម្មខ្វរខ្វាយទៅក្នុងលោក ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា តាវតឹសេហិ ។ អធិប្បាយថា សុនីធអាមាត្យ និងវស្សការអាមាត្យនោះ ហាក់ដូចជាបានប្រឹក្សាទេវតាជាន់តាវត្តិង្សហើយ ទើបបានសាង ។

បទថា យាវតា អរិយានំ អាយតនំ : ទីប្រជុំរបស់ព្រះអរិយបុគ្គលទាំងឡាយដែលមានទាំងអម្បាលមាណ មានសេចក្តីថា ឈ្មោះថា ស្ថានជាទីប្រជុំនៃមនុស្សជាអរិយៈទាំងឡាយ មានទំហំប៉ុនណា ។

បទថា យាវតា វណិជ្ជបថោ : មកឈ្នួញដែលមានទាំងអម្បាលមាណ មានសេចក្តីថា ឈ្មោះថា ស្ថានជាទីទិញនិងលក់ ដោយអំណាចនៃទំនិញទាំងឡាយដែលនាំមកហើយនោះឯង របស់ឈ្នួញទាំងឡាយ មានទំហំប៉ុនណា ។

ពីរបទថា ឥទំ អគ្គនគរំ : នេះ ក៏ជាក្រុងប្រសើរជាង មានសេចក្តីថា ក្រុងបាដលីបុត្តដែលជាដែននៃព្រះអរិយៈ ជាស្ថាននៃការជំនួញលក់របស់មនុស្ស ទាំងនោះ នេះនឹងជាក្រុងកំពូល ។

បទថា បុដភេទនំ : ជាទីកន្លែងបែកធ្លាយឬរបូតបង្វេចទ្រព្យ បានដល់ ជាស្ថានទីស្រាយកញ្ចប់ទំនិញ ។ មានពាក្យអធិប្បាយថា នឹង

ជាស្ថានទីស្រោយនូវចំណងទំនិញទាំងឡាយ ។

វិនិច្ឆ័យបទថា អគ្គិតោ វា : អន្តរាយអំពីភ្លើង ១ ជាដើម គប្បីជ្រាបដូច្នេះ ៖

វា សទ្ទ ប្រើក្នុងសមុច្ចយត្ថៈ ពិតមែន បណ្តាចំណែកទាំងនោះ អន្តរាយនឹងមានដល់ចំណែកមួយអំពីភ្លើង, ដល់ចំណែកមួយអំពីទឹក, ដល់ចំណែកមួយ អំពីខាងក្នុងគឺ សេចក្តីបែកខ្ញែកនៃគ្នានិងគ្នា ។

[១២២] បទថា ឧឡុម្បំ : ផែ បានដល់ ជលពាហនៈដែលគេធ្វើស្នៀតសៀត ដើម្បីប្រយោជន៍ដល់ការឆ្លងទៅត្រើយម្ខាង ។

បទថា កុល្លំ : ក្បូន បានដល់ ជលពាហនៈដែលគេធ្វើចងរឹត ដោយវល្លិ៍ជាដើម ។

ពាក្យថា អណ្ណវំ : សមុទ្រ(ដ៏ជ្រៅឆ្ងាយទូលាយ) នេះ ជាឈ្មោះរបស់ឧទកស្ថាន ទាំងជម្រៅនិងទំហំ ប្រហែលមួយយោជន៍ ដោយកំណត់យ៉ាងទាបបំផុតនៃកំណត់ទាំងពួង ។

ស្ទឹង ព្រះមានព្រះភាគទ្រង់ប្រាថ្នាក្នុងបទថា សរំ នេះ ។ មានពាក្យអធិប្បាយថា ជនពួកណាឆ្លងស្ទឹង គឺ តណ្ហាដ៏ជ្រៅនិងធំទូលាយ (ពួកជននោះឯង) តែងធ្វើស្ពាន ពោលគឺ អរិយមគ្គ មិនឱ្យប៉ះពាល់ទីជាទំនាបទាំងឡាយ ហើយឆ្លងបាន, សេចក្តីពិតថា ជនធម្មតា (ដែលប្រាថ្នានឹងឆ្លងទឹកបន្តិចបន្តួច តែងចងក្បូន (ទើបឆ្លងទៅបាន),

ឯជនជាអ្នកប្រាជ្ញទាំងឡាយ គឺព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធ លោកបានឆ្លងរួចហើយ ។

[១២៣] បទថា អននុពោធា គឺ អពុជ្ឈនេន : ព្រោះបានមិនត្រាស់ដឹង ។

បទថា សន្ធាវិតំ : ត្រាច់រង្គត់ទៅ មានសេចក្ដីថា ត្រាច់ទៅហើយ ដោយអំណាចដែលចេញចាកភពទៅកាន់ភព ។

បទថា សំសរិតំ : អន្ទោលទៅ មានសេចក្ដីថា អន្ទោលទៅហើយ ដោយអំណាចការទៅរឿយ ៗ ។

ពីរបទថា មមញ្ចេវ តុម្ហាកញ្ច : តថាគតក្ដី អ្នកទាំងឡាយក្ដី គឺ តថាគតផង អ្នកទាំងឡាយផង ។ ម្យ៉ាងទៀត គប្បីឃើញសេចក្ដីក្នុងពាក្យថា សន្ធាវិតំ សំសរិតំ នេះ យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី អន្ទោលទៅ និងត្រាច់រង្គត់ទៅកាន់មកឆ្ងាយយ៉ាងនេះ" ។

[១២៤] បទថា សំសិតំ បានដល់ សំសរិតំ : ការអន្ទោលទៅ ។

ពីរបទថា ភវនេត្តិ សមូហតា : តណ្ហាជាអ្នកនាំទៅកាន់ភព ក៏តថាគតនិងអ្នកទាំងឡាយ មានសេចក្ដីថា ខ្សែគឺ តណ្ហាជាហេតុទៅ គឺត្រាច់អំពីភពមួយ (ទៅកាន់ភពមួយ) ដែលយើងទាំងឡាយកម្ចាត់ គឺកាត់ បានដល់ ធ្វើឱ្យប្រព្រឹត្តទៅមិនបានដោយល្អហើយ ។

# រឿងស្តេចលិច្ឆវី

[១២៥] ពាក្យថា ខៀវ នេះ ជាពាក្យប្រមូលយកចំណែកទាំងពួងចូលផង ។

បទថា នីលវណ្ណា : មានសម្បុរខៀវ ជាដើម លោកពោលដើម្បីសម្តែងវិភាគនៃពាក្យថា ខៀវនោះឯង ។ ក្នុងបណ្តាពណ៌ទាំងនោះ ពណ៌ខៀវជាពណ៌ប្រក្រតីរបស់ស្តេចលិច្ឆវីទាំងនោះ ក៏ទេ, ពាក្យថា ខៀវ នោះ លោកពោលដោយអំណាចនៃគ្រឿងលាបពណ៌ខៀវជារបស់ស្រស់ល្អ ។

បទថា បដិវត្តេសិ[១] : បំប៉ះ បានដល់ បហារេសិ : ប៉ះទង្គិច ។

ពីរបទថា សាហារំ ទជ្ជយ្យាថ : ប្រទាន...ព្រមទាំងសួយសារអាករដែលមាននៅក្នុងជនបទ មានសេចក្តីថា គប្បីប្រទានក្រុងវេសាលី និងជនបទ ។

ពីរបទថា អង្គុលឹ ផោដេសុំ : ទះម្រាមព្រះហស្ត មានសេចក្តីថា ទ្រង់បានទះម្រាមព្រះហស្ត[២] ។

បទថា អម្ពកាយ[៣] : មាតុគ្រាម បានដល់ ឥត្ថិកាយ : ស្រី ។

បទថា ឱលោកេថ : អ្នកទាំងឡាយ ចូរមើលមើល គឺ ចូរឃើញ ។

---

១. ថៃ. ភូមា. បដិវដ្ដេសិ ។ ២. ទះតែម្រាមនឹងម្រាម ។ ៣. ស្រីកើតលើដើមស្វាយ ។

បទថា អបលោកេថ : អ្នកទាំងឡាយ ចូរមិលមើលរឿយ ៗ គឺ ចូរឃើញរឿយ ៗ ។

បទថា ឧបសំហរថ : អ្នកទាំងឡាយ ចូរប្រៀបធៀប បានដល់ ចូរប្រៀបប្រដូច អធិប្បាយថា ចូរនាំលិច្ឆវីបរិស័ទនេះទៅ ប្រៀបធៀបនឹងបរិស័ទនៃទេវតាជាន់តាវត្តិង្ស ដោយចិត្តរបស់លោកទាំងឡាយ គឺថា ចូរមើលធ្វើឱ្យសមគ្នាដល់ទេវតាជាន់តាវត្តិង្ស ។

## ពណ៌នាឧទ្ទិស្សមំសៈ

[១២៦] ពាក្យថា ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ : ដ្បិតព្រះអង្គតែងពោលជាក់ច្បាស់នូវធម៌សមគួរដល់ធម៌ មានសេចក្ដីថា ជនពួកនោះ រមែងពោលហេតុសមគួរដល់ហេតុដែលព្រះមានព្រះភាគត្រាស់ហើយឯងឬ ?

ពីរបទថា សហធម្មិកោ វាទានុវាទោ : សហធម្មិកបាននិយាយត្រូវតាមព្រះពុទ្ធដីកាដែលព្រះអង្គបានពោល មានសេចក្ដីថា ក៏វាទៈរបស់ព្រះអង្គជាហេតុដែលជនពួកដទៃពោលហើយ យ៉ាងណាមួយ គឺ សូម្បីមានប្រមាណតិច មិនមកដល់ហេតុដែលវិញ្ញូជននឹងគប្បីតិះដៀលឬ ? មានពាក្យអធិប្បាយថា វាទៈជាប្រធានរបស់ព្រះអង្គ ដែលជាហេតុគួរតិះ

ជៀលមិនមាន សូម្បីដោយហេតុទាំងពួងឬ ?

បទថា អនព្ភក្ខាតុកាមា : មិនចង់ពោលបង្អាច់ មានសេចក្តីថា ខ្ញុំព្រះករុណា មិនមានប្រាថ្នានឹងពោលគ្រប់សង្កត់ ។

[១២៨] បទថា អនុវិច្ចការំ : អ្នកឯងចូរធ្វើការគិតសញ្ជឹងមើលសិន មានពាក្យអធិប្បាយថា លោកចូរធ្វើការដើងតាម គឺគិតពិចារណាហើយសិន សឹមធ្វើ ។

បទថា ញាតមនុស្សានំ : របស់មនុស្សជាអ្នកដឹងទាំងឡាយបានដល់ (មនុស្ស) អ្នកមានកិត្តិស័ព្ទក្នុងលោក ។

ពីរបទថា សាធុ ហោតិ : ជាការប្រពៃ មានសេចក្តីថា ទើងជាសេចក្តីល្អ ។

ពីរបទថា បដាកំ បរិហរេយ្យុំ : មុខជាគេលើកទង់ជុំវិញ មានសេចក្តីថា តិរ្ថិយទាំងឡាយ គប្បីលើកទង់ផ្ទាំងសំពត់ ត្រាច់ស្រែកប្រកាសក្នុងព្រះនគរ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះពួកគេគិតថា ភាពជាធំទើងមានដល់ពួកយើងដោយឧបាយយ៉ាងនេះ ។

បទថា ឱបានភូតំ : ជាអណ្តូងបម្រុង មានសេចក្តីថា (ត្រកូលរបស់លោក) តែងទុកហើយ គឺត្រៀមទុកហើយដូចជាអណ្តូងទឹក ។

បទថា កុលំ : ត្រកូល បានដល់ និវេសន៍ ។

ពីរបទថា ធាតព្វំ មញ្ញេយ្យាសិ : ជាអ្នកសម្គាល់ថា បានអ្នកណានឹងឱ្យ មានសេចក្ដីថា ព្រះមានព្រះភាគទ្រង់ជាស់តឿនថា “អ្នកកុំកាត់ទេយ្យធម៌របស់និគ្រន្ថទាំងនេះឱ្យខូចឡើយ តែអ្នកគប្បីសម្គាល់នូវទេយ្យធម៌ ដែលខ្លួនគួរឱ្យដល់និគ្រន្ថទាំងនោះ ដែលមកដល់ហើយ” ។

បទថា ឱកាភោ គឺ អវកាភោ : ការធ្វើឱ្យទាប បានដល់ ជារបស់លាមក ។

បទថា សាមុក្កំសិកា : តែងលើកឡើងសម្ដែងដោយព្រះអង្គឯង បានដល់ (ធម្មទេសនា) ដែលព្រះអង្គទ្រង់លើកឡើង អធិប្បាយថា មិនទូទៅដល់ព្រះសាវកពួកដទៃ ។

បទថា ឧទ្දិស្ស កតំ : ធ្វើចំពោះខ្លួន បានដល់ មំសៈដែលគេធ្វើចំពោះខ្លួន ។

បទថា បដិច្ចកម្មំ : ធ្វើបម្រុង មានសេចក្ដីថា មំសៈដែលគេធ្វើព្រោះអាស្រ័យខ្លួន ។ ម្យ៉ាងទៀត ពាក្យថា បដិច្ចកម្មនេះ ជាឈ្មោះរបស់និមិត្តកម្ម ។ សូម្បីមំសៈ លោកហៅថា បដិច្ចកម្ម ក៏ព្រោះហេតុថា ក្នុងមំសៈនេះ មានបដិច្ចកម្មនោះ ។ ពិតមែន អ្នកណា បរិភោគមំសៈ មានសភាពបែបនោះ, អ្នកនោះ រមែងជាអ្នកទទួល ផលនៃកម្មនោះ អធិប្បាយថា កម្ម គឺ ការសម្លាប់សត្វ រមែងមានដល់អ្នក

(បរិភោគ)នោះ ដូចមានដល់អ្នកសម្លាប់អ៊ីចឹងដែរ ។

បទថា ន គិរន្តិ[១] : មិនអស់មិនហើយឡើយ មានសេចក្តីថា លោកដ៏មានអាយុទាំងនោះ កាលពោលបន្ទាប់(បន្តុចឈ្មោះ) រមែងមិនស្រាកស្រានទៅ អធិប្បាយថា រមែងមិនមានទីបំផុតនៃការពោលបន្ទាប់ ។ កថាសម្ដែងមំសៈមានសេចក្តីបរិសុទ្ធិដោយចំណែកបី បានពោលទុកហើយក្នុងអដ្ឋកថានៃសង្ឃភេទសិក្ខាបទ[២] ។

## ពណ៌នាកប្បិយភូមិ

[១៣០] បទថា សកដបរិវដ្តំ[៣] : បង្វិលរទេះ មានសេចក្តីថា សម្រាកដូចជាធ្វើឱ្យហែហមដោយរទេះទាំងឡាយ ។

បទថា បច្ចន្តិមំ : ចុងក្រោយគេ នេះ ត្រឹមតែជាព្រះតម្រាស់ប៉ុន្តែថា ទោះបីវិហារជិត ក៏គួរនឹងសន្មតបាន ព្រោះព្រះបាលីដែលត្រាស់ទុកថា "យំ សង្ឃោ អាកង្ខតិ : បើសង្ឃប្រាថ្នានៅទីណា" សូម្បីនឹងមិនសូធ្យកម្មវាចា សូម្បីធ្វើដោយអបលោកន៍ជំនួស ក៏គួរដូចគ្នា ។

បទថា គាវោរវសទ្ទំ : សំឡេងគឹកកង បានដល់ សំឡេង

---

១. ថៃ. ជីរន្តិ; ភូមា. ជិរិទន្តិ ។ ២. សមន្ត. សង្ឃា. សង្ឃភេទសិក្ខាបទ. ៣. ២៩០/១៩៩ ។ ៣. ថៃ. សកដបរិវត្តកំ; ភូមា. សកដបរិវដ្តំ; បិដកខ្មែរ. សកដបរិវត្តំ ។

ស្រែកខ្សៀវខ្វានៃក្អែកទាំងឡាយដែលប្រជុំគ្នា ពេលព្រឹកព្រលឹមតែម្តង ដើម្បីត្រូវការនឹងស៊ីចំណីដែលគេចោលហើយក្នុងទីនោះ ៗ ។ ព្រះថេរៈឈ្មោះយសោជៈ ជាបុរសកំពូលលើសនៃបព្វជិតប្រាំរយ ក្នុងវេលាចប់កបិលសូត្រ ។

វិនិច្ឆ័យក្នុងបទថា ឧស្សាវនន្តិកាំ ជាដើម គប្បីជ្រាបដូច្នេះ ៖

កប្បិយភូមិ ឈ្មោះឧស្សាវនន្តិកា គប្បីធ្វើមុនយ៉ាងនេះ ទីណា គេតម្កល់លើសសរឬក្នុងជើងជញ្ជាំង ឬដែលទ្រសសរខាងក្រោមនោះ ទីនោះ មានគតិដូចផែនដីដែរ ។

ក៏កាលនឹងឱ្យតាំងសសរជាដំបូង ឬជើងជញ្ជាំងជាដំបូង ភិក្ខុច្រើនរូបគប្បីឈរព័ទ្ធជុំវិញ បញ្ចេញវាចាថា កប្បិយកុដឹ ករោមៈ យើងធ្វើកប្បិយកុដិ កាលមនុស្សទាំងឡាយ លើកដាក់ឱ្យតម្កល់ចុះ គប្បីចាប់ឬលើកដោយខ្លួនឯងក៏បាន ឱ្យតាំងសសរឬជើងជញ្ជាំង ។

ចំណែកក្នុងកុរុន្ទីនិងមហាបច្ចរី លោកពន្យល់ថា ភិក្ខុទាំងឡាយគប្បីឱ្យតាំងចុះពោលថា "កប្បិយកុដិ កប្បិយកុដិ" ។

ក្នុងអន្ធកដ្ឋកថាពន្យល់ថា គប្បីពោលថា សង្ឃស្ស កប្បិយកុដឹ អធិដ្ឋាមិ ប្រែថា ខ្ញុំព្រះករុណាអធិដ្ឋានកប្បិយកុដិដើម្បីសង្ឃ ។ តែសូម្បីនឹងមិនពោលពាក្យនោះ រមែងមិនមានទោស ព្រោះពាក្យដែលពោលហើយ តាមន័យដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយប៉ុណ្ណោះ ។

តែក្នុងអធិការពោលអំពី ការធ្វើកប្បិយភូមិ ឈ្មោះ ឧស្សាវនន្តិកានេះ មានលក្ខណៈដែលទូទៅដូច្នេះ ខណៈដែលសសរតាំងចុះ និងខណៈដែលចប់ពាក្យ ជាវេលាព្រមគ្នា ប្រើបាន ។ តែបើកាលពាក្យមិនទាន់ចប់ សសរតាំងចុះមុន ឬកាលសសរនោះ មិនទាន់តាំងចុះ ពាក្យចប់មុន ។ កប្បិយកុដិ មិនឈ្មោះថា បានធ្វើ ។ ព្រោះហេតុនោះឯង ក្នុងមហាបច្ចរី លោកទើបពន្យល់ថា ភិក្ខុច្រើនអង្គជាមួយគ្នា គប្បីឈរព័ទ្ធជុំវិញ ហើយពោល ។ ព្រោះថា ការចប់ពាក្យ និងការតាំងចុះនៃសសររបស់ភិក្ខុមួយរូប ក្នុងភិក្ខុទាំងនេះ ទឹងមានព្រមគ្នាបាន ដោយពិត ក៏ក្នុងកុដិទាំងឡាយដែលមានជញ្ជាំងរៀបដោយឥដ្ឋ ថ្ម ឬជីខាងក្រោមកប្បិយកុដិ ទឹងពូនឡើងក៏ដោយ មិនពូនក៏ដោយ ភិក្ខុទាំងឡាយប្រាថ្នានឹងឱ្យតាំងជញ្ជាំងឡើងតាំងពីឥដ្ឋ ឬថ្ម ឬដុំដីយ៉ាងណា គប្បីកាន់យកឥដ្ឋ ឬថ្ម ឬដុំដីយ៉ាងនោះ មុនទីដទៃទាំងអស់ ធ្វើកប្បិយកុដិតាមន័យដែលពោលហើយនុ៎ះឯង តែឥដ្ឋជាដើមដែលរៀបឡើង លើផែនដី ខាងក្រោមនៃឥដ្ឋដុំដំបូងជាដើមនៃជញ្ជាំង មិនគួរ ។ ចំណែកសសរ រមែងឡើងខាងលើ ព្រោះហេតុនោះ សសរ ទើបគួរ ។

ក្នុងអន្ធកដ្ឋកថាពន្យល់ថា ពិតមែន កាលប្រើសសរ គប្បីអធិដ្ឋានសសរ ៤ ដើម ត្រង់មុំ ៤ កាលប្រើជញ្ជាំងដែលរៀប ឥដ្ឋជាដើម គប្បីអធិដ្ឋានឥដ្ឋ ២, ៣ ដុំ ត្រង់មុំទាំង ៤ ។ តែសូម្បីកប្បិយកុ

ដិដែលមិនធ្វើយ៉ាងនោះ ក៏មិនមានទោស ព្រោះថា ពាក្យដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយប៉ុណ្ណោះ រមែងជាប្រមាណ ។

កប្បិយកុដិ ឈ្មោះ គោនិសាទិកា មាន ២ យ៉ាង គឺ អារាមគោនិសាទិកា ១ វិហារគោនិសាទិកា ១ ។ ក្នុង២ យ៉ាង នោះ ក្នុងវត្តណាអារាមក៏មិនមានរបង សេនាសនៈទាំងឡាយ ក៏មិនមានរបង វត្តនេះឈ្មោះអារាមគោនិសាទិកា, ក្នុងវត្តណា សេនាសនៈមានរបងទាំងអស់ ឬមានរបងខ្លះ ចំណែកអារាមមិនមានរបង វត្តនេះ ឈ្មោះវិហារគោនិសាទិកា ។ ភាវៈដែលអារាមមិនមានរបងនុ៎ះឯង ជាប្រមាណក្នុងគោនិសាទិកាទាំង ២ យ៉ាង ដោយប្រការដូច្នេះ ។

តែក្នុងកុរុន្ទីនិងមហាបច្ចរីពោលថា អារាមដែលមានរបងពាក់កណ្ដាលក្ដី មានរបងច្រើនជាងពាក់កណ្ដាលក្ដី ចាត់ជាអារាមដែលមានរបងបាន ។ ក្នុងអារាមដែលមានរបងពាក់កណ្ដាលជាដើមនេះ គួរនឹងបានកប្បិយកុដិ ។

បទថា **គហបតិ (ជនជាម្ចាស់ផ្ទះ)** មានសេចក្ដីថា ជនទាំងឡាយធ្វើអាវាស ហើយពោលថា "ខ្ញុំព្រះករុណាប្រគេនកប្បិយកុដិ សូមលោកប្រើប្រាស់ចុះ" កប្បិយកុដិនេះ ឈ្មោះថា គហបតី ។ សូម្បីគេពោលថា "ខ្ញុំព្រះករុណាប្រគេនដើម្បីធ្វើកប្បិយកុដិ" ដូច្នេះ រមែងគួរដូចគ្នា ។ ចំណែកក្នុងអន្ធកដ្ឋកថាពោលថា របស់ដែលទទួលអំពីដៃនៃ

សហធម្មិកដ៏សេស វៀរភិក្ខុចេញ និងរបស់ទេវតានិងមនុស្សទាំងពួង របស់ជាសន្និធិ និងរបស់ដែលរក្សាទុក ខាងក្នុងជារបស់នៃសហធម្មិកដ៏សេស និងរបស់ទេវតា មនុស្សទាំងនោះ រមែងគួរដល់ភិក្ខុ ព្រោះហេតុនោះ កុដិនៃសហធម្មិកទាំងនោះ ឬកប្បិយកុដិដែលសហធម្មិកទាំងនោះប្រគេន ទើបហៅថា គហបតី ។ មិនមែន តែប៉ុណ្ណោះទេ លោកពោលទៀតថា "វៀរកុដិរបស់ភិក្ខុសង្ឃចេញ ទីនៅរបស់ពួកភិក្ខុនីក្តី របស់ពួកអារាមិកបុរសក្តី របស់ពួកតិរ្ថិយក្តី របស់ពួកទេវតាក្តី របស់ពួកនាគក្តី ឬសូម្បីវិមាននៃពួកព្រហ្ម រមែងជាកប្បិយកុដិបាន" ពាក្យនោះលោកពោលប្រពៃ ព្រោះថា កុដិជារបស់សង្ឃតែម្យ៉ាងក្តី ជារបស់ភិក្ខុក្តី ជាកុដិរបស់គហបតីមិនបាន ។

កប្បិយកុដិ ដែលភិក្ខុសូធ្យប្រកាស ធ្វើដោយកម្មវាចា ឈ្មោះ សម្មតិកា ដូច្នេះឯង ។

អាមិសណា រក្សាទុកនៅក្នុងកប្បិយភូមិទាំង ៤ នេះ អាមិសទាំងអស់នោះ មិនរាប់ថា អន្តោវុត្ថៈ ព្រោះថា កប្បិយកុដិ ព្រះមានព្រះភាគទ្រង់អនុញ្ញាត ដើម្បីដោះឱ្យផុតពីអន្តោវុត្ថៈ និងអន្តោបក្កៈរបស់ភិក្ខុនិងភិក្ខុនីទាំងឡាយ ចំណែកអាមិសណា ជារបស់សង្ឃក្តី ជារបស់បុគ្គលក្តី ជារបស់ភិក្ខុ ឬភិក្ខុនីក្តី ដែលរក្សាទុកក្នុងកុដិដែលល្មមនឹងជាអាបត្តិព្រោះសហសេយ្យបាន ក្នុងអកប្បិយភូមិ រក្សាទុកសូម្បីតែមួយរាត្រី

អាមិសនោះជាអន្តោវុត្ថៈ និងអាមិសដែលចម្អិនក្នុងកុដិនោះ រមែងចាត់ជាអន្តោបក្កៈ អាមិសនោះ មិនគួរ ។ តែរបស់ដែលជាសត្តាហកាលិកនិងយាវជីវិក គួរ ។

វិនិច្ឆ័យក្នុងអន្តោវុត្ថៈនិងអន្តោបក្កៈនោះ គប្បីជ្រាបដូច្នេះ ៖

សាមណេរនាំអាមិសមានអង្ករជាដើម របស់ភិក្ខុមករក្សាទុកក្នុងកប្បិយកុដិ ព្រឹកឡើងដាំប្រគេន អាមិសនោះ មិនជាអន្តោវុត្ថៈ ។

សាមណេរយករបស់ណាមួយ មានទឹកដោះថ្លាជាដើមដែលរក្សាទុកក្នុងអកប្បិយកុដិដាក់ចូលក្នុងអាមិស មានបាយជាដើមនោះប្រគេន អាមិសនោះចាត់ជាមុខសន្និធិ ។ តែក្នុងមហាបច្ចរីពោលថា អាមិសនោះជាអន្តោវុត្ថៈ ។ ការធ្វើផ្សេងគ្នាក្នុងមុខ សន្និធិ និងអន្តោវុត្ថៈនោះ ក៏ត្រឹមតែឈ្មោះប៉ុណ្ណោះ ។

ភិក្ខុយកទឹកដោះថ្លាដែលរក្សាទុកក្នុងអកប្បិយកុដិ និងបន្លែដែលជាយាវជីវិក ដាក់ចូលជាមួយគ្នាហើយឆាន់ បន្លែនោះជារបស់ប្រាសចាកអាមិស គួរឆាន់បាន ៧ ថ្ងៃ ។ បើភិក្ខុឆាន់លាយ នឹងអាមិស បន្លែនោះជាអន្តោវុត្ថៈផង ជាសាមបក្កៈផង ។ ការលាយគ្នានៃកាលិកគ្រប់យ៉ាងគប្បីជ្រាបដោយឧបាយនេះ ។

សួរថា ក៏កប្បិយកុដិទាំងនេះ កាលណានឹងលះវត្ថុហ្ន៎ ?

ឆ្លើយថា គួរជ្រាបឧស្សាវនន្តិកាជាមុន កប្បិយកុដិណាដែលគេ

តម្កល់លើសសរ ឬក្នុងជើងជញ្ជាំងចុះ, កប្បិយកុដិនោះ ទឹងលះវត្ថុក្នុងកាលរុះរើសសរ និងជើងជញ្ជាំងទាំងពួង ចេញហើយ ។ តែបើជនទាំងឡាយផ្លាស់សសរ ឬជើងជញ្ជាំងចេញ សសរឬជើងជញ្ជាំងណាឋិតនៅ កប្បិយកុដិរមែងតាំងនៅលើសសរ ឬជើងជញ្ជាំងនោះ តែរមែងលះវត្ថុក្នុងកាលសសរ ឬជើងជញ្ជាំងផ្លាស់ប្តូរទាំងអស់ ។ កប្បិយកុដិដែលធ្វើដោយឥដ្ឋជាដើម រមែងលះវត្ថុ ក្នុងវេលាដែលវត្ថុផ្សេង ៗ ជាដើមថា ឥដ្ឋ ឬថ្ម ឬដុំដី ដែលដាក់ទុកដើម្បីទ្រជើងជញ្ជាំង លើកន្លែងដែលកឡើង ជារបស់វិនាសទៅហើយ ។ ចំណែកកប្បិយកុដិដែលអធិដ្ឋានដោយឥដ្ឋជាដើមពួកណា កាលឥដ្ឋជាដើមពួកនោះ សូម្បីត្រូវរុះរើចេញហើយ តែឥដ្ឋជាដើមដទៃពីឥដ្ឋដុំដំបូងនោះឋិតនៅ កប្បិយកុដិ មិនទាន់លះវត្ថុទេ ។ កប្បិយកុដិ ឈ្មោះថា គោនិសាទិកា រមែងលះវត្ថុក្នុងកាលគេធ្វើរបងព័ទ្ធដោយកំផែងជាដើម ភិក្ខុគួរបានកប្បិយកុដិក្នុងអារាមនោះទៀត ។ តែបើគ្រឿងលោមព័ទ្ធមានកំផែងជាដើម ជារបស់បាក់បែកទៅទីនោះ ៗទៀត គោទាំងឡាយ រមែងចូលទៅមកដែលបាក់បែកនោះ ៗ កុដិនោះ រមែងត្រឡប់ជាកប្បិយកុដិទៀត ។ ចំណែកកប្បិយកុដិ ២ ប្រភេទ ក្រៅនេះ ទឹងលះវត្ថុ ក្នុងកាលគ្រឿងប្រក់ទាំងពួងពុកផុយអស់ទៅ នៅសល់ត្រឹមតែបង្កង់ ។ បើលើបង្កង់ទាំងឡាយ នៅមានគ្រឿងប្រក់ជាចំណែកជាប់គ្នាជាកណ្តប សូម្បីតែមួយ នៅរក្សាបាន ។

សួរថា ក៏ក្នុងវត្តណា មិនមានកប្បិយភូមិទាំង ៤ នេះ ក្នុងវត្តនោះនឹងគប្បីធ្វើយ៉ាងណា ?

ឆ្លើយថា ភិក្ខុគប្បីឱ្យដល់អនុបសម្បន្ន ធ្វើឱ្យជារបស់លោកហើយឆាន់ ។

ក្នុងសេចក្តីនោះ មានរឿងសាធក ដូច្នេះ ៖

បានឮថា ព្រះករវិកតិស្សត្ថេរជាប្រធាននៃព្រះវិន័យធរ បានទៅកាន់សំណាក់របស់ព្រះមហាសិវត្ថេរ ។ លោកឃើញឆ្នាំងទឹកដោះថ្លាដោយពន្លឺប្រទីប ទើបសួរថា "នោះជាអ្វី លោកម្ចាស់ ?"

ព្រះថេរៈឆ្លើយថា "អ្នកមានអាយុ ឆ្នាំងទឹកដោះថ្លា យើងនាំមកពីស្រុក ដើម្បីត្រូវការឆាន់ទឹកដោះថ្លា ក្នុងថ្ងៃដែលមានអាហារតិច" ។

លំដាប់នោះ ព្រះតិស្សត្ថេរ ទើបប្រាប់លោកថា "មិនគួរទេលោកម្ចាស់" ។

ក្នុងថ្ងៃស្អែក ព្រះថេរៈទើបឱ្យរក្សាទុកត្រង់យ៉មុខ ។ ថ្ងៃមួយបន្ទាប់មកទៀតព្រះតិស្សត្ថេរ មកឃើញឆ្នាំងទឹកដោះថ្លានោះ ទើបសួរយ៉ាងនោះឯង ហើយប្រាប់ថា "ការរក្សាទុកក្នុងទីដែលអាចត្រូវអាបត្តិដោយសហសេយ្យៈ មិនសមគួរទេ លោកម្ចាស់" ។

ស្អែកឡើង ព្រះថេរៈឱ្យលើកចេញទៅរក្សាទុកខាងក្រៅ ។ ពួកចោរលួចឆ្នាំងទឹកដោះថ្លានោះទៅ ។ លោកទើបនិយាយចំពោះព្រះតិស្ស

ត្រូវដែលមកក្នុងថ្ងៃបន្ទាប់មកទៀតថា “អ្នកមានអាយុ កាលលោកប្រាប់ថា មិនគួរ ឆ្នាំងនោះរក្សាទុកខាងក្រៅ ត្រូវពួកចោរលួចទៅហើយ” ។

លំដាប់នោះ ព្រះតិស្សត្ថេរ ទើបណែនាំលោកថា “ឆ្នាំងទឹកដោះថ្លានោះ គប្បីជារបស់ដែលលោកគួរឱ្យដល់អនុបសម្បន្ន មិនមែនឬលោកម្ចាស់ ?” ព្រោះថា កាលឱ្យដល់អនុបសម្បន្នហើយ ទឹងធ្វើឱ្យជារបស់លោកម្ចាស់ លោកម្ចាស់ឆាន់ ក៏រមែងគួរ ។

## បញ្ចគោរសនិងស្បៀងតាមមក

[១៣១] រឿងមេណ្ឌកសេដ្ឋី ជាក់ច្បាស់ហើយ ។

[១៣៣] ក៏ប៉ុន្តែថា ក្នុងរឿងមេណ្ឌកសេដ្ឋីនេះ ពាក្យថា **អនុជានាមិ ភិក្ខវេ បញ្ចគោរសេ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគោរស ៥** មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឆាន់គោរសទាំង ៥ នេះ ដោយការបរិភោគផ្សេងគ្នា ។

វិនិច្ឆ័យក្នុងពាក្យថា **បាថេយ្យំ បរិយេសិតុំ : ភិក្ខុស្វែងរកស្បៀងបាន** នេះ គប្បីជ្រាបដូចតទៅនេះ ៖

បើជនពួកខ្លះជ្រាបហើយ ប្រគេនដោយខ្លួនឯងតែម្តង យ៉ាងនោះការប្រគេននោះជាការល្អ បើគេមិនប្រគេន គប្បីស្វែងរកអំពីសំណាក់

ញាតិ និងជនបវារណា ឬដោយភិក្ខាចារវត្ត, កាលមិនបានដោយអាការយ៉ាងនោះ គប្បីសូមអំពីសំណាក់នៃជនដែលមិនបានបវារណា ក៏បាន ។

ក្នុងមកដែលនឹងត្រូវទៅត្រឹមតែមួយថ្ងៃ គប្បីស្វែងរកស្បៀងដើម្បីប្រយោជន៍ដល់អាហារមួយថ្ងៃ ។ ក្នុងមកឆ្ងាយ ខុននឹងផ្លូវកន្តារទៅបានដោយស្បៀងប៉ុនណា គប្បីស្វែងរកប៉ុណ្ណោះ ។

## ទឹកអដ្ឋបាន

[១៣៤] ពីរបទថា **កាជេហិ គាហាបេត្វា : ឱ្យរែកទៅដោយអម្រែកទាំងឡាយហើយ** មានសេចក្តីថា ប្រើមនុស្សឱ្យជញ្ជូនថ្នាំងទឹកផ្លែពុទ្រា ដែលផ្សំល្អហើយ មួយពាន់ថ្នាំង ដោយអម្រែកប្រាំរយ ។

ពាក្យថា **ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា : ព្រោះនិទាននេះ ដំណើរនេះ ទើបទ្រង់ធ្វើធម្មីកថា** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយល្អណាស់ កាលអ្នកទាំងឡាយមិនផឹកទឹកបាន ឈ្មោះថា មិនញ៉ាំងវាទៈឱ្យកើតឡើងថា ពួកសាវករបស់ព្រះសមណគោតម ជាអ្នកប្រាថ្នាច្រើនដោយបច្ច័យ, និងឈ្មោះថា បានធ្វើសេចក្តីគោរពក្នុងតថាគត, និងឈ្មោះថា អ្នកទាំងឡាយ បានញ៉ាំងសេចក្តីគោរពដ៏ល្អឱ្យកើតដល់

តថាគត តថាគតជ្រះថ្លាយ៉ាងល្អ ដោយហេតុនេះរបស់អ្នកទាំងឡាយ” ដោយប្រការយ៉ាងនេះ ហើយត្រាស់ពាក្យជាដើមថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកបានទាំងឡាយ ៨ យ៉ាង” ។

បណ្តាទឹកបាន ៨ យ៉ាងនោះ អម្ពបាននោះ បានដល់ ទឹកបាន ដែលធ្វើដោយទឹកផ្លែស្វាយខ្ចីឬទុំ ។ បណ្តាស្វាយខ្ចី និងស្វាយ ទុំ ២ យ៉ាងនោះ កាលទឹងធ្វើដោយស្វាយខ្ចី គប្បីបុកស្វាយខ្ចី ដាក់ក្នុងទឹក ហាលថ្ងៃឱ្យឆ្អិនដោយកម្តៅព្រះអាទិត្យ ហើយត្រង ផ្សំដោយទឹកឃ្មុំ ស្ករ ត្នោតនិងកាបូរជាដើម ដែលទទួលប្រគេនក្នុងថ្ងៃនោះ ។

អម្ពបានដែលភិក្ខុធ្វើយ៉ាងនេះ រមែងគួរក្នុងបុរេភត្តប៉ុណ្ណោះ ។ ចំណែកអម្ពបានដែលពួកអនុបសម្បន្នធ្វើ ដែលភិក្ខុបានមកទទួលប្រគេន ក្នុងបុរេភត្ត រមែងគួរ សូម្បីដោយបរិភោគលាយអាមិសក្នុងបុរេភត្ត, ដែលទទួលប្រគេនក្នុងបច្ឆាភត្ត រមែងគួរ ដោយបរិភោគប្រាសចាកអាមិស ដរាបដល់វេលាអរុណរះ ។ ក្នុងទឹកបានគ្រប់ប្រភេទ ក៏ន័យនេះ ។

មួយទៀត បណ្តាទឹកបានទាំងនោះ ជម្ពុបាននោះ បានដល់ ទឹកបានដែលធ្វើដោយផ្លែព្រីង ។

ចោចបាននោះ បានដល់ ទឹកបានដែលធ្វើដោយផ្លែចេកមានគ្រាប់ ។

មោចបាននោះ បានដល់ ទឹកបានដែលធ្វើដោយផ្លែចេកមិនមានគ្រាប់ ។

មធុកបាននោះ បានដល់ ទឹកបានដែលធ្វើដោយរសជាតិនៃផ្លែស្រគំ ។ និងមធុកបាននោះ លាយទឹក ទើបគួរ, សុទ្ធ ៗ មិនសមគួរ ។

មុទ្ទិកបាននោះ បានដល់ ទឹកបានដែលគេច្របាច់ផ្លែចន្ទន៍ ក្នុងទឹកធ្វើ ដូចអម្ពបាន ។

សាលុកបាននោះ បានដល់ ទឹកបានដែលគេច្របាច់ក្រអៅឧប្បលក្រហម និងឧប្បលខៀវជាដើមធ្វើ ។

ផារុសកបាននោះ បានដល់ ទឹកបានដែលធ្វើដោយផ្លែម៉ាក់ប្រាង ដូចអម្ពបាន ។ អដ្ឋបានទាំងនេះ ត្រជាក់ក្តី ឆ្អិនដោយកម្តៅព្រះអាទិត្យក្តី រមែងគួរ ។ ឆ្អិនដោយភ្លើងមិនគួរ ។

## រស ៤ យ៉ាង

ធញ្ញផលរសនោះ បានដល់ រសនៃស្រូវ ៧ ប្រភេទ[1] ។

ឍាករសនោះ បានដល់ រសនៃបន្លែដែលឆ្អិន ។ ពិតមែន រសនៃបន្លែដែលជាយាវកាលិក រមែងគួរក្នុងបុរេភត្តប៉ុណ្ណោះ ។ រសនៃបន្លែដែលជាយាវជីវិកដែលឆ្អិន ព្រមទាំងទឹកដោះថ្លាជាដើម ដែលទទួល

---

១. សាលិ ស្រូវសាលី ។ ២. គោធូម ស្រូវដំណើប ។ ៣. វីហិ ស្រូវខ្សាយ ។ ៤. យវ ស្រូវ ស្រងែ ។ ៥. កង្គុ ឬ កង្គុ ថ្ងៅ ។ ៦. វរក ស្លួយ ។ ៧. កុទ្រូស (កុរុស) ស្មៅកេលលក ។

ប្រគេនរក្សាទុក គួរឆាន់បាន ៧ថ្ងៃ ។ តែបើរសនៃបន្លែនោះចម្អិនដោយទឹកសុទ្ធ គួរឆាន់បានដរាបរហូតដល់អស់ជីវិត ។ ភិក្ខុនឹងស្ងោរបន្លែដែលជាយាវជីវិកនោះ ធ្វើឱ្យឆ្អិនព្រមទាំងទឹកដោះស្រស់ជាដើមដោយខ្លួនឯងមិនគួរ ។ សូម្បីដែលជនពួកដទៃ ធ្វើឱ្យឆ្អិនហើយ រមែងរាប់ថា រសបន្លែដូចគ្នា ។ ចំណែកក្នុងកុរុន្ទីពន្យល់ថា រសសូម្បីនៃបន្លែដែលជាយាវកាលិក ដែលប្របាច់ក្នុងទឹកត្រជាក់ធ្វើក្តី ឆ្អិនដោយកម្តៅព្រះអាទិត្យក្តី រមែងគួរ ។

វិនិច្ឆ័យក្នុងពាក្យថា ឋបេត្វា មធុកបុប្ផរសំ : លើកលែងតែទឹកផ្កាស្រគំ នេះ គប្បីជ្រាបដូច្នេះ ៖

រសផ្កាស្រគំទឹងឆ្អិនដោយភ្លើង ឬឆ្អិនដោយកម្តៅព្រះអាទិត្យ ក៏ដោយ រមែងមិនគួរក្នុងបច្ឆាភត្ត ជនទាំងឡាយកន់យករសផ្កាឈើយ៉ាងណា ដែលឆ្អិនហើយ ធ្វើឱ្យជាទឹកស្រវឹង រសនៃផ្កាឈើនោះ រមែងមិនគួរតាំងពីដើម សូម្បីក្នុងទាំងអស់នោះ រមែងគួរក្នុងបុរេភត្ត រសអំពៅដែលមិនមានកាក គួរក្នុងបច្ឆាភត្ត ។ បុរេភត្ត ។ ចំណែកផ្កាស្រគំស្រស់ ឬស្ងួត ឬលីងហើយ ឬលាយទឹកអំពៅហើយ ក៏ដោយ គេមិនទាន់ធ្វើឱ្យជាទឹកស្រវឹង ចាប់ផ្តើមតាំងពីផ្កាប្រភេទណា ផ្កាប្រភេទរសទាំង ៤ យ៉ាងនេះ ដែលព្រះមានព្រះភាគ កាលទ្រង់អនុញ្ញាតទឹកបាន

ក៏ទ្រង់បានអនុញ្ញាតទុក ដោយប្រការដូច្នេះឯង ។

[១៣៥] ក្នុងពាក្យថា **អគ្គិហុត្តមុខា យញ្ញា : យញ្ញទាំងឡាយមានការបូជាភ្លើងជាប្រធាន** ជាដើម ជាពាក្យដែលលោកពោលហើយដោយសេចក្ដីថា ការបូជាភ្លើងជាការប្រសើរ ការបូជាភ្លើងជាប្រធានដូច្នេះ ។

## ពណ៌នាបន្លែនិងម្សៅ

[១៣៦] រឿងនៃមល្លៈឈ្មោះកេជៈ ជាក់ច្បាស់ហើយទាំងអស់ ។

បណ្ដាបទទាំងនោះ ពីរបទថា សព្វញ្ច ឌាកំ : **អន្នក់គ្រប់មុខផង** បានដល់ បន្លែប្រភេទណាមួយ ដែលចម្អិនដោយទឹកដោះថ្លាជាដើមក្ដី មិនបានចម្អិនក្ដី ។

បទថា **បិដ្ឋខាទនីយំ** បានដល់ ខាទនីយៈដែលធ្វើដោយម្សៅ ។ បានឮថា ស្ដេចរោជឱ្យតាក់តែងរបស់ទាំងពីរយ៉ាងនេះ ដោយបរិច្ចាគព្រទ្យមួយសែន ។

ពីរបទថា សច្ចរំ អកាំសុ : **ធ្វើការប្ដេជ្ញាគ្នា** មានសេចក្ដីថា បានធ្វើកតិការ ។

ប្រើនបទថា ឧឡារំ ខោ តេ ឥទំ : **នេះជាការប្រពៃរបស់អ្នក**

ហើយ មានសេចក្ដីថា ការទទួលព្រះមានព្រះភាគរបស់លោកនេះ ជាកិច្ចល្អណាស់ ។

ច្រើនបទថា ឆាយាំ ភន្តេ អានន្ទ ពហុកតោ : បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនមែនធ្វើ(សេចក្ដីគោរព)ច្រើន មានសេចក្ដីថា ស្ដេចពេជៈ នោះ សម្ដែងថា យើងនឹងបានមកទីនេះ ដោយសេចក្ដីជ្រះថ្លានិងសេចក្ដីរាប់អានច្រើន ដែលប្រព្រឹត្តទៅ ក្នុងព្រះពុទ្ធជាដើម ក៏ទេ ។

## រឿងភិក្ខុធ្លាប់ជាជាងកោរសក់

[១៣៧] បទថា មញ្ជុកា : សំឡេងពីរោះ បានដល់ ជាអ្នកមានពាក្យពីរោះ ។

បទថា បដិភាណេយ្យកា : ប្រកបដោយសេចក្ដីវាងវៃ មានសេចក្ដីថា ជាអ្នកដល់ព្រមដោយការឆ្លាតវាងវៃក្នុងវិជ្ជារបស់ខ្លួន ។

បទថា ទក្ខា : ជាអ្នកឆ្លាស គឺ ជាអ្នកប៉ិនស្រប់ ឬជាអ្នកមិនខ្ជិលប្រអូស ។

បទថា បរិយោទាតសិប្បា : សម្រេចសិល្បៈ បានដល់ អ្នកមានចំណេះវិជ្ជា មិនមានទោស ។

បទថា **ឆាឡិយាវាបកេន** : ព្រមទាំងបំពង់និងថង់ បានដល់ នាឡិនិងថង់ ។ មានពាក្យអធិប្បាយថា ជនទាំងឡាយ រមែងប្រេក គឺ រមែងដាក់អង្ករដែលបានហើយ ៗ ក្នុងភាជនៈណា ភាជនៈនោះ ឈ្មោះថា **អាវាបក** : ថង់ ។

វិនិច្ឆ័យក្នុងពាក្យថា **ន ភិក្ខវេ នហាបិតបុព្វេន ខុរភណ្ឌំ** : ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលធ្លាប់ជាជាងកោរកាត់ មិន(ត្រូវរក្សា) គ្រឿងប្រដាប់កោរកាត់ទុកទេ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុដែលធ្លាប់ជាជាងកោរសក់ មិនគួររក្សាកាំបិតកោរទុកឡើយ តែនឹងកោរសក់ដោយកាំបិតកោរជារបស់អ្នកដទៃ គួរ ។ បើនឹងកាន់យកតម្លៃឈ្នួល មិនគួរ ។ ភិក្ខុណាមិនធ្លាប់ជាជាងកោរសក់ សូម្បីភិក្ខុនោះនឹងរក្សាកាំបិតកោរទុក រមែងគួរ; សូម្បីនឹងកាន់យកកាំបិតកោរនោះ ឬកាំបិតកោរដទៃកោរសក់ ក៏គួរ ។

[១៣៩] ពីរបទថា **ភាគំ ទត្វា** : ត្រូវភិក្ខុឱ្យចំណែក មានសេចក្តីថា គប្បីឱ្យចំណែកទី ១០ ។ បានឮថា ការឱ្យចំណែកទី ១០ នេះ ជាទំនៀមចាស់ ក្នុងជម្ពូទ្វីប ព្រោះហេតុនោះ គប្បីបែងចែកជា ១០ ចំណែក ហើយឱ្យដល់ពួកម្ចាស់ដីមួយចំណែក ។

# មហាបទេស ៤

[១៤០] ដើម្បីប្រយោជន៍ដែលភិក្ខុទាំងឡាយ នឹងបានកាន់យកនូវន័យ ទើបព្រះមានព្រះភាគត្រាស់មហាបទេស (គឺ គោល សម្រាប់អាងធំ) ៤ ប្រការទាំងនេះ ថា យំ ភិក្ខវេ មយា ឥទំ ន កប្បតិ : ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត (មិនបានហាមទុកថា) របស់នេះមិនគួរទេ ជាដើម ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលកាន់យកសូត្រផ្ទៀងផ្ទាត់មើលក្នុងមហាបទេសនោះ បានឃើញសេចក្ដីនេះថា ៖

ដោយព្រះបាលីថា ឋបេត្វា ធញ្ញផលរសំ : លើកលែងតែផ្លែស្រូវ នេះ ធញ្ញជាតិ ៧ ប្រភេទជាការហាមហើយថា មិនគួរក្នុងបច្ឆាភត្ត ។ មហាផល ៩ យ៉ាង គឺ ផ្លែត្នោត ផ្លែដូង ផ្លែខ្នុរ ផ្លែខ្នុរសម្លឃ្លោក ត្រឡាច ត្រសក់ ឪឡឹក ល្ពៅ ជាការទ្រង់ហាម និងអបរណ្ណជាតិគ្រប់ប្រភេទ មានគតិដូចធញ្ញជាតិដែរ ។ មហាផលនិងអបរណ្ណជាតិនោះ មិនបានទ្រង់ហាមទុក ក៏ពិតមែន តែថា រមែងអនុលោមចូលវត្ថុដែលជាអកប្បិយ, ព្រោះហេតុនោះ ទើបមិនគួរក្នុងបច្ឆាភត្ត ។

ទឹកបាន ៨ យ៉ាង ទ្រង់អនុញ្ញាតទុក ទឹកបាននៃផ្លែឈើតូច មានផ្គាំ អំពិល ក្រូច ខ្ទិត ពង្រ និងផ្លែសង្កែរជាដើម មានគតិដូចអដ្ឋបាន

ពិត ទឹកបាននៃផ្លែឈើទាំងនោះ ទ្រង់មិនបានអនុញ្ញាតទុក ក៏ពិតមែនហើយ តែថា រមែងចូលជាមួយនឹងវត្ថុដែលជាកប្បិយ; ព្រោះដូច្នោះទើបគួរ ។

ក្នុងកុរុន្ទីពោលថា ពិតមែន វៀររសនៃផ្លែស្រូវព្រមទាំងវត្ថុដែលអនុលោមចេញហើយ ដែលឈ្មោះថា ទឹកផ្លែឈើដទៃដែលមិនគួរមិនមាន ទឹកផ្លែឈើគ្រប់ប្រភេទជាយាមកាលិកពិត ។

ចីវរព្រះមានព្រះភាគទ្រង់អនុញ្ញាតទុក ៦ ប្រភេទ ។ ចីវរដទៃទៀត ៦ ប្រភេទដែលអនុលោមចីវរទាំងនោះ គឺ **ទុកូលៈ** សំពត់សម្បកឈើ, **បត្តុណ្ណៈ** សំពត់ដែនបត្តុណ្ណៈ, **ចីនបដ្ដៈ** សំពត់ប្រទេសចិន, **សោមារបដ្ដៈ** សំពត់ប្រទេសក្លិង្គ, **ឥទ្ធិមយិកៈ** សំពត់សម្រេចដោយឫទ្ធិ, **ទេវទត្តិយៈ** សំពត់ទេវតាឱ្យ, ព្រះធម្មសង្គាហកត្ថេរទាំងឡាយអនុញ្ញាតហើយ ។

បណ្ដាសំពត់ទាំងនោះ សំពត់បត្តុណ្ណៈនោះ បានដល់ សំពត់ដែលកើតដោយសូត្រក្នុងបត្តុណ្ណប្រទេស ។ សំពត់ ២ ប្រភេទ ហៅតាមឈ្មោះរបស់ប្រទេសទាំងឯង ។ សំពត់ ៣ ប្រភេទនោះ អនុលោមសំពត់សូត្រ សំពត់ទុកុលៈ អនុលោមសំពត់ធ្មៃ, ២ ប្រភេទ ក្រៅពីនេះអនុលោមសំពត់កប្បាស( សំពត់អំបោះ ) ឬសំពត់គ្រប់យ៉ាង ។

បាត្រព្រះមានព្រះភាគទ្រង់ហាម ១១ យ៉ាង អនុញ្ញាត ២ យ៉ាង

គឺ បាត្រដែក បាត្រដី ។ ភាជនៈ ៣ យ៉ាង គឺ ភាជន៍ដែក១ ភាជន៍ដី១ ភាជន៍ទង់ដែង១ អនុលោមតាមបាត្រនោះឯង ។

បំពង់ទឹក ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុក ៣ យ៉ាង គឺ បំពង់លោហៈ បំពង់ឈើ បំពង់ផ្លែឈើ ។ ភាជន៍ទឹក ៣ យ៉ាង គឺ កុណ្ឌីទឹក (ប្រដាប់សម្រាប់ដាក់ទឹកជ្រូច) ផ្តិលមាស ក្អមទឹក អនុលោមតាមបំពង់ទឹក ៣ យ៉ាង នុ៎ះឯង ។ តែក្នុងកុរុន្ទីពោលថា ស័ង្ខសម្រាប់ដាក់ទឹកឆាន់ និងផ្តិលទឹក អនុលោមតាមបំពង់ទាំងនោះដែរ ។

កាយពន្ធទ្រង់អនុញ្ញាតទុក ២ ប្រភេទ គឺ កាយពន្ធធ្វើជាផ្ទាំង ១ កាយពន្ធដែលមានសណ្ឋានដូចពោះវៀនជ្រូក១ ។ កាយពន្ធដែលធ្វើអំពីផ្ទាំងសំពត់ និងអំពីខ្សែ អនុលោមចូលកាយពន្ធ ២ ប្រភេទនោះដែរ ។

ឆត្រទ្រង់អនុញ្ញាតទុក ៣ ប្រភេទ គឺ សេតច្ឆត្តំ ឆត្រដែលគេពាសដោយសំពត់មានពណ៌ស ១ កិលញ្ជច្ឆត្តំ ឆត្រដែលគេធ្វើដោយផែង ១ បណ្ណច្ឆត្តំ ឆត្រដែលគេធ្វើដោយស្លឹកឈើ ១[១] ឆត្រស្លឹកឈើមួយសន្លឹក អនុលោមតាមឆត្រ ៣ ប្រភេទនោះឯង; សូម្បីរបស់ដទៃ ៗ ដែលអនុលោមចូលវត្ថុដែលគួរ និងមិនគួរអ្នកបដិបត្តិគប្បីពិចារណាមើលបាលី និងអដ្ឋកថាហើយជ្រាបតាមន័យនេះចុះ ។

---

១. វិន. បាចិ. សេក្ខិយកណ្ឌ. ៤. ៤៧៦/៤៧៨ ។

# កាលិកលាយគ្នា

[១៤១] ពាក្យថា តទហុប្បដិគ្គហិតំ កាលេ កប្បតិ : ដែលទទួលក្នុងថ្ងៃនោះ គួរតែក្នុងកាល ជាដើម ព្រះមានព្រះភាគត្រាស់សំដៅយករសដែលលាយគ្នាគ្រប់យ៉ាង ។ ក៏បើទឹកបានដែលទទួលប្រគេនលាយជាមួយនឹងដូងទាំងផ្លែ (ទាំងសំបក) យកដូងចេញហើយ ទឹកបាននោះ គួរសូម្បីក្នុងវេលាវិកាល ។

ពួកទាយកប្រគេនបាយបាយាសត្រជាក់ ដាក់ដុំសប្បិទុកខាងលើ សប្បិណា មិនលាយជាមួយនឹងបាយបាយាស នឹងយកសប្បិនោះចេញទុកឆាន់ ៧ ថ្ងៃក៏គួរ ។

សូម្បីក្នុងសត្តាហកាលិកដ៏សេស មានទឹកឃ្មុំ និងដុំស្ករត្នោតជាដើម ក៏ន័យនេះឯង ។

ពួកទាយកប្រគេនបិណ្ឌបាត ប្រដាប់ដោយក្រវាញ និងផ្លែចន្ទន៍ជាដើមខ្លះ ក្រវាញនិងផ្លែចន្ទន៍ជាដើមនោះ គប្បីលើកចេញ លាងទុកឆាន់បានរហូតដល់អស់ជីវិត ក្នុងខ្ញីដែលគេដាក់ក្នុងយាគូ ប្រគេនជាដើមក្តី ក្នុងឈើអែមដែលគេដាក់ក្នុងប្រេងជាដើម ហើយប្រគេនជាដើមក្តី មានន័យដូចគ្នា ។

កាលិកណា ៗ ជារបស់មានរសមិនលាយគ្នាយ៉ាងនោះ កាលិ

កនោះ ៗ សូម្បីទទួលប្រគេនរួមគ្នា; លាងឬចិតចេញឱ្យស្អាតហើយឆាន់ដោយអំណាចនៃកាលរបស់កាលិកនោះ ៗ រមែងគួរ ។ តែបើកាលិកណា មានរសចូលលាយគ្នាបាន កាលិកនោះ រមែងមិនគួរ ។

ពិតមែន យាវកាលិក រមែងទាញកាលិកទាំង ៣ មានយាមកាលិកជាដើម ដែលមានរសលាយនឹងខ្លួនចូលកាន់សភាពរបស់ខ្លួន, សូម្បីយាមកាលិក ក៏ទាញ កាលិក ២ មានសត្តាហកាលិកជាដើមចូលកាន់សភាពរបស់ខ្លួន, ឯសត្តាហកាលិក ក៏រមែងទាញ យាវជីវិកដែលលាយចូលនឹងខ្លួន ចូលកាន់សភាពរបស់ខ្លួនដូចគ្នា ព្រោះដូច្នោះ គប្បីជ្រាបសន្និដ្ឋានថា យាវជីវិកដែលទទួលប្រគេន ក្នុងថ្ងៃនោះក្តី ទទួលប្រគេនក្នុងថ្ងៃមុន ៗក្តី លាយជាមួយនឹងសត្តាហកាលិកនោះ ដែលទទួលប្រគេនក្នុងថ្ងៃនោះ គួរត្រឹមតែ ៧ ថ្ងៃ លាយជាមួយសត្តាហកាលិកដែលទទួលប្រគេនទុក ២ ថ្ងៃ គួរ ត្រឹមតែ ៦ ថ្ងៃ លាយជាមួយនឹងសត្តាហកាលិកដែលទទួលប្រគេនទុក ៣ ថ្ងៃ គួរត្រឹមតែ ៥ ថ្ងៃ លាយជាមួយនឹងសត្តាហកាលិក ដែលទទួលប្រគេនទុក ៧ ថ្ងៃគួរក្នុងថ្ងៃនោះប៉ុណ្ណោះ ក៏ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគមិនត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យាវជីវិកដែលទទួលប្រគេនក្នុងថ្ងៃនោះ លាយជាមួយសត្តាហកាលិក គួរ ៧ ថ្ងៃ" ទេ, ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ វត្ថុជា

យាវជីវិក (លាយឡំ) ដោយវត្ថុជាសត្តាហកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរអស់ ៧ ថ្ងៃ” ក៏កាលកាលិក ៣ នេះឈានកន្លងកាលយាម និង ៧ ថ្ងៃ គប្បីជ្រាបអាបត្តិ ដោយអំណាចវិកាលភោជនសិក្ខាបទ សន្និធិសិក្ខាបទ និងភេសជ្ជសិក្ខាបទ ។

ក៏ឯក្នុងកាលិក ៤ នេះ កាលិក ២ គឺ យាវកាលិក ១ យាមកាលិក ១ នេះប៉ុណ្ណោះ ជាអន្តោវុត្ថៈផង ជាសន្និធិការកៈផង; តែសត្តាហកាលិកនិងយាវជីវិក សូម្បីទឹងរក្សាទុកក្នុងអកប្បិយកុដិ ក៏គួរ ។ ទាំងមិនឱ្យកើតសន្និធិផង ដូច្នេះឯង ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ភេសជ្ជក្ខន្ធកវណ្ណនា ចប់ ។**

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### មហាវគ្គ

## ទុតិយភាគ

## ៧

### ចប់

# សមន្តប្បាសាទិកា

## អដ្ឋកថា  វិនយបិដក

### មហាវគ្គ

## តតិយភាគ

## ៨

# ៧. កឋិនក្ខន្ធកវណ្ណនា

## រឿងភិក្ខុក្នុងដែនបាវេយ្យៈ

[១] វិនិច្ឆ័យក្នុងកឋិនក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

បទថា ធាវេយ្យកា មានសេចក្ដីថា ជាអ្នកនៅក្នុងដែនបាវេយ្យៈ[១] ។ មានពាក្យអធិប្បាយថា នៅទិសខាងលិច ក្នុងកោសលជនបទ មានដែនឈ្មោះបាវេយ្យៈ, ភិក្ខុទាំងនោះ មានប្រក្រតីនៅក្នុងដែននោះ ។ ពាក្យថា បាវេយ្យកានោះ ជាឈ្មោះរបស់ពួកភិក្ខុភទ្ទវគ្គិយត្ថេរ ដែលជាបងប្អូនរួមព្រះបិតារបស់ព្រះបាទកោសល ។ ក្នុងព្រះថេរៈ ៣០ រូបនោះ ព្រះថេរៈដែលមានគុណធម៌ខ្ពស់ជាងគេ ជាព្រះអនាគាមី, ព្រះថេរៈដែលមានគុណធម៌ទាបជាងគេទាំងអស់ជាព្រះសោតាបន្ន; ដែលជាព្រះអរហន្ត ឬបុថុជ្ជន សូម្បីតែមួយរូប ក៏មិនមាន ។

បទថា អារញ្ញកា : ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ មានសេចក្ដីថា មានប្រក្រតីនៅព្រៃ ដោយអំណាចសមាទានធុតង្គ, មិនមែនត្រឹមតែនៅព្រៃទេ សូម្បីភិក្ខុទាំងនោះ ជាអ្នកកាន់បិណ្ឌបាតជាដើម ក៏មានន័យដូចគ្នា ។ ពិតណាស់ ពាក្យថា មានប្រក្រតីនៅព្រៃ នេះ លោកពោល

---

១. បិដកខ្មែរ បាឋា; យោជនា បាវា; ភូមា បាវេយ្យៈ ។

ដោយអំណាចធុតង្គជាប្រធាន តែភិក្ខុទាំងនេះ សមាទានធុតង្គទាំង ១៣ នោះឯង ។

បទថា ឧទកសង្គហេ : **មានទឹកភក់រអិលនៅឡើយ** មានសេចក្តីថា កាលភូមិភាគត្រូវទឹកជន់លិច គឺ ឃាំងទុកហើយ, អធិប្បាយថា ទាំងទីទួល ទាំងទីទំនាប ជាទីមានទឹកជាប់តែមួយ ។

បទថា ឧទកចិក្ខល្លេ : **ទទឹក** មានសេចក្តីថា ក្នុងទីដែលលោកទាំងឡាយជាន់ហើយ ៗ ទឹកភក់ក៏បាញ់ឡើងដល់ត្រគាក, ជាមករអិលដូច្នេះ ។

បទថា ឱកបុណ្ណេហិ : **ជោក** មានសេចក្តីថា សើមជោគដោយទឹក ។

បានឮថា ចីវររបស់ពួកលោក មានសាច់ម៉ត់, ទឹកដែលធ្លាក់លើចីវរទាំងនោះ ទើបមិនហូរទៅ ព្រោះជាសំពត់សាច់ម៉ត់, រមែងឋិតនៅដូចចង់កញ្ចប់ទុក; ព្រោះដូច្នោះ ទើបលោកពោលថា មានចីវរទទឹកជោគដោយទឹក ។ បាលីថា ឱឃបុណ្ណេហិ ក៏មាន ។

វិនិច្ឆ័យក្នុងពាក្យថា អវិវទមានា វស្សំ វសិម្ហា : **ឥតមានវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួល** នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុទាំងនោះ នៅមិនសប្បាយ ព្រោះមិនមានភាពសប្បាយដោយ

សេនាសនៈក្នុងឋានដែលខ្លួនជាអាគន្តុកៈ និងព្រោះជាអ្នកខ្វល់ខ្វាយក្នុងចិត្ត ដោយមិនបានគាល់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបពួកលោកមិនទូលថា "ខ្ញុំព្រះអង្គទាំងអស់គ្នា ឥតមានវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួល" ។

[២] ពាក្យថា ធម្មឹ កថំ កត្វា : ធ្វើធម្មីកថា មានសេចក្តីថា ព្រះមានព្រះភាគ ត្រាស់ទូន្មានដោយអនមតគ្គិយកថាដល់ភិក្ខុទាំងនោះ ។ លោកទាំងអស់ បានសម្រេចព្រះអរហត្តក្នុងវេលាចប់កថា ហើយបានហោះទៅក្នុងអាកាស ចាកទីដែលខ្លួនអង្គុយតែម្តង ។ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សំដៅយកអនមតគ្គិយកថានោះពោលថា ធម្មឹ កថំ កត្វា ខាងក្រោយព្រះមានព្រះភាគទ្រង់ត្រិះរិះថា "បើតថាគតបានបញ្ញត្តិនូវការក្រាលកឋិនរួចហើយសោត ភិក្ខុទាំងនោះ នឹងរក្សាចីវរទុកមួយផ្ទាំងហើយ មកដោយអន្តរវាសកៈនិងឧត្តរាសង្គៈ នឹងមិនចាំបាច់លំបាកយ៉ាងនោះ; ក៏ធម្មតាការក្រាលកឋិននេះ ដែលព្រះពុទ្ធគ្រប់ ៗ ព្រះអង្គ ទ្រង់បញ្ញត្តិហើយ" ដូច្នេះ ។ មានព្រះប្រាថ្នានឹងទ្រង់អនុញ្ញាតការក្រាលកឋិន ទើបត្រាស់ហៅភិក្ខុទាំងឡាយមក, លុះទ្រង់ត្រាស់ហៅមកហើយ ទើបត្រាស់ពាក្យថា អនុជានាមិ ភិក្ខវេ ជាដើម ។

## អានិសង្ស ៥

វិនិច្ឆ័យក្នុងពាក្យនោះ គប្បីជ្រាបដូច្នេះ ៖

ក្នុងពាក្យថា **អត្ថតកឋិនានំ វោ : កាលបើអ្នកទាំងឡាយបានក្រាលកឋិនហើយ** នេះ **វោ** អក្សរ ត្រឹមតែជានិបាត, សេចក្តីថា អ្នកក្រាលកឋិនហើយ ។ ពិតមែន កាលជាយ៉ាងនោះ ពាក្យថា **សោ នេសំ ភវិស្សតិ : ចីវរនោះ នឹងមានដល់ភិក្ខុទាំងនោះ** ខាងមុខ ទើបសមគ្នា ។

ម្យ៉ាងទៀត បទថា **វោ** នេះ ជាឆដ្ឋីវិភត្តិទុំះឯង ។ ចំណែកក្នុងពាក្យថា **សោ នេសំ** នេះ មានសេចក្តីថា ចីវរដែលកើតឡើងនោះ នឹងជារបស់ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនហើយ ។

បណ្តាអានិសង្សទាំង ៥ នោះ ពាក្យថា **អនាមន្តចារោ : ត្រាស់ទៅមិនបាច់លា** មានសេចក្តីថា កឋិនដែលសង្ឃមិនទាន់បានដោះត្រឹមណា, ការត្រាច់ទៅណាមិនពោលលាភិក្ខុផងគ្នា នឹងគួរត្រឹមនោះ; គឺនឹងមិនជាអាបត្តិ ព្រោះចារិត្តសិក្ខាបទ ។

ពាក្យថា **អសមាទានចារោ : មិនបាច់យកត្រៃចីវរ** បានដល់ត្រាច់ទៅណាមិនបាច់យកត្រៃចីវរទៅផង, សេចក្តីថា ការនៅប្រាសចាកចីវរ នឹងគួរ ។

ពាក្យថា គណភោជនំ : គណភោជនបាន មានសេចក្តីថា សូម្បីការឆាន់គណភោជន ក៏គួរ ។

ពាក្យថា យាវទត្ថចីវរំ : អតិរេកចីវរបានតាមត្រូវការ មានសេចក្តីថា ត្រូវការដោយចីវរប៉ុន្មាន, ( ទុកដាក់ )ចីវរប៉ុណ្ណោះ មិនបាច់អធិដ្ឋាន មិនបាច់វិកប្ប ក៏គួរ ។

ពាក្យថា យោ ច តត្ថ ចីវរុប្បាទោ : ចីវរណាដែលកើតក្នុងអាវាសនោះ មានសេចក្តីថា ទឹងជាចីវររបស់ភិក្ខុសាមណេរ ដែលមរណភាពក្នុងសីមា ដែលបានក្រាលកឋិនហើយនោះ ឬចីវរដែលទាយកប្រគេនចំពោះសង្ឃ ឬ ចីវរដែលទិញមកដោយតម្លៃទ្រព្យរបស់សង្ឃដែលកើតឡើងក្នុងសីមានោះ ក៏ដោយ, ចីវរណាជារបស់សង្ឃកើតឡើងដោយអាការយ៉ាងណាទីមួយ, ចីវរនោះ ទឹងជារបស់ពួកលោក ។

## ពណ៌នាអំពីអ្នកបានក្រាលកឋិន

វិនិច្ឆ័យក្នុងពាក្យថា ឯវញ្ច បន ភិក្ខវេ កឋិនំ អត្ថរិតព្វំ : ម្នាលភិក្ខុទាំងឡាយ ក៏ឯកឋិន ( នោះ ) ត្រូវអ្នកទាំងឡាយក្រាលយ៉ាងនេះ នេះគប្បីជ្រាបដូច្នេះ ៖

ក្នុងមហាបច្ចរីពោលថា សួរថា អ្នកណាបានក្រាលកឋិន អ្នក

ណាមិនបាន ?

ឆ្លើយថា ពោលដោយអំណាចនៃចំនួនមុន ៗ ភិក្ខុ ៥ រូប[១] ជាយ៉ាងតិច រមែងបានក្រាល, យ៉ាងច្រើនសូម្បីភិក្ខុមួយសែនរូប ក៏បាន ។ តិចជាង ៥ រូប មិនបាន[២] ។

ពោលដោយអំណាចភិក្ខុដែលចាំវស្សា ។ ភិក្ខុដែលចាំវស្សាក្នុងបុរិមិកាវស្សា បវារណាក្នុងថ្ងៃបឋមបវារណាហើយ រមែងបាន, ភិក្ខុដែលមានវស្សាដាច់ ឬចាំវស្សាក្នុងបច្ឆិមិកាវស្សា រមែងមិនបាន; សូម្បីភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ ក៏មិនបាន ។ និងភិក្ខុទាំងពួងអ្នកចាំវស្សាក្រោយ ជាគណបូរកៈរបស់ភិក្ខុដែលចាំវស្សាដើមក៏បាន, តែពួកលោកមិនបានអានិសង្ស; អានិសង្សរមែងសម្រេចដល់ពួកភិក្ខុក្រៅនេះប៉ុណ្ណោះ ។ បើភិក្ខុដែលចាំវស្សាដើមមាន ៤ រូប ឬ ៣ រូប ឬ ២ រូប ឬតែមួយរូប, គប្បីនិមន្តភិក្ខុដែលចាំវស្សាក្រោយ មកបន្ថែមឱ្យគ្រប់គណៈ ហើយក្រាលកឋិនចុះ ។ បើភិក្ខុដែលចាំវស្សាដើមមាន ៤ រូប, មានសាមណេរអាយុគ្រប់មួយរូប, បើសាមណេរនោះ ឧបសម្បទាក្នុងវស្សាក្រោយ, លោកជាគណបូរកៈបាន ទាំងបានអានិសង្សផង ។

---

១. ភិក្ខុ ៤ រូប ជាសង្ឃ ប្រគល់ឱ្យភិក្ខុ ១ រូប ។ ២. ព្រោះភិក្ខុ ៣ រូប មិនមែនជាសង្ឃ, មិនអាចប្រគល់ឱ្យភិក្ខុក្រាលទេ ។ (ភិក្ខុអ្នកទទួលមិនរាប់ថា ជាអ្នកប្រគល់ គឺ មិនជាគណបូរកៈ) ។

សូម្បីក្នុងពាក្យថា មានភិក្ខុ ៣ សាមណេរ ២, មានភិក្ខុ ២ សាមណេរ ៣, មានភិក្ខុតែមួយរូប សាមណេរ ៤ នេះ ក៏មាន ន័យយ៉ាងនេះឯង ។ បើភិក្ខុដែលចាំវស្សាដើម មិនឈ្លាសក្នុងការក្រាលកឋិន, គប្បីស្វែងរកព្រះថេរៈអ្នកពោលគម្ពីរខន្ធកៈ ដែលឈ្លាសក្នុងការក្រាលកឋិន ហើយនាំមក; លោកបង្រៀនឱ្យសូធ្យកម្មវាចា ឱ្យក្រាលកឋិន ហើយទទួលទានហើយនឹងទៅ ។ ចំណែកអានិសង្ស រមែងសម្រេចដល់ភិក្ខុក្រៅនេះប៉ុណ្ណោះ ។

## អ្នកថ្វាយសំពត់កឋិន

កឋិនអ្នកណាថ្វាយ ទើបប្រើបាន ?

បុគ្គលអ្នកណាម្នាក់ ទោះជាទេវតា ឬមនុស្ស ឬសហធម្មិក[1]ទាំង ៥ ណាមួយថ្វាយ ក៏ប្រើបាន ។

ធម្មទំនៀមរបស់អ្នកថ្វាយកឋិន មាន; បើគេមិនដឹងធម្មទំនៀមនោះ ។ ទើបសួរថា "កឋិនគួរថ្វាយយ៉ាងណា លោកម្ចាស់" ភិក្ខុគប្បីប្រាប់គេយ៉ាងនេះថា "គួរថ្វាយសំពត់ល្មមធ្វើត្រៃចីវរផ្ទាំងណាមួយបាន"

---

១. សហធម្មិក ៥ គឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ។

ក្នុងវេលាអរុណរះថា “ពួកខ្ញុំព្រះករុណា ប្រគេនសំពត់កឋិន”, គួរប្រគេនម្ជុលប៉ុណ្ណេះ អំបោះប៉ុណ្ណេះ ទឹកជ្រលក់ប៉ុណ្ណេះ ដើម្បីធ្វើចីវរនោះ និងប្រគេនយាគូ និងភត្តដល់ពួកភិក្ខុដែលជួយធ្វើប៉ុណ្ណេះរូប ៗ ចំណែកភិក្ខុដែលត្រូវក្រាលកឋិន គប្បីក្រាលកឋិនដែលកើត ឡើងដោយធម៌ដោយប្រពៃ ។ កាលនឹងក្រាល ត្រូវស្គាល់ធម្មទំនៀម ។

ពិតមែន សូម្បីសំពត់ដែលប្រលាក់ទឹកបាយ ដោយបន្តជាប់មកពីផ្ទះជាងតម្បាញនោះឯង ក៏ប្រើមិនបាន, សូម្បីសំពត់ចាស់ក៏ប្រើមិនបាន; ព្រោះដូច្នោះ បានសំពត់សម្រាប់ក្រាលកឋិនហើយ ត្រូវបោកគក់ឱ្យស្អាត ត្រៀមគ្រឿងដែសម្រាប់ធ្វើចីវរមានម្ជុលជាដើមទុកហើយព្រមដោយភិក្ខុទាំងឡាយ ជួយគ្នាដេរ ជ្រលក់ចីវរដែលដេរសម្រេច ឱ្យកប្បពិន្ទុហើយក្រាលកឋិនក្នុងថ្ងៃនោះឯង ។ បើកឋិននោះមិនទាន់បានក្រាល, អ្នកដទៃនាំសំពត់កឋិនមក; និងប្រគេនសំពត់អានិសង្សកឋិនដទៃ ៗ ជាច្រើន, អ្នកណាប្រគេនអានិសង្សច្រើន, គប្បីក្រាលដោយសំពត់កឋិនរបស់អ្នកនោះចុះ ។ តែត្រូវពន្យល់ប្រាប់ទាយកផ្នែកឯទៀត ឱ្យយល់ព្រមផង ។

# អ្នកគួរក្រាល

ក៏កឋិនអ្នកណាគួរក្រាល ? សង្ឃឱ្យចីវរកឋិនដល់ភិក្ខុណា, ភិក្ខុនោះគួរក្រាល ។

ក៏សង្ឃគួរឱ្យអ្នកណា ? ភិក្ខុណាមានចីវរចាស់, គួរឱ្យដល់ភិក្ខុនោះ ។ បើភិក្ខុមានចីវរចាស់ច្រើនរូប គប្បីឱ្យដល់ភិក្ខុចាស់ ។ ក្នុងពួកភិក្ខុចាស់សោត ភិក្ខុណាជាមហាបុរស អាចធ្វើចីវរសម្រេចទាន់ក្រាលក្នុងថ្ងៃនោះ, គួរឱ្យដល់ភិក្ខុនោះ បើភិក្ខុចាស់មិនអាច; ភិក្ខុខ្ចីជាងអាច; គប្បីប្រគល់ឱ្យដល់លោក( គឺភិក្ខុខ្ចី ) ។ តែសង្ឃគួរធ្វើសេចក្ដីសង្គ្រោះដល់ព្រះមហាថេរៈ, ព្រោះដូច្នោះ សង្ឃគប្បីទូលលោកថា សូមលោកទទួលចុះ, ពួកខ្ញុំព្រះករុណានឹងជួយធ្វើប្រគេន ។ ក្នុងត្រៃចីវរផ្ទាំងណាគ្រាំគ្រា, គួរឱ្យដើម្បីប្រយោជន៍ដល់ផ្ទាំងនោះ ។ តាមប្រក្រតីព្រះមហាថេរៈគ្រងចីវរពីរជាន់ គប្បីឱ្យដើម្បីល្មមធ្វើបានពីរជាន់ ។ បើសូម្បីលោកគ្រងចីវរមួយជាន់ តែសាច់ក្រាស់, តែសំពត់កឋិនសាច់ស្ដើង; គប្បីប្រគល់ឱ្យល្មមពីរជាន់តែម្ដង ដើម្បីបានសមរម្យ ។ សូម្បីលោកនិយាយថា កាលមិនបាន យើងក៏នឹងគ្រងតែមួយជាន់ ក៏គួរឱ្យពីរជាន់, តែបើភិក្ខុណា ជាអ្នកមានប្រក្រតីល្មោភ, មិនគួរឱ្យដល់ភិក្ខុនោះ ។ លោកអ្នកទទួលនោះ ក៏មិនគួរទទួលដោយគិតថា "យើងក្រាលកឋិនហើយ ខាងក្រោយ នឹងរុះចេញធ្វើជាចីវរពីរផ្ទាំង" ។

# កឋិនវត្ត

ក៏ដើម្បីសម្ដែងវិធីដែលនឹងគួរឱ្យដល់ភិក្ខុដែលសង្ឃនឹងឱ្យ ព្រះមានព្រះភាគទ្រង់ប្រារព្ធថា "ម្នាលភិក្ខុទាំងឡាយ ក៏ឯកឋិន (នោះ) ត្រូវអ្នកទាំងឡាយក្រាលយ៉ាងនេះ" ដូច្នេះហើយ ទើបត្រាស់កម្មវាចាសម្រាប់ឱ្យជាមុន មានពាក្យថា សុណាតុ មេ ភន្តេ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ជាដើម ។

ក៏កាលកឋិនដែលសង្ឃឱ្យយ៉ាងនេះហើយ បើសំពត់កឋិននោះជារបស់មានបរិកម្មសម្រេចសព្វគ្រប់ហើយ យ៉ាងនោះ ជាការល្អ; បើមានបរិកម្មមិនទាន់សម្រេច សូម្បីភិក្ខុមួយរូប នឹងមិនជួយធ្វើដោយប្រកាន់ខ្លួនថា "យើងជាថេរៈ" ឬថា "យើងជាពហុស្សុត" ដូច្នេះមិនបាន ; ការបោកគក់ដេរនិងជ្រលក់ ភិក្ខុទាំងអស់ត្រូវប្រជុំជួយគ្នាឱ្យសម្រេច ក៏ការនេះ ឈ្មោះថា កឋិនវត្ត ដែលព្រះពុទ្ធទ្រង់សរសើរ ។

ពិតមែន ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា បទុមុត្តរៈ ក៏បានទ្រង់ធ្វើកឋិនវត្តមកហើយ ក្នុងអតីតកាល ។ បានឮថា ព្រះអគ្គសាវករបស់ព្រះអង្គ ឈ្មោះសុជាតត្ថេរ បានទទួលកឋិន ។ ព្រះសាស្ដាបានទ្រង់គង់ធ្វើកឋិនវត្តនោះ ព្រមដោយភិក្ខុប្រាំមួយលានប្រាំបីសែនរូប ។

# វិធីក្រាល

ភិក្ខុជាអ្នកក្រាល គប្បីកាន់យកសំពត់កឋិនដែលធ្វើសម្រេចសព្វ ហើយ ក្រាលកឋិនតាមវិធីដែលលោកពោលទុកក្នុងគម្ពីរបរិវារៈ[1] មានពាក្យជាដើមថា បើ ( ភិក្ខុអ្នកក្រាល ) ចង់ក្រាលកឋិនដោយសង្ឃាដិ ត្រូវដកសង្ឃាដិចាស់ចេញ អធិដ្ឋានសង្ឃាដិថ្មីឡើង គប្បីបញ្ចេញវាចាថា "ខ្ញុំព្រះករុណាក្រាលកឋិន ដោយសង្ឃាដិនេះ" ។ ក៏ឯគ្រាក្រាលហើយ គប្បីឱ្យភិក្ខុទាំងឡាយ អនុមោទនាតាមវិធី ដែលលោកពោលទុក ក្នុងគម្ពីរបរិវារៈ[2] មានពាក្យជាដើមយ៉ាងនេះឯងថា "ភិក្ខុអ្នកក្រាលកឋិននោះ ចូលទៅរកភិក្ខុសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលី ឡើង រួចពោលយ៉ាងនេះថា អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ : បពិត្រព្រះសង្ឃដ៏ចម្រើន កឋិនរបស់សង្ឃ ខ្ញុំព្រះករុណាបានក្រាលហើយ ការក្រាលកឋិននេះ ប្រកបដោយធម៌ សូមលោកម្ចាស់ទាំងឡាយទទួលអនុមោទនាចុះ ។ ពួកភិក្ខុជាអ្នកអនុមោទនានោះ គប្បីធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើង រួចពោលយ៉ាងនេះថា អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម : ម្នាលអាវុសោ កឋិនរបស់សង្ឃ លោកបានក្រាលហើយ

---

១.២. វិន. បរិ. កឋិនភេទ. ១៣. ២៣០/២៤២ ។

ការក្រាលកឋិននេះ ប្រកបដោយធម៌ យើងរាល់គ្នា សូមអនុមោទនា” ។

ចំណែកពួកភិក្ខុក្រៅនេះ គប្បីអនុមោទនា ។ កឋិនជាការដែលភិក្ខុគ្រប់ ៗ រូបក្រាលហើយ ដោយប្រការយ៉ាងនេះ ។

ពិតមែន ក្នុងគម្ពីរបរិវារៈ[១] លោកពោលថា “បុគ្គល ២ ពួកដែលឈ្មោះថា បានក្រាលកឋិន គឺបុគ្គលដែលបានក្រាល ១ បានអនុមោទនា ១” ។ ទាំងបានពោលទុកទៀតថា[២] “សង្ឃក្រាលកឋិនមិនឡើង គណៈក្រាលកឋិនមិនឡើង បុគ្គលក្រាលកឋិនទើបឡើង; ប៉ុន្តែកឋិនក៏ឈ្មោះថា សង្ឃបានក្រាល, កឋិន ក៏ឈ្មោះថា គណៈបានក្រាល, កឋិនក៏ឈ្មោះថា បុគ្គលបានក្រាល, ព្រោះសង្ឃបានអនុមោទនា គណៈបានអនុមោទនា បុគ្គលក្រាល” ។ ក៏កាលកឋិនក្រាលហើយយ៉ាងនោះ បើពួកទាយកថ្វាយអានិសង្ស ដែលនាំមកព្រមនឹងកឋិនចីវរថា “ភិក្ខុរូបណា បានទទួលសំពត់កឋិនរបស់ពួកខ្ញុំព្រះករុណា ពួកខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុរូបនោះ” ដូច្នេះ ភិក្ខុសង្ឃ មិនជាធំ ។ បើគេមិនបានចាត់ចែងទុកថ្វាយហើយក៏ទៅ ភិក្ខុសង្ឃជាធំ; ព្រោះហេតុនោះ បើសូម្បីចីវរដ៏សេសទាំងឡាយ របស់ភិក្ខុដែលក្រាលជារបស់ទ្រុឌ ទ្រោមសង្ឃគប្បីអបលោកន៍ ឱ្យសំពត់ដើម្បីប្រយោជន៍ដល់ចីវរ សូម្បីទាំង

១. វិន. បរិ. កឋិនភេទ. ១៣. ២០៩/២២៧ ។ ២. វិន. បរិ. កឋិនភេទ. ១៣. ២៣១/២៤៤ ។

នោះ ៗ ចំណែក កម្មវាចាគន់ប្រើបានម្តងប៉ុណ្ណោះ ៗ សំពត់អានិសង្ស កឋិនដ៏សេស គប្បីចែកគ្នាដោយលំដាប់នៃសំពត់ចំណាំវស្សា ៗ ព្រោះ មិនមានលំដាប់ គប្បីចែកតាំងពីថេរាសនៈចុះមក ៗ គុរុភ័ណ្ឌមិនគួរ ចែក ៗ តែបើក្នុងសីមាមួយ មានវិហារច្រើន ត្រូវឱ្យភិក្ខុទាំងពួងប្រជុំគ្នា ក្រាលកឋិនក្នុងទីតែមួយ; នឹងក្រាលផ្សេង ៗគ្នា មិនគួរ ៗ

## អនត្ថតាការ និង អត្ថតាការ

(៣) ក៏ឥឡូវនេះ ដើម្បីសម្តែងវិធីដែលកឋិនក្រាលឡើង និងក្រាលមិន ឡើងដោយពិស្តារ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឯកឋិនដែលភិក្ខុក្រាលឡើងបែបនេះ ក្រាលមិនឡើងបែបនេះ" កាលនឹង ទ្រង់សម្តែងអករណីយកិច្ច មហាភូមិកៈ និងអនត្ថតលក្ខណៈមុន ទើប ទ្រង់សម្តែងអាការ ២៤ មានពាក្យថា ឧល្លិខិតមត្តេន ជាដើម; តពី នោះទៅ កាលនឹងទ្រង់សម្តែងអត្ថតលក្ខណៈ ទើបទ្រង់សម្តែងអាការ ១៧ មានពាក្យថា អហតេន អត្ថតំ ជាដើម ៗ ពិតមែន សូម្បីក្នុង គម្ពីរបរិវារៈ លោកក៏បានពោលលក្ខណៈយ៉ាងនេះដូចគ្នាថា "កឋិនដែល ភិក្ខុក្រាលមិនឡើង ដោយអាការ ២៤, កឋិនដែលភិក្ខុក្រាលឡើងដោយ អាការ ១៧" ៗ

បណ្ដាបទទាំងនោះ បទថា ឧល្លិខិតមត្តេន : សំពត់ដែលគ្រាន់តែវាស់គូសក្រិតចំណាំ បានដល់ ដោយត្រឹមតែកាន់យកប្រមាណផ្នែកបណ្ដោយ និងផ្នែកទទឹង ។

ពិតមែន កាលនឹងកាន់យកប្រមាណ រមែងប្រើក្រចកជាដើមគូសក្រិត សម្ដែងទីកំណត់កាត់យ៉ាងនោះ ឬទីមុខឆ្លូតជាដើមដើម្បីចាំប្រទេសនោះ ៗ ព្រោះហេតុនោះ ការកាន់យកប្រមាណនោះ ទើបព្រះមានព្រះភាគត្រាស់ថា "គ្រាន់តែវាស់គូសក្រិតចំណាំ" ។

បទថា ធោវនមត្តេន : សំពត់ដែលគ្រាន់តែបោកគក់លាង គឺ សំពត់កឋិនដែលគ្រាន់តែបោកគក់លាង ។

បទថា ចីវរវិចារណមត្តេន : សំពត់ដែលគ្រាន់តែចាត់ចែងលៃលកជាចីវរ គឺ ដោយគ្រាន់តែចាត់ចែងលៃលកយ៉ាងនេះថា ចូរជាចីវរ ៥ ខណ្ឌ ឬថា ចូរជាចីវរ ៧ ខណ្ឌ ឬថា ចូរជាចីវរ ៩ ខណ្ឌ ឬថា ចូរជាចីវរ ១១ ខណ្ឌ ។

បទថា ឆេទនមត្តេន : សំពត់ដែលគ្រាន់តែកាត់ គឺ ដោយត្រឹមតែកាត់សំពត់តាមដែលចាត់ចែងលៃលកទុកហើយ ។

បទថា ពន្ធនមត្តេន : សំពត់ដែលគ្រាន់តែដានភ្ជាប់គ្នា គឺ ដោយត្រឹមតែដានឱ្យជាប់គ្នា ដោយអំបោះផ្ដាន ។

បទថា ឱវដ្ដិយករណមត្តេន : សំពត់ដែលគ្រាន់តែដេរ គឺ

ដោយត្រឹមតែដេរតាមបណ្តោយតាមជួរអំបោះដែលផ្តាន ។

បទថា កណ្ឌុ សករណមត្តេន : សំពត់ដែលគ្រាន់តែភ្ជាប់កណ្ដុំ គឺ ដោយត្រឹមតែភ្ជាប់ក្រវិលសំពត់ ។

បទថា ទឡ្ហីកម្មករណមត្តេន : សំពត់ដែលគ្រាន់តែថែមសំពត់ឱ្យមាំ គឺ ដោយត្រឹមតែដេរសំពត់ផ្អបពីរផ្ទាំងភ្ជាប់ចូលគ្នា ។

ម្យ៉ាងទៀត មានសេចក្តីថា ដោយត្រឹមតែដេរសំពត់កឋិន ធ្វើឱ្យជាសំពត់ផ្អបផ្ទៃនៃសំពត់ផ្អបផ្ទាំងដំបូង ដែលភ្ជាប់ទុកហើយ ដូច្នេះខ្លះ ។

ក្នុងមហាបច្ចរីពោលថា ដោយភ្ជាប់សំពត់ទ្រាប់ចីវរប្រក្រតី ។ ចំណែកក្នុងកុរុន្ទីពោលថា ដោយត្រឹមតែភ្ជាប់សំពត់ផ្អបផ្ទៃចូល ដើម្បីធ្វើចីវរដែលដេរទុកតែមួយជាន់តាមប្រក្រតីឱ្យជាពីរជាន់ ។

បទថា អនុវាតករណមត្តេន : សំពត់ដែលគ្រាន់តែប្រក់អនុវាតខាងខ្នង គឺ ដោយត្រឹមតែភ្ជាប់អនុវាតផ្នែកបណ្តោយ ។

បទថា បរិភណ្ឌករណមត្តេន : សំពត់ដែលគ្រាន់តែប្រក់អនុវាតខាងពោះ គឺ ដោយត្រឹមតែភ្ជាប់អនុវាតផ្នែកទទឹង ។

បទថា ឱវដ្ដេយ្យករណមត្តេន : សំពត់ដែលគ្រាន់តែដេរគួបគ្នា គឺ ដោយត្រឹមតែបន្ថែមសំពត់ផ្អបផ្ទៃចូល ។

ម្យ៉ាងទៀត ដោយត្រឹមតែកាន់យកសំពត់អំពីចីវរកឋិន ភ្ជាប់ចូល

នូវសំពត់ចីវរកឋិនផ្ទាំងដទៃ ។

បទថា កម្ពលមទ្ទនមត្តេន : **សំពត់ដែលគ្រាន់តែជ្រលក់ម្តង** គឺ ដោយចីវរដែលដាក់ចុះក្នុងទឹកជ្រលក់ត្រឹមតែម្តង មានពណ៌ដូចភ្លុកដំរី ឬមានពណ៌ដូចស្លឹកឈើទុំ ។ តែបើសូម្បីជ្រលក់ម្តង ឬពីរដង ក៏បានពណ៌, សមគួរប្រើបាន ។

បទថា និមិត្តកតេន : **សំពត់ដែលបានមកព្រោះធ្វើនិមិត្ត** គឺ ដោយសំពត់ដែលភិក្ខុធ្វើនិមិត្តយ៉ាងនេះថា យើងនឹងក្រាលកឋិនដោយសំពត់នេះ ។ ពិតមែន ក្នុងគម្ពីរបរិវារៈលោកពោលទុកត្រឹមតែប៉ុណ្ណេះ តែក្នុងអដ្ឋកថាទាំងឡាយពោលថា ដោយសំពត់ដែលភិក្ខុធ្វើនិមិត្តបានមកយ៉ាងនេះថា សំពត់នេះល្អ អាចក្រាលកឋិនដោយសំពត់នេះបាន ។

បទថា បរិកថាកតេន : **សំពត់ដែលបានមកព្រោះនិយាយបញ្ចុះបញ្ចូលគេ** គឺ ដោយសំពត់ដែលភិក្ខុឱ្យកើតឡើងដោយនិយាយបញ្ចុះបញ្ចូលយ៉ាងនេះថា "ការថ្វាយសំពត់កឋិន សមគួរ ទាយកអ្នកប្រគេនសំពត់កឋិន រមែងបានបុណ្យច្រើន" ដែលឈ្មោះថា សំពត់កឋិនជារបស់បរិសុទ្ធិពិត ៗ ទើបសមគួរ សូម្បីមាតារបស់ខ្លួន ក៏មិនគួរសូមបាក់ដូចជាសំពត់ដែលអណ្តែតមកពីអាកាសទុំះឯង ទើបសមគួរ ។

បទថា កុក្កុកតេន : **សំពត់ដែលខ្ចីគេមក** គឺ ដោយសំពត់ដែលខ្ចីមក ។

ក្នុងបទថា សន្និធិកតេន : សំពត់ដែលមិនបានធ្វើឱ្យស្រេចក្នុងថ្ងៃនោះ នេះ សន្និធិមាន ២ យ៉ាង គឺ ករណសន្និធិ ១ និចយសន្និធិ ១ ក្នុងសន្និធិ ២ យ៉ាងនោះ ការរក្សាទុកធ្វើ(ថ្ងៃក្រោយ) មិនធ្វើឱ្យស្រេចក្នុងថ្ងៃនោះតែម្ដង ឈ្មោះថា ករណសន្និធិ ។ សង្ឃបានសំពត់កឋិនក្នុងថ្ងៃនេះ តែប្រគល់ក្នុងថ្ងៃស្អែក នេះឈ្មោះថា និចយសន្និធិ ។

បទថា និស្សគ្គិយេន : សំពត់ដែលឱ្យកន្លងរាត្រី គឺ ដោយសំពត់ដែលធ្វើឱ្យកន្លងរាត្រី ។ សូម្បីក្នុងគម្ពីរបរិវារៈ លោកក៏ពោលថា "និស្សគ្គិយំ នាម ករិយមានេ អរុណំ ឧទ្រយតិ[១] : កាលបើភិក្ខុកំពុងធ្វើ(សំពត់នោះ)អរុណក៏រះឡើង ហៅថា សំពត់ជានិស្សគ្គិយ"[២] ។

បទថា អកប្បកតេន : សំពត់ដែលមិនបានធ្វើពិន្ទុកប្ប គឺ ដោយសំពត់ដែលមិនបានធ្វើកប្បពិន្ទុ ។

ក្នុងពាក្យថា អញ្ញត្រ សង្ឃាដិយា : វៀរចាកសង្ឃាដិ ជាដើម មានសេចក្ដីថា កឋិនដែលក្រាលដោយសំពត់កម្រាលជាដើម ដែលជាសំពត់ដទៃ ក្រៅ អំពីសំពត់សង្ឃាដិ សំពត់ឧត្តរាសង្គៈ និងសំពត់អន្តរវាសកៈ មិនឈ្មោះថា ក្រាល ។

ពាក្យថា អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា :

---

១. ភូមា. ឧដ្ឋហតិ ។ ២. វិន. បរិ. កឋិនភេទ. ១៣. ២១១/២២៩ ។

វៀរចាកចីវរមានមណ្ឌលគ្រប់គ្រាន់ដែលកាត់ដាច់ជាបញ្ចក្ខណ្ឌក្តី លើសពីបញ្ចក្ខណ្ឌក្តី មានសេចក្តីថា កឋិនដែលក្រាលដោយសំពត់ដែលធ្វើជា ៥ ខណ្ឌ ឬច្រើនជាង ៥ ខណ្ឌ សម្តែងមហាមណ្ឌល និងអឌ្ឍមណ្ឌលប៉ុណ្ណោះ ទើបប្រើបាន ។ ដោយថា កាលធ្វើយ៉ាងនោះ ចីវរជាការធ្វើបានមណ្ឌល វៀរចីវរនោះចេញ កឋិនដែលក្រាលដោយសំពត់ដទៃដែលមិនបានកាត់ ឬដោយសំពត់ដែលមានខណ្ឌ ២ មានខណ្ឌ ៣ មាន ខណ្ឌ ៤ ប្រើមិនបាន ។

ពាក្យថា អញ្ញត្រ បុគ្គលស្ស អត្ថារា : មិនឱ្យបុគ្គលក្រាល មានសេចក្តីថា កឋិន មិនឈ្មោះថា ក្រាល ដោយការក្រាលរបស់សង្ឃ ឬរបស់គណៈដទៃ ព្រោះវៀរការក្រាលរបស់បុគ្គលចេញ ។

ពាក្យថា និស្សីមដ្ឋោ អនុមោទតិ : នៅក្រៅសីមា ហើយអនុមោទនា មានសេចក្តីថា ភិក្ខុដែលនៅខាងក្រៅឧបចារសីមា អនុមោទនា ។

[៤] បទថា អហតេន : សំពត់ថ្មី គឺ ដោយសំពត់ដែលមិនទាន់បានប្រើ ។

បទថា អហតកប្បេន : សំពត់ជំនំ គឺ ដោយសំពត់ថ្មី គឺដែលបោកម្តងហើយឬ ២ ដង ។

បទថា បិលោតិកាយ : សំពត់ចាស់ គឺ ដោយសំពត់សាដកចាស់ ។

បទថា បំសុកូលេន : សំពត់បង្សុកូល គឺ ដោយសំពត់បង្សុកូលដែលកើតក្នុងខេត្ត ២៣ ។ ក្នុងកុរុន្ទីនិងមហាបច្ចរីពន្យល់ថា បានដល់ដោយចីវរដែលភិក្ខុកាន់បង្សុកូល ធ្វើដោយសំពត់ដែលខ្លួនត្រាច់សូមបានមក ។

បទថា អាបណិកេន[1] : សំពត់ដែលធ្លាក់ទៀបរានផ្សារ មានសេចក្តីថា ទាយកប្រមូលសំពត់ចាស់ដែលធ្លាក់តាមទ្វារនៃរានផ្សារ ថ្វាយដើម្បីប្រយោជន៍ដល់កឋិន កឋិនដែលក្រាលហើយសូម្បីដោយសំពត់នោះ រមែងប្រើបាន ។

បទដ៏សេស គប្បីជ្រាបដោយសេចក្តីប្លែកពីដែលពោលហើយ ។ តែក្នុងទីនេះ អដ្ឋកថាជាច្រើន បានពោលពាក្យជាដើមថា ធម៌ប៉ុន្មាន រមែងកើតព្រមគ្នានឹងការក្រាលកឋិន ពាក្យទាំងអស់នោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានលើកឡើងកាន់បាលីក្នុងគម្ពីរបរិវារៈទុកហើយពិត; ព្រោះដូច្នោះ គប្បីជ្រាបតាមន័យដែលមកហើយក្នុងគម្ពីរបរិវារៈនោះចុះ ។ ព្រោះថា សេចក្តីណា ៗ នៃការក្រាលកឋិននឹងសាបសូន្យអស់ទៅ ព្រោះមិនពោលពាក្យនោះទុកក្នុងទីនេះ ក៏ទេ ។

---

១. បិដកខ្មែរ. ភូមា. បាបណិកេន ។

# ការដោះកឋិន

[៥] លុះព្រះមានព្រះភាគ ទ្រង់សម្តែងការក្រាលកឋិនយ៉ាងនេះហើយ ឥឡូវនេះ នឹងទ្រង់សម្តែងការដោះ ទើបត្រាស់ពាក្យថា កថញ្ច ភិក្ខវេ ឧព្ភតំ ហោតិ កឋិនំ **: ម្នាលភិក្ខុទាំងឡាយ ឯកឋិននឹងដោះ (នោះ) តើដូចម្តេច ?** ជាដើម

វិនិច្ឆ័យក្នុងពាក្យនោះ គប្បីជ្រាបដូច្នេះ ៖

មាតិកានោះ បានដល់ មាតា អធិប្បាយថា អ្នកបង្កើត ។ ពិតមែន អ្នកបង្កើត គឺ មាតិកា ៨ នោះ ញុំាងការដោះកឋិនឱ្យកើត ។

ក្នុងមាតិកាទាំងនោះ ដែលឈ្មោះថា បក្កមនន្តិកា **: មានការជៀសចេញទៅជាកំណត់** ព្រោះមានការជៀសទៅជាទីបំផុត ។ សូម្បីមាតិកាដ៏សេស ក៏គប្បីជ្រាបយ៉ាងនេះ ។

[៦] បទថា ន បច្ចេស្សំ **: អញនឹងមិនមកវិញទេ** មានសេចក្តីថា យើងនឹងមិនត្រឡប់មកទៀតទេ ។

ក៏ក្នុងការដោះកឋិន មានការជៀសចេញទៅជាកំណត់នេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ពេលក្រោយ ។ ពិតមែន កាលភិក្ខុជៀសចេញទៅយ៉ាងនោះ ចីវរបលិពោធ រមែងដាច់នៅខាងក្នុងសីមាតែម្តង, អាវាសបលិពោធិដាច់នៅ ក្នុងកាលកន្លងសីមាផុតទៅ ។

ពិតណាស់ សូម្បីក្នុងគម្ពីរបរិវារៈ លោកក៏ពោលថា ៖

បក្កមនន្តិកោ កឋិនុទ្ធារោ វុត្តោ អាទិច្ចពន្ធុនា
ឯតញ្ញ តាហំ វិស្សជ្ជិស្សំ ចីវរបលិពោធោ បឋមំ ឆិជ្ជតិ
បច្ឆា អាវាសបលិពោធោ ឆិជ្ជតិ ។

"ការដោះកឋិនគឺអស់អំណាចអានិសង្ស កឋិនមានការចៀសចេញទៅជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះនឹងលោកម្ចាស់ថា ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ជាមួយនឹងដំណើរដែលភិក្ខុនោះទៅខាងក្រៅសីមា"[១] ។

ពីរបទថា ចីវរំ អាទាយ : នាំយកចីវរ មានសេចក្តីថា កាន់យកចីវរដែលមិនទាន់ធ្វើ (ចៀសទៅ)

បទថា ពហិសីមាគតស្ស : ទៅដល់ក្រៅសីមា មានសេចក្តីថា ទៅកាន់វត្តដទៃដែលនៅជិត ។

ពីរបទថា ឯវំ ហោតិ : ត្រិះរិះយ៉ាងនេះ មានសេចក្តីថា សេចក្តីរំពឹងយ៉ាងនោះ រមែងមាន ព្រោះបានឃើញសេនាសនៈ ដែលជាទីសប្បាយ ឬសហាយសម្បត្តិ (ដល់ព្រមដោយសម្លាញ់ក្នុងវត្ត)ក្នុងវត្តនោះ ។

១. វិន. បរិ. កឋិនភេទ. ១៣. ២៣២/២៤៥ ។

ចំណែកការដោះកឋិន មានសេចក្តីសម្រេចជាកំណត់នេះ អាវាស
បលិពោធដាច់មុន ពិតមែន អាវាសបលិពោធនោះ រមែងដាច់ក្នុងកាល
ត្រឹមតែកើតសេចក្តីគិតក្នុងចិត្តឡើងថា "យើងនឹងមិនត្រឡប់មកទេ"
ប៉ុណ្ណោះ ។ សមដូចពាក្យដែលលោកពោលហើយ ក្នុងគម្ពីរបរិវារៈថា ៖

និដ្ឋានន្តិកោ កឋិនុទ្ធារោ វុត្តោ អាទិច្ចពន្ធុនា
ឯតញ្ច តាហំ វិសជ្ជិស្សំ អាវាសបលិពោធោ បឋមំ ឆិជ្ជតិ
ចីវរេ និដ្ឋិតេ ចីវរបលិពោធោ ឆិជ្ជតិ ។

"ការដោះកឋិន មានការធ្វើចីវរស្រេចជាកំណត់ ដែលព្រះ
ពុទ្ធអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមឆ្លើយសេចក្តី
នេះទឹងលោកម្ចាស់ថា អាវាសបលិពោធដាច់មុន កាលបើ
ចីវរសម្រេចហើយ ចីវរបលិពោធទើបដាច់"[១] ។

សូម្បីក្នុងការចែកមាតិកាដ៏សេស គប្បីជ្រាបសេចក្តី ដោយន័យ
នេះ តែ ក្នុងមាតិកាដ៏សេសមានប្លែកគ្នាដូច្នេះ ៖

ក្នុងការដោះកឋិនមានការសន្និដ្ឋានជាកំណត់ បលិពោធទាំងពីរ
រមែងដាច់ព្រមគ្នា ក្នុងកាលត្រឹមតែចិត្តគិតកើតឡើងថា យើងនឹងមិនធ្វើ
ចីវរនេះទេ យើងនឹងមិនត្រឡប់មកទេ ដូច្នេះតែម្តង ។ ពិតមែន ក្នុង

១. វិន. បរិ. កឋិនភេទ. ១៣. ២៣៣/២៤៦ ។

គម្ពីរបរិវារៈលោកក៏ពោលទុកថា ៖

សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ វុត្តោ អាទិច្ចពន្ធុនា
ឯតញ្ច តាហំ វិស្សជ្ជិស្សំ ទ្វេ បលិពោធា អបុព្វំ អចរិមំ
ឆិជ្ជន្តិ ។

ការដោះកឋិនមានសេចក្តីសន្និដ្ឋានជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ, ខ្ញុំសូមឆ្លើយសេចក្តីនេះ ទឹងលោកម្ចាស់ថា បលិពោធទាំង ២ ដាច់មិនមុន មិនក្រោយ ដូច្នេះ ។[១]

ការដាច់បលិពោធក្នុងការដោះកឋិនទាំងពួង គប្បីជ្រាបដោយន័យយ៉ាងនេះ ៖

ក៏ឯសេចក្តីដាច់បលិពោធិនោះ បណ្ឌិតអាចជ្រាបបានតាមន័យដែលពោលនេះ និងតាមដែលមានមកក្នុងគម្ពីរបរិវារៈ, ព្រោះដូច្នោះ ខ្ញុំព្រះករុណាទើបមិនពោលដោយពិស្តារ ។

ចំណែកសេចក្តីសង្ខេបក្នុងកឋិនុទ្ធារ ៥ មាននាសនន្តិកាជាដើមនេះ ដូច្នេះ ៖

ក្នុងការដោះកឋិនដែលមានការវិនាសចីវរជាកំណត់ អាវាសបលិពោធដាច់មុន កាលចីវរវិនាស ចីវរបលិពោធ ទើបដាច់ ។

---

១. វិន. បរិ. កឋិនភេទ. ១៣. ២៣៤/២៤៧ ។

កាលចីវរវិនាស ចីវរបលិពោធទើបដាច់ ព្រោះហេតុណា ហេតុនោះ លោកពោលថា នាសនន្តិកា ដូច្នេះ ។

ដែលមានការឮដំណឹងជាកំណត់ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ព្រមគ្នានឹងការបានឮដំណឹងរបស់ភិក្ខុនោះ ។

ដែលមានសេចក្ដីអស់សង្ឃឹមជាកំណត់ អាវាសបលិពោធដាច់មុន, ចីវរបលិពោធដាច់ក្នុងកាលអស់សេចក្ដីសង្ឃឹមនឹងបានចីវរហើយ ។

ក៏ការដោះកឋិន មានសេចក្ដីអស់សង្ឃឹមជាកំណត់នេះ មានច្រើនប្រភេទ មានការសម្ដែងលាយឡំគ្នា ទៅនឹងការដោះក្រៅអំពីនេះ ដោយន័យជាដើមថា ភិក្ខុរមែងបានក្នុងទីដែលមិនបានសង្ឃឹម, មិនបានក្នុងទីដែលប្រាថ្នា, លោកមានសេចក្ដីរំពឹងយ៉ាងនេះថា "យើងនឹងធ្វើចីវរនេះក្នុងទីនេះឯង, នឹងមិនត្រឡប់ទេ" ដូច្នេះ, ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ចែកត្រាស់ឱ្យពិស្ដារខាងមុខ, មិនត្រាស់ទុកក្នុងលំដាប់នេះ ។ តែបានត្រាស់ការដោះកឋិន មានសេចក្ដីឈានកន្លងសីមាជាកំណត់ជាលំដាប់នៃការដោះកឋិន មានការឮដំណឹងជាទីកំណត់ក្នុងលំដាប់នេះ ។

ក្នុងការដោះកឋិនដែលមានការជៀសចេញទៅជាកំណត់នោះ ចីវរបលិពោធដាច់មុន, អាវាសបលិពោធ រមែងដាច់ចំពោះភិក្ខុនោះនៅក្រៅសីមា ។

ក្នុងការដោះកឋិនដោយសន្និដ្ឋានព្រមព្រៀងគ្នា បលិពោធទាំង ២ ដាច់មិនមុន មិនក្រោយគ្នា ។

[៨] ព្រះមានព្រះភាគ កាលទ្រង់សម្តែងកឋិនុទ្ធារ ៧ ក្នុងអាទាយវារៈយ៉ាងនេះហើយ, ទើបទ្រង់សម្តែងកឋិនុទ្ធារ ៧ ទាំងនោះឯងទៀតនៃចីវរដែលភិក្ខុធ្វើមិនទាន់ស្រេច ក្នុងសមាទាយវារខ្លះ តាមសមគួរក្នុងអាទាយសមាទាយវារៈខ្លះ ។

[១២] ខាងមុខអំពីនោះ ព្រះមានព្រះភាគទ្រង់សម្តែងកឋិនុទ្ធារទាំងឡាយ ដែលសមដោយន័យជាដើមថា អនធិដ្ឋិតេន : **ដោយមិនបាន**តាំងចិត្ត ដែលពាក់ព័ន្ធដល់វិធីនេះថា “ន បច្ចេស្សំ : **អញនឹងមិនត្រឡប់វិញ**” ដូច្នេះប៉ុណ្ណោះ, មិនជាប់ទាក់ទងដល់វិធីនេះ “បច្ចេស្សំ ន បច្ចេស្សំ : **អញនឹងត្រឡប់ខាងក្នុងសីមា អញនឹងមិនត្រឡប់**” ដូច្នេះឡើយ ។

[១៩] ខាងមុខអំពីនោះ កាលទ្រង់សម្តែងកឋិនុទ្ធារដែលមានសេចក្តីអស់សង្ឃឹមជាទីបំផុតច្រើនគ្រា ដោយន័យដែលលាយឡំនឹងកឋិនុទ្ធារក្រៅនេះ ដោយន័យជាដើមថា ចីវរាសាយ បក្កមតិ : **ព្រោះចង់បាន**ចីវរ ហើយទ្រង់សម្តែងកឋិនុទ្ធារទាំងឡាយ ដែលសមគួរក្នុងមាតិកាមានទិដ្ឋានន្តិកាជាដើម ដោយអំណាចនៃភិក្ខុដែលទៅកាន់ទិស និងដោយ

អំណាចនៃភិក្ខុដែលមានសេចក្ដីនៅសប្បាយទៀត ។

[៣២] កាលទ្រង់សម្ដែងកឋិនុទ្ធារ ដោយប្រភេទយ៉ាងនេះហើយ, ឥឡូវនេះ ទឹងទ្រង់សម្ដែងបលិពោធដែលជាបដិបក្ខដល់បលិពោធទាំងឡាយ ដែលត្រាស់ទុកថា "កឋិនុទ្ធារេ បលិពោធា ជិជ្ជន្តិ : បលិពោធទាំងឡាយ រមែងដាច់ ដោយកឋិនុទ្ធារនោះ ៗ"[១] ដូច្នេះ ទើបត្រាស់ពាក្យថា "ទ្វេមេ ភិក្ខវេ កឋិនស្ស បលិពោធា : ម្នាលភិក្ខុទាំងឡាយ បលិពោធរបស់កឋិននេះ មាន ២ យ៉ាង" ដូច្នេះ ជាដើម ។

បណ្ដាបទទាំងនោះ បទថា ចត្តេន : លះបង់ មានសេចក្ដីថា អាវាសនោះ ជាស្ថានទីដែលភិក្ខុលះបង់ហើយ ដោយការលះបង់យ៉ាងណា, ការលះបង់យ៉ាងនោះ, ឈ្មោះថា ភិក្ខុនោះលះបង់ហើយ ដោយការលះបង់នោះ ។

សូម្បីក្នុងវន្តេន : បោលស្រឡះ, និង មុត្តេន : ដាច់អាល័យ, ក៏ន័យនេះឯង ពាក្យដ៏សេសគ្រប់ ៗ ស្ថានងាយយល់ទាំងនោះដូច្នេះឯង ។

## កឋិនក្ខន្ធកវណ្ណនា ចប់ ។

១. ពាក្យនេះ ជាព្រះបំណងរបស់ព្រះអដ្ឋ ។

# ៨. ចីវរក្ខន្ធកវណ្ណនា

## រឿងហ្វជីវក

[៣៤] វិនិច្ឆ័យក្នុងចីវរក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

បទថា បធក្វា : ហើយជាស្រីប្រសប់ បានដល់ វាងវៃ គឺ ឆ្លាត ។

បទថា អភិសដា គឺ អភិគតា : តែងចូលទៅរកច្រើន ។

សួរថា ជនពួកណាទៅរក ?

ឆ្លើយថា ពួកមនុស្សអ្នកមានសេចក្តីត្រូវការ ។

ក៏ព្រះមានព្រះភាគត្រាស់ថា អត្ថិកានំ អត្ថិកានំ មនុស្សានំ : ជាស្រីដែលពួកមនុស្ស ត្រូវការទាំងប៉ុន្មាន ៗ តែងចូលទៅរកច្រើន ដូច្នេះ ព្រោះទ្រង់ប្រើឆដ្ឋីវិភត្តិ ក្នុងអត្ថនៃតតិយាវិភត្តិ ។

ច្រើនបទថា បញ្ញាសាយ ច រត្តឹ គច្ឆតិ : ទៅក្នុងមួយ យប់ ៗ ៥០ កហាបណៈ មានសេចក្តីថា នាងអម្ពបាលីគណិកាទៅក្នុង មួយយប់ ៗ តែងយកទ្រព្យ ៥០ កហាបណៈ ។

បទថា នេគមោ : អ្នកនិគម បានដល់ ពួកកុដុម្ពី ។

ពាក្យថា សាលវតី កុមារី គណិកាំ វុដ្ឋាបេសិ : ក៏បានតាំង

នាងសាលវតីកុមារីឱ្យធ្វើជាស្រីផ្កាមាស មានសេចក្តីថា ពួកអ្នកនគរឱ្យទ្រព្យពីរសែន ព្រះរាជាព្រះរាជទានបីសែន និងដែនកំណាត់ឧទ្យាន និងពាហនៈជាដើមយ៉ាងដទៃហើយ ឱ្យនាងសាលវតីទទួលរាប់រងអធិប្បាយថា ទ្រង់តាំងទុកក្នុងតំណែងនាងនគរសោភិនី ។

ប្រើនបទថា បដិសតេន ច រត្តឹ គច្ឆតិ : ឯនាងនោះទៅក្នុង១យប់ ១០០ កហាបណៈ មានសេចក្តីថា ទៅនៅរួមគ្នាមួយយប់ ៗ ១០០ កហាបណៈ ។

ពីរបទថា គិលានំ បដិវេទេយ្យំ : គួរតែប្រាប់គេថា មានជម្ងឺ មានសេចក្តីថា យើងគប្បីឱ្យជ្រាបភាវៈ ដែលយើងជាអ្នកមានជម្ងឺ ។

បទថា កត្តរសុប្បេ បានដល់ ជិណ្ណសុប្បេ : ក្នុងចង្អេរចាស់ ។

ព្រោះហេតុអ្វី ? ជីវកទើបសួរថា កា មេ ទេវ មាតា កោ បិតា : បពិត្រព្រះសម្មតិទេព អ្នកណាជាមាតារបស់ទូលបង្គំ អ្នកណាជាបិតារបស់ទូលបង្គំ ?

បានឮថា ពួកក្មេង ៗនៃស្តេចដទៃ ដែលលេងជាមួយគ្នា កាលកើតឈ្លោះគ្នាឡើង រមែងពោលទឹងជីវកនោះថា "អាកូនអត់ម៉ែ អត់ឪ" ។

ដូចយ៉ាងថា ក្នុងការឈ្លោះគ្នាកាសស្រពជាដើម ញាតិទាំងឡាយ មាន

ពូនិងមីងជាដើម រមែងបញ្ជូនរបស់ជាទីគាប់ចិត្តណានីមួយ ទៅឱ្យដល់ក្មេងពួកដទៃយ៉ាងណា, ជនឯណានឹងបញ្ជូនរបស់ជាទីគាប់ចិត្តណា ៗ ទៅឱ្យដល់ជីវកនោះ ដូច្នោះ មិនមាន ព្រោះហេតុនោះ គេនឹកដល់ហេតុទាំងពួងនោះហើយ ដើម្បីជ្រាបថា "តើយើងជាអ្នកមិនមានម៉ែឪពិតប្រាកដឬហ្ន៎ ?" ទើបទូលសួរថា "បពិត្រព្រះសម្មតិទេព អ្នកណាជាមាតា អ្នកណាជាបិតារបស់ទូលបង្គំ ?"

ពីរបទថា យន្នូនាហំ សិប្បំ មានសេចក្ដីថា ជីវកគិតថា "បើដូច្នោះ យើងត្រូវសិក្សានូវវិជ្ជាពេទ្យចុះ" ។

បានឮថា គេបានរំពឹងយ៉ាងនេះថា វិជ្ជាហ្វឹកហាត់ដំរី និងវិជ្ជាហ្វឹកហាត់សេះជាដើមទាំងនេះ ជាប់ដោយការបៀតបៀនអ្នកដទៃ ។ ឯវិជ្ជាពេទ្យមានមេត្តាជាចំណែកខាងដើម ជាប់ដោយប្រយោជន៍ជួយដល់សត្វទាំងឡាយ ព្រោះដូច្នោះ គេទើបបំណងយកតែវិជ្ជាពេទ្យ គិតថា "បើដូច្នោះ យើងត្រូវសិក្សាមុខវិជ្ជាចុះ" ។

ម្យ៉ាងទៀត រាប់ពីកប្បនេះទៅមួយសែនកប្ប ជីវកនេះបានឃើញពេទ្យដែលជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា បទុមុត្តរៈ ដែលមានគុណផ្សាយទៅក្នុងខាងក្នុងបរិស័ទទាំងបួនថា "ពេទ្យនេះជាពុទ្ធុបដ្ឋាក" ទើបគិតថា "ធ្វើយ៉ាងណាហ្ន៎ យើងនឹងគប្បីដល់ឋាននូវដូច្នេះខ្លះ ?" ហើយថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានរហូតដល់

អស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះមានព្រះភាគហើយ បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ក្នុងអនាគតកាល "ខ្ញុំព្រះអង្គគប្បីបានជាពុទ្ធបដ្ឋាក ដូចពេទ្យឈ្មោះឯណោះ ដែលជាឧបដ្ឋាករបស់ព្រះអង្គចុះ" ។

ជីវកនោះ ជាអ្នកដែលសេចក្តីប្រាថ្នាតាំងពីដើមនោះ ដាស់តឿនចិត្ត ទើបបំណងសុំដោយកនូវចំណេះវិជ្ជាពេទ្យ គិតថា "បើដូច្នោះ យើងគប្បីសិក្សាចំណេះវិជ្ជាចុះ" ។

[៣៥] បទថា **ទិសាបាមោក្ខោ : ជាទិសាបាមោក្ខ** មានសេចក្តីថា ជាអ្នកដែលមានកេរ្តិ៍ឈ្មោះ គឺ ជាធំ មានអ្នកស្គាល់ទូទៅគ្រប់ទិស ។

ក៏ក្នុងសម័យនោះ ពួកឈ្មួញអ្នកក្រុងតក្កសិលា បានទៅដើម្បីគាល់អភ័យរាជកុមារ ជីវកសួរឈ្មួញទាំងនោះថា "ពួកលោកមកពីណា ?"

គេបានឆ្លើយថា "មកពីក្រុងតក្កសិលា" ។

ទើបសួរថា "ក្នុងក្រុងនោះ មានអាចារ្យបង្រៀនមុខវិជ្ជាពេទ្យទេ ?"

បានស្តាប់ថា "អើ កុមារ ពេទ្យជាទិសាបាមោក្ខ អាស្រ័យនៅក្នុងក្រុងតក្កសិលាមាន" ។

ទើបប្រាប់ថា បើដូច្នោះ "វេលាដែលលោកនឹងទៅ លោកគប្បីប្រាប់យើងផង" ។

ឈ្មួញទាំងនោះ បានធ្វើតាមបណ្តាំ ។ គេមិនទូលលាព្រះបិតា បានទៅក្រុងតក្កសិលានឹងឈ្មួញទាំងនោះ ។ ដោយហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា មិនទូលលាអភ័យរាជកុមារ ជាដើម ។

ច្រើនបទថា ឥច្ឆាមហំ អាចរិយ សិប្បំ សិក្ខិតុំ : បពិត្រលោកអាចារ្យ ខ្ញុំប្រាថ្នានឹងសិក្សាសិល្បសាស្ត្រ មានសេចក្តីថា បានឮថា ពេទ្យនោះឃើញគេចូលទៅរក ។

ទើបសួរថា "ឬា ជាអ្នកណា ?"

គេឆ្លើយថា "ខ្ញុំជាចៅរបស់ព្រះបាទពិម្ពិសារមហារាជ ជាបុត្ររបស់អភ័យរាជកុមារ" ។

ពេទ្យសួរថា "ក៏ហេតុអ្វីហ្ន៎ ទើបបាមកទីនេះ ?"

លំដាប់នោះ គេទើបឆ្លើយថា "ដើម្បីសិក្សាវិជ្ជា ក្នុងសំណាក់របស់លោក" ។ ហើយពោលថា "លោកអាចារ្យ ខ្ញុំចង់សិក្សាមុខវិជ្ជា" ។

ពាក្យថា ពហុញ្ច គណ្ហាតិ : រៀនសិល្បៈសាស្ត្របានច្រើនផង មានសេចក្តីថា សិស្សពួកដទៃ មានខត្តិយរាជកុមារជាដើម ឱ្យទ្រព្យដល់អាចារ្យហើយ មិនធ្វើការងារណា ៗ សិក្សាតែវិជ្ជាប៉ុណ្ណោះ យ៉ាងណា, ជីវកនោះ មិនបានធ្វើយ៉ាងនោះទេ ។ ចំណែកគេមិនឱ្យទ្រព្យណា ៗ ប្រតិបត្តិ ដូចជាធម្មន្តេវាសិកប៉ុណ្ណោះ ធ្វើការងាររបស់ឧបជ្ឈាយ៍ ក្នុង

វេលាមួយ សិក្សាក្នុងវេលាមួយប៉ុណ្ណោះ ។ សូម្បីកាលជាយ៉ាងនោះ កុលបុត្រដល់ព្រមដោយអភិនិហារ ព្រោះខ្លួនជាអ្នកមានបញ្ញា រមែងរៀនបានច្រើន រៀនបានរហ័ស រមែងទ្រទ្រង់ចាំទុកល្អ ទាំងចំណេះវិជ្ជាដែលគេរៀនហើយ រមែងមិនភ្លេចភ្លាំង ។

វិនិច្ឆ័យក្នុងពាក្យថា សត្ត ច មេ វស្សានិ អធិយន្តស្ស នយិមស្សសិប្បស្ស អន្តោ បញ្ញាយតិ : មួយទៀត អាត្មាអញ រៀនអស់ ៧ ឆ្នាំហើយ ក៏ទីបំផុតសិល្បសាស្ត្រមិនប្រាកដសោះ នេះ គប្បីជ្រាបដូច្នេះ ៖

បានឮថា ត្រឹមតែ ៧ ឆ្នាំ ជីវកនេះរៀនវិជ្ជាពេទ្យចប់ ស្មើនឹងអាចារ្យដឹងទាំងអស់ ដែលសិស្សពួកដទៃរៀនដល់ ១៦ ឆ្នាំ ។

ចំណែកស្តេចសក្កទេវរាជ បានមានព្រះរំពឹងយ៉ាងនេះថា "ជីវកនេះនឹងជាឧបដ្ឋាក ជាអ្នកមានសេចក្តីជិតដិតយ៉ាងកំពូលរបស់ព្រះពុទ្ធណ្ហើយចុះ យើងនឹងឱ្យគេសិក្សាការផ្សំថ្នាំ" ។ ទើបចូលស្ថិតក្នុងសរីរៈរបស់អាចារ្យ ឱ្យជីវកនោះសិក្សាការផ្សំថ្នាំ ដោយវិធីដែលពេទ្យអាចព្យាបាលរោគ មិនមានសេសសល់ វៀរលែងតែវិបាករបស់កម្មចេញ ឱ្យជាសះស្បើយដោយការផ្សំថ្នាំកំរិតតែមួយប៉ុណ្ណោះ ។

ចំណែកគេសម្គាល់ថា "យើងរៀនក្នុងសំណាក់អាចារ្យ" ព្រោះ

ដូច្នោះ លុះមស្តេចសក្កៈចេញទៅដោយទ្រង់ត្រិះរិះថា "ឥឡូវនេះ ក៏ជីវក អាចដើម្បីផ្សំថ្នាំព្យាបាលបាន" គេទើបគិតយ៉ាងនោះ ហើយសួរអាចារ្យ ។

ចំណែកអាចារ្យជ្រាបច្បាស់លុះថា "ជីវកនេះ មិនបានរៀនវិជ្ជាពេទ្យដោយអានុភាពរបស់យើងទេ រៀនដោយអានុភាពរបស់ទេវតា" ទើបពោលពាក្យជាដើមថា តេនហិ ភណេ : នែនាយ បើដូច្នោះ ។

បីបទថា សមន្តា យោជនំ អាហិណ្ឌន្តោ : ដើរទៅចំនួន ១ យោជន៍ មានសេចក្តីថា ចេញតាមច្រកទ្វារមួយ ៗ ( ទាំង ៤ ទិស ) ក្នុងមួយថ្ងៃ ៗ ហើយត្រាច់ទៅរហូតដល់អស់ ៤ ថ្ងៃ ។

បីបទថា បរិត្តំ ឞាថេយ្យំ ឞាទាសិ[១] : ក៏ប្រគល់ស្បៀងបន្តិចបន្តួច មានសេចក្តីថា បានឱ្យស្បៀងមានប្រមាណតិច ។

ព្រោះហេតុអ្វី ?

បានឮថា ពេទ្យដែលជាអាចារ្យនោះ បានត្រិះរិះយ៉ាងនេះថា ជីវកនេះជាបុត្ររបស់មហាត្រកូល លុះមទៅដល់ប៉ុណ្ណោះ នឹងបានសក្ការៈដ៏ច្រើនអំពីសំណាក់បិតានិងជីតា ហេតុនោះ គេនឹងមិនដឹងគុណរបស់យើង ឬរបស់វិជ្ជា តែគេអស់ស្បៀងក្នុងចន្លោះមកហើយនឹងត្រូវប្រើចំណេះវិជ្ជា ហើយនឹងដឹងគុណរបស់យើង និងរបស់វិជ្ជាពិតប្រាកដ ព្រោះហេតុនោះ ទើបឱ្យស្បៀងតែបន្តិចបន្តួច ។

---

១. ថៃ. អទាសិ ។

[៣៦] បទថា បសតេន[១] : ដោយទូកដៃ គឺ មួយទូកដៃ ។

បទថា បិច្ឆា សំឡី គឺ សំឡីកប្បាស ។

បទថា យត្រ ហិ ឆាម គឺ ឈ្មោះអ្វី ?

បទថា កិម្បិមាយំ កាត់បទជា កិម្បិ មេ អយំ : ស្រីជាម្ចាស់ផ្ទះនេះ ... ដល់អញដូចម្ដេចបាន ។

ពីរបទថា ឧបជានាមេតស្ស សញ្ញមស្ស : គួរចេះសំចៃសប្បិនេះ សប្បិនេះនឹងធ្វើជាថ្នាំ ដូច្នេះ បំណងយកសេចក្ដីថា យើងទាំងឡាយ ដឹងនូវឧបការៈនៃពេទ្យដែលធ្វើហើយផង នៃរោគដែលស្ងប់ទៅផង ។

[៣៧] បីបទថា សព្វាលង្ការំ តុយ្ហំ ហោតុ : គ្រឿងអលង្ការទាំងពួងនេះ ត្រូវបានអ្នកឯងហើយ មានសេចក្ដីថា បានឮថា ព្រះរាជាទ្រង់ត្រិះរិះថា បើថា ហ្មជីវកនឹងកាន់យកគ្រឿងប្រដាប់ទាំងពួងនេះសោត យើងនឹងតាំងគេក្នុងតំណែងល្មមប្រមាណ; បើថា គេនឹងមិនទទួលយកសោត យើងនឹងតាំងគេឱ្យជាអ្នកស្និទ្ធស្នាលខាងក្នុងរាជវាំង ដូច្នេះ ទើបត្រាស់យ៉ាងនោះ ។

អភ័យរាជកុមារក្ដី ពួកនាងរបាំទាំងឡាយក្ដី កើតគំនិតថា "ដូច

១. ថៃ. បសទេន ។

ម្តេចហ្ន៎ ជីវកទឹងមិនគប្បីកាន់យក ?” សូម្បីគេក៏សង្កេតមើលដូចទឹង ជ្រាបនូវគំនិតរបស់ជនទាំងនោះ ទើបក្រាបទូលថា “បពិត្រព្រះសម្មតិទេព នេះជាគ្រឿងប្រដាប់របស់អយ្យិកាទូលបង្គំ ដែលគ្រឿងប្រដាប់នេះ មិនសមគួរដល់ទូលបង្គំទទួលទុកទេ” ដូច្នេះហើយ ក្រាបទូលថា អលំ ទេវ : បពិត្រព្រះទេវ កុំព្រួយ ជាដើម ។

ប្រើនបទថា អធិការំ មេ ទេវោ សរតុ : សូមព្រះសម្មតិទេពទ្រង់គ្រាន់តែរលឹកឧបការរបស់ខ្ញុំព្រះអង្គចុះ មានសេចក្តីថា សូមទ្រង់រលឹកដល់ឧបការៈនៃកិច្ចការដែលទូលបង្គំបានធ្វើទុក ។

ព្រះរាជាទ្រង់ជ្រះថ្លា ព្រះរាជទានផ្ទះព្រមដោយគ្រឿងប្រដាប់ទាំងពួង សួនអម្ពវ័ន ស្រុកមានចំណែកមួយសែនប្រចាំឆ្នាំ និងសក្ការៈដ៏ច្រើន ហើយត្រាស់ពាក្យជាដើមថា តេនហិ ភណេ : នែនាយ បើដូច្នោះ ។

# រឿងរាជគហសេដ្ឋី

[៣៨] សួរថា ហេតុអ្វីបានជាជីវកោមារភត្តពោលថា នែគហបតីលោកអាចនឹងសម្រាន្តផ្អៀងតែម្ខាងអស់ ៧ ខែបានឬទេ ?

ឆ្លើយថា ជីវកោមារភត្តដឹងថា បានឮមកថា ខួរក្នុងក្បាលមិនតាំងនៅស៊ប់ ដោយការប្រព្រឹត្តទៅនៃឥរិយាបថទេ តែកាលបើគហបតីនោះ

ដេកមិនកម្រើកអស់ ៧ ថ្ងៃ បីដង ខួរក្នុងក្បាលនឹងតាំងនៅស៊ប់វិញ ហើយពោលនឹងគហបតីនោះយ៉ាងនេះ ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ គេគប្បីដឹងថា អស់៧ខែ ៗ ហើយសម្រាន្តត្រឹមតែ ៧ ថ្ងៃ ៗ ប៉ុណ្ណោះ ។ ព្រោះហេតុនោះឯង ពេទ្យជីវក ទើបពោលខាងមុខថា "អបិ ច បដិកាច្ចេវ មយា ញាតោ : ម្យ៉ាងទៀត យើងបានដឹងពីមុនហើយ ។

ពីរបទថា សីសច្ឆវឹ ឧប្បាដេត្វា : រះស្បែកក្បាល បានដល់ស្បែកសិរសៈ ។

ពីរបទថា សិព្វិនី វិនាមេត្វា : វែកថ្នេរ បានដល់ បើកស្នាមថ្នេរលលាក្បាល ។

ច្រើនបទថា ឆាហំ អាចរិយ សក្កោមិ : លោកអាចារ្យ ខ្ញុំមិនអាច... បានទេ មានសេចក្ដីថា បានឮថា សេចក្ដីក្ដៅក្រហាយខ្លាំង កើតឡើងក្នុងសរីរៈរបស់សេដ្ឋីនោះ, ព្រោះហេតុនោះ គេទើបពោលយ៉ាងនោះ ។

ពីរបទថា តីហិ សត្តាហេន : ដល់គ្រប់ ៧ ថ្ងៃ ៣ ដង គឺ ៣ ខាង, ម្ខាង ៗ មួយសប្ដាហ៍ ។

[៣៩] ពីរបទថា ឆនំ ឧស្សារេត្វា : បណ្ដេញជនឱ្យដើរចេញ គឺ ឱ្យដេញជនចេញទៅ ។

# រឿងព្រះបាទចណ្ឌបជ្ជោត

[៤០] បីបទថា ជេគុច្ឆំ មេ សប្បិ ៖ ដ្បិតសប្បិជាទីខ្ពើរអើមរបស់ខ្ញុំ មានសេចក្តីថា បានឮថា ព្រះរាជានេះមានកំណើតនៃសត្វខ្ទួយ, ទឹកដោះថ្លាជាថ្នាំ និងជារបស់បដិកូលនៃសត្វខ្ទួយទាំងឡាយ ព្រោះកម្ចាត់ពិសសត្វខ្ទួយចេញ; ព្រោះដូច្នោះ ស្តេចទើបប្រាប់យ៉ាងនោះ ។

ពីរបទថា ឧទ្ទេកំ ទស្សតិ ៖ មុខជានឹងចង្អោរចេញ គឺ នឹងឱ្យក្អួត ។

ពីរបទថា បញ្ញាសយោជនិកា ហោតិ ៖ អាចដើរទៅបាន ៥០ យោជន៍ មានសេចក្តីថា ដំរីញីឈ្មោះភទ្ទវតិកា ជាពាហនៈអាចធ្វើដំណើរបាន ៥០ យោជន៍ (ក្នុងមួយថ្ងៃ) ។

តែព្រះរាជានោះ នឹងមានតែដំរីញីតែម៉្យាងប៉ុណ្ណោះ ក៏ទេ, សូម្បីដំរីឈ្មោល ឈ្មោះ នាឡាគិរី រមែងធ្វើដំណើរបាន ១០០ យោជន៍ ។ សេះ ២ គឺ វេលុកណ្ណៈ មួយ មុញ្ជកេសៈមួយ រមែងធ្វើដំណើរបាន ១២០ យោជន៍ ។ ទាសឈ្មោះកាកៈ រមែងធ្វើដំណើរបាន ៦០ យោជន៍ ។

បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើងនៅឡើយ ថ្ងៃមួយ

កាលកុលបុត្រម្នាក់អង្គុយដើម្បីនឹងបរិភោគ ព្រះបច្ចេកពុទ្ធឈរត្រង់ទ្វារ ហើយបានចេញទៅ ។ បុរសម្នាក់ ប្រាប់ដល់កុលបុត្រនោះថា "ព្រះបច្ចេកពុទ្ធមកហើយចេញទៅ" ។ កុលបុត្រនោះ បានស្តាប់ទើបប្រាប់ថា "លោកចូរទៅ, ចូរនាំបាត្រមកដោយរហ័ស" ដូច្នេះ ឱ្យនាំបាត្រមកហើយ ឱ្យភត្តដែលត្រៀមទុកសម្រាប់ខ្លួនទាំងអស់បញ្ជូនទៅ ។

បុរសក្រៅនេះ នាំបាត្រនោះ បញ្ជូនទៅដល់ដៃរបស់ព្រះបច្ចេកពុទ្ធ ហើយបានធ្វើសេចក្តីប្រាថ្នាថា "បពិត្រលោកដ៏ចម្រើន ដោយប្រកបសេចក្តីខ្វល់ខ្វាយមកកាយ ដែលខ្ញុំព្រះករុណាធ្វើដល់លោកម្ចាស់នេះ ខ្ញុំព្រះករុណាកើតក្នុងទីណា ៗ សូមឱ្យជាអ្នកសម្បូរណ៍ដោយពាហនៈចុះ" ។ បុរសនោះ បានកើតជាព្រះរាជាទ្រង់ព្រះនាមថា ចណ្ឌប្បជ្ជោតនេះ[1] ក្នុងកាលឥឡូវនេះ, ការសម្បូរណ៍ដោយពាហនៈនេះ មានដោយសេចក្តីប្រាថ្នានោះ ។

ពីរបទថា សប្បឹ ធាយេត្វា : សោយសប្បិរួចហើយ គឺ ឱ្យផឹកទឹកដោះថ្លាដោយប្រាប់វិធីចាត់អាហារដល់នាងបម្រើទាំងឡាយផង ។

បីបទថា នខេន ភេសជ្ជំ ឱលុម្បេត្វា : បានបង់ថ្នាំដោយក្រចក

១. មើលរឿងក្នុងសាមាវតីវត្ថុ អប្បមាទវគ្គ ធម្មបទដ្ឋកថា ។

គឺ ចុចថ្នាំចូលដោយក្រចក, អធិប្បាយថា ដាក់ ។

បទថា និច្ឆារេសិ : ក៏ចុះរាក បានដល់ វិរេចេសិ រាករូសខ្លាំង ហើយ ។

សំពត់អព្ភមង្គល ដែលគេចោលក្នុងព្រៃជាទីចោលសាកសពក្នុង ឧត្តរកុរុទ្វីប ឈ្មោះសំពត់សិវេយ្យកៈ ។ បានឮថា មនុស្សទាំងឡាយក្នុង ទ្វីបនោះ យកសំពត់នោះឯង រុំក្រសោបមនុស្សស្លាប់ហើយបោះចោល ។ បក្សីហត្ថិសោណ្ឌកទាំងឡាយ កំណត់រម្មូរមនុស្សស្លាប់នោះថា ដុំសាច់ ហើយឆាបនាំទៅដាក់លើកំពូលភ្នំហិមពាន្ត កកាយសំពត់ចេញហើយ ស៊ី ។ គ្រានោះពួកព្រានព្រៃចូលទៅជួបសំពត់ ហើយនាំមកថ្វាយព្រះ រាជា ។ សំពត់សិវេយ្យកៈ ជារបស់ដែលព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ បានហើយ ដោយប្រការយ៉ាងនេះ ។

អាចារ្យពួកខ្លះពោលថា ស្រីឆ្លាតក្នុងដែនសិវិត្បាញអំបោះដោយ រោមសត្វ ៣ សរសៃ, សំពត់សិវេយ្យកៈនោះ ជាសំពត់ដែល ត្បាញដោយអំបោះនោះ ដូច្នេះ ។

# ទ្រង់អនុញ្ញាតសំពត់ជាវារជាដើម

[៤១] បទថា សិនេហេថ : សម្រួល មានសេចក្ដីថា ក៏ព្រះកាយរបស់ព្រះមានព្រះភាគសៅហ្មង ឬមិនសៅហ្មង ។ ព្រោះថា ទេវតាទាំងឡាយ រមែងដាក់ទិព្វឱជាក្នុងអាហាររបស់ព្រះមានព្រះភាគគ្រប់កាល, ក៏ប៉ុន្តែថា ទឹកជរ រមែងញាំងទោសទាំងឡាយ ឱ្យជោគជាំនៅក្នុងព្រះសរីរៈទាំងអស់ ។ រមែងធ្វើសរសៃល្អិតទាំងឡាយ ឱ្យថយកម្លាំង; ដោយហេតុនោះ ហ្មជីវកនេះ ទើបពោល យ៉ាងនោះ ។

ពីរបទថា តីណិ ឧប្បលហត្ថានិ : ផ្កាឧប្បល ៣ ក្ដាប់ មានសេចក្ដីថា ឧប្បលមួយក្ដាប់ ដើម្បីបំបាត់ទោសយ៉ាងគ្រោតគ្រាត មួយក្ដាប់ដើម្បីបំបាត់ទោសយ៉ាងកណ្ដាល, មួយក្ដាប់ដើម្បីបំបាត់ទោសយ៉ាងល្អិត ។

ច្រើនបទថា នចិរស្សេវ បកតត្តោ អហោសិ : មិនយូរប៉ុន្មានកាយរបស់ព្រះមានព្រះភាគ ក៏ជាប្រក្រតីឡើងវិញ មានសេចក្ដីថា ក៏កាលព្រះកាយជាប្រក្រតីហើយយ៉ាងនោះ អ្នកក្រុងទាំងឡាយបានត្រៀមទានទុក ។ ហ្មជីវកមកហើយបានក្រាបទូលសេចក្ដីនេះចំពោះព្រះមានព្រះភាគថា "បពិត្រព្រះមានព្រះភាគថ្ងៃនេះ ពួកអ្នកក្រុងប្រាថ្នានឹងថ្វាយទានចំពោះព្រះអង្គ, សូមព្រះអង្គស្ដេចចូលកាន់ចន្លោះស្រុក ដើម្បីបិណ្ឌបាតចុះ" ។ ព្រះមហាមោគ្គល្លានត្ថេរគិតថា "ថ្ងៃនេះ ព្រះមានព្រះភាគសមគួរ

បានបឋមបិណ្ឌបាត អំពីទីណាហ្ន៎ ?" លំដាប់នោះ លោកគិតថា "សោណសេដ្ឋីបុត្រ ចាប់ផ្ដើមតាំងពីធ្វើស្រែមក រមែងបរិភោគបាយនៃស្រូវសាលីក្រអូប ដែលថែរក្សាដោយស្រោចទឹកដោះស្រស់ មិនសាធារណៈដោយពួកជនដទៃ យើងនឹងនាំបិណ្ឌបាតអំពីសោណសេដ្ឋីបុត្រនោះ មកដើម្បីព្រះមានព្រះភាគ លោកទៅដោយឫទ្ធិ សម្ដែងខ្លួនលើផ្ទៃប្រាសាទរបស់សោណសេដ្ឋីបុត្រនោះ ។ គេបានទទួលបាត្ររបស់ព្រះថេរៈហើយ ថ្វាយបិណ្ឌបាតយ៉ាងប្រណីត, និងបានឃើញអាការនឹងទៅរបស់ព្រះថេរៈ ទើបពោលថា "និមន្តឆាន់ចុះ លោកម្ចាស់" ។ ព្រះថេរៈប្រាប់សេចក្ដីនោះ ។ គេពោលថា "និមន្តឆាន់ចុះ លោកម្ចាស់, ខ្ញុំព្រះករុណា នឹងថ្វាយ ចំណែកដទៃចំពោះព្រះមានព្រះភាគ" ឱ្យព្រះថេរៈឆាន់ហើយ បានអប់បាត្រដោយគ្រឿងក្រអូបហើយថ្វាយបិណ្ឌបាត ។ ព្រះថេរៈ បាននាំបាត្រនោះ មកថ្វាយព្រះមានព្រះភាគ ។ សូម្បីព្រះបាទពិម្ពិសារ ក៏ទ្រង់ត្រិះរិះថា "ថ្ងៃនេះព្រះមានព្រះភាគនឹងសោយអ្វី ?" ទើបស្ដេចមកវិហារលុះស្ដេចចូលទៅ ក៏ទ្រង់ជុំក្លិនបិណ្ឌបាត បានជាអ្នកមានព្រះប្រាថ្នានឹងសោយ ។ ក៏ទេវតាទាំងឡាយ ដាក់ឱជាក្នុងបិណ្ឌបាតរបស់ព្រះមានព្រះភាគ ដែលនៅក្នុងភាជនៈ ២ ដងប៉ុណ្ណោះ គឺ បិណ្ឌបាតដែលនាងសុជាតាថ្វាយ ១ ដែលនាយចុន្ទកម្មារបុត្របានថ្វាយ ក្នុងកាលបរិព្វាន ១, ក្នុងបិណ្ឌបាតដទៃ ៗ បានដាក់ម្ដងមួយពុំនូត ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់បានជ្រាបសេចក្តីចង់របស់ព្រះរាជា ទើបបង្គាប់ឱ្យថ្វាយបិណ្ឌបាតបន្តិចបន្តួច ដែលទេវតាមិនទាន់បានដាក់ឱជាចុះដល់ព្រះរាជា ។ ស្តេចសោយហើយទូលសួរថា “ភោជននេះនាំមកពីឧត្តរកុរុទ្វីបឬ ព្រះអង្គ ?” ព្រះមានព្រះភាគត្រាស់ថា “មហាបពិត្រ មិនបាននាំមកពីឧត្តរកុរុទ្វីបទេ, តាមពិតនេះ ជាភោជនរបស់គហបតីបុត្រ ជាអ្នកនៅក្នុងដែនរបស់ព្រះអង្គទ៊ុំះឯង” ដូច្នេះហើយ ទ្រង់ប្រាប់សម្បត្តិរបស់សោណៈ ។ ព្រះរាជាទ្រង់ស្តាប់សេចក្តីនោះហើយមានព្រះបំណងនឹងទតមើលសោណ ទ្រង់បានធ្វើការអញ្ជើញមករបស់សោណៈព្រមដោយកុលបុត្រ ៨ ម៉ឺននាក់ តាមន័យដែលពោលហើយក្នុងចម្មក្ខន្ធកៈ ។ កុលបុត្រទាំងនោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ហើយ បានសម្រេចជាព្រះសោតាបន្ន ។ ចំណែកសោណៈបួសហើយតាំងនៅ ក្នុងព្រះអរហត្ត ។ ចំណែកព្រះមានព្រះភាគត្រាស់បង្គាប់ឱ្យថ្វាយ បិណ្ឌបាតដល់ព្រះរាជាក៏ដើម្បីប្រយោជន៍នេះឯង ។

កាលព្រះមានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយយ៉ាងនោះ, លំដាប់នោះឯង ពេទ្យជីវកកោមារភត្ត កាន់គូសំពត់សិវេយ្យកៈនោះហើយ ។ល ។ បានក្រាបទូលសេចក្តីនោះ ។

វិនិច្ឆ័យក្នុងពាក្យថា **អតិក្កន្តវរា : មានពរកន្លងហើយ** នេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងមហាខន្ធកៈនោះឯង ។

ពាក្យថា ភគវា ភន្តេ បង្សុកូលិកោ ភិក្ខុសង្ឃោ ច : សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគក្តី ភិក្ខុសង្ឃក្តីតែងទ្រទ្រង់សំពត់បង្សុកូល មានសេចក្តីថា ពិតមែន ក្នុងចន្លោះនេះ គឺ តាំងពីព្រះមានព្រះភាគដល់ភាពជាព្រះពុទ្ធ ដរាបដល់រឿងនេះកើតឡើង ជាវេលា ២០ ឆ្នាំ, ភិក្ខុណា ៗ មិនត្រេកអរគហបតីចីវរ, ភិក្ខុទាំងពួងបាន ជាអ្នកកាន់បង្សុកូលប៉ុណ្ណោះ; ដោយហេតុនោះ ពេទ្យជីវកនេះ ទើបក្រាបទូលយ៉ាងនោះ ។

បទថា គហបតិចីវរំ : គហបតិចីវរ បានដល់ ចីវរដែលគហបតីទាំងឡាយថ្វាយ ។

ពីរបទថា ធម្មិយា កថាយ : ដោយធម្មីកថា គឺ ពាក្យដែលប្រកបព្រមដោយអានិសង្សនៃការថ្វាយសំពត់ ។

បទថា ឥតរិតរេនាបិ : ដោយបច្ច័យណាមួយ គឺ មានតម្លៃតិចក៏ដោយ មានតម្លៃច្រើនក៏ដោយ, សេចក្តីថា យ៉ាងណាទីមួយ ។ សំពត់ដណ្តប់ដែលធ្វើដោយកប្បាសប្រភេទដែលមានរោម ឈ្មោះថា សំពត់បាវារ ។

[៤៣] ក្នុងពាក្យថា អនុជានាមិ ភិក្ខវេ កោជវំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលព្រំ នេះ មានសេចក្តីថា កម្រាលព្រំ

គឺ កម្រាលក្រាលតាមប្រក្រតីប៉ុណ្ណោះ ទើបគួរ, កម្រាលព្រំផ្ទាំងធំ មិនគួរ ។ កម្រាលព្រំនោះ ធ្វើដោយរោមសត្វស្រដៀងសំពត់បាវារ ។

## ទ្រង់អនុញ្ញាតចីវរ ៦ ប្រភេទ

[៤៤] ព្រះបាទកាសីនោះ គឺ ព្រះរាជានៃអ្នកដែនកាសី, ស្ដេចជាប្អូនរួមព្រះបិតាតែមួយជាមួយនឹងព្រះបាទបសេនទិ ។

វិនិច្ឆ័យក្នុងបទថា អឌ្ឍកាសិយំ : មានតម្លៃប្រាំរយកហាបណៈនេះ គប្បីជ្រាបដូច្នេះ ៖

មួយពាន់ហៅថា មួយកសិ, សំពត់កម្ពលមានតម្លៃមួយពាន់ ឈ្មោះថា មានតម្លៃមួយកសិ; តែសំពត់កម្ពលផ្ទាំងនេះ មានតម្លៃ ៥០០, ព្រោះដូច្នោះ លោកទើបពោលថា មានតម្លៃកន្លះកាសិ; ដោយហេតុនេះឯង ព្រះឧបាលីថេរៈទើបពោលថា គួរដល់តម្លៃកន្លះកាសិ ។

[៤៥] បទថា ឧច្ចាវចានិ : ខ្ពស់និងទាប គឺ ស្អាតនិងមិនស្អាត ឬល្អនិងមិនល្អ ។ សំពត់ដែលធ្វើលាយគ្នាដោយអំបោះ ៥ ប្រភេទ មានអំបោះសំបកឈើជាដើម ឈ្មោះថា សំពត់ភង្គៈ អាចារ្យពួកខ្លះពោលថា សំពត់ដែលធ្វើដោយធ្មៃប៉ុណ្ណោះ ដូច្នេះខ្លះ ។

ពាក្យថា ឯកំយេវ ភគវតា ចីវរំ អនុញ្ញាតំ ន ទ្វេ : ព្រះមានព្រះភាគអនុញ្ញាតតែចីវរមួយ មិនអនុញ្ញាតចីវរពីរទេ មានសេចក្ដីថា បានឮថា ភិក្ខុទាំងនោះ កំណត់សេចក្ដីនៃបទមួយថា "ដោយចីវរតាមមាន

តាមបាន" យ៉ាងនេះថា ដោយគហបតីចីវរ ឬដោយសំពត់បង្សុកូល ។

[៤៦] បទថា ឆាគមេសុំ : **មិនបានរង់ចាំ** មានសេចក្តីថា ភិក្ខុទាំងនោះ មិននៅចាំ ដរាបដល់ពួកលោកមកពីព្រៃជាទីចោលសាកសព, គឺ ជៀសចេញទៅមុន ។

បីបទថា ឆាគាមា ភាគំ ធាតុំ : **មិនប្រាថ្នានឹងឱ្យ ក៏កុំឱ្យនូវចំណែក** មានសេចក្តីថា មិនប្រាថ្នានឹងឱ្យ ក៏កុំឱ្យ, តែបើប្រាថ្នានឹងឱ្យសោត, គួរឱ្យ ។

បទថា អាគមេសុំ : **បានរង់ចាំ** គឺ នៅរង់ចាំក្នុងទីជិត ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលទុកជាមិនចង់ឱ្យ ក៏ត្រូវឱ្យចំណែកដល់ភិក្ខុទាំងឡាយដែលរង់ចាំ" ។ ក៏បើថា មនុស្សទាំងឡាយថ្វាយថា "លោកម្ចាស់ទាំងឡាយ ដែលមកទីនេះប៉ុណ្ណោះ ចូរកាន់យក", ឬធ្វើគ្រឿងសំគាល់ទុកថា "លោកដ៏មានអាយុទាំងឡាយ អ្នកមកដល់ហើយ ចូរកាន់យក" ដូច្នេះហើយចេញទៅ; ចីវររមែងត្រូវបានដល់ភិក្ខុគ្រប់រូប អ្នកមកដល់ហើយ ។ បើគេចោលទុកហើយចេញទៅ, ភិក្ខុដែលកាន់យកប៉ុណ្ណោះជាម្ចាស់របស់ ។

ពីរបទថា សធិសា ឱក្កមីសុ : **ដែលចូលទៅកាន់ព្រៃស្មសានព្រមគ្នា** មានសេចក្តីថា ចូលទៅគ្រប់រូប, ឬចូលទៅដោយទិសតែមួយ

រួមគ្នា ។

ប្រើនបទថា តេ កតិកំ កត្វា : ភិក្ខុទាំងនោះបានធ្វើការបេ្តជ្ញា មានសេចក្តីថា ភិក្ខុទាំងនោះ ធ្វើកតិកាគ្នាទុកតាំងពីខាងក្រៅថា យើងនឹងបែងចែកសំពត់បង្សុកូលដែលបានហើយកន់យកគ្រប់គ្នា ។

## អ្នកទទួលចីវរជាដើម

[៤៧] បទថា ចីវរបដិគ្គាហកំ : ឱ្យជាអ្នកទទួលចីវរ បានដល់ ភិក្ខុជាអ្នកទទួលចីវរដែលគហបតីទាំងឡាយថ្វាយដល់សង្ឃ ។

វិនិច្ឆ័យក្នុងពាក្យថា យោ ន ឆន្ទាគតឹ គច្ឆតិ : ភិក្ខុមិនបានលុះឆន្ទាគតិ ជាដើម គប្បីជ្រាបដូច្នេះ ៖

ក្នុងភិក្ខុដែលមាននាទីទទួលចីវរ ភិក្ខុទទួលរបស់បិយជនទាំងឡាយ មានញាតិជាដើមរបស់ខ្លួនមុន សូម្បីមកខាងក្រោយគេ, ឬទទួលសម្តែងសេចក្តីពេញចិត្តក្នុងទាយកខ្លះ ។ ឬបង្អោនមកដើម្បីខ្លួន ដោយភាពជាអ្នកមានលោភជាប្រក្រតី, ឈ្មោះថា ដល់សេចក្តីលំអៀង ព្រោះសេចក្តីស្រឡាញ់ ។ ភិក្ខុណាទទួលខាងក្រោយនូវរបស់ទាយកសូម្បីមកមុន ដោយអំណាចសេចក្តីក្រោធ, ឬទទួលធ្វើអាការមើលងាយអ្នកក្រីក្រ ។ ឬធ្វើលាភន្តរាយដល់សង្ឃយ៉ាងនេះថា "ទីរក្សាក្នុងផ្ទះរបស់លោកមិនមានឬ, លោកចូរកាន់យករបស់លោកទៅចុះ" ភិក្ខុនេះ ឈ្មោះ

ថា **ដល់សេចក្ដីលំអៀង ព្រោះសេចក្ដីស្អប់** ។ ចំណែកភិក្ខុណា វង្វេងភ្លេចសតិ មិនដឹងខ្លួន ភិក្ខុនេះ ឈ្មោះថា **ដល់សេចក្ដីលំអៀង ព្រោះល្ងង់** ភិក្ខុដែលទទួលរបស់ឥស្សរជនទាំងឡាយមុន សូម្បីមកក្រោយ ព្រោះសេចក្ដីខ្លាច, ឬសេចក្ដីតក់ស្លុតថា “តំណែងអ្នកទទួលចីវរនេះធ្ងន់ណាស់”, ឈ្មោះថា **ដល់សេចក្ដីលំអៀង ព្រោះខ្លាច**, ភិក្ខុដែលដឹងប្រាកដថា ចីវរនេះផង នេះផង យើងទទួលហើយ, និងចំណែកនេះ យើងមិនបានទទួល ឈ្មោះថា **ស្គាល់ចីវរដែលទទួល ហើយនិងមិនបានទទួល** ព្រោះហេតុនោះ ភិក្ខុណា មិនលំអៀង ដោយអំណាចនៃឆន្ទាគតិជាដើម, ទទួលតាមលំដាប់អ្នកមក មិនធ្វើឱ្យប្លែកគ្នាក្នុងអ្នកដែលជាញាតិ និងមិនមែនញាតិ អ្នកមាននិង អ្នកក្រ ជាអ្នកប្រកបដោយសីលាចារ បដិបត្តិ មានសតិ បញ្ញា ជាពហុស្សូត, អាចដើម្បីធ្វើអនុមោទនាដោយបទ និងព្យញ្ជនៈដែលរៀបរយ ដោយវាចាដ៏ពីរោះរណ្ដំ ញុំាងសេចក្ដីជ្រះថ្លាឱ្យកើតដល់ទាយកទាំងឡាយ; ភិក្ខុបែបនេះ សង្ឃគួរសន្មត ។

ក៏វិនិច្ឆ័យក្នុងពាក្យថា ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ : ម្នាលភិក្ខុទាំងឡាយ **ត្រូវសង្ឃសន្មតយ៉ាងនេះ** នេះគប្បីជ្រាបដូច្នេះ ៖

សមគួរពិតដែលនឹងសន្មតនៅកណ្ដាលសង្ឃទាំងពួង ខាងក្នុងវត្តក៏បាន ក្នុងខណ្ឌសីមាក៏បាន ដោយកម្មវាចាតាមដែលត្រាស់នោះក៏បាន

ដោយអបលោកន៍ក៏បាន ក៏ភិក្ខុដែលសង្ឃសន្មតហើយយ៉ាងនោះ មិនគប្បីនៅក្នុងកុដិជាលំនៅខាងចុងបង្អស់ ឬក្នុងទីធ្វើសេចក្តីព្យាយាម ។ ក៏ប៉ុន្តែថា ជនទាំងឡាយដែលមក ហើយ នឹងជួបបានងាយ ក្នុងទីណា គប្បីដាក់ផ្លិតទុកជិតខ្លួន ស្លៀកដណ្តប់រៀបរយអង្គុយក្នុងទីនៃកុដិនៅជិតដូច្នោះ ។

[៤៨] ពីរបទថា **តតោ ឧជ្ឈិត្វា** : **ចោលក្នុងទីនោះឯង** មានសេចក្តីថា ភិក្ខុដែលមាននាទីទទួលចីវរពោលថា "ការទទួលប៉ុណ្ណោះ ជាធុរៈរបស់ពួកខ្ញុំព្រះករុណា" ហើយចោលទុកក្នុងទីដែលខ្លួនទទួលនុ៎ះឯង ហើយចេញទៅ ។

បទថា **ចីវរនិធាហកំ** : **ឱ្យជាអ្នកទុកដាក់ចីវរ** បានដល់ ភិក្ខុជាអ្នកមាននាទីរក្សាចីវរ ។

ក្នុងពាក្យថា **យោ ន ឆន្ទាគតិ** : **ភិក្ខុដែលមិនលំអៀង ព្រោះសេចក្តីស្រឡាញ់** ជាដើម ក្នុងអធិការពោលអំពីសន្មតអ្នករក្សាចីវរនេះ និងក្នុងអធិការទាំងពួងក្រៅអំពីនេះ គប្បីជ្រាបវិនិច្ឆ័យ តាមន័យដែលពោលហើយនោះឯង ។ សូម្បីវិនិច្ឆ័យក្នុងការសន្មត ក៏គប្បីជ្រាបដោយទំនងដូចពោលហើយ ដូចគ្នា ។

[៤៩] វិនិច្ឆ័យក្នុងពាក្យថា **វិហារំ វា** : **វិហារក្តី** ជាដើម

គប្បីជ្រាបដូច្នេះ ៖

ទីនៅយ៉ាងណាច្របូកច្របល់ដោយជនទាំងឡាយ មានអារាមិកជន និងសាមណេរជាដើមក្នុងវត្ត ជាកុដិសម្រាប់នៅក៏ដោយ ជាភនហាលក៏ដោយ នៅក្នុងស្ថានជាទីប្រជុំរបស់ជនទាំងពួង ទីនៅយ៉ាងនោះ មិនគប្បីសន្មត ៗ មួយទៀត សេនាសនៈចុងដែន ក៏មិនគួរសន្មត ៗ ការដែលភិក្ខុទាំងឡាយទៅកាន់ខណ្ឌសីមាអង្គុយក្នុងខណ្ឌសីមា សន្មតភណ្ឌាគារនេះ រមែងមិនគួរ ត្រូវសន្មតនៅក្នុងវត្តប៉ុណ្ណោះ ។

វិនិច្ឆ័យក្នុងពាក្យថា គុត្តាគុត្តញ្ច ជានេយ្យ : ដឹងនូវរបស់ដែលខ្លួនគ្រប់គ្រងរក្សាហើយនិងមិនទាន់គ្រប់គ្រងរក្សា នេះ គប្បីជ្រាបដូច្នេះ ៖

ទោសណា ៗ ក្នុងសម្ភារៈទាំងឡាយមានជំបូលជាដើម នៃឃ្លាំងណាមិនមានទេ ឃ្លាំងនោះ ឈ្មោះថា រក្សាទុកបាន ចំណែកឃ្លាំងណា មានស្មៅសម្រាប់ប្រក់ ឬក្បឿងសម្រាប់ប្រក់ ធ្លាក់ចុះទៅក្នុងទីកន្លែងណាទីមួយ ឬមានប្រហោងក្នុងទីកន្លែងខ្លះ មានជញ្ជាំងជាដើមដែលមានភ្លៀងស្រោចបាន ឬមានមកចូលនៃសត្វទាំងឡាយមានកណ្ដុរជាដើម ឬកណ្ដៀរឡើងបាន ឃ្លាំងទាំងអស់នោះ ឈ្មោះថា រក្សាទុកមិនបាន គប្បីត្រួតមើលឃ្លាំងនោះ ហើយជួសជុលឱ្យល្អ ៗ ក្នុងរដូវត្រជាក់

គប្បីបិទទ្វារ និងបង្អួចឱ្យល្អ ព្រោះថា ចីវររមែងខូចពណ៌, ព្រោះចំហាយត្រជាក់ ។ ក្នុងរដូវក្តៅ ទ្វារនិងបង្អួច គួរបើកដើម្បីឱ្យខ្យល់ចូលក្នុងចន្លោះ ៗ ។ ដោយថា កាលធ្វើយ៉ាងនោះ ឈ្មោះថា ស្គាល់ឃ្លាំងដែលរក្សាទុកបាន និងរក្សាទុកមិនបាន ។

ក៏ភិក្ខុទាំង ៣ នេះ មានភិក្ខុទទួលចីវរជាដើម ត្រូវស្គាល់វត្តរបស់ខ្លួន ។

បណ្ដាភិក្ខុទាំង ៣ នោះ សំពត់គ្រប់ប្រភេទដែលជនទាំងឡាយថ្វាយថា កាលចីវរក្តី ថា អកាលចីវរក្តី ថា អច្ចេកចីវរក្តី ថា វស្សិកសាដិកាក្តី ថា សំពត់និសីទនៈក្តី ថា សំពត់កម្រាលក្តី ថា សំពត់ជូតមុខក្តី ដែលភិក្ខុអ្នកទទួលចីវរ មិនគួរទទួលលាយឡំប្រមូលផ្តុំជាគំនរតែមួយរួមគ្នា; គប្បីទទួលចាត់ទុកជាផ្នែក ៗ ហើយប្រាប់យ៉ាងនោះឯង ប្រគល់ដល់ភិក្ខុអ្នកទុកដាក់ចីវរ ភិក្ខុអ្នកទុកដាក់ចីវរនោះ កាលនឹងប្រគល់ដល់ភិក្ខុអ្នករក្សាឃ្លាំង គប្បីប្រាប់ប្រគល់សញ្ញា សំគាល់ថា នេះកាលចីវរ ។ល ។ នេះសំពត់ជូតមុខ ។ ចំណែកភិក្ខុអ្នករក្សាឃ្លាំង គប្បីធ្វើគ្រឿងសំគាល់រក្សាទុកជាផ្នែក ៗ យ៉ាងនោះដូចគ្នា ។ ខាងក្រោយកាលសង្ឃបង្គាប់ថា "ចូរនាំកាលចីវរមក" គប្បីថ្វាយចំពោះកាលចីវរ; ។ល ។ កាលសង្ឃបង្គាប់ថា "ចូរនាំសំពត់ជូតមុខមក" គប្បីថ្វាយតែសំពត់ជូតមុខប៉ុណ្ណោះ ។ ភិក្ខុអ្នកទទួលចីវរ ព្រះមានព្រះភាគ

ទ្រង់អនុញ្ញាតហើយ ភិក្ខុអ្នកទុកដាក់ចីវរ ទ្រង់អនុញ្ញាតហើយ ភិក្ខុអ្នករក្សាឃ្លាំង ក៏ទ្រង់អនុញ្ញាតហើយ ដើម្បីភាពជាអ្នកប្រាថ្នាច្រើន ក៏ទេ ដើម្បីសេចក្តីមិនសន្តោស ក៏ទេ តែតាមពិត ទ្រង់អនុញ្ញាតហើយ ដើម្បីអនុគ្រោះសង្ឃ ដោយប្រការដូច្នេះ ។

ក៏បើថា ភិក្ខុទាំងឡាយ នឹងគប្បីកាន់យកចីវរដែលទាយកនាំមកហើយ ហើយបែងចែកគ្នាសោត លោកទាំងឡាយ នឹងមិនជ្រាបចីវរដែលទាយកនាំមកហើយ មិនជ្រាបចីវរដែលទាយកមិនទាន់បាននាំមក មិនជ្រាបចីវរដែលខ្លួនឱ្យហើយ មិនជ្រាបចីវរដែលខ្លួនមិនទាន់បានឱ្យ មិនជ្រាបចីវរដែលភិក្ខុបានហើយ មិនជ្រាបចីវរដែលភិក្ខុមិនទាន់បាន; នឹងគប្បីថ្វាយចីវរដែលទាយកនាំមកហើយក្នុងថេរាសនៈ ឬនឹងគប្បីកាត់ជាកំណាត់តូច-ធំកាន់យក; កាលបើដូច្នេះ ការប្រើប្រាស់ចីវរដែល មិនសមគួរ រមែងមាន; ទាំងមិនជាការបានធ្វើការសង្គ្រោះដល់គ្នាទូទៅ ។ ក៏ប៉ុន្តែថា ភិក្ខុទាំងឡាយរក្សាចីវរទុកក្នុងឃ្លាំងហើយ ក្នុងកាលមានចីវរច្រើន នឹងឱ្យចីវរដល់ភិក្ខុមួយរូប ១ ត្រៃខ្លះ, មួយរូប ២ ផ្ទាំង ៗ ខ្លះ, មួយរូប ១ ផ្ទាំង ៗ ខ្លះ, លោកទាំងឡាយនឹងជ្រាបចីវរ ដែលភិក្ខុបានហើយនិងមិនទាន់បាន កាលជ្រាបចីវរដែលភិក្ខុមិនទាន់បាន នឹងសម្គាល់ដើម្បីធ្វើការសង្គ្រោះគ្នា ដូច្នេះ ។

# បុគ្គលដែលមិនគួរបណ្តេញ

[៥១] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ ភណ្ឌាគារិកោ វុដ្ឋាបេតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញភិក្ខុអ្នករក្សាឃ្លាំងចេញទេ នេះ គប្បីជ្រាបដូច្នេះ ៖

គប្បីស្គាល់ភិក្ខុដែលមិនគួរបណ្តេញ សូម្បីដទៃទៀត ពិតមែន មិនគួរបណ្តេញភិក្ខុ ៤ ពួក គឺ ភិក្ខុដែលចាស់ជាង១ ភិក្ខុអ្នករក្សាឃ្លាំង១ ភិក្ខុដែលអាពាធ១ ភិក្ខុបានសេនាសនៈអំពីសង្ឃ១ ក្នុងភិក្ខុ៤ពួកនោះ, ភិក្ខុខ្ចីមិនគួរបណ្តេញភិក្ខុដែលចាស់ជាង ព្រោះលោកជាភិក្ខុចាស់ជាងខ្លួន, ភិក្ខុដែលរក្សាឃ្លាំង មិនគប្បីបណ្តេញ ព្រោះឃ្លាំងដែលសង្ឃសន្មតប្រគល់ឱ្យ, ភិក្ខុដែលអាពាធ មិនគប្បីបណ្តេញ ព្រោះលោកជាភិក្ខុអាពាធ, ប៉ុន្តែថា សង្ឃប្រគល់ទីលំនៅដែលសប្បាយធ្វើ ឱ្យជាស្ថានទីមិនត្រូវបណ្តេញ ដល់ភិក្ខុដែលជាពហុស្សូត មានឧបការៈច្រើន ដោយឧទ្ទេសនិងបរិបុច្ឆាជាដើម អ្នកជួយភារៈ, ព្រោះដូច្នោះ ភិក្ខុដែលជាពហុស្សូតនោះ មិនគប្បីបណ្តេញ ព្រោះលោកជាអ្នកមានឧបការៈ និងព្រោះតម្លៃដែលសេនាសនៈជារបស់ដែលលោកបានអំពីសង្ឃ ដូច្នេះឯង ។

# ភិក្ខុជាអ្នកចែកចីវរ

[៥២] ពីរបទថា ឧស្សន្នំ ហោតិ : ក៏សម្បូរណ៍ឡើង មានសេចក្តីថា ចីវរមានច្រើន ត្រូវចាត់គំនរទុក គឺ ឃ្លាំងមិនល្មមគ្រប់គ្រាន់ ។

បទថា សម្មុខីភូតេន : ដែលនៅប្រជុំគ្នា គឺ ឈរខាងក្នុងឧបចារសីមា ។

បទថា ភាជេតុំ មានសេចក្តីថា ដើម្បីឱ្យប្រកាសវេលាចែកគ្នាតាមលំដាប់ ។

ពីរបទថា កោលាហលំ អកាសិ : ក៏ធ្វើនូវសេចក្តីកោលាហលឡើង គឺ បានធ្វើសំឡេងខ្លាំងយ៉ាងនេះថា លោកចូរឱ្យដល់អាចារ្យរបស់យើង លោកចូរឱ្យដល់ឧបជ្ឈាយ៍របស់យើង ។

វិនិច្ឆ័យក្នុងអង្គរបស់ភិក្ខុអ្នកចែកចីវរ គប្បីជ្រាបដូច្នេះ ៖

កាលឱ្យចីវរដែលមានតម្លៃច្រើន សូម្បីមិនទាន់ដល់(លំដាប់) ដល់ភិក្ខុទាំងឡាយជាសភាគគ្នា ឈ្មោះថា ដល់សេចក្តីលំអៀង ព្រោះសេចក្តីស្រឡាញ់ ។ មិនឱ្យចីវរមានតម្លៃច្រើន សូម្បីត្រូវបានដល់ភិក្ខុដែលចាស់ជាងពួកដទៃ តែត្រឡប់យកចីវរមានតម្លៃតិចមកឱ្យ ឈ្មោះថា ដល់សេចក្តីលំអៀង ព្រោះសេចក្តីស្អប់ខ្ពើម ។ ភិក្ខុដែលល្ងង់ព្រោះភាព

ជាអ្នកល្ងង់ខ្លៅ មិនស្គាល់វត្ត(របៀប)នៃការចែកចីវរ ឈ្មោះថា ដល់សេចក្ដីលំអៀង ព្រោះល្ងង់ ព្រោះខ្លាចសូម្បីតែភិក្ខុទីដែលមានមាត់រឹងទើបឱ្យចីវរមានតម្លៃច្រើន ទាំងដែលនៅមិនទាន់ដល់ (លំដាប់) ឈ្មោះថា ដល់សេចក្ដីលំអៀង ព្រោះខ្លាច ។ ភិក្ខុណាមិនដល់សេចក្ដីលំអៀងយ៉ាងនោះ គឺ ជាអ្នកស្មោះត្រង់ជាអ្នកសមល្មម តម្កល់ចិត្តជាកណ្ដាលចំពោះភិក្ខុទាំងពួង ភិក្ខុបែបនេះ សង្ឃគួរសន្មត ។

បទថា **ភាជិតាភាជិតំ : របស់ដែលខ្លួនបានចែកហើយនិងមិនទាន់បានចែក** មានសេចក្ដីថា ភិក្ខុដែលជ្រាបថា សំពត់ចែកទៅហើយប៉ុណ្ណេះ មិនទាន់បានចែកប៉ុណ្ណេះ ព្រះមានព្រះភាគត្រាស់ថា "ដឹងនូវរបស់ដែលខ្លួនបានចែកហើយ និងមិនទាន់បានចែក" ។

បទថា **ឧច្ចិនិត្វា : ជ្រើសរើស** មានសេចក្ដីថា ជ្រើសរើសសំពត់ទាំងឡាយយ៉ាងនេះថា នេះសាច់គ្រោតគ្រាត នេះសាច់ល្អិតទន់ នេះសាច់ក្រាស នេះសាច់ស្ដើង នេះបានប្រើហើយ នេះមិនទាន់បានប្រើ នេះបណ្ដោយប៉ុណ្ណេះ នេះទទឹងប៉ុណ្ណោះ ។

បទថា **តុលយិត្វា : ស្ទង់មើល** មានសេចក្ដីថា ធ្វើការកំណត់តម្លៃយ៉ាងនេះថា ផ្ទាំងនេះថ្លៃប៉ុណ្ណេះ ផ្ទាំងនេះថ្លៃប៉ុណ្ណេះ ។

ពីរបទថា **វណ្ណាវណ្ណំ កត្វា : ហើយលៃលកចីវរដែលមានសណ្ឋានតូចធំថ្លៃច្រើនតិច** មានសេចក្ដីថា បើចំពោះផ្ទាំងមួយ ៗ ដែល

មានតម្លៃមួយផ្ទាំង ១០ កហាបណៈ ៗ ល្មមគ្រប់រូប យ៉ាងនោះ ជាការល្អ; បើមិនល្មម ផ្ទាំងណា វាយតម្លៃ ៩ ឬ ៨ កហាបណៈ ផ្ទាំងនោះ គួបនឹងផ្ទាំងដទៃ ដែលមានតម្លៃ ១ កហាបណៈ ឬមានតម្លៃ ២ កហាបណៈ ចាត់ចំណែកស្មើ ៗ គ្នា ដោយឧបាយនេះឯង ។

ពាក្យថា ភិក្ខូ គណេត្វា វគ្គំពន្ធិត្វា : ហើយរាប់ភិក្ខុ ហើយចងចីវរឱ្យជាពួក ៗ មានសេចក្ដីថា បើថា កាលចែកម្ដងមួយរូប ៗ ថ្ងៃមិនល្មម តថាគតអនុញ្ញាតឱ្យរាប់ភិក្ខុមួយក្រុម ១០ រូប ៗ ចាត់ចំណែកចីវរជាបាច់ ៗ មួយដុំ ១០ ចំណែក ៗ ធ្វើជាបាច់តែមួយ រួមគ្នាតាំងជាចំណែកចីវរតែមួយ កាលចំណែកចីវរបានចាត់តាំងទុកយ៉ាងនេះហើយ គប្បីឱ្យចាប់ស្លាក សូម្បីភិក្ខុទាំងនោះ ក៏គប្បីចាប់ស្លាកចែកគ្នាទៀត ។

វិនិច្ឆ័យក្នុងពាក្យថា សាមណេរានំ ឧឌ្ឍបដិវីសំ : ចំណែកពាក់កណ្ដាលដល់ពួកសាមណេរ នេះ គប្បីជ្រាបដូច្នេះ ៖

សាមណេរពួកណា ជាឥស្សរៈដល់ខ្លួន មិនធ្វើការងារដែលគួរធ្វើរបស់ភិក្ខុសង្ឃ ខ្វល់ខ្វាយក្នុងឧទ្ទេសនិងបរិបុច្ឆា ធ្វើវត្តបដិបត្តិដល់អាចារ្យនិងឧបជ្ឈាយ៍ប៉ុណ្ណោះ មិនធ្វើដល់ភិក្ខុពួកដទៃ ចំពោះសាមណេរទាំងនោះ គប្បីឱ្យពាក់កណ្ដាលចំណែក ចំណែកសាមណេរពួកណា ធ្វើកិច្ចដែលគួរធ្វើរបស់ភិក្ខុសង្ឃប៉ុណ្ណោះ ទាំងបុរេភត្តនិងបច្ឆាភត្តគប្បីឱ្យ

ចំណែកស្មើគ្នា ដល់សាមណេរទាំងនោះ ។ តែពាក្យនេះ ពោលចំពោះដោយអកាល ចីវរដែលកើតឡើងខាងក្រោយសម័យ បានរក្សាទុកក្នុងឃ្លាំង ចំណែកកាលចីវរត្រូវឱ្យស្មើ ៗ គ្នាពិត ។

សំពត់ចំណាំវស្សា ដែលកើតក្នុងទីនោះ ភិក្ខុនិងសាមណេរ គប្បីធ្វើផាតិកម្មដល់សង្ឃមានចង់អំបោសជាដើម ហើយកន់យក ។ ពិតមែនការធ្វើហត្ថកម្មមានចង់អំបោសជាដើម ជាវត្តរបស់ភិក្ខុសាមណេរទាំងពួងក្នុងការកាន់យកសំពត់ចំណាំវស្សានេះ ទាំងក្នុង ( អកាល ) ចីវរដែលរក្សាទុកក្នុងឃ្លាំង ( តាមប្រក្រតី ) ។ បើថា សាមណេរទាំងឡាយ មកយំថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាដាំបបរ ពួកខ្ញុំព្រះករុណាដាំបាយ ពួកខ្ញុំព្រះករុណា ចម្អិនបង្អែម ពួកខ្ញុំព្រះករុណា ជម្រះស្មៅ ពួកខ្ញុំព្រះករុណារកឈើស្ទន់មក ពួកខ្ញុំព្រះករុណា ធ្វើក្រម៉ទឹកជ្រលក់ចីវរឱ្យគួរប្រគេន តើអ្វីខ្លះទៀតដែលថា ពួកខ្ញុំព្រះករុណាមិនបានធ្វើ" គប្បីឱ្យចំណែកស្មើគ្នាដល់សាមណេរទាំងនោះចុះ ។ ការឱ្យចំណែកស្មើគ្នាកាលពួកសាមណេរធ្វើការយំ ( សូមចំណែក ) ព្រះមានព្រះភាគត្រាស់សំដៅយកសាមណេរដែលធ្វើខុស និងសាមណេរដែលមានការផែរមិនប្រាកដ ។ តែក្នុងកុរុន្ទីពន្យល់ថា បើសាមណេរទាំងឡាយអង្វរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាមិនធ្វើការផែររបស់សង្ឃព្រោះហេតុអ្វី ពួកខ្ញុំព្រះករុណានឹងធ្វើ គប្បីឱ្យចំណែកស្មើគ្នា" ។

បទថា ឧត្តរិត្តុកាមោ : មានសេចក្តីប្រាថ្នានឹងឆ្លង មានសេចក្តីថា អ្នកប្រាថ្នានឹងឆ្លងទន្លេ ឬមកកន្តារ គឺ អ្នកបានពួកហើយប្រាថ្នា នឹងជៀសទៅកាន់ទិស ។

ពាក្យថា សកំ ភាគំ ធាតុំ : ឱ្យចំណែករបស់ខ្លួន នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្តីនេះថា កាលជញ្ជូនចីវរចេញពីឃ្លាំងចាត់គរ ទុកហើយ វាយរគាំងហើយ ភិក្ខុសង្ឃប្រជុំគ្នាហើយ, ភិក្ខុដែលបានពួកហើយប្រាថ្នានឹងទៅ មិនត្រូវបែកចេញអំពីពួក ។ ព្រោះដូច្នោះ កាលចីវរមិនទាន់បានជញ្ជូនចេញក្តី មិនទាន់បានវាយរគាំងក្តី សង្ឃមិនទាន់បានប្រជុំគ្នាក្តី មិនគួរឱ្យ ។ តែកាលចីវរជញ្ជូនចេញហើយ វាយរគាំងហើយ ភិក្ខុសង្ឃប្រជុំគ្នាហើយ ភិក្ខុដែលជាអ្នកចែកចីវរ គប្បីប៉ាន់ស្មានមើលថា ចំណែករបស់ភិក្ខុនេះ គប្បីមានប៉ុណ្ណេះហើយឱ្យចីវរតាមសេចក្តីប៉ាន់ស្មាន; ព្រោះថា មិនអាចឱ្យប៉ុនគ្នា ដូចថ្លឹងដោយជញ្ជីងបាន ព្រោះដូច្នោះ ទឹងខ្វះ ឬលើសក៏ដោយ ចីវរដែលឱ្យហើយដោយប៉ាន់ស្មានដោយន័យយ៉ាងនេះ ជាការឱ្យដោយល្អពិត; ខ្វះក៏មិនត្រូវថែមទៀត លើសក៏មិនត្រូវយកវិញ ដូច្នេះឯង ។

ពាក្យថា អតិរេកភាគេន : ចំណែកដែលថ្លៃច្រើនជាងគេ មានសេចក្តីថា ភិក្ខុមាន ១០ រូប ទាំងសំពត់ក៏មាន ១០ ផ្ទាំងដូចគ្នា ក្នុងសំពត់ទាំងនោះ ផ្ទាំងមួយ វាយតម្លៃ ១២ កហាបណៈ ផ្ទាំងដ៏សេស

វាយតម្លៃមួយផ្ទាំង ៗ ១០ កហាបណៈ; កាលបានចាប់ស្លាកក្នុងសំពត់ទាំងពួង ដោយអំណាចការវាយតម្លៃមួយផ្ទាំង ៗ ១០ កហាបណៈស្មើគ្នា ស្លាកក្នុងសំពត់មានតម្លៃ ១២ កហាបណៈ ឱ្យធ្លាក់ដល់ភិក្ខុណា ភិក្ខុនោះជាអ្នកប្រាថ្នានឹងទៅទាំងចំណែកដែលលើសនោះ ដោយពោលថា “ចីវររបស់យើង រមែងល្មមគ្រប់គ្រាន់ដោយចំណែកប៉ុណ្ណេះ” ភិក្ខុទាំងឡាយពោលថា “អ្នកមានអាយុ ចំណែកដែលលើស ត្រូវជារបស់សង្ឃ”; ព្រះមានព្រះភាគទ្រង់ស្តាប់ពាក្យនោះ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ កាលបើកប្បិយភណ្ឌគេបានឱ្យហើយ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យដ៏ច្រើនចុះ” ដូច្នេះ ដើម្បីសម្តែងសេចក្តីនោះថា ឈ្មោះថា តិច រមែងមិនមានក្នុងរបស់សង្ឃ និងរបស់គណៈ ភិក្ខុគប្បីធ្វើសេចក្តីសង្រួមក្នុងរបស់សង្ឃ និងរបស់គណៈទាំងពួង សូម្បីភិក្ខុដែលនឹងកាន់យក ក៏គប្បីរង្កៀស ។

ក្នុងបទថា អនុក្ខេបេ ទិន្នេ : កាលបើកប្បិយភណ្ឌគេបានឱ្យហើយ នោះ មានសេចក្តីថា ដែលឈ្មោះថា វត្ថុសម្រាប់ជំនួស បានដល់ កប្បិយភណ្ឌៈ ឯណា ទីមួយ ដែលគប្បីជំនួស គឺ គប្បីសងជំនួសមកវិញ ។ ក្នុងចំណែករបស់ភិក្ខុនោះ ដែលលើសទៅប៉ុនណា កាលកប្បិយ ភណ្ឌៈឯណាទីមួយដែលមានតម្លៃប៉ុណ្ណោះ ដែលលោកឱ្យហើយ ។ ការខ្វះ ក្នុងពាក្យថា វិកលកេ តោសេត្វា : កាលបើចីវរខ្វះហើយ អ្នកទាំងឡាយញ៉ាំងភិក្ខុឱ្យត្រេកអរសិន នេះ, (ការ

ខ្វះ ) មាន ២ គឺ ខ្វះចីវរ ១ ខ្វះបុគ្គល ១ ។

ដែលឈ្មោះថា ការខ្វះចីវរ គប្បីជ្រាបដូច្នេះ ៖

សំពត់ត្រូវបានភិក្ខុក្នុងមួយរូប ៥ ផ្ទាំង គ្រប់រូប ។ ទាំងនៅមានសំពត់នៅសល់, តែមិនល្មមក្នុងមួយរូប ១ ផ្ទាំង ៗ ទៀត, គប្បីកាត់បែកគ្នា; ក៏ឯកាលទឹងកាត់ គប្បីធ្វើឱ្យជាកំណាត់ ល្មមដល់ចីវរ មានអឌ្ឍមណ្ឌលជាដើម ឬបរិក្ខារដទៃមានថង់ដាក់ស្បែកជើងជាដើម; ដោយកំណត់យ៉ាងទាបទីបំផុត សមគួរកាត់កំណាត់ឱ្យទទឹងត្រឹមតែ ៤ ធ្នាប់ បណ្ដោយល្មមដល់អនុវាត ។ តែមិនគប្បីធ្វើជាកំណាត់ដរាបប្រើមិនបាន; ព្រោះដូច្នោះ ការដែលចីវរមិនល្មមគ្រប់គ្រាន់ ឈ្មោះថា ការខ្វះចីវរ ក្នុងពាក្យថា **វិកលកេ តោសេត្វា** នេះ ដោយប្រការដូច្នេះ ។

មួយទៀត កាលកាត់ចីវរឱ្យហើយ ចីវរនោះ ជារបស់ថែមឱ្យភិក្ខុទាំងឡាយពេញចិត្ត, លំដាប់នោះ គប្បីធ្វើការចាប់ស្លាក; ក្នុងអនុកដ្ឋកថាពន្យល់ថា បើក្នុងចំណែករបស់ភិក្ខុមួយរូប សំពត់ទឹងមិនល្មម ១ផ្ទាំង ឬ ២ផ្ទាំង, គប្បីថែមសមណបរិក្ខារយ៉ាងដទៃ ក្នុងចំណែកនោះ ភិក្ខុណាពេញចិត្តដោយចំណែកនោះ, គប្បីឱ្យចំណែកនោះដល់ភិក្ខុនោះហើយគប្បីធ្វើការចាប់ស្លាកជាខាងក្រោយ; សូម្បីនេះក៏ឈ្មោះថា ការខ្វះចីវរ ។

ដែលឈ្មោះថា ការខ្វះបុគ្គល គប្បីជ្រាបដូច្នេះ ៖

កាលរាប់ភិក្ខុចាត់ជាមួយពួក ៗ ១០ រូប, មួយពួកមិនគ្រប់ មាន

ភិក្ខុតែ ៨ រូប ឬ ៩ រូប គប្បីឱ្យដល់ភិក្ខុទាំងនោះ ៨ ចំណែក ឬ ៩ ចំណែកថា លោកទាំងឡាយ ចូរពប់ចំណែកទាំងនេះ បែងចែកគ្នាចុះ ។ ការដែលបុគ្គលមិនគ្រប់ល្មមនេះ ឈ្មោះថា ការខ្វះបុគ្គល ដោយប្រការដូច្នេះ ។ ក៏កាលឱ្យជាផ្នែកហើយ ចីវរនោះ រមែងជារបស់ដែលឱ្យភិក្ខុទាំងឡាយពេញចិត្តបាន, កាលឱ្យពេញចិត្តបានយ៉ាងនោះហើយ គប្បីធ្វើការចាប់ស្លាក ។

ម្យ៉ាងទៀត ពាក្យថា វិកលកេ តោសេត្វា មានសេចក្ដីថា ចំណែកចីវរណាខ្វះខាត, គប្បីយកបរិក្ខារដទៃថែមចំណែកចីវរនោះឱ្យស្មើគ្នាហើយ គប្បីធ្វើការចាប់ស្លាក ។

## ទឹកជ្រលក់

[៥៣] បទថា ឆកណេន : ដោយអាចម៍របស់សត្វទាំងឡាយមានសេះជាដើម បានដល់ អាចម៍គោ ។

បទថា បណ្ឌុមត្តិកាយ : ដោយដីស្អិតមានពណ៌លឿង បានដល់ តម្ពមត្តិកាយ : ដោយដីស្អិតមានពណ៌ក្រហម ។

វិនិច្ឆ័យក្នុងទឹកជ្រលក់កើតពីមើមជាដើម គប្បីជ្រាបដូច្នេះ ៖

វៀរល្មៀតចេញ ទឹកជ្រលក់កើតពីមើម គួរគ្រប់យ៉ាង ។ វៀរលែងតែស្បូងនិងឈ្លេចេញទឹកជ្រលក់កើតពីដើម គួរគ្រប់យ៉ាង ។ ដើមឈើមានបន្ទាមួយប្រភេទ ឈ្មោះថា តុង្គហារ, ទឹកជ្រលក់កើតពីដើមនៃឈ្លេនោះ ជារបស់មានពណ៌ស្រដៀងហរិតាល (ពណ៌លឿងឬសខ្ចី) វៀរលែងតែសំបកលោត សំបកព្រហូត (កណ្ឌុល)ចេញ ទឹកជ្រលក់កើតពីសំបក គួរគ្រប់យ៉ាង ។ វៀរលែងតែស្លឹកមឈ្លេ”វនិងស្លឹកត្រុំចេញ ទឹកជ្រលក់កើតពីស្លឹកឈើ គួរគ្រប់យ៉ាង ។ តែសំពត់ដែលគ្រហស្ថប្រើហើយ សមគួរជ្រលក់ដោយស្លឹកមឈ្លេ”វម្តង ។ វៀរលែងតែផ្កាចារនិងផ្កាកុសុម្ភៈចេញ ទឹកជ្រលក់កើតអំពីផ្កា គួរគ្រប់យ៉ាង ។ ចំណែកក្នុងទឹកជ្រលក់កើតអំពីផ្លែ មិនមានផ្លែណា ដែលមិនគួរទេ ។

ទឹកជ្រលក់ដែលមិនបានស្ងោរ ហៅថា ទឹកត្រជាក់ ។

ប្រទាសសម្រាប់ការពារទឹកផុលហៀរនោះ បានដល់ ប្រទាសសម្រាប់ការពារមូល ៗ ។ សេចក្តីថា តថាគតអនុញ្ញាតឱ្យដាក់ប្រទាសការពារនោះ តាំងទុកកណ្តាលឆ្នាំងទឹកជ្រលក់ហើយ ទើបដាក់ទឹកជ្រលក់ ។ ព្រោះថា កាលធ្វើយ៉ាងនោះហើយ ទឹកជ្រលក់ រមែងមិនហៀរ ។

ពីរបទថា ឧទកេ វា នខបិដ្ឋិកាយ វា : បន្តក់តំណក់ទឹកលើទឹកក៏បាន លើខ្នងក្រចកក៏បាន មានសេចក្តីថា ក៏បើថា ទឹកជ្រលក់ជា

របស់ឆ្អិនហើយ, តំណក់ទឹកដែលដាក់ក្នុងស្នូកទឹក រមែងមិនជ្រួតជ្រាបទៅរហ័ស ។ សូម្បីស្រក់ចុះលើខ្នងក្រចក រមែងតាំងនៅ មិនជ្រួតជ្រាបចេញ ។

បទថា រជនុឡុង្កំ[១] : **បោយសម្រាប់ដងទឹកជ្រលក់** បានដល់ បោយដួសទឹកជ្រលក់ ។

បទថា ទណ្ឌកថាលិកំ : **បោយដែលមានដង** បានដល់ បោយនុំះឯង ព្រមទាំងដង ។

បទថា រជនកោលម្ពំ : **ឆ្នាំងសម្រាប់ដាក់ទឹកជ្រលក់** បានដល់ រជនកុណ្ឌំ : ឆ្នាំងសម្រាប់ជ្រលក់ ។

បទថា មទ្ទន្តិ : គត់ បានដល់ ញីប្រឫបាច់ចុះ ។

ច្រើនបទថា ន ច អច្ឆិន្នេ ថេវេ បក្កមិតុំ : **កាលបើតំណក់ទឹកមិនទាន់ដាច់អស់ទេ** មានសេចក្ដីថា តំណក់ទឹក រមែងនៅហូរមិនដាច់ត្រឹមណា, ភិក្ខុមិនគួរទៅក្នុងទីដទៃត្រឹមនោះ ។

បទថា បត្ថិន្នំ : **ជិតខ្លាំងពេក** គឺ ចីវរជារបស់រឹង ៗ ព្រោះជ្រលក់ច្រើនពេក, អធិប្បាយថា ទឹកជ្រលក់ជិតខ្លាំងពេក ។

ពីរបទថា ឧទកេ ឱសារេតុំ : **ត្រាំងទៅក្នុងទឹក** មានសេចក្ដីថា

១. ថៃ. រជនុលុង្កំ ។

ដើម្បីត្រាំទុកក្នុងទឹក ។ កំឯកាលទឹកជ្រលក់ចេញហើយ គប្បីចាក់ទឹកនោះចោល ហើយគប្បីប្រចាប់ចីវរ ។

[៥៤] បទថា ទន្តកសាវានិ : ចីវរជ្រលក់ដោយទឹកចត់មានពណ៌ដូចភ្លុក មានសេចក្តីថា ភិក្ខុឆព្វគ្គិយ ជ្រលក់ចីវរម្តង ឬពីរដង ប្រើចីវរមានពណ៌ដូចពណ៌ភ្លុកដំរី ។

## ចីវរកាត់

[៥៥] បទថា អច្ឆិពទ្ធំ : មានសណ្ឋានជាស្រែមានជ្រុងបួន គឺមានខ្ទង់ស្រែជាប់គ្នាជាបួនជ្រុង ។

បទថា បាលិពទ្ធំ : មានសណ្ឋានជាស្រែមានភ្លឺវែង គឺ ពូនទំនប់ស្រែវែងទាំងផ្នែកបណ្តោយ និងផ្នែកទទឹង ។

បទថា មរិយាទពទ្ធំ : មានសណ្ឋានជាស្រែមានភ្លឺខ្លី គឺ ពូនទំនប់ភ្លឺស្រែយ៉ាំងក្នុងចន្លោះ ៗ ដោយទំនប់ស្រែខ្លី ៗ ។

បទថា សិង្ឃាដកពទ្ធំ : មានសណ្ឋានជាបួនជ្រុងដោយមានភ្លឺខ្វែបាញ់រត់គ្នា គឺ ពូនទំនប់ស្រែភ្ជាប់គ្នាដូចមកបែកជា ៤ តាមកន្លែងដែលទំនប់ស្រែទឹងទំនប់ស្រែឆ្លងកាត់គ្នាទៅ, អធិប្បាយថា មានសណ្ឋានដូចមកបែកជា ៤ ។

ពីរបទថា ឧស្សហសិ ត្វំ អានន្ទ : នែអានន្ទអ្នកហ៊ានឬទេ មានសេចក្ដីថា សក្កោសិ ត្វំ អានន្ទ នែអានន្ទ អ្នកអាចឬទេ ?

បទថា សំវិធហិតុំ : ចាត់ចែងចីវរ បានដល់ ដើម្បីធ្វើ ។

ពីរបទថា ឧស្សហាមិ ភគវា : បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គហ៊ាន មានសេចក្ដីថា ព្រះអានន្ទសម្ដែងថា ខ្ញុំព្រះអង្គអាចធ្វើបានតាមន័យដែលព្រះអង្គប្រទាន ។

បទថា យត្រ ហិ នាម គឺ យោ នាម ។

វិនិច្ឆ័យក្នុងពាក្យថា កុសិម្បិ នាម : សំពត់ឈ្មោះកុសិផង ជាដើម គប្បីជ្រាប ដូច្នេះ ៖

ពាក្យថា កុសិ នេះ ជាឈ្មោះនៃសំពត់វែង មានអនុវាតផ្នែកបណ្ដោយ និងផ្នែកទទឹងជាដើម ។

ពាក្យថា អឌ្ឍកុសិ ជាឈ្មោះនៃសំពត់ខ្លីក្នុងចន្លោះ ៗ ។

មណ្ឌល នោះ បានដល់ ខ្ទង់ធំ ក្នុងខណ្ឌនីមួយ ៗ នៃចីវរមាន ៥ ខណ្ឌ ។

អឌ្ឍមណ្ឌល នោះ បានដល់ ខ្ទង់តូច ។

វិវដ្ដៈនោះ បានដល់ ខណ្ឌត្រង់កណ្ដាលដែលដេរមណ្ឌល នឹងអឌ្ឍមណ្ឌលជាប់គ្នា ។

អនុវិវដ្ដៈនោះ បានដល់ ២ ខណ្ឌក្នុងខាងទាំងពីរនៃវិវដ្ដៈនោះ ។ គីវេយ្យកៈនោះ បានដល់ សំពត់ផ្អួបដទៃដែលដេរដោយអំបោះ ដើម្បីធ្វើឱ្យរឹងមាំក្នុងទីដែលរុំក ។

ជង្ឃេយ្យកៈនោះ បានដល់ សំពត់ដែលដេរយ៉ាងនោះ ដូចគ្នាក្នុងទីដែលត្រូវស្មង ។

អាចារ្យពួកខ្លះពោលថា ពាក្យថា គីវេយ្យកៈ និង ជង្ឃេយ្យកៈនោះ ជាឈ្មោះនៃសំពត់ដែលតាំងនៅក្នុងទីនៃក និងក្នុងទីនៃស្មង ។

ពាហន្តៈនោះ បានដល់ ខណ្ឌមួយ ៗ ក្រៅអនុវិវដ្ដៈ ។

ពាក្យថា កុសិម្បិ ឆាម ជាដើមនេះ ព្រះអាចារ្យទាំងឡាយពិចារណាហើយដោយចីវរមាន ៥ ខណ្ឌ ដោយប្រការ ដូច្នេះឯង ។

មួយទៀត ពាក្យថា អនុវិវដ្ដៈនេះ ជាឈ្មោះនៃ ២ ខណ្ឌ ដោយខាងតែមួយ នៃវិវដ្ដៈ ជាឈ្មោះនៃ ៣ ខណ្ឌខ្លះ ៤ ខណ្ឌខ្លះ ដោយខាងតែមួយនៃវិវដ្ដៈ ។

ពាក្យថា ពាហន្តៈ នេះ ជាឈ្មោះនៃជាយទាំងពីរ (នៃចីវរ) ដែលភិក្ខុដណ្ដប់ចីវរបានខ្ទាតល្មមល្អ មូរពាក់ទុកលើដៃ មានផ្នែកខាងមុខនៅក្រៅ ។

ពិតមែន ន័យនេះឯង លោកពោលក្នុងមហាអដ្ឋកថា ។

# ត្រៃចីវរ

[៥៦] ពីរបទថា ចីវរេហិ ឧព្ភណ្ឌិកតេ : មានចីវរវេចជាសំពាយ បានដល់ ភិក្ខុទាំងឡាយ យកចីវរទាំងឡាយ ធ្វើឱ្យជាបង្វិចសម្រាប់ស្ពាយ គឺធ្វើឱ្យដូចជាភណ្ឌដែលគេលើកឡើង អធិប្បាយថា ឱ្យដល់នូវភាពជាបង្វិចដែលគេលើកឡើង ។

ចីវរ ២-៣ ផ្ទាំង ដែលភិក្ខុត្រូវគ្នាចូលហើយបត់ ដោយមានទំនងដូចពូកហៅថា ពូក ក្នុងបទថា ចីវរភិសី : ផ្នត់ចីវរ នេះ ។

បានឮថា ភិក្ខុទាំងនោះធ្វើក្នុងចិត្តថា ព្រះមានព្រះភាគ នឹងស្តេចត្រឡប់អំពីទក្ខិណាគិរីជនបទរហ័ស កាលនឹងទៅក្នុងជនបទនោះ ទើបបានរក្សាចីវរដែលបានក្នុងរឿងហ្មជីវកទុកហើយក៏ទៅ ។

ក៏ឥឡូវនេះ ពួកលោកសម្គាល់ថា ព្រះមានព្រះភាគ នឹងស្តេចមកព្រមដោយចីវរ ទើបកាន់យក (ចីវរ) ជៀសទៅ ។

បទថា អន្តរដ្ឋកាសុ : ឋិតនៅក្នុងចន្លោះ មានសេចក្តីថា (សេចក្តីត្រជាក់) បានតាំងនៅក្នុងចន្លោះខែ មាឃ ខែ ផល្គុន) (ខែ៣ ខែ ៤) ។

ប្រើនបទថា ឩ ភគវន្តំ សីតំ អហោសិ : ព្រះអង្គក៏បាត់រងាទៅ មានសេចក្តីថា សេចក្តីត្រជាក់មិនបានមានហើយដល់ព្រះមានព្រះ

ភាគ ៗ

ច្រើនបទថា ឯតទហោសិ យេបិ ខោ តេ កុលបុត្តា : ទ្រង់រិះគិតថា កុលបុត្រទាំងឡាយ មានសេចក្ដីថា ព្រះមានព្រះភាគមិនបានប្រថាប់អង្គុយក្នុងទីវាល នឹងទ្រង់មិនជ្រាបសេចក្ដីនេះ ក៏ទេ, តែបានជាទ្រង់ធ្វើយ៉ាងនោះ ក៏ដើម្បីឱ្យមហាជនយល់ព្រម ។

បទថា សីតាលុកា : ដែលជាអ្នករងាជាប្រក្រតី បានដល់ កុលបុត្រអ្នកមានសេចក្ដីត្រជាក់ជាប្រក្រតី គឺ អ្នកលំបាកដោយសេចក្ដីត្រជាក់ដោយប្រក្រតីមែន ។

ពីរបទថា ទិ្វគុណំ សង្ឃាដឹ : សង្ឃាដិពីរជាន់ បានដល់ ធុបដ្ដំ សង្ឃាដឹ : សំពត់សង្ឃាដិពីរផ្ទាំង ។

បទថា ឯកច្ចិយំ : ១ ជាន់ បានដល់ សំពត់តែមួយផ្ទាំង ។ ដើម្បីកាត់ឱកាសនៃពាក្យដែលថា ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះអត្តភាពឱ្យប្រព្រឹត្តទៅ ដោយចីវរ ៤ ផ្ទាំង ដោយព្រះអង្គឯង, តែទ្រង់អនុញ្ញាតត្រៃចីវរដល់យើងទាំងឡាយ ដូច្នេះ ទើបទ្រង់អនុញ្ញាតសង្ឃាដិ ២ ជាន់, ទ្រង់អនុញ្ញាតចីវរក្រៅនេះតែមួយជាន់, ពិតមែន កាលជាដូច្នេះ ចីវររបស់ភិក្ខុទាំងនោះនឹងជា ៤ ផ្ទាំង ដោយប្រការដូច្នេះឯង ។

[៥៨] ពីរបទថា អគ្គឡំ អច្ចុបេយ្យំ : ប៉ះនូវបម្ទះ មាន

សេចក្តីថា យើងគប្បីផ្អឹបកំណាត់សំពត់ចាស់ក្នុងទីដែលធ្លុះ ។

បទថា អហតកប្បានំ : ដែលគេបោកលាងម្តងហើយ បានដល់ បោកម្តងហើយ ។

បទថា ឧតុទ្ធតានំ : ដែលគេរើឡើងពីរដូវ បានដល់ រក្សាទុកដោយរដូវ គឺ ដោយកាលយូរ, មានពាក្យអធិប្បាយថា សំពត់ចាស់ដែលមានពណ៌ឆ្លកហើយ ។

បទថា អាបណិកេ[1] : ដែលធ្លាក់ចុះក្នុងរានផ្សារ បានដល់ ចីវរចាស់ ដែលធ្លាក់អំពីរានផ្សារ ។

ពីរបទថា ឧស្សាហោ ករណីយោ : គួរធ្វើសេចក្តីប្រឹងប្រែងស្វែងរក បានដល់ គប្បីធ្វើការស្វែងរក ។ តែខេត្តកំណាត់មិនមាន, ទឹងស្វែងរកមកសូម្បីទាំងរយផ្ទាំង ក៏គួរ ។ ចីវរនេះទាំងអស់ ព្រះមានព្រះភាគត្រាស់សម្រាប់ភិក្ខុដែលត្រេកអរ ។

វិនិច្ឆ័យក្នុងពាក្យថា អគ្គឡំ តុន្នំ : នូវបម្ទះ នូវការជុល នេះ គប្បីជ្រាបដូច្នេះ ៖

កំណាត់សំពត់ដែលភិក្ខុលើកឡើងផ្ទប់ឱ្យជាប់គ្នា ឈ្មោះថា សំពត់

១. បិដកខ្មែរ. ភូមា. បាបណិកេន ។

បម្ទះ, ការដេរភ្ជាប់ដោយអំបោះឈ្មោះថា ការផុល ឬការដេរប៉ះ ។

អន្ទាក់ជាទីខ្ទាស់ទុក ឈ្មោះថា ក្រវិលកណ្ដុំ ។

ឡែវសម្រាប់ភ្ជាប់ ហៅថា កណ្ដុំ ។

ទឡ្ហីកម្មំ : ការធ្វើឱ្យមាំ នោះ បានដល់ កំណាត់សំពត់ដែលប៉ះមិនរុះរើ (សំពត់ចាស់)ធ្វើឱ្យជាទ្រនាប់ ។

[៥៩] រឿងនាងវិសាខា មានសេចក្ដីងាយយល់, រឿងដទៃក្រៅពីរឿងនាងវិសាខានោះ បានវិនិច្ឆ័យហើយខាងដើមនោះឯង ។

[៦០] បទថា សោវគ្គិកំ : តែងបាននូវផល គឺអារម្មណ៍ដ៏ប្រសើរដោយប្រពៃ បានដល់ ធ្វើឱ្យជាហេតុនៃសួគ៌ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ប្រព្រឹត្តទៅដើម្បីកើតក្នុងសួគ៌ ។

ទានណា រមែងកម្ចាត់សេចក្ដីសោកចេញ ហេតុនោះ ទាននោះឈ្មោះថា សោកនុទ បន្ទោបង់នូវសេចក្ដីសោកចេញ ។

បទថា អនាមយា : ឥតមានទុក្ខ គឺ អ្នកមិនមានរោគ ។

ពីរបទថា សគ្គម្ហិ កាយម្ហិ : ក្នុងស្ថានសួគ, បានដល់ អ្នកកើតក្នុងសួគ៌ ។

## កាន់យកដោយវិស្សាសៈជាដើម

[៦២] បីបទថា បុថុជ្ជនា កាមេសុ វីតរាគា : ជាពួកបុថុជ្ជនមែន តែគ្មានតម្រេក បានដល់ បុថុជ្ជនដែលបានឈាន ។

[៦៥] បទថា សន្ទិដ្ឋោ : មិត្រដែលគ្រាន់តែឃើញគ្នាម្ដងម្កាល បានដល់ សម្លាញ់ដែលគ្រាន់តែធ្លាប់ឃើញគ្នា ។

បទថា សម្ភត្តោ : មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន បានដល់ សម្លាញ់អ្នករួមសម្ភោគ គឺ សម្លាញ់ជិតដិត ។

បទថា អាលបិតោ : មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ បានដល់ អ្នកដែលសម្លាញ់អនុញ្ញាតទុកយ៉ាងនេះថា "លោកត្រូវការវត្ថុណា ដែលជារបស់យើង, លោកគប្បីកាន់យកវត្ថុនោះចុះ" ។

វិស្សាសៈ រមែងឡើងដោយអង្គទាំង ៣ នេះ គឺ មានជីវិតរស់នៅ ១ កាលរបស់នោះដែលខ្លួនកាន់យកហើយ ម្ចាស់របស់ត្រេកអរពេញចិត្ត ១ និងក្នុងបណ្ដាភិក្ខុជាសម្លាញ់ទាំងបីរូបនោះ ណា ១ ។

[៦៦] បទថា បំសុកូលិកតោ : ក្នុងសំពត់បង្សុកូល គឺ សំពត់ឧត្តរាសង្គៈដែលធ្វើដោយសំពត់ បង្សុកូល ។

ពីរបទថា គរុកោ ហោតិ : ជាអ្នកធ្វើសេចក្តីគោរព គឺ ជារបស់ធ្ងន់ ព្រោះផ្ទប់សំពត់ប៉ះក្នុងទីដែលទ្រុឌទ្រោមហើយ ៗ ។

ពីរបទថា សុត្តលូខំ គាតុំ : ធ្វើចីវរឱ្យសៅហ្មងដោយចេស មានសេចក្តីថា ដើម្បីធ្វើការដេរត្រួតពីលើដោយអំបោះប៉ុណ្ណោះ ។

បទថា វិកណ្ណោ : ចីវរមានជាយមិនស្មើគ្នា គឺ កាលភិក្ខុទាំងឡាយកាត់ហើយ ៗនូវអំបោះ ហើយដេរ មុំសង្ឃាដិម្ខាងជារបស់វែងជាង ។

ពីរបទថា វិកណ្ណំ ឧទ្ធរិតុំ : រុះរើចីវរដែលមានជាយមិនស្មើគ្នា គឺ ដើម្បីកាត់មុំដែលវែងចេញ ។

បទថា ឱគិរិយន្តិ : រសាត់ចេញ គឺ របូតចេញចាកមុំដែលកាត់ ។

ពីរបទថា អនុវាតំ បរិភណ្ឌំ : អនុវាតខាងខ្នងនិងអនុវាតខាងពោះ បានដល់ អនុវាតនិងសំពត់អប ។

ពីរបទថា បត្តា លុជ្ជន្តិ : ជាន់ទាំងឡាយដាច់ចេញពីគ្នា គឺ អំបោះទាំងឡាយដែលដេរ ក្នុងមុខសំពត់ធំ រមែងរបូតចេញ គឺ សំពត់របូតចេញចាកសំពត់ផ្ទាំងចាស់នោះ ។

ពីរបទថា អដ្ឋបទកំ កាតុំ : ធ្វើថ្នេរឱ្យមានសណ្ឋានដូចជាក្រឡាបត្រង្គ គឺ ដើម្បីដេរមុខសំពត់ដោយថ្នេរឱ្យដូចស្នាមគូសក្នុងក្តារក្រឡាបត្រង្គ ។

[៦៧] ពីរបទថា អន្វាធិកំបិ អារោបេតុំ : ឱ្យភិក្ខុលើកឡើងនូវសំពត់ថ្មី គឺ ដើម្បីបន្ថែមសំពត់អាគន្តុក(សំពត់ថ្មី) ។ តែសំពត់ថ្មីនេះ គប្បីបន្ថែមក្នុងកាលសំពត់មិនល្មម, បើសំពត់ល្មម មិនគួរបន្ថែមសំពត់ថ្មី គប្បីកាត់ប៉ុណ្ណោះ ។

## ពណ៌នាអំពីធ្វើសទ្ធាទេយ្យឱ្យធ្លាក់ជាដើម

[៦៨] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ សទ្ធាទេយ្យំ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន(ត្រូវ)ធ្វើទានដែលគេឱ្យដោយសទ្ធា នេះ គប្បីជ្រាបដូច្នេះ ៖

កាលឱ្យដល់ញាតិដ៏សេសទាំងឡាយ ឈ្មោះថា ញុំាងសទ្ធាទេយ្យឱ្យធ្លាក់ចុះពិត, ចំណែកមាតាបិតាសូម្បីតាំងនៅក្នុងភាពជាព្រះរាជា បើប្រាថ្នា គប្បីឱ្យ ។

[៦៩] បទថា គិលានោ : ភិក្ខុមានជម្ងឺ បានដល់ អ្នកមិនអាច

នឹងកាន់យកទៅបាន ព្រោះជាអ្នកអាពាធ ។

បទថា វស្សំវុដ្ឋោ សាវត្ថិយំ : មានកំណត់ដោយរដូវភ្លៀង ៤ ខែ បានដល់ ៤ ខែក្នុងរដូវភ្លៀង ។

បទថា ឧធ្ធារំ : ត្រើយស្ទឹងខាងនាយ បានដល់ ជាភត្តដែលភិក្ខុគប្បីឆាន់នៅក្បែរមាត់ស្ទឹង ។

បទថា អគ្គឡគុត្តិវិហារោ : វិហារមានការរក្សាមាំមួន មានសេចក្តីថា ក៏កុដិដែលនៅមានស្នៀតជាគ្រឿងឃុំគ្រងប៉ុណ្ណោះ ជាប្រមាណក្នុងភាពជាអ្នកអាពាធ សេចក្តីកំណត់ សំដៅសេចក្តីថា ជាខែមានក្នុងរដូវភ្លៀង ការទៅកាន់ត្រើយស្ទឹង និងការមានកឋិនដែលក្រាលហើយ ទាំងអស់នេះឯង, ពិតមែន ភិក្ខុរក្សាទុកក្នុងកុដិដែលឃុំគ្រងបានប៉ុណ្ណោះ ទើបគួរទៅក្នុងខាងក្រៅ រក្សាទុកក្នុងកុដិដែលមិនបានឃុំគ្រងមិនគួរទៅ ។ តែកុដិរបស់ភិក្ខុដែលនៅក្នុងព្រៃ រមែងមិនជាកុដិដែលឃុំគ្រងដោយល្អ ដែលភិក្ខុនៅក្នុងព្រៃនោះ គប្បីរក្សាទុកក្នុងផ្ទាំងសម្រាប់រក្សាភណ្ឌៈ ហើយលាក់ទុកក្នុងទីដែលជាប់មាំល្អ មានរូងថ្ម និងរូងឈើជាដើមហើយ សឹមទៅ ។

# សំពត់ដែលកើតឡើងក្នុងចីវរកាល

[៧០] ពាក្យថា តុម្ហេវ ភិក្ខុ តាហិ ចីវរានិ : ម្នាលភិក្ខុទាំងឡាយ ចីវរទាំងនោះ ជារបស់អ្នក មានសេចក្តីថា ចីវរទាំងនោះសូម្បីដែលលោកកាន់នាំទៅហើយក្នុងទីដទៃ រមែងជារបស់លោកប៉ុណ្ណោះ, អ្នកណា ៗ ដទៃមិនជាធំនៃចីវរទាំងនោះ ។

ក៏គ្រាត្រាស់យ៉ាងនោះហើយ ទើបត្រាស់ពាក្យថា ឥធ បន ជាដើម ដើម្បីសម្តែងថា សូម្បីក្នុងអនាគត ភិក្ខុទាំងឡាយ នឹងជាអ្នកមិនមានសេចក្តីវង្វេងសកាន់យក ។

ពាក្យថា តស្សេវ តានិ ចីវរានិ យាវ កឋិនស្ស ឧព្ភារាយ : ចីវរទាំងនោះដល់ភិក្ខុនោះឯង កំណត់ត្រឹមកឋិនដោះ មានសេចក្តីថា បើបានភិក្ខុគ្រប់គណៈ កឋិនជាការក្រាលហើយ ចីវរទាំងនោះ ជារបស់លោករហូតអស់ ៥ ខែ; បើមិនបានក្រាលកឋិន ជារបស់លោករហូតអស់ចីវរមាស តែមួយខែ ប៉ុណ្ណោះ ។

ចីវរណា ៗ ដែលពួកទាយកថ្វាយថា "ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ"ក្តី "ខ្ញុំព្រះករុណាថ្វាយចំពោះសង្ឃ"ក្តី "ខ្ញុំព្រះករុណា ថ្វាយដល់សង្ឃដែលចាំវស្សាហើយ"ក្តី "ខ្ញុំព្រះករុណា ថ្វាយសំពត់ចំណាំវស្សាក្តី" សូម្បីថា ចីវរមតិកនៅមិនទាន់បានចែក ភិក្ខុទាំងឡាយចូលទៅកាន់វត្តនោះ

ចីវរទាំងពួងនោះ រមែងជារបស់ភិក្ខុដែលក្រាលកឋិននោះប៉ុណ្ណោះ ។ ភិក្ខុនោះ កាន់យកសំពត់ចាំវស្សាអំពីទ្រព្យដែលវេយ្យាវច្ចករតាំងទុក ប្រកបផ្កាប្រាក់ ដើម្បីប្រយោជន៍ដល់សំពត់ចំណាំវស្សា ឬ អំពីទ្រព្យសង្ឃដែលកើតក្នុងវត្តនោះ សំពត់ចំណាំវស្សាទាំងអស់នោះ ជាការដែលលោកកាន់យកដោយល្អពិត ។

ពិតមែន ក្នុងពាក្យថា តស្សេវ តានិ ចីវរានិ យាវ កឋិនស្ស ឧព្ភារាយ នេះ មានលក្ខណៈដូច្នេះ ៖

សំពត់ដែលកើតឡើងដល់សង្ឃដោយអាការណា ៗ ក៏ដោយ រមែងត្រូវបានដល់ភិក្ខុដែលក្រាលកឋិនហើយ រហូតអស់ ៥ ខែ ដល់ភិក្ខុដែលមិនបានក្រាលកឋិន រហូតដល់អស់ចីវរមាសមួយខែ ។

ចំណែកសំពត់ណា ដែលទាយកពោលថ្វាយថា “ខ្ញុំព្រះករុណាថ្វាយដល់សង្ឃដែលចាំវស្សាក្នុងវត្តនេះ” ឬថា “ខ្ញុំព្រះករុណា ថ្វាយសំពត់ចំណាំវស្សា” សំពត់នោះ រមែងដល់សូម្បីភិក្ខុដែលមិនបានក្រាលកឋិន រហូតដល់អស់ ៥ ខែ ។ សំពត់ចំណាំវស្សាដែលកើតឡើងក្រៅអំពីសំពត់ដែលពោលហើយនោះ ភិក្ខុគប្បីសួរមើលថា នេះជាសំពត់ចំណាំវស្សាសម្រាប់វស្សា ដែលកន្លងទៅហើយឬ ? ឬថាសម្រាប់វស្សាដែលនៅមិនទាន់មកដល់ ហេតុអ្វី ទើបត្រូវសួរ ? ព្រោះសំពត់នោះ កើតឡើងក្រោយសម័យ ។

# សំពត់ដែលកើតឡើងក្នុងរដូវកាល

បទថា ឧតុកាលំ : កាលនៃរដូវ បានដល់ កាលដទៃអំពីរដូវភ្លៀង ។

វិនិច្ឆ័យក្នុងពាក្យថា តានិ ចីវរានិ អាទាយ សាវត្ថឹ គន្ត្វា : ភិក្ខុនោះ ក៏បាននាំយកចីវរទាំងនោះទៅកាន់ក្រុងសាវត្ថី នេះ គប្បីជ្រាបដូច្នេះ ៖

ចីវរទាំងនោះ រមែងជារបស់សង្ឃ ក្នុងទីដែលលោកទៅដល់ហើយ ៗ ប៉ុណ្ណោះ សំពត់ត្រឹមតែភិក្ខុទាំងឡាយ ឃើញហើយប៉ុណ្ណោះ ជាប្រមាណក្នុងការកាន់យកចីវរនេះ; ព្រោះហេតុនោះ បើភិក្ខុពួកខ្លះ ធ្វើដំណើរតាមមកមក សួរថា "លោកនិមន្តទៅណា ?" បានស្ដាប់សេចក្ដីនោះហើយពោលថា "យើងទាំងឡាយមិនជាសង្ឃឬអ្នកមានអាយុ ?" ហើយបែងចែកគ្នាកាន់យកក្នុងទីនោះតែម្ដង ជាការកាន់យកដោយល្អ ។ សូម្បីបើថា ភិក្ខុនោះ គេចចេញអំពីមកឆៀងចូលមកកាន់វត្ត ឬអាសនៈសាលាកន្លែងណាមួយក្ដី កាលត្រាច់បិណ្ឌបាត ចូលកាន់ផ្ទះណាមួយក្ដី ក៏ឯភិក្ខុទាំងឡាយក្នុងទីនោះ ឃើញលោកហើយសួរសេចក្ដីនោះ ហើយបែងចែកគ្នា កាន់យក ជាការកាន់យកដោយល្អដូចគ្នា ។

វិនិច្ឆ័យក្នុងពាក្យថា អធិដ្ឋាតុំ នេះ គប្បីជ្រាបដូច្នេះ ៖

បើភិក្ខុបំណងនឹងអធិដ្ឋាន គប្បីស្គាល់វត្ត សេចក្តីពិស្តារថា ភិក្ខុនោះគប្បីវាយរគាំងប្រកាសវេលាហើយ រង់ចាំបន្តិចសិន បើភិក្ខុទាំងឡាយមកតាមសញ្ញារគាំង ឬតាមកំណត់វេលា គប្បីបែងចែកជាមួយនឹងភិក្ខុទាំងនោះ; បើមិនមក គប្បីអធិដ្ឋានថា "ចីវរទាំងនេះ ត្រូវបានដល់យើង" កាលអធិដ្ឋានហើយយ៉ាងនោះ ចីវរទាំងពួងជារបស់លោកប៉ុណ្ណោះ ។

ចំណែកលំដាប់មិនតាំងនៅ ។ បើលើកឡើងម្តងមួយផ្ទាំង ៗ កាន់យកយ៉ាងនេះថា នេះចំណែកទី ១ ត្រូវបានដល់យើង នេះចំណែកទី ២, កាលចីវរដែលលោកកាន់យកហើយ ជាការកាន់យក ហើយដោយល្អ; តែលំដាប់គង់តាំងនៅ ។ ចីវរជាការដែលភិក្ខុឱ្យដល់ការកាន់យកយ៉ាងនោះ អធិដ្ឋានហើយដូចគ្នា តែបើភិក្ខុវាយរគាំង ឬមិនវាយក៏ដោយ ប្រកាសវេលា ឬមិនប្រកាសក៏ដោយ កាន់យកដោយធ្វើក្នុងចិត្តថា "ទីនេះមានតែយើងប៉ុណ្ណោះ ចីវរទាំងនេះ រមែងជារបស់យើង" ចីវរទាំងនោះ ជាការកាន់យកមិនប្រពៃ ។ បើលោកកាន់យកដោយធ្វើក្នុងចិត្តថា "ទីនេះមិនមានអ្នកណាដទៃ ចីវរទាំងនេះ រមែងត្រូវបានដល់យើង" ជាការកាន់យកដោយល្អ ។

ពីរបទថា **បាតិតេ កុសេ** : ស្លាកធ្លាក់អស់ទៅហើយ មានសេចក្តីថា កាលស្លាកក្នុងចំណែកទីមួយត្រឹមតែថា ឱ្យចាប់ហើយ សូម្បី

បើមានភិក្ខុទាំងពាន់រូប ចីវរ ឈ្មោះថា ដែលភិក្ខុទាំងពួងកាន់យកហើយពិត ៗ

ពាក្យថា នាកាមា ភាគោ ទាតព្វោ[១] : មិនបាច់ចែកឱ្យទេ មានសេចក្ដីថា ក៏បើថា ភិក្ខុទាំងឡាយជាអ្នកប្រាថ្នានឹងឱ្យតាមពេញចិត្តរបស់ខ្លួនសោត ចូរឱ្យចុះ ។ សូម្បីក្នុងអនុភាគ ក៏មានន័យយ៉ាងនេះដូចគ្នា ។

បទថា សចីវរានិ : ព្រមទាំងចីវរ មានសេចក្ដីថា ជនទាំងឡាយនិយាយគ្នាថា យើងទាំងឡាយនឹងថ្វាយ សូម្បីនូវកាលចីវរដល់សង្ឃ អំពីចំណែកដែលគប្បីថ្វាយដល់ព្រះថេរៈនេះ កាលចីវរនោះដែលយើងទាំងឡាយ ចាត់ទុកមួយ ផ្នែក នឹងយឺតយូរពេក ដូច្នេះ ហើយបានធ្វើភត្តទាំងឡាយ ព្រមទាំងចីវរដោយឆាប់រហ័សតែម្ដង ។

ច្រើនបទថា ថេរេ អាគម្ម ឧប្បន្នានិ : ចីវរទាំងនេះកើតឡើងក៏ព្រោះព្រះថេរៈទាំងឡាយ មានសេចក្ដីថា ចីវរទាំងនេះឆាប់កើតឡើងព្រោះសេចក្ដីជ្រះថ្លាក្នុងលោកទាំងឡាយ ។

ពាក្យថា សង្ឃស្ស ទេមាតិ ចីវរានិ ទេន្តិ : ប្រគេនចីវរទាំងឡាយ ដោយពាក្យថា "សង្ឃស្ស ទេម, យើងទាំងឡាយ សូមប្រគេនចីវរទាំងឡាយនេះ ចំពោះសង្ឃ" មានសេចក្ដីថា ជនទាំងឡាយ ថ្វាយ

១. បិដកថា នាកាមា ទាតព្វោ ភាគោ ។

ជយតិច ៗ ដរាបដល់អស់ចីវរកាលទាំងមូល ។ ចំណែក ២ រឿងមុន ព្រះធម្មសង្គាហកាចារ្យពោលថា អធំសុ : **មនុស្សទាំងនោះ** ព្រោះ មនុស្សទាំងឡាយ មានការថ្វាយដោយកំណត់ហើយ ។

ពីរបទថា សម្ពហុលា ថេរា : **ព្រះថេរៈច្រើនអង្គ** បានដល់ ព្រះថេរៈជាព្រះវិន័យធរទាំងឡាយ ។ ក៏ឯរឿងនេះ និងរឿងព្រះថេរៈពីរ នាក់បងប្អូនមុន កើតឡើងកាលព្រះមានព្រះភាគបរិនិព្វានហើយ ចំណែក ព្រះថេរៈទាំងនេះជាអ្នកធ្លាប់ឃើញព្រះតថាគត ព្រោះហេតុនោះ ក្នុងរឿង មុន ៗ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានពោលហើយ តាមន័យ ដែលព្រះតថាគតទ្រង់បញ្ញត្តិទុកនុ៎ះឯង ។

[៧១] ពីរបទថា **គាមកាវាសំ អគមាសិ** : **ក៏បានដើរទៅកាន់ អាវាសក្បែរស្រុកតូចមួយ** មានសេចក្តីថា ព្រះឧបនន្ទសក្យបុត្រនោះ កំណត់ហើយនូវកាលជាទីបែងចែកចីវរថា "ធ្វើដូចម្តេចហ្ន៎ ភិក្ខុទាំង ឡាយកលនាំគ្នាបែងចែកចីវរ គប្បីធ្វើសេចក្តីសង្គ្រោះដល់យើងខ្លះ" ដូច្នេះ ទើបបានទៅ ។

បទថា សាទិយិស្សសិ : **តើលោកត្រេកអរដែរទេ** គឺ នឹងកាន់ យកឬ ? ពិតមែន ក្នុងរឿងនេះ ចំណែករមែងមិនត្រូវបានដល់ព្រះ ឧបនន្ទសក្យបុត្រនោះ ក៏ពិតហើយ ប៉ុន្តែ ភិក្ខុទាំងនោះ បានពោលថា

“លោកនឹងទទួលឬ ?” ដូច្នេះ ដោយធ្វើក្នុងចិត្តថា “ព្រះថេរៈនេះ ជាអ្នកក្រុងជាធម្មកថិក មានថ្វីមាត់” ។

ក៏វិនិច្ឆ័យក្នុងពាក្យថា **យោ សាធិយេយ្យ, អាបត្តិ ទុក្កដស្ស : ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ** នេះ គប្បីជ្រាបដូច្នេះ ៖

ជាលហុកាបត្តិ ក៏ពិតមែន តែថា ចីវរដែលកាន់យកហើយ ក៏គួរសងវិញក្នុងកន្លែងដែលខ្លួនកាន់យក; សូម្បីបើថា ចីវរទាំងនោះ ជារបស់វិនាសអស់ទៅក្តី ចាស់ទៅក្តី រមែងជាសំណាងដែលភិក្ខុនោះ ត្រូវសងវិញដោយពិត ។ កាលភិក្ខុទាំងនោះពោលថា “លោកចូរឱ្យ” កាលលោកមិនឱ្យ គប្បីឱ្យពិន័យតាមតម្លៃរបស់ក្នុងកាលដាក់ធុរៈ ។

បទថា **ឯកាធិប្បាយំ : តែមួយចំណែក** មានសេចក្តីថា លោកទាំងឡាយ ចូរឱ្យចំណែកជាទីប្រាថ្នាតែមួយ គឺ ចំណែកនៃបុគ្គលតែម្នាក់ប៉ុណ្ណោះ ។ ឥឡូវនេះ ព្រះមានព្រះភាគនឹងទ្រង់ដាក់បែបផែន ទើបត្រាស់ពាក្យថា **ឥធ បន : បើក្នុងសាសនានេះ** ជាដើម ដើម្បីសម្តែងអាការសម្រាប់ភិក្ខុ នឹងគប្បីឱ្យចំណែកចំពោះបុគ្គលតែម្នាក់នោះ ។

បណ្តាបទទាំងនោះ ប្រើនបទថា សចេ អមុត្រ ឧបឌ្ឍំ អមុត្រ ឧបឌ្ឍំ : **បើភិក្ខុចាំវស្សាក្នុងអាវាសឯណោះ បានពាក់កណ្តាល ចាំវស្សាក្នុងអាវាសឯណោះបានពាក់កណ្តាល** មានសេចក្តីថា បើថា ភិក្ខុនោះ

នៅក្នុងវត្តទីមួយ ៗ ១ ថ្ងៃខ្លះ ៧ ថ្ងៃខ្លះ បុគ្គលម្នាក់ រមែងបានចំណែកណា ក្នុងវត្តទីមួយ ៗ គប្បីឱ្យមួយវត្ត ៗ កន្លះចំណែក, អំពីចំណែក (ម្នាក់)នោះ ៗ ។

ចំណែកជាទីប្រាថ្នាតែមួយ ឈ្មោះថា ជាការដែលភិក្ខុទាំងឡាយឱ្យហើយ ដោយប្រការដូច្នេះ ។

ពាក្យថា យត្ថ វា បន ពហុតរំ : **ប្រសិនបើភិក្ខុចាំវស្សាក្នុងអាវាសណាច្រើនជាង** មានសេចក្តីថា បើភិក្ខុនៅក្នុងវត្តមួយ ទទួលតែអរុណប៉ុណ្ណោះ, ដោយវារៈ ៧ ថ្ងៃ នៅក្នុងវត្តក្រៅនេះ ដោយប្រការយ៉ាងនេះ លោកឈ្មោះថា នៅច្រើនជាងក្នុងវត្តមុន; ព្រោះដូច្នោះ គប្បីឱ្យចំណែកអំពីវត្តដែលលោកនៅច្រើនជាងនោះដល់លោក; ចំណែកជាទីប្រាថ្នាតែមួយ ជាការដែលភិក្ខុទាំងឡាយឱ្យហើយ ដោយប្រការយ៉ាងនេះខ្លះ ។ ក៏ការឱ្យចំណែកជាទីប្រាថ្នាតែមួយនេះ ព្រះមានព្រះភាគត្រាស់ដោយច្រើន វត្តមានសីមាតែមួយ តែលាភផ្សេងគ្នា ឧបចារៈផ្សេងគ្នា ។ ចំណែកក្នុងវត្ត ដែលមានសីមាផ្សេងគ្នា ការកាន់សេនាសនៈ រមែងរម្ងាប់ ។ ព្រោះហេតុនោះ ចំណែកនៃចីវរក្នុងវត្តនោះ រមែងមិនត្រូវបាន (ដល់លោក) ។ តែវត្ថុដ៏សេសទាំងអស់ មានអាមិសនិងភេសជ្ជៈជាដើម រមែងត្រូវបានដល់ភិក្ខុដែលនៅខាងក្នុងសីមាក្នុងវត្តដែលមានសីមាតែមួយ និងវត្តដែលមានសីមាផ្សេង ៗ គ្នាទាំងពួង ។

# គិលានុបដ្ឋាក

[៧២] ពីរបទថា មញ្ចកេ និបាតេសុំ : ដាក់ឱ្យដេកលើគ្រែតូច មានសេចក្តីថា គ្រាលាងហើយយ៉ាងនោះ ស្លៀកសំពត់កាសាវៈ ផ្ទាំងដទៃឱ្យហើយ ទើបឱ្យដេកលើគ្រែ; ក៏លួមឱ្យដេកហើយ ព្រះអានន្ទដ៏មានអាយុបានបោកគក់សំពត់កាសាវៈ ដែលប្រលាក់មូត្រ និងករីស ហើយ បានធ្វើការលាងជម្រះទីផ្ទៃដី ។

ពាក្យថា យោ ភិក្ខវេ មំ ឧបដ្ឋហេយ្យ សោ គិលានំ ឧបដ្ឋហេយ្យ : អ្នកណាបម្រើតថាគត អ្នកនោះឈ្មោះថា បម្រើភិក្ខុឈឺ មានសេចក្តីថា ភិក្ខុណា ឧបដ្ឋាកតថាគត ដោយធ្វើតាមឱវាទានុសាសនី, ភិក្ខុនោះ គប្បីឧបដ្ឋាកភិក្ខុអាពាធចុះ ។

ក្នុងសេចក្តីនេះ មានសេចក្តីដូច្នេះថា ភិក្ខុដែលធ្វើតាមឱវាទរបស់តថាគត គប្បីឧបដ្ឋាកភិក្ខុដែលអាពាធ និងក្នុងសេចក្តីនេះ មិនគួរកាន់យកសេចក្តីយ៉ាងនេះថា ការឧបដ្ឋាកព្រះមានព្រះភាគ នឹងឧបដ្ឋាកភិក្ខុអាពាធដូចតែគ្នា ។

ពាក្យថា សង្ឃេន ឧបដ្ឋាបេតព្វោ : សង្ឃត្រូវបម្រើភិក្ខុមានជម្ងឺនោះ មានសេចក្តីថា ភិក្ខុទាំងនេះ មានឧបជ្ឈាយ៍ជាដើម របស់ភិក្ខុណា មិនមានក្នុងវត្តនោះ ភិក្ខុណាជាអាគន្តុកៈត្រាច់ទៅតែមួយរូប, ភិក្ខុ

នោះ ជាភារៈរបស់ភិក្ខុសង្ឃ ព្រោះហេតុនោះ លោកដែលសង្ឃគប្បីឧបដ្ឋាក បើមិនឧបដ្ឋាក ជាអាបត្តិដល់សង្ឃទាំងអស់ ។

ក៏ឯក្នុងភិក្ខុទាំងឡាយអ្នកតាំងវារៈព្យាបាល ភិក្ខុណា មិនព្យាបាលក្នុងវារៈរបស់ខ្លួន ជាអាបត្តិដល់ភិក្ខុនោះប៉ុណ្ណោះ ។ សូម្បីព្រះសង្ឃត្រូវក៏មិនផុតពីវារៈ ។

បើសង្ឃទាំងអស់ទុកដាក់ភារៈដល់ភិក្ខុមួយរូប ឬភិក្ខុដែលបរិបូណ៌ដោយវត្តមួយរូប ទទួលរាប់រងថា "ខ្ញុំព្រះករុណានឹងព្យាបាលដោយខ្លួនឯង" ហើយក៏បដិបត្តិដល់ភិក្ខុអាពាធនោះ សង្ឃរមែងផុតពីអាបត្តិ ។

ក្នុងពាក្យថា អភិក្កន្តំ វា អភិក្កមតិ **: មិនប្រាប់អាពាធដែលចម្រើនឡើងថា ចម្រើនឡើងក្តី មិនប្រាប់អាពាធដែលធូរថយថា ធូរថយក្តី** ជាដើម គប្បីយល់សេចក្តីយ៉ាងនេះថា ៖

ភិក្ខុដែលអាពាធមិនបញ្ជាក់ប្រាប់នូវអាពាធ ដែលកម្រើកឡើងតាមពិតថា "កាលខ្ញុំព្រះករុណាបរិភោគថ្នាំឈ្មោះនេះ អាពាធចម្រើនកាលខ្ញុំព្រះករុណាបរិភោគថ្នាំឈ្មោះនេះ អាពាធក៏ធូរស្រាល កាលខ្ញុំព្រះករុណាបរិភោគ ថ្នាំឈ្មោះនេះ អាពាធនៅតែដដែល" ។

បទថា ឆាលំ **: មិនគួរទេ** មានសេចក្តីថា អ្នកមិនសមគួរ គឺមិនសមគួរដើម្បីព្យាបាល ។

ពីរបទថា ភេសជ្ជំ សំវិធាតុំ **: ចាត់ចែងថ្នាំ** មានសេចក្តីថា ជា

អ្នកមិនអាចដើម្បីផ្សំថ្នាំ ។

បទថា អាមិសន្តរោ : ចង់បានតែអាមិស មានវិគ្រោះថា អាមិសជាហេតុរបស់ភិក្ខុនោះ ព្រោះដូច្នោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានអាមិសជាហេតុ ។ ហេតុលោកហៅថា អន្តរំ : ចង់បាន សេចក្ដីថា ភិក្ខុដែលមានអាមិសជាហេតុ ប្រាថ្នាយាគូ ភត្ត បាត្រ និងចីវរ ទើបព្យាបាល ។

[៧៣] បទថា កាលកតេ : ធ្វើមរណៈកាលទៅហើយ គឺព្រោះធ្វើកាលកិរិយា ។

វិនិច្ឆ័យក្នុងពាក្យថា គិលានុបដ្ឋាកានំ ទាតុំ : ឱ្យដល់ភិក្ខុអ្នកបម្រើជម្ងឺចុះ នេះ គប្បីជ្រាបដូច្នេះ ៖

បាត្រនិងចីវររបស់ភិក្ខុអ្នកធ្វើកាលកិរិយានោះ ដែលសង្ឃឱ្យដល់ភិក្ខុអ្នកព្យាបាល ដោយកម្មវាចាដែលត្រាស់ជាលំដាប់ទៅក្ដី អបលោកន៍ឱ្យក្ដី រមែងជាការឱ្យដូចគ្នា, គួរទាំងពីរយ៉ាង ។

ក្នុងពាក្យថា យំ តត្ថ លហុភណ្ឌំ យំ តត្ថ គរុភណ្ឌំ : វត្ថុណាជាគ្រឿងលហុភណ្ឌនៅក្នុងទីនោះ វត្ថុណាជាគ្រឿងគរុភណ្ឌនៅក្នុងទីនោះ ខ្ញុំព្រះករុណា នឹងពណ៌នាការធ្វើផ្សេងគ្នានៃលហុភណ្ឌ និងគរុភណ្ឌខាងមុខ[១] ។

១. សមន្ត. ចុល្ល. សេនាសនក្ខន្ធក ៦. ៣០៩.../១៣៥ ។

# វិនិច្ឆ័យក្នុងលាភរបស់ភិក្ខុអ្នកព្យាបាលជម្ងឺ

ចំណែកក្នុងលាភរបស់ភិក្ខុជាអ្នកព្យាបាលជម្ងឺ មានវិនិច្ឆ័យតាំងអំពីដើម ដូចតទៅនេះ ៖

បើភិក្ខុសង្ឃទាំងអស់ព្យាបាល ភិក្ខុឈឺធ្វើកាលកិរិយា, សង្ឃជាម្ចាស់របស់ទាំងអស់ ។

បើថា ពួកខ្លះធ្វើវេន ។ ពួកខ្លះមិនធ្វើវេនឡើយ, ភិក្ខុឈឺធ្វើកាលកិរិយា ក្នុងកាលកិរិយាយ៉ាងនោះរបស់ភិក្ខុនោះ អាចារ្យពួកខ្លះពោលថា ភិក្ខុសូម្បីទាំងពួង គប្បីធ្វើក្នុងវារៈដែលដល់ខ្លួន, ព្រោះដូច្នោះ ភិក្ខុសូម្បីទាំងពួងជាម្ចាស់របស់ ។

ពួកខ្លះពោលថា ភិក្ខុឈឺនោះ ដែលភិក្ខុពួកណាព្យាបាល, ភិក្ខុពួកនោះប៉ុណ្ណោះ រមែងបាន, ភិក្ខុក្រៅអំពីនោះ មិនបាន ។

បើថា កាលសាមណេរ សូម្បីធ្វើកាលកិរិយា ចីវររបស់លោកមាន, គប្បីឱ្យដល់អ្នកព្យាបាលជម្ងឺ, បើចីវរមិនមាន, វត្ថុណាមាន គប្បីឱ្យវត្ថុនោះ, កាលបរិក្ខារដទៃមាន គប្បីធ្វើឱ្យជាចំណែកនៃចីវរហើយឱ្យ ។

ទាំងភិក្ខុនិងសាមណេរ បើថា ព្យាបាលស្មើគ្នា, គប្បីឱ្យចំណែកស្មើគ្នា ។

បើថា សាមណេរប៉ុណ្ណោះព្យាបាល, កិច្ចត្រឹមតែថា ជួយចាត់ចែងប៉ុណ្ណោះជារបស់ភិក្ខុ គប្បីឱ្យចំណែកធំដល់សាមណេរ ។

បើថា សាមណេរដាំបបរដោយទឹកដែលភិក្ខុនាំមក ធ្វើកិច្ចត្រឹមតែឱ្យទទួលប្រគេនប៉ុណ្ណោះ, ភិក្ខុព្យាបាល, គប្បីឱ្យចំណែកធំដល់ភិក្ខុ, ភិក្ខុច្រើនរូប ជាអ្នកព្រមព្រៀងជួយគ្នា ព្យាបាលទាំងអស់, គប្បីឱ្យចំណែកស្មើគ្នាដល់លោកគ្រប់រូប ។

ក៏ក្នុងភិក្ខុទាំងនេះ រូបណាព្យាបាលដោយពិសេស, គប្បីឱ្យចំណែកពិសេសដល់ភិក្ខុនោះ ។

មួយទៀត អ្នកណាចម្អិនយាគូនិងភត្តឱ្យ ឬចាត់ចែងផ្តួតទឹកដែលជាប់ដោយអ្នកព្យាបាលជម្ងឺ មួយថ្ងៃ, សូម្បីអ្នកនោះក៏ចាត់ថា អ្នកព្យាបាលជម្ងឺដូចគ្នា ។

ភិក្ខុណាមិនចូលជិត បញ្ចូនតែថ្នាំនិងអង្ករជាដើមខ្លះ, ភិក្ខុនេះមិនចាត់ថា អ្នកព្យាបាលជម្ងឺ ។

ចំណែកភិក្ខុណា ស្វែងរកឱ្យអនុបសម្បន្នកាន់មក, ភិក្ខុនេះចាត់ជាអ្នកព្យាបាលជម្ងឺពិត, គប្បីឱ្យចំណែកសូម្បីដល់ភិក្ខុនោះ ។

ភិក្ខុមួយរូបព្យាបាលដោយសម្ងំវត្តជាធំ, មួយរូបព្យាបាលដោយប្រាថ្នាលាភ, ក្នុងវេលាដែលភិក្ខុឈឺមរណភាព លោកទាំងពីរមានបំណងចង់បាន, គប្បីឱ្យដល់លោកទាំងពីររូប ។

មួយរូបព្យាបាលហើយ ចេញទៅក្នុងទីណា ៗ ដោយធុរៈរបស់ភិក្ខុឈឺ ឬដោយធុរៈរបស់ខ្លួន គិតថា យើងនឹងមកព្យាបាលទៀត សូម្បី

ភិក្ខុនេះ ក៏គួរឱ្យ ។

មួយរូបនៅព្យាបាលយូរមកហើយ ដាក់ធុរៈថា "ឥឡូវនេះ យើងមិនអាច" ហើយចេញទៅ; សូម្បីបើថា ភិក្ខុឈឺមរណភាពក្នុងថ្ងៃនោះឯង, មិនគប្បីឱ្យចំណែកនៃអ្នកព្យាបាល ។

ដែលឈ្មោះថា អ្នកព្យាបាលជម្ងឺ ជាគ្រហស្ថ ឬជាបព្វជិត ឬដោយហោចទៅ សូម្បីជាមាតុគ្រាមក៏ដោយ, គ្រប់រូបរមែងបានចំណែក ។ បើថា របស់ភិក្ខុនោះ មានត្រឹមតែបាត្រនិងចីវរប៉ុណ្ណោះ, របស់ដទៃមិនមាន, បាត្រនិងចីវរទាំងអស់ គប្បីឱ្យដល់អ្នកព្យាបាលជម្ងឺប៉ុណ្ណោះ, សូម្បីបើថា នឹងមានតម្លៃមួយពាន់ ។

តែអ្នកព្យាបាលទាំងនោះ រមែងមិនបានបរិក្ខារសូម្បីច្រើនយ៉ាងដទៃ, បរិក្ខារដទៃទៀត រមែងជារបស់សង្ឃប៉ុណ្ណោះ ។ វត្ថុដ៏សេសច្រើននិងមានតម្លៃច្រើន, ត្រៃចីវរមានតម្លៃតិច, បរិក្ខារ គឺ ត្រៃចីវរ គប្បីកាន់យកអំពីទ្រព្យដ៏សេសនោះឱ្យ, ក៏បាត្រត្រៃចីវរទាំងអស់នោះ ដែលអ្នកព្យាបាលជម្ងឺ រមែងបានពីទ្រព្យរបស់សង្ឃ ។

ក៏បើថា ភិក្ខុឈឺនោះនៅរស់ បានលះបរិក្ខាររបស់ខ្លួនទាំងអស់ឱ្យដល់អ្នកណា ៗ ជាមុនហើយ, ឬថា អ្នកណា ៗ បានកាន់យកជាវិស្សាសៈមុនហើយ, របស់នោះ លោកឱ្យហើយដល់អ្នកណា, និងអ្នកណាកាន់យកហើយ, រមែងជារបស់អ្នកនោះប៉ុណ្ណោះ ។ អ្នកព្យាបាល

ជម្ងឺ រមែងបានដោយសេចក្ដីពេញចិត្តរបស់អ្នកនោះប៉ុណ្ណោះ ។

ចំណែកបរិក្ខារទាំងឡាយ ដែលភិក្ខុឈឺមិនបានឱ្យដល់បុគ្គលពួកដទៃ រក្សាទុកក្នុងទីឆ្ងាយ រមែងជារបស់សង្ឃក្នុងទីនោះ ៗ ប៉ុណ្ណោះ ។

បើជារបស់ពីរម្ចាស់ មិនបានបែងចែកគ្នា, កាលភិក្ខុមួយរូបធ្វើកាលកិរិយា ភិក្ខុមួយរូបទៀត រមែងជាម្ចាស់របស់, ក្នុងរបស់សូម្បីច្រើនម្ចាស់ ក៏ន័យនេះឯង ។

កាលម្ចាស់របស់មរណភាពទាំងអស់ រមែងជារបស់សង្ឃ ។

ប្រសិនបើថា ភិក្ខុដែលជាម្ចាស់របស់ទាំងនោះ មិនបែងចែកគ្នាឱ្យដល់និស្សិតទាំងឡាយ មានសទ្ធិវិហារិកជាដើម, មិនឈ្មោះថា ឱ្យឡើយ, តែបែងចែកហើយឱ្យ ទើបជាការឱ្យដោយល្អ, កាលភិក្ខុដែលជាម្ចាស់របស់ទាំងនោះ សូម្បីមរណភាពហើយ រមែងជារបស់និស្សិតទាំងឡាយ មានសទ្ធិវិហារិកជាដើមប៉ុណ្ណោះ, មិនជារបស់សង្ឃ ។

## ចីវរដែលមិនគួរ

វិនិច្ឆ័យក្នុងចីវរធ្វើពីស្បូវជាដើម គប្បីជ្រាបដូច្នេះ ៖

[៧៤] បទថា អក្កនាលំ : សំពត់ដែលគេធ្វើពីដើមរាក់ បានដល់ ចីវរដែលធ្វើដោយដើមរាក់ ។

សំពត់ដែលធ្វើដោយផ្ទៃ ហៅថា សំពត់សំបកឈើ ។ សំពត់

ដ៏សេស បានពោលទុកហើយក្នុងអដ្ឋកថានៃបឋមបារាជិក[១] ។

ក្នុងសំពត់ទាំងនោះ ចំពោះសំពត់សំបកក្រចៅ ពិន័យទុក្កដ ក្នុងសំពត់ដ៏សេសពិន័យថុល្លច្ច័យ ។

ចំណែកសំពត់សំបករាក់ សំពត់ស្រទបចេកនិងសំពត់សំបកវែទឹក មានគតិដូចសំពត់សំបកក្រចៅដែរ ។

[៧៥] ចីវរមានពណ៌ខៀវសុទ្ធជាដើម គប្បីសម្រេកពណ៌ចេញជ្រលក់ថ្មីហើយ សឹមប្រើ, បើជារបស់ដែលមិនអាចសម្រេកពណ៌ចេញបាន, គប្បីឱ្យធ្វើជាសំពត់កម្រាល ឬគប្បីសៀតចូលខាងក្នុងកណ្តាលចីវរពីរជាន់ ។

ការផ្សេងគ្នានៃពណ៌របស់ចីវរទាំងនោះ មានន័យដូចពោលហើយក្នុងស្បែកជើងនុ៎ះឯង ។ សំពត់ទាំងឡាយ ដែលមានជាយមិនបានកាត់ និងមានជាយវែង គប្បីកាត់ជាយចេញហើយសិន សឹមប្រើ ។

ភិក្ខុបានអាវហើយរុះថ្មេរចេញជ្រលក់ប្រើ រមែងគួរ ។ សូម្បីក្នុងសំពត់ជួតក្បាលក៏ន័យនេះឯង ។

ចំណែកមួកជារបស់ដែលធ្វើដោយសំបកឈើ ទឹងធ្វើមួកនោះឱ្យជារបស់សម្រាប់ជូតជើងក៏គួរ ។

---

១. សមន្ត. បារា. ២. ៥៣១៩២ : សំពត់សំបកឈើរបស់ពួកតាបស ឈ្មោះថាសំពត់សំបកផ្ទៃ ។

# អ្នកគួរទទួលចីវរជាដើម

[៧៦] ពីរបទថា បដិរូបេ គាហកេ : អ្នកទទួលយកចីវរដ៏សមគួរ មានសេចក្ដីថា បើភិក្ខុរូបខ្លះ ទទួលយកដោយពោលថា "យើងទទួលជំនួសភិក្ខុនោះ" គប្បីឱ្យ ។ ដោយប្រការយ៉ាងនេះឯង បណ្ដាបុគ្គលទាំង ២៣ នាក់នោះ មិនបាន ១៦ នាក់ បាន ៧ នាក់ ដូច្នេះឯង ។

ពីរបទថា សង្ឃោ ភិជ្ជតិ : សង្ឃក៏បែកគ្នា មានសេចក្ដីថា ភិក្ខុទាំងឡាយ បែកគ្នាជា ២ ពួក ដូចភិក្ខុក្រុងកោសម្ពី ។

ពីរបទថា ឯកស្មឹ បក្ខេ : ចំពោះភិក្ខុមួយពួក មានសេចក្ដីថា ជនទាំងឡាយ ថ្វាយទឹកទក្ខិណោទក និងវត្ថុមានរបស់ក្រអូបជាដើមក្នុងចំណែកមួយ ។ ថ្វាយចីវរក្នុងចំណែកមួយ ។

បទថា សង្ឃស្សេវេតំ : ទឹកនិងចីវរនេះ ក៏នៅជារបស់ពួកដដែល មានសេចក្ដីថា ចីវរនោះ ក៏ជារបស់សង្ឃទាំងអស់ គឺ របស់ទាំងពីរចំណែក, ទាំងពីរចំណែកគប្បីវាយរគាំងហើយចែកជាមួយគ្នា ។

បទថា បក្ខស្សេវេតំ : ទឹកនិងចីវរនេះ ក៏នៅជារបស់ពួក

ដដែល មានសេចក្តីថា កាលជនទាំងឡាយ ថ្វាយយ៉ាងនោះ ទឹកដែលគេថ្វាយហើយដល់ចំណែកណា, ទឹកនុ៎ះឯង រមែងជារបស់ចំណែកនោះ, ចីវរដែលថ្វាយហើយ ដល់ចំណែកណា, ចីវរ រមែងជារបស់ចំណែកនោះប៉ុណ្ណោះ ។

ក្នុងមហាអដ្ឋកថា ពោលថា ក៏ក្នុងទីណា ទឹកទក្ខិណោទកជាប្រមាណ, ក្នុងទីនោះ ចំណែកមួយ រមែងបានចីវរ ព្រោះខ្លួនបានទឹកទក្ខិណោទក, មួយចំណែកក៏រមែងបាន ព្រោះតម្លៃដែលចីវរនោះឯងខ្លួនបានហើយ, ព្រោះដូច្នោះ ពីរចំណែកគប្បីជាអ្នកព្រមព្រៀងគ្នា ចែកគ្នាតាមលំដាប់វស្សា ។

បានឮថា នេះជាលក្ខណៈក្នុងសមុទ្រដទៃ[១] (គឺ ជម្ពូទ្វីប)

ចំណែកក្នុងពាក្យថា តស្មឹំយេវ បក្ខេ : ចំពោះភិក្ខុមួយពួកនោះឯង នេះ មានសេចក្តីថា ចំណែកក្រៅនេះ មិនជាធំឡើយ ។

[៧៧] រឿងបញ្ជូនចីវរទៅជាក់ច្បាស់ហើយនោះឯង ។

១. បរសមុទ្ទេតិ ជម្ពុទីបេតិ សារត្ថ ច វិមតិ ច ។

# មាតិកា ៨ នៃការកើតឡើងរបស់ចីវរ

[៧៨] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **អដ្ឋិមា ភិក្ខវេ មាតិកា : ម្នាលភិក្ខុទាំងឡាយ មាតិកា មាន ៨ យ៉ាង** ដើម្បីសម្តែងខេត្តជាទីបានចីវរ ដែលត្រាស់ហើយ ចាប់តាំងពីដំបូង ។

ពាក្យថា **សីមាយ ទេតិ : គេឱ្យចីវរក្នុងសីមា** ជាដើម ត្រាស់ដោយន័យនៃបុគ្គលាធិដ្ឋាន ។

ក៏បណ្តាមាតិកាទាំងនេះ ការថ្វាយដល់សីមា ជាមាតិកាទី១, ការថ្វាយតាមកតិកា ជាមាតិកាទី២, ការថ្វាយក្នុងទីដែលតាក់តែងភិក្ខា ជាមាតិកាទី៣, ការថ្វាយដល់សង្ឃ ជាមាតិកាទី៤, ការថ្វាយដល់សង្ឃ២ចំណែក ជាមាតិកាទី៥, ការថ្វាយដល់សង្ឃចាំវស្សា ជាមាតិកាទី៦, ការថ្វាយចំពោះ ជាមាតិកាទី៧, ការថ្វាយដល់បុគ្គល ជាមាតិកាទី៨ ។

វិនិច្ឆ័យក្នុងមាតិកាទាំងនោះ គប្បីជ្រាបដូច្នេះ ៖

កាលទាយកថ្វាយដល់សីមា យ៉ាងនេះថា "ខ្ញុំព្រះករុណា ថ្វាយដល់សីមា" ឈ្មោះថា **ថ្វាយដល់សីមា** ។ ក្នុងមាតិកាទាំងពួងក៏ន័យនេះឯង ។

# ថ្វាយដល់សីមា

ក៏ក្នុងមាតិកាទី១ នេះថា ខ្ញុំព្រះករុណាថ្វាយដល់សីមា ក្នុងមាតិកានិទ្ទេសដើម ដែលថា ទាយកថ្វាយដល់សីមា, ភិក្ខុមានចំនួនប៉ុនណានៅខាងក្នុងសីមា ភិក្ខុទាំងនោះ គប្បីចែកគ្នា ដូច្នេះ គប្បីជ្រាបសីមា ១៥ ប្រភេទជាមុន គឺ ៖

ខណ្ឌសីមា ឧបចារសីមា សមានសំវាសសីមា អវិប្បវាសសីមា លាភសីមា គាមសីមា និគមសីមា នគរសីមា អព្ភន្តរសីមា ឧទកុក្ខេបសីមា ជនបទសីមា រដ្ឋសីមា រជ្ជសីមា ទីបសីមា ចក្រវាឡសីមា ។

បណ្ដាសីមាទាំងនោះ ខណ្ឌសីមា បានពោលហើយក្នុងសីមាកថា ។ ឧបចារសីមាជាដែនដែលកំណត់ដោយរបងនៃវត្ត, ដោយទីគួរដល់ការធ្វើរបងឡោមព័ទ្ធ នៃវត្តដែលមិនមានរបងព័ទ្ធ ។

ម្យ៉ាងទៀត អំពីស្ថានទីភិក្ខុប្រជុំគ្នាជានិច្ច ឬអំពីរោងឆាន់ដែលតាំងនៅក្នុងទីបំផុតនៃវត្ត ឬអំពីអាវាសដែលនៅប្រចាំខាងក្នុង២ លេណ្ឌបាទរបស់មជ្ឈិមបុរសចូលមក គប្បីជ្រាបថា ជាឧបចារសីមា ។ ក៏

ឧបចារសីមានោះ កាលអាវាសពង្រីកទំហំចេញទៅ រមែងរីកចេញ, កាលអាវាសបង្រួមចូលមក រមែងរួមចូលដែរ ។

តែក្នុងមហាបច្ចរីពោលថា ឧបចារសីមានោះ កាលភិក្ខុកើនឡើង រមែងរីកចេញ ជាប់ដោយលាភ, បើភិក្ខុទាំងឡាយ អង្គុយពេញ ១០០ យោជន៍ជាប់តគ្នាជាពួកតែមួយ មួយអន្លើ ដោយពួកភិក្ខុដែលប្រជុំគ្នាក្នុងវត្ត ។ សូម្បីក្នុងទីមួយរយយោជន៍ រមែងជាឧបចារសីមាផង, លាភរមែងត្រូវបានដល់ភិក្ខុគ្រប់ ៗ រូប ។ សូម្បីសមានសំវាសសីមា និងអវិប្បវាសសីមាទាំង ២ មានន័យ ដូចពោលហើយនុ៎ះឯង ។

ដែលឈ្មោះថា លាភសីមា ព្រះសម្មាសម្ពុទ្ធមិនបានទ្រង់អនុញ្ញាតទេ, ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ក៏មិនបានតាំងទុក, ក៏ប៉ុន្តែថា ព្រះរាជា និង មហាមាត្យរបស់ព្រះរាជាឱ្យសាងវត្តហើយ កំណត់ផ្ទៃដីដោយជុំវិញមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ មួយយោជន៍ខ្លះ បោះសសរចារឹកនូវឈ្មោះទុកថា "នេះជាលាភសីមា សម្រាប់វត្តរបស់យើង" ហើយតាំងនូវសីមាទុកថា "វត្ថុណាកើតឡើង ខាងក្នុងសីមានេះ, វត្ថុទាំងអស់នោះ យើងថ្វាយដល់វត្តរបស់យើង" នេះឈ្មោះថា លាភសីមា ។ សូម្បីគាមសីមា និគមសីមា នគរសីមា អព្ភន្តរសីមា និងឧទកុក្ខេបសីមា ក៏បានពោលហើយ ។

ជនបទសីមានោះ ជនបទជាច្រើន មានខាងក្នុងដែនកាសី និង កោសលជាដើម, ក្នុងជនបទទាំងនោះ ដែនកំណត់នៃជនបទនីមួយ ៗ ឈ្មោះថា ជនបទសីមា ។

ដែនកំណត់នៃដែនកាសី និងកោសលជាដើម ឈ្មោះថា រដ្ឋសីមា[១] ។

ស្ថានជាទីប្រព្រឹត្តទៅនៃអំណាចរបស់ស្តេចផែនដីមួយអង្គ ៗ យ៉ាងនេះគឺ ពលិភោគ ចោលភោគ គេរដ្ឋភោគ ឈ្មោះថា រដ្ឋសីមា ។

កោះធំ និងកោះតូច ដែលកំណត់ដោយសមុទ្រជាទីបំផុត ឈ្មោះ ថា ទីបសីមា ។

ដែនដែលកំណត់ដោយភ្នំចក្រវាឡប៉ុណ្ណោះ ឈ្មោះថា ចក្រវាឡ សីមា ។

ក្នុងសីមាទាំងនេះ ដែលពោលហើយដោយប្រការយ៉ាងនេះ កាល ទាយកឃើញសង្ឃប្រជុំគ្នាក្នុងខណ្ឌសីមា ដោយកម្មឯណានីមួយ ទើប

១. សទ្ទម្មបប្បជ្ជោតិកា បឋម ១៦ ថា "រដ្ឋន្តិ ជនបទេកទេសំ ។ ជនបទោតិ កាសិកោសលាទិ ជនបទោ ? កាន់យកសេចក្តីថា "រដ្ឋ" តូចជាងជនបទ, ជនបទ គឺ ប្រទេស ។ តែតាមដែលពន្យល់ក្នុងទីនេះ ត្រឡប់ផ្ទុយគ្នា ទើបសូមផ្ញើទុកក្នុងអ្នក

សិក្ខាផង ។

ពោលថា ខ្ញុំព្រះករុណាថ្វាយដល់សង្ឃក្នុងសីមា នេះប៉ុណ្ណោះ ដូច្នេះ ។ ភិក្ខុមានចំនួនប៉ុនណានៅខាងក្នុងខណ្ឌសីមា ភិក្ខុពួកនោះ គប្បីបែងចែកគ្នា ។ ព្រោះថា ចីវរនោះ រមែងត្រូវបានដល់ភិក្ខុទាំងនោះប៉ុណ្ណោះ, មិនត្រូវបានដល់ភិក្ខុពួកដទៃ សូម្បីអ្នកតាំងនៅត្រង់សីមន្តរិក ឬត្រង់ឧបចារសីមា ។ តែរមែងត្រូវបានដល់ភិក្ខុដែលតាំងនៅលើដើមឈើ ឬលើភ្នំដែលដុះឡើងនៅក្នុងខណ្ឌសីមា ឬអ្នកនៅត្រង់កណ្តាលផែនដីខាងក្រោមខណ្ឌសីមា ដោយពិត ។

មួយទៀត ចីវរដែលទាយកថ្វាយថា "ខ្ញុំព្រះករុណា សូមថ្វាយដល់សង្ឃក្នុងឧបចារសីមានេះ" រមែងបានសូម្បីដល់ភិក្ខុទាំងឡាយអ្នកតាំងនៅ ក្នុងខណ្ឌសីមានិងសីមន្តរិក ។

ចំណែកចីវរដែលទាយកថ្វាយថា "ខ្ញុំព្រះករុណាថ្វាយដល់សមានសំវាសសីមា" រមែងមិនត្រូវបានដល់ភិក្ខុទាំងឡាយ ដែលតាំងនៅក្នុងខណ្ឌសីមា និង សីមន្តរិក ។

ចីវរដែលទាយកថ្វាយក្នុងអវិប្បវាសសីមា និងលាភសីមា រមែងត្រូវបានដល់ភិក្ខុទាំងឡាយ ដែលនៅរួមក្នុងសីមាទាំងនោះ ។

ចំណែកចីវរដែលទាយកថ្វាយក្នុងគាមសីមាជាដើម រមែងបាន

ដល់សូម្បីភិក្ខុដែលតាំងនៅក្នុងពទ្ធសីមា ខាងក្នុងនៃសីមាទាំងនោះ ។

ចីវរដែលថ្វាយក្នុងអព្ភន្តរសីមា និងឧទកុក្ខេបសីមា រមែងត្រូវបានដល់ភិក្ខុដែលនៅខាងក្នុងសីមាទាំងនោះប៉ុណ្ណោះ ។

ក្នុងជនបទសីមា រដ្ឋសីមា រជ្ជសីមា ទីបសីមា និងចក្រវាឡសីមា មានវិនិច្ឆ័យដូចពោលហើយក្នុងគាមសីមាជាដើមនុ៎ះឯង ។

ក៏បើថា ទាយកនៅក្នុងជម្ពូទ្វីប ពោលថា "ខ្ញុំព្រះករុណា សូមថ្វាយដល់សង្ឃក្នុងតម្ពបណ្ណិទ្វីប ភិក្ខុសូម្បីមួយរូប ទៅអំពីតម្ពបណ្ណិទ្វីប រមែងបានដើម្បីទទួលជំនួសភិក្ខុទាំងពួង ។ សូម្បីបើថា ភិក្ខុដែលពេញចិត្តគ្នាមួយរូប ក្នុងជម្ពូទ្វីបនោះឯង នឹងទទួលចំណែកជំនួសភិក្ខុទាំងឡាយដែលពេញចិត្តគ្នាសោត, មិនគប្បីហាមលោក ។ ក្នុងការថ្វាយរបស់ទាយក ជាអ្នកថ្វាយទាក់ទងដល់សីមា គប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះមុន ។

ចំណែកទាយកណាមិនដឹងដើម្បីពោលថា "ក្នុងសីមាឯណោះ" ដឹងត្រឹមតែពាក្យថា សីមាតែម៉្យាងប៉ុណ្ណោះ មកកាន់វត្តពោលថា "ខ្ញុំព្រះករុណាថ្វាយដល់សីមា" ឬថា "ខ្ញុំព្រះករុណា ថ្វាយដល់សង្ឃដែលតាំងនៅក្នុងសីមា" ដូច្នេះ ។

គប្បីសួរទាយកនោះថា "ដែលឈ្មោះថា សីមា មានច្រើនយ៉ាង, លោកនិយាយសំដៅយកសីមាយ៉ាងណា ?"

បើគេពោលថា "ខ្ញុំព្រះករុណាមិនដឹងថា សីមាប្រភេទ ឯណោះ ៗ សង្ឃអ្នកតាំងនៅក្នុងសីមាចូរបែងចែកគ្នាកាន់យកចុះ" ដូច្នេះ ។

សួរថា តើសង្ឃក្នុងសីមាណា នឹងគប្បីបែងចែកគ្នា ?

ឆ្លើយថា បានឮថា ព្រះមហាសិវត្ថេរពោលថា សង្ឃក្នុងអវិប្បវាសសីមា គប្បីបែងចែកគ្នា ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា ធម្មតាអវិប្បវាសសីមាប្រមាណ ៣ យោជន៍ កាលបើយ៉ាងនេះ ភិក្ខុដែលតាំងនៅក្នុង៣ យោជន៍នឹងទទួលលាភបាន ។ អ្នកតាំងនៅក្នុង៣ យោជន៍ គប្បីបំពេញអាគន្តុកវត្តចូលកាន់អារាម, អ្នកត្រៀមនឹងទៅនឹងធ្វើដំណើរ ៣ យោជន៍ ទើបនឹងប្រាប់ប្រគល់សេនាសនៈ, សម្រាប់អ្នកបដិបត្តិនិស្ស័យ, និស្ស័យនឹងរម្ងាប់ក្នុងកាលកន្លងហួស ៣ យោជន៍ទៅ, អ្នកនៅបរិវាស នឹងគប្បីឈានកន្លង ៣ យោជន៍ហើយទទួលអរុណ ។ ភិក្ខុនីតាំងនៅក្នុងចម្ងាយ ៣ យោជន៍ គប្បីប្រាប់នូវបំណងដែលខ្លួនប្រាថ្នានឹងចូលកាន់អារាម, កិច្ចទាំងអស់នេះ សមគួរធ្វើ ដោយអំណាចដែនកំណត់នៃឧបចារសីមាប៉ុណ្ណោះ, ព្រោះហេតុនោះ សង្ឃដែលតាំងនៅក្នុងឧបចារសីមាប៉ុណ្ណោះ គប្បីបែងចែកគ្នា ។

# ថ្វាយតាមកតិកា

បទថា កតិកាយ : ដោយសេចក្តីប្តេជ្ញា បានដល់ កតិកា មានលាភស្មើគ្នា ។ ដោយហេតុនោះឯង ព្រះមានព្រះភាគត្រាស់ថា "អាវាសច្រើន មានលាភស្មើគ្នា" ។

ក្នុងអាវាសច្រើន ដែលមានលាភស្មើគ្នានោះ គប្បីតាំងកតិកាយ៉ាងនេះ ៖

ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងវិហារមួយ បញ្ជាក់ឈ្មោះវត្ត ដែលខ្លួនមានប្រាថ្នានឹងសង្គ្រោះ ប្រាថ្នានឹងធ្វើឱ្យជាដែនមានលាភស្មើគ្នា ពោលហេតុយ៉ាងណាមួយថា វត្តឯណោះ ជាវត្តចាស់ ឬថា វត្តឯណោះជាទីដែលព្រះពុទ្ធធ្លាប់គង់នៅ ឬថា វត្តឯណោះ មានលាភតិច ហើយប្រកាស ៣ ដងថា "ការដែលធ្វើវត្តនោះ នឹងវត្ត សូម្បីនេះ ឱ្យជាដែនមានលាភតែមួយរួមគ្នា គាប់ចិត្តដល់សង្ឃ" ដូច្នេះ ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ ភិក្ខុសូម្បីអង្គុយហើយក្នុងវត្តនោះ លោករមែងដូចជាអង្គុយហើយក្នុងវត្តនេះ, សូម្បីសង្ឃក្នុងវត្តនោះ គប្បីធ្វើយ៉ាងនោះដូចគ្នា ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ភិក្ខុសូម្បីអង្គុយហើយក្នុងវត្តនេះ, លោករមែងដូចជាអ្នកអង្គុយហើយក្នុងវត្តនោះ ។ កាលបែងចែកលាភគ្នានៅក្នុងវត្តមួយ, ដែលភិក្ខុតាំងនៅក្នុងវត្តមួយទៀត សមគួរបានទទួលចំណែកបែងចែកផង ។ សូម្បីវត្តច្រើន ក៏គប្បីធ្វើឱ្យ

ជាទីមានលាភតែមួយ រួមគ្នានឹងវត្តមួយ ដោយឧបាយយ៉ាងនោះ ។

## ថ្វាយក្នុងទីដែលតាក់តែងភិក្ខា

បទថា ភិក្ខាបញ្ញត្តិយា : ដោយសេចក្តីបញ្ញត្តិនៃភិក្ខា បានដល់ក្នុងស្ថានជាទីតាក់តែងទានបរិច្ចាគរបស់ខ្លួន ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា "ការបូជាជានិច្ច ដែលគេធ្វើចំពោះសង្ឃក្នុងទីណា" ។

គប្បីជ្រាបសេចក្តីនៃពាក្យនោះដូច្នេះ ៖

ភត្តទានរបស់សង្ឃ ដែលជារបស់ទាយកអ្នកថ្វាយចីវរនេះ ប្រព្រឹត្តទៅក្នុងវត្តណាក្តី, ទាយកធ្វើភិក្ខុទាំងឡាយក្នុងវត្តណា ឱ្យជាភារៈរបស់ខ្លួន និមន្តឱ្យឆាន់ក្នុងផ្ទះគ្រប់កាលក្តី, ក្នុងវត្តណា គេសាងទីនៅទុកក្តី, ក្នុងវត្តណាគេថ្វាយសលាកភត្តជាដើមជានិច្ចក្តី, តែវត្តសូម្បីទាំងអស់ដែលទាយកណាសាង, ក្នុងវត្តនោះរបស់ទាយកនោះ មិនមានពាក្យដែលនឹងគប្បីពោលឡើយ ។ ភត្តបរិចាគទាំងនេះ ចាត់ជាភត្តបរិច្ចាគជាប្រចាំ, ព្រោះហេតុនោះ បើគេពោលថា "ភត្តបរិច្ចាគជាប្រចាំរបស់ខ្ញុំព្រះករុណាធ្វើនៅក្នុងវត្តណា, ខ្ញុំព្រះករុណា ថ្វាយក្នុងវត្តនោះ" ឬថា "លោកចូរឱ្យក្នុងវត្តនោះ" សូម្បីបើថា មានភត្តបរិច្ចាគជាប្រចាំក្នុងទីច្រើនកន្លែង, ចីវរនោះ ឈ្មោះថា គេ ថ្វាយទូទៅគ្រប់កន្លែងតែម្តង ។

ក៏បើថា ក្នុងវត្តមួយមានភិក្ខុច្រើនជាង, ភិក្ខុទាំងនោះ គប្បីប្រាប់ថា ក្នុងវត្តដែលមានភត្តបរិច្ចាគជាប្រចាំរបស់ពួកលោក វត្តមួយមានភិក្ខុច្រើន វត្តមួយមានភិក្ខុតិច ។

ប្រសិនបើគេពោលថា "លោកទាំងឡាយ ចូរកាន់យកតាមចំនួនភិក្ខុចុះ" សមគួរបែងចែកកាន់យកតាមនោះ ។

ក៏ក្នុងពាក្យថា "លោកទាំងឡាយចូរកាន់យកតាមចំនួនភិក្ខុចុះ" នេះ សូម្បីសំពត់និងភេសជ្ជជាដើមតិច រមែងបែងចែកគ្នា បានដោយងាយ; តែបើថា គ្រែ ឬតាំងមានតែមួយប៉ុណ្ណោះ, គប្បីសួរគេហើយ គប្បីឱ្យសម្រាប់វត្ត ឬសេនាសនៈ សូម្បីក្នុងវត្តមួយដែលគេចាត់ចែង បើគេពោលថា ភិក្ខុឯណោះ ចូរកាន់យក ដូច្នេះគួរ ។ បើថា គេពោលថា "លោកចូរឱ្យសម្រាប់វត្តដែលមានភត្តបរិច្ចាគជា ប្រចាំរបស់ខ្ញុំព្រះករុណា" ដូច្នេះហើយ មិនទាន់បានចាត់ចែងហើយទៅ, សូម្បីសង្ឃនឹងចាត់ចែង ក៏គួរ ។

ក៏ឯសង្ឃគប្បីចាត់ចែងការយ៉ាងនេះ ៖

គប្បីចាត់ចែងថា លោកចូរឱ្យក្នុងស្ថានជាទីនៅរបស់ព្រះសង្ឃត្ថេរ ។ បើក្នុងទីនោះ មានសេនាសនៈបរិបូណ៌, ក្នុងទីណាសេនាសនៈមិនគ្រប់គ្រាន់, គប្បីឱ្យក្នុងទីនោះ ។ បើភិក្ខុមួយរូបពោលថា "ក្នុងទីនៅរបស់ខ្ញុំព្រះករុណា មិនមានរបស់ប្រើប្រាស់ សម្រាប់សេនាសនៈ" គប្បី

ឱ្យក្នុងទីនោះ ។

## ថ្វាយដល់សង្ឃ

ពាក្យថា សង្ឃស្ស ទេតិ **: គេឱ្យចីវរចំពោះសង្ឃ** មានសេចក្ដីថា ទាយកចូលទៅកាន់វត្តពោលថា "ខ្ញុំព្រះករុណា ថ្វាយចីវរទាំងនេះដល់សង្ឃ" ។

ពាក្យថា សម្មុខីភូតេន **: ជួបជុំមុខគ្នា** មានសេចក្ដីថា សង្ឃអ្នកតាំងនៅក្នុងឧបចារសីមា គប្បីវាយរគាំងឱ្យប្រកាសវេលាហើយចែកគ្នា ។ ភិក្ខុដែលត្រូវទទួលចំណែកជំនួសភិក្ខុ ដែលតាំងនៅក្នុងសីមា តែមកមិនទាន់ មិនគួរហាម ។ វត្តធំ, កាលថ្វាយសំពត់តាំងពីថេរាសនៈ ចុះមក, ព្រះមហាថេរៈអ្នកឃើតយូរ រមែងមកខាងក្រោយ, កុំពោលទឹងលោកថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុមានវស្សា ២០, លំដាប់របស់លោកម្ចាស់កន្លងផុតទៅហើយ" ដូច្នេះឡើយ, គប្បីវៀរលំដាប់ទុកសិន ថ្វាយដល់ព្រះមហាថេរៈទាំងនោះ រួចស្រេចហើយ សឹមថ្វាយតាមលំដាប់ជាខាងក្រោយ ។ ភិក្ខុទាំងឡាយ បានស្ដាប់ដំណឹងថា "បានឮថា ក្នុងវត្តឯណោះ ចីវរកើតឡើងច្រើន" ទើបនាំគ្នាមកពីវត្តដែលតាំងនៅ ក្នុងចម្ងាយមួយយោជន៍ខ្លះ, គប្បីឱ្យចាប់ផ្ដើមតាំងពីកន្លែងដែលលោកទាំងឡាយ មកទាន់ហើយ ហើយចូលតាមលំដាប់ ។ ចំពោះដែល

លោកមកមិនទាន់ចូលឧបចារសីមាហើយ កាលអន្តេវាសិក ជាដើមនឹងទទួលជំនួស ក៏គួរឱ្យពិត ។ អន្តេវាសិកជាដើម ពោលថា "លោកចូរឱ្យដល់ភិក្ខុ ដែលតាំងនៅខាងក្រៅឧបចារសីមា" ដូច្នេះ មិនគប្បីឱ្យ ។

ក៏បើថា ភិក្ខុទាំងឡាយអ្នកនៅត្រង់ទ្វារវត្តរបស់ខ្លួន ឬនៅខាងក្នុងវត្តរបស់ខ្លួន ជាទីតែមួយជាប់តគ្នាអំពីភិក្ខុទាំងឡាយ ដែលចូលឧបចារសីមាសោត, សីមា ឈ្មោះថា រីកចេញដោយអំណាចបរិស័ទ; ព្រោះដូច្នោះ គួរឱ្យ ។ សូម្បីកាលឱ្យចីវរដល់សង្ឃនវកៈហើយ, ក៏គួរថ្វាយដល់ព្រះថេរៈទាំងឡាយ ដែលមកខាងក្រោយ ដូចគ្នា ។

មួយទៀត កាលចំណែកទី២ បានលើកឡើងកាន់ថេរាសនៈហើយ ចំណែកទី ១ រមែងមិនត្រូវបានដល់ភិក្ខុទាំងឡាយ ដែលមកហើយ, គប្បីឱ្យតាមលំដាប់វស្សា តាំងពីចំណែកទី ២ ទៅ ។ បើក្នុងវត្តមួយមានភិក្ខុ ១០ រូប, ទាយកថ្វាយសំពត់ ១០ ផ្ទាំងថា ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ; សំពត់ទាំងនោះ គប្បីចែកគ្នាមួយរូបមួយផ្ទាំង ។ បើភិក្ខុទាំងនោះ កាន់យកទៅទាំងអស់តែម្តង ដោយគិតថា សំពត់ទាំងនេះ ត្រូវបានដល់ពួកយើង ដូច្នេះសោត, ជាការឱ្យសម្រេច (ដល់ខ្លួន) មិនល្អ; ទាំងជាការកាន់យកមិនល្អ; សំពត់ទាំងនោះ រមែងជារបស់សង្ឃក្នុងទីដែល លោកទៅហើយនុ៎ះឯង ។

មួយទៀត ទឹងវើឡើងមួយផ្ទាំងថ្វាយដល់សង្ឃត្ថេរថា ផ្ទាំងនេះត្រូវបានដល់លោកម្ចាស់ ដូច្នេះហើយ កាន់យកសំពត់ដ៏សេសដោយគិតថា "សំពត់ទាំងនេះ ត្រូវបានដល់ពួកយើង" ដូច្នេះ គួរ ។ ទាយកនាំសំពត់មកតែមួយផ្ទាំង ថ្វាយថា "ខ្ញុំព្រះករុណា ថ្វាយដល់សង្ឃ" ភិក្ខុទាំងឡាយមិនបែងចែកគ្នា កាន់យកដោយគិតថា "សំពត់នេះត្រូវបានដល់ពួកយើង"; សំពត់នោះ ជាការដែលលោកទាំងឡាយឱ្យដល់ខ្លួនមិនប្រពៃ ទាំងជាការកាន់យកមិនប្រពៃ ។ គួរយកកាំបិតឬល្មៀតជាដើមធ្វើឱ្យជាស្នាម ឱ្យចំណែកមួយដល់ព្រះសង្ឃត្ថេរថា "ផ្នែកនេះត្រូវបានដល់លោកម្ចាស់" ហើយកន់យកចំណែកដ៏សេសថា "ផ្នែកនេះ ត្រូវបានពួកយើង" ។ ទឹងធ្វើការកំណត់ចែកគ្នា ដោយលាយផ្កាឈើ ឬផ្លែឈើ ឬ វល្លិនៃសំពត់នោះឯង មិនគួរ ។ បើហូតសរសៃអំបោះចេញមួយសរសៃ ថ្វាយដល់ព្រះថេរៈថា "ផ្នែកនេះ ត្រូវបានដល់លោកម្ចាស់" ហើយកន់យកថា "ចំណែកដ៏សេសត្រូវបានដល់ពួកយើង" គួរ ។ សំពត់ដែលភិក្ខុកាត់ជាកំណាត់តូចកំណាត់ធំ បែងចែកគ្នា គួរពិត ។

កាលចីវរទាំងឡាយកើតឡើងដល់សង្ឃក្នុងវត្ត ដែលមានភិក្ខុតែមួយរូប, បើភិក្ខុនោះ កាន់យកថា "ចីវរទាំងអស់រមែងបានដល់យើង" តាមន័យដូចពោលហើយខាងដើមនោះឯង, ជាការដែលលោកកាន់យក

ប្រពៃ, ចំណែកលំដាប់មិនតាំងនៅ ។ បើលោកលើកឡើងម្តងមួយ ផ្ទាំង ៗកាន់យកថា "សំពត់នេះត្រូវបានដល់យើង" ។ លំដាប់ រមែង តាំងនៅ ។ បណ្តាលំដាប់ដែលមិនតាំងនៅ និងតាំងនៅទាំងពីរនេះ កាលលំដាប់មិនតាំងនៅ កាលចីវរដទៃកើតឡើងទៀត បើភិក្ខុមួយរូប មក, លោកទាំងពីរគប្បីកាត់ត្រង់កណ្តាលកាន់យក ។ កាលលំដាប់តាំង នៅ កាលចីវរដទៃកើតឡើងទៀត បើភិក្ខុខ្ចីជាងមក, លំដាប់ រមែងដល់ ខាងក្រោយ; បើភិក្ខុដែលចាស់ជាងមក, លំដាប់រមែងដល់មុន ។ បើ មិនមានភិក្ខុដទៃ, គប្បីឱ្យដល់ខ្លួនកាន់យកទៀត ។

តែចីវរដែលគេថ្វាយទាក់ទងដល់សង្ឃ ដោយអាការឯណានីមួយ ថា "ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ"ក្តី ថា "ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុ សង្ឃ"ក្តី មិនគួរដល់ភិក្ខុដែលកាន់សំពត់បង្សុកូល, ព្រោះហេតុដែល លោក ពោលពាក្យថា "ខ្ញុំព្រះករុណា សូមវៀរគហបតីចីវរចេញ, សមា ទានអង្គរបស់អ្នកកាន់សំពត់បង្សុកូល ជាវត្ត" ចីវរនេះមិនគួរ ដល់ភិក្ខុ ដែលកាន់សំពត់បង្សុកូល ព្រោះហេតុដែលចីវរនោះ ជាអកប្បិយ ប៉ុណ្ណោះ ក៏ទេ, សូម្បីភិក្ខុសង្ឃអបលោកនឱ្យហើយ ក៏មិនគួរទទួល ដែរ ។ ក៏ភិក្ខុឱ្យចីវរណា ដែលជារបស់ខ្លួន, ចីវរនោះ ឈ្មោះថា របស់ ដែលភិក្ខុឱ្យ គួរ; ប៉ុន្តែថា ចីវរនោះ មិនជាសំពត់បង្សុកូល ។ សូម្បី

កាលជាដូច្នោះ, ធុតង្គរមែង មិនដាច់ ។

មួយទៀត កាលទាយកថ្វាយថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយ, ខ្ញុំព្រះករុណាថ្វាយដល់ព្រះថេរៈទាំងឡាយ" ដូច្នេះ សូម្បីភិក្ខុដែលកាន់សំពត់បង្សុកូល ក៏គួរ ។ សូម្បីចីវរដែលទាយកថ្វាយថា "ខ្ញុំព្រះករុណាថ្វាយសំពត់នេះដល់សង្ឃ សូមលោកម្ចាស់ដ៏ចម្រើនទាំងឡាយធ្វើថង់ដាក់ស្បែកជើង ស្លោកបាត្រ សំពត់រឹតជើង និងខ្សែស្ពាយ (អំសពទ្ធក ប្រែថា អង្សៈក៏មាន) ជាដើម ដោយសំពត់នេះ" ដូច្នេះ រមែងគួរ ។ សំពត់ដែលទាយកថ្វាយ ដើម្បីប្រយោជន៍ដល់ស្លោកបាត្រជាដើម មានច្រើន, ជារបស់គ្រាន់ល្មម សូម្បីដើម្បីប្រយោជន៍ដល់ចីវរនឹងធ្វើចីវរអំពីសំពត់នោះដណ្ដប់ ក៏គួរ ។ ក៏បើថាសង្ឃកាត់សំពត់ដ៏សេសអំពីសំពត់ ដែលចែកគ្នាហើយ ចែកឱ្យដើម្បីប្រយោជន៍ដល់ថង់ស្បែកជើងជាដើម, នឹងកាន់យកអំពីសំពត់នោះ មិនគួរ ។ តែសំពត់នោះ ពួកម្ចាស់របស់ចាត់ការ ដោយខ្លួនឯងនោះឯងគួរ, ក្រៅពីនោះ មិនគួរ ។

សូម្បីកាលទាយកពោលថា "ខ្ញុំព្រះករុណា ថ្វាយដើម្បីប្រយោជន៍ដល់សំពត់ចងធម្មក្រកជាដើម ដល់សង្ឃអ្នកកាន់សំពត់បង្សុកូល" ដូច្នេះ សមគួរកាន់យក ។ ដែលឈ្មោះថា បរិក្ខារ សូម្បីភិក្ខុដែលកាន់សំពត់បង្សុកូល ក៏គប្បីប្រាថ្នាក្នុងសំពត់ដែលគេថ្វាយ ដើម្បីឱ្យជាសំពត់ចងធម្ម

ក្រកជាដើមទាំងនោះ សំពត់ណា ជារបស់ច្រើន ពោរពាស ទឹងបង្អោន សំពត់នោះចូល ក្នុងចីវរខ្វះ ក៏គួរ ។ ទាយកថ្វាយអំបោះដល់សង្ឃ អំបោះនោះ សូម្បីភិក្ខុដែលកាន់សំពត់បង្សុកូល ក៏គួរទទួល ។

វិនិច្ឆ័យក្នុងសំពត់ដែលទាយកចូលទៅកាន់វត្ត ហើយថ្វាយថា "ខ្ញុំព្រះករុណាថ្វាយចីវរទាំងនេះដល់សង្ឃ" ប៉ុណ្ណេះមុន ។ ក៏បើថា ទាយកឃើញភិក្ខុទាំងឡាយ ធ្វើដំណើរទៅខាងក្រៅ ឧបចារសីមា ហើយប្រាប់ដល់ព្រះសង្ឃត្ថេរ ឬព្រះសង្ឃនវកៈថា "ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ" សូម្បីបើបរិស័ទឋិតនៅពេញមួយយោជន៍ ជាប់តគ្នា រមែងត្រូវបានដល់ភិក្ខុគ្រប់រូបទាំងអស់; ចំណែកភិក្ខុពួកណា មិនទាន់ដល់បរិស័ទត្រឹមតែ ១២ ហត្ថ មិនបានដល់ភិក្ខុទាំងនោះ ។

## ថ្វាយដល់សង្ឃពីរចំណែក

វិនិច្ឆ័យក្នុងមាតិកាថា "ឧភតោសង្ឃស្ស ទេតិ : គេឱ្យចីវរចំពោះឧភតោសង្ឃ" នេះ គប្បីជ្រាបដូច្នេះ ៖

កាលគេពោលថា "ឧភតោសង្ឃស្ស ទម្មិ ខ្ញុំព្រះករុណាថ្វាយដល់សង្ឃទាំងពីរផ្នែក"ក្ដី "ទ្វិធា សង្ឃស្ស ទម្មិ : ខ្ញុំព្រះករុណាថ្វាយដល់សង្ឃដោយចំណែកទាំងពីរ"ក្ដី "ទ្វិន្នំ សង្ឃានំ ទម្មិ ខ្ញុំព្រះករុណាថ្វាយ

ដល់សង្ឃទាំងពីរពួក”ក្តី ពោលថា “ភិក្ខុសង្ឃស្ស ច ភិក្ខុនិសង្ឃស្ស ច ធម្មំ : ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ភិក្ខុនីសង្ឃផង”ក្តី សំពត់នោះ ជាការដែលគេថ្វាយដល់សង្ឃពីរផ្នែកពិត ។

ពាក្យថា ឧបឌ្ឍំ ទាតព្វំ : សង្ឃក៏ត្រូវឱ្យចីវរពាក់កណ្តាល មានសេចក្តីថា គប្បីធ្វើជាពីរចំណែកស្មើ ៗគ្នាឱ្យចំណែកមួយ ។ កាលគេពោលថា “ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ ២ ចំណែកផង ដល់លោកផង” បើមានភិក្ខុ ១០រូប ភិក្ខុនី ១០រូប គប្បីធ្វើឱ្យជា ២១ ចំណែក, ឱ្យដល់បុគ្គលមួយចំណែក, ឱ្យដល់ភិក្ខុសង្ឃ ១០ ចំណែក, ឱ្យដល់ភិក្ខុនីសង្ឃ ១០ ចំណែក; ចំណែកចំពោះបុគ្គលដែលភិក្ខុណាបានហើយ ភិក្ខុនោះ រមែងបានដើម្បីកាន់យកតាមលំដាប់ វស្សារបស់ខ្លួន អំពីសង្ឃទៀត ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា លោកដែលគេរួមចូលដោយសព្ទថា ឧភតោសង្ឃ ។ សូម្បីក្នុងសំពត់ដែលគេពោលថ្វាយថា “ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ ២ ចំណែកផង ដល់ចេតិយផង” ក៏មានន័យដូចគ្នា ។ តែក្នុងពាក្យថ្វាយនេះ មិនមានចំណែកដែលនឹងដល់ចេតិយអំពីសង្ឃ, មានតែមួយចំណែកស្មើនឹងចំណែកដល់បុគ្គលម្នាក់ប៉ុណ្ណោះ ។

មួយទៀត កាលគេពោលថា “ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ ២ ចំណែកផង ដល់លោកផង ដល់ចេតិយផង” គប្បីធ្វើឱ្យជា ២២

ចំណែក គឺ ឱ្យភិក្ខុ ១០ ចំណែក, ឱ្យដល់ភិក្ខុនី ១០ ចំណែក, ឱ្យដល់បុគ្គល១ចំណែក ឱ្យដល់ចេតិយ ១ ចំណែក; ក្នុងបុគ្គលនិងចេតិយនោះ បុគ្គលរមែងបានដើម្បីកាន់យកមួយចំណែកទៀតតាមលំដាប់វស្សារបស់ខ្លួនអំពីសង្ឃផង, សម្រាប់ចេតិយ គប្បីបានតែមួយចំណែកប៉ុណ្ណោះ ។

មួយទៀត កាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ភិក្ខុនីទាំងឡាយផង" កុំចែកឱ្យពាក់កណ្តាល គប្បីរាប់ភិក្ខុ និងភិក្ខុនីហើយឱ្យ ។

មួយទៀត កាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ភិក្ខុនីទាំងឡាយផង ដល់លោកផង" បុគ្គលមិនបានចំណែកមួយទៀតទេ; រមែងបានតែមួយចំណែក អំពីលំដាប់ដែលដល់ប៉ុណ្ណោះ ព្រោះហេតុអ្វី ? ព្រោះហេតុថា បុគ្គលដែលគេរួមចូលដោយសព្ទថា "ភិក្ខុសង្ឃ" សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ភិក្ខុនីទាំងឡាយផង ដល់លោកផង ដល់ចេតិយផង" ចេតិយបានចំណែកប៉ុនបុគ្គលម្នាក់ បុគ្គលមិនបានចំណែកមួយផ្សេងទៀតទេ ព្រោះដូច្នោះ គប្បីឱ្យដល់ចេតិយមួយចំណែកដ៏សេសគប្បីរាប់ភិក្ខុនិងភិក្ខុនីចែកគ្នា ។ សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុផង

ដល់ភិក្ខុនីផង" កុំបែងចែកពាក់កណ្ដាលឱ្យ គប្បីបែងចែកតាមចំនួនបុគ្គលប៉ុណ្ណោះ កាលគេពោលយ៉ាងនេះថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុផង ដល់ភិក្ខុនីផង ដល់លោកផង" ដូច្នេះក្ដី, ពោលយ៉ាងនេះថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុផង ដល់ភិក្ខុនីផង ដល់ចេតិយផង" ដូច្នេះក្ដី, ពោលយ៉ាងនេះថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុផង ដល់ភិក្ខុនីផង ដល់លោកផង ដល់ចេតិយផង" ដូច្នេះក្ដី, ចេតិយបាន ចំណែកតែមួយ បុគ្គលមិនមានចំណែកមួយផ្សេងទៀត គប្បីរាប់ភិក្ខុ និងភិក្ខុនីទាំងឡាយប៉ុណ្ណោះ ចែកគ្នា ។ ដូចយ៉ាងថា ខ្ញុំព្រះករុណាលើកភិក្ខុសង្ឃឱ្យជាដើម អធិប្បាយសេចក្ដីយ៉ាងណា បណ្ឌិតគប្បីលើកភិក្ខុនីសង្ឃឱ្យជាដើមខ្លះ អធិប្បាយសេចក្ដីដូច្នោះ ។ កាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុនីសង្ឃផង ដល់លោកផង" ។ បុគ្គលមិនបានចំណែកមួយផ្សេងទៀត គប្បីកាន់យកតាមលំដាប់វស្សា ប៉ុណ្ណោះ ។

មួយទៀត កាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ចេតិយផង, ចេតិយបានចំណែកមួយផ្សេងទៀត, សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់លោកផង ដល់ចេតិយផង", ចេតិយប៉ុណ្ណោះ បានចំណែកមួយផ្សេងទៀត បុគ្គលមិនបាន ។ សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយ

ផង ដល់លោកផង”, បុគ្គលមិនបានចំណែកមួយផ្សេងទៀត ។ តែកាលគេពោលថា “ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុទាំងឡាយផង ដល់ចេតិយផង” ចេតិយ រមែងបានចំណែកមួយផ្សេងទៀត សូម្បីកាលគេពោលថា “ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុទាំងឡាយផង ដល់លោកផង ដល់ចេតិយផង” ចេតិយប៉ុណ្ណោះ រមែងបានចំណែកមួយផ្សេងទៀត បុគ្គលមិនបាន ។ គប្បីលើកភិក្ខុនីសង្ឃឱ្យជាដើមខ្លះ ប្រកបសេចក្តីយ៉ាងនេះដូចគ្នា ។

សួរថា ក្នុងកាលមុន ទាយកទាំងឡាយថ្វាយទានដល់សង្ឃទាំងពីរផ្នែកមានព្រះពុទ្ធជាប្រធាន ព្រះមានព្រះភាគប្រថាប់អង្គុយត្រង់កណ្តាលភិក្ខុអង្គុយខាងស្តាំ ភិក្ខុនីអង្គុយខាងឆ្វេង ព្រះមានព្រះភាគទ្រង់ជាព្រះសង្ឃត្ថេរនៃសង្ឃ ២ ចំណែក គ្រានោះ ព្រះមានព្រះភាគទ្រង់សោយបច្ច័យដែលព្រះអង្គបាន ដោយព្រះអង្គឯងខ្លះ បង្គាប់ឱ្យប្រគេនដល់ភិក្ខុទាំងឡាយខ្លះ ។ ចំណែកក្នុងឥឡូវនេះ អ្នកឆ្លាតទាំងឡាយតាំងព្រះបដិមាឬព្រះចេតិយដែលតម្កល់ព្រះធាតុ ហើយថ្វាយទានដល់សង្ឃ ២ ចំណែកមានព្រះពុទ្ធជាប្រធាន តាំងបាត្រលើជើងទ្រខាងមុខនៃព្រះបដិមា ឬ ព្រះចេតិយហើយថ្វាយទក្ខិណោទក ពោលថា “សូមថ្វាយដល់ព្រះពុទ្ធ” ដូច្នេះហើយ ដាក់ខាទនីយៈ ភោជនីយៈយ៉ាងណាជាទីមួយក្នុង

បាត្រនោះ ឬនាំមកកាន់វត្ថុថ្វាយបិណ្ឌបាត និងវត្ថុមានកម្រងផ្កា និងគ្រឿងក្រអូបជាដើមពោលថា "នេះថ្វាយព្រះចេតិយ"; នឹងគប្បីបដិបត្តិយ៉ាងណា ក្នុងខាទនីយ និងរបស់គួរបរិភោគនោះ ?

ឆ្លើយថា វត្ថុមានកម្រងផ្កា និងគ្រឿងក្រអូបជាដើម គួរតម្កល់ទុកទីព្រះចេតិយមុន, សំពត់គប្បីធ្វើជាទង់ផ្ទាំងសំពត់ ប្រេង គប្បីប្រើអុជប្រទីប; ចំណែកបិណ្ឌបាតនិងភេសជ្ជៈមានទឹកឃ្មុំ និងទឹកអំពៅជាដើម គប្បីឱ្យដល់បព្វជិត ឬគ្រហស្ថដែលជាអ្នករក្សា ព្រះចេតិយជាប្រចាំ កាលមិនមានអ្នករក្សាជាប្រចាំ សមគួរ នឹងតាំងទុកដូចភត្តដែលខ្លួនឯងនាំមកធ្វើវត្តហើយឆាន់ ៗ ក្នុងវេលា ថ្ងៃជិតត្រង់ឆាន់ហើយ សឹមធ្វើវត្តជាខាងក្រោយ ក៏គួរដូចគ្នា ៗ ក៏កាលគេពោលថា "សូមលោកម្ចាស់ទាំងឡាយនាំវត្ថុនេះ ទៅធ្វើការបូជាព្រះចេតិយ ដូច្នេះ បណ្តាវត្ថុមានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ឯណាទីមួយ សូម្បីក្នុងទីឆ្ងាយ គួរនាំទៅបូជាសូម្បីកាលគេពោលថា "សូមលោកម្ចាស់នាំទៅដើម្បីភិក្ខុសង្ឃ" គួរនាំទៅ ៗ ក៏បើថា កាលភិក្ខុពោលថា "យើងនឹងត្រាច់បិណ្ឌបាតឯអាសនៈសាលាមានភិក្ខុ លោកទាំងឡាយនឹងនាំទៅ គេពោលថា "លោកដ៏ចម្រើន ខ្ញុំព្រះករុណាថ្វាយលោកម្ចាស់ទុះឯង" សមគួរឆាន់ ៗ ក៏បើថា កាលភិក្ខុកំពុងនាំទៅតាំងចិត្តថា "នឹងថ្វាយភិក្ខុសង្ឃ" វេលាចូល

កាន់តែជិត ក្នុងចន្លោះមកនោះឯង សមគួរឱ្យដល់ខ្លួនហើយឆាន់ចុះ ។

## ថ្វាយដល់សង្ឃដែលនៅចាំវស្សា

ពាក្យថា “វស្សំវុដ្ឋសង្ឃស្ស ទេតិ : **គេឱ្យចីវរចំពោះសង្ឃដែលនៅចាំវស្សា** មានសេចក្តីថា ទាយកចូលទៅកាន់វិហារហើយថ្វាយថា “ខ្ញុំព្រះករុណា ថ្វាយចីវរទាំងនេះ ដល់សង្ឃដែលចាំវស្សា” ។

ពាក្យថា យាវតិកា ភិក្ខូ តស្មឹ អាវាសេ វស្សំវុត្ថា : **ភិក្ខុមានកំណត់ប៉ុន្មានរូប នៅចាំវស្សាក្នុងអាវាសនោះ** មានសេចក្តីថា ភិក្ខុមានចំនួនប៉ុនណា ចាំវស្សាដំបូង មិនធ្វើឱ្យដាច់វស្សា ភិក្ខុទាំងនោះគប្បីចែកគ្នា; ចីវរនោះ មិនត្រូវបានដល់ភិក្ខុពួកដទៃ ។ កាលអ្នកទទួលជំនួសមាន គប្បីឱ្យសូម្បីដល់ភិក្ខុអ្នកជៀសទៅកាន់ទិសដរាបដល់កឋិនដោះ ។ ព្រះអាចារ្យទាំងឡាយ អ្នកយល់លក្ខណៈពោលថា “តែកាលមិនបានក្រាលកឋិន ក៏ឯចីវរដែលគេពោលថ្វាយយ៉ាងនោះ ក្នុងខាងក្នុងហេមន្តរដូវ រមែងត្រូវបានដល់ភិក្ខុទាំងឡាយ អ្នកចាំវស្សាក្រោយ” ។ ចំណែកក្នុងអដ្ឋកថាទាំងឡាយ មិនបានបំភ្លឺសេចក្តីនេះទុកទេ ។ ក៏បើថាទាយកតាំងនៅខាងក្រៅឧបចារសីមាពោលថា “ខ្ញុំព្រះករុណាថ្វាយដល់សង្ឃដែលចាំវស្សា” ចីវរនោះ រមែងត្រូវបានដល់ភិក្ខុទាំងពួងដែលចូលមកដល់ ។ បើគេពោលថា “ខ្ញុំព្រះករុណា ថ្វាយដល់សង្ឃដែលចាំ

វស្សាក្នុងវត្តឯណោះ” ។ រមែងត្រូវបានដល់ភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងវត្តនោះប៉ុណ្ណោះ ដរាបដល់វេលាដោះកឋិន ។ ក៏បើថា គេពោលយ៉ាងនោះ ចាប់តាំងពីថ្ងៃដើមនៃគិម្ហរដូវទៅ រមែងត្រូវបានដល់ភិក្ខុទាំងពួង ដែលមកជួបជុំគ្នានៅក្នុងវត្តនោះ ។ ព្រោះហេតុអ្វី ? ព្រោះចីវរនោះកើតឡើងខាងក្រោយសម័យ ។ កាលគេពោលថា “ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយដែលនៅចាំវស្សា” ដូច្នេះ ខាងក្នុងវស្សាតែម្តងភិក្ខុដែលដាច់វស្សា រមែងមិនបាន ចំពោះភិក្ខុដែលចាំវស្សារហូត ទើបបាន ។ ចំណែកក្នុងចីវរមាស កាលគេពោលថា “ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយ ដែលនៅចាំវស្សា” ។ រមែងត្រូវបានដល់ភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងបច្ឆិមវស្សា ប៉ុណ្ណោះ, មិនត្រូវបានដល់ភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងបុរិមវស្សា និងភិក្ខុដែលដាច់វស្សា ។ ចាប់ផ្តើមតាំងពីចីវរមាសទៅដរាប ដល់ថ្ងៃចុងបង្អស់នៃហេមន្តរដូវ កាលគេពោលថា “ខ្ញុំព្រះករុណា ថ្វាយសំពត់ចំណាំវស្សា, កឋិននឹងបានក្រាលឬមិនបានក្រាលក៏ដោយសំពត់នោះ រមែងត្រូវបានដល់ភិក្ខុទាំងឡាយដែលចាំវស្សាកន្លងទៅ ហើយប៉ុណ្ណោះ ។

មួយទៀត កាលគេពោលចាប់ផ្តើមតាំងពីថ្ងៃដើមនៃគិម្ហរដូវទៅ ។ គប្បីលើកមាតិកាឡើងថា សម្រាប់កាលចាំវស្សាដែលជាអតីត កន្លងទៅហើយ ៥ ខែ កាលចាំវស្សាដែលជាអនាគត ចំពោះកន្លងទៅ ៤ ខែ

ទើបនឹងមាន លោកឱ្យដល់សង្ឃដែលចាំវស្សាណា ។ បើគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយដែលចាំវស្សាកន្លងទៅហើយ" រមែងត្រូវបានដល់ភិក្ខុទាំងឡាយ ដែលនៅចាំរហូតអស់ខាងក្នុងវស្សានោះប៉ុណ្ណោះ ។ ភិក្ខុដែលពេញចិត្តគ្នា រមែងបានដើម្បីទទួលជំនួសភិក្ខុដែលជៀសទៅកាន់ទិស ។ បើគេពោលថា "ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុដែលចាំវស្សា ក្នុងវស្សាដែលនឹងមកដល់ខាងមុខ" គប្បីរក្សាសំពត់នោះទុក កាន់យកក្នុងថ្ងៃចូលវស្សា ។ បើថា ទីនៅគ្រប់គ្រងមិនបាន, ទាំងមានចោរភ័យ កាលភិក្ខុពោលថា "មិនអាចរក្សាទុក ឬមិនអាចកាន់ត្រាច់ទៅ" គេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយដែលនៅព្រមហើយ"; គប្បីចែកគ្នាកាន់យក ។ បើគេពោលថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា មិនបានថ្វាយសំពត់ណា ដល់ភិក្ខុទាំងឡាយដែលចាំវស្សាក្នុងវស្សាទី ៣ អំពីវស្សានេះទៅ ខ្ញុំព្រះករុណាថ្វាយសំពត់នោះ" រមែងត្រូវបានភិក្ខុទាំងឡាយ ដែលចាំវស្សាខាងក្នុងវស្សានោះ ។ បើភិក្ខុទាំងនោះចៀសចេញទៅកាន់ទិសហើយ ភិក្ខុដទៃដែលជិតជិតគ្នា នឹងទទួលជំនួស គប្បីឱ្យ ។ បើនៅសល់តែមួយរូបប៉ុណ្ណោះ ក្រៅអំពីនោះមរណភាពអស់ រមែងត្រូវបានភិក្ខុតែមួយរូបទុំះឯងទាំងអស់ ។ បើថាសូម្បីតែមួយរូប ក៏មិនមាន រមែងជារបស់សង្ឃ; សំពត់នោះ ភិក្ខុដែលនៅក្នុងទីចំពោះមុខ គប្បីចែកគ្នា ។

## ថ្វាយចំពោះ

ពាក្យថា “អាទិស្ស ទេតិ : ចំពោះវត្ថុឬកំណត់វត្ថុហើយ ទើបគេឱ្យចីវរ” មានសេចក្ដីថា គេឧទ្ទិសចំពោះ គឺ កំណត់ថ្វាយ ។

ក្នុងបទថា យាគុយា : ដែលគេឱ្យបបរហើយ ជាដើម មានសេចក្ដីដូច្នេះ ៖

គេចំពោះថ្វាយក្នុងបបរ ឬបាយ ឬខាទនីយ ឬចីវរ ឬសេនាសនៈ ឬភេសជ្ជៈ ។

ក្នុងបទទាំងនោះ មានយោជនាដូច្នេះ ៖

ទាយកនិមន្តភិក្ខុដោយបបរប្រចាំថ្ងៃនេះ ឬប្រចាំថ្ងៃស្អែក ហើយថ្វាយបបរដល់ពួកលោកអ្នកចូលកាន់ផ្ទះហើយ, កាលថ្វាយរួចស្រេចហើយ កាលភិក្ខុទាំងឡាយឆាន់បបរហើយ ទើបថ្វាយថា “ខ្ញុំព្រះករុណាថ្វាយចីវរទាំងនេះ ដល់លោកម្ចាស់ទាំងឡាយ ដែលឆាន់បបររបស់ខ្ញុំព្រះករុណា” ។ ចីវរនោះ រមែងត្រូវបានភិក្ខុដែលបានទទួលនិមន្ត បានឆាន់បបរហើយប៉ុណ្ណោះ ចំណែកបបរដែលភិក្ខុពួកណាអ្នកកន្លងទៅមកទ្វារផ្ទះ

ឬអ្នកចូលទៅកាន់ផ្ទះដោយភិក្ខាចារវត្ត; ទើបបាន ឬបបរដែលជនទាំងឡាយ នាំបាត្ររបស់ភិក្ខុពួកណា មកអំពីអាសនៈសាលាហើយនាំទៅថ្វាយ, ឬបបរដែលព្រះថេរៈទាំងឡាយ បញ្ជូនទៅដើម្បីភិក្ខុពួកណា រមែងមិនត្រូវបានដល់ភិក្ខុទាំងនោះ ។ តែបើថា ភិក្ខុសូម្បីពួកដទៃ នឹងភិក្ខុដែលបានទទួលនិមន្តមកយ៉ាងច្រើន អង្គុយពេញទាំងខាងក្នុងផ្ទះ និងក្រៅផ្ទះ, បើទាយកពោលយ៉ាងនេះថា "លោកម្ចាស់ទាំងឡាយ នឹងជាអ្នកបានទទួលនិមន្ត ឬមិនបានទទួលនិមន្តក៏ដោយ បបរខ្ញុំព្រះករុណាបានថ្វាយហើយដល់លោកម្ចាស់ពួកណា សំពត់ទាំងនេះ ចូរជារបស់លោកម្ចាស់ទាំងពួងនោះ" ដូច្នេះ រមែងបានគ្រប់គ្នា ។ ចំណែកភិក្ខុពួកណាបានបបរអំពីដៃព្រះថេរៈ រមែងមិនត្រូវបានដល់ភិក្ខុទាំងនោះ ។ បើគេពោលថា "លោកម្ចាស់ពួកណាឆាន់បបររបស់ខ្ញុំព្រះករុណា សំពត់ទាំងនេះ ចូរជារបស់លោកម្ចាស់ពួកនោះ ដរាបដល់គ្រប់រូប" ដូច្នេះ រមែងបានគ្រប់រូប ។ សូម្បីក្នុងភត្ត និងខាទនីយៈ ក៏ន័យនេះឯង ។

បទថា **ចីវរេ វា : គេឱ្យចីវរផង** មានសេចក្តីថា បើទាយកអ្នកធ្លាប់ថ្វាយ ចីវរដល់ភិក្ខុទាំងឡាយ ដែលខ្លួននិមន្តឱ្យចាំវស្សាសូម្បីក្នុងកាលមុន ឱ្យភិក្ខុឆាន់ហើយពោលថា "ក្នុងកាលមុនខ្ញុំព្រះករុណាបាន

ថ្វាយចីវរ ដល់លោកម្ចាស់ពួកណា ចីវរនេះក្តី ទឹកដោះថ្លា ទឹកឃ្មុំទិន ទឹកអំពៅជាដើមក្តី ចូរជារបស់លោកម្ចាស់ពួកនោះឯង” គ្រប់យ៉ាង រមែងត្រូវបានដល់ភិក្ខុទាំងនោះប៉ុណ្ណោះ ។

បទថា សេនាសនេ វា : ជូនកាលគេឱ្យសេនាសនៈហើយគេឱ្យទាំងចីវរផង មានសេចក្តីថា កាលគេពោលថា “លោកម្ចាស់បាននៅក្នុងទីលំនៅ ឬក្នុងបរិវេណដែលខ្ញុំព្រះករុណាសាង សំពត់នេះចូរជារបស់លោកម្ចាស់នោះ” រមែងជារបស់ភិក្ខុនោះ ប៉ុណ្ណោះ ។

បទថា ភេសជ្ជេ វា : ពុំនោះសោត គេឱ្យភេសជ្ជៈព្រមទាំងចីវរផង មានសេចក្តីថា កាលគេពោលថា “ពួកខ្ញុំព្រះករុណាថ្វាយភេសជ្ជៈមានទឹកដោះថ្លាជាដើម ដល់ព្រះថេរៈទាំងឡាយគ្រប់វេលា, ភេសជ្ជៈទាំងនោះ ដែលព្រះថេរៈពួកណាបានហើយ; សំពត់នេះ ចូរជារបស់ព្រះថេរៈទាំងនោះប៉ុណ្ណោះ” ដូច្នេះ, រមែងជារបស់ព្រះថេរៈទាំងនោះប៉ុណ្ណោះ ។

## ថ្វាយដល់បុគ្គល

ពាក្យថា “បុគ្គលស្ស ទេតិ : គេឱ្យចីវរចំពោះបុគ្គល” មានសេចក្ដីថា គេថ្វាយកំបាំងមុខ យ៉ាងនេះថា “ខ្ញុំព្រះករុណាថ្វាយចីវរនេះដល់លោកអ្នកមានឈ្មោះយ៉ាងនេះ” ឬដាក់ទុកទៀបបាទមូល ថ្វាយចំពោះមុខយ៉ាងនេះថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាថ្វាយចីវរនេះ ដល់លោកម្ចាស់”ដូច្នេះក្ដី ។ ក៏បើថា គេពោលយ៉ាងនេះថា “ខ្ញុំព្រះករុណាថ្វាយចីវរនេះដល់លោកម្ចាស់ផង ដល់អន្តេវាសិកទាំងឡាយរបស់លោកម្ចាស់ផង” ដូច្នេះ ។ រមែងត្រូវបានដល់ព្រះថេរៈ និងពួកអន្តេវាសិក ។ ភិក្ខុដែលមកដើម្បីរៀនឧទ្ទេស និងអ្នករៀនហើយនឹងទៅមាន, រមែងត្រូវបានសូម្បីដល់លោក ។ កាលគេពោលថា “ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយដែលនៅ ជាមួយលោកម្ចាស់ជានិច្ច រមែងបានដល់ឧទ្ទេសន្តេវាសិកទាំងពួង ដែលធ្វើវត្តរៀនឧទ្ទេស និងបរិបុច្ឆាជាដើមត្រាច់ទៅ ។ នេះជាវិនិច្ឆ័យ ក្នុងបទនេះថា ថ្វាយដល់បុគ្គល ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ពណ៌នាចីវរក្ខន្ធកវណ្ណនា ចប់ ។**

# ៩. ចម្បេយ្យក្ខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងចម្បេយ្យក្ខន្ធកៈ

[៨០] វិនិច្ឆ័យក្នុងចម្បេយ្យក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

ច្រើនបទថា គគ្គរាយ បោក្ខរណិយា តីរេ : នាឆ្នេរស្រះបោក្ខរណី ឈ្មោះ គគ្គរា គឺ ត្រង់ច្រាំងនៃស្រះបោក្ខរណីដែលស្រីមានឈ្មោះថា គគ្គរាសាង ។

បទថា តន្តិពទ្ធោ : មានចិត្តជាប់ជំពាក់ដោយការរៀបចំក្នុងអាវាសនោះ មានសេចក្ដីថា ឈ្មោះថា អ្នកជាប់ក្នុងសេចក្ដីខ្វល់ខ្វាយ ព្រោះការខ្វល់ខ្វាយជាកិច្ចដែលលោកគប្បីធ្វើក្នុងអាវាសនោះ ។

វិនិច្ឆ័យក្នុងពាក្យថា ឧស្សុក្កម្បិ អកាសិ យាគុយា : ធ្វើសេចក្ដីខ្វល់ខ្វាយក្នុងបបរ ជាដើម គប្បីជ្រាបដូច្នេះ ៖

សមគួរធ្វើសេចក្ដីខ្វល់ខ្វាយ តែក្នុងទីដែលជនទាំងឡាយ បង្គាប់ទុកថា កាលភិក្ខុអាគន្តុកៈមក លោកគប្បីប្រាប់, មិនសមគួរធ្វើក្នុងទីដែលគេមិនបានបង្គាប់ ។

ពាក្យថា គច្ឆ ត្វំ ភិក្ខុ : ម្នាលភិក្ខុអ្នកចូរទៅ មានសេចក្ដីថា ព្រះសាស្ដាបានទ្រង់ឃើញថា សេនាសនៈក្នុងអាវាសនោះឯងរបស់ភិក្ខុនោះ ជាទីសប្បាយ, ដោយហេតុនោះឯង ទើបត្រាស់ថា លោកចូរសម្រេចការនៅក្នុងវាសភគ្រាមនោះឯង ។

[៨១] ការធ្វើផ្សេងនៃពាក្យថា អធម្មេន វគ្គកម្មំ ករោន្តិ :

ធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ ជាដើម នឹងមកក្នុងបាលីខាងមុខពិត ៗ

[៨៤] ពាក្យថា អញ្ញត្រាបិ ធម្មា កម្មំ ករោន្តិ : ធ្វើកម្មខុសចាកធម៌ខ្លះ មានសេចក្តីថា ភិក្ខុឆព្វគ្គិយ ធ្វើកម្ម វៀរចាកធម៌ខ្លះ; ម្យ៉ាងទៀត បាឋៈនេះ ឯងជាបាលី; កម្មដែលធ្វើដោយវត្ថុពិត ចាត់ជាកម្មដែលធ្វើតាមធម៌; សេចក្តីថា ភិក្ខុឆព្វគ្គិយ មិនធ្វើយ៉ាងនោះ ។

សូម្បីក្នុងពាក្យថា អញ្ញត្រាបិ វិនយា កម្មំ, អញ្ញត្រាបិ សត្ថុសាសនា កម្មំ : កម្មខុសចាកវិន័យខ្លះ កម្មខុសចាកសត្ថុសាសនាខ្លះ ក៏ន័យនេះឯង ។ ក៏ក្នុងវិន័យនិងសត្ថុសាសនានេះ ការចោទនិងការប្រកាស ឈ្មោះថា វិន័យ ។ ញត្តិសម្បទា និងអនុសាវនសម្បទា ឈ្មោះថា សត្ថុសាសនា, សេចក្តីថា ភិក្ខុឆព្វគ្គិយធ្វើកម្មវៀរចាកការចោទ ការប្រកាសញត្តិសម្បទា និងអនុសាវនសម្បទាទាំងនោះ ។

បទថា បដិក្កុដ្ឋកតំ : ធ្វើកម្មដែលព្រះពុទ្ធតិះដៀលហើយ បានដល់ កម្មដែលត្រូវជំទាស់ និងដែលលោកនៅតែចចេសធ្វើ ។ កម្មណា ដែលភិក្ខុនៅតែចចេសធ្វើក្នុងកាលភិក្ខុពួកដទៃជំទាស់ហើយ ។ កម្មនោះចាត់ជាកម្មដែលត្រូវជំទាស់ និងដែលភិក្ខុនៅតែចចេសធ្វើ; សេចក្តីថា ភិក្ខុឆព្វគ្គិយធ្វើកម្មដូច្នោះខ្លះ ។

# កម្ម ៦ យ៉ាង

[៨៦] ក៏ក្នុងពាក្យថា ឆយិមានិ ភិក្ខវេ កម្មានិ អធម្មកម្មំ : ម្នាលភិក្ខុទាំងឡាយ កម្មនេះមាន ៦ យ៉ាង គឺ កម្មមិនប្រកបដោយធម៌ ជាដើមពាក្យថា ធម៌ ជាឈ្មោះនៃបាលី ។ ព្រោះហេតុនោះ កម្មណា សង្ឃមិនធ្វើដោយបាលី តាមដែលព្រះមានព្រះភាគត្រាស់ទុក, កម្មនោះ គប្បីជ្រាបថា កម្មមិនជាធម៌ ។ សេចក្តីសង្ខេបក្នុងឆកម្មាធិការនេះប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារមកហើយ ក្នុងបាលីនុ៎ះឯង ។

ក៏សេចក្តីពិស្តារនោះឯង មកហើយដោយអំណាចនៃញត្តិទុតិយកម្ម និងញត្តិចតុត្ថកម្មប៉ុណ្ណោះ ។ ដែលក្នុងញត្តិកម្មមិនមានការបន្ទូបន្ទយ ឬដោយប្រការយ៉ាងដទៃ ដូចក្នុងញត្តិទុតិយកម្ម និងញត្តិចតុត្ថកម្ម, ចំណែកអបលោកនកម្មដែលភិក្ខុ រមែងធ្វើត្រឹមតែសូចប្រកាស; ព្រោះដូច្នោះ ញត្តិកម្ម និង អបលោកនកម្មនោះ ទើបព្រះមានព្រះភាគ ទ្រង់មិនសម្តែងទុកក្នុងបាលី ។ ខ្ញុំព្រះករុណានឹងពណ៌នាវិនិច្ឆ័យនៃកម្មទាំងនោះ សូម្បីទាំងអស់ខាងមុខ ។

[៩៣] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យថា បញ្ច សង្ឃា : ជំនុំសង្ឃ មាន ៥ ពួក ជាដើម ដើម្បីសម្តែងប្រភេទនៃសង្ឃទាំងឡាយ អ្នកនឹងគប្បីធ្វើកម្មដែលព្រមព្រៀងដោយធម៌ ដែលជាគម្រប់៦ ។

បទថា កម្មប្បត្តោ : ឈ្មោះថា គួរដល់កម្ម គឺ អ្នកចូលកម្ម

បានដល់ អ្នកប្រកបក្នុងកម្ម គឺអ្នកគួរដល់កម្ម, សេចក្តីថា មិនគួរដើម្បីធ្វើកម្មណា ៗ ក៏មិនមែន ។

[៩៤] ពាក្យថា ចតុវគ្គករណញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនីចតុត្ថោ : ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ សង្ឃមានភិក្ខុនីជាគម្រប់ ៤ ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងវិបត្តិនៃកម្មដោយបរិស័ទ ។

ក្នុងពាក្យនោះ បុគ្គលដែលមានសំវាសផ្សេងគ្នាព្រោះកម្ម ព្រះមានព្រះភាគទ្រង់កាន់យកដោយឧក្ខិត្តកស័ព្ទ ។ បុគ្គលមានសំវាសផ្សេងគ្នាព្រោះលទ្ធិ ទ្រង់កាន់យកដោយនានាសំវាសកស័ព្ទ ។

ពីរបទថា នានាសីមាយ ឋិតចតុត្ថោ : មានភិក្ខុដែលឋិតនៅក្នុងសីមាផ្សេងគ្នាជាគម្រប់ ៤ មានសេចក្តីថា ជាចតុវគ្គនឹងភិក្ខុដែលតាំងនៅក្នុងហត្ថបាសត្រង់សីមន្តរិក ឬខាងក្រៅសីមា ។

[៩៨] ពាក្យថា បារិវាសិកចតុត្ថោ : សង្ឃមានភិក្ខុអ្នកនៅបរិវាសជាគម្រប់ ៤ ជាដើម ព្រះមានព្រះភាគត្រាស់ ដើម្បីសម្តែងវិបត្តិដោយបរិស័ទនៃបរិវាសកម្មជាដើមប៉ុណ្ណោះ ។ ខ្ញុំព្រះករុណានឹងពណ៌នាវិនិច្ឆ័យនៃកម្មទាំងនោះខាងមុខ ។

[៩៩] ដើម្បីសម្តែងសេចក្តីដែលកម្មត្រូវជំទាស់ហើយ និងនៅតែចេសធ្វើ ជាកម្មកម្រើកនិងមិនកម្រើក ទើបព្រះមានព្រះភាគត្រាស់

ពាក្យថា ឯកច្ចស្ស ភិក្ខវេ សង្ឃស្ស មជ្ឈេ បដិក្កោសនា រូហតិ : ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃរបស់បុគ្គលខ្លះ ឡើង ជាដើម ។

បទថា បកតត្តស្ស : របស់ភិក្ខុជាបកតត្ត បានដល់ អ្នកមាន សីលមិនវិបត្តិ គឺ ជាអ្នកមិនត្រូវអាបត្តិបារាជិក ។

បទថា អនន្តរិកស្ស : ភិក្ខុដែលអង្គុយនៅជាលំដាប់ បានដល់ អ្នកអង្គុយជាលំដាប់នៃខ្លួន ។

[១០០] ដើម្បីសម្តែងកម្មទាំងឡាយជារបស់កម្រើកនិងមិនកម្រើក ដោយវត្ថុ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា "ទ្វេមា ភិក្ខវេ និស្សារណា : ម្នាលភិក្ខុទាំងឡាយ ការបណ្តេញចេញនេះមាន ២ យ៉ាង" ជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា អប្បត្តោ និស្សារណំ, តំ ចេ សង្ឃោ និស្សារេតិ, សុនិស្សារិតោ : បុគ្គលដែលមិនទាន់ដល់និស្សារណាកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ នេះ ព្រះមានព្រះភាគត្រាស់សំដៅយកបព្វាជនីយកម្ម ។ ពិតមែន សង្ឃរមែងបណ្តេញឱ្យចេញចាកវត្ត ដោយបព្វាជនីយកម្ម, ព្រោះដូច្នោះ បព្វាជនីយកម្មនោះ លោកទើបហៅថា និស្សារណា ។ ក៏ព្រោះហេតុដែលមិនជាអ្នកទូស្តត្រកូល, បុគ្គលនោះ ទើប

មិនដល់បញ្ជាជនីយកម្មនោះ ដោយលក្ខណៈមួយផ្នែក; ប៉ុន្តែថា ព្រោះហេតុដែលព្រះមានព្រះភាគ ត្រាស់ទុកថា "កាលបើសង្ឃប្រាថ្នា គប្បីធ្វើបញ្ជាជនីយកម្មដល់ភិក្ខុ (ដែលប្រកបដោយអង្គ៣) នេះឯង"[១] ដូច្នេះ ភិក្ខុនោះ ទើបចាត់ថា ជាភិក្ខុដែលសង្ឃបណ្តេញចេញដោយល្អហើយ ។

## និស្សារណា

ពាក្យថា តញ្ចេ សង្ឃោ និស្សារេតិ : បើសង្ឃបណ្តេញបុគ្គលនោះចេញ មានសេចក្តីថា បើសង្ឃបណ្តេញចេញ ដោយអំណាចនៃតជ្ជនីយកម្មជាដើមសោត, បុគ្គលនោះ ឈ្មោះថា ត្រូវបណ្តេញចេញដោយល្អ ព្រោះហេតុដែលក្នុងវិន័យ ពោលដោយតជ្ជនីយកម្មជាដើមនោះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតនិស្សារណាដោយអង្គ សូម្បីមួយយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុអ្នកបង្កហេតុ បង្កជម្លោះ បង្កទាស់ទែង បង្កតិរច្ឆានកថា បង្ករអធិករណ៍ក្នុងសង្ឃ ១ ភិក្ខុពាលមិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ភិក្ខុនៅប្រឡូកប្រឡំដោយគ្រហស្ថដោយការប្រឡូកប្រឡំមិនសមគួរ ១"[២] ។

---

១. វិន. ចុល្ល. កម្មក្ខន្ធកៈ. ៩. ១០៥/៧៤ ។ ២. វិន. ចុល្ល. កម្មក្ខន្ធកៈ. ៩. ២៨/១៩ ។

# ឱសារណា

[១០១] កិរិយាហៅចូលពួក ឈ្មោះថា ឱសារណា ។

ក្នុងរឿងឱសារណានោះ ពាក្យថា តញ្ចេ សង្ឃោ ឱសារេតិ : បើសង្ឃហៅបុគ្គលនោះបញ្ចូល បានដល់ ហៅចូលពួក ដោយអំណាចឧបសម្បទាកម្ម ។

បទថា ទោសារិតោ : ដោយអាក្រក់ មានសេចក្ដីថា បុគ្គលនោះ សង្ឃឱ្យឧបសម្បទាហើយ សូម្បីទាំងពាន់ដង ក៏គង់ជាអនុបសម្បន្នទុះឯង ។ ចំណែកអាចារ្យ និងឧបជ្ឈាយ៍ រមែងមានទោស, ការកសង្ឃដ៏សេសក៏ដូចគ្នា, អ្នកណា ៗ មិនផុតចាកពីអាបត្តិ ។ អភព្វបុគ្គល ១១ ពួកទាំងនេះ សង្ឃហៅចូលពួកមិនបានឡើយ ដោយប្រការដូច្នេះ ។ ចំណែកបុគ្គល ៣២ ពួក មានមនុស្សកំបុតដៃជាដើម ហៅចូលពួកដោយប្រពៃ, សង្ឃឱ្យឧបសម្បទាហើយ រមែងជាឧបសម្បន្នពិត, បុគ្គលទាំងនោះ អ្នកណា ៗ និងពោលអ្វី ៗមិនបាន; តែអាចារ្យ និងឧបជ្ឈាយ៍ព្រមទាំងការកសង្ឃ រមែងមានទោស, អ្នកណា ៗ មិនផុតចាកអាបត្តិ ។

[១០២] ដើម្បីសម្ដែងកម្មមិនប្រកបដោយធម៌ ដោយអំណាចវត្ថុមិនពិត និងកម្មប្រកបដោយធម៌ ដោយអំណាចវត្ថុពិត ទើបព្រះមាន

ព្រះភាគត្រាស់ពាក្យថា ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ ធដ្ឋព្វា : ម្នាលភិក្ខុទាំងឡាយ បើអាបត្តិដែលភិក្ខុត្រូវឃើញ មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ជាដើម ។

បណ្តាបទទាំងនោះ បទថា បដិនិស្សជ្ជេតា : ដែលត្រូវលះបង់ គឺ ទិដ្ឋិលាមកដែលនឹងគប្បីលះបង់ចេញ ។

[១០៩] កម្មប្រកបដោយធម៌និងមិនប្រកបដោយធម៌ ដោយអំណាចវត្ថុនុ៎ះឯង ។ ព្រះមានព្រះភាគទ្រង់ចែកទុក ក្នុងឧបាលីបញ្ហា ក៏មាន ។ ក្នុងឧបាលិបញ្ហានោះ មានន័យ ២ គឺ ន័យមានមូលតែមួយ ១ ន័យមានមូលពីរ ១, ន័យមានមូលមួយជាក់ច្បាស់ហើយ ។ ក្នុងន័យមានមូលពីរ សតិវិន័យនិងអមូឡ្ហវិន័យ លោកធ្វើឱ្យជាពាក្យសួរតែមួយរួមគ្នា យ៉ាងណា, សម្មុខាវិន័យជាដើម នឹងតស្សបាបិយសិកាជាដើម ក៏គប្បីធ្វើឱ្យជាពាក្យសួរតែមួយរួមគ្នា យ៉ាងនោះ ។ ចំណែកក្នុងពាក្យខាងចុង ពាក្យថា ឧបសម្បទរហំ ឧបសម្បាទេតិ រមែងជាបទតែមួយរួមគ្នាពិត ។ ខាងមុខ ព្រះមានព្រះភាគទ្រង់ប្រកបបទទាំងឡាយដ៏សេស នឹងបទមួយ ៗ ធ្វើសតិវិន័យសម្មុខានៃភិក្ខុឱ្យជាដើម ។

[១១០] ដើម្បីសម្តែងវិបត្តិក្នុងកម្ម ៧ យ៉ាង មានតជ្ជនីយកម្មជាដើម ព្រមទាំងកិរិយាដែលរម្ងាប់ ចាត់ជាពួកដោយអំណាចបទទាំងនេះ គឺ អធម្មេន វគ្គំ, អធម្មេន សមគ្គំ, ធម្មេន វគ្គំ, ធម្មបដិរូបកេន វគ្គំ, ធម្ម

បដិរូបកេន **សមគ្គំ** : កម្មជាពួកមិនប្រកបដោយធម៌, កម្មព្រមព្រៀងគ្នា មិនប្រកបដោយធម៌, កម្មជាពួកតែប្រកបដោយធម៌, កម្មជាពួកប្រកបដោយធម៌ប្លម, កម្មព្រមព្រៀងគ្នា ប្រកបដោយធម៌ប្លម ; ទើបព្រះមានព្រះភាគត្រាស់ថា ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ : ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុជាអ្នកធ្វើនូវវិវាទ ជាដើម ។

បណ្ដាបទទាំងនោះ បទថា អនធាធានោ : មិនមានការកំណត់អាបត្តិ បានដល់ អ្នកវៀរចាកមារយាទ, អាការជាគ្រឿងកំណត់ ហៅថា មារយាទ ។ សេចក្ដីថា អ្នកវៀរចាកសេចក្ដីកំណត់អាបត្តិ ។ ខាងមុខអំពីនោះ ព្រះមានព្រះភាគត្រាស់បាលីនោះឯង ប្រៀបធៀបនឹងបទថា អកាតំ កាម្មំ : កម្ម ឈ្មោះថា ភិក្ខុមិនបានធ្វើហើយ ជាដើម ដើម្បីសម្ដែងប្រភេទនៃកម្មដែលត្រូវជំទាស់ហើយ និងនៅតែចបេសធ្វើ ។ ក្នុងបាលីនោះ អ្នកណា ៗ មិនអាចនឹងជ្រាប ពាក្យណា ៗ ដោយទំនងនៃបាលី ក៏មិនមាន, ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបមិនពណ៌នាឱ្យពិស្ដារ ដូច្នេះឯង ។

**ចម្បេយ្យក្ខន្ធកវណ្ណនា ចប់**

# ១០. កោសម្ពិកក្ខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងកោសម្ពិកក្ខន្ធកៈ

[១៨៤] វិនិច្ឆ័យក្នុងកោសម្ពិកក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

ក្នុងពាក្យថា តំ ភិក្ខុំ អាបត្តិយា អទស្សនេ ឧក្ខិបឹសុ : ក៏លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ នេះ មានអនុបុព្វិកថា ដូចតទៅនេះ ៖

បានឮថា ភិក្ខុ ២ រូប គឺ ព្រះវិន័យធរ ១ ព្រះសុត្តន្តិកៈ ១ នៅក្នុងអាវាសតែមួយរួមគ្នា ។ ក្នុងភិក្ខុ ២ រូបនោះ ថ្ងៃមួយ ព្រះសុត្តន្តិកភិក្ខុចូលទៅកាន់វច្ចកុដិ បន្សល់ទឹកជម្រះដ៏សេស ទុក ក្នុងភាជនៈហើយចេញទៅ ។ ព្រះវិន័យធរចូលទៅខាងក្រោយ ឃើញទឹកនោះ ចេញទៅហើយ ទើបសួរភិក្ខុនោះថា ៖

- អ្នកមានអាយុ លោកបន្សល់ទឹកនេះទុកឬ ?

+ ករុណា អ្នកមានអាយុ

- លោកមិនដឹងថា ជាអាបត្តិ ព្រោះការបន្សល់ទឹកទុកនេះ ឬ ?

+ ករុណា ខ្ញុំព្រះករុណាមិនដឹង ។

- អ្នកមានអាយុ ត្រូវអាបត្តិ ព្រោះហេតុនេះ ។

+ បើមាន, ខ្ញុំព្រះករុណានឹងសម្តែង ។

អ្នកមានអាយុ តែបើលោកមិនក្លែង ធ្វើដោយមិនមានសតិ, ក៏មិនមានអាបត្តិ ។

ព្រះសុត្តន្តិកៈនោះ មានសេចក្តីឃើញថា មិនជាអាបត្តិ ចំពោះអាបត្តិនោះ ។ ចំណែកព្រះវិន័យធរ បានប្រាប់ដល់ពួកនិស្សិតរបស់ខ្លួនថា "ព្រះសុត្តន្តិកៈនេះ សូម្បីត្រូវអាបត្តិហើយ ក៏នៅតែមិនដឹង" ។ និស្សិតទាំងនោះ ជួបពួកនិស្សិតរបស់ព្រះសុត្តន្តិកៈនោះហើយ ទើបពោលថា "ឧបជ្ឈាយ៍របស់ពួកលោក សូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថា ជាអាបត្តិ" ។ និស្សិតទាំងនោះ ទើបមកប្រាប់ដល់ឧបជ្ឈាយ៍ ។ លោកទើបពោលយ៉ាងនេះថា "វិន័យធរនេះ ពីមុននិយាយថា មិនត្រូវអាបត្តិ មកឥឡូវនេះ និយាយថា ត្រូវអាបត្តិ, លោកនិយាយកុហក" ។ និស្សិតទាំងនោះ ទើបទៅបង្កការឈ្លោះគ្នាយ៉ាងនេះថា "ឧបជ្ឈាយ៍របស់ពួកលោកនិយាយកុហក" ។ លំដាប់នោះ ព្រះវិន័យធរបានឱកាស ទើបបានដាក់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិដល់លោក ។ ដោយហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា បានលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ ។

[១៨៥] វិនិច្ឆ័យក្នុងពាក្យថា ភិន្នោ ភិក្ខុសង្ឃោ ភិន្នោ ភិក្ខុសង្ឃោ : ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ នេះ

គប្បីជ្រាបដូច្នេះ ៖

ភិក្ខុសង្ឃនៅមិនទាន់បែកគ្នា, ដូចយ៉ាងថា កាលភ្លៀងធ្លាក់ ជនទាំងឡាយ រមែងពោលថា "ឥឡូវនេះ សន្ទូងសម្រេចហើយ" ពិតមែន សន្ទូងនោះ នឹងសម្រេចជាពិតប្រាកដ មានឧបមាយ៉ាងណាមិញ; ដោយហេតុនេះតទៅ ភិក្ខុសង្ឃនឹងបែកគ្នាពិតប្រាកដ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ពិតមែន ភិក្ខុសង្ឃនោះឯងនឹងបែកគ្នាដោយអំណាចការឈ្លោះ, មិនមែនបែកគ្នាដោយអំណាចសង្ឃភេទទេ; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "បែកគ្នាហើយ" ។ ចំណែកពាក្យដែលត្រាស់ដដែលក្នុងសេចក្តីនេះ គប្បីជ្រាបដោយអំណាចសេចក្តីដែលប្រាកដ ។

ពាក្យថា **ឯតមត្ថំ ភាសិត្វា ឧដ្ឋាយាសនា បក្កាមិ : បាន**សម្តែងសេចក្តីនោះ រួចហើយក៏ទ្រង់ក្រោកចាកអាសនៈ មានពាក្យសួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគគ្រាត្រាស់យ៉ាងនោះហើយ ទើបស្តេចជៀសចេញទៅ ?

ឆ្លើយថា ក៏បើថា ព្រះមានព្រះភាគនឹងគប្បីត្រាស់ចំពោះ ពួកភិក្ខុដែលលើកវត្តថា "ភិក្ខុនោះ ដែលអ្នកទាំងឡាយលើកវត្តហើយ ដោយមិនមែនហេតុ", ឬ នឹងគប្បីត្រាស់ចំពោះពួកភិក្ខុដែលប្រព្រឹត្តតាមភិក្ខុដែលត្រូវលើកវត្តថា "អ្នកទាំងឡាយត្រូវអាបត្តិ", ភិក្ខុទាំងនោះ នឹងគប្បី

ពោលថា "ព្រះមានព្រះភាគជាបក្ខពួកនៃភិក្ខុទាំងនេះ, ព្រះមានព្រះភាគជាបក្ខពួកនៃភិក្ខុទាំងនេះ" និងចងអាឃាត; ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់តាំងត្រឹមតែបែបផែនប៉ុណ្ណោះ ទើបទ្រង់ត្រាស់សេចក្តីនោះហើយស្តេចក្រោកអំពីអាសនៈចៀសចេញទៅ ។

[១៤៦] ក្នុងពាក្យថា អត្តនា វា អត្តានំ : ខ្លួនដោយខ្លួនឯង ១ នេះ មានសេចក្តីថា ភិក្ខុណា អង្គុយក្នុងចំណោមនៃពួកអធម្មវាទី អ្នកមានកម្មដែលសង្ឃគប្បីធ្វើដល់ភិក្ខុដែលគួរលើកវត្ត សួរថា ពួកលោកពោលយ៉ាងណា ? បានស្តាប់លទ្ធិរបស់ពួកលោក និងរបស់មួយផ្នែកទៀត ញ៉ាំងចិត្តឱ្យកើតឡើងថា "ភិក្ខុទាំងនេះ ជាអធម្មវាទី, ភិក្ខុក្រៅអំពីនេះ ជាធម្មវាទី"; ភិក្ខុនេះអង្គុយត្រង់ កណ្តាលនៃពួកភិក្ខុអធម្មវាទីនោះ រមែងជានានាសំវាសរបស់ពួកលោក; រមែងញ៉ាំងកម្មឱ្យកម្រើក; ឈ្មោះថា ញ៉ាំងកម្មរបស់មួយផ្នែកទៀតឱ្យកម្រើកផង ព្រោះលោកមិនមកចូលហត្ថបាស ។ ភិក្ខុរមែងធ្វើខ្លួនឱ្យជានានាសំវាសដោយខ្លួនឯង ដោយប្រការយ៉ាងនេះ ។

សូម្បីក្នុងពាក្យថា សមានសំវាសកំ : មានសំវាសផ្សេងគ្នា នេះ មានសេចក្តីថា ភិក្ខុណា អង្គុយក្នុងចំណោមអធម្មវាទីជ្រាបថា ពួកនេះជាអធម្មវាទី ពួកក្រៅអំពីនេះជាធម្មវាទី ហើយចូលទៅក្នុងកណ្តាល

នៃភិក្ខុទាំងនោះ, អន្លុយហើយក្នុងចំណែកណាមួយ កាន់យកថា ពួកនេះជាធម្មវាទី ។ ភិក្ខុនេះគប្បីជ្រាបថា ធ្វើខ្លួនឱ្យជាសមានសំវាសដោយខ្លួនឯង ។

[១៤៧] ក្នុងពាក្យថា កាយកម្មំ វចីកម្មំ : កាយកម្មនិងវចីកម្ម នេះ មានសេចក្ដីថា ភិក្ខុទាំងនោះ កាលប្រហារគ្នាដោយកាយគប្បីជ្រាបថា ញ៉ាំងកាយកម្មឱ្យប្រព្រឹត្តទៅ កាលពោលពាក្យគ្រោតគ្រាតគប្បីជ្រាបថា ញ៉ាំងវចីកម្មឱ្យប្រព្រឹត្តទៅ ។

ពីរបទថា ហត្ថបរាមសំ ករោន្តិ : ធ្វើការប៉ះពាល់ដោយដៃ មានសេចក្ដីថា ភិក្ខុទាំងនោះ ធ្វើការវាយគ្នានិងគ្នាដោយដៃ ដោយអំណាចសេចក្ដីក្រោធ ។

បទថា អធម្មិយមានេ : ធ្វើកិច្ចមិនប្រកបដោយធម៌ បានដល់អ្នកធ្វើនូវកិច្ចទាំងឡាយ ដែលមិនសមគួរដល់ធម៌ ។

ពីរបទថា អសម្មោធិកាយ វត្តមានាយ : កំពុងតែពោលវាចាមិនជាទីរីករាយរកគ្នា គឺ កាលពាក្យដែលបបួលឱ្យរីករាយ មិនប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត បាឋ:នេះឯង ជាបាលី ។ សេចក្ដីថា កាលពាក្យជាគ្រឿងរីករាយព្រមមិនប្រព្រឹត្តទៅ ។

វិនិច្ឆ័យក្នុងពាក្យថា ឯត្តាវតា ន អញ្ញមញ្ញំ : មិនសមគួរដល់

គ្នានិងគ្នា ដោយហេតុមានប្រមាណប៉ុណ្ណោះទេ នេះ គប្បីជ្រាប ដូច្នេះ ៖

គប្បីធ្វើឱ្យជា ២ ជួរ អន្ទុយវៀរឧបចារទុក ។ ចំណែកក្នុងផ្នែកអ្នកធ្វើកម្មសមគួរដល់ធម៌ កាលពាក្យដែលនាំឱ្យរីករាយ ប្រព្រឹត្តទៅ គប្បីអន្ទុយក្នុងជួរមានអាសនៈយ៉ាំងក្នុងចន្លោះ គឺ គប្បីអន្ទុយវៀរអាសនៈមួយ ៗ ទុកក្នុងចន្លោះ ។

[១៤៨] ក្នុងបទថា **មា ភណ្ឌនំ : កុំធ្វើសេចក្តីបង្កហេតុ** ជាដើម គប្បីកាន់យកបាលីដ៏សេសថា **អកត្ថ : កុំធ្វើឡើយ** ឃើញសេចក្តីយ៉ាងនេះថា “**មា ភណ្ឌនំ អកត្ថ : អ្នកទាំងឡាយកុំធ្វើសេចក្តីបង្កហេតុឡើយ**” ។

បទថា **អធម្មវាទី : ភិក្ខុជាអធម្មវាទី** បានដល់ ភិក្ខុណាមួយក្នុងបណ្តាពួក ភិក្ខុដែលប្រព្រឹត្តតាមភិក្ខុដែលត្រូវលើកវត្ត ។ ដែលភិក្ខុនេះ ជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះមានព្រះភាគ ។ បានឮថា សេចក្តីប្រាថ្នារបស់ភិក្ខុនោះ ដូច្នេះថា ភិក្ខុទាំងនេះ ត្រូវសេចក្តីក្រោធ គ្របសង្កត់ រមែងមិនជឿស្តាប់ពាក្យរបស់ព្រះសាស្តា, ព្រះមានព្រះភាគ កុំឱ្យទ្រង់លំបាកក្នុងការជាស់តឿនភិក្ខុទាំងនោះឡើយ, ព្រោះដូច្នោះ លោកទើបទូលយ៉ាងនោះ ។

[១៤៩] ចំណែកព្រះមានព្រះភាគទ្រង់នាំរឿង ក្នុងអតីតមក

ត្រាស់ដោយទ្រង់អាណិតដល់ភិក្ខុទាំងនោះ ។ ពួកលោកនឹងបានសេចក្តីរលឹកដឹងហើយវៀរចាកក្នុងកាលជាខាងក្រោយខ្លះ ។

[១៥០] បណ្តាបទទាំងនោះ បទថា អនត្ថតោ កាត់បទថា អនត្ថោ អតោ : **សេចក្តីវិនាស** ; មានពាក្យអធិប្បាយថា សេចក្តីសាបសូន្យនឹងមានដល់យើងអំពីបុរសនោះ ។ ម្យ៉ាងទៀត បទថា អនត្ថតោ បានដល់ អនត្ថទោ ប្រែថា បុរសនោះនឹងជាអ្នកឱ្យសេចក្តីវិនាស ។ ពាក្យដ៏សេសជាក់ច្បាស់ហើយ ។

[១៥៣] ក៏វិនិច្ឆ័យក្នុងគាថាថា បុថុសទ្ទោ : **ជននេះមានសំឡេងខ្លាំង** ជាដើម គប្បីជ្រាបដូច្នេះ ៖

ជនឈ្មោះថា អ្នកមានសំឡេងខ្លាំង ព្រោះគេមានសំឡេងច្រើន គឺធ្ងន់ ។ ជនដែលដូចគ្នាតែមួយ ឈ្មោះថា ជនដែលសមគ្នា ។ មានពាក្យអធិប្បាយថា ពិតមែន ជនដែលធ្វើសេចក្តីទាស់ទែងគ្នា នេះទាំងអស់ ជាអ្នកមានសំឡេងខ្លាំង ព្រោះបញ្ចេញសំឡេងជុំវិញ និងដូចតែគ្នា ។

បាទគាថាថា ន ពាលោ កោចិ មញ្ញថ : **សូម្បីជនណាមួយដឹងខ្លួនថា ជាបុគ្គលពាលក៏គ្មាន** មានសេចក្តីថា ក្នុងជននោះ សូម្បីអ្នកណាម្នាក់ (ក៏មិន) សម្គាល់ខ្លួនថា "យើងជាពាល"ឡើយ, គ្រប់រូបទាំង

អស់ សុទ្ធតែជាអ្នកមានសេចក្តីសម្គាល់ថា "យើងជាបណ្ឌិត"ពិត ។

បាទគាថាថា ឆាត្តំ ភិយ្យោ អមញ្ញរុំ : ជនទាំងឡាយ ក៏មិនបានដឹងហេតុដ៏ក្រៃលែង មានសេចក្តីថា សូម្បីអ្នកណាម្នាក់ ក៏មិនសម្គាល់ខ្លួនថា "យើងជាបុគ្គលពាល" សោះឡើយ, និងក្រៃលែងជាងនោះ កាលសង្ឃបែកគ្នាហើយ ក៏នៅតែមិនសម្គាល់ដល់ហេតុមួយសូម្បីដទៃ គឺ ហេតុយ៉ាងនេះថា "សង្ឃបែកគ្នាព្រោះយើងជាហេតុ" ។

បទថា បរិមុដ្ឋា : ពួកជនដែលភ្លេចស្មារតី បានដល់ អ្នកវង្វេងភ្លេចសតិ ។

បាទគាថាថា វាចាគោចរភាណិនោ : មានសំដីជាអារម្មណ៍ គឺធ្វើអាទេស រ អក្សរឱ្យជារស្សៈ, មានសេចក្តីថា អ្នកមានវាចាជាគោចរ មិនមែនអ្នកមានសតិប្បដ្ឋានជាដើម ជាគោចរទេ ។

បទថា ភាណិនោ : និយាយច្រើន បានដល់ អ្នកច្រើនពោលពាក្យសំដី ។

បាទគាថាថា យាវិច្ឆន្តិ មុខាយាមំ : ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ មានសេចក្តីថា ភិក្ខុទាំងនោះ ខ្លួនប្រាថ្នានឹងតមាត់គ្នាត្រឹមណា, រមែងជាអ្នកពោលច្រើនទៅត្រឹមនោះ, សូម្បីមួយរូប ក៏មិនធ្វើមុខក្រញូវ ដោយសេចក្តីគោរពចំពោះសង្ឃ ។

ពីរបទថា យេន នីតា : ទុកជាគេនាំទៅប្រជល់ឱ្យឈ្លោះគ្នា មានសេចក្តីថា គឺជម្លោះណា នាំទៅកាន់ភាពជាអ្នកមិនមានសេចក្តីខ្មាស ។

ពីរបទថា ន តំ វិទូ : ក៏មិនដឹងសេចក្តីនោះថា ជាសេចក្តីឈ្លោះគ្នាឡើយ មានសេចក្តីថា ភិក្ខុទាំងនោះ មិនដឹងនូវជម្លោះនោះថា "ការឈ្លោះនេះ មានទោសយ៉ាងនេះ" ។

បាទគាថាថា យេ ច តំ ឧបនយ្ហន្តិ : ពួកជនណាចងសេចក្តីក្រោធនោះទុកដោយគិតថា មានសេចក្តីថា ជន ពួកណាចូលទៅចងអាការដែលថា "អ្នកនេះបានជេរយើង", ជាដើមនោះទុក ។

បទថា សនន្តនោ : តែងមានពីដើមរៀងមក គឺ ជារបស់ចាស់ ។

បទថា បរេ : ពួកជនដទៃ មានសេចក្តីថា វៀរពួកបណ្ឌិតចេញ ជនពួកដទៃពីបណ្ឌិតនោះ គឺ អ្នកបង្កសេចក្តីទាស់ទែងគ្នា ឈ្មោះថា ជនពួកដទៃ ។ ជនពួកដទៃនោះ កាលធ្វើការឈ្លោះនៅក្នុងជំនុំសង្ឃនេះ រមែងមិនដឹងឡើយថា "យើងទាំងឡាយ ឧបរមាម គឺ វិនាស ខេចខី ទៅកាន់ទីជិតសេចក្តីស្លាប់រឿយ ៗ គឺ ជានិច្ច" ។

បាទគាថាថា យេ ច តត្ថ វិជានន្តិ : បណ្តាពួកជននោះ បើ

ពួកជនណាមួយដឹងច្បាស់ មានសេចក្តីថា ចំណែកជនពួកណាជាបណ្ឌិត នៅក្នុងសង្ឃនោះ ជ្រាបច្បាស់ថា "យើងទាំងឡាយទៅកាន់ទីជិតនៃសេចក្តីស្លាប់" ។

បាទគាថាថា តតោ សម្មន្តិ មេធគា : សេចក្តីឈ្លោះទើបរម្ងាប់អំពីសំណាក់ជននោះបាន មានសេចក្តីថា ពិតមែន ជនទាំងនោះ កាលជ្រាបយ៉ាងនោះ ញ៉ាំងយោនិសោមនសិការឱ្យកើតឡើង រមែងបដិបត្តិដើម្បីសេចក្តីចូលទៅរម្ងាប់នៃការទាស់ទែង គឺ ការឈ្លោះចេញ ។

គាថាថា អដ្ឋិច្ឆិទា : អម្បាលដ្ឋឹងមាតាបិតារបស់ទីឃាវុកុមារគេកាត់ចោល នេះ ព្រះមានព្រះភាគត្រាស់សំដៅយកព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារ ។ សេចក្តីថា សេចក្តីព្រមព្រៀងគ្នា សូម្បីនៃជនទាំងនោះក៏អាចបាន, ហេតុអ្វីបានជាសេចក្តីព្រមព្រៀងរបស់លោកទាំងឡាយ មិនអាចបានហ្ន៎ ? ឆ្អឹងរបស់មាតាបិតាដែលពួកលោកនា ក៏មិនបានត្រូវកាត់ចោលឡើយ, ជីវិត ក៏មិនបានត្រូវបំផ្លាញសោះទេ, គោ សេះ និងទ្រព្យទាំងឡាយ ក៏មិនមានចោរណាមកលួច ។

គាថាថា សចេ លភេថ និបកំ សហាយំ : បើបុគ្គលបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ព្រះមានព្រះភាគត្រាស់ ដើម្បីសម្តែងគុណនៃសម្លាញ់ដែលជាបណ្ឌិត និងទោសនៃសម្លាញ់ដែលជា

ពាល ។

បាទគាថាថា អភិក្កុយ្យ សព្វានិ បរិស្សយានិ ៖ បុគ្គលនោះអាចគ្រប់សង្កត់នូវសេចក្ដីអន្តរាយទាំងពួងបាន មានសេចក្ដីថា គប្បីញាំញីអន្តរាយដែលប្រាកដ និងអន្តរាយដែលលាក់កំបាំងចេញ មានចិត្តរីករាយជាមួយនឹងសម្លាញ់នោះ មានសតិត្រាច់ទៅ ។

ច្រើនបទថា រាជាវ រដ្ឋំ វិជិតំ ៖ ប្រៀបដូចជាស្ដេច(លះបង់)នូវដែន ដែលខ្លួនឈ្នះហើយ មានសេចក្ដីថា ព្រះរាជាទ្រង់ព្រះនាមថា មហាជនក និងព្រះមហារាជាទ្រង់ព្រះនាមថា អរិន្ទមៈ ទ្រង់លះព្រំដែន គឺ ដីដែនជាទីត្រេកអររបស់ព្រះអង្គចេញត្រាច់ទៅតែម្នាក់ឯង យ៉ាងណា, គប្បីត្រាច់ទៅ ដូច្នោះ ។

ពីរបទថា មាតង្គរញ្ញេវ នាគោ ៖ ដំរីដ៏ប្រសើរក្នុងព្រៃ មានសេចក្ដីថា ដូចជាដំរីដ៏ប្រសើរលះហ្វូង ត្រាច់ទៅក្នុងព្រៃ ។

សត្វមានប្រមោយ ហៅថា ដំរី ។

ពាក្យថា នាគនេះ ជាឈ្មោះនៃអ្នកជាដ៏ប្រសើរ ។ មានពាក្យអធិប្បាយថា ប្រៀបដូចជាដំរីដ៏ប្រសើរដែលចិញ្ចឹមមាតា ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ។ ទាំងមិនបានធ្វើបាបទាំងឡាយ យ៉ាងណា; មួយទៀតដំរីបារិលេយ្យកៈ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង, ទាំងមិនបានធ្វើបាបទាំង

ទ្បាយ យ៉ាងណា; បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯង, ទាំងមិនគប្បីធ្វើបាប ទាំងឡាយ ក៏យ៉ាងនោះដែរ ។

[១៥៤] ត្រង់បទថា បារិលេយ្យកេ វិហរតិ រក្ខិតវនសណ្ឌេ : ទ្រង់គង់នៅ (ក្រោមម្លប់ភទ្ទសាលព្រឹក្ស) ក្នុងដងព្រៃឈ្មោះរក្ខិត នាប្រទេសបាលិលេយ្យកៈនោះ មានសេចក្ដីថា ព្រះមានព្រះភាគទ្រង់ចូលទៅអាស្រ័យស្រុកឈ្មោះ បារិលេយ្យកៈ ស្ដេចនៅក្នុងរក្ខិតព្រៃស្រោង ។

[១៥៥] បទថា ហត្ថិនាគោ : ដំរីដ៏ប្រសើរ បានដល់ ដំរីដ៏ប្រសើរ ។

បទថា ហត្ថិកលភេហិ : ពួកដំរីស្ទាវ បានដល់ កូនដំរីជំទង់ ។

បទថា ហត្ថិច្ឆាបេហិ : ពួកកូនដំរី បានដល់ កូនដំរីតូច ៗ ដែលនៅបៅដោះ ។

បទថា ឆិន្នគ្គានិ : ប្រោចផ្ដាច់ចុងចេញ មានសេចក្ដីថា ទំពារស៊ីស្មៅ មានចុង ដែលដំរីទាំងនោះទៅខាងមុខ ៗ មួលកំទេចចេញ គឺដូចដង្គត់ដែលសល់ពីទំពារស៊ីហើយ ។

ពាក្យថា ឱភគ្គោភគ្គំ : បំបាក់ខ្ទេចខ្ទីវិញ មានសេចក្ដីថា ដែល

ដំរីដ៏ប្រសើរនោះ កាច់បំបាក់ឱ្យធ្លាក់ចុះបាកទ្ទិខសហើយ ។

ពីរបទថា អស្ស សាខាភង្គំ : ក៏ស៊ីមែកឈើបាក់ ៗ ដែលដំរីដ៏ប្រសើនោះកាច់ សេចក្តីថា ដំរីទាំងនោះ រមែងទំពារស៊ីមែកឈើដែលគប្បីកាច់បំបាក់ ដែលជារបស់ដំរីចាស់នោះ ។

បទថា អាវិលានិ : ល្អក់ មានសេចក្តីថា ដំរីដ៏ប្រសើរនោះ រមែងផឹកទឹកល្អក់ ដែលដំរីទាំងនោះ កាលចុះផឹកមុនលុកលុយហើយ ។

បទថា ឱគាហា : ទីចុះ គឺ អំពីកំពង់ទឹក ។

ពីរបទថា នាគស្ស នាគេន : ដំរីប្រសើរ... របស់ព្រះពុទ្ធនាគដែរ គឺ នៃសត្វប្រសើរ គឺ ដំរី ដោយអ្នកជាចម្បង គឺ ព្រះពុទ្ធ ។

បទថា ឦសាទន្តស្ស : មានភ្លុកងរទន្ទាំ គឺ អ្នកមានភ្លុកដូចនឹងចន្ទោលរថ ។

បាទគាថាថា យទេកោ រមតី វនេ : រមែងត្រេកអរក្នុងព្រៃតែម្នាក់ឯង ហេតុណា មានសេចក្តីថា សត្វប្រសើរ គឺ ដំរីសូម្បីនេះ ជាសត្វតែម្នាក់ឯង គឺ ស្ងៀមស្ងាត់ត្រេកអរក្នុងព្រៃ ដូចមនុស្សដ៏ប្រសើរ គឺ ព្រះពុទ្ធ, ព្រោះដូច្នោះ ចិត្តរបស់សត្វប្រសើរនោះ ឈ្មោះថា ស្មើដោយបុគ្គលដ៏ប្រសើរ គឺដូចគ្នា ដោយការត្រេកអរក្នុងភាពជាសត្វតែម្នាក់ឯង ។

[១៥៦] គប្បីជ្រាបសេចក្ដីក្នុងពាក្យថា យថាភិរន្តំ វិហរិត្វា : ទ្រង់គង់នៅគួរដល់ពុទ្ធអធ្យាស្រ័យហើយ នេះថា ព្រះមានព្រះភាគស្ដេចនៅស្រុកបារិលេយ្យកៈនោះ រហូតដល់អស់ត្រៃមាស ។ ពាក្យដែលនិយាយគ្នា បានបែកសែឥតខ្វះខ្វាយទៅក្នុងទីទាំងពួងថា បានឮថា ព្រះមានព្រះភាគត្រូវបានភិក្ខុក្រុងកោសម្ពី បៀតបៀនដោយហេតុប៉ុណ្ណោះ ទើបស្ដេចចូលព្រៃនៅរហូតដល់អស់ត្រៃមាស ។

[១៥៧] ត្រើនបទថា អថ ខោ កោសម្ពិកា ឧបាសកានំ : វេលានោះ ពួកឧបាសកដែលនៅក្នុងក្រុងកោសម្ពី មានសេចក្ដីថា គ្រានោះឯង ពួកឧបាសកនៅក្រុងកោសម្ពី បានស្ដាប់ពាក្យដែលចរចាគ្នានេះ ។

[១៥៨] ខ្ញុំព្រះករុណានឹងពណ៌នាភេទករវត្ថុ ១៨ មានពាក្យថា អធម្មំ ធម្មោ : សភាវៈមិនមែនធម៌ថា ធម៌វិញ ជាដើម ក្នុងសង្ឃភេទក្ខន្ធកៈ[១] ។

[១៦២] បទថា អាធាយំ បានដល់ កំពង់នៃលទ្ធិ ។

[១៦៣] បទថា វិវិត្តំ បានដល់ ជាក់ ។

---

១. សមន្ត. ចុល្ល. ៦. ៦៩/២៦៨ ។

[១៦៤] ប្រើនបទថា តំ ឧក្ខិត្តកំ ភិក្ខុំ ឱសារេត្វា : ធ្វើឱសារណាកម្មចំពោះឧក្ខិត្តកភិក្ខុនោះរួចហើយ មានសេចក្តីថា នាំភិក្ខុដែលត្រូវលើកវត្តនោះទៅក្រៅសីមា ឱ្យសម្តែងអាបត្តិហើយ ហៅចូលពួកដោយកម្មវាចា ។

ពីរបទថា តាវទេវ ឧបោសថោ : ឧបោសថ...ក្នុងខណៈនោះឯង មានសេចក្តីថា គប្បីធ្វើសាមគ្គីឧបោសថ តាមន័យដែលពោលហើយក្នុងឧបោសថក្ខន្ធកៈ ក្នុងថ្ងៃនោះតែម្តង ។

[១៦៥] ប្រើនបទថា អមូលា មូលំ គន្ត្វា : មិនទាន់ដឹងដើមហេតុតាមហេតុនៃរឿងនោះ មានសេចក្តីថា មិនចេញចាកមូលទៅរកមូល អធិប្បាយថា មិនវិនិច្ឆ័យវត្ថុនោះ ។

ពាក្យថា អយំ វុច្ចតិ ឧបាលិ សង្ឃសាមគ្គី អត្ថាបេតា ព្យញ្ជនុបេតា : នៃឧបាលិសង្ឃសាមគ្គីនេះ តថាគតហៅថា ប្រកបទាំងអត្ថ ទាំងព្យញ្ជនៈ មានសេចក្តីថា សង្ឃសាមគ្គីនេះ ប្រាសចាកអត្ថតែអាស្រ័យព្យញ្ជនៈថា សង្ឃសាមគ្គីនេះ ។

# អត្ថនៃគាថា

[១៦៦] ពីរបទថា សច្ចស្ស ករិច្ចេសុ : កិច្ច...ចំពោះសង្ឃ មានសេចក្ដីថា កាលកិច្ចដែលនឹងគប្បីធ្វើ កើតឡើងដល់សង្ឃ ។

បទថា មន្តនាសុ : ការប្រឹក្សា បានដល់ កាលការប្រឹក្សាវិន័យ ។

ពីរបទថា អត្ថេសុ ជាតេសុ : សេចក្ដីអធិប្បាយ កើតឡើង បានដល់ កាលសេចក្ដីនៃវិន័យកើតឡើង ។

បទថា វិនិច្ឆយេសុ : សេចក្ដីវិនិច្ឆ័យ បានដល់ គ្រាវិនិច្ឆ័យអត្ថទាំងនោះឯង ។

បទថា មហត្ថិកោ : មានឧបការៈច្រើន បានដល់ អ្នកមានឧបការៈធំ ។

បទថា បគ្គហារហោ : គួរលើកតម្កើង បានដល់ សមគួរដើម្បីលើកតម្កើង ។

បាទគាថាថា អនានុវជ្ជោ បឋមេន សីលតោ : ភិក្ខុនោះដែលគេមិនគួរតិះដៀលដោយសីលជាបឋម មានសេចក្ដីថា ក្នុងជាន់ដើមមែនពិត អ្នកណា ៗ ក៏តិះដៀលមិនបានដោយសីលជាបឋម ។

បទថា អវេក្ខិតាចារោ : បានពិចារណាមើលមារយាទខ្លួន គឺអ្នកមានអាចារៈដែលខ្លួនពិចារណាហើយ បានដល់ អ្នកមានអាចារៈដែលខ្លួនធ្លាប់ត្រួតពិនិត្យហើយ ដោយន័យជាដើមថា មានប្រក្រតី ធ្វើសេចក្ដីរលឹកដឹងខ្លួន ក្នុងកាលសម្លឹងមើល ក្នុងកាលក្រឡេកមើល ។

ចំណែកក្នុងអដ្ឋកថា ទាំងឡាយពោលថា អ្នកមានអាចារៈមិនបិទបាំង គឺ អ្នកប្រុងប្រយ័ត្នខ្លួនល្អ ។

បទថា វិសយ្ហ : អង់អាច បានដល់ អភិភវិត្វា គ្របសង្កត់ ។

ពីរបទថា អនុយុត្តំ ភណំ : ភិក្ខុនោះ(មិន)បាននិយាយពាក្យមិនគួរ គឺ កាលនិយាយ មិនក្រៅហេតុដែលគួរ គឺមិនចូលគ្នា ។

ព្រះមានព្រះភាគទ្រង់សម្ដែងថា ពិតមែន បុគ្គលនោះរមែងនិយាយមិនក្រៅហេតុដែលគួរ, គឺ មិននិយាយប្រាសចាកហេតុ ដោយសេចក្ដីឫស្យា ឬដោយអំណាចសេចក្ដីលំអៀង, ព្រោះដូច្នោះ ទើបឈ្មោះថា មិនញ៉ាំងប្រយោជន៍ឱ្យខូច ។ ចំណែកបុគ្គលអ្នកនិយាយដោយសេចក្ដីឫស្យា ឬដោយអំណាចសេចក្ដីលំអៀង ឈ្មោះថា រមែងញ៉ាំងប្រយោជន៍ឱ្យខូច, បុគ្គលណា មិនពោលហេតុ បុគ្គលនោះ ទៅក្នុងបរិស័ទ រមែងរអែង និងខ្លាចក្រែង, បុគ្គលណា មិនជាអ្នកយ៉ាងនេះ, បុគ្គលនេះសមគួរ ដើម្បីលើកតម្កើង ។

គាថាថា តថេវ បញ្ហំ : ប្រស្នាយ៉ាងនោះ គប្បីជ្រាបឱ្យច្បាស់ត្រឹមតែបន្តិចទៀត, សេចក្ដីនៃគាថានោះ បុគ្គលដែលនិយាយមិនក្រៅហេតុ ដែលសមគួរ រមែងមិនញ៉ាំងប្រយោជន៍ឱ្យខូចយ៉ាងណា គេជាអ្នកត្រូវសួរបញ្ហា ត្រង់កណ្ដាលបរិស័ទ រមែងមិនសញ្ជប់សញ្ជឹង និង មិនអៀនអន់ ក៏យ៉ាងនោះដែរ ។

ពិតមែន អ្នកណាមិនដឹងអត្ថ អ្នកនោះរមែងអន្ទុយ ស្មៀម, អ្នកណា មិនអាចដើម្បីតបអ្នកនោះ រមែងជាអ្នកអឹមអៀម ។ ចំណែកអ្នកណា ដឹងអត្ថផង អាចដើម្បីតបផង អ្នកនោះ រមែងមិនអន្ទុយ ស្មៀម មិនជាអ្នកអឹមអៀម ។

បទថា កាលាគតំ : មានមកក្នុងកាលគួរ មានសេចក្ដីថា សមគួរក្នុងកាលដែលគួរពោល ។

បទថា ព្យាករណារហំ : គួរជាទីដោះស្រាយប្រស្នាបាន សេចក្ដីថា ឈ្មោះថា ជាព្យាករណ៍ដែលសមគួរ ព្រោះយល់នូវសេចក្ដីនៃបញ្ហា ។

បទថា វចោ : ពាក្យ បានដល់ កាលនិយាយ អធិប្បាយថា កាលពោលពាក្យមានសភាពបែបនោះ ។

បទថា រញ្ជេតិ : ឱ្យត្រេកអរ បានដល់ រមែងឱ្យពេញចិត្ត ។

បទថា វិញ្ញូបរិសំ : ញុំាងបរិស័ទជាអ្នកប្រាជ្ញ សេចក្តីថា ញុំាងបរិស័ទនៃវិញ្ញូជនទាំងឡាយ ។

ពីរបទថា អាចេរកម្ហិ ច សកេ : ក្នុងពាក្យអាចារ្យរបស់ខ្លួន មានសេចក្តីថា ជាអ្នកក្លៀវក្លា ក្នុងវាទៈនៃអាចារ្យរបស់ខ្លួន ។

ពីរបទថា អលំ បមេតុំ : ហើយពិចារណានូវហេតុនោះ ៗ មានសេចក្តីថា ជាអ្នកអាចដើម្បីពិចារណា គឺដើម្បីថ្លឹងមើលហេតុនោះ ៗ ដោយបញ្ញា ។

ពីរបទថា បគុណោ : ស្ទាត់ មានសេចក្តីថា អ្នកបានធ្វើសេចក្តីសន្សំទុក គឺ បានសេចក្តីសេពសោយដរាបជាទម្លាប់ ។

បទថា កថេតវេ : ក្នុងពាក្យដែលគួរនិយាយ បានដល់ ក្នុងពាក្យដែលនឹងគប្បីពោល ។

បទថា វិរទ្ធិកោវិទោ : ឆ្លាសក្នុងហេតុដែលភ្លាត់ខុស បានដល់ អ្នកឆ្លាត គឺ ដឹងទាន់ក្នុងហេតុដែលពិរុទ្ធ ។

គាថាថា បច្ចត្ថិកា យេន វជន្តិ : ពួកសត្រូវសន្តត់សន្ធឹន នេះព្រះមានព្រះភាគត្រាស់ ដើម្បីសម្តែងពាក្យដែលគប្បីពោល ដែលជាទីជំនាញ ។ ពិតមែន ក្នុងគាថានេះ មានសេចក្តីដូច្នេះ ៖

ដោយពាក្យយ៉ាងណា ដែលខ្លួនពោលហើយ សត្រូវទាំងឡាយ

រមែងដល់សេចក្ដីត្រូវបន្ទ្រាប, និងមហាជន រមែងដល់សេចក្ដីយល់ព្រម, អធិប្បាយថា ដល់សេចក្ដីធ្លាក់ចុះតាមពាក្យប្រកាស ។

ពិតមែន បុគ្គលនេះ កាលពោល ឈ្មោះថា រមែងមិនលុបលាងលទ្ធិជាទីជឿរបស់ខ្លួន គឺ វាទៈនៃអាចារ្យខ្លួន ។

អធិករណ៍កើតឡើង ព្រោះរឿងណា, កាលបកស្រាយបញ្ហាសមគួរដល់រឿងនោះ គឺ មិនធ្វើសេចក្ដីជំទាស់ដល់រឿងនោះ ឈ្មោះថាជាអ្នកជំនាញក្នុងពាក្យដែលនឹងគប្បីពោល ដូច្នោះ ។

ពីរបទថា **ទូតេយ្យកម្មេសុ អលំ : ហើយអាចក្នុងកម្មជាប់ដោយទូតផង** មានសេចក្ដីថា ឈ្មោះថា អ្នកអាចក្នុងកម្មជាប់ដោយទូតរបស់សង្ឃ ព្រោះជាអ្នកប្រកបដោយអង្គនៃទូត ៨ ប្រការ ។ ឈ្មោះថា អ្នកព្រមទទួល ព្រោះអត្ថថា ទទួលដោយល្អ គឺ ដោយងាយ ។

មានពាក្យអធិប្បាយដូច្នេះថា ភិក្ខុទាំងឡាយ រមែងទទួលដោយល្អនូវសក្ការៈដែលគេគប្បីនាំមកគួរទទួលគឺ បិណ្ឌបាតដែលឈ្មោះថា របស់គួរទទួល សេចក្ដីនេះយ៉ាងណា, បុគ្គលនេះ រមែងជាអ្នកព្រមទទួលក្នុងកិច្ចទាំងឡាយរបស់សង្ឃ ដោយទឹកចិត្តដែលមានបីតិនិងសោមនស្សពិតសេចក្ដីនេះក៏យ៉ាងនោះ, សេចក្ដីថា ជាអ្នកទទួលជួយកិច្ចនោះ ក្នុងបណ្ដាកិច្ចរបស់សង្ឃ ។

ពីរបទថា គារំ វទោ : ធ្វើនូវពាក្យ មានសេចក្តីថា កាលធ្វើនាទីចរបា ។

ពីរបទថា ន តេន មញ្ញតិ : មិនបានមើលងាយដោយអំពើនោះ មានសេចក្តីថា រមែងមិនប្រព្រឹត្តប្រកាន់ខ្លួននិងផ្ទើងកទ្រើងថា "យើងធ្វើ, យើងជួយភារៈសង្ឃ" ព្រោះការធ្វើនាទីចរបាយ៉ាងនោះ ។

បទថា អាបជ្ជតិ យាវតកេសុំ : បើត្រូវអាបត្តិមានប្រមាណប៉ុនណា មានសេចក្តីថា កាលទឹងត្រូវអាបត្តិ រមែងត្រូវក្នុងវត្ថុមានប្រមាណប៉ុនណា ។

បីបទថា ហោតិ យថា ច វុដ្ឋិតិ : ក៏ចេញចាក ដោយសមគួរតាមប្រមាណប៉ុណ្ណោះ មានសេចក្តីថា និងការចេញចាកអាបត្តិនោះ រមែងមានដោយប្រការណា ។

ពីរបទថា ឯតេ វិភត្តា : វិភង្គទាំងនេះ មានសេចក្តីថា រមែងត្រូវក្នុងវត្ថុពួកណានិងការចេញ រមែងមានដោយប្រការណា, វិភង្គទាំងពីរទាំងនេះរបស់ភិក្ខុនោះ ដែលបំភ្លឺសេចក្តីទាំងនេះ មកល្អហើយ គឺ មកត្រឹមត្រូវហើយ ។

បាទគាថាថា អាបត្តិវុដ្ឋានបទស្ស កោវិទោ : ហើយវាងវៃក្នុងហេតុដែលចេញចាកអាបត្តិ គឺ អ្នកឆ្លាតក្នុងហេតុនៃការចេញចាក

អាបត្តិ ។

ពីរបទថា យានិ ចាចរំ : ប្រព្រឹត្តនូវអំពើទាំងឡាយណា មានសេចក្តីថា មួយទៀត កាលប្រព្រឹត្តនូវកម្ម មានការបង្ក្រាបទំនាស់ទាស់ទែងជាដើម ពួកណា ទើបដល់សេចក្តីត្រូវបណ្តេញចេញ ដោយអំណាចតជ្ជនីយកម្មជាដើម ។

បាទគាថាថា ឱសារណំ តំ វុសិតស្ស ជន្តុនោ : កម្មដែលសង្ឃឱ្យចូលពួកវិញណា ដែលសង្ឃត្រូវធ្វើចំពោះជន គឺភិក្ខុដែលប្រព្រឹត្តតាមវត្តនោះ មានសេចក្តីថា កាលបុគ្គលដែលចប់វត្តនោះហើយ, ការហៅចូលពួកយ៉ាងណា សង្ឃគប្បីធ្វើឱ្យ, រមែងដឹងការហៅចូលពួកសូម្បីនោះ ។

ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

**ពណ៌នាគោសម្ពិកក្ខន្ធកខណ្ឌនា ចប់ ៕**

# សមន្តបាសាទិកា

## អដ្ឋកថា  វិនយបិដក

### មហាវគ្គ

## តតិយភាគ

## ៨

### ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### មហាវគ្គ

## ភាគ ៦_៧_៨

## ចប់ ដោយបរិបូណ៌



